# របត់នយោបាយ

## សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន




ភាគ ១

ឈឹម សេរីត្តួន



# របត់នយោបាយ

## សីហនុ ~ លន់ នល់ ~ ប៉ុល ពត ~ ហ៊ុន សែន

ភាគ ១

បោះពុម្ពលើកទី២

ហាមថតចម្លង

ស្លាកដែនេះត្រូវបានចុះបញ្ជីលេខ Ⓡ ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

***-អ្នកពិនិត្យអក្ខរាវិរុទ្ធ***

វេជ្ជ. អ៊ុន សុវណ្ណា

ង៉ែត សោភ័ណ

ង៉ែត ជិនបុត្រ

***-អ្នករចនាទំព័រ***

ហែម សិទ្ធា

***-ការីកុំព្យូទ័រ***

ប៉ោ កុសល

សេង រ៉ានី

ឈឹម មករា

រក្សាសិទ្ធិ© ឈឹម សេរីភួន គ.ស.២០២២

ISBN-13 : 978-9924-969-808

# ឧទ្ទិសកថា

ប្រជាជាតិខ្មែរបានឆ្លងកាត់ភ្លើងសង្គ្រាមឈាមហូរដោបផែនដី និងរបបវាលពិឃាតប្រល័យពូជសាសន៍មហាព្រៃផ្សៃបន្សល់ទុកគំនរភ្នំឆ្អឹង ស្ទឹងទឹកភ្នែកបន្សល់ទុកស្លាកស្នាមដានប្រវត្តិសាស្ត្រឈឺចាប់ថ្មីៗនេះ ។

យើងប្រាកដជាមិនចង់ឲ្យប្រជាជាតិយើងដើរជាន់ដានប្រវត្តិសាស្ត្រគួរឲ្យឈឺចាប់វេទនាខ្លោចផ្សានេះជាថ្មីម្តងទៀតឡើយ។

ដូច្នេះសូមអ្នកនយោបាយខ្មែរគ្រប់និន្នាការទាំងអស់ មេត្តាបោះបង់ចោលនូវមហិច្ឆតាដណ្តើមអំណាចគ្នា បង្កជាជម្លោះបែកបាក់ ធ្វើឱ្យរង្គោះរង្គើដល់សង្គមជាតិយើងដូចសម័យមុនៗទៀតទៅ។

គួរចាំទុកថា សង្គមជាតិមួយដែលមានតែជម្លោះបែកបាក់មិនឈប់ឈរនោះ លទ្ធផលគឺគ្មានអ្វីក្រៅពីការបង្កើតឱ្យមានចលាចល វឹកវរ បង្កអសន្តិសុខនោះឡើយ ហើយទីបំផុតមានតែការបង្ហូរឈាមគ្នាតែ ប៉ុណ្ណោះ។

សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយតាមថែរក្សាប្រជាជាតិមាតុភូមិខ្មែរឲ្យជួបតែសុខសន្តិភាពយូរអង្វែងតទៅមុខទៀត ដើម្បីមានឱកាសកសាងអភិវឌ្ឍន៍ប្រទេស ឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿង ប្រជាពលរដ្ឋរស់នៅដោយសុខសាន្ត មានសុភមង្គល ដូចនៅបណ្តាអារ្យប្រទេសផ្សេងៗទៀតនៅលើសកលលោក។

ថ្ងៃចន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១

**អ្នកសិក្សាស្រាវជ្រាវ**

**ឈឹម សេរីត្នួន**

# មាតិកា

●១ បារាំងចូលមកត្រួតត្រាឥណ្ឌូចិន ........................................................1
●២ កម្ពុជា ក្រោមអាណានិគមបារាំង ..........................................................16
●៣ លន់ នល់ និង ប៉ុល ពត ....................................................................27
●៤ រជ្ជកាលព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស..................................................31
●៥ បារាំងកាត់ខេត្តខ្មែរ ឲ្យថៃ ...................................................................... 35
●៦ ហេតុអ្វីបារាំង លើកយុវព្រះអង្គម្ចាស់ សីហនុ ឲ្យឡើងសោយរាជ្យ ?..................47
●៧ ទេសាភិបាលបារាំងថ្មី មកជួយស្តារព្រះកិត្តិនាមមហាក្សត្រសីហនុ ................. 55
●៨ ព្រះមហាក្សត្រសីហនុ មិនសព្វព្រះទ័យជាមួយកញ្ញាជួន ជឿម ........................64
●៩ ព្រះមហាក្សត្រវ័យក្មេង ជាមួយអ្នកម្នាងកាញ៉ុល និងម្ចាស់ក្សត្រី ពង្សសានមុនី ....69
●១០ ព្រះមហាក្សត្រសីហនុ និងមហេសីផ្សេងៗទៀត ............................................ 80
●១១ កញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី ជានរណា ?...........................................................91
●១២ មហាក្សត្រសីហនុ សព្វព្រះទ័យលើកញ្ញា ប៉ូល ម៉ូនិក អ៊ីហ្ស៊ី ជាងគេ...............99
●១៣ ចលនាតស៊ូសឹង ង៉ុកថាញ់ និងអាចារ្យហែម ចៀវ ....................................103
●១៤ មរណភាពអាចារ្យហែម ចៀវ.................................................................. 116
●១៥ ជប៉ុន ដណ្តើមអំណាចបារាំង ត្រួតត្រាប្រទេសខ្មែរ....................................123
●១៦ បារាំង ត្រឡប់មកត្រួតត្រាប្រទេសខ្មែរវិញ...........................................139
●១៧ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដំបូងនៅកម្ពុជា ..................................144
●១៨ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៩......................................................................160
●១៩ ក្រោយទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស ឡើងធ្វើនាយករដ្ឋមន្ត្រី.................................176
●២០ ព្រះមហាក្សត្រសីហនុ យាងសាងផ្នួសលាបំណន់
មុននាយករដ្ឋមន្ត្រី យុត្តិវង្ស សុគត.................................................... 181

●២១ ព្រះមហាក្សត្រសីហនុ ចាប់ផ្តើមថ្លែងសង្កថាមិនស្របតាមបារាំង ................185
●២២ ការបែកបាក់របស់គណបក្សប្រជាធិបតេយ្យ ......................................189
●២៣ ការបាត់បង់ទឹកដីកូសាំងស៊ីន ...........................................................201
●២៤ ចលនាតស៊ូខ្មែរឥស្សរៈ............................................................ 225
●២៥ ខ្មែរឥស្សរៈវាយប្រហារក្រុងសៀមរាប ..................................................231
●២៦ នរណាសម្លាប់មេខ្មែរឥស្សរៈរស់ យឿន និងម៉ី ភូរិន្ទ ? ...............................241
●២៧ គណៈកម្មាធិការរំដោះប្រជាជនខ្មែរ.....................................................245
●២៨ គណៈកម្មាធិការរំដោះជាតិខ្មែរ .......................................................... 252
●២៩ ដាប ឈួន ចុះចូលជាមួយព្រះមហាក្សត្រសីហនុ ...................................262
●៣០ នួន ជា ចូលរួមក្នុងចលនាតស៊ូជាមួយស៊ីវ ហេង .......................................268
●៣១ ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ......................................................272
●៣២ ប៉ែន សុវណ្ណ ចូលបម្រើកងទ័ពឥស្សរៈ តាំងពីអាយុ១៤ឆ្នាំ.........................279
●៣៣ ខ្មែរឥស្សរៈបែកបាក់ សម្លាប់តែគ្នាឯង...................................................282
●៣៤ ឃាតកម្មគប់គ្រាប់បែកដៃសម្លាប់អៀវ កើស ............................................289
●៣៥ សឺន សាន ឡើងជាប្រធានសភា ដោះស្រាយបញ្ហាបាតុកម្ម.......................295

# ១
# បារាំងចូលមកត្រួតត្រាឥណ្ឌូចិន



**ព្រះមហាក្សត្រីអង្គមី ម្ចាស់ក្សត្រីអង្គពៅ និងម្ចាស់ក្សត្រីអង្គស្ងួន**

នៅក្នុងរជ្ជកាលព្រះមហាក្សត្រអង្គចន្ទទី២ ប្រទេសខ្មែរ ត្រូវស្ថិតនៅក្រោមចំណុះរបស់ប្រទេសសៀមផង និងប្រទេសអណ្ណាមផង។

ប្រទេសទាំង២នេះ បានដណ្តើមគ្នាប្លន់យកទឹកដីខ្មែរ ស្ទើរតែយកទន្លេមេគង្គធ្វើជាព្រំប្រទល់របស់ពួកគេទៅហើយ។

ក្រោយពីព្រះមហាក្សត្រអង្គចន្ទទី២ ដែលមានសុទ្ធតែបុត្រី៣នាក់ គឺអង្គមី អង្គពៅ និងអង្គស្ងួន សោយទិវង្គតទៅ ព្រះអង្គពុំមានបុត្រាណាឡើងគ្រងរាជសម្បត្តិបន្តទៀតតាមទំនៀមទម្លាប់ពីមុនមកទេ ។ តែស្តេចអណ្ណាម មិនព្រមឲ្យអនុជព្រះអង្គ៣អង្គទៀត គឺព្រះអង្គអឹម អង្គភឹម ឬព្រះអង្គឌួង ឡើងគ្រងរាជសម្បត្តិបន្តទេ ដោយសារតែអនុជទាំងបីអង្គនេះជាមនុស្សរបស់ស្តេចសៀម ។

## របត់នយោបាយ



ព្រះមហាក្សត្រីអង្គមី

ផ្ទុយទៅវិញ ស្ដេចអណ្ណាម បានចេញបញ្ជាឱ្យក្រុមមន្ត្រីរបស់ខ្លួន ដែលជាអ្នកគ្រប់គ្រងព្រះរាជាណាចក្រខ្មែរ គឺឧត្តមសេនីយ៍ទ្រឿង មិញយ៉ាង ប្រជុំជាមួយរដ្ឋមន្ត្រីខ្មែរជាច្រើននាក់ទៀត ដើម្បីជ្រើសរើសក្សត្រីអង្គម៉ី មានព្រះជន្ម២១វស្សា ជាបុត្រីរបស់ព្រះអង្គចន្ទ ជាមួយជាយាទីបី ឈ្មោះអ្នកម្នាងក្រចាន់ ឲ្យឡើងគ្រងរាជសម្បត្តិបន្ត ហើយក្សត្រីអង្គពៅ ជាអនុជបន្ទាប់របស់ព្រះនាង ត្រូវបានតែងតាំងជាឧបរាជិនី និងក្សត្រីអង្គស្ងួន ដែលជាអនុជពៅ ត្រូវបានតែងតាំងជាព្រះកែវហ្វា ។

ក្រោយពេលឡើងសោយរាជ្យ ក្សត្រីអង្គម៉ី គង់នៅរាជវាំងស្លាកែត ប៉ុន្តែកិច្ចការដឹកនាំប្រទេសទាំងអស់ ស្ថិតក្នុងកណ្ដាប់ដៃរបស់ឧត្តមសេនីយ៍ ទ្រឿង មិញយ៉ាង នោះ។

ជាមួយគ្នានោះ ពួកគេបានចុះធ្វើសម្រង់ស្ថិតិប្រជាជន និងចុះបញ្ជីដីធ្លី ហើយតម្រូវឲ្យមន្ត្រីខ្មែរត្រូវស្លៀកពាក់បែបប្រពៃណីអណ្ណាម និងតម្រូវឲ្យប្រជារាស្ត្រខ្មែរ គោរពប្រតិបត្តិព្រះពុទ្ធសាសនាតាមបែបព្រះពុទ្ធសាសនាមហាយានទៀតផង ។

ហេតុការណ៍នេះ ធ្វើឲ្យប្រជារាស្ត្រខ្មែរមានការឈឺចាប់ ក៏នាំគ្នាងើបឡើងបះបោរនៅតំបន់ជនបទ កាប់សម្លាប់ជនជាតិយួនអស់ជាច្រើន ដែលជារឿងនឹកស្មានមិនដល់ថាប្រជារាស្ត្រខ្មែរហ៊ានធ្វើដូច្នេះសោះ។

ពេលនោះដែរ ពួកមន្ត្រីខ្មែរធំៗមួយចំនួនបានប្រជុំគ្នាជាសម្ងាត់ថា ត្រូវតែពឹងសៀមម្ដងទៀត រួចចាត់ឲ្យឧកញ៉ាវិបុលរាជ ឡុង និងឧកញ៉ាសួគ៌ាលោក មួក (ចៅហ្វាយខេត្តពោធិ៍សាត់) នាំញត្តិមួយទៅបាងកក ថ្វាយព្រះចៅសៀម ដើម្បីសុំអន្តរាគមន៍ឲ្យព្រះអង្គ

តែងតាំងព្រះអង្គឌួង ជាបុត្រពៅរបស់ព្រះអង្គអេង ដែលគង់នៅបាងកក ជាច្រើនឆ្នាំមកហើយនោះ ឲ្យមកសោយរាជ្យជំនួសក្សត្រីអង្គម៉ី តាមបំណងប្រជារាស្ត្រខ្មែរ ។

ព្រះចៅសៀម យល់ព្រមតាមសំណើនេះ ហើយចាត់ឲ្យចៅឃុនបឌិនតេជោ នាំទ័ពខ្មែរ-សៀម ដង្ហែព្រះអង្គឌួង ចូលមកស្រុកខ្មែរវិញ ដោយបានវាយកម្ចាត់កងទ័ពអណ្ណាមដកថយទៅដល់ចូវដុក (អតីតខេត្តមាត់ជ្រូក។

ក្រោយទទួលបានជ័យជម្នះ ព្រះអង្គឌួង បានយាងមកគង់នៅវាំងឃ្លាំងស្លឹក នៅជិតពញាឮ បានចាប់ផ្តើមដឹកនាំកិច្ចការប្រទេស ដោយតែងតាំងចៅហ្វាយខេត្តនានាជាថ្មីឡើងវិញ ។

នៅឆ្នាំ១៨៤១ កងទ័ពអណ្ណាម បានធ្វើការវាយបកមកលើទ័ពខ្មែរ-សៀម របស់ចៅឃុនបឌិនតេជោ វិញ ដោយចាប់វាយពីបន្ទាយពាមមានជ័យ (បាណាម) រួចវាយឡើងតាមទន្លេតូច មកបន្ទាយដែក ខាងកើតច្បារអំពៅ យ៉ាងខ្លាំងក្លា បណ្តាលឱ្យកងទ័ពរបស់ចៅឃុនបឌិនតេជោ បាក់ទ័ព និងនាំព្រះអង្គឌួង ដកថយទៅនៅឧដុង្គ និងរៀបចំកំពែងការពារទីតាំងថ្មីនោះ ដើម្បីទប់ទល់ជាមួយនឹងកងទ័ពអណ្ណាម បន្តទៀត។

ក្រោយពីច្បាំងបង្ហូរឈាមគ្នា មិនចាញ់ មិនឈ្នះ អស់រយៈពេល៥ឆ្នាំមក នៅខែធ្នូឆ្នាំ១៨៤៥ ព្រះចៅសៀម និងអណ្ណាម ព្រមព្រៀងគ្នាថា លើកព្រះអង្គឌួង ឱ្យសោយរាជ្យបន្តពីក្សត្រីអង្គម៉ី ។

ព្រះរាជពិធីអភិសេកព្រះអង្គឌួង ជាព្រះមហាក្សត្រ បានធ្វើឡើងនៅរាជធានីឧដុង្គនាថ្ងៃទី០៧ ខែមីនា ឆ្នាំ១៨៤៨ ក្នុងព្រះជន្មាយុ៥២ព្រះវស្សា ដោយមានការចូលរួមពីតំណាងព្រះចៅអណ្ណាម ឈ្មោះអុង ខាំម៉ាង និងតំណាងព្រះចៅសៀមពីរនាក់ គឺពញាពេជ្រពិជ័យ និងបាគូម្នាក់ទៀត។

ចាប់តាំងពីបានឡើងសោយរាជ្យមក ព្រះបាទអង្គឌួង ទ្រង់តូចព្រះទ័យយ៉ាងខ្លាំងចំពោះការបាត់បង់ទឹកដីយ៉ាងច្រើន ដែលពួកយួន និងសៀម បានដណ្តើមយកទៅ។ ព្រះអង្គបានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីដណ្តើមទឹកដីមកវិញ និងធ្វើយ៉ាងណាឲ្យ



**ព្រះបាទអង្គឌួង**

ប្រទេសជាតិលែងនៅក្រោមចំណុះយួន និងសៀម ដែរ តែមិនដឹងថា ត្រូវដោះស្រាយតាមវិធីណាឡើយ។

នៅក្នុងឆ្នាំ១៨៥២ អ្នកផ្សព្វផ្សាយសាសនាកាតូលិក ជាជនជាតិបារាំងម្នាក់ឈ្មោះ ហ្សង់ ក្លូដ មីស្ហ (Jean Claude Miche) ដែលជាមនុស្សជិតស្និទ្ធនឹងព្រះអង្គ បានថ្វាយយោបល់ដល់ព្រះអង្គឲ្យធ្វើទំនាក់ទំនងជាមួយព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ ដើម្បីសុំចងមិត្តភាពជាមួយប្រទេសបារាំង និងសុំឲ្យព្រះចៅអធិរាជបារាំង ជួយការពារប្រទេសកម្ពុជា ឲ្យរួចផុតពីការប្លន់ដណ្ដើមទឹកដីពីពួកសៀម និងយួន ផងដែរ។

នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ ព្រះមហាក្សត្រអង្គឌួង បានលបផ្ញើព្រះរាជសារមួយច្បាប់តាមរយៈកុងស៊ុលបារាំង នៅសិង្ហបុរី ដើម្បីទាក់ទងជាសម្ងាត់ជាមួយព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ ក្នុងបំណងសុំចងសម្ព័ន្ធភាពដោយក្ដីគោរពដ៏ជ្រាលជ្រៅ និងក្នុងគោលបំណងឲ្យបារាំង ជួយការពារប្រទេសខ្មែរផងដែរ។

ក្រោយពីទទួលព្រះរាជសាររបស់ព្រះមហាក្សត្រអង្គឌួង មក ព្រះចៅអធិរាបារាំង ណាប៉ូឡេអុងទី៣ បានបញ្ជាឱ្យឯកអគ្គរាជទូតបារាំង ប្រចាំនៅប្រទេសសៀម និងប្រទេសសិង្ហបូរី ឈ្មោះដឺម៉ុង ទីញី ដែលទើបតែចុះហត្ថលេខាលើសន្ធិសញ្ញាពាណិជ្ជកម្មជាមួយស្ដេចសៀម ហើយថ្មីៗ នៅក្រុងបាងកកនោះ ឲ្យបន្តដំណើរទៅទាក់ទងចុះសន្ធិសញ្ញាមិត្តភាព និងពាណិជ្ជកម្មជាមួយប្រទេសខ្មែរ តាមការស្នើសុំពីព្រះមហាក្សត្រអង្គឌួង នៅរាជធានីឧដុង្គ បន្តទៀត ។ ពេលនោះដែរ ឯកអគ្គរាជទូតបារាំងរូបនេះ ក៏បានប្រាប់ព្រះចៅសៀម ឲ្យដឹងពីរឿងនេះដែរ។

ពេលឯកអគ្គរាជទូត ដឺម៉ុង ទីញី ធ្វើដំណើរចាកចេញពីប្រទេសសៀម ចូលមកកាន់

ប្រទេសខ្មែរ ព្រះចៅសៀម បានចាត់មន្ត្រីសម្ងាត់ម្នាក់ឲ្យចុះកប៉ាល់ មកជាមួយ ដើម្បីឃ្លាំមើលសកម្មភាពរបស់ឯកអគ្គរាជទូតរូបនេះផង និងឲ្យនាំយកព្រះរាជសារមួយ មកថ្វាយព្រះមហាក្សត្រអង្គឌួង ដើម្បីគំរាមមិនឲ្យព្រះអង្គទាក់ទងកិច្ចការអ្វីជាមួយឯកអគ្គរាជទូតបារាំង ផងដែរ ។ ប៉ុន្តែនៅពេលកប៉ាល់ចូលចតនៅឆ្នេរសមុទ្រខេត្តកំពត នៅខែសីហា ឆ្នាំ១៨៥៦ ឯកអគ្គរាជទូត ដឺម៉ុង ទីញី មិនបានធ្វើដំណើរទៅចូលគាល់ព្រះមហាក្សត្រអង្គឌួង ដោយផ្ទាល់ទេ បែរជាចាត់ព្រះសង្ឃកាតូលិកជាជនជាតិបារាំងមួយអង្គ ប្រចាំការនៅខេត្តកំពតនោះ ឲ្យនាំយកសន្ធិសញ្ញាមួយ ដែលចម្លងតាមសន្ធិសញ្ញាពាណិជ្ជកម្ម ដែលទើបតែចុះហត្ថលេខាជាមួយព្រះចៅសៀមនោះ មកថ្វាយព្រះមហាក្សត្រអង្គឌួង ឲ្យឡាយព្រះហស្ថលេខាទៅវិញ ធ្វើឲ្យព្រះមហាក្សត្រខ្មែរខកព្រះទ័យជាខ្លាំង ហើយព្រះអង្គមិនត្រឹមតែមិនព្រមឡាយព្រះហស្តលេខាលើសន្ធិសញ្ញានោះទេ ថែមទាំងធ្វើឲ្យព្រះចៅសៀមមានការខឹងសម្បាយ៉ាងខ្លាំង។ ដូច្នេះព្រះអង្គមានតែបង្ខំព្រះទ័យនៅស្ងៀមស្ងាត់សិន រង់ចាំឱកាសល្អ នឹងទាក់ទងបារាំង ជាថ្មីទៀត។

ក្រោយមក ព្រះអង្គក៏បានកោះហៅព្រះសង្ឃកាតូលិកប្រចាំការនៅខេត្តកំពត ដែលឯកអគ្គរាជទូត ដឺម៉ុង ទីញី ប្រើឲ្យនាំយកសន្ធិសញ្ញាមកថ្វាយព្រះអង្គឱ្យឡាយព្រះហស្តលេខាពីមុននោះ ចូលគាល់។

ពេលនោះ ព្រះអង្គបានប្រគល់ព្រះរាជសារមួយ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៨៥៦ និងតង្វាយមានតម្លៃមួយចំនួនទៀត ដើម្បីឲ្យសង្ឃកាតូលិកនោះ ជួយធ្វើទៅថ្វាយព្រះចៅអធិរាជបារាំង។

នៅក្នុងព្រះរាជសារនោះ ព្រះអង្គបានរៀបរាប់អំពីប្រវត្តិនៃការបាត់បង់ទឹកដីកម្ពុជាក្រោម តាំងពីសម័យស្តេចយួន យ៉ាឡុង ដែលកាលណោះ បានមកពឹងពាក់ព្រះបិតាព្រះអង្គឲ្យជួយ ដើម្បីធ្វើសង្គ្រាមជាមួយពួកតៃសឺន (Tay Son) រហូតទទួលបានជ័យជម្នះ ហើយឡើងគ្រងរាជ្យនៅអណ្ណាម ។ តែក្រោយមក ស្តេចយួនអង្គនេះ បែរជាងាកមកធ្វើបាបខ្មែរទៅវិញ។ ព្រះអង្គក៏បានរៀបរាប់ដែរ អំពីការដើកព្រែកវិញ-តេ តាមបញ្ជារបស់ស្តេចមិញ



**រូបសំណាកឧត្តមសេនីយ៍ រីហ្គូលត៍ ដឺ ហ្សង់នូលី (Rigault de Genouilly) ដែលដឹកនាំកងទ័ពវាយដណ្តើមយកកំពង់ផែ ដាណាង ក្នុងឆ្នាំ១៨៥៨**

ម៉ាង ដែលជារាជបុត្រសោយរាជ្យបន្តពីស្តេចយ៉ាឡុង និងអំពីសកម្មភាពស្តេចយួនអង្គនេះ បានចាប់ព្រះកាយរាជវង្សានុវង្ស និងមន្ត្រីខ្មែរ ព្រមទាំងការធ្វើបាបលើប្រជារាស្ត្រខ្មែរគ្រប់បែបយ៉ាង។

តែតាំងពីពេលនោះមក ព្រះមហាក្សត្រអង្គឌួង មិនបានទទួលការឆ្លើយតបណាមួយពីព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ បន្តិចឡើយ។

លុះ៣ឆ្នាំក្រោយមក ដោយយកលេសថា ស្តេចយួនធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយសាសនាជាតិបារាំង ព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ ក៏បានបញ្ជូនកងទ័ពជើងទឹកក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ រីហ្គូលត៍ ដឺ ហ្សង់នូលី (Rigault de Genouilly) មកវាយប្រហារដណ្តើមយកកំពង់ផែដាណាង បាននៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨។

បន្ទាប់មកទៀត កងទ័ពបារាំង ក៏វាយដណ្តើមយកបានក្រុងព្រៃនគរ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩ ទៀត។

ព្រះមហាក្សត្រអង្គឌួង ចូលទិវង្គតនៅវេលាម៉ោង ៤:១៥នាទី ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំវក ទោស័ក ព.ស.២៤០៤ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ១៨៦០ ក្នុងព្រះជន្មា

យុ៦៥វស្សា ។

ព្រះមហាក្សត្រអង្គឌួង ជាព្រះរាជបុត្រពៅ របស់ព្រះបាទនរាយណ៍រាជាទី៣ គឺព្រះអង្គអេង និងមានមាតានាម អ្នកម្នាងរស់ ។ ព្រះអង្គមានរាជបុត្រសំខាន់ៗបីព្រះអង្គ គឺព្រះនរោត្តម, ព្រះស៊ីវត្ថា និងព្រះស៊ីសុវត្ថិ ឯមួយចំនួនទៀតមិនសូវសំខាន់។

ក្រោយពីព្រះមហាក្សត្រអង្គឌួង បានចូលទិវង្គត រាជបុត្រច្បងរបស់ព្រះអង្គ ព្រះនាមនរោត្តម បានឡើងគ្រងរាជសម្បត្តិបន្ត ។ ប៉ុន្តែព្រះចៅសៀម មិនព្រមប្រគល់ព្រះខ័ន និងមកុដរាជ្យ ដែលរក្សាទុកនៅប្រទេសសៀមនោះ ដើម្បីឲ្យព្រះអង្គរៀបចំធ្វើព្រះរាជពិធីប្រាប្តាភិសេកឡើងគ្រងរាជសម្បត្តិតាមទំនៀមទម្លាប់ពីបុរាណមកនោះទេ ។

នៅក្នុងឆ្នាំ១៨៦១ ព្រះអង្គស៊ីវត្ថា ជាបុត្រាទី៣ មានការច្រណែននឹងព្រះរៀមនរោត្តម ឡើងសោយរាជ្យ ទ្រង់ក៏គេចបាត់ពីរាជធានីឧដុង្គ ទៅបង្កើតចលានាតស៊ូវាយដណ្តើមបានរាជធានីឧដុង្គ។

ពេលនោះ ព្រះមហាក្សត្រនរោត្តម ក៏បានរត់ភៀសព្រះកាយទៅខេត្តបាត់ដំបងរួចបន្តព្រះរាជដំណើរទៅដល់ក្រុងបាងកកទៀត។

តែក្រោយពីកងទ័ពព្រះអង្គបានវាយកងទ័ពព្រះអង្គស៊ីវត្ថា ឲ្យរត់ខ្ចាត់ខ្ចាយអស់ហើយដណ្តើមរាជធានីឧដុង្គ បានមកវិញ នៅខែមីនា ឆ្នាំ១៨៦២ ព្រះអង្គក៏បានយាងត្រឡប់ពីប្រទេសសៀម មកគង់នៅរាជធានីឧដុង្គ វិញដែរ។

នៅក្នុងឆ្នាំ១៨៦២ លោកឧត្តមសេនីយ៍ត្រីបូណា មេបញ្ជាការនៅដែនដីកម្ពុជាក្រោម បានចូលមកក្នុងប្រទេសខ្មែរ ដើម្បីក្តាប់សភាពការណ៍ និងឆ្លៀតឱកាសចូលគាល់ព្រះមហាក្សត្រនរោត្តម ផងដែរ។

តាមសន្ធិសញ្ញាចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៨៦២ ស្តេចយួន បានទទួលស្គាល់ខេត្តបៀនវ៉ា(កំពង់ស្រកាត្រី), យ៉ាឌិញ (ឧកញ៉ាឌិន), ឌិញទឿង (មេស) និងកោះត្រឡាចដែលយួនបានដណ្តើមយកពីខ្មែរពីមុនមកនោះជាកម្មសិទ្ធិរបស់បារាំង។

នៅក្នុងខែកក្កដា ឆ្នាំ១៨៦៣ ឧត្តមនាវីបារាំង ដឺឡា ហ្រ្កង់ឌីយែរ (De La Grandière)

របត់នយោបាយ

មេបញ្ជាការនៅទឹកដីកម្ពុជាក្រោម បានធ្វើដំណើរទៅរាជធានីឧដុង្គ ដើម្បីបញ្ចុះបញ្ចូលឲ្យព្រះមហាក្សត្រនរោត្តម ឈប់ដាក់ប្រទេសនៅក្រោមចំណុះសៀមទៀត តាមការសុំអន្តរាគមន៍របស់ព្រះមហាក្សត្រអង្គឌួង ជាព្រះបិតារបស់ព្រះអង្គ ទៅព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ កាលពីឆ្នាំ១៨៥៤។

ពេលនោះ ព្រះមហាក្សត្រនរោត្តម មានព្រះទ័យរារែកយ៉ាងខ្លាំង ព្រោះម្យ៉ាងខ្លាចស្តេចសៀម ធ្វើទុក្ខបុកម្នេញ ម្យ៉ាងទៀតខ្លាចបារាំងការពារប្រទេសមិនបាន បណ្តាលឲ្យយួនលេបទឹកដីអស់។ តែព្រះអង្គឈ្វេងយល់ថា ការដែលព្រះមហាក្សត្រអង្គឌួង ជាព្រះបិតាបានស្នើសុំទៅព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ ឲ្យជួយអន្តរាគមន៍ការពារទឹកដីខ្មែរ ឲ្យរួចផុតពីការបែងចែកទឹកដីរវាងប្រទេសសៀម និងយួន កាលពីឆ្នាំ១៨៥៤នោះក៏ជាមធ្យោបាយមួយល្អប្រសើរដែរ។

ទោះបីព្រះមហាក្សត្រនរោត្តម មានព្រះទ័យរារែកយ៉ាងណាក៏ដោយ ក៏ឧត្តមនាវី ដឺឡា ហ្គ្រង់ឌីយ៉ែរ មានផែនការរួចជាស្រេចហើយ គឺមិនឲ្យប្រទេសខ្មែរធ្លាក់នៅក្រោមចំណុះសៀម តទៅទៀតជាដាច់ខាត ព្រោះពេលនោះ ប្រទេសអង់គ្លេស ដែលជាគូប្រជែងរបស់ខ្លួនបានចូលមកបោះទីតាំងយោធានៅក្នុងប្រទេសសៀម រួចទៅហើយ និងបម្រុងពង្រីកឥទ្ធិពលរបស់គេនៅតំបន់អាស៊ីអាគ្នេយ៍បន្តទៀត។

លុះដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ឧត្តមនាវី ដឺឡា ហ្គ្រង់ឌីយ៉ែរ (De La Grandière) បានធ្វើដំណើរទៅរាជធានីឧដុង្គ ម្តងទៀត ដើម្បីឲ្យព្រះមហាក្សត្រនរោត្តមឡាយព្រះហស្តលេខាលើសន្ធិសញ្ញាយល់ព្រមទទួលយកបារាំង ធ្វើអាណាព្យាបាលលើប្រទេសខ្មែរ។ ពេលនោះ ព្រះមហាក្សត្រនរោត្តម យល់ព្រមឡាយព្រះហស្តលេខាជាមួយឧត្តមនាវី ដឺឡា ហ្គ្រង់ឌីយ៉ែរ ទាំងញញើតញញើម។

សន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ មានខ្លឹមសារជាអាទិ៍ថា៖ ប្រទេសបារាំង និងប្រទេសខ្មែរផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក។ ព្រះចៅអធិរាជបារាំងសន្យាថា នឹងរៀបចំប្រទេសកម្ពុជាឲ្យស្ថិតក្នុងសន្តិភាព និងមានរបៀបរៀបរយ ការពារ

ចំពោះការឈ្លានពានទាំងឡាយមកពីខាងក្រៅ និងជួយខ្មែរក្នុងការហូតពន្ធគយ ផ្តល់ភាពងាយស្រួលក្នុងការធ្វើគមនាគមន៍តាមផ្លូវសមុទ្រ។

ប៉ុន្តែសន្ធិសញ្ញានេះ បានចែងដែរថា បើគ្មានការយល់ព្រមពីបារាំងទេ ព្រះមហាក្សត្រខ្មែរក៏មិនអាចទាក់ទងជាមួយប្រទេសណាមួយផ្សេងទៀតបានដែរ។

ដើម្បីអនុវត្តសន្ធិសញ្ញានេះ បារាំងត្រូវតែងតាំងទេសាភិបាលជាន់ខ្ពស់ម្នាក់ ជាតំណាង ឲ្យមកប្រចាំការនៅរាជធានីឧដុង្គ ហើយអាណាចក្រខ្មែរ ក៏ត្រូវតែងតាំងតំណាងរបស់ខ្លួនម្នាក់ ប្រចាំនៅក្រុងព្រៃនគរដែរ។

ជាថ្នូរវិញ ប្រទេសកម្ពុជាព្រមធ្វើសម្បទានដល់ប្រទេសបារាំង នូវដីម្តុំជ្រោយចង្វា និងបើកសិទ្ធិឲ្យបារាំងកាប់ឈើក្នុងព្រៃ នៃព្រះរាជាណាចក្រខ្មែរ ដើម្បីយកទៅស្ថាបនាកប៉ាល់ ។

ទោះបីសន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ខាងភាគីខ្មែរចាញ់ប្រៀបបារាំងខ្លះៗក៏ដោយ ក៏មតិខ្មែរខ្លះយល់ថា អាចទទួលយកបាន ព្រោះបារាំង មិនបានដកហូតអំណាចពីព្រះមហាក្សត្រខ្មែរនោះទេ។ តែក៏មានអ្នកស្នេហាជាតិមួយចំនួន បានក្រោកឈរឡើងធ្វើការតស៊ូបះបោរ ប្រឆាំងនឹងបារាំងដែរ។

ចាប់តាំងពីមានសន្ធិសញ្ញានោះមក ព្រះមហាក្សត្រនរោត្តម បានចុះព្រះហស្តលេខាលើព្រះរាជក្រឹត្យជាច្រើន ដែលផ្តល់ផលចំណេញដល់បារាំង ទាំងអស់។ ដោយសារហេតុនេះ ព្រះមហាក្សត្រនរោត្តម ក៏បានចាត់ឲ្យមន្ត្រីជំនិតរបស់ព្រះអង្គមួយចំនួន បង្កឲ្យមានការបះបោរ ដើម្បីការពារព្រះអង្គផងដែរ។

ចំណែកព្រះចៅសៀម វិញ មានការខឹងសម្បាយ៉ាងខ្លាំង ចំពោះការចុះសន្ធិសញ្ញានេះ ហើយបានគំរាមកំហែងព្រះមហាក្សត្រនរោត្តម ដោយមិនព្រមប្រគល់ព្រះខ័ន និងមកុដរាជ្យខ្មែរ ដែលខ្លួនយកទៅរក្សាទុកនៅក្នុងរាជវាំងនោះ ថ្វាយមកព្រះអង្គវិញជាដាច់ខាត។

ពេលនោះ ពួកមន្ត្រីខ្មែរមួយចំនួនដែលមាននិន្នាការលម្អៀងទៅខាងសៀម បានអូសទាញព្រះមហាក្សត្រនរោត្តម ឲ្យវិលមករកសៀម វិញដែរ ។ ប៉ុន្តែបារាំងបានប្រឆាំង

តបវិញ ដោយបញ្ជូនកប៉ាល់៥គ្រឿង និងទាហានជើងទឹក ១០០នាក់ ឡើងមកកាន់រាជធានីឧដុង្គ។

នៅដើមឆ្នាំ១៨៦៤ បារាំងបានធ្វើការគាបសង្កត់ស្តេចសៀម តាមផ្លូវទូត និងតាមផ្លូវយោធា រហូតស្តេចសៀម យល់ព្រមបញ្ជូនព្រះខ័នរាជ្យ និងមកុដរាជ្យ សម្រាប់ធ្វើពិធីរាជាភិសេកព្រះបាទនរោត្តម ជាព្រះមហាក្សត្រពេញលក្ខណៈច្បាប់ជាផ្លូវការ នៅរាជធានីឧដុង្គ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤។

ក្រោយពីបានរាជាភិសេកជាព្រះមហាក្សត្រពេញលក្ខណៈជាផ្លូវការមក ព្រះមហាក្សត្រ នរោត្តម អមព្រះរាជដំណើរដោយទេសាភិបាលជាន់ខ្ពស់បារាំង ឌូដា ដឺ ឡាគ្រេ (Doudart de lagrée) បានយាងទៅជួបអគ្គទេសាភិបាល ដឺឡា ហ្គ្រង់ឌីយ៉ែរ (Dela Grandière) នៅទីក្រុងព្រៃនគរ។

ពេលនោះ ព្រះមហាក្សត្រនរោត្តម បានស្នើសុំបារាំងបង្វិលសងខេត្ត៣ គឺខេត្តលង់ហោរ ខេត្តមាត់ជ្រូក និងខេត្តពាម មកឲ្យអាណាចក្រខ្មែរវិញ ។ បារាំងបានទទួលការស្នើសុំនេះហើយ។ ប៉ុន្តែ ដោយនៅក្នុងខេត្តទាំង៣នេះ ជាកន្លែងដែលពួកអ្នកតស៊ូយួនធ្វើសកម្មភាពប្រឆាំងនឹងខ្លួនខ្លាំងពេក បារាំងចេះតែពន្យារពេលយូរទៅៗ រហូតដល់ឆ្នាំ១៨៦៧ បារាំង ក៏បានបញ្ចូលខេត្តទាំងនេះជាទឹកដីឯនាយសមុទ្ររបស់ខ្លួន ដោយភ្លេចគិតដល់ពាក្យសន្យាជាមួយព្រះមហាក្សត្រនរោត្តម។

ពីឆ្នាំ១៨៥៩ ដល់ឆ្នាំ១៨៦៧ កងទ័ពបារាំង បានដណ្តើមយកខេត្តទាំងអស់នៅកម្ពុជាក្រោម តែបារាំង មិនប្រគល់ខេត្តទាំងអស់នោះ មកឲ្យខ្មែរវិញទេ គឺបារាំងបានយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនក្នុងក្របខ័ណ្ឌជាដែនដីបារាំងនៅឯនាយសមុទ្រ (Territoire d'Ou-etre-Mer) និងបានដាក់ឈ្មោះថា កូសាំងស៊ីន ទៅវិញ ។

ម្ល៉ោះហើយអាជ្ញាធរបារាំង នៅកូសាំងស៊ីន បានធ្វើការកែប្រែខ្សែបន្ទាត់ព្រំដែនតាមទំនើងចិត្ត ដោយសំអាងលើបញ្ហានយោបាយ និងសេដ្ឋកិច្ច ហើយការកែប្រែខ្សែបន្ទាត់ព្រំដែននោះ សុទ្ធតែចំណេញទឹកដីទៅខាងកូសាំងស៊ីន ជានិច្ច ដោយមិនអើពើដល់ការតវ៉ា



វាំងចាស់នៅរាជធានីពីឧដុង្គ



រាជវាំងថ្មីនៅរាជធានីភ្នំពេញ

របស់ព្រះមហាក្សត្រខ្មែរ ម្តងណាឡើយ។

ក្នុងឆ្នាំ១៨៦៦ ព្រះមហាក្សត្រនរោត្តម បានសម្រេចព្រះទ័យរុះរើផ្លាស់ប្តូររាជធានីពីឧដុង្គ មកសាងសង់ព្រះបរមរាជវាំង នៅភ្នំពេញ ត្រង់ខាងលិចទន្លេចតុមុខ។

នៅក្នុងខែឧសភា ឆ្នាំ១៨៦៦ អាចារ្យពោធិ៍កំបោរ ជាព្រះសង្ឃមួយអង្គ គង់នៅក្រុងព្រៃនគរ បានភៀសខ្លួនទៅខេត្តពោធិ៍សាត់ ជាស្រុកកំណើតរបស់គាត់ ដើម្បីប្រមូលកម្លាំងធ្វើការតស៊ូប្រឆាំងនឹងបារាំង។

មួយខែក្រោយមក កម្លាំងតស៊ូរបស់គាត់បានធ្វើសកម្មភាពសម្លាប់មេទាហានបារាំង ២នាក់។ ពេលនោះ កងទ័ពបារាំងនៅក្រុងព្រៃនគរ ក៏បានចេញទៅរកបង្ក្រាបពួកគាត់ដែរ តែមិនបានសម្រេច។

នៅខែធ្នូ ឆ្នាំដដែលនោះ អាចារ្យពោធិ៍កំបោរ បានប្រមូលកម្លាំងប្រជារាស្ត្រប្រហែលមួយម៉ឺននាក់ មកចូលរួមក្នុងចលនាតស៊ូរបស់គាត់។ បន្ទាប់មក គាត់បានដឹកនាំកងទ័ពឆ្លងចូលក្នុងប្រទេសខ្មែរ ហើយធ្វើសកម្មភាពប្រឆាំងនឹងបារាំង នៅតាមតំបន់សងខាងទន្លេមេគង្គ និងនៅតំបន់ចន្លោះពីភ្នំពេញ ទៅរាជធានីឧដុង្គ ។

ពេលវាយប្រយុទ្ធគ្នាជាមួយកងទ័ពបារាំង នៅជាយភ្នំពេញ កងទ័ពរបស់គាត់ត្រូវទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ ហើយគាត់បានរត់គេចខ្លួន ទៅសំងំលាក់ខ្លួននៅខេត្តកំពង់ស្វាយ តែត្រូវកងទ័ពបារាំងចាប់បាន ហើយសម្លាប់គាត់យកក្បាលមកដោតនៅរាជធានីឧដុង្គ នៅខែធ្នូ ឆ្នាំ១៨៦៧។

## របត់នយោបាយ

នៅក្នុងឆ្នាំ១៨៦៤នោះដែរ អាចារ្យស្វា ជាខ្ញុំបម្រើរបស់នាម៉ឺនម្នាក់ឈ្មោះឧកញ៉ាវិជ្ជាសុខ នៅរាជធានីឧដុង្គ បានភៀសទៅខេត្តទ្រាំង ដើម្បីកទ័ពបង្កើតចលនាតស៊ូប្រឆាំងនឹងបារាំងដែរ។

លុះបង្កើតកម្លាំងតស៊ូបានសមល្មមហើយ អាចារ្យស្វា ក៏លើកទ័ពឆ្ពោះទៅរាជធានីឧដុង្គ តែមកដល់ភ្នំពេញ ត្រូវកងទ័ពព្រះមហាក្សត្រនរោត្តម និងកងទ័ពបារាំង វាយឱ្យបាក់ទ័ព ហើយដេញតាមចាប់គាត់បាននៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៨៦៦។

អាចារ្យស្វា ត្រូវបារាំងនិរទេសយកទៅដាក់នៅកោះត្រឡាច រួចបញ្ជូនទៅដាក់គុកនៅរ៉េអុយនីញ៉ុង (Réunion) ដែលជាកោះមួយនៅមហាសមុទ្រឥណ្ឌា ដែលជាទឹកដីឯនាយសមុទ្ររបស់បារាំង។

លុះមកដល់ឆ្នាំ១៨៦៧ ក្រោយពីប្រទេសបារាំង និងអង់គ្លេស បានក្លាយទៅជាសម្ព័ន្ធមិត្តនឹងគ្នា ទើបបារាំង និងសៀម មានការស្រុះស្រួលគ្នាដែរ។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧ បារាំង និងសៀម បានព្រមព្រៀងគ្នាចុះសន្ធិសញ្ញាមួយ ដោយបារាំង ព្រមប្រគល់ខេត្តបាត់ដំបង និងសៀមរាប ទៅឲ្យសៀម។ ឯសៀម យល់ព្រមទទួលស្គាល់ប្រទេសបារាំង ជាអាណាព្យាបាលលើប្រទេសខ្មែរ។

ជាមួយគ្នានោះ បារាំងក៏បានសន្យាថា ខ្លួននឹងមិនបញ្ចូលប្រទេសខ្មែរ ជាប្រទេសអាណានិគម ដូចកម្ពុជាក្រោមនោះឡើយ។

តែទោះបីជាព្រះចៅសៀម បានព្រមព្រៀងគ្នាចុះសន្ធិសញ្ញាទទួលស្គាល់ប្រទេសបារាំង ជាអាណាព្យាបាលលើប្រទេសខ្មែរ ក៏ពិតមែន តែសៀម នៅត្រួតត្រាខេត្តបាត់ដំបង សៀមរាប សិរីសោភ័ណ ម្លូព្រៃ និងទន្លេរពៅ ដដែល ។

នៅឆ្នាំ១៨៧០ ពួកបារាំង បានចាប់ផ្តើមសាងសង់សណ្ឋាគារ សាលារៀន ពន្ធនាគារ បន្ទាយទាហាន ធនាគារ ការិយាល័យការងារសាធារណៈ ការិយាល័យទូរលេខ ប្រៃសណីយ៍ សាលាកាត់ក្តី និងអគារបម្រើសេវាសុខភាព នៅតាមមាត់ទន្លេចតុម្មុខនោះ ។

ក្នុងរជ្ជកាលព្រះបាទមុនីវង្ស (១៩២៧ ១៩៤១) ភ្នំពេញ ស្ថិតនៅជាស្រុកមួយ

ចំណុះខេត្តកណ្តាល ហើយថៅហ្វាយស្រុកភ្នំពេញ មានងារជា បំរុងរាជា និងបាឡាត់ស្រុកភ្នំពេញ មានងារជាពិភ័ក្តរាជាសង្គ្រាម។ ក្រោយមកទៀត កងទ័ពបារាំង បានចូលទៅឈរជើងនៅទឹកដីតុងកឹង (វៀតណាមភាគខាងជើង) ហើយបានកាន់កាប់ក្រុងហាណូយ បានពីរដង គឺនៅក្នុងឆ្នាំ១៨៧៣ ម្តង និង១៨៨២ ម្តង ទោះបីការដណ្តើមកាន់កាប់ក្រុងហាណូយ ទាំងពីរលើកនេះ មេបញ្ជាការកំពូលៗរបស់ពួកគេ គឺឧត្តមសេនីយ៍ ហ្វ្រង់ស៊ីស ហ្គានី (Francis Garnie) និងឧត្តមសេនីយ៍ ហង់រី រីវីយ៉េរ (Henri Rivière) ត្រូវបានពួកយួនស្ទាក់វាយប្រហារ និងសម្លាប់ចោលក៏ដោយ ។

មកដល់ឆ្នាំ១៨៧៦ ព្រះអង្គស៊ីវត្ថា បានលេចមុខចេញមកបំបះបំបោរប្រជារាស្ត្រនៅខេត្តបាភ្នំ រំដួល ព្រៃវែង ដើម្បីប្រឆាំងនឹងពួកបារាំង ជាថ្មីម្តងទៀត។ តែលើកនេះដោយមានជំនួយពីទ័ពបារាំងផង ព្រះមហាឧបរាជស៊ីសុវត្ថិ ជាអនុជរបស់ព្រះមហាក្សត្រនរោត្តម បានចេញទៅបង្ក្រាបដោយជោគជ័យ។ ចំណែកព្រះអង្គស៊ីវត្ថា បានដកកងទ័ពខ្លួនថយរហូតទៅដល់ភាគខាងត្បូងនៃប្រទេសលាវ នៅខែកុម្ភៈ ឆ្នាំ១៨៧៧ ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ហ្សាល ថុំសុន (Charles Thomson) ទេសាភិបាលជាន់ខ្ពស់នៅដែនដីកូសាំងស៊ីន បានបញ្ជូនទាហានជើងទឹកមួយក្រុមឲ្យចូលទៅក្នុងរាជវាំង ទាំងកណ្តាលអធ្រាត្រ។

ពេលនោះ ប្រតិភូបារាំងម្នាក់បានបញ្ជាឲ្យដាស់ព្រះមហាក្សត្រនរោត្តម ដែលកំពុងផ្ទំលក់ ហើយបង្ខំឲ្យឡាយព្រះហស្តលេខាលើសន្ធិសញ្ញាថ្មីមួយទៀត ។ សន្ធិសញ្ញានេះ បានដកសិទ្ធិដឹកនាំគ្រប់គ្រងប្រទេសពីព្រះមហាក្សត្រ ដើម្បីឲ្យបារាំង ធ្វើជាអ្នកត្រួតត្រាលើប្រទេសខ្មែរទាំងមូលជំនួសវិញ។

កិច្ចព្រមព្រៀងដោយចាប់បង្ខំនេះ មានខ្លឹមសារជាអាទិ៍ថា៖ ព្រះមហាក្សត្រ ត្រូវទទួលស្គាល់ជាមុន នូវកំណែទម្រង់ផ្នែករដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលសាធារណរដ្ឋបារាំង យល់ថា គួរតែធ្វើក្នុងអនាគតកាល ។

ក្នុងការគ្រប់គ្រងខេត្ត និងក្រសួងនានា មន្ត្រីខ្មែរ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ

របស់អាជ្ញាធរបារាំង ។ ឯក្រសួងគយ ពន្ធដារ ក្រសួងសាធារណការ និងក្រសួងឯទៀត ដែលត្រូវប្រើវិស្វករ បានត្រូវបារាំង ជាអ្នកកាន់កាប់ដោយផ្ទាល់។

រដ្ឋាភិបាលបារាំង ជាអ្នកតែងតាំងទេសាភិបាល (រ៉េស៊ីដង់) និងទេសាភិបាលរង (រ៉េស៊ីដង់រង) ឲ្យដឹកនាំត្រួតត្រាពីលើមន្ត្រីខ្មែរនៅតាមបណ្ដាខេត្តនីមួយៗ។

ការចំណាយទាំងឡាយរបស់មន្ត្រីរាជការខ្មែរ និងរបស់មន្ត្រីរដ្ឋការអាណាព្យាបាល បារាំង ជាបន្ទុករបស់ប្រទេសកម្ពុជា។

ព្រះមហាក្សត្រ ត្រូវទទួលប្រាក់បៀវត្សដែលមានកម្រិតជាក់លាក់ ហើយមិនអាច យកប្រាក់រដ្ឋ ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលបារាំង ឡើយ។

ដីធ្លីក្នុងព្រះរាជាណាចក្រទាំងមូល ពីដើមជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ ត្រូវពួក អាជ្ញាធរបារាំង រៀបចំឲ្យមានកម្មសិទ្ធិឯកជនខាងដីធ្លីវិញ។

ចាប់ពីពេលនោះ ប្រទេសខ្មែរ ក៏ក្លាយជាប្រទេសដែលឋិតនៅក្រោមនឹមអាណានិគម របស់បារាំង យ៉ាងពិតប្រាកដ។

ព្រះមហាក្សត្រនរោត្តម យល់ថា ការបង្ខំឲ្យទទួលយកសន្ធិសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤នោះ គឺជាបញ្ហារំលោភបំពានយ៉ាងធ្ងន់ធ្ងរ ចំពោះអធិបតេយ្យភាពរបស់ប្រទេស ខ្មែរ ហើយព្រះអង្គក៏បានរកមធ្យោបាយ ដើម្បីរំដោះប្រទេសព្រះអង្គឲ្យរួចពីនឹមត្រួតត្រា ផ្ទាល់ របស់បារាំង នេះដែរ។

នៅឆ្នាំ១៨៨៥ ព្រះអង្គស៊ីវត្ថា បានរៀបចំកងទ័ពប្រុងវាយឧដុង្គរាំងចាស់ ជាថ្មីម្ដង ទៀត ប៉ុន្តែត្រូវអាក់ខានទៅវិញ ហើយបានដកខ្លួនទៅព្រំដែនសៀម។

ក្នុងខែឧសភា ឆ្នាំ១៨៨៦ កងទ័ពរបស់ព្រះអង្គស៊ីវត្ថា ប្រមាណ៥០០០នាក់ បើក ការវាយលុកចូលរាជធានីភ្នំពេញ តែត្រូវកងទ័ពបារាំង វាយកម្ចាត់កម្ចាយដកថយវិញអស់ ។ តែចាប់ពីពេលនោះមក រហូតដល់ឆ្នាំ១៨៩០ កងទ័ពរបស់ព្រះអង្គស៊ីវត្ថា បានបើកការវាយ ប្រហារជាច្រើនកន្លែង ធ្វើឲ្យកងទ័ពបារាំង និងកងទ័ពព្រះមហាក្សត្រ ខូចខាតយ៉ាងដំណំ។

តែនៅឆ្នាំ១៨៩១ ព្រះអង្គស៊ីវត្ថា បានទទួលមរណភាពដោយជំងឺ ចលនាតស៊ូរបស់

ទ្រង់ ក៏រលំរលាយត្រឹម នោះមក។

ក្នុងឆ្នាំ១៨៨៥នោះដែរ ចលនាតស៊ូជាច្រើនបាន ផ្ទុះឡើង ពិសេសចលនាតស៊ូដឹកនាំដោយពិស្ណុលោកឈូក និងក្រឡាហោមគង់។ ចលនាបះបោរក្រឡាហោមគង់ បានទទួលការគាំទ្រពីប្រជាកសិករ ជនជាតិចិនមួយចំនួន និងព្រះសង្ឃផងដែរ មានបំណងប្រយុទ្ធរំដោះប្រទេស ជាតិពីអំពើជិះជាន់របស់ពួកបារាំង។



ព្រះអង្គស៊ីវត្ថា

តែនៅឆ្នាំ១៨៨៦ បារាំងបានប្រើល្បិចអញ្ជើញ ក្រឡាហោមគង់ ឱ្យចូលមកធ្វើការចរចាគ្នា រួចក៏ចាប់ចង គាត់ផ្អោបនឹងបំពង់ផ្សែងកប៉ាល់ រហូតដល់បាត់បង់ជីវិត។

ចំណែកចលនាបះបោររបស់ពិស្ណុលោកឈូក បានចូលរួមជាមួយក្រឡាហោមគង់ ដើម្បីប្រយុទ្ធរំដោះប្រទេសជាតិពីអំពើជិះជាន់របស់ពួកបារាំង ដែរនោះ ក៏ត្រូវបារាំងបាន ប្រើល្បិចអញ្ជើញឱ្យចូលមកធ្វើការចរចាគ្នា រួចសម្លាប់ចោលដែរ ។

ពួកមន្ត្រីបារាំងភាគច្រើនយល់ថា ព្រះមហាក្សត្រនរោត្តម ជាអ្នកនៅពីក្រោយខ្នង ចលនាតស៊ូដឹកនាំដោយពិស្ណុលោកឈូក និងក្រឡាហោមគង់ នេះ។

ក្នុងឆ្នាំ១៨៨៦ បារាំងបានបង្កើតឲ្យមានទេសាភិបាល និងទេសាភិបាលរង នៅក្រុង ភ្នំពេញ និងនៅតាមខេត្ត៤ទៀត គឺខេត្តកំពត ខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តពោធិ៍សាត់ ដើម្បីត្រួតត្រាមើលការខុសត្រូវពីលើចៅហ្វាយក្រុង និងចៅហ្វាយខេត្តខ្មែរ ថែមទៀត ។

ក្រោយពីបានកាន់កាប់ត្រួតត្រាលើប្រទេសវៀតណាមទាំងមូលមក នៅក្នុងខែតុលា ឆ្នាំ១៨៨៧ បារាំងបានបង្កើតសហភាពឥណ្ឌូចិនមួយ ដែលរួមមាន៖ ប្រទេសតុងកឹង ប្រទេសអណ្ណាម ប្រទេសកូសាំងស៊ីន និងប្រទេសខ្មែរ ។ លុះឆ្នាំ១៨៩៣ បារាំងបានបញ្ចូល ប្រទេសលាវ ( ឡាវ ) មួយទៀត ទៅក្នុងសហភាពឥណ្ឌូចិន នេះដែរ។

# ២
# កម្ពុជា ក្រោមអាណានិគមបារាំង



**ព្រះមហាក្សត្រ នរោត្តម**

នៅក្នុងសហភាពឥណ្ឌូចិន កូសាំងស៊ីន ជាទឹកដីឯនាយសមុទ្ររបស់បារាំង។ ចំណែកតុងកឹង ព្រមទាំងអណ្ណាម ដែលមានរាជវង្សង្វៀន នៅតែបន្តគ្រប់គ្រងដដែល រួមទាំងប្រទេសខ្មែរ ដែលមានព្រះមហាក្សត្រនរោត្តម កំពុងសោយរាជសម្បត្តិ និងប្រទេសលាវ (ឡាវ) ដែលមានព្រះមហាក្សត្រកំពុងសោយរាជសម្បត្តិដែរនោះ មានឋានៈជារដ្ឋនៅក្រោមអាណាព្យាបាលរបស់បារាំង។

នៅខែតុលា ឆ្នាំ១៨៨៧ មុនវាយដណ្តើមប្រទេសលាវ បារាំងមានគម្រោងបង្កើតសហព័ន្ធមួយនៅលើទឹកដីទាំងឡាយដែលខ្លួនកាន់កាប់ ហៅថា សហព័ន្ធឥណ្ឌូចិន។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៨៩៣ បារាំងបានបញ្ជូននាវាចម្បាំងចំនួន២គ្រឿង ឲ្យឡើងតាមទន្លេចៅព្រះយ៉ា ឬទន្លេមេណាម ទៅចតនៅមុខក្រុងបាងកក។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំដដែល បារាំងបានបង្ខំព្រះចៅសៀម ចុឡាឡុងកន ចុះសន្ធិសញ្ញាដកកងទ័ពសៀម ដែលឈរជើងនៅត្រើយខាងលិចទន្លេមេគង្គ ឲ្យអស់ មិនឲ្យមានកងទ័ពសៀម នៅទីនោះទៀត។

ជាមួយគ្នានោះដែរ បារាំងបានបញ្ជូនកងទ័ពខ្លួនឲ្យទៅឈរជើងនៅខេត្តចន្ទបុរីរបស់សៀម ដើម្បីបង្ខំឱ្យសៀមគោរពសន្ធិសញ្ញានេះ ។ តែពេលនោះ បារាំងមិនបានទាមទារឲ្យសៀមប្រគល់ខេត្តបាត់ដំបង និងសៀមរាប មកឲ្យខ្មែរវិញទេ។

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៨៩៣ ទើបសុខចិត្តដកថយ ពីដែនដីទាំងអស់ដែលនៅត្រើយខាងលិចនៃទន្លេមេគង្គ។

តាមសន្ធិសញ្ញានេះ សៀមលែងមានសិទ្ធិតាំងទ័ព ឬសង់បន្ទាយនៅតំបន់ដែលមានទទឹងចម្ងាយ២៤គីឡូម៉ែត្រ ស្របតាមត្រើយខាងលិចនៃទន្លេមេគង្គ ព្រមទាំងនៅខេត្តបាត់ដំបង និងសៀមរាបផងដែរ។ ដូចនេះពួករាជការសៀម បានផ្តើមពង្រឹងអំណាចប៉ូលិស ដើម្បីត្រួតត្រាតំបន់គ្មានកងទ័ពសៀមនោះជំនួសវិញ។

នៅឆ្នាំ១៨៩៦ បារាំងបានបញ្ជូនស្នងការម្នាក់ ឲ្យមកតាំងទីនៅខេត្តបាត់ដំបង ដើម្បីការពារសិទ្ធិរស់នៅរបស់ជនជាតិខ្មែរ លាវ យួន នៅខេត្តមួយនោះ។

នៅឆ្នាំ១៨៩៧ ព្រះចៅជុឡាឡុងកន បានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសនានានៅទ្វីបអឺរ៉ុប ដែលរួមមានប្រទេសរុស្ស៊ី ប្រទេសអាល្លឺម៉ង់ ប្រទេសអង់គ្លេស ប្រទេសបារាំង ។

នៅក្រុងប៉ារីស ព្រះចៅសៀម បានចូលទៅជួបប្រធានាធិបតីបារាំងឈ្មោះ ភេលិចផូរ ស្នើសុំឲ្យលុបចោលមាត្រាទី៤ នៃសន្ធិសញ្ញាថ្ងៃទី២០ ខែកក្កដា ដែលបារាំងមានសិទ្ធិការពារជនជាតិខ្មែរ យួន លាវ នៅក្នុងទឹកដីដែលសៀម កាន់កាប់នោះចេញ។

នៅក្នុងឆ្នាំ១៩០២ បារាំងបានយល់ព្រមចុះសន្ធិសញ្ញាជាមួយសៀម លុបចោលសិទ្ធិការពារជនជាតិខ្មែរ យួន លាវ ដែលមានចែងក្នុងមាត្រា៤ នៃសន្ធិសញ្ញាឆ្នាំ១៨៩៣នោះវិញ ដោយគ្រាន់តែយកខេត្តម្លូព្រៃ និងទន្លេរពៅមកវិញ ។ តែការលុបចោលនេះ សន្ធិសញ្ញាថ្មីនេះត្រូវបានសាធារណមតិបារាំង រិះគន់យ៉ាងខ្លាំង ហើយសាធារណរដ្ឋបារាំង ក៏ខកខានមិនបានផ្តល់សច្ចាប័នពីបញ្ហានេះទៅវិញដែរ ។

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៤ វេលាម៉ោង៣រសៀល ព្រះមហាក្សត្រនរោត្តមទ្រង់បានសោយទិវង្គត ក្នុងជន្មាយុ៧០ព្រះវស្សា ដោយបន្សល់ទុកមហេសី និងស្នំចំនួន



ព្រះអង្គម្ចាស់នរោត្តម
យុគន្ធរ

៤៧អង្គ ហើយព្រះបរមសពមានព្រះមរណនាមថា ព្រះសុវណ្ណកោដ្ឋ។

ប៉ុន្មាននាទីក្រោយព្រះអង្គសោយទិវង្គត ក្រោមអធិបតីទេសាភិបាលជាន់ខ្ពស់បារាំង ក្រុមប្រឹក្សារាជបល្ល័ង្ក បានបើកសម័យប្រជុំពិសេស ក្រោមអធិបតីទេសាភិបាលជាន់ខ្ពស់បារាំង ដើម្បីជ្រើសតាំងព្រះមហាក្សត្រថ្មី តាមប្រពៃណីខ្មែរ។

ដោយសារព្រះមហាក្សត្រនរោត្តម ពុំសូវមានការចុះសម្រុងជាមួយទេសាភិបាលជាន់ខ្ពស់បារាំង ទើបទេសាភិបាលជាន់ខ្ពស់បារាំង សង្ស័យថា ព្រះអង្គជាអ្នកនៅពីក្រោយខ្នងចលនាតស៊ូបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់បារាំងនោះ ពិសេសព្រះអង្គម្ចាស់យុគន្ធរ ជាព្រះរាជបុត្រសំណព្វព្រះហឫទ័យ ដែលព្រះអង្គចង់ឲ្យសោយរាជ្យបន្តនោះ ធ្លាប់បានធ្វើដំណើរទៅកាន់អឺរ៉ុប ហើយបានបើកកកាយពីរឿងពួកអាណានិគមបារាំង រំលោភអធិបតេយ្យភាព ជិះជាន់សង្កត់សង្កិន ធ្វើបាបប្រជារាស្ត្រខ្មែរសាហាវឃោរឃៅបំផុត ដើម្បីឲ្យពិភពលោកបានដឹងនោះ ព្រះរាជបុត្ររបស់ព្រះអង្គទាំងអស់ពុំត្រូវបានជ្រើសតាំងឲ្យឡើងសោយរាជ្យស្នងព្រះបិតាទេ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សារាជបល្ល័ង្ក ដែលស្ថិតនៅក្រោមឥទ្ធិពលទេសាភិបាលជាន់ខ្ពស់បារាំងនោះ បានសម្រេចជ្រើសតាំងព្រះមហាឧបរាជ ស៊ីសុវត្ថិ ជាព្រះអនុជរបស់ព្រះមហាក្សត្រ នរោត្តម ឲ្យឡើងសោយរាជ្យបន្ត។

ប៉ុន្មានខែក្រោយព្រះបាទស៊ីសុវត្ថិ បានឡើងសោយរាជ្យ បារាំងបានបង្ខំឱ្យព្រះចៅសៀម ចុះសន្ធិសញ្ញាប្រគល់ខេត្តត្រាត កោះកុង ម្លូព្រៃ និងទន្លេរពៅ ដែលមានទំហំ២០០០០ គីឡូម៉ែត្រក្រឡា មកឲ្យប្រទេសខ្មែរវិញ ។

នៅពេលជាមួយគ្នានោះ បារាំងបានដកខេត្តស្ទឹងត្រែង និងស្រុកសៀមប៉ាង ពី

ប្រទេសលាវ ប្រគល់មកឲ្យប្រទេសខ្មែរវិញផងដែរ។

៣ឆ្នាំក្រោយមកទៀត តាមរយៈសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩០៧ ប្រទេសសៀម បានប្រគល់ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តស៊ីសូផុន ដែលសៀមបានរឹបយកពីខ្មែរ តាំងពីឆ្នាំ១៧៩៥ មកឲ្យប្រទេសខ្មែរវិញ។ តែបារាំងក៏បានប្រគល់ខេត្តត្រាត ខេត្តចន្ទបុរី និងកោះមួយចំនួនឲ្យទៅប្រទេសថៃ ជាថ្នូរទៅវិញដែរ។

កន្លះឆ្នាំក្រោយមក ព្រះករុណាព្រះមហាក្សត្រស៊ីសុវត្ថិ ទ្រង់បានចេញព្រះរាជប្រកាសលេខ៦៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩០៧ កំណត់បែងចែកដែនដីបាត់ដំបង ជា៣ខេត្ត គឺខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តសិរីសោភ័ណ។

កាលពីឆ្នាំ១៨៨៦ នៅទីក្រុងប៉ារីស អាជ្ញាធរបារាំងបានបើកសាលាមួយឈ្មោះសាលាបេសកកម្មខ្មែរ ដែលមានយុវជនខ្មែរចំនួនប្រមាណជាង១០នាក់ ទៅសិក្សាពីជំនាញរដ្ឋបាលតាមបែបបស្ចិមប្រទេស។ រយៈពេល៣ឆ្នាំក្រោយមក សាលានេះបានប្រែក្លាយជាសាលារដ្ឋបាលអាណានិគម។


ព្រះមហាក្សត្រ ស៊ីសុវត្ថិ

លុះដល់ឆ្នាំ១៩១៤ ដោយការរីកដុះដាលផ្នែករដ្ឋបាល តម្រូវឲ្យមានមន្ត្រីរដ្ឋបាលថ្នាក់មធ្យមច្រើន ទើបបារាំងបង្កើតសាលាក្រមការមួយនៅក្រុងភ្នំពេញ សម្រាប់បណ្តុះបណ្តាលមន្ត្រីរដ្ឋបាលខ្មែរ។ នៅឆ្នាំ១៩១៧ សាលានេះបានប្រែឈ្មោះថា ជាសាលារដ្ឋបាលតុលាការខ្មែរវិញ សម្រាប់បណ្តុះបណ្តាលអ្នករាជការក្នុងក្រុមរដ្ឋបាលផង ក្នុងក្រុមតុលាការផង ប៉ុន្តែត្រូវបានបិទទ្វារវិញ នៅឆ្នាំ១៩៤៨-១៩៤៩។

នៅក្នុងឆ្នាំ១៩១៥ ព្រះមហាក្សត្រស៊ីសុវត្ថិ បានអំពាវនាវឲ្យប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ធ្វើពិធីបួងសួងឲ្យកងទ័ពបារាំង កំពុងធ្វើសង្គ្រាមលោកលើកទី១

ដែលចាប់ផ្តើមកើតមានឡើងនៅឆ្នាំ១៩១៤ នោះ សូមឲ្យមានជ័យជម្នះលើខ្មាំងសត្រូវ។

ពេលនោះដែរ បារាំងបានកេណ្ឌប្រជាជនវៀតណាម ឡាវ និងខ្មែរ នៅឥណ្ឌូចិន ដែលស្ថិតនៅក្រោមនឹមអាណានិគមរបស់ខ្លួន ឲ្យចូលបម្រើក្នុងជួរកងទ័ពបារាំង និងបានបញ្ជូនពួកគេឲ្យទៅច្បាំង នៅប្រទេសបារាំង ។

ក្រោយពេលបញ្ចប់សង្គ្រាមលោកលើកទី១ ក្នុងឆ្នាំ១៩១៨ បារាំង ក៏បានបញ្ជូនពួកទាហានជាជនជាតិវៀតណាម ឡាវ និងខ្មែរនៅឥណ្ឌូចិន ឲ្យត្រឡប់មកមាតុប្រទេសវិញរៀងៗខ្លួនដែរ នៅក្នុងនោះក៏មានអ្នកបកប្រែភាសាបារាំង-ខ្មែរ ឈ្មោះប៉ាច ឈឺន ធ្វើជាទាហានផ្នែកបញ្ជូនសារម្នាក់ដែរ ។

ក្រោយបញ្ចប់អាជីពជាទាហានបារាំង ពេលត្រឡប់មកដល់មាតុប្រទេសវិញ ប៉ាច ឈឺន បានចូលធ្វើការនៅយានដ្ឋានមួយឈ្មោះថា ស៊ីត្រូអ៊ែន និងប៉ឺហ្សូ (Citroen et Peugeot) នៅទីក្រុងភ្នំពេញ ។ ចំណែកឈ្មោះ ឃឹម ទិត ធ្លាប់ទៅធ្វើសង្គ្រាមនៅប្រទេសបារាំងជាមួយគ្នាដែរនោះ ក្រោយពេលត្រឡប់មកដល់មាតុប្រទេសវិញ បានចូលបម្រើការងារជាមន្ត្រីបារាំង ហើយបានឡើងបុណ្យស័ក្តិជាបន្តបន្ទាប់។

នៅក្នុងឆ្នាំ១៩១៧ បារាំងបានបង្កើតសាលាអប់រំបច្ចេកទេសខាងសិល្បៈ និងសិប្បកម្មមួយ គឺសាលារចនា។

ចាប់ពីឆ្នាំ១៩២១មក ជនជាតិវៀតណាម មានប្រមាណជិត៧ភាគរយ នៃប្រជារាស្ត្រខ្មែរសរុប ។ កាលនោះ ពួកគេបានចាកចេញពីប្រទេសខ្លួន មកធ្វើជាកម្មករនៅតាមចម្ការកៅស៊ូនានារបស់បារាំង ដែលការងារនេះ មានជនជាតិខ្មែរតិចតួចប៉ុណ្ណោះដែលចូលចិត្តធ្វើ។

ជាមួយគ្នានោះ ពួកកសិករ និងអ្នកនេសាទវៀតណាម ជាច្រើនទៀត ក៏បានចាកចេញពីដែនដីកូសាំងស៊ីន ចូលមករកដីប្រកបមុខរបរកសិកម្ម និងនេសាទ នៅក្នុងប្រទេសខ្មែរផងដែរ។

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥ ប្រជារាស្ត្រនៅភូមិក្រាំងលាវ ស្រុករលាប្អៀរ ខេត្ត

កំពង់ឆ្នាំង បានងើបឡើងបះបោរប្រឆាំងនឹងការគាបសង្កត់ទារពន្ធពីពួកបារាំង រហូត ដល់ផ្ទុះកំហឹងកាប់សម្លាប់ទេសាភិបាលខេត្តកំពង់ឆ្នាំង ឈ្មោះហ្វេលីក្ស បារដេស (Felix Bardez) និងជនជាតិខ្មែរជាអ្នកបកប្រែភាសាបារាំងម្នាក់ឈ្មោះ សួន ព្រមទាំងកងរក្សា ស្រុកម្នាក់ឈ្មោះ ឡាច ផងដែរ ។

ក្រោយពីកើតហេតុការណ៍នោះបាន៥ ថ្ងៃ ទេសាភិបាលជាន់ខ្ពស់បារាំង ប្រចាំប្រទេសកម្ពុជា ហ្វ្រង់ស័រ ម៉ារីយុស បូឌាំង (François Marius Baudoin) បានកោះប្រជុំមន្ត្រីជាន់ខ្ពស់ សម្រេចឲ្យព្រះមហាក្សត្រព្រះបាទស៊ីសុវត្ថិ ចេញព្រះរាជក្រឹត្យមួយប្តូរឈ្មោះភូមិក្រាំងលាវ ទៅជាភូមិតិរច្ឆានវិញ។

ពីឆ្នាំ១៩២២ ដល់ឆ្នាំ១៩២៥ ទេសាភិបាលជាន់ខ្ពស់របស់បារាំង បានក្តោបក្តាប់អំណាចស្ទើរតែទាំងអស់នៅប្រទេសខ្មែរ ខណៈព្រះមហាក្សត្រ គ្រាន់តែជាអ្នកគោរពសក្ការៈរបស់អាណាប្រជានុរាស្ត្រខ្មែរប៉ុណ្ណោះ។

នៅតាមបណ្តាខេត្តទាំងអស់ ទេសាភិបាលបារាំង មានអំណាចក្នុងការសម្រេចកិច្ចការគ្រប់បែបយ៉ាង ហើយចៅហ្វាយខេត្តជាជនជាតិខ្មែរ ជាអ្នកអនុវត្តតាមការសម្រេចចិត្តរបស់ទេសាភិបាលបារាំងនោះ និងជាអ្នកបញ្ជាលើអាជ្ញាធរមូលដ្ឋានដោយផ្ទាល់ ។ ពួកទេសាភិបាលបារាំង និងចៅហ្វាយខេត្តខ្មែរទាំងនោះ បានរួមសហការគ្នា ក្នុងការបំពេញភារកិច្ចយ៉ាងល្អប្រសើរ ហើយមានមន្ត្រីអាណាព្យាបាលបារាំងជាច្រើនត្រូវបានទទួលការកោតសរសើរ និងគោរពពីបណ្តាមន្ត្រីរាជការខ្មែរ។ តែក៏មានមន្ត្រីអាណាព្យាបាលបារាំងមួយចំនួន បានធ្វើខ្លួនឲ្យទៅជាមនុស្សដែលគួរឲ្យស្អប់ ដោយសារភាពក្រអឺតក្រទមរបស់ពួកគេផងដែរ។

នៅចុងទសវត្សរ៍១៩១០ ព្រះមហាក្សត្រស៊ីសុវត្ថិ សព្វព្រះហឫទ័យចង់ឱ្យមានការសិក្សាផ្នែកព្រះពុទ្ធសាសនាឱ្យបានទូលំទូលាយ ។ ខណៈដែលអាណាព្យាបាលបារាំង ក៏ចង់បង្កើតមជ្ឈមណ្ឌលសម្រាប់សិក្សាផ្នែកព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា ដើម្បីប្រកួតប្រជែងជាមួយប្រទេសសៀម ផងដែរ ។

## របត់នយោបាយ


**ព្រះរាជបណ្ណាល័យជាតិ ឆ្នាំ១៩២៥**
(រូបថត របស់បណ្ណាសារដ្ឋានជាតិកម្ពុជា)

ដោយមានការឯកភាពគ្នាជាមួយទេសាភិបាលជាន់ខ្ពស់ប្រចាំកម្ពុជា ព្រះមហាក្សត្រស៊ីសុវត្ថិ បានចេញរាជប្រកាសចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩២១ បង្កើតបណ្ណាល័យមួយឈ្មោះថា "ខេមរបណ្ណាល័យ "នៅភ្នំពេញ ដើម្បីសិក្សាផ្នែកព្រះពុទ្ធសាសនាឱ្យបានទូលំទូលាយ ។

លុះដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៥ បណ្ណាល័យនេះត្រូវបានប្តូរឈ្មោះថា " ព្រះរាជបណ្ណាល័យ" វិញ។

ព្រះរាជបណ្ណាល័យនេះ កញ្ញាជនជាតិបារាំងម្នាក់ឈ្មោះស៊ុយសាន កាប៉ឺឡែស មកពីសាលាបារាំងចុងបូព៌ាប្រទេសជាអ្នកគ្រប់គ្រង ដោយមានក្រុមជំនុំជាជនជាតិខ្មែរ រួមមាន៖ សេនាបតី ( រដ្ឋមន្ត្រី ) ក្រសួងមហាផ្ទៃ និងធម្មការ ជាអធិបតី , សេនាបតីក្រសួងរចនា, សេនាបតីក្រសួងសិក្សាធិការ ,រាជាគណៈ២អង្គ ដែលមកពីគណៈមហានិកាយ១អង្គ និងមកពីគណៈធម្មយុត្តនិកាយ១អង្គ ។

សាលាបារាំងចុងបូព៌ាប្រទេស ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៨៩៨ ដោយមានឈ្មោះដំបូងបំផុតថា បេសកកម្មបុរាណវិទ្យា មានទីស្នាក់ការដំបូងបង្អស់នៅព្រៃនគរ តែក្រោយមក នៅឆ្នាំ១៩០២ ទីស្នាក់ការនេះត្រូវបានប្តូរមកទីក្រុងហាណូយវិញ។

ព្រះរាជបណ្ណាល័យមានភារៈស្រាវជ្រាវប្រមែប្រមូលសៀវភៅសាវតារខាងនយោបាយ ខាងរចនា ខាងសាសនា សាស្ត្រា លិខិតបោះពុម្ព លិខិតសរសេរដោយដៃគ្រប់មុខជាភាសាខ្មែរ បាលី សំស្ក្រឹត ឬលិខិតដែលមានប្រយោជន៍សម្រាប់ប្រទេសជាតិទាំងអស់ មករក្សាទុក និងបោះពុម្ពផ្សាយបន្តទៀត។

នៅឆ្នាំ១៩២៦ ព្រះរាជបណ្ណាល័យបានបង្កើតទស្សនាវដ្ដីមួយដែលមានឈ្មោះថា " កម្ពុជសុរិយា " ។ ទស្សនាវដ្ដីនេះ មិនត្រឹមតែបោះពុម្ពផ្សាយអំពីរឿងរ៉ាវដែលទាក់ទងនឹងព្រះពុទ្ធសាសនាប៉ុណ្ណោះទេ តែថែមទាំងបានបោះពុម្ពផ្សាយអត្ថបទមួយចំនួនផ្សេងទៀតដែលនិយាយអំពីប្រពៃណី ទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ និងរឿងព្រេងរបស់ខ្មែរ ព្រមទាំងប្រវត្តិសាស្ត្រ និងអក្សរសាស្ត្រនៃប្រទេសដទៃផងដែរ ។

នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៣០ តាមការណែនាំរបស់អង្គការកុម្មុយនិស្តអន្តរជាតិដែលហៅកាត់ថា កូមីនតែន(COMINTERN) ដែលមានស្នាក់ការនៅក្រុងម៉ូស្គូ សហភាពសូវៀត ហូ ជីមិញ បានសម្រេចដូរឈ្មោះបក្សកុម្មុយនិស្តវៀតណាម មកជាបក្សកុម្មុយនិស្តឥណ្ឌូចិន វិញ ដើម្បីប្រមូលចលនាកុម្មុយនិស្តនៅកម្ពុជា នៅឡាវ និងនៅវៀតណាម ឲ្យចូលគ្នាជាបក្សតែមួយ។ ប៉ុន្តែដោយសារនៅកម្ពុជា ពុំមានចលនាកុម្មុយនិស្តនៅឡើយនោះ ហូ ជីមិញ បានសម្រេចជ្រើសរើសពួកកម្មករវៀតណាម ដែលកំពុងធ្វើការក្នុងចម្ការកៅស៊ូនានារបស់បារាំង នៅភាគខាងកើតប្រទេសកម្ពុជា ឲ្យចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន នោះតែម្តង។ រហូតក្រោយពេលបារាំងធ្វើការបង្ក្រាបបាតុកម្មរបស់ព្រះសង្ឃដែលទាមទារឲ្យដោះលែងលោកគ្រូអាចារ្យហែម ចៀវ នៅក្នុងឆ្នាំ១៩៤២ ទើបបក្សកុម្មុយនិស្តឥណ្ឌូចិន ចាប់ផ្តើមបញ្ចូលជនជាតិខ្មែរជាសមាជិករបស់ខ្លួន ពិសេសព្រះសង្ឃដែលរត់ចូលព្រៃតស៊ូ ប្រឆាំងនឹងបារាំង។

នៅដើមទសវត្សរ៍ឆ្នាំ១៩៣០នោះ ប្រជារាស្ត្រខ្មែរត្រូវរងទុក្ខលំបាកវេទនាជាទីបំផុត ។ ផលិតផលផ្សេងៗរបស់ខ្មែរ នៅលើទីផ្សារអន្តរជាតិត្រូវចុះថោក ហើយពន្ធអាករផ្សេងៗបារាំងនៅតែទារស្មើមុនដដែល ហើយការបង្ខំឲ្យបង់ពន្ធអាករនេះ គឺច្រើនជាងនៅប្រទេសវៀតណាម និងឡាវ ទៀតផង ខណៈប្រជារាស្ត្រខ្មែរខ្វះខាតសម្លៀកបំពាក់ និងការហូបចុកយ៉ាងខ្លាំង។

ទោះបីយ៉ាងនេះក៏ដោយ ក៏ប្រជាជនខ្មែរមិនបានធ្វើសកម្មភាពអ្វីប្រឆាំងនឹងបារាំងគួរឲ្យគួរកត់សម្គាល់ដែរ ។ ប៉ុន្តែក្រោយពីការចេញផ្សាយរបស់កាសែត "នគរវត្ត" និងដោយ

មានការបំផុសពីបក្សកុម្មុយនិស្តឥណ្ឌូចិនផងដែរនោះ ប្រជារាស្ត្រខ្មែរក៏ចាប់ផ្តើមមានគំនិតប្រឆាំងនឹងការជិះជាន់របស់អាណានិគមបារាំង កាន់តែខ្លាំងបន្តិចម្តងៗ។

ចំណែកនៅប្រទេសវៀតណាម វិញ នៅក្នុងខែតុលា ឆ្នាំ១៩៣០ ពេលសេដ្ឋកិច្ចក៏ធ្លាក់ចុះដុនដាបដែរនោះ មានការបះបោរសម្លាប់មន្ត្រីបារាំង និងកើតមានចលនាតស៊ូប្រឆាំងបារាំង ជាច្រើនកន្លែងទៀត ក្រោមការញុះញង់ពីសំណាក់បក្សកុម្មុយនិស្តឥណ្ឌូចិន។

ដើម្បីឲ្យងាយស្រួលក្នុងការកសាងមនុស្ស សម្រាប់បម្រើការងារឲ្យរាជការ នៅក្នុងឆ្នាំ១៩៣០ បារាំងបានបង្កើតឲ្យមានសាលាបឋមសិក្សានៅទូទាំងប្រទេស ចំនួន៣០សាលា និងបង្កើតអនុវិទ្យាល័យមួយ គឺអនុវិទ្យាល័យព្រះស៊ីសុវត្ថិ។ លុះ៥ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៣៥ អនុវិទ្យាល័យនេះ ត្រូវបានដំឡើងឲ្យទៅជាវិទ្យាល័យស៊ីសុវត្ថិ។

នៅឆ្នាំ១៩៣៦ ទេសាភិបាលបារាំង បានចេញច្បាប់មួយ បង្ខំឲ្យសិស្សវិទ្យាល័យស៊ីសុវត្ថិ ទាំងអស់ ដែលមានអាយុចាប់ពី២០ឆ្នាំឡើងទៅ ត្រូវបង់ពន្ធដូចប្រជារាស្ត្រខ្មែរទូទៅដែរ។ ពេលនោះហើយ ដែលធ្វើឲ្យសិស្សវិទ្យាល័យនេះ មានការខឹងសម្បា ហើយនាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងបារាំង ជាលើកដំបូងបង្អស់។

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៣៦ ពួកសិស្សវិទ្យាល័យស៊ីសុវត្ថិ បានចាប់ផ្តើមធ្វើកូដកម្ម និងបានសរសេរលិខិតមួយផ្ញើទៅទេសាភិបាលជាន់ខ្ពស់បារាំង ដោយតវ៉ាថា ពួកយើងជាសិស្សកំពុងសិក្សា មិនទាន់មានការងារធ្វើផង តើបានប្រាក់ឯណាយកទៅបង់ពន្ធនោះ? បាតុករបានបញ្ជាក់ថា ពួកគេ នឹងធ្វើកូដកម្មនេះបន្តទៅទៀត ប្រសិនបើពុំមានដំណោះស្រាយណាមួយពីបញ្ហានេះ។



ទិដ្ឋភាពវិទ្យាល័យព្រះស៊ីសុវត្ថិ
ពេលចាប់ផ្តើមកសាងដំបូង

លុះដល់ថ្ងៃទី៧ ខែឧសភា អគ្គទេសាភិបាលឥណ្ឌូចិន បានបដិសេធមិនទទួលយកសំណើរបស់

ពួកសិស្សទាំងនេះទេ ហើយចោទថា ការធ្វើកូដកម្មនេះពាក់ព័ន្ធដល់រឿងនយោបាយ និងថា ការធ្វើកូដកម្មនេះ ដោយសារពួកកូនសិស្សទាំងនោះខ្ជិលចូលរៀនទៅវិញ។

តែនៅក្នុងរបាយការណ៍ប្រចាំខែឧសភា ឆ្នាំ១៩៣៦ ស្តីពីសភាពការណ៍នៅប្រទេសកម្ពុជា ទេសាភិបាលជាន់ខ្ពស់បារាំង បានរាយការណ៍ថា ការធ្វើកូដកម្មនេះ បណ្តាលមកពីសិស្សដែលស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន មានការខឹងសម្បាចំពោះនាយកវិទ្យាល័យ ដែលបានដាក់វិន័យតឹងតែងទៅលើពួកគេខ្លាំងពេក។

ជាមួយគ្នានេះ ក៏មានរបាយការណ៍មួយទៀតបានលើកឡើងថា ការធ្វើបាតុកម្មនេះ គឺដោយសារគ្រឹះស្ថានសិក្សាឯកជនមួយឈ្មោះឡឺរ៉ូយ៉ាល់ បានដាក់ទណ្ឌកម្មទៅលើកូនសិស្សម្នាក់ធ្ងន់ធ្ងរពេក ។ តែសិស្សវិទ្យាល័យនេះភាគច្រើនមិនគិតថា ការធ្វើកូដកម្មនេះ មិនមែនជាការប្រឆាំងនឹងពួកបារាំងឡើយ គឺពួកគេនៅស្រឡាញ់ចូលចិត្តសាស្ត្រាចារ្យជាជនជាតិបារាំងរបស់ខ្លួន ហើយការធ្វើកូដកម្មនេះ ក៏គ្មានទាក់ទងអ្វីជាមួយអ្នករាជការរដ្ឋបាល ឬមន្ត្រីប៉ូលិសណាម្នាក់ឡើយ។

នៅក្នុងឆ្នាំ១៩៣៦ ចំនួនប្រជាជនសរុបនៅក្នុងទីក្រុងភ្នំពេញ មានប្រមាណ ១០០.០០០នាក់ប៉ុណ្ណោះ ហើយជាងពាក់កណ្តាលនៃចំនួននេះ សុទ្ធតែជាពួកអន្តោ-ប្រវេសន៍ចិន និងវៀតណាម ជាអ្នកគ្រប់គ្រងលើសកម្មភាពពាណិជ្ជកម្មតូចធំទាំងអស់ ។

ចំណែកជនជាតិខ្មែរ ប្រមាណ៤៥០០០នាក់ទៀត ភាគច្រើនរស់នៅប្រមូលផ្តុំគ្នានៅជុំវិញព្រះបរមរាជវាំង។ ផ្ទះសម្បែងរបស់ជនជាតិខ្មែរ សង់ពីឈើ ឬឫស្សី ខ្ពស់ផុតពីដីក្នុងទីធ្លាដែលមានដើមចេក ដើមស្វាយដុះព័ទ្ធជុំវិញ ដូចផ្ទះសម្បែងជនជាតិខ្មែរនៅតាមតំបន់ជនបទដែរ ហើយភាគច្រើនជាមន្ត្រីរាជការ ជាអ្នកជួលប្រវាស់ដី និងជាអ្នកសាងផ្នួសក្នុងព្រះពុទ្ធសាសនា ដោយទុកមុខរបររកស៊ីជួញដូរឲ្យពួកអន្តោប្រវេសន៍ចិន វៀតណាមទាំងស្រុងទៅវិញ។

ពេលនោះ ជនជាតិវៀតណាម ត្រូវបានអាជ្ញាធរបារាំង លើកទឹកចិត្តឲ្យចូលមករស់នៅក្នុងទឹកដីខ្មែរកាន់តែច្រើនឡើងៗ។ ដោយសារយល់ឃើញថា ជនជាតិមួយនេះមាន



**បឹងតេជោស្រី បារាំងចាក់ដីលុបធ្វើផ្សារធំថ្មី ក្នុងទសវត្សឆ្នាំ១៩៣០**

ភាពស្វាហាប់ និងមានចំណេះដឹងខាងភាសាបារាំង ជាងជនជាតិខ្មែរនោះ បារាំងបានផ្តល់បុណ្យស័ក្តិ មុខតំណែងដល់ពួកគេជាច្រើននៅក្នុងកិច្ចការរដ្ឋបាលរបស់ប្រទេសកម្ពុជាទៀតផង។

នៅក្នុងឆ្នាំ១៩៣៧ សាលាបឋមសិក្សានៅទូទាំងប្រទេស បានកើនឡើងដល់៨១៣ សាលា។ ឆ្នាំ១៩៣៨ ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស បានព្រមព្រៀងគ្នាជាផ្លូវការជាមួយរដ្ឋមន្ត្រីក្រសួងអាណានិគមរបស់រដ្ឋាភិបាលបារាំង ហ្សក ម៉ង់ដែល គ្រោងតែងតាំងបុត្រា ស៊ីសុវត្ថិ មុនីរ៉េត ជារាជទាយាទដែលត្រូវស្នងរាជ្យបន្ត។ ពេលនោះ រដ្ឋមន្ត្រីក្រសួងអាណានិគមបារាំងរូបនេះ បានយាងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត និងព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត ទៅក្រុងប៉ារីស ដើម្បីចង់ដឹងពីទស្សនៈរបស់ខ្សែរាជវង្សស៊ីសុវត្ថិ និងខ្សែរាជវង្សនរោត្តម ព្រមទាំងធ្វើការសម្របសម្រួលរវាងខ្សែរាជវង្សទាំងពីរនេះផងដែរ ។ រដ្ឋមន្ត្រីក្រសួងអាណានិគមបារាំងរូបនេះ បានផ្តល់គ្រឿងឥស្សរិយយសដល់ព្រះអង្គម្ចាស់ទាំងពីរអង្គ និងបានឲ្យព្រះអង្គម្ចាស់ទាំងពីរអង្គនេះសន្យាថា មិនយករឿងនេះទៅផ្សព្វផ្សាយឲ្យមនុស្សណាផ្សេងទៀតដឹងផងដែរ។

# ៣
# លន់ នល់ និង ប៉ុល ពត



លន់ នល់



ប៉ុល ពត

មុនពេលសម្តេចព្រះនរោត្តម សីហនុ ទៅបន្តការសិក្សានៅវិទ្យាល័យសាស្ស៊ីលូឡូបា នោះ លន់ នល់ ដែលជាអនាគតប្រធានាធិបតីនៃរបបសាធារណរដ្ឋខ្មែរ ពីឆ្នាំ១៩៧០ ដល់១៩៧៥ បានបញ្ចប់ការសិក្សានៅវិទ្យាល័យនោះ នៅក្នុងឆ្នាំ១៩៣៤ និងបានត្រឡប់មកមាតុប្រទេសវិញ បាន៤ឆ្នាំទៅហើយ។

២ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៣៦ លន់ នល់ ដែលមានវ័យត្រឹមតែ២៣ឆ្នាំ បានចូលបម្រើការងារជាចៅក្រម និងសាលាដំបូងខេត្តសៀមរាប ។ ក្រោយពីបំពេញមុខងារជាចៅក្រមបានរយៈពេល១ឆ្នាំ លន់ នល់ ក៏បានផ្លាស់មកបម្រើការងារជាមន្ត្រីរដ្ឋបាលខេត្តកំពង់ចាម វិញ។

លន់ នល់ កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩១៣ នៅខេត្តព្រៃវែង មានអាយុច្រើនជាងសម្តេចសីហនុ ៩ឆ្នាំ។ ឪពុកឈ្មោះ លន់ ហ៊ិន ម្តាយឈ្មោះម៉ៅ នួន។

ក្រោយពីមានស្នាដៃបង្ក្រាបក្រុមចោរប្លន់ដ៏ធំមួយនៅខេត្តព្រៃវែង លន់ ហ៊ិន ជាឪពុកត្រូវបានអាជ្ញាធរបារាំង តែងតាំងឱ្យធ្វើជាចៅហ្វាយស្រុក ពីស្រុកមួយទៅស្រុកមួយទៀត

ជាបន្តបន្ទាប់ រហូតដល់ឡើងឋានៈជាចៅហ្វាយខេត្តសៀមរាប និងខេត្តកំពង់ធំ។

កាលពីនៅវ័យកុមារ លន់ នល់ បានចូលសិក្សានៅសាលាបឋមសិក្សាឌូដា ឌឺឡាហ្គ្រេ ក្រុងភ្នំពេញ និងបានទៅបន្តសិក្សានៅវិទ្យាល័យសាស៊្សីលូ ឡូបា នៅទីក្រុងព្រៃនគរ ពីឆ្នាំ១៩២៨ ដល់ឆ្នាំ ១៩៣៤។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩២០ ក៏មានអនាគតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ម្នាក់ទៀតដែរ គឺសាឡុត ស ។

សាឡុត ស កើតនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩២៥ (បើគិតតាមថ្ងៃខែឆ្នាំកំណើតដែលបានចុះក្នុងបញ្ជីជាតិ ឆ្នាំ១៩២៨) នៅភូមិព្រែកស្បូវ ឃុំអូរគន្ធរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (បច្ចុប្បន្ន ក្រុងស្ទឹងសែន) ក្នុងគ្រួសារកសិករមួយមានដីស្រែជាង ១០ហិកតារ មានផ្ទះក្បឿងធំទូលាយ នៅឯត្រើយ ម្ខាងស្ទឹងសែន ចម្ងាយប្រមាណ ៧គីឡូម៉ែត្រពីទីក្រុងកំពង់ធំ។ ឪពុកឈ្មោះ សាឡុត ប៉ែន និងម្តាយឈ្មោះ សុក ណែម មានបងប្អូន៧នាក់។ សាឡុត ស ជាកូនពៅគេ។

នៅក្នុងឆ្នាំ១៩២២ បងប្រុស សាឡុត សួង ដែលទើបមានអាយុ១២ឆ្នាំ ត្រូវបានឪពុកបញ្ជូនមកទីក្រុងភ្នំពេញ ឲ្យស្នាក់នៅក្នុងវត្តមួយ ដើម្បីបន្តការសិក្សានៅទីនោះ។

នៅក្នុងឆ្នាំ១៩២៥ បងស្រីជីដូនមួយរបស់សាឡុត ស ម្នាក់ ឈ្មោះឡុង មាយ ជាអ្នករាំបាំព្រះរាជទ្រព្យប្រចាំព្រះបរមរាជវាំង ដែលមានឪពុកឈ្មោះឡុង ឈឹម និងម្តាយឈ្មោះជ័យ បានក្លាយជាស្នំរបស់ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស និងមានគោរម្យងារថា ឃុនព្រះម្នាង បុប្ផានរលក្ខណ៍ មាយ មានអំណាចត្រួតលើស្រីស្នំទាំងអស់នៅក្នុងវាំង លើកលែងតែសម្តេចព្រះអគ្គមហេសី គឺមហាក្សត្រី នរោត្តម កាញ្ចនវិមាន នរលក្ខណ៍ទេវី និងព្រះជាយា គឺម្ចាស់ក្សត្រី នរោត្តម បុប្ផាក្អួង។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩២៦ ឃុនព្រះម្នាង ប្រសូតបានបុត្រាមួយអង្គព្រះនាម ស៊ីសុវត្ថិ មុនីវង្ស កុស្សរៈ។

នៅក្នុងឆ្នាំ១៩២៨ ឃុនព្រះម្នាង បុប្ផានរលក្ខណ៍ មាយ បាននាំសាឡុត សួង

ឲ្យបានចូលបម្រើការងារជាមន្ត្រីនៅការិយាល័យពិធីការក្នុងព្រះបរមរាជវាំង ហើយបានរៀបការជាមួយស្រីជាអ្នករាំរបាំម្នាក់ឈ្មោះជា សាមី ។

នៅពេលបងស្រីរបស់សាឡុត ស ម្នាក់ឈ្មោះសាឡុត រឿង ចូលដល់វ័យ១៤ឆ្នាំ យុនព្រះម្នាង មាយ បងស្រីជីដូនមួយ បានយកមកឲ្យធ្វើជាអ្នករាំរបាំនៅក្នុងព្រះបរមរាជវាំងដែរ តែមិនយូរប៉ុន្មាន សាឡុត រឿង ក៏បានក្លាយទៅជាស្នំរបស់ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ដែរ។

ចំណែក សាឡុត ស នៅឆ្នាំ១៩៣៤ មានអាយុ៦ឆ្នាំ (បើគិតតាមថ្ងៃខែឆ្នាំកំណើតដែលបានចុះក្នុងបញ្ជីជាតិ ឆ្នាំ១៩២៨) និងបងប្រុសម្នាក់ទៀតឈ្មោះ សាឡុត ឆាយ ត្រូវបានគ្រួសារបញ្ជូនពីស្រុកកំណើតនៅខេត្តកំពង់ធំ ឲ្យមករស់នៅភ្នំពេញ ជាមួយសាឡុត សួង និងជា សាមី នៅផ្លូវគ្រសក់ផ្អែម។ ក្រោយពីមកដល់ភ្នំពេញ ជាង១ឆ្នាំ សាឡុត ស ក៏បានសាងផ្នួសរៀនធម៌ និងភាសាខ្មែរ នៅវត្តបុទមវតី ដែលស្ថិតនៅជាប់នឹងព្រះបរមរាជវាំង ព្រោះពេលនោះប្រទេសកម្ពុជា កំពុងស្ថិតក្រោមអាណាព្យាបាលបារាំង ហើយនៅតាមសាលារៀនរបស់រដ្ឋ គេតម្រូវឲ្យរៀនជាភាសាបារាំង។

ក្រោយពីបានបួសអស់ប៉ុន្មានខែមក នៅឆ្នាំ១៩៣៦ សាឡុត ស ក៏បានចូលរៀននៅសាលាបឋមសិក្សាកាតូលិកមួយ ឈ្មោះសាលាមីហ្ស (Miche) ដែលនៅជិតព្រះបរមរាជវាំង។ សិស្សនៅសាលានេះ ភាគច្រើនជាកូនមន្ត្រីរាជការ ឬអ្នកមានឋានៈធំដុំ ហើយថ្លៃសាលានោះទៀតសោត ក៏មានតម្លៃខ្ពស់ដែរ។

នៅពេលដែលសាឡុត ស ទើបតែបានចូលរៀននៅសាលាបឋមសិក្សានោះ សឺង ង៉ុកថាញ់ ស៊ឹម វ៉ា និងប៉ាច ឈឺន ដែលធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងក្រុង ភ្នំពេញ ត្រូវបានទទួលការអនុញ្ញាតពីអាជ្ញាធរបារាំង ឲ្យចេញផ្សាយកាសែតជាភាសាខ្មែរមួយឈ្មោះកាសែត "នគរវត្ត" ជាកាសែតភាសាខ្មែរលើកដំបូងបង្អស់ នៅប្រទេសកម្ពុជា ។ កាសែត "នគរវត្ត" មានចុះផ្សាយអត្ថបទរិះគន់ណែកថាជាច្រើន ដែលបង្ហាញពីគំនិតជាតិនិយម។

## របត់នយោបាយ

ពេលនោះ សាឡុត ស ដែលរស់នៅជាមួយបងៗ ប្រហែលជាបានអានកាសែតនេះរាល់ថ្ងៃ ពីព្រោះសាឡុត សួង ដែលត្រូវជាបងបង្កើត បានជាវកាសែត "នគរវត្ត" នោះ មកអានជាប្រចាំ។ អំឡុងពេលនោះហើយ ដែលធ្វើឲ្យសាឡុត ស ចាប់ផ្តើមមានគំនិតជាតិនិយម។

នៅឆ្នាំ១៩៤២ សាឡុត ស បានជាប់ឈ្មោះក្នុងចំណោមសិស្ស២០នាក់ ដែលត្រូវបានជ្រើសរើសឲ្យទៅរៀននៅអនុវិទ្យាល័យព្រះសីហនុ ដែលបារាំងទើបនឹងបង្កើតនៅទីរួមខេត្តកំពង់ចាម។

---

# ៤
# រជ្ជកាលព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស



**ព្រះមហាក្សត្រ ស៊ីសុវត្ថិ មុនីវង្ស**

ព្រះមហាក្សត្រស៊ីសុវត្ថិ ប្រសូតនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៨៤០ ហើយសោយទិវង្គត នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩២៧ ក្នុងព្រះជន្ម៨៧វស្សា ។ ក្រោយពីព្រះមហាក្សត្រស៊ីសុវត្ថិ សោយទិវង្គតទៅ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស ជាបុត្រទី៦ ក្នុងចំណោមបុត្រាបុត្រីទាំងអស់ និងជាបុត្រាទី២ របស់ព្រះអង្គ ជាមួយអ្នកម្នាងវ៉ាន់ បានឡើងសោយរាជ្យបន្ត ។

ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ទ្រង់ព្រះសម្ភពនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៨៧៥ ក្នុងរាជធានីភ្នំពេញ ។ ព្រះអង្គបានយាងអមព្រះរាជដំណើរព្រះបាទស៊ីសុវត្ថិ ជាបិតា ទៅកាន់ប្រទេសបារាំង ។ ពេលនោះ ព្រះអង្គបានចូលសិក្សានៅក្នុងសាលាយោធាសាំង-មេហ្សង់ (Saint-Maixent)។ ព្រះអង្គបានសិក្សានៅទីនោះរយៈពេល២ឆ្នាំ និងបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ត្រី នៅក្នុងជួរកងបរទេស របស់បារាំង (French Foreign Legion) ។

## របត់នយោបាយ

ឆ្នាំ១៩០៩ ព្រះអង្គបានយាងត្រឡប់មកកម្ពុជាវិញ ។ ព្រះអង្គត្រូវបានដំឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ទោ ក្នុងឆ្នាំ១៩១០ , ជាអនុសេនីយ៍ឯក ក្នុងឆ្នាំ១៩១៦, ជាមេបញ្ជាការកងវរសេនាតូច ក្នុងឆ្នាំ១៩២២ ។ ក្នុងអំឡុងសង្គ្រាមលោកលើកទី១ ព្រះអង្គបានបំពេញតួនាទីជានាយទាហានស្ម័គ្រចិត្តយ៉ាងសកម្ម ហេតុព្រះអង្គបានទទួលព្រះគោរម្យងារជាសម្តេចព្រះកែវហ្វា។ បន្ទាប់មកព្រះអង្គបានទទួលព្រះតំណែងជាអគ្គលេខាធិការនៃគណៈ-រដ្ឋមន្ត្រី និងជាអធិបតី នៃក្រុមសង្គហព្រះរាជវង្សានុវង្ស។

ជាមួយគ្នានោះដែរ ក៏មានខ្មែរនៅកូសាំងស៊ីន ម្នាក់ទៀត ឈ្មោះសឺង ង៉ុកថាញ់ កើតនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩០៨ ដំបូងបានសិក្សានៅសាលាបឋមសិក្សានៅក្នុងស្រុកកំណើត និងបានបន្តការសិក្សានៅទីក្រុងព្រៃនគរ រួចហើយក៏បានទៅសិក្សានៅសាលាមធ្យមសិក្សានៅទីក្រុងម៉ុងប៉េលលីយេ ប្រទេសបារាំង បន្តទៀត ដោយបានចូលសិក្សាមហាវិទ្យាល័យច្បាប់ នៅទីក្រុងប៉ារីស បានមួយឆ្នាំ ក៏ត្រឡប់មកទឹកដីកូសាំងស៊ីន វិញ។

នៅក្នុងឆ្នាំ១៩៣៣ ក្រោយពីបានចូលបម្រើការងារជាស្មៀន នៅបណ្ណាល័យជាតិក្រុងភ្នំពេញ មួយរយៈពេលខ្លីមក គាត់បានផ្លាស់ទៅបម្រើការងារជាចៅក្រម នៅសាលាដំបូងខេត្តពោធិ៍សាត់ វិញ ។ បន្ទាប់មកទៀត គាត់បានបម្រើការងារជាព្រះរាជអាជ្ញាសាលាដំបូងក្រុងភ្នំពេញ និងក្រោយមកទៀតជានាយករងពុទ្ធសាសនបណ្ឌិត្យ។

នៅក្នុងឆ្នាំ១៩៣៤ សមាគមអតីតសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ត្រូវបានបង្កើតឡើងដោយមានសឺង ង៉ុកថាញ់ ជាទីប្រឹក្សា ។

នៅក្នុងឆ្នាំ១៩៣៦ សឺង ង៉ុកថាញ់, ប៉ាច ឈឿន និងស៊ឹម វ៉ា បានរួមគ្នាបង្កើតកាសែតជាភាសាខ្មែរលើកដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជា ឈ្មោះកាសែត "នគរវត្ត" ។

កាសែត "នគរវត្ត" បានចុះផ្សាយពីសកម្មភាពនានារបស់ឥស្សរជនខ្មែរ ផ្សព្វផ្សាយឡើងវិញពីខ្លឹមសារទាំងស្រុងស្តីពីបទប្បញ្ញត្តិច្បាប់ និងព្រះរាជក្រឹត្យផ្សេងៗ។ ប៉ុន្តែនៅក្នុងអត្ថបទវិចារណកថារបស់ខ្លួន កាសែតនេះបានសរសេរបំផុសប្រជារាស្ត្រខ្មែរ ឲ្យមានការភ្ញាក់រលឹកក្នុងការរកស៊ីធ្វើស្រែចម្ការ ពិសេសចេះប្រកបមុខរបររកស៊ីជួញដូរ ដូចពួក

អាណិកជនចិន និងវៀតណាម ព្រមទាំងបំផុសឲ្យមានគំនិតជាតិនិយម និងទាមទារឲ្យមានសមភាពគ្នារវាងជនជាតិខ្មែរ និងបារាំង ផងដែរ។

កាសែត "នគរវត្ត" ចង់បានការជួយឧបត្ថម្ភ គាំទ្រក្នុងការបោះពុម្ពផ្សាយរបស់ខ្លួនពីសំណាក់ព្រះមហាក្សត្រមុនីវង្ស ដែរ ប៉ុន្តែបំណងប្រាថ្នានេះ ត្រូវបានព្រះរាជបុត្រច្បងរបស់ព្រះអង្គ គឺទ្រង់ស៊ីសុវត្ថិ មុនីរ៉េត បដិសេធ ហើយមានបន្ទូលដោយត្រង់ៗថា ការផ្សព្វផ្សាយអប់រំតាមរយៈកាសែត "នគរវត្ត" នោះ គឺជាការខាតបង់ពេលវេលា ហើយវានឹងធ្វើឲ្យកាន់តែមានការពិបាកក្នុងការគ្រប់គ្រង ដឹកនាំប្រទេសថែមទៀត នៅពេលណាដែលខ្មែរមានអ្នកចេះដឹងច្រើនពេក។

តែទោះបីជាយ៉ាងណា ក៏ព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត ជាព្រះរាជបុត្រប្រសារបស់ព្រះមហាក្សត្រមុនីវង្ស និងជាបិតាសម្ដេចសីហនុ បានជួយឧបត្ថម្ភគាំទ្រកាសែតមួយនេះ ហើយទ្រង់កាន់តែបង្កើនភាពជិតស្និទ្ធជាមួយក្រុមសឺង ង៉ុកថាញ់, ប៉ាច ឈឿន និងស៊ឹម វ៉ា ថែមទៀតផង។

កាសែត "នគរវត្ត" ចេញផ្សាយមួយសប្ដាហ៍ម្ដង ហើយម្ដងៗបោះពុម្ពចំនួន ៥០០០ ច្បាប់។ ទន្ទឹមនឹងការធ្វើសកម្មភាពប្រឆាំងបារាំង សឺង ង៉ុកថាញ់ ក៏បានចាត់ទុកថា ប្រទេសជិតខាងដែលគ្រោះថ្នាក់បំផុតនោះ គឺប្រទេសថៃ មិនមែនជាប្រទេសវៀតណាម ទេ។

ទន្ទឹមនឹងការចេញផ្សាយកាសែត "នគរវត្ត" សឺង ង៉ុកថាញ់, ប៉ាច ឈឿន និងស៊ឹម វ៉ា ក៏ឆ្លៀតឱកាសទាក់ទងព្រះសង្ឃនៅតាមវត្តនានា ឲ្យជួយទេសនាបំផុសគំនិតជាតិនិយម និងបំផុសឲ្យមានការក្រោកឡើងប្រឆាំងនឹងពួកអាណានិគមបារាំង ទាំងនៅក្រុងភ្នំពេញ និងនៅតាមខេត្តនានាផងដែរ។

នៅក្នុងឆ្នាំ១៩៣៧ ថាច់ ឈឿន ដែលជាសកម្មជនប្រឆាំងនឹងពួកអាណានិគមបារាំងដ៏ប្លូរផ្ដាច់ម្នាក់ដែរនោះ បានរត់គេចខ្លួនពីក្រុងភ្នំពេញ ទៅរស់នៅទឹកដីកូសាំងស៊ីន មួយរយៈ ក៏បានវិលត្រឡប់មកកម្ពុជា វិញ ដោយសំងំលាក់ខ្លួនសាងផ្នួសនៅវត្តមួយ ក្នុងខេត្តតាកែវ ហើយពេលសិក្ខមកវិញនៅក្នុងឆ្នាំ១៩៣៩ ក៏បានក្លាយជាលេខាបក្សកុម្មុយនិស្ត

## របត់នយោបាយ

ឥណ្ឌូចិន ប្រចាំខេត្តស្វាយរៀង តែមិនឃើញមានធ្វើសកម្មភាពអ្វីគួរឲ្យកត់សម្គាល់ទេ ហើយគាត់ក៏មិនបានធ្វើទំនាក់ទំនងជាមួយនឹងក្រុមសឹង ង៉ុកថាញ់, ស៊ឹម វ៉ា និងប៉ាច ឈឿន ដែរ។

នៅក្នុងឆ្នាំ១៩៣៨ សឹង ង៉ុកថាញ់ បានបង្កើតអង្គការយុវជនមួយ ក្នុងគោលបំណង ធ្វើឲ្យយុវជនកម្ពុជា និងវៀតណាម មានទំនាក់ទំនងគ្នាជាភាតរភាព ។ ជាមួយគ្នានេះ មាន ខ្មែរនៅកូសាំងស៊ីន ម្នាក់ឈ្មោះឡាំ ផៃ ត្រូវជាប្អូនថ្លៃរបស់សឹង ង៉ុកថាញ់ ដែលធ្លាប់បានទៅ សិក្សានៅប្រទេសបារាំង អស់រយៈពេលជាច្រើនឆ្នាំដែរ ក៏បានចូលជាសមាជិកបក្សកុម្មុយ-និស្តឥណ្ឌូចិន នៅដើមទសវត្សរ៍ឆ្នាំ១៩៤០ ដោយដូរឈ្មោះមកជា ចាន់ សម័យ ទៅវិញ។

---

# ៥
# បារាំងកាត់ខេត្តខ្មែរ ឲ្យថៃ




**ប្រជារាស្ត្រខ្មែរធ្វើបាតុកម្មទាមទារទឹកដីបាត់ដំបង សៀមរាប ស៊ីសុផុន ពីសៀម មកវិញ**

នៅដើមឆ្នាំ១៩៣៩ សង្គ្រាមលើកទី២ ចាប់ផ្ដើមផ្ទុះឡើង នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ១៩៣៩ កងទ័ពណាហ្ស៊ី ហ៊ីត្លែរ របស់អាល្លឺម៉ង់ ចាប់ផ្ដើមវាយលុកទៅលើប្រទេសប៉ូឡូញ ដោយយកលេសថា កងទ័ពប៉ូឡូញ ជាអ្នកឈ្លានពានមកលើព្រំដែនអាល្លឺម៉ង់ខាងលិច មុន។

ក្រោយវាយដណ្ដើមយកប្រទេសប៉ូឡូញ បានហើយ កងទ័ពណាហ្ស៊ី ហ៊ីត្លែរ បាន បន្តបើកការវាយលុកចូលទៅប្រទេសបារាំង, បែលហ្ស៊ិក, ហុល្លង់ និងវាយលុកទៅដល់ សហភាពសូវៀត នៅក្នុងឆ្នាំ១៩៤១។

ពេលនោះ សហរដ្ឋអាមេរិក សហភាពសូវៀត អង់គ្លេស និងបារាំង បានចងសម្ព័ន្ធ ភាពគ្នា ដើម្បីទប់ទល់កងទ័ពណាហ្ស៊ី ហ៊ីត្លែរ ដែលកំពុងចងសម្ព័ន្ធភាពជាមួយប្រទេស អ៊ីតាលី និងជប៉ុន ផងដែរ ។ មុនពេលកងទ័ពណាហ្ស៊ី ហ៊ីត្លែរ ចាប់ផ្ដើមវាយលុកចូល

ប្រទេសបារាំង នៅខែសីហា ឆ្នាំ១៩៣៩ រដ្ឋាភិបាលក្រុងប៉ារីស បានស្នើសុំឲ្យមានកតិកាសញ្ញាសន្តិភាព មិនឈ្លានពានគ្នាទៅវិញទៅមក រវាងប្រទេសកម្ពុជា ជាមួយប្រទេសសៀម ដែលបានដូរឈ្មោះជាប្រទេសថៃ វិញ នៅក្នុងឆ្នាំ១៩៣៩នោះដែរ។ ប៉ុន្តែភាគីថៃ បានដាក់លក្ខខណ្ឌឲ្យរដ្ឋាភិបាលក្រុងប៉ារីស ជាមុនថា ត្រូវសើរើកិច្ចព្រមព្រៀងបារាំង-សៀម ស្តីពីបញ្ហាព្រំដែនខ្មែរ ដែលបានព្រមព្រៀងគ្នា កាលពីឆ្នាំ១៩០៧ នោះជាមុនសិន។

តែរដ្ឋាភិបាលក្រុងប៉ារីស មិនទទួលយកលក្ខខណ្ឌនេះ ធ្វើឲ្យគម្រោងចុះហត្ថលេខាលើកតិកាសញ្ញាសន្តិភាព មិនឈ្លានពានគ្នាទៅវិញទៅមករវាងប្រទេសកម្ពុជា ជាមួយប្រទេសសៀមនោះ ក៏ត្រូវខកខានវិញ។

នៅពេលកងទ័ពណាហ្ស៊ី ហ៊ីត្លែរ និងសម្ព័ន្ធមិត្តមិនទាន់ទទួលជ័យជម្នះនៅអឺរ៉ុបពិសេសមិនទាន់វាយបានប្រទេសបារាំង នៅឡើយ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៤០ រាជរដ្ឋាភិបាលថៃ សុខចិត្តចុះហត្ថលេខាលើកតិកាសញ្ញាសន្តិភាពជាមួយរដ្ឋាភិបាលក្រុងប៉ារីស ដោយគ្មានលក្ខខណ្ឌ ហើយបន្ទាប់មកទៀត ថៃ ក៏បានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពជាមួយអង់គ្លេស និងជប៉ុន ផងដែរ ដើម្បីបង្ហាញពីជំហរអព្យាក្រឹតរបស់ខ្លួនថាមិនចូលបក្សសម្ព័ន្ធណាមួយឡើយ។

ប៉ុន្តែក្រោយពេលដឹងថា កងទ័ពណាហ្ស៊ី ហ៊ីត្លែរ វាយដណ្តើមយកបានទីក្រុងប៉ារីសរបស់បារាំង នាយករដ្ឋមន្ត្រីបារាំង ប៉ូល រ៉េណូល ( Paul Raynauld ) សុំលាលែងពីតំណែង ហើយសេនាប្រមុខបារាំងឈ្មោះហ្វីលីព ប៉េតាំង( Phillipe Petain ) ត្រូវពួកណាហ្ស៊ី ហ៊ីត្លែរ លើកបន្តុបឲ្យឡើងដឹកនាំរដ្ឋាភិបាលបារាំងថ្មីមួយ នៅក្រុងវីស៊ី ( Vichi ) មក សេនាប្រមុខ វិបុលសង្គ្រាម នាយករដ្ឋមន្ត្រីថៃ បានប្រកាសថារដ្ឋាភិបាលថៃ នឹងមិនផ្តល់សច្ចាប័នលើកតិកាសញ្ញាសន្តិភាពរវាងសៀម និងបារាំង ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤០ នោះទេ ដរាបណាបារាំងមិនព្រមសើរើកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ១៩០៧ ពីបញ្ហាព្រំដែន ខ្មែរ-ថៃ ឡើង វិញ។

នៅដើមខែកញ្ញា ឆ្នាំ១៩៤០ រដ្ឋាភិបាលវិបុលសង្គ្រាម បានចេញផ្សាយសៀវភៅ

មួយ ភូតកុហកសាធារណមតិអន្តរជាតិថា ទឹកដីខ្មែរ និងឡាវ ដែលបារាំងកំពុងតែត្រួតត្រានោះ គឺជារបស់ថៃ ហើយថាជនជាតិខ្មែរ និងជនជាតិឡាវ គឺជាពូជសាសន៍តែមួយ គឺថៃហ្នឹងឯង។



នាយករដ្ឋមន្ត្រីថៃ ពិបុលសង្គ្រាម

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៤០ នាយករដ្ឋមន្ត្រីថៃ វិបុលសង្គ្រាម បានផ្ញើលិខិតជាផ្លូវការមួយទៅរដ្ឋាភិបាលក្រុងវីឈី (Vi-chi) របស់បារាំង ការទាមទារទឹកដីកម្ពុជា និងលាវ ដែលខ្លួនបានដណ្ដើមកាន់កាប់កាលពីមុនឆ្នាំ១៩០៤នោះ មកជារបស់ខ្លួនវិញ។ ប៉ុន្តែនៅថ្ងៃទី១៨ ខែកញ្ញា រដ្ឋាភិបាលក្រុងវីឈី (Vichi) បានច្រានចោលការទាមទារមិនសមហេតុផលនេះ។

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៤០ នាយករដ្ឋមន្ត្រីថៃ វិបុលសង្គ្រាម បានធ្វើការទាមទារម្តងទៀត។

តែរដ្ឋាភិបាលក្រុងវីឈី(Vichi) មិនទាន់បានឆ្លើយតបវិញផង ស្រាប់តែនៅថ្ងៃទី៣០ ខែកញ្ញា នាយករដ្ឋមន្ត្រីថៃរូបនេះ បានធ្វើការទាមទារជាថ្មីម្តងទៀត។

រហូតដល់ថ្ងៃទី១៤ ខែតុលា ទើបរដ្ឋាភិបាលក្រុងវីឈី (Vichi) ប្រកាសបដិសេធដាច់អហង្ការចំពោះការទាមទារដ៏គឃ្លើននោះ វិបុលសង្គ្រាម ក៏បានបញ្ជាឲ្យកងទ័ពថៃ ធ្វើសកម្មភាពវាយប្រហាររប៉េសរប៉សនៅតាមបណ្តោយព្រំដែនខ្មែរ និងឡាវ ដើម្បីបង្កជម្លោះ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤០ ប្រជារាស្ត្រខ្មែរនៅទីក្រុងភ្នំពេញ និងនៅទីរួមខេត្តបាត់ដំបង នាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងការទាមទារយកទឹកដីខ្មែរទៅវិញនោះយ៉ាងគគ្រឹកគគ្រេង។

ចាប់ពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៤០មក ដោយស៊ូទ្រាំអត់ធ្មត់នឹងការបង្កជម្លោះតាម

## របត់នយោបាយ

ព្រំដែនរបស់ថៃ មិនបាន កងទ័ពបារាំង និងខ្មែរ ក៏បានចាប់ផ្តើមវាយបកទៅលើកងទ័ពថៃវិញ ដោយក្នុងនោះមាននាយទាហានខ្មែរសំខាន់ៗចូលរួមដែរ ដូចជា សូ ខាំខូយ, ដួង សំអុល, ឆាយ ឡាយ, អ៊ុម កង និង ហ៊ឹម សេស ជាដើម ។ ពេលនោះ កងកាំភ្លើងធំ និងយន្តហោះថៃ ក៏ចាប់ផ្តើមបាញ់ផ្លោង និងទម្លាក់គ្រាប់បែកទៅលើទីប្រជុំជននានា និងនៅតាមដងទន្លេមេគង្គ របស់ប្រទេសឡាវ ។

ចំណែកយន្តហោះរបស់បារាំង ដែលមានមូលដ្ឋាននៅឥណ្ឌូចិន សុទ្ធសឹងមានសភាពចាស់ៗទៅហើយនោះ ក៏បានហោះទៅទម្លាក់គ្រាប់បែកនៅពេលយប់ៗ ទៅលើទីក្រុងនានា របស់ថៃវិញដែរ ដូចជានៅណងខាយ, ឧប៊ុន, នគរភ្នំ, និងនគរាជ ជាដើម ។

លុះដល់ដើមខែមករា ឆ្នាំ១៩៤១ កងទ័ពថ្មើរជើងរបស់ថៃ ចាប់ផ្តើមបើកការវាយលុកមកលើតំបន់ប៉ោយប៉ែត សិរីសោភ័ណ និងសំរោង ហើយយន្តហោះថៃ ក៏ហោះមកទម្លាក់គ្រាប់បែកលើទីប្រជុំជនសិរីសោភ័ណ, មង្គលបុរី, ស្ទឹងត្រែង និងសៀមរាប បណ្តាលឲ្យបាត់បង់ជីវិតប្រជារាស្ត្រខ្មែរមួយចំនួន។

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៤១ កងទ័ពថ្មើរជើងបារាំង ក៏បានធ្វើការវាយបកទៅលើកងទ័ពថៃ ឲ្យដកថយវិញ ហើយការប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំបានកើតមាននៅយាងដង្គំ ក្នុងខេត្តសៀមរាប ។ តែពេលនោះ កងទ័ពបារាំង ត្រូវកងទ័ពថៃ វាយឲ្យដកថយមកនៅត្រឹមសិរីសោភ័ណ វិញ។

ប៉ុន្តែនៅល្ងាចថ្ងៃទី១៦ ខែមករា ដដែលនោះដែរ នៅសមរភូមិនៅឈូងសមុទ្រថៃក្បែរកោះឆាង កងនាវាចម្បាំងបារាំង និងកងនាវាចម្បាំងថៃ ទាំងហ្វូងៗបានបើកការប្រយុទ្ធគ្នាកក្រើកសមុទ្រ ។ គ្រាន់តែរយៈពេលប្រមាណ២ម៉ោងប៉ុណ្ណោះ កងនាវាបារាំងបានបាញ់ឲ្យនាវាចម្បាំងថៃលិច និងប្រើការលែងកើតអស់ប្រហែល៤០ភាគរយ ខណៈកងនាវាចម្បាំងបារាំង ពុំត្រូវបានបាញ់លិចនៅក្នុងសមុទ្រមួយគ្រឿងនោះ ធ្វើឲ្យកងទ័ពថៃ ត្រូវទទួលបរាជ័យយ៉ាងអាម៉ាស់ ក្នុងការធ្វើសង្គ្រាមឈ្លានពានដណ្តើមទឹកដីរបស់ប្រទេសខ្មែរ និងឡាវ។

ពេលនោះ ថៃ បានទទួលការគាំទ្រយ៉ាងពេញទំហឹងទាំងខាងការទូត និងយោធាពីរដ្ឋាភិបាលជប៉ុន ហើយជាមួយគ្នានោះ សហរដ្ឋអាមេរិក ក៏លម្អៀងទៅខាងថៃដែរ បើទោះបីបារាំងជាសម្ព័ន្ធមិត្តរបស់ខ្លួនក៏ដោយ។ ចំណែកកាសែតអាមេរិកជាច្រើនបានសរសេរគាំទ្រ និងលើកទឹកចិត្តចំពោះការឈ្លានពានប្លន់យកទឹកដីរបស់រាជរដ្ឋាភិបាលថៃ មកលើទឹកដីខ្មែរ និងឡាវ ទៅវិញ។ ឯប្រទេសអង់គ្លេស ឈរនៅជាអព្យាក្រឹត។



កងនាវាចម្បាំងបារាំង និងកងនាវាចម្បាំងថៃ វាយប្រយុទ្ធគ្នានៅក្បែរកោះឆាង

ក្រោយពីកងទ័ពជើងទឹកថៃ ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរមក នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៤១ រដ្ឋាភិបាលជប៉ុន នៅក្នុងក្រុងតូក្យូ បានដាក់ឱសានវាទបង្ខំឲ្យបារាំង ឈប់ធ្វើសង្គ្រាមជាមួយថៃ និងបង្ខំឲ្យយល់ព្រមទទួលយកជប៉ុន ធ្វើជាអាជ្ញាកណ្ដាលក្នុងការដោះស្រាយក្នុងការបញ្ចប់ជម្លោះនេះទៀតផង ។ ពេលនោះ បារាំង មិនទាន់បានឆ្លើយតបយ៉ាងណាផង ស្រាប់តែមានកងទ័ពនាវាចម្បាំងរបស់ជប៉ុន មួយកងធំ បានចូលទៅដល់មុខឆ្នេរសមុទ្រវង់តាវ ដែលបារាំងឲ្យឈ្មោះថា ឆ្នេរសមុទ្រកាប់សាំងហ្សាក់ (Cap-Saint-Jacques) នៅវៀតណាមខាងត្បូង ដើម្បីគំរាមបារាំង ទៅហើយ។ ដោយសារការគំរាមនេះ បារាំងក៏ត្រូវបង្ខំចិត្តឈប់ធ្វើសង្គ្រាមជាមួយថៃ ចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៤១ តទៅ ។

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៤១ រដ្ឋាភិបាលជប៉ុន បានរៀបចំឲ្យមានកិច្ចចរចាបារាំង-ថៃ នៅទីក្រុងតូក្យូ ក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ម៉ាតស៊ូយូកា ។ ក្នុងពេលនោះ ដោយមានការគាំទ្រពីរដ្ឋាភិបាលជប៉ុនផង ភាគីថៃ បានទាមទារឲ្យភាគីបារាំង ប្រគល់ទឹកដីខ្មែរ និងឡាវ ទៅឲ្យខ្លួនគ្រប់គ្រងដូចកាលសម័យមុនឆ្នាំ១៩០៧ វិញ។

តែភាគីបារាំង បានបដិសេធថា មិនអាចធ្វើបែបនេះបានទេ ប៉ុន្តែដោយសារមានការគាបសង្កត់ពីរាជរដ្ឋាភិបាលក្រុងតូក្យូ ទៅលើរដ្ឋាភិបាលក្រុងវីឈី (Vichi) ដែលនៅក្រោមការត្រួតត្រារបស់អាល្លឺម៉ង់នោះ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៤១ ភាគីបារាំង ក៏ព្រមប្រគល់ទឹកដីខេត្តបាត់ដំបងទាំងមូល ខេត្តសៀមរាបមួយភាគធំ (លើកលែងតែស្រុកពួក តំបន់អង្គរ ស្រុកសូទ្រនិគម និងស្រុកជីក្រែង) ខេត្តកំពង់ធំ ភាគខាងជើង (ស្រុកជាំក្សាន្ត និងស្រុកឆែប សព្វថ្ងៃស្ថិតនៅក្នុងខេត្តព្រះវិហារ) និងទឹកដីខេត្តស្ទឹងត្រែង ប៉ែកខាងលិចទន្លេមេគង្គទាំងអស់ ដែលសរុបទាំងអស់មានទំហំប្រមាណជា ៦០.០០០ គីឡូម៉ែត្រការ៉េ គឺស្មើនឹង១ភាគ៣ នៃផ្ទៃប្រទេសសព្វថ្ងៃ តាមការទាមទាររបស់ថៃ។ ទន្ទឹមគ្នានេះដែរ ប្រជា-រាស្ត្រខ្មែរប្រមាណកន្លះលាននាក់ ក៏ធ្លាក់ទៅក្រោមការគ្រប់គ្រងត្រួតត្រារបស់រាជរដ្ឋាភិបាល




**ផែនទីបង្ហាញពីសៀមដណ្តើមយកទឹកដីខ្មែរ និងឡាវ ក្នុងឆ្នាំ១៩៤១**

ថៃ ផងដែរ។

ចំណែកប្រទេសឡាវ ក៏ត្រូវបាត់បង់ទឹកដីប្រមាណជា១០០០០គីឡូម៉ែត្រការ៉េដែរ ពោលគឺទឹកដីប៉ែកខាងជើង និងខាងត្បូង ដែលនៅខាងលិចទន្លេមេគង្គទាំងមូល ត្រូវថៃដណ្ដើមយកអស់។

ក្រោយប្រទេសកម្ពុជា ត្រូវបាត់បង់ទឹកដី១ភាគ៣ថែមទៀតមកនោះ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៤១ រដ្ឋាភិបាលក្រុងតូក្យូ, រដ្ឋាភិបាលក្រុងវីឈី (Vichi) របស់បារាំង និងរដ្ឋាភិបាលថៃ បានជួបគ្នាចុះហត្ថលេខាលើកតិកាសញ្ញាសន្តិភាពមួយ ហើយពេលនោះដែរ តំណាងរដ្ឋាភិបាលបារាំង បានទទួលទឹកប្រាក់ចំនួន៦លានផ្ញាស្ត្រ៍ (Piastres = លុយឥណ្ឌូចិន) ពីរដ្ឋាភិបាលជប៉ុន និងថៃ ជាថ្នូរនឹងការយល់ព្រមចុះហត្ថលេខាលើកតិកាសញ្ញាសន្តិភាពនេះផងដែរ។

ប្រាក់ផ្ញាស្ត្រ៍ (Piastres)នេះ ត្រូវបានបារាំងផ្ដល់សិទ្ធិពិសេសទៅឱ្យធនាគារឥណ្ឌូចិន ដែលជាធនាគារពាណិជ្ជមួយរបស់បារាំង ដើម្បីបោះពុម្ពនៅក្នុងឆ្នាំ១៨៧៥ ដើម្បីចរាចរនៅតុងកឹង អណ្ណាម កូសាំងស៊ីន ឡាវ និងកម្ពុជា។

ក្រោយពីបាត់បង់ទឹកដីខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពង់ធំ មក ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស មានការឈឺចាប់ក្នុងព្រះទ័យហួសប្រមាណ។ ព្រះអង្គមិនយល់ទាល់តែសោះថា ហេតុអ្វីបានជាបារាំង ដែលវាយពួកឈ្លានពានថៃ ឲ្យបរាជ័យទៅហើយនោះ បែរជាទៅចុះហត្ថលេខាចុះចាញ់ប្រទេសថៃ នៅឯក្រុងតូក្យូ ធ្វើឲ្យបាត់បង់ទឹកដីដ៏ពិសិដ្ឋ មិនអាចកាត់ថ្លៃបានរបស់បុព្វបុរសព្រះអង្គដូច្នេះទៅវិញ?

ដោយសារតែបញ្ហាឈឺចាប់រឿងបាត់បង់ទឹកដីនេះ ព្រះអង្គបានយាងចេញពីទីក្រុងភ្នំពេញ ទៅគង់នៅឯព្រះរាជដំណាក់លើកំពូលភ្នំបូកគោ ក្នុងខេត្តកំពត សំងំកើតទុក្ខរីងរៃស្គាយស្រណោះរកទីបំផុតគ្មាន។

ទ្វារព្រះរាជដំណាក់ត្រូវបិទជិត ទោះបីជាមន្ត្រីជាន់ខ្ពស់បារាំងណាក៏ដោយ ក៏ព្រះអង្គមិនបើកទ្វារឲ្យចូលដែរ ។ ព្រះអង្គសោយក្រយាកាន់តែតិចទៅៗ មិនយូរប៉ុន្មានព្រះអង្គបាន

ធ្លាក់ព្រះកាយប្រឈួនកាន់តែធ្ងន់ធ្ងរទៅៗ ។

នៅពេលនោះដែរ នៅក្នុងសប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ១៩៤១ ព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត ជាបុត្រប្រសា, ម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរត្នន៍ សិរីវឌ្ឍនា ជាបុត្រីសំណព្វ, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជាបុត្រាបង្កើត និងយុវព្រះអង្គម្ចាស់សីហនុ ជាព្រះនត្តា (ចៅ) ដែលទៅសិក្សានៅវិទ្យាល័យស្ហាស៊ីរលូ ឡូបា (Chasse loup-Laubat) ទីក្រុងព្រៃនគរ តែត្រូវមកលេងមាតុប្រទេស ក្នុងឱកាសវិស្សមកាលក្នុងពិធីបុណ្យរំលឹកដល់ការចាប់បដិសន្ធិរបស់ព្រះយេស៊ូគ្រិស្តនោះ បាននាំគ្នាទៅសួរទុក្ខព្រះមហាក្សត្រមុនីវង្ស ជាមួយក្រុមព្រះញាតិវង្សានុវង្សមួយចំនួនទៀត នៅឯព្រះរាជដំណាក់នៅលើកំពូលភ្នំបូកគោ ។

បន្ទាប់ពីយាងតាមរថយន្តអស់រយៈពេលជាច្រើនម៉ោងមក ក្រុមព្រះញាតិវង្សទាំងអស់បានទៅដល់ព្រះរាជដំណាក់នៅលើកំពូលភ្នំបូកគោ ខណៈដែលព្រះមហាក្សត្រមុនីវង្សមានអាការៈកាន់តែធ្ងន់ធ្ងរទៅៗ និងអស់សង្ឃឹមទៅហើយ។

ប៉ុន្មានម៉ោងក្រោយមក ក្នុងថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៤១ ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ក៏បានសោយទិវង្គត គួរឲ្យសោកស្តាយបំផុត ។

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ជាបុត្រច្បង និងជារាជទាយាទ ដែលត្រូវឡើងស្នងរាជ្យបន្ត និងម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរត្នន៍ សិរីវឌ្ឍនា ជាបុត្រីសំណព្វ ជាអ្នកចាត់ចែងដឹកព្រះបរមសពត្រឡប់មកទីក្រុងភ្នំពេញវិញ ទាំងយប់។

ក្បួនដង្ហែបានចូលមកដល់រាជធានី ក្នុងសភាពស្ងាត់ជ្រងំ វេលាម៉ោង១ រំលងអធ្រាត្រ ដោយមិនមានប្រជារាស្ត្រសាមញ្ញណាបានដឹងថា ព្រះមហាក្សត្រខ្លួនសោយទិវង្គតនោះឡើយ។

រាជពិធីតម្កល់ព្រះបរមសព ត្រូវធ្វើឡើងរយៈពេល៣ខែ ដោយមានព្រះសង្ឃចំនួន ៦៤អង្គ គឺត្រូវនឹងព្រះជន្ម ៦៤ព្រះវស្សារបស់ព្រះអង្គ និមន្តមកសូត្រធម៌ ដើម្បីឧទ្ទិសកុសលដល់ព្រះវិញ្ញាណក្ខន្ធជារៀងរាល់ថ្ងៃ ។ ព្រះមេរុកម្ពស់ ៧ជាន់មានកំពូលស្រួច ដណ្តប់



**បុត្រាមុនីវង្ស និងព្រះបិតាមហាក្សត្រស៊ីសុវត្ថិ**

ទៅដោយក្បូរក្បាច់រចនាធ្វើពីឈើពិសេសម្យ៉ាង យកមកពីប្រទេសឥណ្ឌា ត្រូវបានសាងសង់ឡើង ដើម្បីជាព្រះរាជកិត្តិយសដល់ព្រះបរមសព។

ព្រះមហាក្សត្រ មុនីវង្ស ប្រសូតនៅទី២៧ ខែធ្នូ ឆ្នាំ១៨៧៥ នៅរាជធានីភ្នំពេញ ព្រះបិតាព្រះនាមស៊ីសុវត្ថិ ។ ក្រោយពេលព្រះមហាក្សត្រនរោត្តម ជាជេដ្ឋា (បង) សោយទិវង្គតក្នុងខែមេសា ឆ្នាំ១៩០៤ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជាអនុជ (ប្អូន) បានឡើងគ្រងរាជ្យបន្ត ។

ព្រះមាតាព្រះអង្គ ព្រះនាមអ្នកម្នាងវ៉ាន់ ជាត្រកូលប្រជារាស្ត្រ ។ ក្រោយពីបានឡើងជាមហេសីរបស់ព្រះមហាក្សត្រស៊ីសុវត្ថិ មានព្រះគោរម្យងារជាព្រះវររាជជិនី។

ក្នុងចំណោមបុត្រាបុត្រីរបស់ព្រះមហាក្សត្រស៊ីសុវត្ថិ ជាច្រើន ព្រះស៊ីសុវត្ថិ មុនីវង្ស ជាបុត្រាទី៦ និងជាបុត្រាទី២ ក្នុងចំណោមបុត្រាទាំងអស់។ កាលនៅជាយុវវ័យ ព្រះបាទស៊ីសុវត្ថិ មុនីវង្ស បានទៅសិក្សានៅសាលាកងទ័ពសាំង ម៉េហ្សង់ (Saint Maixent) ប្រទេសបារាំង ។ ក្រោយបញ្ចប់ការសិក្សានៅទីនោះរយៈពេល២ឆ្នាំ ព្រះអង្គបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ត្រី (ស័ក្តិ១) នៅក្នុងជួរកងទ័ពបារាំង ហើយត្រូវបញ្ជូនទៅនៅទីក្រុងប្រ៊ីវ (Brive) និងបន្ទាប់មកទៀតទៅនៅទីក្រុងប៉ារីស។

នៅក្នុងឆ្នាំ១៩០៩ បារាំង បញ្ជូនព្រះអង្គឲ្យត្រឡប់មកមាតុប្រទេសវិញ និងបាន

ឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ទោ (ស័ក្តិ២) ។

នៅក្នុងឆ្នាំ១៩១០ ព្រះអង្គបានឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ឯក (ស័ក្តិ៣) ។ នៅក្នុងសង្គ្រាមលោកលើកទី១ ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨ ព្រះអង្គបានបំពេញកាតព្វកិច្ចយោធាយ៉ាងសកម្ម។ នៅឆ្នាំ១៩១៦ ជាមេបញ្ជាការកងវរសេនាតូច។

ក្នុងឆ្នាំ១៩២២ ដែលជាឆ្នាំកំណើតរបស់សម្តេចសីហនុ ជាព្រះនត្តា(ចៅ)ផងដែរ ព្រះអង្គទទួលបានគោរម្យងារជាសម្តេចព្រះកែវហ្វា ។

បន្ទាប់មកទៀត ព្រះអង្គបានទទួលតំណែងជាអគ្គលេខានៃក្រុមប្រឹក្សារដ្ឋមន្ត្រី និងជាអធិបតីនៃក្រុមសង្គហព្រះរាជវង្សានុវង្ស។

នៅក្នុងឆ្នាំ១៩២៧ ព្រះបិតាព្រះមហាក្សត្រស៊ីសុវត្ថិ សោយព្រះទិវង្គត ព្រះអង្គបានឡើងសោយរាជ្យបន្តនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩២៧ ក្នុងព្រះជន្ម៥២ព្រះវស្សា។

ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស មានព្រះអគ្គមហេសី និងព្រះជាយា ចំនួន១៦អង្គ រួមទាំងស្នំផ្សេងៗជិត៥០នាក់ទៀត ហើយនៅក្នុងចំណោមនោះ ស្ត្រីរបាំព្រះរាជទ្រព្យម្នាក់ឈ្មោះមាយ ត្រូវជាបងជីដូនមួយរបស់សាឡុត ស ក៏បានក្លាយជាព្រះជាយាព្រះអង្គដែរ។

នៅក្នុងឆ្នាំ១៩៣៤ អ្នកម្នាងមាយ បានយកប្អូនជីដូនមួយ ២នាក់ ម្នាក់ឈ្មោះ សាឡុត សួង និងម្នាក់ទៀតឈ្មោះសាឡុត ស (ប៉ុល ពត) ដែលកាលនោះ ទើបមានអាយុប្រហែល១០ឆ្នាំ មករស់នៅជាមួយ ។ ក្រោយមក បងប្រុសច្បងរបស់សាឡុត ស (ប៉ុល ពត) ឈ្មោះសាឡុត សួង បានចូលបម្រើការងារនៅក្នុងការិយាល័យពិធីការនៃព្រះបរមរាជវាំងដែរ ហើយមិនយូរប៉ុន្មាន យុនព្រះម្នាងបុប្ផានរលក្ខណ៍ មាយ ក៏បានយកបងស្រីរបស់សាឡុត ស ម្នាក់ទៀតឈ្មោះសាឡុត រឿង ឲ្យមកបម្រើការក្នុងក្រុមរបាំព្រះរាជទ្រព្យ រហូតបានក្លាយជាស្នំឯករបស់ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ទៀតផង។

ព្រះអគ្គមហេសី និងព្រះជាយាចំនួន១៦អង្គ និងព្រះរាជបុត្រា បុត្រីចំនួន២៤អង្គ (មិនគិតពីស្នំ) របស់ព្រះអង្គ រួមមាន៖

១/.សម្តេចព្រះអគ្គមហេសី នរោត្តម កាញ្ចនវិមាន នរលក្ខណ៍ទេវី មានបុត្រា បុត្រី

៤អង្គ គឺ៖

១.សម្តេចបុត្រីព្រះរៀម ស៊ីសុវត្ថិ ថាវេតរង្សី នារីវង្ស (៣០ មីនា ១៨៩៩ - ១៩៧៥)។

២.សម្តេចបុត្រី ស៊ីសុវត្ថិ កុសុមៈនារីរត្ន័ សិរីវឌ្ឍនា (០៩ មេសា ១៩០៤ - ២៨ មេសា ១៩៧៥) ជាមាតាព្រះនរោត្តម សីហនុ ។

៣.សម្តេចក្រុមព្រះ ស៊ីសុវត្ថិ មុនីរ៉េត (២៥ វិច្ឆិកា ១៩០៩ - ១៩៧៥?)។

៤.សម្តេចក្រុមហ្លួង ស៊ីសុវត្ថិ មុនីពង្ស (២៥ សីហា ១៩១២ - ៣១ សីហា ១៩៥៦)។

២/.ព្រះជាយា ស៊ីសុវត្ថិ ស៊ីសុជា មានបុត្រីមួយអង្គ គឺព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ សុជារង្សី (១៣ វិច្ឆិកា ១៩០៣–១៩៧៥)។

៣/. ព្រះជាយា យុនព្រះម្នាង គឹម ហូ មានបុត្រាមួយព្រះអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីជាតិ (៨ តុលា ១៩២២ – ១៩៧៥)។

៤/.ព្រះជាយា យុនព្រះម្នាងបុប្ផានរលក្ខណ៍ មាយ មានបុត្រាមួយអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ កុសរក្ស (២១ ឧសភា ១៩២៦-១៩៧៥)។

៥/. ព្រះជាយា យុនព្រះម្នាង បុប្ផានរលក្ខណ៍ បវរ សៅខន មានបុត្រាមួយព្រះអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សជារ៉ាក់ (៣១ កក្កដា ១៩២៨-១៩៧៥)។

៦/. ព្រះជាយា.យុនព្រះម្នាង លក្ខិណា បានយ៉េន មានបុត្រីមួយអង្គ គឺព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ វង្សមុនី (២២ កុម្ភៈ ១៩២៩-១៩៧៥)។

៧/. ព្រះជាយា យុនព្រះម្នាង បុប្ផានរលក្ខណ៍ យិន តាត មានបុត្រាបុត្រី៤អង្គ គឺ៖

១.ម្ចាស់ក្សត្រី ស៊ីសុវត្ថិ មុនីកេសន (០៦ មេសា ១៩២៩-១៩៤៦) ។ ក្រោយមកក្លាយជាមហេសីរបស់សម្តេចព្រះនរោត្តម សីហនុ ។

២.ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សាមានវរពង្ស (១៣ មេសា ១៩៣១ - ១៩៧៥)។

៣.ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វង្សជីវ័ន្ត (១៥ មិថុនា ១៩៣៣ - ១៩៧០)។

៤.ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស (០១ កុម្ភៈ ១៩៣៦ - ២៨ ធ្នូ ២០១៦)។ ក្រោយមក បានក្លាយជាកូនប្រសារបស់សម្តេចព្រះនរោត្តម សីហនុ (ស្វាមីបុត្រីនរោត្តម បុប្ផាទេវី)។

៨/. ព្រះជាយា យុនព្រះម្នាង កេសរ មាលី ឯក ណាត មានបុត្រាបុត្រី២អង្គ គឺ៖

១.ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ពង្សានមុនី (២៦ មិថុនា ១៩២៩ - ១៩៧៤)។ ក្រោយមក ក្លាយជាមហេសីរបស់សម្តេចព្រះនរោត្តម សីហនុ។

២.ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីលក្ខិណា (១១ មិថុនា ១៩៣១ -១៩៧១)។

៩/. ព្រះជាយា យុនព្រះម្នាង នារីកេសរ យឹង ត្រយ៉ង់ មានបុត្រាបុត្រី២អង្គ គឺ៖

១. ម្ចាស់ក្សត្រី ស៊ីសុវត្ថិ រិន្ទ្រមុនី (៨ មករា ១៩៣០ -១៩៨៤ )។

២.ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីជីវ័ន្ត (២៩ តុលា ១៩៣២ – ១៩៧៥)។

១០/. យុនព្រះម្នាង នារិន្ទ្រកេតសរ អុល មានបុត្រីមួយអង្គ គឺម្ចាស់ក្សត្រី ស៊ីសុវត្ថិ រត្នន៍មុនី (២ មករា ១៩៣១–១៩៧៥)។

១១/. ព្រះជាយា អ្នកម្នាង បវរមាលី ពាង មានបុត្រីមួយព្រះអង្គ គឺម្ចាស់ក្សត្រី ស៊ីសុវត្ថិ សាម៉ានរក្ស (៩ ឧសភា ១៩៣០ – ១៩៧៥)។

១២/. ព្រះជាយា អ្នកម្នាង នារីបុប្ផា ភាព មានបុត្រីមួយអង្គ គឺម្ចាស់ក្សត្រី ស៊ីសុវត្ថិ សុភាពនារី (៣ តុលា ១៩៣១ – ១៩៧៥)។

១៣/. ព្រះជាយា អ្នកម្នាង កានីន មានបុត្រីមួយអង្គ គឺម្ចាស់ក្សត្រី ស៊ីសុវត្ថិ ភួងមុនី (១៦ មេសា ១៩៣២ – ១៩៧៥)។

១៤/. ព្រះជាយា អ្នកម្នាង ឆវីកេសរ សាមូ មានបុត្រីមួយអង្គ គឺម្ចាស់ក្សត្រី ស៊ីសុវត្ថិ លោមាកេសរ (៣ តុលា ១៩៣២ – ២០០៦)។

១៥/. ព្រះជាយា អ្នកម្នាង ម៉ម ឌួងមុនីរក្ស អុស មានបុត្រាមួយអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឌួងជីវិន (២១ ឧសភា ១៩៣៣-១៩៧៥) ។

១៦/. ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ នារីពុំងា (១០ កញ្ញា ១៩៣៥-....?) ។

# ៦
# ហេតុអ្វី បារាំង លើកយុវព្រះអង្គម្ចាស់ សីហនុ ឲ្យឡើងសោយរាជ្យ ?



**ព្រះមហាក្សត្រនរោត្តម សីហនុ  និងអគ្គទេសាភិបាលបារាំង**
(**រូបថត** **www.tandfonline.com**)

នៅវេលាម៉ោង១៩យប់ ថ្ងៃអង្គារ ១១ កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ព.ស.២៤៦៥ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ សម្តេចសីហនុ ប្រសូតនៅរាជធានីភ្នំពេញ។

ព្រះបិតាព្រះនាមនរោត្តម សុរាម្រឹត ជាបុត្រារបស់ព្រះអង្គម្ចាស់នរោត្តម សុធារស។ ចំណែកព្រះមាតាព្រះនាម ម្ចាស់ក្សត្រីនរោត្តម ផះង៉ាង៉ាម ។ ព្រះអង្គម្ចាស់នរោត្តម សុធារស ជាព្រះស្វាមី និងម្ចាស់ក្សត្រីនរោត្តម ផះង៉ាង៉ាម ជាមហេសី គឺជាបុត្រា និងជាបុត្រីបង្កើត របស់ព្រះមហាក្សត្រនរោត្តម តែមានមាតាទីទៃពីគ្នា ។

ចំណែកព្រះមាតាព្រះអង្គ ព្រះនាមម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរត្នន៍ សិរីវឌ្ឍនា ជាបុត្រីសំណព្វព្រះទ័យរបស់ព្រះមហាក្សត្រមុនីវង្ស ជាមួយនឹងម្ចាស់ក្សត្រីនរោត្តម នរលក្ខណ៍ទេវី

ដែលជាបុត្រីរបស់ព្រះអង្គម្ចាស់នរោត្តម ហាស្សកណ្ណ ហើយព្រះអង្គម្ចាស់ហាស្សកណ្ណនេះ ក៏ជាបុត្ររបស់ព្រះមហាក្សត្រនរោត្តម ដែរ ពោលគឺព្រះមាតា និងព្រះបិតារបស់សម្តេច សីហនុ សុទ្ធតែជាចៅរបស់ព្រះមហាក្សត្រនរោត្តម។

ព្រះអង្គម្ចាស់នរោត្តម សុធារស ជាអ្នកចេះដឹងភាសាបាលីជ្រៅជ្រះ បានប្រទាន ព្រះនាមសីហនុ នេះ ថ្វាយចំពោះព្រះនត្តា(ចៅ) របស់ទ្រង់ដោយផ្ទាល់ គឺក្នុងន័យ លើកតម្កើងព្រះអង្គឲ្យមានឫទ្ធីបារមីខ្លាំងពូកែ ប្រៀបដូចជារាជសីហ៍ ដែលជាស្តេចលើអស់ ពួកសត្វទាំងពួង។

ក្រោយពេលប្រសូតមក ដោយជឿតាមទំនាយរបស់ក្រុមហោរាសាស្ត្រប្រចាំព្រះរាជវាំង ដែលបានទស្សន៍ទាយថា ព្រះរាជកុមារសីហនុ ត្រូវប្រគល់ឲ្យរាជវង្សណាផ្សេងជាអ្នក ចិញ្ចឹមបីបាច់រក្សាសិន បើពុំនោះទេ ព្រះអង្គនឹងត្រូវសោយទិវង្គតទាំងវ័យក្មេងខ្ចីជាមិនខាន នោះ ព្រះមាតាព្រះបិតាបានប្រគល់ព្រះអង្គឲ្យអ្នកម្នាងឃុន ប៉ាត់ ដែលមានព្រះជន្ម៧៣ វស្សាទៅហើយ ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា។

អ្នកម្នាងឃុន ប៉ាត់ ជាត្រកូលអភិជន បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់ ហាស្សកណ្ណ ជាអយ្យិកោ របស់ម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរត្ន័ សិរីវឌ្ឍនា ហើយ ក្រោយព្រះមាតាព្រះនាងសោយទិវង្គត តាំងពីព្រះនាងនៅវ័យក្មេងមកនោះ គឺអ្នកម្នាងឃុន ប៉ាត់ នេះហើយ ជាអ្នកបីបាច់ថែរក្សាម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរត្ន័ សិរីវឌ្ឍនា បន្ត ទៀត។

លុះដល់ព្រះរាជកុមារសីហនុ មានព្រះជន្ម៧វស្សា អ្នកម្នាងឃុន ប៉ាត់ ក៏បានសុគត ក្នុងព្រះជន្មាយុ៨០ព្រះវស្សា ។

អស់ពីអ្នកម្នាងឃុន ប៉ាត់ ទៅ ព្រះមាតាបិតាបានប្រគល់បុត្រាសីហនុ ថ្វាយទៅម្ចាស់ ក្សត្រីព្រះនរោត្តម ផះង៉ាង៉ាម និងព្រះអង្គម្ចាស់នរោត្តម សុធារស ជាព្រះអយ្យិកោ ព្រះអយ្យិ កាខាងព្រះបិតា ជាអ្នកបីបាច់ថែរក្សាបន្តទៀត។

ពីឆ្នាំ១៩៣០មក គឺចាប់ពីមានព្រះជន្ម៨វស្សា ព្រះអង្គបានចូលសិក្សានៅសាលា

បឋមសិក្សាហ្វ្រង់ស្វ័រ បូដ្វាំង ( François Baudoin ) និងវិទ្យាល័យព្រះស៊ីសុវត្ថិ។

នៅក្នុងឆ្នាំ១៩៣៦ ពេលព្រះអង្គយាងចូលព្រះជន្ម១៤វស្សា ព្រះមាតាបិតាមានការព្រួយព្រះទ័យពីអនាគតរបស់បុត្រទោលអង្គនេះ ក៏បានបញ្ជូនបុត្រាឲ្យទៅបន្តការសិក្សានៅវិទ្យាល័យសាស្ស៊ីលូ ឡូបា ( chasse loup laubat ) នាទីក្រុងព្រៃនគរ ដោយអាជ្ញាធរបារាំង បានចាត់ឲ្យមានកងអាវុធហត្ថម្នាក់ជាអ្នកតាមការពារព្រះអង្គផងដែរ។



**អ្នកម្នាងយ៉ុន ប៉ាត់ និងព្រះរាជកុមារ នរោត្តម សីហនុ**

យុវក្សត្រនរោត្តម សីហនុ បានធ្វើការកត់សម្គាល់ថា វិទ្យាល័យសាស្ស៊ីលូ ឡូបា ( chasseloup laubat ) អស់លោកសាស្ត្រាចារ្យទាំងប្រុស ទាំងស្រី ដែលបង្រៀននៅទីនោះ សុទ្ធសឹងជាអ្នកមានសមត្ថភាព និងមានគុណសម្បត្តិ ហើយបំពេញតួនាទីក្នុងអាកប្បកិរិយា និងសីលធម៌ល្អ មិនដែលប្រព្រឹត្តអ្វីឲ្យខុសឆ្គងចំពោះសិស្សគ្រប់សញ្ជាតិរបស់ពួកគាត់ឡើយ។

នៅក្នុងវិទ្យាល័យសាស្ស៊ីលូ ឡូបា គ្មានការប្រកាន់ពូជសាសន៍បារាំង ខ្មែរ វៀតណាម ឡាវ នោះទេ។ សិស្សទាំងអស់ស្នាក់នៅជាមួយគ្នាក្នុងភាតរភាព និងយោគយល់គ្នាទៅវិញទៅមក។ ចំណែករឿងនយោបាយរបស់ប្រទេសជាតិនីមួយៗ គឺស្ថិតនៅក្រៅរបងវិទ្យាល័យ គ្មានពាក់ព័ន្ធដល់សិស្សទាំងអស់ដែលនៅទីនោះទេ។ ប៉ុន្តែក្រោយមក មានជនជាតិវៀតណាមមួយចំនួន ដែលជាអតីតសិស្សនៃវិទ្យាល័យបារាំងមួយនេះ បានក្លាយជាមេដឹកនាំចលនា

តស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង ផងដែរ។

សម័យនោះ ក្រៅពីវិទ្យាល័យសាស៊្រីលូ ឡូបា នៅក្រុងព្រៃនគរ បារាំង បានបង្កើតវិទ្យាល័យអាល់ប៊ែរត៍ សារ៉ូត ( Albert Sarraut ) មួយទៀត នៅក្នុងទីក្រុងហាណូយ វៀតណាមភាគខាងជើង សម្រាប់សិស្សជាកូនខ្មែរ វៀតណាម ឡាវ និងសម្រាប់កូនបារាំង ផងដែរ។

ក្នុងអំឡុងពេលមមាញឹក នៃការប្រារព្ធពិធីបុណ្យព្រះបរមសពព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ដ៏អធិកអធមនោះ ដំណឹងដ៏គួរឱ្យភ្ញាក់ផ្អើលមួយត្រូវបានលេចឮពាសពេញរាជធានីនោះ គឺរាជទាយាទដែលត្រូវឡើងសោយរាជ្យបន្តនោះ មិនមែនព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ទេ។

ផ្ទុយទៅវិញ គឺយុវព្រះអង្គម្ចាស់ជាសិស្សវិទ្យាល័យស្វាស៊្រីលូ ឡូបា ម្នាក់ ដែលមានព្រះជន្មត្រឹមតែ១៩វស្សាប៉ុណ្ណោះ ត្រូវបានក្រុមប្រឹក្សារាជបល្ល័ង្កជ្រើសតាំងឲ្យឡើងសោយរាជ្យបន្ត។ ព្រះមហាក្សត្រថ្មីដែលគេមិននឹកស្មានដល់នោះ គឺគ្មាននរណាក្រៅពីយុវព្រះអង្គម្ចាស់សីហនុ ជាព្រះនត្តា ( ចៅ ) របស់ព្រះបរមសពនោះឡើយ។

ការពិតទៅ ការជ្រើសរើសព្រះមហាក្សត្រថ្មីនេះ គឺធ្វើឡើងតាមការចង្អុលបង្ហាញរបស់អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ដែលមានអំណាចជាងក្រុមប្រឹក្សាព្រះរាជបល្ល័ង្កទៅទៀត ។

ពេលនោះដែរ កាសែត "នគរវត្ត" របស់សឺង ង៉ុកថាញ់ ជាក្រុមអ្នកជាតិនិយមប្រឆាំងនឹងបារាំង បានចុះផ្សាយថា រាជបល្ល័ង្ករបស់ប្រទេសកម្ពុជា មិនត្រូវស្ថិតនៅជាកម្មសិទ្ធិផ្តាច់មុខរបស់សៃរាជវង្សស៊ីសុវត្ថិ ដែលបារាំង ងាយស្រួលដឹកមុខតទៅទៀតទេ គឺត្រូវត្រឡប់មកខាងសៃនរោត្តម វិញហើយ។

ប៉ុន្តែបើទោះបីជាពុំមានការទាមទារ និងគាំទ្រពីសំណាក់ក្រុមជាតិនិយម សឺង ង៉ុកថាញ់, ស៊ឹម វ៉ា និងប៉ាច ឈឿន ក៏ដោយ ក៏ពួកបារាំងមើលឃើញយុវព្រះអង្គម្ចាស់សីហនុ តាំងពីមុនព្រះអយ្យិកោព្រះបាទមុនីវង្ស សោយទិវង្គតទៅទៀត ព្រោះព្រះអង្គម្ចាស់នរោត្តម សុធារស ជាព្រះអយ្យិកោ និងអ្នកម្នាងផះង៉ាង៉ាម ជាព្រះអយ្យិកា ក៏ដូចជាព្រះបិតានរោត្តម

សុរាម្រឹត និងព្រះមាតាម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា ដែរ គឺសុទ្ធតែជាមិត្តភក្តិដ៏ល្អរបស់មន្ត្រីជាន់ខ្ពស់បារាំង ។

ពិសេសនៅពេលយុវព្រះអង្គម្ចាស់សីហនុ ទៅសិក្សានៅវិទ្យាល័យសាស្ស៊ីលូ ឡូបា នៅទីក្រុងព្រៃនគរនោះ ភរិយារបស់ឧត្តមនាវី ហ្សង់ ដឺគូ ( Jean decoux ) អគ្គទេសាភិបាលបារាំង ប្រចាំឥណ្ឌូចិនទាំងមូល ដែលស្នាក់នៅនិវេសនដ្ឋានក្នុងទីក្រុងព្រៃនគរនោះ មានការចាប់អារម្មណ៍ និងស្រឡាញ់រាប់អានយុវព្រះអង្គម្ចាស់សីហនុ យ៉ាងខ្លាំង។ ពេលឃើញព្រះអង្គដំបូង ភរិយារបស់អគ្គទេសាភិបាលបារាំង រូបនេះ បានលាន់មាត់ថា គួរឲ្យស្រឡាញ់ណាស់ យុវជនតូចច្រឡឹងនេះ! ហើយអគ្គទេសាភិបាលជាស្វាមី ក៏បានយាងព្រះអង្គទៅសោយព្រះស្ងោយនៅនិវេសនដ្ឋានរបស់គាត់ផងដែរ ។

ជាមួយគ្នានោះ យុវព្រះអង្គម្ចាស់សីហនុ ក៏បានទទួលការអប់រំដ៏ល្អពីបារាំង ផងដែរ ។ ប៉ុន្តែមានមជ្ឈដ្ឋានខ្លះគិតថា មូលហេតុដែលបារាំង ឲ្យយុវព្រះអង្គម្ចាស់សីហនុ ឡើងសោយរាជ្យទាំងព្រះជន្មវ័យក្មេងដូចនេះ គឺដើម្បីងាយស្រួលក្នុងការឲ្យព្រះអង្គធ្វើអ្វីៗតាមបង្គាប់បញ្ជារបស់បារាំង តែប៉ុណ្ណោះ ។

ការពិតនៅ រាជទាយាទដែលត្រូវឡើងសោយរាជ្យបន្ត គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជាព្រះរាជបុត្រាច្បងរបស់ព្រះបរមសពមុនីវង្ស ឯណោះទេ។ ប៉ុន្តែ ដោយសារទ្រង់មុនីរ៉េត ចូលចិត្តប្រើពាក្យសម្ដីស្រែកគំហកតាមចរិតជាមេទ័ពសុទ្ធសាធ ជាហេតុធ្វើឲ្យឥស្សរជនបារាំង ភាគច្រើនមិនពេញចិត្ត ហើយបានឲ្យយោបល់ទៅថ្នាក់លើថា បើទ្រង់មុនីរ៉េត បានឡើងសោយរាជ្យជាស្ដេច គឺប្រាកដជាមិនងាយស្ដាប់បង្គាប់បារាំង ឡើយ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ប្រសូតនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩០៩ ក្នុងរាជធានីភ្នំពេញ។ មុនពេលចូលរៀនសាលាយោធា សាំងស៊ីា នៅប្រទេសបារាំង ទ្រង់បានទៅសិក្សានៅវិទ្យាស្ថានម៉ុងតាញ អារ៉ង់។ ឆ្នាំ១៩៣៤ ទ្រង់បានបង្កើតអង្គការកាយរិទ្ធិមួយ ឈ្មោះថា អង្គការខេមរៈកាយរិទ្ធិ ជាលើកដំបូង ដែលមានសមាជិកប្រមាណ១០០នាក់។

ចាប់ពីឆ្នាំ១៩៣៤ដល់១៩៣៧ ទ្រង់កាន់តំណែងជាលេខាធិការរបស់ព្រះមហាក្សត្រ



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត

មុនីវង្ស ជាព្រះបិតា។ ចាប់ពីឆ្នាំ១៩៣៧ ដល់ឆ្នាំ១៩៣៩ ទ្រង់បានចូលរួមក្នុងកិច្ចការសង្គមសុខាភិបាល និងកីឡា ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៣៩ ពេលសង្គ្រាមលោកលើកទី២ផ្ទុះឡើង ទ្រង់បានចូលបម្រើក្នុងជួរកងទ័ពបារាំង ម្តងទៀត ដោយមានឋានន្តរស័ក្តិជាអនុសេនីយ៍ទោ ( ស័ក្តិ២ ) និងបានចេញទៅជួយធ្វើសង្គ្រាមបារាំង ដើម្បីប្រយុទ្ធជាមួយកងទ័ពណាហ្ស៊ីអាល្លឺម៉ង់ ដែលឈ្លានពានប្រទេសបារាំង បានមួយរយៈខ្លីដែរ។

នៅក្រុងភ្នំពេញ ក៏ដូចជានៅក្រុងហាណូយ និងនៅក្រុងព្រៃនគរដែរ ក្នុងចំណោមពួកមន្ត្រីដែលនៅជុំវិញឧត្តមនាវីហ្សង់ ដឺគូ (Jean Decoux) អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ពួកគេបានយកចិត្តទុកដាក់មកលើព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត និងម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរ័ត្ន ជាងរាជវង្សផ្សេងៗទៀត។

ចំណែកឡេអុង អែមម៉ានុយអែល ធីបូដូ (Leon Emmanuel thibaudeau) ទេសាភិបាលជាន់ខ្ពស់បារាំង (Resident Superieur) ប្រចាំប្រទេសកម្ពុជា ជាមនុស្សមានសម្តីគំរោះគំរើយ តែចិត្តល្អនោះ គឺជាអ្នកប្រឆាំងដាច់ខាតចំពោះបេក្ខភាពឡើងគ្រងរាជសម្បត្តិរបស់ទ្រង់ស៊ីសុវត្ថិ មុនីរ៉េត ដោយចាត់ទុកទ្រង់ជាមនុស្សមានះ រឹងរូស និងធ្លាប់រិះគន់ក្រុមប្រឹក្សារដ្ឋមន្ត្រីថា គ្មានបានការអ្វី ចាំតែឆ្លើយ "បាទ" ជាមួយបារាំង ប៉ុណ្ណោះ។

ម្យ៉ាងទៀត ទេសាភិបាលជាន់ខ្ពស់ ធីបូដូ (Thibaudeau) មិនចូលចិត្តនឹងមហេសីរបស់ទ្រង់មុនីរ៉េត គឺអ្នកម្នាងប៉ុក វ៉ាន់ណេ មុនីរ៉េត ជាចៅរបស់ឧកញ៉ាចៅហ្វាវាំង ជួន ដែលបានធ្វើព្យុះ ធ្វើភ្លៀងនៅក្នុងព្រះបរមរាជវាំង អស់៣រជ្ជកាលព្រះមហាក្សត្រមកហើយ គឺ

រដ្ឋកាលព្រះនរោត្តម, រដ្ឋកាលព្រះស៊ីសុវត្ថិ និងរដ្ឋកាលព្រះមុនីវង្ស។

ទេសាភិបាលជាន់ខ្ពស់បារាំង រូបនេះ មានគម្រោងរួចហើយថា ថ្ងៃណាមួយ លោកនឹងដាក់ឲ្យឧកញ៉ាថៅហ្វាំងជួន ចូលនិវត្តន៍ ព្រោះគាត់ជាមនុស្សពុករលួយ និងមានមុខពីរ គឺក្បត់ព្រះមហាក្សត្រខ្លួនឯងផង និងក្បត់បារាំងផង។

អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺទេសាភិបាលជាន់ខ្ពស់បារាំង ធីបូដូ (Thibaudeau) បានសរសេរលិខិតស្នើសុំទៅអគ្គទេសាភិបាលប្រចាំឥណ្ឌូចិន ហ្សង់ ដឺគូ (Jean Decoux) ឲ្យដកបេក្ខភាពទ្រង់មុនីរ៉េត ចេញ ហើយដាក់បេក្ខភាពយុវព្រះអង្គម្ចាស់នរោត្តម សីហនុ ឲ្យឡើងគ្រងរាជ្យបន្តពីព្រះបរមសពមុនីវង្ស វិញ។

ទាក់ទងដល់ការជ្រើសរើសយុវព្រះអង្គម្ចាស់ សីហនុ ឲ្យឡើងគ្រងរាជ្យនេះដែរ ក៏ដោយសារសហការីភាគច្រើនរបស់ឧត្តមនាវីហ្សង់ ដឺគូ (Jean Decoux) ដែលភាគច្រើនជាមិត្តភក្តិរបស់ព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត ជាបិតា ដូចជា ទេសាភិបាល ហូលហ្វែល (Hoeffel), សាស្ត្រាចារ្យវ៉ាស្នឺរ(Vasner) ស៊ីសេរ៉ុង ( Ceiceron ) និងដេម៉ូស្ទីន (Demostine) ជាដើម សុទ្ធតែជាមិត្តភក្តិជិតស្និទ្ធបំផុតរបស់ទ្រង់សុរាម្រឹត ផងដែរ។

ក្រោយពេលទទួលដំណឹងថា ក្រុមប្រឹក្សារាជបល្ល័ង្ក បានសម្រេចជ្រើសតាំងបុត្រាសំណព្វរបស់ព្រះអង្គឲ្យឡើងសោយរាជ្យភ្លាម ម្ចាស់ក្សត្រីកុសុមៈនារីរ័ត្ន និងព្រះអង្គម្ចាស់នរោត្តម សុរាម្រឹត ជាមាតាបិតា មានព្រះទ័យត្រេកអររកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ ប៉ុន្តែយុវព្រះអង្គម្ចាស់សីហនុ បានបដិសេធថា មិនគួរណាឲ្យព្រះអង្គទទួលបន្ទុកដ៏សែនធ្ងន់បែបនេះទាល់តែសោះ ព្រោះព្រះអង្គនៅក្មេងខ្ចីណាស់។

ក្រោយពីក្រុមប្រឹក្សារាជបល្ល័ង្កជ្រើសតាំងឲ្យឡើងសោយរាជ្យមក ព្រះមហាក្សត្រសីហនុ ត្រូវយាងចាកចេញពីដំណាក់ប្រចាំគ្រួសារ ដែលនៅក្បែរវិមានឯករាជ្យ (សព្វថ្ងៃជាស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ) ទៅគង់នៅក្នុងប្រាសាទខេមរិន្ទក្នុងព្រះបរមរាជវាំងវិញ និងចាប់ផ្តើមយាងជាព្រះរាជាធិបតីក្នុងផ្លូវសាសនា និងក្នុងព្រះរាជពិធីផ្សេងៗទៀត ព្រមទាំងនៅក្នុងព្រះរាជពិធីបុណ្យឧទ្ទិសកុសលដល់ព្រះវិញ្ញាណក្ខន្ធ



ព្រះមហាក្សត្រនរោត្តម សីហនុ ពេលឡើងគ្រងរាជ្យ

ព្រះបរមសពមុនីវង្ស ជាព្រះអយ្យិកោផងដែរ។

ពេលឡើងគ្រងរាជ្យដំបូង ព្រះអង្គត្រូវរៀបចំព្រះកាយឲ្យបានសមរម្យតាមអាសនានុក្រម (លំដាប់ទីតាំងដែលត្រូវគង់) និងព្យាយាមផ្លាស់ប្តូរឥរិយាបថគ្រប់បែបយ៉ាង ដើម្បីឲ្យស័ក្តិសមជាព្រះមហាក្សត្រ។

ទន្ទឹមនឹងនេះ ព្រះអង្គត្រូវកែប្រែរបៀបរបបព្រះមហាក្សត្រពីមុនមកខ្លះៗ ដើម្បីចៀសវាងការសៅហ្មងនៅក្នុងជួរព្រះញាតិវង្ស ។ ព្រះអង្គមិនអនុញ្ញាតឲ្យព្រះអយ្យិកោ ព្រះអយ្យិកា ព្រះមាតាព្រះបិតា ព្រះមាតុច្ឆា ពិសេសព្រះបិតុលា (ឪពុកមា) ស៊ីសុវត្ថិ មុនីរ៉េត ដែលជារាជទាយាទខកចិត្តនោះ ក្រាបថ្វាយបង្គំព្រះអង្គឡើយ។

តែទោះជាមិនបានឡើងគ្រងរាជ្យដូចការគ្រោងទុកក៏ដោយ ក៏ទ្រង់ស៊ីសុវត្ថិ មុនីរ៉េត នៅតែរក្សាព្រះភ័ក្ត្រីករាយស្រស់ស្រាយធម្មតា ដោយទ្រង់តែងតែឱនព្រះកាយគោរពរាជវង្សានុវង្សទាំងអស់ ដូចមុនៗដដែល។

ពេលនោះ ទោះបីព្រះមហាក្សត្រសីហនុ មកគង់នៅក្នុងប្រាសាទខេមរិន្ទ ក្នុងព្រះបរមរាជវាំង ក៏ពិតមែន តែព្រះអង្គមិនទាន់ធ្វើព្រះរាជពិធីអភិសេកឡើងគ្រងរាជសម្បត្តិជាផ្លូវការនៅឡើយ ហើយមិនបានប៉ុន្មានសប្តាហ៍ក្រោយមក ព្រះអង្គបានលង់ស្នេហ៍ងុបងល់ទៅលើនាងការបាំព្រះរាជទ្រព្យម្នាក់ គឺអ្នកម្នាងផាត់ កាញ៉ុល ។

# ៧
# ទេសាភិបាលបារាំងថ្មី
# មកជួយស្តារព្រះកិត្តិនាមមហាក្សត្រសីហនុ



**ព្រះមហាក្សត្រនរោត្តម សីហនុ  និងអគ្គទេសាភិបាលបារាំង**
(រូបថត www.tandfonline.com)

ក្រោយពេលជ្រើសរើសសម្តេចព្រះនរោត្តម សីហនុ ឲ្យឡើងគ្រងរាជសម្បត្តិនោះ អគ្គទេសាភិបាលប្រចាំឥណ្ឌូចិន ឧត្តមនាវី ហ្សង់ ដឺគូ (Jean Decoux) បានចាត់ឲ្យមន្ត្រីបារាំង៣នាក់ ម្នាក់ឈ្មោះហ្កាស្តុង បារ៉ូត៍ និងម្នាក់ទៀតឈ្មោះ រីណេ ម៉ូរីហ្សុង មកធ្វើជាទីប្រឹក្សា និងជួយបង្ហាត់បង្ហាញក្នុងការតាក់តែងសុន្ទរកថា ព្រមទាំងលិខិតស្នាមផ្សេងៗ ហើយម្នាក់ទៀតឈ្មោះអាម៉េដេ ហ្វីលីព ឌី ប៊ិយសុន ជារាជង្គរក្ស។

ក្រោយមកទៀត ដើម្បីឲ្យព្រះអង្គបានយល់ដឹងពីបញ្ហាសេដ្ឋកិច្ចផងដែរនោះ ទីប្រឹក្សាហ្កាស្តុង បារ៉ូត៍ នេះ បានចាត់ឱ្យសឺន សាន មានសញ្ញាបត្រជាន់ខ្ពស់ខាងពាណិជ្ជកម្ម មកពីប្រទេសបារាំង និងពាណិជ្ជករដ៏ល្បីល្បាញម្នាក់ទៀតឈ្មោះ តាន់ ប៉ា ឲ្យមកជួយបង្ហាត់

បង្ហាញពីបញ្ហាសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារទៀតផង។

តែព្រះអង្គហាក់ដូចជាមិនសូវមាននិស្ស័យពីបញ្ហាសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារនេះប៉ុន្មានទេ ផ្ទុយទៅវិញ ព្រះអង្គបែរជាលង់ព្រះទ័យស្នេហាយ៉ាងងុបងល់ទៅលើស្រីរបាំព្រះរាជទ្រព្យប្រចាំនៅក្នុងព្រះបរមរាជវាំង ម្នាក់ឈ្មោះផាត់ កាញ៉ុល ទៅវិញ។

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៤១ ព្រះរាជពិធីអភិសេកសម្តេចព្រះនរោត្តម សីហនុ ឲ្យឡើងគ្រងរាជសម្បត្តិជាផ្លូវការ បានប្រព្រឹត្តឡើងយ៉ាងអធិកអធមបំផុត។

ថ្ងៃប្រារព្ធធ្វើព្រះរាជពិធីអភិសេកឡើងគ្រងរាជសម្បត្តិនេះ ត្រូវនឹងព្រះជន្មគម្រប់ ១៩ព្រះវស្សារបស់ព្រះមហាក្សត្រនរោត្តម សីហនុ គ្មានលើស ឬខ្វះមួយថ្ងៃឡើយ ពោលគឺព្រះអង្គទ្រង់ប្រសូតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ ហើយថ្ងៃប្រារព្ធធ្វើព្រះរាជពិធីអភិសេកឡើងសោយរាជសម្បត្តិនេះ ក៏បានប្រារព្ធធ្វើនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៤១ដែរ។

ព្រះរាជពិធីនេះ ធ្វើឡើងតាមការទស្សន៍ទាយគន់គូរបស់ក្រុមព្រះគ្រូហោរាសាស្ត្រប្រចាំព្រះបរមរាជវាំង តាមសំណើរបស់ព្រះមាតារបស់ព្រះអង្គផ្ទាល់តែម្តង។

នៅលើវេទិកាកិត្តិយស សុទ្ធសឹងជាមន្ត្រីជាន់ខ្ពស់បារាំង ពិសេសគឺវត្តមានដ៏ខ្ពង់ខ្ពស់របស់ឧត្តមនាវីហ្សង់ ដឺគូ ជាអគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិនទាំងមូល និងព្រះមហាក្សត្រឡាវ ស៊ីសាវ៉ាងវង្ស ផងដែរ។

ព្រះរាជពិធីនេះ គេសង្កេតឃើញមានក្បួនដង្ហែដ៏វែងឆ្លងកាត់មហាវិថីមួយចំនួនក្នុងរាជធានីភ្នំពេញ រួចត្រឡប់ចូលមកប្រាសាទទេវាវិនិច្ឆ័យ ដើម្បីឲ្យសម្តេចព្រះសង្ឃរាជទាំង ២គណៈ និងព្រះរាជគ្រូព្រាហ្មណ៍បុរោហិតបំពាក់មកុដរាជ្យ។

ក្រោយពីព្រះរាជពិធីរាជាភិសេកឡើងគ្រងរាជសម្បត្តិជាផ្លូវការរួចមក សម្តេចព្រះសុជាសេ ជាព្រះអយ្យិកោ បានបង្ខំឲ្យព្រះអង្គផ្តាច់ទំនាក់ទំនងស្នេហាជាមួយអ្នកម្នាងផាត់ កាញ៉ុលឲ្យបាន ដោយទ្រង់មានបំណងចង់ឲ្យព្រះមហាក្សត្រជាព្រះនត្តា (ចៅ) របស់ទ្រង់ ទៅរៀបអភិសេកជាមួយម្ចាស់ក្សត្រីយ៍ក្មេងមួយអង្គ និងមានសម្រស់ស្រស់ប្រិមប្រិយរបស់ប្រទេសថៃ ឯណោះវិញ ព្រោះកាលនៅយុវវ័យ ព្រះអង្គធ្លាប់ទៅសិក្សានៅប្រទេសថៃ ហើយទ្រង់ក៏

ជារាជវង្សមួយអង្គដែលនិយម ចូលចិត្តថៃ ជាងបារាំងផងដែរ។

ដោយឡែក សម្រាប់ម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា បានជំទាស់ជាដាច់ខាត មិនឲ្យព្រះមហាក្សត្រជាបុត្រារៀបអភិសេក (រៀបការ) ជាមួយស្រីណាម្នាក់ឡើយ ព្រោះ



ព្រះរាជពិធីរាជាភិសេកឡើងគ្រងរាជ្យរបស់
ព្រះមហាក្សត្រសីហនុ

ដើម្បីកុំឲ្យខុសនឹងការគន់គូរជើងលេខជោគជតារាសីរបស់ក្រុមព្រះគ្រូហោរាសាស្ត្រប្រចាំព្រះបរមរាជវាំង ដែលបានកំណត់ថា ពេលនេះព្រះមហាក្សត្រជាបុត្រារបស់ព្រះនាង មិនទាន់អាចយកមហេសីបានទេ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៤១ ធីបូដូ (Thibaudeau) ដែលមកទទួលភារកិច្ចជាទេសាភិបាលជាន់ខ្ពស់បារាំង ប្រចាំនៅប្រទេសកម្ពុជា តាំងពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៣៦មកនោះ ត្រូវផ្លាស់ចេញទៅបំពេញភារកិច្ចថ្មី ហើយហ្សង់ ដឺឡង់ (Jean de Lens) ត្រូវចូលមកជំនួស ។

តែទេសាភិបាលជាន់ខ្ពស់បារាំងថ្មី ឈ្មោះហ្សង់ ដឺឡង់ (Jean de Lens) នេះមិនបានយកចិត្តទុកដាក់ក្នុងការណែនាំអប់រំព្រះមហាក្សត្រសីហនុ កុំឲ្យប្រព្រឹត្តរឿងស្នេហាផ្តេសផ្តាសជាមួយអ្នកម្នាងផាត់ កាញ៉ុល នោះទេ ។ ដូច្នេះហើយ ទើបបានជាព្រះមហាក្សត្រវ័យក្មេងនេះ មិនត្រឹមតែមានព្រះទ័យស្នេហាផ្តេសផ្តាសជាមួយនាងការបាំព្រះរាជទ្រព្យឈ្មោះផាត់ កាញ៉ុល ម្នាក់ប៉ុណ្ណោះទេ គឺនៅក្នុងឆ្នាំ១៩៤២ នោះដែរ ព្រះអង្គក៏បានប្រព្រឹត្តរឿងស្នេហាផ្តេសផ្តាសជាមួយនឹងព្រះនាងស៊ីសុវត្ថិ ពង្សសានមុនី ដែលទើបមានវ័យ១៣ វស្សាកន្លះ ថែមមួយអង្គទៀត។

## របត់នយោបាយ

ព្រះនាងស៊ីសុវត្ថិ ពង្សសានមុនី ជាបុត្រីរបស់ព្រះបរមសពព្រះមុនីវង្ស ដែលជាព្រះអយ្យិកោរបស់ព្រះអង្គ ពោលគឺព្រះនាងស៊ីសុវត្ថិ ពង្សសានមុនី នេះ ត្រូវជាម្តាយមីងរបស់ព្រះអង្គតែម្តង ។

រូបសម្រស់ដ៏ស្រស់ល្វតល្វន់របស់ម្ចាស់ក្សត្រីក្មេងខ្ចីអង្គនេះ ព្រះអង្គបានទតឃើញនៅពេលព្រះមាតាព្រះនាង គឺឃុនព្រះម្នាង កេសរ មាលី ណាត ដែលជាមហេសីរបស់ព្រះបរមសពព្រះមុនីវង្ស ដែរនោះ បាននាំព្រះនាងមកបង្ហួតសម្រស់នៅមុខព្រះភ័ក្ត្រព្រះអង្គក្នុងព្រះបរមរាជវាំង ដោយយកលេសថា នាំព្រះនាងមកថ្វាយបង្គំសម្តែងការគួរសមចំពោះម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា ជាព្រះមាតារបស់ព្រះអង្គ និងជាអ្នកមើលខុសត្រូវលើបុត្រាបុត្រីរាប់សិបអង្គ របស់ព្រះបរមសពព្រះមុនីវង្ស ក្រោយពេលព្រះអង្គសោយទិវង្គតទៅនោះ។

ប៉ុន្តែទំនាក់ទំនងស្នេហារបស់ព្រះមហាក្សត្រសីហនុ ជាមួយម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ត្រូវបានពួកមន្ត្រីបារាំង និងពួកគហបតីខ្មែរជាច្រើនប្រឆាំងជំទាស់ ព្រោះព្រះនាងមានវ័យក្មេងខ្ចីពេក ហើយត្រូវជាប់សាច់ឈាមជាម្តាយមីងរបស់ព្រះអង្គថែមទៀតផង។ ពួកគេមិនសប្បាយចិត្តចំពោះព្រះមហាក្សត្រ ដែលមានរឿងស្នេហាបែបនេះជាដាច់ខាត។

មិនតែប៉ុណ្ណោះ ពួកមន្ត្រីបារាំងខ្លះបានទម្លាយរឿងរ៉ាវស្នេហាអាស្រូវនេះទៅប្រាប់ឧត្តមនាវី ហ្សង់ ដឺគូ (Jean Deeoux) អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន នៅទីក្រុងព្រៃនគរ ឲ្យបានដឹងផងដែរ។ ក្រោយពីបានដឹងរឿងរ៉ាវស្នេហាអាស្រូវនេះ ឧត្តមនាវីហ្សង់ ដឺគូ (Jean Deeoux ) មានការខឹងសម្បាយ៉ាងខ្លាំង ហើយបានសម្រេចប្តូរផ្លាស់ហ្សង់ ដឺ ឡង់ (Jean de lens) ដែលមកបំពេញតួនាទីជាទេសាភិបាលជាន់ខ្ពស់នៅកម្ពុជាកាលពីចុងឆ្នាំ ១៩៤១ នោះចេញ ដោយសារទេសាភិបាលជាន់ខ្ពស់ ហ្សង់ ដឺ ឡង់ នេះ មិនមានសមត្ថភាពក្នុងការណែនាំ អប់រំព្រះអង្គមហាក្សត្រសីហនុ បណ្តាលឲ្យព្រះអង្គប្រព្រឹត្តរឿងស្នេហាផ្តេសផ្តាសបែបនេះ។



**ព្រះមហាក្សត្រសីហនុ និងឧត្តមនាវីហ្សង់ ដឺគូ** ( **Jean Deeoux** )
**អគ្គទេសាភិបាលបារាំង ប្រចាំឥណ្ឌូចិន**

ចាប់ពីថ្ងៃទី២ ខែមីនា ឆ្នាំ១៩៤៣មក ឧត្តមនាវីហ្សង់ ដឺគូ ( Jean Deeoux ) បាន តែងតាំងមន្ត្រីថ្មីម្នាក់ទៀតឈ្មោះហ្សក អាម៉ង់ ឡេអុង ហ្គោដេ (George Armand Leon Gauthier) ឲ្យមកកាន់តំណែងជាទេសាភិបាលជាន់ខ្ពស់នៅប្រទេសកម្ពុជា ជំនួសវិញ ។

ក្រោយពេលមកកាន់តំណែង ជាទេសាភិបាលជាន់ខ្ពស់នៅកម្ពុជាភ្លាម ហ្គោដេ (Gauthier) បានធ្វើការស្តីបន្ទោសទៅលើព្រះមហាក្សត្រសីហនុ យ៉ាងចាស់ដៃ ពីបញ្ហា ស្នេហាផ្តេសផ្តាសជាមួយម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី នោះ ហើយព្រះបិតាព្រះមាតា របស់ព្រះអង្គ ក៏បានគាំទ្រការស្តីបន្ទោសរបស់ទេសាភិបាលជាន់ខ្ពស់នោះដែរ។

តែទោះបីទេសាភិបាលជាន់ខ្ពស់ និងព្រះមាតាបិតាស្តីបន្ទោសពីរឿងនេះយ៉ាងណា ក៏ព្រះមហាក្សត្រសីហនុ មិនត្រឹមតែមិនផ្តាច់ព្រះទ័យស្នេហាពីម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្ស សានមុនី នោះទេ បែរជាព្រះអង្គព្យាយាមអង្វរសុំរាជានុញ្ញាតពីព្រះមាតាបិតារៀបអភិសេក ជាមួយម្ចាស់ក្សត្រីពង្សសានមុនី ឲ្យពេញមុខតាមប្រពៃណីតែម្តង។

តែព្រះមាតាស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា បដិសេធ មិនព្រមអនុញ្ញាតឱ្យ

**របត់នយោបាយ**

ព្រះអង្គរៀបអភិសេកជាមួយម្ចាស់ក្សត្រីពង្សសានមុនី ជាដាច់ខាត។

ជាមួយគ្នានេះ ទេសាភិបាលជាន់ខ្ពស់ ហ្គោដេ ក៏បានប្រកាន់ជំហរដាច់ខាតថា ទោះបីនៅក្នុងកាលៈទេសៈបែបណាក៏ដោយ ក៏ប្រទេសបារាំង ប្រឆាំងដាច់ខាតចំពោះការប៉ុនប៉ងរៀបអភិសេករបៀបនេះដែរ។ ទោះបីមានការរារាំង និងគាបសង្កត់ពីសំណាក់លោកទេសាភិបាលជាន់ខ្ពស់ ហ្គោដេ ដែលទើបនឹងមកគ្រប់គ្រងប្រទេសកម្ពុជា ថ្មីៗ និងព្រះមាតាបិតាយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចធ្វើឲ្យព្រះអង្គកាត់ព្រះទ័យពីម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី បានដែរ ហើយសេចក្តីស្នេហារវាងព្រះអង្គ និងម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី នៅតែលួចបន្តក្រៅផ្លូវការទៀតដដែល។

ហ្គោដេ (Gauthier) ដែលទើបមកកាន់តំណែងជាទេសាភិបាលជាន់ខ្ពស់ថ្មីៗ នៅព្រះរាជាណាចក្រកម្ពុជា ជាមនុស្សមានធន្ទៈមោះមុតបំផុត ក្នុងការឃើតឃោងលើកតម្កើងព្រះមហាក្សត្រសីហនុ បានរៀបចំគម្រោងយុទ្ធសាស្ត្រ៣ចំណុចគឺៈ

យុទ្ធសាស្ត្រទី១ លោកបានរៀបចំឲ្យមានព្រះរាជដំណើររបស់ព្រះមហាក្សត្រសីហនុ តាមបណ្តាខេត្តមួយចំនួន និងនៅតំបន់ព្រៃភ្នំ ដូចជានៅភ្នំក្រវាញ ជាដើម រួចហើយឆ្លងកាត់តាមទឹកដីកូសាំងស៊ីន, អណ្ណាម ហេូតដល់តុងកឹង ព្រមទាំងឆ្លងចូលប្រទេសលាវ ពីខាងជើង មកខាងត្បូង គឺពីសៀងក្វាង, ហ្លួងប្រាបាង, វៀងច័ន្ទ និងមកដល់ប៉ាក់សេ ទើបត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដោយឆ្លងកាត់ខេត្តស្ទឹងត្រែង។

យុទ្ធសាស្ត្រទី២ លោកមានគម្រោងធ្វើរ៉ូម៉ាំងភាវូបនីយកម្មអក្សរសាស្ត្រខ្មែរ ពោលគឺឈប់ឲ្យប្រើអក្សរខ្មែរដែលមានតាំងពីដើមមកនោះ ត្រូវដូរមកប្រើជាអក្សររ៉ូម៉ាំង ដូចអក្សរវៀតណាម និងការផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ ខែចេត្រ ដែលធ្លាប់តែធ្វើនៅពាក់កណ្តាលខែមេសា ជារៀងរាល់ឆ្នាំនោះ ឲ្យមកធ្វើនៅថ្ងៃទី១ ខែមករា តាមឆ្នាំសាកលវិញ។

យុទ្ធសាស្ត្រទី៣ លោកមានគម្រោងរៀបចំអភិសេកព្រះមហាក្សត្រសីហនុ ជាមួយកូនស្រីគហបតីខ្មែរម្នាក់ ដែលមានការរៀនសូត្រចេះដឹងខ្ពង់ខ្ពស់ ដើម្បីឲ្យក្លាយជាព្រះមហេសី

ប្រកបដោយកិត្តិយសឧត្តុង្គឧត្តម ដូចព្រះចៅបៅ ដាយ ដែលបានរៀបអភិសេកជាមួយកូនស្រីគហបតីវៀតណាមម្នាក់ ដែលមានចំណេះដឹងខ្ពង់ខ្ពស់ និងមានរូបសម្រស់ដ៏ស្រស់ស្អាត ។

ក្នុងការអនុវត្តយុទ្ធសាស្ត្រទី១ ទេសាភិបាលជាន់ខ្ពស់ ហ្គោដេ (Gauthier) បានតាមដង្ហែព្រះមហាក្សត្រ នរោត្តម សីហនុ ជាប់ជានិច្ច ទាំងតាមរថយន្ត តាមកាណូត ដោយមានកងទ័ពបារាំងមួយក្រុមតូច ដឹកនាំដោយហ្គាស្តុង ប៉ារ៉ូត៍ និងបិយសុន ជារាជង្គរក្សផ្ទាល់របស់ព្រះអង្គ, ហ្គាហ្សា ដាំង ជានាយកផ្នែកព័ត៌មានរបស់ព្រះអង្គ និងលោកវេជ្ជបណ្ឌិតរីស្វ។

ព្រះអង្គបានចេញដំណើរពីខេត្តពោធិ៍សាត់ ឆ្លងកាត់ជួរភ្នំក្រវាញ កាត់តាមព្រៃភ្នំឆ្ពោះទៅដល់ខេត្តកោះកុង។ បន្ទាប់មកទៀត បានចូលដល់ទឹកដីកូសាំងស៊ីន ដែលប្រជា-រាស្ត្រខ្មែរនៅទីនោះនាំគ្នាមកចោមរោមឱបព្រះអង្គ ហាក់ដូចជាមិនចង់ឲ្យយាងទៅណាឆ្ងាយពីពួកគេឡើយ។

លុះយាងទៅដល់ក្រុងវ៉េ នៃទឹកដីអណ្ណាម ព្រះចៅបៅ ដាយ និងអគ្គមហេសីណាំផួង បានទទួលស្វាគមន៍ព្រះអង្គយ៉ាងកក់ក្តៅ អធិកអធមបំផុត និងរៀបចំពិធីលៀងសាយភោជន៍ យ៉ាងឱឡារិកមួយ ថ្វាយព្រះអង្គទៀតផង។

ក្រោយពីចាកចេញពីក្រុងវ៉េ ព្រះមហាក្សត្រសីហនុ បានយាងទៅដល់ទឹកដីតុងកឹង ព្រះអង្គគង់នៅលើរថយន្តបើកដំបូល ទស្សនាទីក្រុងហាណូយ។

នៅទីក្រុងហាណូយ នេះ ព្រះអង្គបានជួបអ្នកស្រី ហ្គោឌ្រី ជាសាស្ត្រាចារ្យដែលព្រះអង្គចាប់ចិត្តស្នេហាកាលនៅរៀនវិទ្យាល័យសាស្ស៊ីលូ ឡូបា (Chasseloup-Laubat) នៅទីក្រុងព្រៃនគរ មុនពេលឡើងសោយរាជ្យនោះ គឺចំពេលអ្នកស្រីជាមេម៉ាយលែងលះស្វាមីទៅហើយ ឯព្រះអង្គក៏នៅលីវដែរ។

ពេលនោះ ព្រះអង្គមានព្រះទ័យចង់សុំអ្នកស្រីរៀបការជាមួយដែរ តែព្រះអង្គក៏បណ្តោយឲ្យរឿងនោះកន្លងផុតទៅ ដើម្បីកុំឲ្យមានការហ្មងសៅដល់ប្រជារាស្ត្រខ្មែរ ពេលបានដឹងថា ព្រះមហាក្សត្រខ្លួនមានមហេសីជាស្រីបារាំង ហើយថែមទាំងជាស្រីមេម៉ាយលែងប្តីទៀតផងនោះ ពួកគេប្រាកដជាមានការអាក់អន់ចិត្តជាមិនខាន ។

## របត់នយោបាយ

បន្ទាប់ពីបញ្ចប់ព្រះរាជទស្សនកិច្ចនៅលើទឹកដីតុងកឹង រួចមក ព្រះមហាក្សត្រសីហនុ បានយាងទៅដល់ទីក្រុងហ្លួងព្រះបាង ប្រទេសឡាវ ។ ពេលនោះ ព្រះអង្គបានចូលសម្ដែងការគួរសមដល់ព្រះមហាក្សត្រឡាវ ស៊ីសាវ៉ាង វង្ស និងព្រះរាជបុត្រា ស៊ីសាវ៉ាងវឌ្ឍនា ជារាជទាយាទ ដែលបានយាងជាព្រះរាជកិត្តិយសក្នុងពិធីអភិសេកព្រះអង្គឡើងសោយរាជ្យជាផ្លូវការ នៅក្រុងភ្នំពេញ កាលពីចុងខែតុលា ឆ្នាំ១៩៤១នោះផងដែរ។

ព្រះមហាក្សត្រឡាវ ស៊ីសាវ៉ាង វង្ស ប្រសូតនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៨៨៥ នៅទីក្រុងហ្លួងប្រាបាង ។ ព្រះបិតាព្រះនាមហ្សាការិន និងព្រះមាតាព្រះនាមថងស៊ី។

ព្រះអង្គបានទៅសិក្សានៅវិទ្យាល័យសាស្ស៊ីលូ ឡូបា ទីក្រុងព្រៃនគរ និងនៅក្រុងបារីស ប្រទេសបារាំង។ ព្រះអង្គបានឡើងសោយរាជសម្បត្តិនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩០៤។ ព្រះអង្គមានមហេសីចំនួន១៥អង្គ ក្នុងនោះមានមហេសី២អង្គត្រូវជាបងប្អូនបង្កើតនឹងគ្នា (បិតាតែមួយ មាតាទីទៃ) និងមហេសីមួយអង្គទៀត ត្រូវជាក្មួយ ។ ព្រះអង្គមានបុត្រាបុត្រី ចំនួន៥០អង្គ។ ប៉ុន្តែបុត្រាបុត្រីចំនួន១៤អង្គ ត្រូវបាត់បង់ព្រះជន្មក្នុងគ្រោះថ្នាក់លិចនាវាទេសចរណ៍មួយនៅក្នុងទន្លេមេគង្គ។

នៅពេលកងទ័ពជប៉ុន ចូលមកដណ្ដើមបារាំង កាន់កាប់ឥណ្ឌូចិន ព្រះមហាក្សត្រស៊ីសាវ៉ាង វង្ស ត្រូវបានបាត់បង់រាជបល្ល័ង្ក ដោយសារតែព្រះអង្គនៅតែស្មោះត្រង់នឹងពួកអាណានិគមបារាំង ដោយព្រះអង្គបដិសេធមិនសហការជាមួយពួកអ្នកជាតិនិយមលាវ និងបានបដិសេធមិនទទួលស្គាល់ឯករាជ្យរបស់ប្រទេស ដែលប្រកាសឡើងដោយពួកឥស្សរៈឡាវ។

ប៉ុន្តែក្រោយពេលជប៉ុន ចុះចាញ់សង្គ្រាមលោកលើកទី២ ហើយកងទ័ពបារាំង ត្រឡប់មកត្រួតត្រាតំបន់ឥណ្ឌូចិនវិញ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាលើកទី២ នៅក្នុងឆ្នាំ១៩៤៦។ ព្រះមហាក្សត្រស៊ីសាវ៉ាង វង្ស សោយទិវង្គតនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៥៩ ក្នុងព្រះជន្ម៧៤ព្រះវស្សា។

ក្រោយពីព្រះមហាក្សត្រ ស៊ីសាវ៉ាង វង្ស សោយទិវង្គតទៅ ព្រះអង្គម្ចាស់ស៊ីសាវ៉ាង



**ព្រះមហាក្សត្រសីហនុ យាងទៅប្រទេសឡាវ**

វឌ្ឍនា ជាបុត្រា បានឡើងគ្រងរាជសម្បត្តិបន្ត។

ព្រះមហាក្សត្រស៊ីសាវ៉ាង វឌ្ឍនា ប្រសូតនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩០៤ នៅក្នុងព្រះបរមរាជវាំងហ្លួងប្រាបាង។

ពេលមានព្រះជន្ម១០វស្សា ព្រះបិតាស៊ីសាវ៉ាង វង្ស បានបញ្ជូនព្រះអង្គឲ្យទៅសិក្សានៅប្រទេសបារាំង។ បន្ទាប់មក ព្រះអង្គបានចូលសិក្សានៅវិទ្យាល័យមួយ ក្នុងទីក្រុងម៉ុងប៉េលលីយេ (Montpellier) រួចហើយបានបន្តការសិក្សានៅមហាវិទ្យាល័យ រហូតទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រនយោបាយ។

ព្រះអង្គបានរៀបអភិសេកជាមួយព្រះអង្គម្ចាស់ក្សត្រីខាំផយ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៣០។ ព្រះអង្គមានព្រះរាជបុត្រាបុត្រីចំនួន៥អង្គ។

នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៥ រាជបល្ល័ង្ករបស់ព្រះមហាក្សត្រស៊ីសាវ៉ាង វឌ្ឍនា ត្រូវដួលរលំ ដោយសារពួកកុម្មុយនិស្តបាថេតលាវ របស់ព្រះអង្គម្ចាស់សុផានុវង្ស ទទួលបានជ័យជម្នះ ហើយព្រះរាជាណាចក្រឡាវ បានក្លាយជាប្រទេសកុម្មុយនិស្ត ដែលមានឈ្មោះថា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រហូតដល់សព្វថ្ងៃនេះ។

# ៨
# ព្រះមហាក្សត្រសីហនុ
# មិនសព្វព្រះទ័យជាមួយកញ្ញាជួន ជឿម



ព្រះមហាក្សត្រសីហនុ



កញ្ញាជួន ជឿម

ចំពោះយុទ្ធសាស្ត្រទី៣ ទេសាភិបាលជាន់ខ្ពស់បារាំង ហ្គោជេ (Gauthier) មានគម្រោងរៀបចំអភិសេកព្រះមហាក្សត្រនរោត្តម សីហនុ ជាមួយកូនស្រីគហបតីខ្មែរម្នាក់ ដែលមានការរៀនសូត្រចេះដឹងខ្ពង់ខ្ពស់ ដើម្បីឲ្យក្លាយជាមហេសីប្រកបដោយកិត្តិយសដូច ព្រះចៅបៅ ដាយ និងម្ចាស់ក្សត្រី ណាំ ផ្វង នៅអណ្ណាមនោះដែរ។

ព្រះចៅបៅ ដាយ ឈ្មោះដើម ង្វៀនភុក វិញធុយ (Nguyen Phuc Vinh thuy ) ប្រសូតនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩១៣ នៅទីក្រុងវេ ។ ពេលមានព្រះជន្ម៩វស្សា ត្រូវបិតាបញ្ជូនឲ្យទៅរៀននៅប្រទេសបារាំង តាំងពីថ្នាក់បឋមសិក្សា ដល់ថ្នាក់វិទ្យាល័យ រហូតបានចូលរៀននៅវិទ្យាស្ថានសិក្សានយោបាយ នៅទីក្រុងប៉ារីស។

ក្រោយពេលព្រះបិតាព្រះនាមខាយ ឌីង (Khai Dinh) សោយទិវង្គត ព្រះអង្គបានឡើងសោយរាជសម្បត្តិបន្ត នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩២៦ (ក្នុងព្រះជន្ម១៣វស្សា) ដោយមានព្រះនាមថា ព្រះចៅបៅ ដាយ ។

ក្រោយឡើងសោយរាជ្យសម្បត្តិរួច ព្រះអង្គបានវិលត្រឡប់ទៅបន្តការសិក្សានៅប្រទេសបារាំង វិញ រហូតដល់ទទួលបានសញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រនយោបាយ ទើបត្រឡប់មកគ្រងរាជសម្បត្តិបន្តទៀត។



**ព្រះចៅបៅ ដាយ និងម្ចាស់ក្សត្រី ណាំ ភឿង**

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៣៤ ក្នុងព្រះជន្ម២១វស្សា ព្រះចៅបៅ ដាយ បានរៀបអភិសេកជាមួយកូនស្រីគហបតីម្នាក់ ដែលមានចំណេះដឹងជ្រៅជ្រះ និងរូបសម្បត្តិដ៏ស្រស់ស្អាត ឈ្មោះម៉ារី តេរ៉េស ង្វៀន ហ៊ុយជីឡាយ វ័យ២០ឆ្នាំ ។

ក្រោយពីបានរៀបអភិសេករួច កញ្ញាម៉ារី តេរ៉េស ង្វៀន ហ៊ុយជីឡាយ មានព្រះនាមថា ម្ចាស់ក្សត្រី ណាំ ភឿង វិញ។ ក្រោយមក ព្រះចៅបៅ ដាយ មានមហេសី ៣អង្គទៀត។

បន្ទាប់ពីបាត់បង់រាជបល្ល័ង្ក នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៤៥ ពេលកងទ័ពជប៉ុនចូលមកកាន់កាប់ឥណ្ឌូចិន ក្នុងសង្គ្រាមលោកលើកទី២ មក ទ្រង់បានភៀសព្រះកាយទៅគង់នៅទីក្រុងហុងកុង, ចិន និងបារាំង។ ទ្រង់បានត្រឡប់មកធ្វើជាប្រមុខរដ្ឋប្រទេសវៀតណាមខាងត្បូងវិញ ចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៤៥។

លុះដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៥ ត្រូវឧត្តមសេនីយ៍ង៉ោ ឌិនយៀម ធ្វើរដ្ឋប្រហារទម្លាក់ចេញពីអំណាច ទ្រង់ក៏បានភៀសព្រះកាយទៅគង់នៅប្រទេសបារាំង ជាថ្មី

ម្តងទៀត និងបានសោយទិវង្គតនៅក្រុងប៉ារីស ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧ ក្នុងព្រះជន្ម៨៤ វស្សា។

កូនស្រីគហបតីខ្មែរ មានការរៀនសូត្រចេះដឹងខ្ពង់ខ្ពស់ ដែលទេសាភិបាលជាន់ខ្ពស់ហ្គោជេ (Gauthier) សម្លឹងឃើញនោះ គឺកញ្ញាជួន ជឿម ជាចៅរបស់ឧកញ៉ាចៅហ្វាវាំងជួន ។ កញ្ញាជួន ជឿម មានឪពុកឈ្មោះជួន ហ៊ល និងមានម្តាយឈ្មោះប៉ុណ្ណ ចន្ទម៉ូលី ។ ប៉ុណ្ណ ចន្ទម៉ូលី នេះ ជាបងបង្កើតរបស់ប៉ុណ្ណ ចន្ទម៉ុល។

តែទោះបីកញ្ញាជួន ជឿម ជាកូនស្រីគហបតី និងមានការរៀនសូត្រចេះដឹងខ្ពង់ខ្ពស់យ៉ាងណា ក៏ព្រះមហាក្សត្រសីហនុ មិនសព្វព្រះទ័យនឹងរូបសម្បត្តិរបស់នាង ដើម្បីយកមកធ្វើជាអគ្គមហេសីរបស់ព្រះអង្គដែរ ។

តែក្រោយមក កញ្ញាជួន ជឿម បានរៀបការជាមួយឈាន វ៉ម ដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីអប់រំជាតិ ពីថ្ងៃទី២ ខែមករា ឆ្នាំ១៩៤៨ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៤៨ ។

ព្រះមហាក្សត្រសីហនុ ឈ្វេងយល់ថា ការមិនសព្វព្រះទ័យយកកញ្ញាជួន ជឿម មកធ្វើជាអគ្គមហេសីរបស់ព្រះអង្គនេះ គឺជាការប្រមាថដ៏ធ្ងន់ធ្ងរមួយរបស់ព្រះអង្គ ចំពោះកិត្តិយសក្រុមគ្រួសារត្រកូលជួន នេះ ក៏អាចថាបាន ព្រោះដោយសារបញ្ហានេះហើយ ទើបក្រោយមកមានក្មួយប្រុសអ្នកម្នាងប៉ុក វ៉ាណេ ឬរ៉ូហ្សេត ប៉ុក ម្នាក់ ឈ្មោះប៉ុក ដឹកុមារ ជាអ្នកការទូតដ៏ល្អម្នាក់ក្នុងសម័យសង្គមរាស្ត្រនិយម ដែលព្រះអង្គជាអ្នកដឹកនាំនោះ បានរត់ចូលព្រៃ ទៅតស៊ូជាមួយពួកខ្មែរក្រហម ដើម្បីប្រឆាំងនឹងព្រះអង្គ ហើយបងប្អូនប្រុសៗរបស់កញ្ញាជួន ជឿម ៣នាក់ទៀត គឺជួន ជឿន, ជួន មុម្ម និងជួន ប្រាសិទ្ធ ក៏បានចូលរួមជាមួយពួកមេដឹកនាំខ្មែរក្រហម ដើម្បីផ្តួលរំលំព្រះអង្គដែរ។ តែមានប្អូនប្រុសកញ្ញាជួន ជឿម ម្នាក់ ឈ្មោះជួន ជុំ មិនបានចូលរួមតស៊ូជាមួយពួកមេដឹកនាំខ្មែរក្រហមទេ។

តែរឿងនេះ ជួន មុម្ម បានឱ្យដឹងថា ទោះបីព្រះមហាក្សត្រីយានីស៊ីសុវត្ថិ កុសុមៈ ចង់ឱ្យព្រះមហាក្សត្រសីហនុ រៀបការជាមួយជួន ជឿម ជាបងស្រីគាត់យ៉ាងណាក៏ដោយ ក៏

គ្រួសារត្រកូលជួន មិនអាចទទួលបានដែរ ព្រោះត្រកូលជួន ចាំបណ្ដាំឧកញ៉ាចៅហ្វាជួន ដែលបានផ្ដាំទុកថា កុំឱ្យទុកដាក់កូនចៅជាមួយស្ដេច។



ព្រះមហាក្សត្រ មុនីវង្ស និងឧកញ៉ាចៅហ្វាវាំង ជួន

( រូបថត Colorise & Old Photos of Cambodia )

ឧកញ៉ាចៅហ្វាវាំង ជួន កើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ១៨៦៤ នៅខេត្តកំពង់ឆ្នាំង ។ នៅឆ្នាំ១៨៨៥ គាត់ត្រូវបានអ្នកស្រាវជ្រាវជនជាតិបារាំងម្នាក់ឈ្មោះអូហ្គុស្ត ប៉ាវី (AU-GUSTE PAVIE) បញ្ជូនឲ្យទៅរៀននៅប្រទេសបារាំង ។

ពេលត្រឡប់ចូលកម្ពុជាវិញ គាត់បានធ្វើជាអ្នកបកប្រែភាសា ឲ្យជនជាតិបារាំងម្នាក់នោះ។ ពីថ្ងៃទី២៤ ខែមីនា ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ ១៨៩៤ គាត់បានធ្វើដំណើរជាមួយអ្នកស្រាវជ្រាវជនជាតិបារាំង អូហ្គុស្ត ប៉ាវី ( AUGUSTE PAVIE) នោះ ទៅក្រុងបាងកក ប្រទេសថៃ រួចបន្តដំណើរទៅប្រទេសលាវ ប៉ែកខាងកើត និងខាងលិច ។

នៅក្នុងឆ្នាំ១៩០០ ទេសាភិបាលជាន់ខ្ពស់បារាំងប្រចាំប្រទេសកម្ពុជា ឈ្មោះប៊ូឡូស (Boulloche) បានចាត់តាំងគាត់ឲ្យធ្វើការជាមួយមហាក្សត្រនរោត្តម ហើយព្រះមហាក្សត្របានតែងតាំងគាត់ជារដ្ឋមន្ត្រីព្រះបរមរាជវាំង ហិរញ្ញវត្ថុ និងវិចិត្រសិល្បៈ ដែលកាលសម័យនោះហៅថា ឧកញ៉ាចៅហ្វាវាំង រហូតមក។

នៅក្នុងឆ្នាំ១៩០៦ គាត់បានដង្ហែមហាក្សត្រស៊ីសុវត្ថិ យាងទៅធ្វើទស្សនកិច្ចជា

ផ្លូវការនៅប្រទេសបារាំង។ គាត់បានបម្រើការងារជាមន្ត្រីជាន់ខ្ពស់ក្នុងរជ្ជកាលព្រះមហាក្សត្រខ្មែរបីជំនាន់ គឺតាំងពីរជ្ជកាលព្រះមហាក្សត្រ ព្រះបាទនរោត្តម ,ព្រះបាទស៊ីសុវត្ថិ និងព្រះបាទមុនីវង្ស។

ឧកញ៉ាចៅហ្វាវាំង ជួន បានទទួលអនិច្ចកម្ម នៅក្នុងខែកញ្ញា ១៩៤៦ ក្នុងជន្មាយុ ៨២ឆ្នាំ។ វង្សត្រកូលរបស់គាត់សម្បូរអ្នកចេះដឹង។ ចៅៗរបស់គាត់ ដូចជា ប៉ុក ដឹកុមារ, ជួន មុម្ម និងជួន ជឿន បានទៅសិក្សានៅវៀតណាមភាគខាងជើង និងទៅប្រទេសបារាំងមានសញ្ញាបត្រថ្នាក់បណ្ឌិត។

នៅពេលដែលបញ្ចប់ការសិក្សា វិលត្រឡប់ចូលមកកម្ពុជាវិញ អ្នកទាំងអស់នេះបានចូលរួមតស៊ូប្រឆាំងនឹងបារាំង ជាមួយសឺង ង៉ុកថាញ់ ជាអ្នកនយោបាយស្តាំនិយម។ លុះប្រហែល២០ឆ្នាំក្រោយមកទៀត ពួកគេបានងាកទៅរកនយោបាយឆ្វេងនិយមម្តងវិញ ដោយចូលរួមធ្វើការតស៊ូជាមួយពួកខ្មែរក្រហមប៉ុល ពត។

# ៩
# ព្រះមហាក្សត្រវ័យក្មេង ជាមួយអ្នកម្នាងកាញ៉ុល និងម្ចាស់ក្សត្រី ពង្សសានមុនី



**ព្រះមហាក្សត្រសីហនុ**

ទោះបីជាទេសាភិបាលជាន់ខ្ពស់បារាំង ហ្គោដេ (Gauthier) ព្យាយាមរារាំងយ៉ាងណា ក៏មិនអាចបំបែកស្នេហារបស់ព្រះមហាក្សត្រសីហនុ ជាមួយអ្នកម្នាងផាត់ កាញ៉ុល ជានាដការបាំព្រះរាជទ្រព្យ ដែលមានវ័យច្រើនជាងព្រះអង្គ២ឆ្នាំ (អ្នកម្នាងកាញ៉ុល កើតនៅក្នុងឆ្នាំ១៩២០) និងម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ជាបុត្រីព្រះបរមសពព្រះមុនីវង្ស ជាមួយអ្នកម្នាងកេសមាលី ណាត បានដែរ ។

តែយ៉ាងណា ព្រះមាតាស៊ីសុវត្ថិ កុសុមៈនារីរត្នន៍ សិរីវឌ្ឍនា សព្វព្រះទ័យស្រឡាញ់រាប់អាន និងការពារអ្នកម្នាងផាត់ កាញ៉ុល ជានិច្ច។

នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៤៣ អ្នកម្នាងផាត់ កាញ៉ុល ប្រសូតបានបុត្រីមួយព្រះអង្គ ព្រះនាមនរោត្តម បុប្ផាទេវី ។ លុះដល់វ័យសិក្សា បុត្រីបុប្ផាទេវី បានចូលសិក្សានៅសាលាបឋមសិក្សាសុធារស។ ទន្ទឹមនឹងនោះដែរ ព្រះនាង ក៏បានចាប់ផ្ដើមហាត់រាំរបាំព្រះរាជទ្រព្យ



**អ្នកម្នាងផាត់ កាញ៉ុល**
(**រូបថត** Colorise & Old Photos of Cambodia)

នៅក្នុងព្រះបរមរាជវាំង ដូចព្រះមាតាផងដែរ។

ក្រោយពីបញ្ចាប់ការសិក្សានៅសាលាបឋមសិក្សាសុជារស ព្រះនាងបានបន្តការសិក្សានៅអនុវិទ្យាល័យព្រះនរោត្តម ហើយចាប់ពីមានព្រះជន្ម១៥វស្សាមក ព្រះនាងបានក្លាយជាអ្នករាំរបាំព្រះរាជទ្រព្យដ៏ល្បីល្បាញបំផុត។

ព្រះនាងបុប្ផាទេវី បានរៀបអាពាហ៍ពិពាហ៍លើកទី១ ជាមួយព្រះអង្គម្ចាស់នរោត្តម នរិនរៈ ទេវង្ស(ប្រសូតនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៣៥) និងបានលែងលះគ្នាវិញ នៅក្នុងឆ្នាំ១៩៦០។ ព្រះអង្គម្ចាស់នរោត្តម នរិនរៈ ទេវង្ស សោយទិវង្គតក្នុងឆ្នាំ១៩៧០។

នៅក្នុងឆ្នាំ១៩៦០នោះដែរ ព្រះនាងបានរៀបអាពាហ៍ពិពាហ៍លើកទី២ ជាមួយរាជវង្សមួយអង្គទៀតព្រះនាមស៊ីសុវត្ថិ មុនីជីវ័ន្ត (ប្រសូតនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៣២) និងមានបុត្រី២អង្គ គឺទី១.ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកុសុម៉ា (ប្រសូតឆ្នាំ១៩៦០) និងទី២. ម្ចាស់ក្សត្រីស៊ីសុវត្ថិ កល្យាណទេវី (ប្រសូតនៅឆ្នាំ១៩៦១)។

ព្រះនាង និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីជីវ័ន្ត បានលែងលះគ្នានៅក្នុងឆ្នាំ១៩៦២។ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីជីវ័ន្ត បានសោយទិវង្គតនៅក្នុងឆ្នាំ១៩៧៥។

ក្រោយពីលែងលះគ្នាជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវ័ន្ត ព្រះនាងបានរៀបអាពាហ៍ពិពាហ៍លើកទី៣ ជាមួយជនជាតិបារាំងម្នាក់ឈ្មោះប្រុយណូ ហ្វ័ររ៉េណេទី (Bruno

Foreineti) នៅក្នុងឆ្នាំ១៩៦៣ ហើយបានបុត្រីមួយអង្គព្រះនាមនរោត្តម ច័ន្ទស៊ីតា ឬច័ន្ទស៊ីតា ហ្វ័រណេទី (Chansida Foreineti) ប្រសូតឆ្នាំ១៩៦៥។ ប្រ៉ុយណូ ហ្វ័រណេទី កើតនៅឆ្នាំ១៩៤២ និងបានទទួលមរណភាពក្នុងឆ្នាំ១៩៧២ នៅប្រទេសបារាំង។

ក្នុងខែកក្កដា ឆ្នាំ១៩៦៧ ព្រះនាងបានរៀបអាពាហ៍ពិពាហ៍ជាលើកទី៤ ជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្តមុនីរ័ក្ស ដែលត្រូវជាស្វាមីរបស់ម្ចាស់ក្សត្រីនរោត្តម បុទុមបុប្ផា និងមានបុត្រា២អង្គ គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្តណាឫទ្ធិ ប្រសូតនៅឆ្នាំ១៩៦៨ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ៉ាវុឌ្ឍ ប្រសូតឆ្នាំ១៩៧៣។

ក្រោយកងទ័ពវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិ វាយដណ្តើមបានទីក្រុងភ្នំពេញ ពីរបបខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យ នៅក្នុងឆ្នាំ១៩៨១ ព្រះនាងបានចូលរួមនៅក្នុងចលនាតស៊ូហ្វ៊ុនស៊ិនប៉ិច ជាមួយព្រះបិតា។

នៅឆ្នាំ១៩៩២ ព្រះនាងបានចាកចេញពីចលនាតស៊ូហ្វ៊ុនស៊ិនប៉ិច ទៅចូលរួមជាមួយរដ្ឋាភិបាលនៃរបបរដ្ឋកម្ពុជា និងមានតួនាទីជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងព័ត៌មាន។

ពីឆ្នាំ១៩៩៣ ដល់១៩៩៨ ជារដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ព្រះនាងបានទទួលគោរម្យងារជាសម្តេចព្រះរាជបុត្រី ព្រះរៀមនរោត្តម បុប្ផាទេវី ។ ក្រោយមក ព្រះនាងបានលែងលះជាមួយព្រះអង្គម្ចាស់ជីវ័ន្តមុនីរ័ក្ស ហើយបានយកស្វាមីទី៥ ឈ្មោះខែក វ៉ាន់ឌី ដែលបានជាប់ឆ្នោតជាតំណាងរាស្ត្រមណ្ឌលតាកែវ អាណត្តិទី១ និងអាណិត្តទី២។

នៅវេលាម៉ោង៥ល្ងាច ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ស្វាមីទី៥ ខែក វ៉ាន់ឌី បានទទួលមរណភាពនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ក្នុងជន្មាយុ៨៥ឆ្នាំ។

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១២:៣០នាទី សម្តេចរាជបុត្រីព្រះរៀមនរោត្តម បុប្ផាទេវី ដែលជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ បានសុគតដោយរោគាពាធ ក្នុងព្រះជន្មាយុ៧៧ព្រះវស្សា នៅមន្ទីរពេទ្យមួយ នៅព្រះរាជាណាចក្រថៃ។

# របត់នយោបាយ



**អ្នកម្នាងផាត់ ភាញ៉ុល សុគតនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៦៩**
(រូបថត Colorise & Old Photos of Cambodia)

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៤៣ ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ដែលអាចចាត់ទុកជាមហេសីទី២ របស់ព្រះមហាក្សត្រសីហនុ ក៏បានប្រសូតបុត្រាមួយអង្គ ព្រះនាម នរោត្តម យុវនាថ ។

ព្រះអង្គម្ចាស់នរោត្តម យុវនាថ បានបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងធ្លាប់បានយាងជាតំណាងដ៏ខ្ពង់ខ្ពស់នៃប្រទេសកម្ពុជា ចូលរួមក្នុងកម្មវិធីជួបជុំក្រុមកាយរិទ្ធិនៅក្នុងប្រទេសហ្វីលីពីន នាឆ្នាំ១៩៥៩ និងបានយាងដង្ហែព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម របស់ព្រះករុណាបិតាព្រះបរមរតនកោដ្ឋ ជាច្រើនប្រទេសផងដែរ ។

នៅក្នុងឆ្នាំ១៩៥៩ ទ្រង់បានរៀបអាពាហ៍ពិពាហ៍លើកទី១ ជាមួយអ្នកម្នាងម៉ៅ ប្រិប និងមានបុត្រ២អង្គ គឺទី១ ម្ចាស់ក្សត្រីនរោត្តម ឆវន្តរង្សី ប្រសូតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៦០ និងទី២ ព្រះអង្គម្ចាស់នរោត្តម យុវធុរិយ ប្រសូតនៅឆ្នាំ១៩៦២ ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦២ ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាលើកទី២ ជាមួយអ្នកម្នាងទៀ គឹម-យិន និងមានបុត្រ៤អង្គ គឺ៖

ទី១ ព្រះអង្គម្ចាស់នរោត្តម វង្ស៉វុឌ្ឍ ប្រសូតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៦៦ ។

ទី២ ព្រះអង្គម្ចាស់នរោត្តម វង្សរិទ្ធ កើតឆ្នាំ១៩៦៩។ ព្រះអង្គម្ចាស់នរោត្តម វង្សរិទ្ធ នេះ ត្រូវបានគេនឹកស្មានថាសុគតនៅក្នុងឆ្នាំ១៩៧៦ សម័យខ្មែរក្រហមទៅហើយ ។ តែក្រោយឆ្នាំ១៩៧៩ ទ្រង់បានរត់កៀសខ្លួនទៅព្រំដែនថៃ និងបានចេញទៅរស់នៅប្រទេសស៊ុយអែត រហូតដល់ឆ្នាំ២០១៣ ទើបវិលត្រឡប់មករស់នៅប្រទេសកម្ពុជា វិញ ។

ទី៣ ម្ចាស់ក្សត្រីនរោត្តម ភខិណា ប្រសូតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧០ នៅក្រុងភ្នំពេញ។  សព្វថ្ងៃ ម្ចាស់ក្សត្រីនរោត្តម ភខិណា កំពុងរស់នៅក្រៅប្រទេស ។

ទី៤ ម្ចាស់ក្សត្រីនរោត្តម យុវទេវី ប្រសូតនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៤ នៅក្រុងប៉េកាំង។

ពេលមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ព្រះអង្គម្ចាស់នរោត្តម យុវនាថ និងអ្នកម្នាងទៀ គឹមយិន កំពុងបំពេញទស្សនកិច្ចនៅប្រទេសសិង្ហបុរី ពុំអាចយាងនិវត្តន៍មកកាន់មាតុប្រទេសវិញបាន ត្រូវបង្ខំឲ្យព្រះអង្គកៀសព្រះកាយទៅគង់នៅប្រទេសចិន ជាមួយព្រះបិតា ។ លុះដល់ឆ្នាំ១៩៧៥ ទ្រង់សម្រេចមិនយាងនិវត្តន៍មកកាន់មាតុប្រទេសវិញជាមួយព្រះបិតាទេ គឺបានកៀសព្រះកាយទៅគង់នៅទីក្រុងហុងកុង បន្តទៀត។ រហូតដល់ឆ្នាំ១៩៨០ ទ្រង់បានកៀសព្រះកាយបន្តទៅរស់នៅក្នុងសហរដ្ឋអាមេរិក និងបានបំពេញការងារក្នុងក្រុមហ៊ុនមួយ ( US Surgical Corporation ) អស់រយៈពេលប្រមាណជាង១៤ ឆ្នាំ ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៣ ទ្រង់បានយាងនិវត្តន៍មកកាន់ប្រទេសកម្ពុជាវិញ ហើយត្រូវបានព្រះមហាក្សត្រសីហនុ ជាព្រះបិតា ប្រោសព្រះរាជទានព្រះរាជក្រឹត្យ តែងតាំងជាស្តេចក្រុមហ្លួង និងជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ឋានៈស្មើឧបនាយករដ្ឋមន្ត្រី ។ នៅខែសីហា ឆ្នាំ ២០០៤ ទ្រង់ត្រូវបានទទួលគោរម្យងារជាសម្តេចព្រះបរមរាមា ។

នៅរាត្រីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ សម្តេចព្រះបរមរាមា នរោត្តម យុវនាថ បានសុគតដោយព្រះជរាពាធ ក្នុងព្រះជន្មាយុ៧៨ព្រះវស្សា នៅសហរដ្ឋអាមេរិក។

## របត់នយោបាយ

នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៤៤ អ្នកម្នាងផាត់ កាញ៉ុល បានប្រសូតបុត្រាមួយអង្គទៀត ព្រះនាមនរោត្តម រណឫទ្ធិ។

នៅឆ្នាំ១៩៦៨ ទ្រង់បានទទួលសញ្ញាបត្របរិញ្ញាបត្រច្បាប់ និងវិទ្យាសាស្ត្រនយោបាយនៅប្រទេសបារាំង ។ នៅក្នុងឆ្នាំ១៩៦៨ នោះដែរ ទ្រង់បានរៀបអាពាហ៍ពិពាហ៍លើកទី១ ជាមួយអ្នកម្នាងអេង ម៉ារី (កើតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៨)។ ឆ្នាំ១៩៦៩ ទ្រង់បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ច្បាប់សាធារណៈ នៅប្រទេសបារាំង។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទ្រង់ត្រូវបានតុលាការសឹកនៃរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយសេនាប្រមុខលន់ នល់ កាត់ទោសនៅក្នុងខែកក្កដា ឆ្នាំ១៩៧១ ពីបទធ្វើវិទ្ធង្សនា។ តែក្រោយមក ត្រូវបានគេដោះលែងវិញ និងបានចាកចេញពីប្រទេស ទៅរស់នៅជាមួយព្រះបិតាសីហនុ នៅក្រុងប៉េកាំង ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៣។

នៅឆ្នាំ១៩៧៤ ទ្រង់បានទទួលសញ្ញាបត្របណ្ឌិតច្បាប់ នៅប្រទេសបារាំង និងនៅឆ្នាំ១៩៧៩ ទ្រង់បានទទួលសញ្ញាបត្រជាន់ខ្ពស់ ជំនាញដឹកជញ្ជូនតាមផ្លូវអាកាស ខណៈនោះ ទ្រង់ក៏ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រនយោបាយ នៅប្រទេសបារាំង ផងដែរ។

បន្ទាប់ពីបានបុត្រានរោត្តម រណឫទ្ធិ ប៉ុន្មានឆ្នាំមក អ្នកម្នាងផាត់ កាញ៉ុល និងព្រះមហាក្សត្រ សីហនុ បានលែងលះគ្នា ហើយអ្នកម្នាងបានទៅរៀបការជាមួយមន្ត្រីប៉ូលិសម្នាក់ឈ្មោះ ចាប ហួត និងមានកូន ៥នាក់ទៀត ក្នុងនោះកូនទី៣ ឈ្មោះ ចាប ញ៉ាលីវ៉ុធ ។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ចាប ញ៉ាលីវ៉ុធ បានជាប់ឆ្នោតជាតំណាងរាស្ត្រ។ ក្រោយមកទៀត ជាអភិបាលរងរាជធានីភ្នំពេញ និងបន្ទាប់មកជាអភិបាលខេត្តសៀមរាប ។

អ្នកម្នាងផាត់ កាញ៉ុល សុគតនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៦៩។ ពិធីបូជាសពរបស់អ្នកម្នាង បានប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ទី៦ ខែកុម្ភៈ ឆ្នាំ១៩៦៩ នៅទីលានសួនច្បារមុខវត្តបទុមវតី ដោយមានសម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ ជាអ្នកប្រទានភ្លើង ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៤ ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ប្រសូតបុត្រទី២

ព្រះនាមនរោត្តម រ័ក្សវរិង្ស។

ក្រោយរដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ព្រះអង្គម្ចាស់រ័ក្សវរិង្ស បានយាងចូលព្រៃដើម្បីចូលរួមតស៊ូជាមួយចលនាតស៊ូរណសិរ្សរួបរួមជាតិ ដើម្បីឯករាជ្យ អព្យាក្រឹតសន្តិភាព និងសហប្រតិបត្តិការ (FUNCINPEC) ដែលមានព្រះបិតាសីហនុ ជាប្រធាន ដើម្បីរួមចំណែកក្នុងការផ្តួលរំលំរបបសាធារណរដ្ឋរបស់លន់ នល់ ដែរ តែទ្រង់បានសុគតដោយជំងឺនៅក្នុងព្រៃ ក្នុងឆ្នាំ១៩៧៣។

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៤៥ ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ប្រសូតបុត្រទី៣ ព្រះនាមនរោត្តម ចក្រព័ង្ស។

ព្រះអង្គម្ចាស់ចក្រព័ង្ស បានយាងទៅបន្តការសិក្សានៅប្រទេសបារាំង និងបានទៅសិក្សានៅវិទ្យាស្ថានកងទ័ពជើងអាកាស នៅប្រទេសយូហ្គោស្លាវី ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៦៩ ទ្រង់បានចូលបម្រើការងារជាអាកាសយានិកនៅក្នុងកងទ័ពជើងអាកាសកម្ពុជា។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទ្រង់ត្រូវបានឃុំខ្លួនឲ្យនៅតែក្នុងផ្ទះ រហូតដល់ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ទើបមានឱកាសបានយាងចេញទៅទីក្រុងប៉េកាំង ប្រទេសចិន ជាមួយអតីតព្រះមហាក្សត្រីយានីស៊ីសុវត្ថិ កុសុមៈ ដែលមេដឹកនាំរបបសាធារណរដ្ឋខ្មែរ អនុញ្ញាតឲ្យចាកចេញទៅរស់នៅជាមួយសម្តេចសីហនុ នៅទីនោះ។

ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ ពេលរស់នៅជាមួយព្រះបិតានៅក្រុងប៉េកាំង ទ្រង់ចក្រព័ង្ស មានតួនាទីជាប្រធានពិធីការខុទ្ទការល័យរបស់សម្តេចសីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា។

ក្រោយជ័យជម្នះរបស់ពួកខ្មែរក្រហម ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទ្រង់បានសម្រេចព្រះទ័យមិនត្រឡប់មកមាតុប្រទេសតាមព្រះបិតាវិញទេ ទ្រង់បានទៅរស់នៅប្រទេសបារាំង។

រហូតដល់ចុងឆ្នាំ១៩៨០ ទ្រង់បានចូលរួមក្នុងចលនាតស៊ូសីហនុនិយម ដែលមានព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ជាអគ្គមេបញ្ជាការរងនៃកងទ័ព ។

## របត់នយោបាយ

មហេសីទី១ របស់ទ្រង់ចក្រព័ង្ស មានឈ្មោះអ្នកម្នាង ហ៊ុន សឿន កើតនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៤៣ ជាអ្នករាំរបាំព្រះរាជទ្រព្យ។ មានបុត្រ៥អង្គ៖

ទី១ ព្រះអង្គម្ចាស់នរោត្តម ពុទ្ធពង្ស កើតថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៦៦។

ទី២ ព្រះអង្គម្ចាស់នរោត្តម ម៉ារីធីវង្ស កើតថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៦៧។

ទី៣ ព្រះអង្គម្ចាស់ នរោត្តម ណារ៉ាវង្ស កើតថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧០។

ទី៤ ព្រះអង្គម្ចាស់នរោត្តម ណារិធីពង្ស កើតថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៧២។

ទី៥ ព្រះអង្គម្ចាស់នរោត្តម រ៉ា វីចក្រ កើតថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៤។

នៅថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ១៩៦៥ ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាលើកទី២ ជាមួយអ្នកម្នាង ជូឡុង កេតធី (កើតនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៥១) ជាកូនស្រីរបស់ឧត្តមសេនីយ៍ញឹក ជូឡុង។ អ្នកម្នាង មានបុត្រីមួយអង្គ ព្រះនាមនរោត្តម ណាន់ដាទេវី ។

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាលើកទី៣ ជាមួយអ្នកម្នាង ឌួង ឌីយ៉ាត (កើតនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៤៨) និងមានបុត្រី៣អង្គ គឺ៖

ទី១ ម្ចាស់ក្សត្រី នរោត្តម រីម៉ាណា កើតថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៦៨។

ទី២ ម្ចាស់ក្សត្រីនរោត្តម បុប្ផារី កើតថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧១។

ទី៣ ព្រះអង្គម្ចាស់នរោត្តម ឥទ្ធិពង្ស កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧២។

ទ្រង់នរោត្តម ចក្រព័ង្ស បានរៀបអាពាហ៍ពិពាហ៍លើកទី៤ នៅទីក្រុងប៉េកាំង ប្រទេសចិន ក្នុងឆ្នាំ១៩៧៤ ជាមួយអ្នកម្នាងឌួង យ៉ានី (កើតនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៥៣) និងមានបុត្រាមួយអង្គព្រះនាមនរោត្តម រិន្ត្រា កើតថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៥ នៅទីក្រុងប៉េកាំង។

នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ក្រោយពេលទ្រង់បានចូលរួមក្នុងចលនាតស៊ូសីហនុនិយម មិនបានប៉ុន្មាន ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាលើកទី៥ ជាមួយអ្នកម្នាង ឆាវ៉ាវ៉ាន់ ដួងច័ន្ទ ជាជនជាតិថៃ (កើតនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៦) និងមានបុត្រមួយអង្គព្រះនាមនរោត្តម ឆាវ៉ាចក្រ កើតនៅក្នុងឆ្នាំ១៩៨៥។

ក្រោយពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទ្រង់បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩២ ទ្រង់ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីអមទីស្តីការគណៈរដ្ឋមន្ត្រី នៃរបបរដ្ឋកម្ពុជា ។

ក្រោយការបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់ (UNTAC) នៅខែឧសភា ឆ្នាំ ១៩៩៣ គណបក្សប្រជាជនកម្ពុជា ចាញ់ឆ្នោត (គណបក្សប្រជាជនកម្ពុជា ទទួលបានអាសនៈនៅក្នុងរដ្ឋសភា ៥១អាសនៈ, គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន៥៨អាសនៈ) ទ្រង់ចក្រព័ង្ស និងឧត្តមសេនីយ៍ ស៊ិន សុង អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៃរបបរដ្ឋកម្ពុជា បានបង្កើតតំបន់អបគមន៍ នៅត្រើយខាងកើតទន្លេមេគង្គ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៥ ដោយសារទ្រង់ចក្រព័ង្ស ជាប់ពាក់ព័ន្ធក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារមិនបានសម្រេច ទ្រង់ត្រូវបាននិរទេសខ្លួនទៅរស់នៅប្រទេសម៉ាឡេស៊ី និងប្រទេសបារាំង ជាថ្មីម្តងទៀត។



ព្រះអង្គម្ចាស់នរោត្តម ចក្រពង្ស

នៅឆ្នាំ១៩៩៨ ទ្រង់ចក្រព័ង្ស ត្រូវបានទទួលការលើកលែងទោសពីព្រះមហា-ក្សត្រ សីហនុ ជាបិតា បានយាងមកមាតុប្រទេសវិញ ហើយបង្កើតក្រុមហ៊ុនដឹកជញ្ជូនតាមយន្តហោះមួយ ឈ្មោះរ៉ូយ៉ាល់ អ៊ែរវ៉េ (Royal Airway) ។

នៅឆ្នាំ២០០៣ ទ្រង់បានបង្កើតគណបក្សនរោត្តម ចក្រព័ង្ស ព្រលឹងខ្មែរ ដើម្បីចូលរួមការបោះឆ្នោតសភា អាណត្តិទី៣ ប៉ុន្តែមិនបានអាសនៈមួយទេ។

នៅក្នុងឆ្នាំ១៩៩៣ អ្នកម្នាងឆារ៉ា

## របត់នយោបាយ

រ៉ាន់ ដួងច័ន្ទ បានសម្រេចចិត្តលែងលះជាមួយទ្រង់ចក្រព័ង្ស ហើយបានទៅរស់នៅប្រទេសថៃវិញ។ ប៉ុន្តែប៉ុន្មានខែក្រោយមក អ្នកម្នាងធ្វើដំណើរវិលត្រឡប់មកទីក្រុងភ្នំពេញ វិញជាមួយបងស្រីសាច់ថ្លៃម្នាក់ ដើម្បីប្រកបរបរអាជីវកម្មមួយ។ ចៃដន្យក៏បានជួបនឹងទ្រង់ចក្សព័ង្ស ហើយទ្រង់បានសុំឲ្យអ្នកម្នាងទៅជួបបុត្រារបស់អ្នកម្នាងព្រះនាមនរោត្តម ឆារ៉ាចក្រ នោះបន្តិច។ លុះទៅជួបបុត្រាហើយ អ្នកម្នាងត្រូវទ្រង់ចក្រព័ង្ស ឃាត់ទុកឲ្យនៅក្នុងផ្ទះ ហើយបើអ្នកម្នាងចង់ចេញទៅណាម្តងៗ ត្រូវមានអ្នកតាមទៅជាមួយទៀតផង។

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៩៩ អ្នកម្នាងដួងច័ន្ទ ក៏បានធ្វើពាក្យបណ្តឹងទៅអង្គការសិទ្ធិមនុស្ស ស្តីពីបញ្ហាទ្រង់បង្ខាំងអ្នកម្នាងឱ្យនៅតែក្នុងផ្ទះនោះ។

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ ព្រះមហាក្សត្រសីហនុ ក៏បានផ្ញើព្រះរាជសារមួយទៅឲ្យទ្រង់ចក្រព័ង្ស ដើម្បីឲ្យដោះលែងអ្នកម្នាងដួងច័ន្ទ ឲ្យមានសេរីភាពវិញ។

ពេលនោះ ទ្រង់ចក្រព័ង្ស បានផ្ញើលិខិតទូលតបព្រះបិតាវិញថា ទ្រង់កំពុងតែស្វែងរកការលះលែងគ្នាជាមួយអ្នកម្នាងដួងច័ន្ទ តាមច្បាប់របស់កម្ពុជា។

ប៉ុន្តែនៅពេលទ្រង់ចក្រព័ង្ស យាងចេញទៅប្រទេសហ្វីលីពីន នៅចុងខែវិច្ឆិកា ឆ្នាំ ២០០៥ អ្នកម្នាងដួងច័ន្ទ ក៏មានឱកាសរត់ចេញពីភូមិគ្រឹះដែលអ្នកម្នាងចាត់ទុកថាជាកន្លែងឃុំឃាំងនោះ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៥ វិលត្រឡប់ទៅប្រទេសថៃវិញ ដើម្បីស្វែងរកសិទ្ធិជ្រកកោន ។

ពាក់ព័ន្ធករណីអ្នកម្នាងឆារ៉ាវ៉ាន់ ដួងច័ន្ទ ចោទប្រកាន់ថា ទ្រង់ចក្រព័ង្ស បានបង្ខាំងអ្នកម្នាងឲ្យនៅតែក្នុងផ្ទះនេះ ព្រះអង្គម្ចាស់នរោត្តម ឆារ៉ាចក្រ ដែលជាបុត្រា បានបដិសេធការចោទប្រកាន់របស់ព្រះមាតា ដោយទ្រង់បានបញ្ជាក់ថា កាលព្រះមាតាទ្រង់គង់នៅភ្នំពេញ ព្រះបិតាមិនមានបង្ខាំងខ្លួនទុកឲ្យនៅតែក្នុងផ្ទះនោះទេ។ មាតាចង់ទៅទីណាបានតាមចិត្ត គ្រាន់តែពេលទៅទីណាម្តងៗ មានអង្គរក្ស ឬអ្នកបម្រើតាមទៅជាមួយប៉ុណ្ណោះ។

ការពិតទៅ អ្នកម្នាងឆារ៉ាវ៉ាន់ ដួងច័ន្ទ មានបំណងចង់លែងលះទ្រង់ចក្រព័ង្ស តែទ្រង់មិនចង់លែងលះអ្នកម្នាងឡើយ ទើបបានជាទ្រង់ចក្រព័ង្ស ឲ្យអ្នកម្នាងគង់នៅតែក្នុង

ផ្ទះ តែបើដើរទៅណាមកណាមានអង្គរក្ស និងអ្នកបម្រើទៅជាមួយ បែរជាអ្នកម្នាងចោទប្រកាន់ថា ទ្រង់ចក្រព័ង្ស បានបង្ខាំងអ្នកម្នាងឲ្យនៅតែក្នុងផ្ទះទៅវិញ។

នៅក្នុងឆ្នាំ១៩៩៦ ទ្រង់ចក្រព័ង្ស បានរៀបអាពាហ៍ពិពាហ៍ជាលើកទី៦ ជាមួយអ្នកម្នាងម៉ូរី រ៉េម និងមានបុត្រ២អង្គ គឺ៖

ទី១ ម្ចាស់ក្សត្រីនរោត្តម ពង្សរាសុរិយា ប្រសូតក្នុងឆ្នាំ១៩៩៧។

ទី២ ព្រះអង្គម្ចាស់នរោត្តម ពង្សមុនីរ៉េត ប្រសូតក្នុងឆ្នាំ២០០០។

ក្រោយមកទៀត ព្រះអង្គម្ចាស់ចក្រព័ង្ស មានមហេសីទី៧ គឺអ្នកម្នាងកាចា នីផា។

# ១០
# ព្រះមហាក្សត្រសីហនុ និងមហេសីផ្សេងៗទៀត



ព្រះមហាក្សត្រសីហនុ

នៅក្នុងឆ្នាំ១៩៤៤ ខណៈកំពុងសព្វព្រះទ័យស្រឡាញ់ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី នោះដែរ ព្រះមហាក្សត្រសីហនុ ក៏បានចាប់ព្រះទ័យស្រឡាញ់ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ មួយអង្គទៀត។

ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ ប្រសូតនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩២៩ ជាបុត្រីរបស់ព្រះបរមសពព្រះមុនីវង្ស ជាមួយអ្នកម្នាងបុប្ផា នរលក្ខណ៍តាត (ឈ្មោះដើម ឃិន តាត)។ ដូច្នេះម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ ក៏ត្រូវជាម្ដាយមីងរបស់ព្រះមហាក្សត្រសីហនុ ដូចម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី ផងដែរ។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៤៦ ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ ដែលជារាជវង្ស





**គុណ្ណាម៉ូល ម៉ូនិក អ៊ីហ្សី**

ប្រកបដោយគុណធម៌មួយអង្គនោះ ប្រសូតបានបុត្រាមួយអង្គ ព្រះនាមនរោត្តម នរទីបោ ខ្លះហៅថា នរោត្តម នរ៉ាឌីប៉ូ ។

ប៉ុន្តែក្រោយពេលប្រសូតបុត្រាអង្គនេះ បានតែរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ ព្រះនាងក៏សុគតនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៤៦ គួរឲ្យស្តាយស្រណោះបំផុត។

បុត្រានរោត្តម នរទីបោ ត្រូវបានព្រះមហាក្សត្រនរោត្តម សីហនុ ស្រឡាញ់ពេញចិត្តជាងគេ ហើយព្រះអង្គបានបញ្ជូនឲ្យទៅរៀននៅប្រទេសចិន ជំនាញខាងក្សេត្រសាស្ត្រ ព្រមទាំងចេះភាសា និងអក្សរសាស្ត្រចិន ជ្រៅជ្រះទៀតផង។ ពិសេសព្រះមហាក្សត្រនរោត្តម សីហនុ ជាបិតា គ្រោងឲ្យធ្វើជារាជទាយាទរបស់ព្រះរាជាណាចក្រកម្ពុជា បន្តពីព្រះអង្គទៀតផង។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បុត្រានរោត្តម នរទីបោ (នរោត្តម នរ៉ាឌីប៉ូ) និងបុត្រីបុត្រាមួយចំនួនដែលគង់នៅក្នុងប្រទេស ត្រូវបានតុលាការនៃរបបសាធារណរដ្ឋខ្មែរកាត់ទោសពីបទធ្វើវិទ្ធង្សនា ក្នុងឆ្នាំ១៩៧១។

ក្រោយពេលកងទ័ពខ្មែរក្រហម ដណ្តើមបានជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ទ្រង់នរោត្តម នរទីបោ ត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅរស់នៅឯតំបន់ជនបទ

ស្រុកស្រែចម្ការ ដូចប្រជាជនខ្មែរផ្សេងៗទៀតដែរ ហើយមិនយូរប៉ុន្មាន ពួកខ្មែរ-ក្រហម ក៏បានធ្វើឃាតទ្រង់ដោយគ្មានការយោគយល់ថា ទ្រង់ជាបុត្រាសម្តេចព្រះនរោត្តម សីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដែលបានរួមចំណែកយ៉ាងធំធេង ដល់ការដណ្តើមជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ របស់សេនាប្រមុខ លន់ នល់ នោះបន្តិចឡើយ។



ម្ចាស់ក្សត្រី នរោត្តម ថាវេត នរលក្ខណ៍
(រូបថត Colorise & Old Photos of Cambodia)

ក្នុងឆ្នាំ១៩៤៦នោះដែរ ព្រះមហា-ក្សត្រ នរោត្តម សីហនុ ក៏បានសព្វព្រះទ័យជាមួយនឹងប្អូនជីដូនមួយរបស់ព្រះអង្គម្នាក់ ព្រះនាមនរោត្តម ថាវេត នរលក្ខណ៍ (ប្រសូតថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩២៩) ជាបុត្រីពៅរបស់ព្រះអង្គម្ចាស់នរោត្តម សីង្ហារ៉ា និងម្ចាស់ក្សត្រីស៊ីសុវត្ថិ ថាវេតរង្សី នារីវង្ស។

ម្ចាស់ក្សត្រីស៊ីសុវត្ថិ ថាវេតរង្សី នារីវង្ស ជាបងបង្កើតរបស់ម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសមៈនារីរតន៍ សិរីវឌ្ឍនា ដែលត្រូវជាព្រះមាតាព្រះមហាក្សត្រសីហនុ។

មុនពេលមានទំនាក់ទំនងស្នេហាជាមួយព្រះមហាក្សត្រនរោត្តម សីហនុ ម្ចាស់ក្សត្រីនរោត្តម ថាវេត នរលក្ខណ៍ មានស្វាមីជារាជវង្សមួយអង្គព្រះនាមនរោត្តម វ៉ាគ្រីវ៉ាន់ ។

ទំនាក់ទំទងស្នេហានេះ មានសាធារណមតិមួយចំនួនបានរិះគន់ថា ព្រះអង្គម្ចាស់នរោត្តម វ៉ាគ្រីវ៉ាន់ ជាស្វាមីបានលក់មហេសី ថាវេត នរលក្ខណ៍ ទៅថ្វាយព្រះមហាក្សត្រសីហនុ ដើម្បីជាថ្នូរនឹងលុយកាក់ និងបុណ្យស័ក្តិផងដែរ។

ចំពោះការរិះគន់ខាងលើនេះ ព្រះមហាក្សត្រសីហនុ បានធ្វើការបកស្រាយបំភ្លឺថា

ម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ ដែលត្រូវជាប្អូនជីដូនមួយព្រះអង្គនេះ ធ្លាប់រស់នៅជាមួយព្រះអង្គតាំងពីតូចៗមកម្ល៉េះ ព្រោះមាតារបស់ព្រះអង្គ និងមាតារបស់ម្ចាស់ក្សត្រី ត្រូវជាបងប្អូនបង្កើតនឹងគ្នា។

ចំណែកព្រះអង្គម្ចាស់នរោត្តម រ៉ាគ្រីវ៉ាន់ ដែលធ្លាប់ឆ្លងកាត់ជីវិតស្នេហាជាច្រើនពីមុនមករាប់មិនអស់នោះ បានស្នើសុំព្រះអង្គឲ្យជួយចែចូវបញ្ចុះបញ្ចូលម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ និងព្រះមាតាព្រះនាង ដើម្បីសុំរៀបអាពាហ៍ពិពាហ៍ជាមួយ ។

តែក្រោយរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចមក ព្រះអង្គម្ចាស់នរោត្តម រ៉ាគ្រីវ៉ាន់ នៅតែខិលខូចរឿងស្រីញីដដែល ធ្វើឲ្យម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ មានការឈឺចុកចាប់ក្នុងចិត្តយ៉ាងខ្លាំង រហូតស៊ូទ្រាំលែងបាន ក៏សម្រេចចិត្តលែងលះគ្នានៅក្នុងឆ្នាំ១៩៤៥។

ព្រះមហាក្សត្រសីហនុ បានបញ្ជាក់ថា គឺក្រោយលែងលះគ្នានោះហើយបាន១ឆ្នាំទើបព្រះអង្គទាក់ទងស្នេហាជាមួយព្រះនាង គឺពុំមែនព្រះអង្គម្ចាស់នរោត្តម រ៉ាគ្រីវ៉ាន់ ជាអ្នកលក់ម្ចាស់ក្សត្រីថាវេត នរលក្ខណ៍ ជាមហេសី ដើម្បីជាថ្នូរនឹងលុយកាក់ បុណ្យស័ក្តិនោះទេ ព្រោះព្រះអង្គម្ចាស់រ៉ាគ្រីវ៉ាន់ ជារាជវង្សមួយអង្គប្រកបដោយកិត្តិយសថ្លៃថ្នូរ និងសម្បូរលុយកាក់ទ្រព្យសម្បត្តិច្រើនទៀតផង។ ម្យ៉ាងទៀត ទ្រង់ក៏ជាមិត្តភក្តិដ៏ជិតស្និទ្ធជាមួយព្រះអង្គតាំងពីដើមមកដែរ ហើយបើទោះបីជាទ្រង់បានលែងលះជាមួយម្ចាស់ក្សត្រីថាវេត នរលក្ខណ៍ ហើយក៏ដោយ ក៏ទ្រង់នៅតែស្រឡាញ់រាប់អានព្រះអង្គដូចមុនដដែល។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ព្រះអង្គបានតែងតាំងព្រះអង្គម្ចាស់ រ៉ាគ្រីវ៉ាន់ ជាចាងហ្វាងពិធីការនៃព្រះបរមរាជវាំង។

ក្រោយពីមហាក្សត្រនរោត្តម សីហនុ សម្រេចព្រះទ័យដាក់រាជ្យ នៅក្នុងឆ្នាំ១៩៥៥មក ឆ្លៀតឱកាសពេលព្រះបិតានរោត្តម សុរាម្រិត និងព្រះមាតាស៊ីសុវត្ថិ កុសុមៈ កំពុងជាប់រវល់ក្នុងពិធីរៀបអភិសេកឡើងគ្រងរាជសម្បត្តិ បន្តពីព្រះអង្គនោះ ព្រះអង្គក៏បានរៀបអភិសេក (រៀបអាពាហ៍ពិពាហ៍) ជាមួយម្ចាស់ក្សត្រីថាវេត នរលក្ខណ៍ ជាព្រះមហេសីផ្លូវការទី១ គឺក្រោយពេលព្រះអង្គបានទាក់ទងស្នេហាជាមួយអ្នកម្នាងម៉ូនិក អស់រយៈពេល៣ឆ្នាំ

មកហើយដែរ ។

ចំណែកអ្នកម្នាងម៉ូនិក វិញ ក្រោយបានទាក់ទងស្នេហាជាមួយគ្នា តាំងពីឆ្នាំ១៩៥២ មក ទើបមហាក្សត្រនរោត្តម សីហនុ រៀបអភិសេក (រៀបអាពាហ៍ពិពាហ៍) ជាមួយអ្នកម្នាង ជាផ្លូវការ នៅក្នុងឆ្នាំ១៩៥៥នោះដែរ ដោយចាត់ទុកអ្នកម្នាងម៉ូនិក ជាមហេសីពេញច្បាប់ ទី២។

តាមពិតទៅ ព្រះមហាក្សត្រនរោត្តម សីហនុ សព្វព្រះទ័យចំពោះមហេសីទាំងពីរ នេះជាងមហេសីផ្សេងៗទៀត។ ប៉ុន្តែ ដោយសារតែម្ចាស់ក្សត្រីនរោត្តមថាវេត នរលក្ខណ៍ មានការច្រណែន និងប្រចណ្ឌនឹងអ្នកម្នាងម៉ូនិក ខ្លាំងពេក ចាប់ពីដើមទសវត្សរ៍ឆ្នាំ ១៩៦០មក ម្ចាស់ក្សត្រីក៏ចេះតែមានភាពរកាំរកូស រង្គោះរង្គើជាមួយព្រះអង្គ ហើយបើ ទោះបីជាមិនដល់ថ្នាក់លះលែង ក៏ត្រូវរស់នៅឆ្ងាយពីគ្នាដែរ។

ពេលនោះដែរ សម្តេចសីហនុ បានព្រះរាជនិពន្ធចម្រៀងមួយបទមានចំណងជើង ថា "ស្នេហាពុំមានសង្ឃឹម" ថ្វាយម្ចាស់ក្សត្រីនរោត្តម ថាវេត នរលក្ខណ៍ ហៅម្ចាស់ពៅ ផង ដែរ។

នៅក្នុងឆ្នាំ១៩៧៣ ម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ ដែលគ្មានបុត្រាបុត្រីមួយអង្គ សោះនោះ បានចេញពីក្រុងភ្នំពេញ ជាមួយម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា ទៅរស់នៅក្រុងប៉េកាំង ជាមួយព្រះមហាក្សត្រនរោត្តម សីហនុ។

ក្រោយពីការសោយទិវង្គតរបស់ម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា ដែលជាព្រះមាតុច្ឆា ( ម្តាយមីងខាងម្តាយ និងជាម្តាយក្មេក )នៅក្រុងប៉េកាំង នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ ម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ បានចាកចេញទៅរស់នៅប្រទេស បារាំង ហើយត្រូវបានអាជ្ញាធរបារាំង ទទួលឲ្យរស់នៅក្នុងមជ្ឈមណ្ឌលសម្រាប់មនុស្សចាស់ ចូលនិវត្តន៍។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ព្រះករុណាព្រះមហាក្សត្រនរោត្តម សីហនុ បាន ចេញព្រះព្រះរាជក្រឹត្យ តែងតាំងគោរម្យងារម្ចាស់ក្សត្រី ថាវេត នរលក្ខណ៍ ជាសម្តេចព្រះរាជ

កនិដ្ឋា នរោត្តម ថាវេត នរលក្ខណ៍ ។

សម្តេចព្រះរាជកនិដ្ឋា នរោត្តម ថាវេត នរលក្ខណ៍ ហៅម្ចាស់ពៅ បានសុគតនៅវេលាម៉ោង ១:៣០ នាទី ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ នាទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ ។

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៤៧ ម្ចាស់ក្សត្រី ស៊ីសុវត្ថិ ពង្សសានមុនី ប្រសូតបុត្រទី៤ ព្រះនាមនរោត្តម សូរិយារង្សី ហៅម្ចាស់ប៉ាង។

ក្នុងឆ្នាំ១៩៦៣ ពេលមានព្រះជន្ម១៦វស្សា ម្ចាស់ក្សត្រីនរោត្តម សូរិយារង្សី បានរៀបអាពាហ៍ពិពាហ៍ស្វាមីទី១ ឈ្មោះទេព ផល្លី (កើតនៅឆ្នាំ១៩៣៨) ជាកូនប្រុសរបស់ឧកញ៉ាទេព ផន ដែលជាមន្ត្រីជាន់ខ្ពស់ម្នាក់ផងដែរ។

នៅក្នុងឆ្នាំ១៩៦៨ ម្ចាស់ក្សត្រីអង្គនោះ ក៏មានស្វាមីទី២ ឈ្មោះហេងវង្ស ប៊ុនឈឿត (កើតនៅឆ្នាំ១៩៤១)។

នៅក្នុង១៩៧៣ ម្ចាស់ក្សត្រីនរោត្តម សូរិយារង្សី បានចាកចេញពីក្រុងភ្នំពេញជាមួយព្រះអយ្យិកា ស៊ីសុវត្ថិ កុសុមៈនារីរតន៍ សិរីវឌ្ឍនា ទៅរស់នៅជាមួយព្រះបិតានរោត្តម សីហនុ នៅទីក្រុងប៉េកាំង ប្រទេសចិន ។

បន្ទាប់មក ម្ចាស់ក្សត្រីនរោត្តម សូរិយារង្សី ក៏មានស្វាមីទី៣ នៅទីនោះម្នាក់ទៀត ឈ្មោះ ហង់ អេង ហៅសមមិត្ត ហាន់ ជាអតីតនិស្សិតខ្មែរម្នាក់ ដែលបានទៅសិក្សាផ្នែកវិស្វករនៅប្រទេសអាល្លឺម៉ង់ខាងកើត និងជាកម្មាភិបាលតស៊ូរបស់ពួកខ្មែរក្រហមផងដែរ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ម្ចាស់ក្សត្រីនរោត្តម សូរិយារង្សី និងស្វាមី ព្រមទាំងបុត្របានស្ម័គ្រចិត្តដង្ហែព្រះបិតា នរោត្តម សីហនុ យាងត្រឡប់មកមាតុប្រទេសវិញ ជាមួយនឹងរាជវង្សមួយចំនួនទៀត។ ប៉ុន្តែក្រោយសម្តេចសីហនុ សុំពួកមេដឹកនាំខ្មែរក្រហម លាឈប់ពីតំណែងប្រមុខរដ្ឋ ក្នុងខែមេសា ឆ្នាំ១៩៧៦មក ព្រះនាង និងស្វាមី ព្រមទាំងបុត្រ ត្រូវបានពួកខ្មែរក្រហមបំបែកចេញពីព្រះបិតានៅទីក្រុងភ្នំពេញ ឲ្យទៅរស់នៅជាមួយប្រជាជននៅតាមសហករណ៍ ឯតំបន់ជនបទ ស្រុកស្រែចង្ការ ហើយបាត់ដំណឹងសូន្យឈឹង តាំងពី

ពេលនោះមក។

នៅក្នុងឆ្នាំ១៩៤៨ ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី បានប្រសូត្របុត្រទី៥ ព្រះនាម នរោត្តម គន្ធបុប្ផា។ តាំងពីប្រសូតមក មេដោះព្រះនាងជាជនជាតិវៀតណាម ជាអ្នកបីបាច់ថែរក្សា និងបានបង្រៀនព្រះនាងឲ្យចេះនិយាយភាសាវៀតណាមផងដែរ។



បុត្រីនរោត្តម គន្ធបុប្ផា

ពេលមានព្រះជន្ម៤វស្សា ដោយសារមានជំងឺឈាមសស៊ីឈាមក្រហម មហារីកគោលិកា.ស តែក្នុងរយៈពេលតែមួយសប្តាហ៍ប៉ុណ្ណោះ ព្រះនាងក៏ទ្រង់សុគតនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥២។

នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៤៩ ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី បានប្រសូត្របុត្រទី៦ ព្រះនាមនរោត្តម ខេមានុរ័ក្ស។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ព្រះអង្គម្ចាស់នរោត្តម ខេមានុរ័ក្ស បានចាកចេញពីក្រុងភ្នំពេញ ទៅចូលរួមតស៊ូជាមួយរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានព្រះបិតាជាប្រធាន ដើម្បីតស៊ូប្រឆាំងនឹងលន់ នល់ និងទ្រង់សិរិមតៈ។ នៅក្នុងព្រៃតស៊ូនោះ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការរបស់រដ្ឋាភិបាលរួបរួមជាតិ ជាអ្នកគ្រប់គ្រង និងជួយថែរក្សាទ្រង់។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ គឺក្រោយពេលរំដោះទីក្រុងភ្នំពេញ បានប្រហែល៥ខែ ទ្រង់បានយាងមកជួបសម្តេចសីហនុ ជាបិតា នៅក្នុងព្រះបរមរាជវាំង បានម្តងដែរ។ តែក្រោយមក ក៏បាត់ដំណឹងសូន្យឈឹងរហូតដល់សព្វថ្ងៃ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៥១ ម្ចាស់ក្សត្រី ពង្សសានមុនី បានប្រសូតបុត្រទី៧ ព្រះនាមនរោត្តម បទុមបុប្ផា ហៅម្ចាស់ឈូក។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៦៧ ព្រះនាងបទុមបុប្ផា បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្តមុនីរ័ក្ស មានព្រះជន្ម២៧វស្សា នៅក្នុងព្រះបរមរាជវាំង និងមានបុត្រា២អង្គ គឺៈ

ទី១.ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធារី សោភា ប្រសូតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៦៤។

ទី២.ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ច័ន្ទរ៉ាវុឌ្ឍ ប្រសូតនៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៦៦ ហើយសុគតនៅក្នុងឆ្នាំ១៩៧៦ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស ជាបុត្រារបស់ព្រះមហាក្សត្រមុនីវង្ស ជាមួយអ្នកម្នាងបុប្ផា នរលក្ខណ៍តាត (ឈ្មោះដើម យិន តាត) និងត្រូវជាប្អូនបង្កើតរបស់ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ ដែលជាមហេសីរបស់ព្រះមហាក្សត្រនរោត្តម សីហនុ និងជាព្រះមាតារបស់ព្រះអង្គម្ចាស់នរោត្តម នរទីបោ (នរ៉ាឌីប៉ូ)។

ដូច្នេះ ដំបូងឡើយ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស ជាឪពុកមារបស់ព្រះ-មហាក្សត្រនរោត្តម សីហនុ ។ លុះព្រះមហាក្សត្រសីហនុ យកម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ ជាមហេសី ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស បានក្លាយមកជាប្អូនថ្លៃរបស់ព្រះមហាក្សត្រ សីហនុ ទៅវិញ។ តែដល់ពេលព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស យកម្ចាស់ក្សត្រី បទុមបុប្ផា ជាមហេសី ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស នេះ បានក្លាយជាកូនប្រសាររបស់ព្រះមហាក្សត្រ សីហនុ ទៅវិញ។

នៅក្នុងឆ្នាំ១៩៦៤ ម្ចាស់ក្សត្រីបទុមបុប្ផា បានលែងលះគ្នាជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ ជីវ័ន្ត មុនីរ័ក្ស រួចបានទៅរៀបអាពាហ៍ពិពាហ៍ជាលើកទី២ នៅព្រះរាជដំណាក់ចំការមន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៦៧ ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឧស្សាឌី (ប្រសូតថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៣៥) ត្រូវជាក្មួយរបស់ព្រះនាងផងដែរ។

នៅក្នុងឆ្នាំ១៩៥១ ក្រោយពេលផ្តាច់និស្ស័យជាមួយព្រះមហាក្សត្រសីហនុ នៅក្នុងឆ្នាំ១៩៥១ មក ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី បានកសាងជីវិតថ្មីជាមួយនាយទាហានថ្នាក់វរសេនីយ៍ទោម្នាក់ឈ្មោះអ៊ុន ជុំ។



**ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី**
(**រូបថត** **Colorise & Old Photos of Cambodia**)

ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី សុគតនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៤ នៅទីក្រុងភ្នំពេញ។

នៅក្នុងឆ្នាំ១៩៤៩ ព្រះមហាក្សត្រ សីហនុ បានយាងទៅសម្រាកវិស្សមកាលរដូវប្រាំង នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយមានព្រះមាតុច្ឆាពីរអង្គ គឺម្ចាស់ក្សត្រីនរោត្តម រស្មីសុផាណា (រស្មីសោភ័ណ) និងម្ចាស់ក្សត្រី នរោត្តម មុំកេតកញ្ញា ជាប្អូនជីដូនមួយរបស់ព្រះបិតាព្រះអង្គ បានទៅតាមបម្រើព្រះអង្គផងដែរ។

នៅក្នុងរាត្រីមួយ ពេលយុវជនយុវនារីក្រុងវៀងច័ន្ទ បាននាំគ្នាមកលេងព្រះរាជដំណាក់ព្រះអង្គ ដោយនាំយកមកជាមួយនូវឧបករណ៍ភ្លេងកេនរបស់ពួកគេ ដើម្បីរាំលេង កម្សាន្តផងនោះ ព្រះអង្គបានចាប់ព្រះទ័យស្រឡាញ់នារីដ៏ស្រស់ស្អាតម្នាក់មានវ័យ១៥ឆ្នាំ ឈ្មោះម៉មម៉ានីវណ្ណ ផាន់ណាវង្ស ជាកូនកំព្រាឪពុក មានដើមកំណើតចេញពីគ្រួសារកសិករ។

ព្រះអង្គបានយល់ព្រមធ្វើពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរបស់ជនជាតិឡាវ ដោយឲ្យព្រះមាតុច្ឆាទាំង២អង្គទៅចាត់ចែងរៀបចំពិធីអាពាហ៍ពិពាហ៍នោះជាមួយម្ដាយនាងនៅឯផ្ទះ។ តែនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ ពុំមានវត្តមានរបស់ព្រះអង្គទេ ។ ព្រះអង្គគ្រាន់តែឲ្យព្រះមាតុច្ឆាទាំង២អង្គ យកអាវកុត មានគ្រឿងតែងលម្អដ៏ស្អាតដាក់លើខ្នើយទន្ទឹមគ្នា ដើម្បីឱ្យកូនក្រមុំក្រាបសំពះផ្ទឹមជាមួយប៉ុណ្ណោះ។

លុះពេលព្រះអង្គនាំនាងមកដល់ទីក្រុងភ្នំពេញ ចូលក្រាបបង្គំព្រះមាតាព្រះបិតា

ព្រះអង្គទាំងទ្វេ បែរទទួលរាប់អាននាង ដោយសោះអង្គើយ។

អ្នកម្នាងម៉មម៉ានីវណ្ណ ផាន់ណាវង្ស កើតនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៣៤។ មានបុត្រ២អង្គគឺៈ

ទី១. ព្រះអង្គម្ចាស់ក្សត្រីនរោត្តម សុជាតា ឬសុផាវត្តិយា បានរៀបការជាមួយព្រះស្វាមីឈ្មោះ សម ចាន់វត្តី នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៦៧។ ព្រះនាង និងស្វាមី បានសុគតដោយសារពួកខ្មែរក្រហមសម្លាប់ ក្នុងពេលចាប់ខ្លួនជាមួយមាតាផាន់ណាវង្ស និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។



**អ្នកម្នាង ម៉មម៉ានីវណ្ណ ផាន់ណាវង្ស**
(រូបថត Colorise & Old Photos of Cambodia)

ទី២. ម្ចាស់ក្សត្រីនរោត្តម អរុណរស្មី ប្រសូតនៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៥៥ នៅក្រុងភ្នំពេញ។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧០ ព្រះនាងនរោត្តម អរុណរស្មី បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីរ័ត្ន (ប្រសូតថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៤៦) ជាបុត្រារបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលទើបនឹងធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ជាព្រះបិតាព្រះនាង បានរយៈពេលជាង៣ខែប៉ុណ្ណោះ។

នៅក្នុងឆ្នាំ១៩៨០ ព្រះនាងបានចូលបម្រើការងារនៅធនាគារមួយ នៅក្រុងឡុងប៊ិច ។ ក្រោយមក ព្រះនាងបានចូលបម្រើការងារនៅធនាគារមួយទៀតឈ្មោះធនាគារពាណិជ្ជកម្មស្យាម (Siam Commercial Bank) នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៧ ព្រះនាងបានក្លាយជាអនុប្រធាន និងបន្ទាប់មកទៀត

បានឡើងជាប្រធានធនាគារកសិកម្មកម្ពុជា ។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៨ ព្រះនាងត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូត ប្រចាំនៅប្រទេសម៉ាឡេស៊ី។ ក្រោយមកទៀត ព្រះនាងត្រូវបានព្រះមហាក្សត្រនរោត្តម សីហមុនី តែងតាំងជាសមាជិកព្រឹទ្ធសភា។

ជាមួយស្វាមីស៊ីវត្ថិ សិរីរ័ត្ន ព្រះនាងមានបុត្រ៣អង្គគឺៈ

ទី១ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ណាគា, ទី២ ស៊ីសុវត្ថិ ណាន់ដូ និងទី៣ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិគិត ណាថាលី ។

ម្ចាស់ក្សត្រីនរោត្តម អរុណរស្មី រៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីទី២ ឈ្មោះកែវ ពុធរស្មី នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩១។

ជាមួយស្វាមីកែវ ពុធរស្មី ព្រះនាងមានបុត្រ២អង្គ គឺម្ចាស់ក្សត្រីនរោត្តម កែវ ប៉ូនីតា និងព្រះអង្គម្ចាស់នរោត្តម កែវ ខេមមុនី។

ម្ចាស់ក្សត្រីនរោត្តម អរុណរស្មី អាចនិយាយភាសាខ្មែរ លាវ ថៃ បារាំង និងអង់គ្លេសបានយ៉ាងស្ទាត់ជំនាញ។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៤ ព្រះនាងទទួលគោរម្យងារជាសម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី។

# ១១
# កញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី ជានរណា ?



**កញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី**

ព្រះមហាក្សត្រនរោត្តម សីហនុ ធ្លាប់ស្គាល់កញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី និងក្រុមគ្រួសាររបស់នាង តាំងពីកាលនាងនៅកុមារីម្ល៉េះ។ លុះដល់ធំពេញវ័យ កញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី ក្លាយជាបវរកញ្ញាដ៏ស្រស់ស្អាត បានទាក់ទាញព្រះទ័យព្រះអង្គឲ្យប្រាថ្នាចង់បានជាគូគាប់តែម្តង។

កញ្ញា ប៉ូល ម៉ូនិក អ៊ីហ្ស៊ី (Paul-Monique Izzi ) មានម្តាយឈ្មោះប៉ុម ពាង និងមានជីដូនឈ្មោះ អ៊ុក រស់នៅទីក្រុងភ្នំពេញ។

លោកយាយ អ៊ុក បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់នរោត្តម ដួងចក្រ

## របត់នយោបាយ

ជាបុត្រាទី៥ របស់ព្រះមហាក្សត្រនរោត្តម ។ ព្រះមាតារបស់ព្រះអង្គម្ចាស់នរោត្តម ដួងចក្រ ព្រះនាម ឃុនព្រះម្នាង ថៅចមសុជាតិបុស្បានារីបុប្ផា នួន ហៅ ឃុន ថាន់ ។ ទ្រង់ប្រសូត នៅក្នុងឆ្នាំ១៨៦១ នៅក្នុងព្រះបរមរាជវាំងនៅក្រុងឧដុង្គមានជ័យ។

ព្រះអង្គម្ចាស់នរោត្តម ដួងចក្រ មានមហេសី៣អង្គ គឺ៖

ទី១. អ្នកម្នាង រំដេញ មានបុត្រា១អង្គ ព្រះនាម នរោត្តម មណ្ឌានថាន្នី ( ១៨៨១ -១៩០៦ )។

ទី២. អ្នកម្នាង អាន (ត្រូវជាកូនករី សន្ធរម៉ុក) មានបុត្រី១អង្គ ព្រះនរោត្តម វិទ្បៃល័ក្ខណ៍ ( ១៨៩១ -៨ សីហា ១៩៧០ )។

ទី៣. អ្នកម្នាង អ៊ុក ត្រូវជាមាតារបស់លោកយាយ ប៉ុម ៣ង និងត្រូវជាជីដូនរបស់ អ្នកម្នាងម៉ូនិក ។

អ្នកម្នាង អ៊ុក មានបុត្រី១អង្គព្រះនាមនរោត្តម ប្រាផៃកត្រ្គ ( ១៨៨១- ១៩៥០ ) និងបុត្រា១អង្គ ព្រះនាមនរោត្តម រដ្ឋារង្សី (ប្រសូត១៨៩៤) ។

បុត្រានរោត្តម រដ្ឋារង្សី អង្គនេះបានក្លាយជាវេជ្ជបណ្ឌិតខ្មែរដំបូងគេបង្អស់នៅ ប្រទេសកម្ពុជា ប៉ុន្តែជាអកុសល ទ្រង់បានសោយទិវង្គតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៤៩។

ចាប់ពីឆ្នាំ១៨៨៥មក ព្រះអង្គម្ចាស់នរោត្តម ដួងចក្រ បានចេញមុខគាំទ្រចលានា បះបោរប្រឆាំងបារាំង យ៉ាងសកម្ម រហូតត្រូវពួកបារាំង ចាប់ឃុំព្រះកាយនៅក្នុងខែមេសា ឆ្នាំ១៨៩០ ។

តែដោយមានព្រះរាជអន្តរាគមន៍ពីព្រះមហាក្សត្រនរោត្តម ជាព្រះបិតា នៅក្នុងឆ្នាំ ១៨៩១ ព្រះអង្គម្ចាស់ នរោត្តម ដួងចក្រ ត្រូវពួកបារាំង ដោះលែងវិញ តែត្រូវនិរទេសព្រះ កាយឲ្យទៅរស់នៅប្រទេសថៃ។

តែដោយសារទ្រង់មិនស្ងប់ព្រះរាជហឫទ័យនឹងការជិះជាន់របស់បារាំង និងការប្រមាថ មើលងាយមើលថោកដល់ព្រះរាជវង្ស និងប្រជារាស្ត្រខ្មែរពីសំណាក់ពួកបារាំង ជាពិសេសពី សំណាក់ទេសាភិបាលជាន់ខ្ពស់បារាំងឈ្មោះ Albert Louis Huyn de Vernéville នៅខែ



ព្រះអង្គម្ចាស់ នរោត្តម ដួងចក្រ

មិថុនា ឆ្នាំ១៨៩៣ ព្រះអង្គបានចាកចេញពីប្រទេសថៃ យាងទៅទីក្រុងប៉ារីស ប្រទេសបារាំង ដើម្បីសុំកិច្ចអន្តរាគមន៍ និងរាយការណ៍ឱ្យមេដឹកនាំបារាំង បានដឹងពីរឿងនេះ ព្រមទាំងសុំឱ្យដាក់ទេសាភិបាលជាន់ខ្ពស់បារាំងថ្មី ជំនួសទេសាភិបាលជាន់ខ្ពស់បារាំង ឈ្មោះ Albert Louis Huyn de Vernéville នេះផងដែរ។ តែផ្ទុយទៅវិញ មេដឹកនាំបារាំងមិនត្រឹមតែមិនបានអើពើនោះទេ គឺថែមទាំងចាប់ទ្រង់ម្តងទៀត។

នៅខែសីហា ឆ្នាំ១៨៩៣ ទ្រង់ត្រូវបានបារាំង និរទេសឱ្យទៅនៅប្រទេសអាល់ហ្សេរី ដែលកាលនោះជាដែនដីអាណានិគមបារាំងមួយដែរ ហើយបង្ខាំងទ្រង់ឱ្យគង់នៅទីនោះតែម្តង។

ក្រោយពីនិរទេសព្រះកាយមករស់នៅក្នុងទឹកដីនៃប្រទេសអាល់ហ្សេរី បានរយៈពេល ៤ឆ្នាំមក នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៨៩៧ ព្រះអង្គម្ចាស់នរោត្តម ដួងចក្រ ក៏បានសុគតទៅនៅក្នុងព្រះជន្ម៣៦វស្សា នៅទីក្រុងដាចេលហ្វា ។

ក្រោយមក អ្នកម្នាងអ៊ុក ក៏មានស្វាមីម្នាក់ទៀត ឈ្មោះពាង ជាមន្ត្រីម្នាក់ ដែលជាកូនចៅដ៏ជិតស្និទ្ធរបស់ព្រះអង្គម្ចាស់នរោត្តម សុជារស។ នៅក្នុងឆ្នាំ១៩០៤ អ្នកម្នាងអ៊ុកបង្កើតបានកូនស្រីមួយ ឈ្មោះប៉ុម ពាង ។ ២ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩០៦ អ្នកម្នាងអ៊ុក បានកូនប្រុសម្នាក់ទៀតឈ្មោះ ហ៊ែល ពាង។

នៅក្នុងឆ្នាំ១៩២៣ កញ្ញាប៉ុម ពាង បានរៀបអាពាហ៍ពិពាហ៍ជាមួយកំលោះម្នាក់ឈ្មោះ អ៊ុំ ផាន់កែវ ជាកូនប្រុសរបស់នាយទាហានល្បីឈ្មោះម្នាក់ គឺលោកស័ក្តិ៣អ៊ុំ ។

## របត់នយោបាយ

ក្រោយបញ្ចប់សង្គ្រាមលោកលើកទី២ មានកិច្ចព្រមព្រៀងបារាំង -សៀម ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤៦ នៅទីក្រុងវ៉ាស៊ីងតោន តម្រូវឲ្យសៀម ប្រគល់ទឹកដីខេត្តបាត់ដំបង សៀមរាប កំពង់ធំ ដែលខ្លួនបានកាន់កាប់ចាប់ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៦ មកឲ្យខ្មែរវិញ គេឃើញលោកស័ក្តិ៣អ៊ុំ បានឡើងឋានន្តរស័ក្តិដល់វរសេនីយ៍ទោ (ស័ក្តិ៤កន្លះ) ទៅហើយនោះ ជាអ្នកដឹកនាំកម្លាំងដើរវាស់វែង និងបោះបង្គោលព្រំដែនខ្មែរ-សៀម ជាថ្មីឡើងវិញ ជាមួយនាយទាហានជាន់ខ្ពស់បារាំង មួយចំនួនទៀត ។

ក្រោយពេលរៀបការបាន៥ឆ្នាំ ប៉ុម ពាង និងអ៊ុំ ផាន់កែវ មានកូនប្រុសស្រីចំនួន ៥នាក់ ៖

ទី១ ឈ្មោះអ៊ុំ ម៉ាន់នូរិន ភេទប្រុស កើតនៅឆ្នាំ១៩២៤។ ក្នុងសម័យសង្គមរាស្ត្រនិយម មានតួនាទីជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការពារលើផ្ទៃប្រទេស។ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ត្រូវមេដឹកនាំរដ្ឋប្រហារចាប់យកទៅឃុំទុកនៅបាតកប៉ាល់ខាងមុខកំពង់ផែភ្នំពេញ ។ នៅក្នុងឆ្នាំ២០១២ ត្រូវបានព្រះមហាក្សត្រ តែងតាំងជាសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ អ៊ុំ ម៉ាន់នូរិន ត្រូវបានទទួលមរណភាព នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ ក្នុងជន្មាយុ៩៣ឆ្នាំ ដោយជរាពាធ។

ទី២ ឈ្មោះអ៊ុំ វីណារុឡ្ល ភេទប្រុស កើតនៅក្នុងឆ្នាំ១៩២៥ ។ ក្រោយមកបានក្លាយជាអ្នកបើកយន្តហោះនៃកងទ័ពអាកាសកម្ពុជា ហើយបានបាត់បង់ជីវិតនៅក្នុងឆ្នាំ ១៩៤៨ ពេលបើកយន្តហោះទៅទម្លាក់គ្រាប់បែកលើកងទ័ពវៀតមិញ នៅក្នុងសមរភូមិមួយនៅក្នុងខេត្តកំពត ហើយត្រូវកងទ័ពវៀតមិញ បាញ់យន្តហោះនោះធ្លាក់។

ទី៣ ឈ្មោះអ៊ុំ ណារីវ៉ាន់ ភេទស្រី កើតឆ្នាំ១៩២៦។ ស្លាប់នៅក្នុងឆ្នាំ១៩៤៨ ។

ទី៤ ឈ្មោះអ៊ុំ សូវ៉ាក់ សាន់ថន ភេទប្រុស កើតនៅឆ្នាំ១៩២៧។

ទី៥ ឈ្មោះអ៊ុំ សុផានិត ភេទស្រី កើតនៅក្នុងឆ្នាំ១៩២៨ ។ អ៊ុំ សុផានិត បានរៀបអាពាហ៍ពិពាហ៍ជាមួយ អៀវ បណ្ណាការ ជាកូនប្រុសរបស់អៀវ កើស ជាប្រធានរដ្ឋសភា ពីឆ្នាំ១៩៤៧មក និងជានាយករដ្ឋមន្ត្រី ក្នុងឆ្នាំ១៩៤៩ ហើយត្រូវគេបង្កៃគ្រាប់បែកធ្វើឃាត



**លោកយាយ ប៉ុម ពាង មាតាអ្នកម្នាងម៉ូនិក** (រូបថតហ្វេសប៊ុក ប៊ី សោភ័ណ្ឌ)

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥០។ ក្នុងសម័យសង្គមរាស្ត្រនិយម អៀវ បណ្ណាការ បាន ទៅរៀនជំនាញខាងថតខ្សែភាពយន្តនៅប្រទេសបារាំង។ ដើមឆ្នាំ១៩៧៩ មានតួនាទីជា អនុប្រធាននាយកដ្ឋានភាពយន្ត នៅក្រសួងឃោសនាការ វប្បធម៌ និងព័ត៌មាន ក្នុងរបប សាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅក្នុងឆ្នាំ២០១២ អៀវ បណ្ណាការ ត្រូវបានព្រះមហា-ក្សត្រ តែងតាំងជាសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ហើយនៅយប់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ គាត់បានទទួលមរណភាព ក្នុងជន្មាយុ៨៩ឆ្នាំ ដោយជរាពាធ។

អ្នកស្រីប៉ុម ពាង មានស្វាមីទី២ ឈ្មោះហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី (Jean-François Izzi) ដែលមានឪពុកជាជនជាតិអ៊ីតាលី និងម្តាយជាជនជាតិបារាំង។

ហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី ជាអ្នកគ្រប់គ្រងធនាគារមួយឈ្មោះក្រេឌីត ហ្វុងស្យេ (Credit Foncier) នៅទីក្រុងព្រៃនគរ នាទឹកដីកូសាំងស៊ីន ។

ក្រោយពីបានជាប្តីប្រពន្ធហើយ លោកហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី បាននាំអ្នកស្រីប៉ុម ពាង ទៅរស់នៅឯទីក្រុងព្រៃនគរ។ នៅទីនោះ អ្នកស្រីប៉ុម ពាង បង្កើតបានកូន២នាក់ទៀត គឺៈ

ទី១ ឈ្មោះ អាន ម៉ារី អ៊ីហ្ស៊ី (Anne Marie Izzi) ឆ្នាំកំណើត ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៣៤ និងទី២ ឈ្មោះ ប៉ូល ម៉ូនិក អ៊ីហ្ស៊ី (Paul Monique Izzi ៖ អ្នកម្នាង ម៉ូនិក) កើតនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៣៦។



កញ្ញាអាន ម៉ារី អ៊ីហ្ស៊ី (Anne Marie Izzi)
រៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់
ស៊ីសុវត្ថិ មេថាវី

ក្នុងសង្គ្រាមលោកលើកទី២ ឆ្នាំ១៩៣៩ ពេលកងទ័ពណាហ្ស៊ីអាល្លឺម៉ង់ ចូលឈ្លានពានដណ្ដើមកាន់កាប់ប្រទេសបារាំង លោកហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី (Jean-François Izzi) ដែលជាប់កំណែនចូលបម្រើក្នុងជួរកងទ័ពបារាំង នៅឥណ្ឌូចិននោះ ត្រូវបានបញ្ជូនពីទីក្រុងព្រៃនគរ ជាមួយកងទ័ពកំណែនជាជនជាតិបារាំង ខ្មែរ វៀតណាម និងឡាវ ជាច្រើនពាន់នាក់ទៀត ដើម្បីទៅធ្វើសង្គ្រាមវាយបណ្ដេញកងទ័ពអាល្លឺម៉ង់ ឲ្យចេញពីប្រទេសបារាំង វិញ ។

ពេលនោះ លោកហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី មានឋានន្តរស័ក្តិជាអនុសេនីយ៍ទោ ក៏បាត់ខ្លួននៅក្នុងសមរភូមិនៅប្រទេសបារាំង តាំងពីឆ្នាំ១៩៤០ រហូតមក។

ចំណែកអ្នកស្រីប៉ុម ពាង ក៏នាំកូនស្រីទាំង២នាក់ (អាន ម៉ារី អ៊ីហ្ស៊ី និងប៉ូល ម៉ូនិក អ៊ីហ្ស៊ី) វិលត្រឡប់មករស់នៅទីក្រុងភ្នំពេញ ជួបជុំកូនៗទាំង៥នាក់ជាមួយស្វាមីទី១ (អ៊ុំ

ផាន់កែវ) របស់គាត់វិញ។

កូនស្រីរបស់អ្នកស្រីប៉ុម ពាង ឈ្មោះអាន ម៉ារី អ៊ីហ្ស៊ី (Anne Marie Izzi) បានសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យដេកាត (Lycée René Descartes) ហើយបានចូលសិក្សានៅមហាវិទ្យាល័យវេជ្ជសាស្ត្រ នៅទីក្រុងភ្នំពេញ និងបន្តការសិក្សានៅទីក្រុងប៉ារីស ប្រទេសបារាំង រហូតទទួលបានសញ្ញាបត្រវេជ្ជបណ្ឌិត ។

នៅក្នុងឆ្នាំ១៩៥១ កញ្ញាអាន ម៉ារី អ៊ីហ្ស៊ី (Anne Marie Izzi) បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ មេថាវី ដែលជាប្អូនបង្កើតរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ។ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួច កញ្ញាអាន ម៉ារី អ៊ីហ្ស៊ី ត្រូវបានទទួលងារជាអ្នកម្នាងស៊ីសុវត្ថិ ណាណែត មេធាវី ។

ចំណែកកញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី បានសិក្សានៅសាលាបឋមសិក្សាព្រះនរោត្តម និងវិទ្យាល័យព្រះស៊ីសុវត្ថិ រហូតដល់វិទ្យាល័យដេកាត (Lycée René Descartes) រាជធានីភ្នំពេញ។

លោកហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី (Jean-François Izzi ) ជាមិត្តជិតស្និទ្ធព្រះបិតា សុរាម្រឹត។ រីឯអ្នកស្រីប៉ុម ពាង ក៏ជាមនុស្សជិតស្និទ្ធជាមួយព្រះអង្គម្ចាស់នរោត្តម សុធារស ជាព្រះអយ្យិកោ និងព្រះនាងផះង៉ាង៉ាម ជាព្រះអយ្យិកាព្រះមហាក្សត្រនរោត្តម សីហនុ ផងដែរ ។

យោងតាមទស្សនាវដ្តី "Time" ដ៏ល្បីល្បាញរបស់អាមេរិក បានឲ្យដឹងថា លោកហ្សង់ ហ្វ្រង់ស័រ អ៊ីហ្ស៊ី (Jean-François Izzi) ឧស្សាហ៍ចេញចូលនៅរាជដំណាក់របស់ព្រះបិតា សុរាម្រឹត ដែលស្ថិតនៅក្បែរវិមានឯករាជ្យ ហើយលោកតែងតែយកសៀវភៅល្អៗពីប្រទេសបារាំង ដូចជា សៀវភៅរឿងអាលីបាបា(Ali Baba), រឿងមួយពាន់មួយយប់ (A Thousand One night), រឿងប៊ីកូ ប៊ីកូតាំង(Bicot Bicotin) និងសៀវភៅផ្សេងៗទៀតទៅផ្ញើសម្តេចសីហនុ ដែលកាលនោះព្រះអង្គនៅវ័យកុមារនៅឡើយ។

ថ្ងៃមួយ ក្នុងឆ្នាំ១៩៤៨ ពេលកញ្ញា ម៉ូនិក ទើបមានវ័យ១២ឆ្នាំ នាងបានរួមដំណើរជាមួយអ្នកម្តាយ ដើម្បីទៅចូលគាល់សួរសុខទុក្ខព្រះអង្គម្ចាស់សុរាម្រឹត និងព្រះអង្គម្ចាស់

ក្សត្រី ស៊ីសុវត្ថិ កុសមៈ ក៏បានជួបនឹងព្រះមហាក្សត្រសីហនុ ផងដែរ ។ ពេលនោះ ព្រះ-មហាក្សត្រនរោត្តម សីហនុ មានព្រះរាជឱង្ការប្រាប់អ្នកស្រីប៉ុម ពាង ថា ក្នុងពេលពីរបីឆ្នាំទៀត ព្រះអង្គនឹងយាងចូលស្ដីដណ្ដឹងកញ្ញា ម៉ូនិក ដើម្បីរៀបអភិសេកហើយ។

ពេលនោះ អ្នកស្រី ប៉ុម ពាង បានឆ្លើយតបវិញថា ៖ «ព្រះអង្គ! ព្រះអង្គល្បីល្បាញថា មានដៃគូស្នេហាច្រើនណាស់។ ព្រះអង្គតែងប្ដូរស្រីកំណាន់។ ដូច្នេះសូមព្រះអង្គទុកឱកាសឱ្យកូនស្រីរបស់ខ្ញុំម្ចាស់មានស្វាមីល្អស្មោះត្រង់ និងមានមហេសីតែមួយ គឺមិនមានមហេសីច្រើនដូចព្រះអង្គនោះផង »។

នៅដើមទសវត្សរ៍ឆ្នាំ១៩៥០ មុនពេលបើកពិធីប្រឡងបវរកញ្ញា ដែលជួយឧបត្ថម្ភគាំទ្រដោយអង្គការយូណេស្កូ ព្រះមហាក្សត្រ សីហនុ បានមានព្រះរាជបន្ទូលលើកទឹកចិត្តឱ្យកញ្ញា ម៉ូនិក ចូលរួមក្នុងការប្រឡងជ្រើសរើសបវរកញ្ញានោះដែរ។

ប៉ុន្តែកញ្ញាម៉ូនិក បានឆ្លើយតបទាំងអៀនប្រៀនថា៖ «ព្រះអង្គ! បើសិនជាខ្ញុំម្ចាស់មិនបានជាប់ជ័យលាភីក្នុងការប្រឡងនេះទេ ខ្ញុំម្ចាស់ច្បាស់ជាយំមិនខាន ហើយខ្ញុំម្ចាស់យំតើព្រះអង្គមានអ្វីលួងខ្ញុំម្ចាស់ទេ ? "។

ពេលនោះ ព្រះមហាក្សត្រ បានឆ្លើយថា បើសិនជានាងពុំមានសំណាងបានជាប់ជ័យលាភីក្នុងការប្រឡងបវរកញ្ញានោះទេ ព្រះអង្គនឹងផ្ដល់រង្វាន់ជាពានប្រាក់ដែលមានក្បូរក្បាច់រចនាយ៉ាងស្រស់ស្អាតមួយ ។

# ១២
# មហាក្សត្រសីហនុ សព្វព្រះទ័យ
# លើកញ្ញា ប៉ូល ម៉ូនិក អ៊ីហ្ស៊ី ជាងគេ



**ព្រះមហាក្សត្រ សីហនុ រៀបពិធីរៀបអភិសេក**
**ជាមួយអ្នកម្នាងម៉ូនិក ជាផ្លូវការ ក្នុងឆ្នាំ១៩៥៥**

ក្រោយពីប្រឡងជាប់ជ័យលាភីជាបវរកញ្ញា បានមួយឆ្នាំ គឺនៅឆ្នាំ១៩៥២ ព្រះមហាក្សត្រ សីហនុ បានស្នើសុំទៅអ្នកស្រីប៉ុម ពាង ជាមាតា ដើម្បីយកកញ្ញា ម៉ូនិក ជាមហេសី។

អ្នកស្រី ប៉ុម ពាង ជាមាតាក៏បានយល់ព្រម និងរៀបចំពិធីរៀបអភិសេកមិនផ្លូវការមួយ។

បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីឃុនព្រះម្នាង បុប្ផានរលក្ខណ៍ មាយ (ជាបងជីដូនមួយប៉ុល ពត) ដែលជាអ្នកគ្រប់គ្រងនារីទាំងអស់ក្នុងព្រះបរមរាជវាំង តាំងពី

រជ្ជកាលព្រះមហាក្សត្រមុនីវង្ស និងពីព្រះអង្គម្ចាស់ ស៊ីសុវត្ថិ កុសរ្សៈ ដែលជាបងប្អូនជីដូនមួយ និងជាដៃគូកីឡាវាយតិន្នីសរបស់ព្រះអង្គមក ព្រះអង្គបានព្រះរាជនិពន្ធចម្រៀងមួយបទ ដែលមានចំណងជើងថា៖ «រាត្រីដែលបានជួបភ័ក្រ្ត» ដើម្បីទុកជាអនុស្សាវរីយ៍ជាមួយប៉ូល ម៉ូនិក អ៊ីហ្ស៊ី ទៀតផង។

នៅក្នុងឆ្នាំ១៩៥៥ ព្រះមហាក្សត្រ នរោត្តម សីហនុ រៀបចំពិធីរៀបអភិសេកជាមួយអ្នកម្នាងម៉ូនិក ជាថ្មីម្តងទៀត ដែលចាត់ទុកថាជាពិធីរៀបអភិសេកផ្លូវការ។

ក្រោយពីបានក្លាយជាមហេសីរបស់ព្រះមហាក្សត្រមក អតីតបវរកញ្ញាប៉ូល ម៉ូនិក អ៊ីហ្ស៊ី មានងារថា អ្នកម្នាងម៉ូនិក សីហនុ។

នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣ អ្នកម្នាងក៏បានប្រសូតបុត្រាមួយព្រះអង្គ ព្រះនាមនរោត្តម សីហមុនី ។ បុត្រាសីហមុនី បានចូលសិក្សានៅសាលាបឋមសិក្សានរោត្តម។

បន្ទាប់មក នៅវិទ្យាល័យដេកាត ពីឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៦២ ហើយនៅចុងឆ្នាំ១៩៦២ ព្រះបិតាបានបញ្ជូនឲ្យទៅបន្តការសិក្សានៅទីក្រុងប្រាជ ប្រទេសឆេកូស្លូវ៉ាគី ជំនាញផ្នែកតន្ត្រី និងរបាំ រហូតដល់ឆ្នាំ១៩៧៥។

ទ្រង់ចេះភាសាបារាំង និងភាសាឆេក យ៉ាងស្ទាត់ជំនាញ។ ក្រៅពីនេះ ព្រះអង្គអាចប្រាស្រ័យទាក់ទងជាភាសាអង់គ្លេស និងរុស្ស៊ី បានល្អប្រសើរផងដែរ។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៥៤ អ្នកម្នាងម៉ូនិក ប្រសូតបានបុត្រាមួយព្រះអង្គទៀត ព្រះនាមនរោត្តម នរិន្ទ្រពង្ស។

ទ្រង់នរិន្ទ្រពង្ស បានចូលសិក្សានៅសាលានរោត្តម និងសាលាដេកាត ដូចព្រះរៀម សីហមុនី ដែរ។ តែក្រោយមក ត្រូវព្រះបិតាបញ្ជូនឲ្យទៅរៀនសាកលវិទ្យាល័យ នៅទីក្រុងមូស្គូ សហភាពសូវៀត ។

ព្រះអង្គម្ចាស់នរោត្តម នរិន្ទ្រពង្ស មានជំនឿជឿជាក់លើលទ្ធិកុម្មុយនិស្ត ដូចពួកមេដឹកនាំខ្មែរក្រហម ដែរ ។ ព្រះអង្គបានរៀបអាពាហ៍ពិពាហ៍ជាមួយក្រមុំខ្មែរម្នាក់ឈ្មោះឯក ស៊ីន្នួន នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៨៣ នៅប្រទេសបារាំង និងមានបុត្រី២អង្គគឺ៖

ទី១ ម្ចាស់ក្សត្រីនរោត្តម ស៊ីម៉ូណារីន ប្រសូតនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៨៤ និង ទី២ ម្ចាស់ក្សត្រីនរោត្តម មុនីនុ ប្រសូតថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨៧។

ព្រះអង្គម្ចាស់នរោត្តម នរិន្ទ្រពង្ស ទ្រង់សុគតនៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៣ នៅទីក្រុងប៉ារីស។

សរុបមក ព្រះមហាក្សត្រនរោត្តម សីហនុ មានមហេសីជាផ្លូវការ ចំនួន៦អង្គ និងបុត្រា បុត្រី១៤អង្គ។

១.អ្នកម្នាង ផាត់ កាញ៉ុល មានបុត្រ២អង្គ គឺនរោត្តម បុប្ផាទេវី និងនរោត្តម រណឫទ្ធិ។

២.ម្ចាស់ក្សត្រីស៊ីសុវត្ថិ ពង្សសានមុនី មានបុត្រ៧អង្គ គឺព្រះអង្គម្ចាស់នរោត្តម យុវនាថ, ព្រះអង្គម្ចាស់ នរោត្តម រ័ក្សរីវង្ស , ព្រះអង្គម្ចាស់នរោត្តម ចក្រពង្ស , ម្ចាស់ក្សត្រីនរោត្តម សុរិយារង្សី, ម្ចាស់ក្សត្រី នរោត្តម គន្ធបុប្ផា, ព្រះអង្គម្ចាស់នរោត្តម ខេមានុរ័ក្ស និងម្ចាស់ក្សត្រីរោត្តម បទុមបុប្ផា។

៣. ម្ចាស់ក្សត្រីស៊ីសុវត្ថិ មុនីកេសរ មានបុត្រាមួយអង្គ ព្រះនាមនរោត្តម នរ៉ាឌីប៉ូ។

៤. ម្ចាស់ក្សត្រីនរោត្តម ថាវេត នរលក្ខណ៍ (គ្មានព្រះរាជបុត្រ) ។

៥. អ្នកម្នាងម៉មម៉ានីវណ្ណ ផាន់ណាវង្ស ជាជនជាតិលាវ មានបុត្រី២អង្គ គឺនរោត្តម សុជាតា ឬសុផាវត្ថិយា និងនរោត្តម អរុណរស្មី ។

៦. អ្នកម្នាង ម៉ូនិក (ប៉ូល ម៉ូនិក អ៊ីហ្ស៊ី) មានបុត្រា២អង្គ គឺព្រះអង្គម្ចាស់នរោត្តម សីហមុនី ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ និងព្រះអង្គម្ចាស់នរោត្តម នរិន្ទ្រពង្ស។

នៅក្នុងឆ្នាំ១៩៤៤ ព្រះមហាក្សត្រនរោត្តម សីហនុ មានទំនាក់ទំនងស្នេហាជាមួយ អតីតស្នំរបស់ព្រះអយ្យិកោព្រះមុនីវង្ស ម្នាក់ឈ្មោះអ្នកម្នាងថាច ដែលមានវ័យច្រើនជាងព្រះអង្គ។

ដោយសារទំនាក់ទំនងស្នេហានោះមានរយៈពេលខ្លីបំផុត ព្រះអង្គក៏មិនចាត់ទុកអ្នកម្នាងថាច ជាមហេសីនោះដែរ។

## របត់នយោបាយ

ព្រះមហាក្សត្រនរោត្តម សីហនុ បានសារភាពដោយស្មោះត្រង់ថា រយៈពេល១១ឆ្នាំ ចាប់ពីពេលព្រះអង្គឡើងគ្រងរាជសម្បត្តិមក ព្រះអង្គភ្លក្សរសជាតិស្រីផ្សេងៗគ្នា សរុបទាំងអស់ ១៩នាក់។

# ១៣
# ចលនាតស៊ូសឹង ង៉ុកថាញ់ និងអាចារ្យហែម ចៀវ



សឺង ង៉ុកថាញ់



អាចារ្យហែម ចៀវ

នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៤១ ជាថ្ងៃខួបកំណើតលើកទី៥១ របស់ហូ ជីមិញ បក្សកុម្មុយនិស្ត ឥណ្ឌូចិន បានបើកមហាសន្និបាតគណៈកម្មាធិការមជ្ឈិមបក្សរបស់ខ្លួនលើកទី៨ នៅតុងកឹង។

ពេលនោះ ហូ ជីមិញ ដែលទើបវិលចូលប្រទេសវិញ បានប្រកាសបង្កើតចលនាតស៊ូមួយឈ្មោះសម្ព័ន្ធដើម្បីឯករាជ្យវៀតណាម ហៅកាត់ថា វៀតមិញ (Việt Minh) និងបានសម្រេចបង្កើតសម្ព័ន្ធដើម្បីឯករាជ្យកម្ពុជា និងសម្ព័ន្ធដើម្បីឯករាជ្យឡាវ ផងដែរ។ពិសេសគ្រោងបង្កើតរណសិរ្សជាតិរបស់ប្រទេសទាំង៣ ដាច់ដោយឡែកពីគ្នា និងគ្រោងបង្កើតសហព័ន្ធដើម្បីឯករាជ្យឥណ្ឌូចិន ទៀតផង។

ចាប់ពីពេលនោះមក នៅកម្ពុជា ចលនាតស៊ូដែលឲ្យឈ្មោះថា ខ្មែរឥស្សរៈ ត្រូវបានបង្កើតឡើងជាច្រើនក្រុម ដោយក្រុមខ្លះមានពួកវៀតមិញ ជាអ្នកគាំទ្រ, ក្រុមខ្លះមានថៃ ជា

អ្នកគាំទ្រ និងមានក្រុមឯករាជ្យផ្សេងៗទៀត ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងបារាំង ហើយក្នុងនោះក៏មានក្រុមជនខិលខូច ដូចជាពួកអ្នកលេងកាប់ចាក់, ពួកចោរលួច ចោរប្លន់មួយចំនួន ក៏បន្លំខ្លួនជាក្រុមខ្មែរឥស្សរៈនេះដែរ។

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៤១ រដ្ឋាភិបាលវីឈី របស់បារាំង (រដ្ឋាភិបាលក្រោមការត្រួតត្រារបស់អាល្លឺម៉ង់) និងរដ្ឋាភិបាលជប៉ុន បានចុះហត្ថលេខាលើសន្ធិសញ្ញាកិច្ចសហប្រតិបត្តិការរួមមួយ ដោយបារាំង អនុញ្ញាតឲ្យកងទ័ពជប៉ុន មានសិទ្ធិចូលមកឈប់សំចតដោយគ្មានលក្ខខណ្ឌ និងអាចប្រើប្រាស់មូលដ្ឋានអាកាសចរណ៍របស់បារាំង នៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសវៀតណាមភាគខាងត្បូង។

ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៤១ ជប៉ុនបានទាមទារឲ្យកងទ័ពខ្លួនមានសិទ្ធិចេញចូលតំបន់តុងកឹង (វៀតណាមភាគខាងជើង) ដែលបារាំងកំពុងត្រួតត្រានោះ ដោយសេរី និងអាចប្រើប្រាស់ព្រលានយន្តហោះតុងកឹង នោះទៀតផង។

លុះដល់ពាក់កណ្តាលខែសីហា ឆ្នាំ១៩៤១ កងទ័ពជប៉ុន បានចូលមកបោះទីតាំងនៅក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងទីក្រុងព្រៃនគរ នៅកូសាំងស៊ីន ហើយមូលដ្ឋានកងទ័ពជើងទឹកបារាំង នៅទីតាំងកាំរ៉ាញ់ ក៏ត្រូវកងទ័ពជប៉ុន ធ្វើសកម្មភាពយ៉ាងពេញទំហឹងដែរ។

និយាយរួម ពេលនោះឥណ្ឌូចិន ដែលបារាំងកំពុងត្រួតត្រាបានក្លាយជាមូលដ្ឋានដ៏សំខាន់របស់កងទ័ពជប៉ុន សម្រាប់ប្រើប្រាស់ធ្វើជាឈ្នាន់ដើម្បីវាយលុកទៅលើប្រទេសផ្សេងៗទៀត ដែលនៅក្នុងតំបន់។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៤១ បារាំង និងជប៉ុន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្តីពីការផ្លាស់ប្តូរសេដ្ឋកិច្ចគ្នានៅក្នុងតំបន់ឥណ្ឌូចិន តាមរយៈឯកអគ្គរដ្ឋទូតបារាំង ឈ្មោះឌីសាំង ពិនតាំង ជាថ្នូរនឹងការទទួលស្គាល់បារាំង ជាអាណាព្យាបាលនៅឥណ្ឌូចិន ដដែល។ ប៉ុន្តែឧត្តមនាវីហ្សង់ ដឺគូ អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន មិនពេញចិត្តកិច្ចព្រមព្រៀងនេះទេ។ ដូច្នេះជប៉ុន ក៏បានរៀបចំកងទ័ពត្រៀមធ្វើការទប់ទល់



**ជប៉ុន លើកកងទ័ពចូលមកក្នុងតំបន់ឥណ្ឌូចិន**

ខ្លាចក្រែងមានការវាយប្រហារណាមួយពីកងទ័ពបារាំងដែរ។

នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៤១ កងទ័ពជប៉ុន មួយកងវរសេនាតូច បានឆ្លងព្រំដែនចិន ចូលមកក្បែរក្រុងឡាងសឺង នៅវៀតណាភាគខាងជើង។ ២សប្តាហ៍ក្រោយមកទៀត កងទ័ពជប៉ុន ក៏បានធ្វើការឡោមព័ទ្ធកងទ័ពជើងគោក និងជើងទឹកបារាំង នៅតុងកឹង ហើយបង្ខំឲ្យឧត្តមនាវីហ្សង់ ដឺគូ ចុះកិច្ចព្រមព្រៀងជាមួយឧត្តមសេនីយ៍ជប៉ុន ជាមេបញ្ជាការនៅឥណ្ឌូចិននោះ ដើម្បីឲ្យកងទ័ពជប៉ុន ឆ្លងកាត់ និងចេញចូលតំបន់តុងកឹង ដោយសេរីទាល់តែបាន។

កិច្ចព្រមព្រៀងនេះ បានប្រព្រឹត្តនៅទីក្រុងហៃហ្វុង (វៀតណាមខាងជើង) នាថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ១៩៤១ ហើយកងទ័ពជប៉ុនចំនួន៦០០០នាក់ បានចូលបោះទីតាំងនៅខាងជើងទន្លេក្រហម និងមានសិទ្ធិប្រើប្រាស់ព្រលានយន្តហោះ៣កន្លែងទៀតនៅតុងកឹងនោះទៀតផង។

បន្ទាប់មកទៀត នៅក្នុងខែឧសភា ឆ្នាំ១៩៤១ កងទ័ពរបស់ព្រះចៅអធិរាជជប៉ុន

បានឆ្លងដែនពីប្រទេសថៃ ចូលមកដល់ក្រុងភ្នំពេញ ហើយបានតាំងបញ្ជាការដ្ឋានមួយនៅក្បែរប៉ុស្តិ៍ប្រៃសណីយ៍ដែលនៅមិនឆ្ងាយពីរមណីយដ្ឋានវត្តភ្នំ។

ពេលនោះ សិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ បាននាំគ្នាធ្វើកូដកម្មប្រឆាំងតវ៉ាចំពោះបារាំងដែលបង្ខំឱ្យពួកគេជាសិស្សបង់ពន្ធនោះជាថ្មីម្តងទៀត។

ពួកបារាំង យល់ច្រឡំថា ប្រជារាស្ត្រខ្មែរជាជនជាតិស្បែកលឿង ស្រឡាញ់ជប៉ុនដែលជាជនជាតិស្បែកលឿងដូចគ្នា ជាងពួកខ្លួន។

ដោយសារការចោទប្រកាន់ថា បានរួមសហការជាមួយកងទ័ពជប៉ុន បងប្រុសម្នាក់របស់ហួត សម្បត្តិ ត្រូវស័ក្តិ៤បារាំងម្នាក់ឈ្មោះហ្គាលឡ័រ (Gallois) ចាប់យកទៅឃុំទុកនៅក្នុងបន្ទាយ វាយធ្វើទារុណកម្ម រហូតដល់ស្លាប់។

ដោយសារការចោទប្រកាន់ដូចគ្នានេះ នៅខេត្តបាត់ដំបង ក៏មានគ្រូបង្រៀនម្នាក់ត្រូវពួកបារាំង ចាប់យកទៅវាយធ្វើទារុណកម្ម រហូតដល់ស្លាប់ដែរ។

ពេលនោះ សឺង ង៉ុកថាញ់ កាន់តែបញ្ចេញសកម្មភាពដឹកនាំចលនាប្រឆាំងនឹងបារាំងខ្លាំងឡើងៗ ហើយកាសែត "នគរវត្ត" របស់គាត់បានសរសេរបំផុសឲ្យប្រជារាស្ត្រខ្មែរងើបឡើងតស៊ូដណ្តើមឯករាជ្យពីបារាំង មកវិញ។ តែកាសែតនេះបានសរសេរលើកសរសើរជប៉ុនផងដែរ។

ចលនាតស៊ូរបស់សឺង ង៉ុកថាញ់ ត្រៀមប្រកាសឯករាជ្យ ដោយសង្ឃឹមថា ពួកយោធាជប៉ុន នឹងគាំទ្រគាត់ជាមិនខាន។ ប៉ុន្តែនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤១នោះ ដោយមានការគាំទ្រពីពួកយោធាជប៉ុន ផងដែរ ប្រទេសថៃ បានលើកទ័ពចូលមកដណ្តើមយកទឹកដីខេត្តបាត់ដំបង ខេត្តកំពង់ធំ (មួយភាគ) និងខេត្តសៀមរាប ដោយទុកតែតំបន់អង្គរ និងក្រុងសៀមរាប ឲ្យបារាំងគ្រប់គ្រងសិន។

នៅទីបំផុត សឺង ង៉ុកថាញ់ និងសហការីគាត់ជាច្រើនទៀត ត្រូវបារាំងតាមចាប់ខ្លួន។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤២ មេគិញបារាំងម្នាក់ អមដំណើរដោយលេខាធិការ (ស្មៀន) ខ្មែរ២នាក់ទៀត បានកាន់សំណុំរឿងមួយបាច់ធំ យកទៅជួបប្រជុំជាមួយអ៊ឹង អ៊ី

ជានាយករដ្ឋមន្ត្រី និងទា សាន ជារដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ ព្រមទាំងមន្ត្រីខ្មែរមួយចំនួនទៀត។

ក្រោយកិច្ចប្រជុំនោះចប់ ទា សាន ជារដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ បានបញ្ជាជុំ មួង ដែលជាលេខាធិការរបស់គាត់ ឲ្យទៅនិមន្តលោកគ្រូអាចារ្យហែម ចៀវ ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់គង់នៅវត្តឧណ្ណាលោម និងជាសិស្សគណសំណព្វចិត្តរបស់សម្ដេចព្រះសង្ឃរាជជួន ណាត ដែលកាលនោះ ព្រះអង្គទើបមានឋានៈជាព្រះពុទ្ធឃោសាចារ្យនៅឡើយ ឲ្យមកជួប ព្រោះមានបញ្ហាសំខាន់ ដើម្បីជួបពិភាក្សាគ្នាបន្ទាន់។

ពេលលោកគ្រូអាចារ្យហែម ចៀវ ចូលទៅដល់ក្នុងការិយាល័យភ្លាម រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ រូបនេះ ក៏បានប្រើមន្ត្រីក្រោមឱវាទឲ្យទៅទិញសម្លៀកបំពាក់មួយកំប្លេ ហើយឲ្យលោកគ្រូអាចារ្យ ហែម ចៀវ ស្រាតស្បង់ចីវរចេញ រួចស្លៀកពាក់ខោអាវនោះវិញ ។

បន្ទាប់មក ពួកគិញបារាំង ក៏បាននាំគ្នាទៅចាប់មេដឹកនាំចលនាប្រឆាំងនឹងបារាំងម្នាក់ទៀត ឈ្មោះនួន ឌួង ដល់ផ្ទះរបស់គាត់ផងដែរ។

ក្រោយពីពួកបារាំង នាំលោកគ្រូអាចារ្យហែម ចៀវ ចេញទៅបាត់ពីការិយាល័យរបស់រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ ជុំ មួង ជាលេខាធិការ កាន់តែភិតភ័យខ្លាំងថែមទៀត ព្រោះគាត់ក៏មានជាប់ពាក់ព័ន្ធជាមួយព្រះគ្រូអាចារ្យហែម ចៀវ ក្នុងសកម្មភាពដឹកនាំចលនាប្រឆាំងនឹងបារាំង ដែរ។

លុះដល់ម៉ោងចេញពីធ្វើការ ជុំ មួង ក៏ប្រញាប់ប្រញាល់ធ្វើដំណើរទៅជួបសឹង ង៉ុកថាញ់ ដើម្បីប្រាប់ឲ្យបានដឹងពីរឿងនេះ ។

សឹង ង៉ុកថាញ់ ក៏បានប្រាប់ជុំ មួង វិញថា ប្រយ័ត្នឲ្យមែនទែន ពេលនេះបារាំងប្រាកដជាតាមចាប់ពួកយើងបន្តទៀតហើយ។

មួយថ្ងៃក្រោយមក ដំណឹងនៃការចាប់ខ្លួនលោកគ្រូអាចារ្យហែម ចៀវ បានលេចឮពីវត្តមួយទៅវត្តមួយទៀត និងពីមជ្ឈដ្ឋានពុទ្ធបរិស័ទមួយទៅមជ្ឈដ្ឋានពុទ្ធបរិស័ទមួយទៀត ធ្វើឲ្យភ្ញាក់ផ្អើលជ្រួលច្របល់កាន់តែខ្លាំងឡើងៗ ពិសេសក្នុងមជ្ឈដ្ឋានជាមិត្តភក្តិ និងសិស្ស



**ព្រះសង្ឃខ្មែរសម័យអាណានិគមបារាំង**

គណរបស់លោកគ្រូអាចារ្យតែម្តង។ ពួកគេចាត់ទុកថា ការចាប់ខ្លួនលោកគ្រូអាចារ្យហែម ចៀវ យកទៅក្រសួងមហាផ្ទៃ និងធម្មការ សម្រាតស្បង់ចីវរផ្សឹកបែបនេះ គឺជាការប្រមាថដល់ព្រះពុទ្ធសាសនាយ៉ាងធ្ងន់ធ្ងរបំផុត។

សឺង ង៉ុកថាញ់ បានបញ្ជាឲ្យប៉ាច ឈឺន រៀបចំធ្វើបាតុកម្មទាមទារឲ្យអាជ្ញាធរបារាំងដោះលែងលោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង មកវិញ។ ប៉ុន្តែ សឺង ង៉ុកថាញ់ មិនបានទៅចូលរួមក្នុងបាតុកម្មនោះទេ ព្រោះដឹងច្បាស់ថា ពួកគិញបារាំង កំពុងតាមរកចាប់ខ្លួនគាត់ដែរ ក៏គេចខ្លួនទៅស្នាក់នៅក្នុងបន្ទាយតម្រួតយោធាជប៉ុន ដើម្បីកុំឲ្យពួកគិញបារាំងតាមរកចាប់គាត់។

លុះវេលាម៉ោង៦ព្រឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ ព្រះសង្ឃដែលភាគច្រើនលើសលប់និមន្តមកពីវត្តលង្កា និងវត្តឧណ្ណាលោម ប្រមាណ៥០០អង្គ ព្រមទាំងគ្រហស្ថប្រមាណ៥០០នាក់ទៀត សរុបទាំងអស់ប្រមាណ ១០០០ អង្គ/នាក់ បានមកជួបជុំគ្នានៅខាងក្រោយព្រះបរមរាជវាំង ។

ដោយមានប៉ាច ឈឺន ជាអ្នកនាំមុខ ក្រុមបាតុករក៏បានចាប់ផ្តើមហែក្បួនតាមផែនការ

របស់សឹង ង៉ុកថាញ់ ដោយចាប់ផ្ដើមចេញដំណើរពីក្រោយព្រះបរមរាជវាំង តាមវិថីឌូដា ដឺឡាហ្គ្រេ (Doudart de Lagrée, សព្វថ្ងៃ ជាមហាវិថីព្រះនរោត្តម) ឆ្ពោះទៅការិយាល័យទេសាភិបាលជាន់ខ្ពស់បារាំង ដែលនៅខាងលិចវត្តភ្នំ តាមការគ្រោងទុក។

នៅតាមផ្លូវគ្មានការរារាំងអ្វី ក្រៅតែពីឃើញពួកគិញបារាំង គិញខ្មែរ និងគិញវៀតណាម តាមឃ្លាំមើលប៉ុណ្ណោះ។

ពេលក្បួនបាតុកម្ម ធ្វើដំណើរទៅឈប់នៅមុខអគារការិយាល័យទេសាភិបាលជាន់ខ្ពស់បារាំង ខាងលិចវត្តភ្នំ ប៉ាច ឈឺន ដែលជាអ្នកនាំមុខបាតុករ បានចូលទៅជួបមន្ត្រីបារាំង ៣-៤ នាក់ ដែលឈរនៅមាត់ជណ្ដើរឡើងទៅជាន់លើ រៀបរាប់ពីគោលបំណងនៃការធ្វើបាតុកម្មស្នើសុំឲ្យអាជ្ញាធរបារាំង ដោះលែងលោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង និងសុំជួបពិភាក្សាបញ្ហានេះជាមួយទេសាភិបាលជាន់ខ្ពស់បារាំង ដោយផ្ទាល់តែម្ដង។

មន្ត្រីបារាំងទាំងនោះ ក៏ប្រាប់ប៉ាច ឈឺន វិញថា តំណាងបាតុករ២ ឬ៣នាក់ អាចអនុញ្ញាតឲ្យចូលជួបទេសាភិបាលជាន់ខ្ពស់បាន។

ឮដូច្នេះ ក្រុមបាតុករដែលនៅឯមាត់របង ចាប់ផ្ដើមស្រែកថា ចូលទៅ២ ឬ៣នាក់មិនបានទេ ពួកបារាំងប្រាកដជាចាប់ខ្លួនជាមិនខាន។

បន្ទាប់មក ក្រុមបាតុករនាំគ្នាសម្រុកចូលទៅខាងក្នុង តែត្រូវពួកបារាំងទាញទ្វាររបងបិទជិត មិនឲ្យចូល រួចហើយចាប់ប៉ាច ឈឺន ដែលនៅខាងក្នុងស្រាប់ យកទៅខាងក្រោយអគារការិយាល័យទេសាភិបាលជាន់ខ្ពស់បារាំងនោះ បង្ខំឲ្យឡើងលើរថយន្តមួយគ្រឿង រួចបើកចេញទៅតាមទ្វារក្រោយបាត់ទៅ។

ពេលនោះ អំពើហិង្សាក៏ចាប់ផ្ដើមផ្ទុះឡើង ដោយកម្លាំងប៉ូលិសប្រើដំបងវាយទៅលើក្រុមបាតុករទាំងគ្រហស្ថ ទាំងព្រះសង្ឃ ដើម្បីរាំងកុំឲ្យចូលទៅក្នុងបរិវេណការិយាល័យទេសាភិបាលជាន់ខ្ពស់បារាំង នោះបាន។

ឯក្រុមបាតុករក៏បានប្រើដំបង ដុំថ្ម និងកូនតឹង ពិសេសព្រះសង្ឃបានប្រើដងឆត្រធ្វើជាអាវុធវាយ និងចាក់ទៅលើកម្លាំងប៉ូលិសវិញ បណ្ដាលឲ្យរងរបួសទាំងសងខាងជាច្រើន

នាក់ ក្នុងនោះ គេឃើញមេគិញបារាំង ឈ្មោះប្រ៉ូស្ទីតុង បែកក្បាលឈាមហូរជោកអាវសើមីស ដោយសារត្រូវនឹងកូនតឹងរបស់ពួកបាតុករ។

ភ្លាមៗនោះដែរ អាជ្ញាធរបារាំងក៏បានបញ្ជូនកម្លាំងទាហានជើងក្រហមជាច្រើនរយនាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ មកជួយកម្លាំងប៉ូលិស ដើម្បីទប់ស្កាត់ និងចាប់បានបាតុករជាច្រើននាក់ ។ ចំណែកបាតុករផ្សេងៗទៀតនាំគ្នារត់គេចប្រសេចប្រសាចតែរៀងៗខ្លួន។

ពេលនោះដែរ កងទ័ពជប៉ុន ចំនួន២រថយន្តបានមកនៅក្បែរកន្លែងកើតហេតុនោះដែរ ប៉ុន្តែមិនបានជួយធ្វើអន្តរាគមន៍ជួយដល់ក្រុមបាតុករទេ ដោយសារតែបាតុកម្មនោះបានក្លាយជាអំពើហិង្សា ខុសការគ្រោងទុករបស់ពួកគេ ដែលបានពិភាក្សាឯកភាពគ្នាជាមួយសឹង ង៉ុកថាញ់ ហើយថា កុំឲ្យប្រើអំពើហិង្សា តែពួកបាតុករបានប្រើអំពើហិង្សារួចទៅហើយ។

ទោះបីជាក្រុមបាតុករបានរត់បែកខ្ញែកគ្នាអស់ទៅហើយក្តី ក៏ពួកបារាំងមិនលើកលែងដែរ ពួកគេនៅតែតាមចាប់ពួកបាតុករបានជាបន្តបន្ទាប់ ព្រោះស្គាល់ឈ្មោះ ស្គាល់មុខ និងមានរូបថតជាភ័ស្តុតាងទៀតផង។

លើសពីនេះទៅទៀត ទោះបីអ្នកនោះមិនចូលរួមធ្វើបាតុកម្មក៏ដោយ ឲ្យតែមានឈ្មោះចូលរួមជាមួយចលនាតស៊ូជាមួយសឹង ង៉ុកថាញ់ ក៏ត្រូវតែចាប់ខ្លួនដែរ។

រយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ បារាំងបានចាប់ពួកបាតុករ និងអ្នកចូលរួមជាមួយចលនាតស៊ូជាមួយសឹង ង៉ុកថាញ់ បានជិត២០០នាក់។

ថ្ងៃធ្វើបាតុកម្ម ២០ កក្កដា នោះ ជុំ មួង ដែលជាលេខាធិការរបស់រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ ខ្លាចបែកការ មិនហ៊ានទៅចូលរួមធ្វើបាតុកម្មទេ គាត់ទៅធ្វើការនៅការិយាល័យដូចធម្មតា តែគាត់ក៏នៅមិនសុខដែរ ។

វេលាទៀបភ្លឺ ឈានចូលថ្ងៃទី២១ ខែកក្កដា ជុំ មួង បានសរសេរសំបុត្រសុំច្បាប់ ផ្ញើទុកឲ្យគេជួយយកទៅដាក់នៅកន្លែងធ្វើការឯក្រសួងមហាផ្ទៃ និងធម្មការ ដោយកុហកថា សុំច្បាប់ទៅសួរសុខទុក្ខបងប្អូនមានជំងឺជាទម្ងន់នៅឯខេត្តបាត់ដំបង ដែលថៃ កំពុងកាន់កាប់នោះ ។

ពេលទៅដល់ខេត្តពោធិ៍សាត់ ជុំ មួង ឃើញគិញបារាំង ចាប់បានព្រះសង្ឃជាបាតុករ ២-៣អង្គ ដែលមានបំណងរត់គេចខ្លួនទៅប្រទេសថៃ បញ្ជូនមកក្រុងភ្នំពេញ វិញដែរ។

ពេលនោះដែរ មានព្រះសង្ឃជាច្រើនអង្គទៀត ក៏នាំគ្នាគេចខ្លួនទៅខេត្តផ្សេងៗរៀងៗខ្លួន ក្នុងនោះមានព្រះសង្ឃមួយអង្គគង់នៅវត្តឧណ្ណាលោម ព្រះនាមព្រះគ្រូអាចារ្យ មៀន ជាគ្រូបង្រៀននៅសាលាបាលីជាន់ខ្ពស់ដែរនោះ ក៏បានរត់គេចទៅសំងំលាក់ខ្លួនក្នុងវត្តយាយទេព ក្នុងខេត្តកំពង់ឆ្នាំង ហើយបានទាក់ទងសម្ងាត់ជាមួយសាខាបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលកំពុងធ្វើសកម្មភាពនៅក្នុងខេត្តបាត់ដំបង។

ក្រោយមក ព្រះគ្រូអាចារ្យ មៀន នេះ បានក្លាយជាមេដឹកនាំខ្មែរកុម្មុយនិស្ត និងបានដូរឈ្មោះជា សឹង ង៉ុកមិញ វិញ។

ដោយឡែក លោកគ្រូអាចារ្យប៉ាង ខាត់ ដែលបានចូលរួមធ្វើបាតុកម្មដែរនោះ ទោះបីភ័យខ្លួន និងរត់ទៅលាក់ខ្លួន ពួនសំងំក្នុងវត្តពិភទ្ធវង្សី (វត្តចិនដំដែក នៅខាងជើងវត្តភ្នំ) ហើយក៏ដោយ ក៏នៅទីបំផុត បែរជាសម្រេចចិត្តនិមន្តទៅឲ្យបារាំង ចាប់ដោយស្រួលនៅឯក្រសួងមហាផ្ទៃ និងធម្មការ ។


ព្រះភិក្ខុ ប៉ាង ខាត់

ព្រះភិក្ខុ ប៉ាង ខាត់ ប្រសូត្រ រវាងឆ្នាំ ១៩១០ នៅភូមិភ្នំដិល ស្រុកបាធាយ ក្នុងខេត្តកំពង់ចាម។ ឪពុកឈ្មោះប៉ាង និងម្តាយឈ្មោះ អ៊ុង។

ពេលធំដឹងក្តី បានបួសរៀនក្នុងសំណាក់ពុទ្ធសាសនា រហូតបានប្រឡងជាប់ចូលរៀន នៅសាលាបាលីជាន់ខ្ពស់ ។

## របត់នយោបាយ

បន្ទាប់ពីបញ្ចប់ការសិក្សានៅសាលាបាលីជាន់ខ្ពស់ ភិក្ខុប៉ាង ខាត់ បានក្លាយជាសាស្ត្រាចារ្យភាសាបាលី ជាដំបូងនៅវត្តប្រាង្គ ក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

បន្ទាប់មកទៀត ភិក្ខុប៉ាង ខាត់ បានប្រឡងជាប់ចូលរៀនជាសាស្ត្រាចារ្យបាលីជាន់ខ្ពស់ នៅក្រុងភ្នំពេញ ហើយបានមកស្នាក់នៅកុដិព្រះពោធិវង្ស ហួត តាត ក្នុងវត្តឧណ្ណាលោម។

ដោយមានចរិតជាសង្ឃជឿនលឿននិយម ឯករាជ្យនិយម ចង់ឲ្យប្រទេសជាតិរួចផុតពីការត្រួតត្រាកាន់កាប់របស់ពួកអាណានិគមបារាំង ភិក្ខុប៉ាង ខាត់ ក៏ដូចជាលោកគ្រូអាចារ្យហែម ចៀវ, លោកគ្រូអាចារ្យ ខៀវ ជុំ (វត្តលង្កា), លោកគ្រូអាចារ្យ សួរ ហាយ និងលោកគ្រូអាចារ្យអ៊ុក ជា ជាដើមដែរ គឺបានចូលរួមក្នុងចលនាតស៊ូជាមួយស៊ឹង ង៉ុកថាញ់ និងបានចូលរួមដឹកនាំធ្វើបាតុកម្មប្រឆាំងនឹងអាណានិគមបារាំង នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ នោះដែរ ។

បន្ទាប់មក ពួកបារាំង ក៏ចាប់ខ្លួនប៉ាច ឈឺន និងប៊ុណ្ណ ចន្ទម៉ុល ដែលពួកគេចាត់ទុកថាជាមេខ្លោងធ្វើបាតុកម្មនោះ យកទៅធ្វើទារុណកម្មដើម្បីសួរចម្លើយ។

ប៉ាច ឈឺន , ប៊ុណ្ណ ចន្ទម៉ុល និងលោកគ្រូអាចារ្យប៉ាង ខាត់ ត្រូវបារាំងបញ្ជូនទៅជាមួយលោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង យកទៅដាក់គុកជាបណ្ដោះអាសន្ននៅក្រុងព្រៃនគរ ដើម្បីឲ្យតុលាការសឹកបារាំង កាត់ទោសតាមច្បាប់ ។

អ្នកទោសខ្មែរទាំង៥នាក់នេះ ត្រូវតុលាការសឹករបស់បារាំង បើកសវនាការជំនុំជម្រះម្នាក់ម្ដងៗ។ តែអាចារ្យប៉ាង ខាត់ ត្រូវតុលាការសឹកបារាំង សម្រេចឲ្យរួចខ្លួន បានបញ្ជូនឲ្យវិលត្រឡប់ទៅទីក្រុងភ្នំពេញ វិញ។

ដោយឡែក លោកគ្រូអាចារ្យហែម ចៀវ, នួន ឌួង, ប៉ាច ឈឺន និងប៊ុណ្ណ ចន្ទម៉ុល ត្រូវតុលាការសឹក បើកសវនាការជាចុងក្រោយ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤២ ។

មុនដំបូង ក្រឡាបញ្ជីបារាំង បានឡើងធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទទាំង៤នាក់នោះ ម្នាក់ម្ដងៗ។

បន្ទាប់មកលោកស័ក្តិ៥បារាំងម្នាក់ដែលជាប្រធានអង្គជំនុំជម្រះបានសួរដេញដោល

ដល់ជនជាប់ចោទម្នាក់ម្តងៗបន្តទៀត។

លុះសួរចប់ ទើបស័ក្តិ៣បារាំងម្នាក់ទៀត ជាតំណាងព្រះរាជអាជ្ញា បានឡើងមក បង្ហាញភ័ស្តុតាង ដើម្បីដាក់បន្ទុកដល់ជនជាប់ចោទ។

បន្ទាប់មកទៀត មេធាវីម្នាក់ដែលជាជនជាតិបារាំងដែរនោះ បានឡើងលើកហេតុផល ផ្សេងៗការពារ និងសុំឲ្យតុលាការដោះលែងជនជាប់ចោទខ្មែរទាំង៤នាក់នេះ ឲ្យវិលត្រឡប់ ទៅប្រទេសកម្ពុជាវិញ។

ទីបំផុត ស័ក្តិ៥បារាំង ដែលជាប្រធានអង្គជំនុំជម្រះ ក៏បានសួរទៅជនជាប់ចោទ ទាំងអស់ថា តើពួកអ្នកទាំងអស់គ្នាមានអ្វីដែលត្រូវតវ៉ាដែរឬទេ ? ជនជាប់ចោទខ្មែរទាំងអស់ ឆ្លើយថា គ្មានអ្វីតវ៉ាទៀតទេ ទើបអង្គជំនុំជម្រះទាំងមូលនាំគ្នាចូលបន្ទប់ខាងក្នុង ដើម្បីពិគ្រោះ យោបល់គ្នាជាសម្ងាត់។ លុះចេញមកវិញ ក៏ចាប់ផ្តើមប្រកាសសាលក្រម ដោយមានអ្នក បកប្រែភាសាខ្មែរម្នាក់ជាជំនួយការ។

ជាដំបូង ស័ក្តិ៥ជាប្រធានអង្គជំនុំជម្រះ បានហៅឈ្មោះប៉ាច ឈឺន មុនគេ ហើយ ប្រកាសថា៖ "អ្នកឯង! ត្រូវផ្តន្ទាទោសប្រហារជីវិត"។ បន្ទាប់មក ក៏ហៅឈ្មោះលោកគ្រូ អាចារ្យហែម ចៀវ ហើយប្រកាសថា៖ "អ្នកឯង! ត្រូវផ្តន្ទាទោសប្រហារជីវិត" ។ បន្ទាប់មក ទៀត គឺឈ្មោះនួន ឌួង ក៏ប្រកាសថា" អ្នកឯង! ក៏ត្រូវផ្តន្ទាទោសប្រហារជិវីតដែរ " ។ ចុងក្រោយ គឺដល់វេនប៊ុណ្ណ ចន្ទម៉ុល តែប្រធានអង្គជំនុំជម្រះប្រកាសថា អ្នកឯងត្រូវជាប់គុក៥ឆ្នាំ និង និរទេសមិនឲ្យចូលស្រុកវិញ១៥ឆ្នាំទៀត។

តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ស័ក្តិ៥បារាំងជាប្រធានអង្គជំនុំជម្រះនោះ បាន បញ្ជាក់ប្រាប់លោកគ្រូអាចារ្យហែម ចៀវ, នួន ឌួង និងប៉ាច ឈឺន ដែលត្រូវផ្តន្ទាទោស ប្រហារជីវិតនោះថា លោកនឹងបញ្ជូនសំណុំរឿងកាត់ទោសប្រហារជីវិតនេះទៅជូនសេនាប្រមុខ ប៉េតាំង នាយករដ្ឋមន្ត្រីបារាំង ដើម្បីសុំឲ្យបន្ធូរបន្ថយទោសដែរ។

បន្ទាប់ពីជាប់គុកធំនៅព្រៃនគរ អស់រយៈពេលជាង២ខែ និងក្រោយពីត្រូវតុលាការ សឹកប្រកាសសាលក្រមផ្តន្ទាទោសរួចមក ប៊ុណ្ណ ចន្ទម៉ុល ជាមួយអ្នកទោសខ្មែរ និងវៀតណាម



នួន ឌួង

មួយចំនួនទៀត ត្រូវបានគេដឹកតាមកប៉ាល់មួយគ្រឿង យកទៅដាក់គុកនៅកោះត្រឡាច ដែលនៅកណ្តាលសមុទ្រឯណោះវិញ។

ចំណែកលោកគ្រូអាចារ្យហែម ចៀវ, នួន ឌួង និងប៉ាច ឈឺន ត្រូវជាប់នៅក្នុងគុកធំ នាទីក្រុងព្រៃនគរ បន្តទៀត ដើម្បីរង់ចាំការសម្រេចពីសេនាប្រមុខប៉េតាំង នាយករដ្ឋមន្ត្រីបារាំង តាមការស្នើសុំរបស់តុលាការសឹកបារាំងនៅក្រុងព្រៃនគរ សិនថា តើត្រូវយកទៅប្រហារជីវិត ឬត្រូវបន្ធូរបន្ថយទោស?

ដោយឡែក សឺង ង៉ុកថាញ់ ក្រោយពីមានការបង្ក្រាបព្រះសង្ឃរបស់បារាំងនោះ គាត់បានផ្ញើលិខិតជាច្រើនទៅសេនាធិការដ្ឋានកងទ័ពជប៉ុន នៅឯក្រុងព្រៃនគរ ដើម្បីសុំឲ្យបញ្ជូនកងទ័ពជប៉ុនមកផ្តួលរំលំពួកបារាំង នៅភ្នំពេញដែរ តែសេនាធិការដ្ឋានកងទ័ពជប៉ុន នៅក្រុងព្រៃនគរនោះ មិនអាចធ្វើបានតាមការចង់បានរបស់គាត់ឡើយ។

បន្ទាប់មក គាត់ត្រូវបានកងទ័ពជប៉ុន ជួយជម្លៀសចេញពីក្រុងភ្នំពេញ ទៅខេត្តបាត់ដំបង រួចបន្តដំណើរទៅប្រទេសថៃ ទៀត។

នៅទីក្រុងបាងកក សឺង ង៉ុកថាញ់ បានផ្ញើលិខិតមួយ ទៅនាយករដ្ឋមន្ត្រីជប៉ុន ហ៊ីដឺគី តូហ្សូ (Hideki Tojo) ឲ្យជួយធ្វើអន្តរាគមន៍ឲ្យបារាំងដោះលែងអ្នកទោសខ្មែរដែលបារាំងចាប់ខ្លួន ក្រោយពេលធ្វើបាតុកម្មថ្ងៃទី២០ ខែកក្កដា នោះជាបន្ទាន់ និងសូមឲ្យកងទ័ពព្រះចៅអធិរាជជប៉ុន ជួយរៀបចំប្រទេសកម្ពុជាឡើងវិញ ដោយសហការគ្នាយ៉ាងជិតស្និទ្ធបំផុតលើវិស័យសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ព្រមទាំងសូមឲ្យជប៉ុន ជួយធ្វើការផ្លាស់

ប្តូររបៀបរបបដឹកនាំប្រទេស ដោយបង្កើតរដ្ឋាភិបាលថ្មីមួយ។

ជាមួយគ្នានេះដែរ សឺង ង៉ុកថាញ់ បានផ្ញើលិខិតមួយទៀត មកអគ្គកុងស៊ុលជប៉ុននៅទីក្រុងភ្នំពេញ មានខ្លឹមសារថា ប្រសិនបើមេដឹកនាំជប៉ុន យល់ព្រមជួយរៀបចំការគ្រប់គ្រងប្រទេសកម្ពុជាឡើងវិញនោះ គាត់នឹងចាប់ផ្តើមធ្វើសង្គ្រាមឈ្លប បង្កភេរវកម្ម និងបាចខិត្តប័ណ្ណប្រឆាំងនឹងបារាំងភ្លាម។ ប៉ុន្តែមេដឹកនាំជប៉ុន មិនបានឆ្លើយតបមកគាត់វិញថាយ៉ាងណានោះទេ។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៤៣ សឺង ង៉ុកថាញ់ បានជិះយន្តហោះកងទ័ពជប៉ុនចាកចេញពីទីក្រុងបាងកក ប្រទេសថៃ ទៅដល់ទីក្រុងតូក្យូ ប្រទេសជប៉ុន ។

រយៈពេល៤ថ្ងៃក្រោយមក គាត់បានផ្ញើសារមកអ្នកគាំទ្រគាត់នៅក្នុងប្រទេសថា ពួកយើងមានតែរង់ចាំជ័យជម្នះរបស់កងទ័ពជប៉ុន នៅអាស៊ីនេះទេ ទើបអាចដោះស្រាយបញ្ហាកម្ពុជាយើងបាន។

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៤៣ សឺង ង៉ុកថាញ់ បានសរសេរលិខិតមួយទៀត ផ្ញើមកសហការីរបស់គាត់ដែលកំពុងតស៊ូនៅក្នុងប្រទេសថា យើងត្រូវសហការគ្រប់ផ្នែកជាមួយកងទ័ពជប៉ុន ដែលនៅក្នុងប្រទេស។ យើងត្រូវបង្ហាញឲ្យជប៉ុន ឃើញថា សត្រូវរបស់យើងម្ខាងគឺបារាំង និងម្ខាងទៀត គឺថៃ ហើយអ្នកដែលគាំទ្រយើង ឬអ្នកជួយរំដោះយើង មានតែជប៉ុន ប៉ុណ្ណោះ។ យើងចង់ឲ្យជប៉ុនជួយ ព្រោះគោលនយោបាយជប៉ុន គឺជាសហប្រតិបត្តិការដោយស្មើភាពគ្នា មិនមែនធ្វើអាណានិគម ឬធ្វើអាណាព្យាបាលដោយអាវុធដូចរបៀបរបបចាស់គំរឹលរបស់ពួកចក្រពត្តិនិយមបារាំង នោះទេ។

ជាមួយគ្នានេះ សឺង ង៉ុកថាញ់ បានដាស់តឿនអ្នកដឹកនាំចលនាតស៊ូរបស់គាត់នៅខេត្តបាត់ដំបង ឲ្យសាងទំនាក់ទំនងឲ្យបានល្អ និងជិតស្និទ្ធបំផុតជាមួយមន្ត្រីស្ថានអគ្គកុងស៊ុលជប៉ុននៅទីនោះ និងបង្កើតក្រុមចលនាតស៊ូមួយ ដោយយកអគ្គកុងស៊ុលនោះធ្វើជាខ្នងបង្អែក។

# ១៤
# មរណភាពអាចារ្យហែម ចៀវ




**អ្នកទោសនៅគុកកោះត្រឡាច**

នៅក្នុងខែមិថុនា ឆ្នាំ១៩៤៣ សេនាប្រមុខប៉េតាំង នាយករដ្ឋមន្ត្រីបារាំង បានសម្រេចបន្ធូរបន្ថយទោសរបស់លោកគ្រូអាចារ្យហែម ចៀវ, នួន ឌួង និងប៉ាច ឈឺន ពីការប្រហាជីវិតឲ្យមកនៅត្រឹមជាប់គុកអស់មួយជីវិតវិញ។

បន្ទាប់មក អាជ្ញាធរបារាំង បានបញ្ជូនពួកគាត់ចេញពីគុកធំ នៅទីក្រុងនគរ យកទៅដាក់គុកកោះត្រឡាច ដែលបារាំង ឲ្យឈ្មោះថា កោះពូឡូកុងឌ័រ (Poulo Condore) ហើយវៀតណាម ហៅថា កោះកូងសឺង (Con son) នោះ។ គុកកោះត្រឡាចនេះ ត្រូវបានអាជ្ញាធរបារាំង បង្កើតឡើងចាប់តាំងពីឆ្នាំ១៨៦១ មកម្ល៉េះ។

អ្នកទោសនយោបាយខ្មែរទាំង៣នាក់នេះ ត្រូវបានគេយកទៅដាក់នៅក្នុងអគារលេខ ៤ ដែលជាអគារដាក់អ្នកទោសឧក្រិដ្ឋ ដោយមិនអនុញ្ញាតឲ្យអ្នកទោសផ្សេងៗទៀត ចូលសួរសុខទុក្ខឡើយ។

ដូច្នេះហើយ ទើបបានជារយៈពេលប្រហែលមួយខែក្រោយមក ទើបប៊ុណ្ណ ចន្ទម៉ុល ដឹងថា លោកគ្រូអាចារ្យហែម ចៀវ, នួន ឌួង និងប៉ាច ឈឺន ត្រូវគេបញ្ជូនទៅដាក់គុកនៅទីនោះដែរ។

ប៉ុន្តែ បើទោះបីមិនមានលទ្ធភាពទៅជួបសួរសុខទុក្ខលោកទាំង៣ ដោយផ្ទាល់ក៏



**ទិដ្ឋភាពអ្នកទោសនៅតុងកឹង**

ពិតមែន ក៏ប៊ុណ្ណ ចន្ទម៉ុល បានដឹងសុខទុក្ខពីលោកទាំង៣ តាមរយៈអ្នកទោសផ្សេងៗទៀត ដែលគេបញ្ជូនឲ្យទៅធ្វើការនៅក្បែរអគារលេខ៤នោះ ហើយគាត់ក៏បានលួចផ្ញើម្ហូបចំណី បន្តិចបន្តួចទៅឲ្យលោកទាំង៣ ម្តងម្កាល ព្រោះប៊ុណ្ណ ចន្ទម៉ុល មានទោសស្រាលជាង លោកទាំង៣ ត្រូវគេបញ្ចេញឲ្យដើរធ្វើការពាសពេញលើដីកោះទាំងមូល អាចរកសត្វព្រៃ ឬ សត្វសមុទ្រមកធ្វើជាម្ហូបអាហារបានខ្លះដែរ។

ប៊ុណ្ណ ចន្ទ ម៉ុល បានឱ្យដឹងថា អ្នកទោសវៀតណាម ដែលមានទោសឧក្រិដ្ឋ ត្រូវគេ បញ្ជូនទៅដាក់គុកកោះត្រឡាច មុននេះទៅទៀតនោះ ភាគច្រើនគឺពួកមេដឹកនាំចលនាតស៊ូ វៀតមិញ ដែលជាអ្នកប្រឆាំងបារាំង យ៉ាងប្តូរផ្តាច់បំផុតនោះ រួមមាន៖ តុង ឌឹកថាំង និងផាំ វ៉ាន់ដុង ព្រមទាំងអ្នកផ្សេងៗមួយចំនួនទៀត ក៏ជាប់គុកនៅអគារលេខ៤នោះដែរ ហើយ ក្រោយមក អ្នកទាំងអស់នោះ ក៏បានក្លាយជាមេដឹកនាំរបបសាធារណរដ្ឋសង្គមនិយមវៀតណាម ផងដែរ។

នៅទីនោះ អ្នកទោសជាពួកតស៊ូវៀតមិញ បានពង្រឹងសាមគ្គីភាព និងតែងតែជួយ

ឈើឆ្កាលយកអាសាអ្នកទោសខ្មែរជានិច្ច។

ប៊ុណ្ណ ចន្ទម៉ុល បានធ្វើការកត់សម្គាល់ថា ជាអ្នកទោសជាពួកមេដឹកនាំចលនាតស៊ូវៀតមិញ បានជួយបង្ហាត់បង្រៀនភាសាអង់គ្លេស ឬបារាំង ឲ្យពួកគេជាក្រុមៗ ដោយយកកំបោរស សរសេរលើកម្រាលឥដ្ឋ ដែលជាកន្លែងពួកគេដេកនោះតែម្តង និងអប់រំសតិអារម្មណ៍ពួកគេទាំងអស់ មិនឲ្យអស់សង្ឃឹមក្នុងការតស៊ូ ដើម្បីដណ្តើមឯករាជ្យពីពួកបារាំង ឡើយ។

នៅគុកកោះត្រឡាចនោះ មានអ្នកទោសវៀតមិញមួយចំនួនដែលមានការរឹងទទឹងខ្លាំងពេក ក៏ត្រូវគេយកទៅប្រហារជីវិតដែរ។

អ្នកទោសវៀតមិញ ដែលត្រូវគេយកចេញពីកន្លែងឃុំឃាំង ទៅប្រហារជីវិតនោះ គឺធ្វើឡើងនៅវេលាម៉ោង៥ភ្លឺស្រាងៗ ហើយពេលពួកឆ្មាំគុកបណ្តើរពួកគេណាម្នាក់ចេញទៅពួកគេតែងតែស្រែកលាគ្នា និងផ្តាំផ្ញើអ្នកដែលនៅកន្លែងឃុំឃាំងទាំងប៉ុន្មាននោះ ឲ្យខំប្រឹងតស៊ូបន្តទៀត ដោយកុំតក់ស្លុតនឹងសេចក្តីស្លាប់ឲ្យសោះ ហើយមិត្តភក្តិរបស់ពួកគេក៏នាំគ្នាក្រោកឈរតាមចម្រឹងទ្វារបន្ទប់ឃុំឃាំង ស្រែកច្រៀងចម្រៀងបដិវត្តន៍ និងស្រែកខ្លាំងៗព្រមៗគ្នាថា៖ "ជយោ ! អ៊ុំហូៗៗ" រហូតដល់ពួកគេដែលឆ្មាំគុកបណ្តើរយកទៅប្រហារជីវិតនោះទៅផុតឆ្ងាយពីបន្ទប់ឃុំឃាំងស្រែកលែងឮ។

បើតាមឯកសាររបស់ប៊ុណ្ណ ចន្ទម៉ុល បានឱ្យដឹងបន្តថា ក្រោយពេលទៅជាប់គុកនៅកោះត្រឡាចបានប្រមាណ៤ខែ លោកគ្រូអាចារ្យហែម ចៀវ ធ្លាក់ខ្លួនមានជំងឺរាកមួលជាទម្ងន់។ ឯនួន ឌួង មានជំងឺស្ពឹកដៃជើង ត្រូវចាក់ថ្នាំច្រើនម្ជុល រហូតដល់អាប់សែនៅត្រង់ត្រគាកហើមប៉ោងធំ ត្រូវគ្រូពេទ្យវះយកខ្ទុះចេញ បណ្តាលឲ្យស្រែកឈឺចុកចាប់វេទនាបំផុត។

នៅពេលជំងឺរបស់លោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង កាន់តែធ្ងន់ធ្ងរដុនដាបទៅៗពួកឆ្មាំគុកក៏បញ្ជូនទៅដាក់នៅកន្លែងព្យាបាលជំងឺដែលនៅក្នុងបរិវេណកន្លែងឃុំឃាំងនោះដែរ។ ពេលនោះហើយ ដែលលោកប៊ុណ្ណ ចន្ទម៉ុល មានឱកាសទៅសួរសុខទុក្ខលោកទាំង២ដោយផ្ទាល់។ គ្រាន់តែឃើញសភាពជំងឺភ្លាម ធ្វើឲ្យគាត់អស់សង្ឃឹមបាត់ទៅហើយ។



**ទិដ្ឋភាពនៅគុកកោះត្រឡាច**

គាត់បានទាក់ទងកាប៉ូរ៉ាល់ និងអ្នកទោសម្នាក់ដែលគេឲ្យធ្វើជាអ្នកសម្អាតកន្លែងព្យាបាលជំងឺអ្នកទោស ឲ្យជួយមើលលោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង ផង ដោយបានឲ្យលុយខ្លះទៅអ្នកទោសម្នាក់នោះផងដែរ។

លុយនោះ គាត់បានមកពីក្រុមគ្រួសារគាត់នៅភ្នំពេញ ផ្ញើមកឲ្យ៦០០រៀល តាមរយៈអ្នកបកប្រែភាសាម្នាក់ ឈ្មោះអង់ដ្រេ ដកម៉ែ កាលពីប៉ុន្មានខែមុន។

ជាមួយគ្នានោះ គាត់បានផ្តាំផ្ញើកាប៉ូរ៉ាល់ និងអ្នកទោសនោះទៀតថា បើអ្នកជំងឺទាំង២នាក់នេះស្លាប់ ពេលឲ្យគេយកទៅកប់ សូមមេត្តាកប់ឲ្យបានស្រួលបួលផង កុំកប់លាយឡំជាមួយខ្មោចអ្នកទោសផ្សេងទៀត។

ក្រោយមក ពេលឮដំណឹងថា លោកគ្រូអាចារ្យហែម ចៀវ បានទទួលមរណភាពហើយ គាត់ក៏ឆ្លៀតឱកាសទៅកាន់កន្លែងព្យាបាលជំងឺអ្នកទោសនោះជាថ្មីម្តងទៀត ឃើញនួន ឌួង យំខ្សឹកខ្សួលអួលដើមក ប្រាប់គាត់ថា លោកគ្រូអាចារ្យហែម ចៀវ ខូច (ស្លាប់)កាលពីម្សិលមិញ ត្រូវគេរុំនឹងកន្ទេលស្អាត មានចងខ្សែត្រឹមត្រូវ ដាក់រទេះរុញយកទៅបញ្ចុះហើយ។

ប៊ុណ្ណ ចន្ទម៉ុល បានអះអាងថា បន្តិចក្រោយមក គាត់ក៏សុំឲ្យកាប៉ូរ៉ាលដែលនៅកន្លែងព្យាបាលនោះ ជួយនាំគាត់ទៅមើលផ្នូរលោកគ្រូអាចារ្យហែម ចៀវ ដែលស្ថិតនៅលើវាលខ្សាច់ដ៏ធំមួយ មានផ្នូរកប់អ្នកទោសរាប់ពាន់នាក់។

## របត់នយោបាយ

នៅមុខផ្នូរលោកគ្រូអាចារ្យហែម ចៀវ មានបន្ទះក្តារតូចមួយសរសេរលេខ១១១៣ ។ លុះ២-៣ ថ្ងៃក្រោយមក គាត់ក៏នាំមិត្តភក្តិជាអ្នកទោសដូចគ្នា៣នាក់ទៀតទៅមើលផ្នូរនោះ និងបានយកដុំធំៗជាង២០ដុំ ទៅដាក់លើផ្នូរនោះ ដើម្បីទុកជាសញ្ញាសម្គាល់ទៅថ្ងៃក្រោយទៀតផង។

លុះមកដល់របបសាធារណរដ្ឋខ្មែរ នៅក្នុងឆ្នាំ១៩៧២ សេនាប្រមុខលន់ នល់ បានបញ្ជាឲ្យប៊ុណ្ណ ចន្ទម៉ុល ទាក់ទងទៅអាជ្ញាធរវៀតណាមខាងត្បូង ដើម្បីជិះឧទ្ធម្ភាគចក្រទៅយកអដ្ឋិធាតុលោកគ្រូអាចារ្យហែម ចៀវ ពីកោះត្រឡាច មកធ្វើពិធីបូជាតាមប្រពៃណីព្រះពុទ្ធសាសនា នៅលើទីធ្លាសួនច្បារមុខវត្តឧណ្ណាលោម យ៉ាងអធិកអធម។

ពេលនោះ សឺង ង៉ុកថាញ់ ដែលកំពុងកាន់តំណែងជារដ្ឋមន្ត្រីទី១ (នាយករដ្ឋមន្ត្រី) ក៏បានចូលរួមក្នុងពិធីបុណ្យនោះដែរ ។

ពេលនោះដែរ ក៏មានកាសែតមួយចំនួនបានសរសេររិះគន់ថា អដ្ឋិធាតុដែលប៊ុណ្ណ ចន្ទម៉ុល ទៅយកពីកោះត្រឡាច មកនោះ មិនប្រាកដថាជាអដ្ឋិធាតុរបស់លោកគ្រូអាចារ្យហែម ចៀវ នោះទេ គឺប៊ុណ្ណ ចន្ទម៉ុល អាចយកឆ្អឹងអ្នកទោសណាផ្សេងទៀតមកធ្វើបុណ្យនេះ ក៏អាចថាបាន ។

ក្រោយពីមានកាសែតមួយចំនួនបានសរសេររិះគន់បែបនេះ ប៊ុណ្ណ ចន្ទម៉ុល មានការខឹងសម្បាយ៉ាងខ្លាំង ហើយគាត់បានឡើងប្រកាសបំភ្លឺតាមកញ្ចក់ទូរទស្សន៍ជាតិ ដោយយំស្រែក ខឹងនឹងកាសែតទាំងឡាយដែលបានសរសេររិះគន់នោះថា អដ្ឋិធាតុនេះច្បាស់ជារបស់អដ្ឋិធាតុលោកគ្រូអាចារ្យហែម ចៀវ ពិតប្រាកដមែន ព្រោះកាលនោះ គាត់បាននាំមិត្តភក្តិជាអ្នកទោសដូចគ្នា៣នាក់ទៀតទៅមើលផ្នូរនោះ និងបានយកដុំធំៗជាង២០ដុំ ទៅដាក់លើផ្នូរនោះ ដើម្បីទុកជាសញ្ញាសម្គាល់ទៀតផង ម៉េចក៏មានអ្នកកាសែតខ្លះចោទប្រកាន់ថា គាត់ទៅយកឆ្អឹងអ្នកទោសណាផ្សេងទៀតទៅវិញ?

លោកគ្រូហែម ចៀវ ប្រសូតនៅថ្ងៃអង្គារ ឆ្នាំច ព.ស. ២៤៤០ គ.ស ១៨៩៨ នៅភូមិអូរកូនទេញ (កោណ្ឌិញ្ញ) ឃុំដំបូកមានលក្ខណ៍ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ

ហែម ជាមេឃុំដំបូកមានលក្ខណ៍ និងម្តាយឈ្មោះទីវ។ មានបងប្អូន៥នាក់ គឺ៖ ទី១-ហែម លី, ទី២-ហែម ចៀវ, ទី -៣ ហែម ហួត, ទី -៤ ហែម សុច (ស្រី) និងទី -៥ ហែម សាយ ។

ក្នុងឆ្នាំ១៩២០ ពេលកុមារហែម ចៀវ មានអាយុ១២ឆ្នាំ មេឃុំដំបូកមានលក្ខណ៍ ជាឪពុកបាននាំយកទៅផ្ញើនឹងព្រះគ្រូសង្ឃសត្ថា ជួន ណាត គង់នៅវត្តឧណ្ណាលោម ទីក្រុងភ្នំពេញ ដែលធ្លាប់ជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា ដើម្បីឲ្យសិក្សារៀនសូត្រ។

កុមារហែម ចៀវ ជាក្មេងខុសប្លែកពីក្មេងដទៃៗទៀត ដោយមានវោហារព្រោកប្រាជ្ញពូកែជាងក្មេងឯទៀតៗទាំងអស់ និងមានអាកប្បកិរិយាសមរម្យគួរឲ្យអ្នកផងស្រឡាញ់ពេញចិត្ត និងបានព្យាយាមយ៉ាងខ្ជាប់ខ្ជួនក្នុងការរៀនអក្សរសាស្ត្រពីសំណាក់ព្រះគ្រូសង្ឃសត្ថា ជួន ណាត នៅវត្តឧណ្ណាលោម តាំងពីដំបូងរៀងមក ។

លុះមកដល់វ័យ១៦ឆ្នាំ ហែម ចៀវ ក៏បានបួសជាសាមណេរ សិក្សាធម៌អាថ៌នៅវត្តឧណ្ណាលោមនោះ រហូតដល់ព្រះជន្ម២០វស្សា ក៏បានបំពេញឧបសម្បទាជាភិក្ខុនៅវត្តលង្កា ដោយមានព្រះមហាវិមលធម្ម ថោង ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ដំបូងគេបង្អស់ជាឧបជ្ឈាយ៍ និងព្រះគ្រូបវរវិជ្ជាល្វី ឯម និងព្រះគ្រូសង្ឃសត្ថា ជួន ណាត ជាគ្រូសូត្រ។

ក្រោយពីបំពេញឧបសម្បទាជាភិក្ខុហើយ ព្រះអង្គក៏បានប្រឡងជាប់បានចូលរៀនសាលាបាលីជាន់ខ្ពស់។ បន្ទាប់ពីបានសិក្សានៅសាលាបាលីជាន់ខ្ពស់នោះ អស់រយៈពេល ៧ឆ្នាំមក ព្រះអង្គក៏ប្រឡងជាប់សញ្ញាបត្រឌីប្លូមសាលាបាលីជាន់ខ្ពស់នោះ ក្នុងចំណាត់ថ្នាក់លេខ៦។

នៅក្នុងឆ្នាំ១៩២៧ ទេសាភិបាលបារាំងប្រចាំខេត្តកំពត ឈ្មោះរ៉េស្សូម បានទៅពឹងព្រះមេគណខេត្ត ដែលគង់នៅវត្តអង្គសុភី ហៅវត្តកន្ថោរ ក្នុងស្រុកកំពង់ត្រាច ឲ្យមកជួយរកព្រះសង្ឃណាមានសញ្ញាបត្រឌីប្លូមសាលាបាលីជាន់ខ្ពស់ ឲ្យទៅជួយបង្រៀនអក្សរសាស្ត្រខ្មែរនៅខេត្តកំពត ។

ពេលនោះ ព្រះអង្គមេគណខេត្ត និងជាចៅអធិការវត្តអង្គសុភី ហៅវត្តកន្ថោរ ក៏បាននិមន្តទៅពឹងព្រះគ្រូសង្ឃសត្ថា ជួន ណាត ដែលគង់នៅវត្តឧណ្ណាលោម ទីក្រុងភ្នំពេញ ឲ្យ

ជួយរកព្រះសង្ឃមួយអង្គមានសញ្ញាបត្រសាលាបាលីជាន់ខ្ពស់ ឲ្យមកជួយបង្រៀនអក្សរសាស្ត្រខ្មែរ នៅខេត្តកំពត តាមការពឹងពាក់របស់ទេសាភិបាលបារាំង នោះ។

ព្រះគ្រូសង្ឃសត្ថា ក៏បានចាត់លោកគ្រូអាចារ្យហែម ចៀវ ឲ្យទៅបង្រៀនព្រះសង្ឃនៅវត្តក្រាំងដូង ស្រុកបន្ទាយមាស និងវត្តអង្គសុភី ស្រុកកំពង់ត្រាច នោះ អស់រយៈពេល ៦ឆ្នាំ ទើបវិលត្រឡប់មកទីក្រុងភ្នំពេញ វិញ ។

នៅក្នុងឆ្នាំ១៩៣២ លោកគ្រូអាចារ្យហែម ចៀវ បានប្រឡងជាប់ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ។

ក្រោយពីកាសែត "នគរវត្ត" ចេញផ្សាយជាភាសាខ្មែរ ជាលើកដំបូងបង្អស់នៅប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៣៦ លោកគ្រូអាចារ្យហែម ចៀវ ក៏បានប្រាស្រ័យទាក់ទងជាមួយសឹង ង៉ុកថាញ់ , ប៉ាច ឈឺន និងស៊ឹម វ៉ា ជាស្ថាបនិកកាសែតនោះ ហើយបានរួមចំណែកយ៉ាងអង់អាចក្លាហាន ក្នុងការតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង ដើម្បីឯករាជ្យ ជាតិ ស្របតាមគោលនយោបាយរបស់ស្ថាបនិកកាសែត "នគរវត្ត" នោះដែរ ។

លុះដល់ថ្ងៃ១៧ ខែកក្កដា ឆ្នាំ១៩៤២ លោកគ្រូអាចារ្យហែម ចៀវ ក៏ត្រូវបារាំងចាប់ខ្លួនតែម្តង។

# ១៥
# ជប៉ុន ដណ្តើមអំណាចបារាំង ត្រួតត្រាប្រទេសខ្មែរ




**ក្បួនកងទ័ពជប៉ុន ធ្វើដំណើរចូលទៅកំពង់ផែហៃហ្វុង** (រូបថត gettyimages)

នៅក្នុងឆ្នាំ១៩៤៣ បន្ទាប់ពីទទួលរងនូវការវាយបករបស់សត្រូវនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកមក កងទ័ពជប៉ុន ក៏បានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួន ដោយបញ្ឈប់ធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាល នៃប្រទេសអាណានិគមជាច្រើន ហើយបង្កើតឲ្យមានរបបឯករាជ្យនៅប្រទេសភូមា, នៅប្រទេសសិង្ហបុរី និងនៅប្រទេសឥណ្ឌូនេស៊ី។

តែជាតុពិត របបឯករាជ្យនោះ គឺជប៉ុន ជាអ្នកបង្កើតឡើង ដើម្បីដាក់ប្រទេសទាំងនោះឲ្យនៅក្រោមអំណាចរបស់ខ្លួនតែប៉ុណ្ណោះ ហើយប្រជាជននៅបណ្តាប្រទេសទាំងនោះ ក៏មិនគាំទ្ររបបឯករាជ្យ ដែលជប៉ុន ជាអ្នកលើកបន្តុបនោះដែរ ។

ដោយមានជំនួយពីសម្ព័ន្ធមិត្តសហរដ្ឋអាមេរិក និងអង់គ្លេស ប្រជាជនភូមា, ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី បាននាំគ្នាក្រោកឡើងប្រយុទ្ធប្រឆាំងនឹងកងទ័ពជប៉ុន យ៉ាងផុសផុល ។

## របត់នយោបាយ

ដោយសារបញ្ហានេះហើយ ទើបបានជាជប៉ុន មិនហ៊ានបង្កើតរដ្ឋាភិបាលអាយ៉ងរបស់ខ្លួន នៅតំបន់ឥណ្ឌូចិន ព្រោះខ្លាចមានការបះបោរប្រឆាំងនឹងខ្លួន ដូចនៅប្រទេសភូមា, ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ទៀត ទើបជប៉ុន សុខចិត្តបណ្តោយឲ្យបារាំង ធ្វើអាណានិគមនៅតំបន់ឥណ្ឌូចិន បន្តទៀត ដោយខ្លួនគ្រាន់តែយកតំបន់ឥណ្ឌូចិន ធ្វើជាប្រភពសេដ្ឋកិច្ចសម្រាប់ផ្គត់ផ្គង់កងទ័ព ដើម្បីធ្វើសង្គ្រាមប៉ុណ្ណោះ។

នៅក្នុងឆ្នាំ១៩៤៤ សង្គ្រាមនៅសមុទ្រប៉ាស៊ីហ្វិក មានសភាពសាហាវខ្លាំងឡើងៗ ដោយមានអន្តរាគមន៍ពីកងទ័ពអាមេរិក និងអង់គ្លេស។

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៤៤ កងទ័ពឯករាជ្យបារាំង ក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ហ្សាល ដឺ ហ្គោល (Charles de Gaulle) បានចាប់ផ្តើមធ្វើសង្គ្រាមរំដោះប្រទេសបារាំង ពីការកាន់កាប់របស់កងទ័ពណាហ្ស៊ីអាល្លឺម៉ង់វិញ។

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៤ កងទ័ពបារាំង បានដណ្តើមទីក្រុងប៉ារីស ឲ្យរួចផុតពីការគ្រប់គ្រងរបស់កងទ័ពអាល្លឺម៉ង់។

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៤៥ យន្តហោះចម្បាំងរបស់អាមេរិក ធុនបេ-២៩ (B29) បានធ្វើសកម្មភាពទម្លាក់គ្រាប់បែកលើទីតាំងកងទព័ជប៉ុន នៅក្នុងទីក្រុងភ្នំពេញ ហើយគ្រាប់បែកខ្លះត្រូវធ្លាក់លើផ្សារកណ្តាល និងវត្តឧណ្ណាលោម បណ្តាលឲ្យសុគតព្រះសង្ឃ ២០អង្គ និងបានស្លាប់ប្រជារាស្ត្រមួយចំនួនទៀត។

ពេលនោះ មានព្រះសង្ឃមួយអង្គ ឈ្មោះទូ សាមុត ដែលគង់នៅវត្តឧណ្ណាលោម និងដូចព្រះសង្ឃមួយចំនួនទៀតដែលបានចូលរួមបាតុកម្ម កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៤២ នោះដែរ មានការភ័យខ្លាចក្នុងការទម្លាក់គ្រាប់បែកនេះ ក៏បានរត់គៀសខ្លួនទៅរស់នៅតំបន់ជនបទ ហើយបានចូលរួមសហការជាមួយពួកវៀតមិញ ។

ទន្ទឹមនឹងការវាយប្រហារទៅលើទីតាំងកងទ័ពជប៉ុន នៅឥណ្ឌូចិន តាមផ្លូវអាកាសនោះដែរ កងទ័ពសម្ព័ន្ធមិត្តរបស់បារាំង គឺអាមេរិក និងអង់គ្លេស ក៏បានបើកការវាយប្រហារតាមផ្លូវសមុទ្រ កាត់ផ្តាច់តំបន់ភាគខាងជើង និងតំបន់ភាគខាងត្បូង របស់ប្រទេសវៀតណាម



**ឧត្តមសេនីយ៍ហ្សាល ដឺ ហ្គោល**

ផងដែរ តែនៅភាគខាងជើងប្រទេសវៀតណាម ពួកវៀតមិញ ក៏ចាប់ផ្ដើមធ្វើការវាយប្រហារទៅលើទីតាំងកងទ័ពជប៉ុនទាំងឡាយដែលនៅដាច់ឆ្ងាយៗពីគ្នា ។

ឧត្ដមសេនីយ៍ហ្សាល ដឺ ហ្គោល ( Charles de Gaulle ) ដែលទើបតែទទួលជ័យជម្នះលើកងទ័ពណាហ្ស៊ីអាល្លឺម៉ង់ ក្នុងការរំដោះប្រទេសបារាំង មកវិញនោះ បានសហការយ៉ាងជិតស្និទ្ធជាមួយអាមេរិក និងអង់គ្លេស ដើម្បីប្រឆាំងនឹងកងទ័ពជប៉ុន ហើយលោកបានសន្យាថា នឹងរៀបចំពង្រីកអំណាចរបស់បារាំងនៅតំបន់ឥណ្ឌូចិន ឲ្យបានរឹងមាំឡើងវិញ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៤៥ នៅលើកោះត្រឡាច ដែលជាពន្ធនាគារធំជាងគេបង្អស់របស់បារាំង នៅឥណ្ឌូចិន ក៏ត្រូវរងការទម្លាក់គ្រាប់បែករបស់យន្តហោះសហរដ្ឋអាមេរិកជាសម្ព័ន្ធមិត្តរបស់បារាំង ដូចនៅទីក្រុងភ្នំពេញដែរ។

ប្រហែលមួយសប្តាហ៍ក្រោយមក ទាហានជប៉ុនមួយក្រុម បានធ្វើដំណើរតាមនាវាចម្បាំងមួយគ្រឿង នាំសារទូរលេខមួយច្បាប់ យកទៅឲ្យអ្នកទទួលខុសត្រូវនៅគុកកោះត្រឡាច

នោះ ដើម្បីនាំយកអ្នកទោសខ្មែរ៤រូប គឺលោកគ្រូអាចារ្យ ហែម ចៀវ, នួន ឌួង, ប៉ាច ឈឿន និងប៊ុណ្ណ ចន្ទម៉ុល វិលត្រឡប់ទៅក្រុងភ្នំពេញ វិញ។

ប៉ុន្តែគួរឲ្យសោកស្តាយ លោកគ្រូអាចារ្យហែម ចៀវ បានសុគតបាត់ទៅហើយ នៅសល់តែនួន ឌួង, ប៉ាច ឈឿន និងប៊ុណ្ណ ចន្ទម៉ុល ប៉ុណ្ណោះ ដែលមានភ័ព្វសំណាងបានវិលត្រឡប់មកជួបជុំក្រុមគ្រួសារនៅឯក្រុងភ្នំពេញ វិញ។

ម៉ោង៦ព្រលប់ កងទ័ពជប៉ុន បាននាំអតីតអ្នកទោសខ្មែរទាំង៣នាក់ ឡើងលើនាវាចម្បាំង ដ៏ធំមួយរបស់ពួកគេ បន្ទាប់មក ក៏មានទាហានខ្មែរកម្ពុជាក្រោមប្រមាណ១០០នាក់ ព្រមទាំងក្រុមគ្រួសារប្រពន្ធកូន ដែលពួកបារាំងបញ្ជូនឲ្យមកធ្វើជាឆ្មាំនៅគុកកោះត្រឡាចនោះ ក៏ត្រូវឡើងលើនាវាត្រឡប់ទៅក្រុងព្រៃនគរ វិញ ជាមួយគ្នាដែរ។

វរសេនីយ៍ឯកជប៉ុន ដែលជាមេបញ្ជាការនៅលើនាវានោះ និងសហការី បានស្វាគមន៍ចំពោះនួន ឌួង, ប៉ាច ឈឿន និងប៊ុណ្ណ ចន្ទម៉ុល យ៉ាងរីករាយរាក់ទាក់បំផុត ។

ពេលមកដល់ដែសមុទ្រ ត្រង់ច្រកចូលទៅកំពង់ផែព្រៃនគរ នាវាចម្បាំងនោះបានអែបច្រាំងប្រហែលកន្លះម៉ោង ទើបមានរថយន្តធុនតូចមួយគ្រឿងរបស់ជប៉ុន មកទទួលអតីតអ្នកទោសខ្មែរទាំង៣នាក់ពីលើនាវាចម្បាំងនោះ ហើយបើកតាមផ្លូវគោក ឆ្ពោះទៅទីក្រុងព្រៃនគរ និងស្នាក់នៅជាមួយមេដឹកនាំក្រុមកៅដាយវ៉ាហាវ ប៊ីនស្វៀង ដែលជាអ្នកតស៊ូវៀតណាម ប្រឆាំងបារាំង អស់រយៈពេល១៤ថ្ងៃ ទើបជប៉ុន ដឹកតាមរថយន្តកងទ័ពមួយគ្រឿងទៀត ចេញដំណើរពីទីក្រុងព្រៃនគរ តាមផ្លូវជាតិលេខ១ ឆ្ពោះមកទីក្រុងភ្នំពេញ។

លុះមកដល់កំពង់ចម្លងអ្នកលឿង ជាថៃ្ងដន្យ នួន ឌួង, ប៉ាច ឈឿន និងប៊ុណ្ណ ចន្ទម៉ុល ក៏បានជួប ជុំ មួង និងលោកគ្រូអាចារ្យប៉ាង ខាត់ ព្រមទាំងមិត្តភក្តិមួយចំនួនទៀត ដែលធ្វើដំណើរជាមួយកងទ័ពជប៉ុន ចុះទៅឃោសនាអប់រំប្រជារាស្ត្រនៅខេត្តព្រៃវែង និងស្វាយរៀង ដើម្បីឲ្យបានយល់ពីបញ្ហាកងទ័ពជប៉ុន ចូលមកជួយដណ្តើមយកឯករាជ្យពីបារាំង មកឲ្យប្រជារាស្ត្រខ្មែរ វិញ។ ពេលនោះ ពួកគាត់ឱបរឹតគ្នាដោយក្តីនឹករឭក និងរីករាយពន់ពេក។

បន្ទាប់មក រថយន្តកងទ័ពជប៉ុន ដែលដឹកអតីតអ្នកទោសគុកកោះត្រ-ឡាចទាំង៣នាក់ ក៏បន្តដំណើរទៅមុខទៀត ហើយបានមកដល់ទីក្រុងភ្នំពេញ នៅវេលាម៉ោង១២ ថ្ងៃត្រង់ ដោយមានក្រុមគ្រួសារ បងប្អូនប្រពន្ធកូនពួកគាត់ នៅរង់ចាំទទួលដោយក្តីរំភើបរីករាយលាយឡំដោយទឹកភ្នែកផងដែរ។



**កងទ័ពបារាំង ដែលត្រូវកងទ័ពជប៉ុន ចាប់ខ្លួន**

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ កងទ័ពជប៉ុន នៅឥណ្ឌូចិនទាំងមូល បានបើកប្រតិបត្តិការសឹកពិសេសមួយហៅថា ប្រតិបត្តិការផ្តេកបន្ទោរ ចាប់មន្ត្រីបារាំងគ្រប់លំដាប់ថ្នាក់ ទាំងទាហាន ទាំងប៉ូលិស និងជនជាតិបារាំងទាំងអស់ ព្រមទាំងទាហានក្នុងស្រុកមួយចំនួន មកឃុំទុកតាមកន្លែងប្រមូលផ្តុំនីមួយៗ។

នៅប្រទេសកម្ពុជា ការចាប់ខ្លួនពួកបារាំងនេះ មិនមែនធ្វើតែនៅក្នុងទីក្រុងភ្នំពេញនោះទេ គឺនៅតាមបណ្តាខេត្តនានាផងដែរ ។

នៅខេត្តស្ទឹងត្រែង អ្នកតស៊ូប្រឆាំងនឹងបារាំងម្នាក់ឈ្មោះចាន់ ដារ៉ា ដែលជាអ្នកស្មោះស្ម័គ្រជាមួយសឹង ង៉ុកថាញ់ ដែលបានចូលបម្រើក្នុងជួរកងទ័ពជប៉ុន ជាងមួយឆ្នាំមកហើយនោះ ក៏បានចូលរួមក្នុងប្រតិបត្តិការចាប់ពួកបារាំងនោះដែរ។

នៅវេលាម៉ោង៦ព្រលប់ ថ្ងៃទី៩ ខែមីនា នោះ មានមេកងទ័ពជប៉ុនម្នាក់ មានឋានន្តរស័ក្តិជាវរសេនីយ៍ និងម្នាក់ទៀតជាយុទ្ធជន បានប្រាប់ចាន់ ដារ៉ា ឲ្យដើរតាមពួកគេ ហើយបានប្រគល់ដាវមួយ និងកាំបិតមួយឲ្យចាន់ ដារ៉ា ទុកការពារខ្លួន។

លុះដល់ម៉ោង១០យប់ មេទ័ពជប៉ុននោះ ប្រាប់ចាន់ ដារ៉ា ថា យប់នេះ យើងត្រូវចាប់ពួកបារាំងទាំងអស់ មិនឱ្យនរណាម្នាក់រួចខ្លួនឡើយ។

បន្ទាប់មក ក្នុងរយៈពេលតែ២ម៉ោងប៉ុណ្ណោះ ពួកបារាំងទាំងអស់នៅក្នុងខេត្តស្ទឹងត្រែង


ព្រះមហាក្សត្រនរោត្តម សីហនុ

ត្រូវកងទ័ពជប៉ុន ចាប់ខ្លួនបានគ្មានសល់ម្នាក់ឡើយ។ ចំណែកនៅខេត្តក្រចេះវិញ ពួកបារាំងបានធ្វើការតបតវិញដែរ តែត្រូវបរាជ័យ។ ក្នុងប្រតិបត្តិការរយៈពេលតែ២៤ម៉ោងប៉ុណ្ណោះ ជនជាតិបារាំងនៅឥណ្ឌូចិនទាំងមូល ត្រូវកងទ័ពជប៉ុនចាប់បានទាំងអស់។

យប់ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ នោះដែរ ព្រះមហាក្សត្រនរោត្តម សីហនុ បានគេចព្រះកាយចេញពីព្រះបរមរាជវាំង ទៅសំងំនៅកុដិរបស់ព្រះតេជគុណកែវ អ៊ួច ក្នុងវត្តបទុមវតី ដោយសារខ្លាចពួកជប៉ុន ចាប់ព្រះកាយដែរ ព្រោះព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាព្រះមហាក្សត្រ ដោយសារតែពួកបារាំង នោះដែរ។

ព្រឹកឡើងថ្ងៃទី១០ ខែមីនា មេបញ្ជាការកងទ័ពជប៉ុន ប្រចាំនៅឥណ្ឌូចិន បានស្នើសុំព្រះមហាក្សត្រខ្មែរ ប្រកាសឯករាជ្យថា បារាំងលែងត្រួតត្រា និងលែងធ្វើអាណាព្យាបាលលើប្រទេសខ្មែរទៀតហើយ។

ដោយមានការគាបសង្កត់ពីកងទ័ពជប៉ុនផងដែរនោះ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៤៥ ព្រះមហាក្សត្រ សីហនុ បានប្រកាសរំលាយសន្ធិសញ្ញាដែលព្រះមហាក្សត្រនរោត្តម ជាព្រះអយ្យិកោបានឡាយព្រះហស្ថលេខាជាមួយបារាំង កាលពីឆ្នាំ១៨៦៣ និង១៨៨៤នោះចោល និងឈប់ទទួលស្គាល់បារាំង ថាជាអាណាព្យាបាលលើប្រទេសកម្ពុជា ចាប់ពីពេលនេះតទៅ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៤៥ ពួកជប៉ុន បានរៀបចំឲ្យមានរាជរដ្ឋាភិបាលថ្មីមួយ

ដោយតែងតាំងព្រះមហាក្សត្រនរោត្តម សីហនុ ជានាយករដ្ឋមន្ត្រី។ តែសមាសភាពសមាជិកគណៈរដ្ឋមន្ត្រីថ្មីនេះសុទ្ធតែជាមន្ត្រីជាន់ខ្ពស់ដែលធ្លាប់ទទួលការតែងតាំងពីពួកបារាំងកាលពីមុនផងដែរ។

សមាសភាពរាជរដ្ឋាភិបាលថ្មី ដែលមានព្រះមហាក្សត្រនរោត្តម សីហនុ ជានាយករដ្ឋមន្ត្រីនោះ មានសមាជិក៩រូប គឺអ៊ឹង អ៊ី (ជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលចាស់ មុននោះ) ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ, មាស ណាល់ រដ្ឋមន្ត្រីក្រសួងអប់រំ និងឃោសនាការ , ទា សាន (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ និងជាអ្នកចាប់គ្រូអាចារ្យហែម ចៀវ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤២) ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងផ្គត់ផ្គង់, ចាន់ ណាក ជាមន្ត្រីក្រសួងយុត្តិធម៌ , ស៊ុម ហៀង អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងកិច្ចការនយោបាយ , វ៉ា កាម៉ែល អនុរដ្ឋមន្ត្រីក្រសួងធម្មការ ពុទ្ធិកសិក្សា និងវិចិត្រសិល្បៈ , នង គឹមនី (ជាអ្នកបកប្រែភាសាខ្មែរ និងបារាំងដ៏ស្ទាត់ជំនាញ) ជានាយសេនាធិការកងទ័ព និងជួន ហ៊ល ជាអនុរដ្ឋមន្ត្រីក្រសួងអប់រំ ។

ពេលនោះ ព្រះមហាក្សត្រសីហនុ បានពិភាក្សាជាមួយទីប្រឹក្សាជាន់ខ្ពស់ជប៉ុន ដែលនៅអមរាជរដ្ឋាភិបាលរបស់ព្រះអង្គ ដើម្បីទាមទារសុំឱ្យព្រះចៅអធិរាជជប៉ុន ប្រកាសទទួលស្គាល់ឯករាជ្យរបស់ប្រទេសខ្មែរនៅពេលនោះជាផ្លូវការផងដែរ តែមិនមានការឆ្លើយតបវិញសោះ ពោលគឺឯករាជ្យនេះ បានត្រឹមតែមេបញ្ជាការកងទ័ពជប៉ុន ប្រចាំនៅឥណ្ឌូចិន ជាអ្នកផ្តល់ឱ្យប៉ុណ្ណោះ។

ក្រោយពេលចាប់មន្ត្រីយោធា និងស៊ីវិល ព្រមទាំងពលរដ្ឋបារាំង យកទៅឃុំឃាំងអស់មក នៅតាមក្រសួង ស្ថាប័ន និងអង្គភាពទាំងអស់ ជប៉ុនបានដាក់មន្ត្រីខ្មែរឲ្យចូលធ្វើការជំនួសវិញ សូម្បីតែនៅតាមវិទ្យាល័យនានា ក៏ជប៉ុន ដាក់បញ្ចូលសាស្ត្រាចារ្យខ្មែរជំនួសសាស្ត្រាចារ្យបារាំង ដែរ។

លុះដល់ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែរ នៅចុងសប្តាហ៍ទី២ នៃខែមេសា

## របត់នយោបាយ

ឆ្នាំ១៩៤៥ ព្រះមហាក្សត្រ នរោត្តម សីហនុ បានប្រកាសជាសាធារណៈថា ឆ្នាំនេះ ជាឆ្នាំដែលចក្រភពនៃព្រះអាទិត្យរះ(ប្រទេសជប៉ុន) បានជួយរំដោះប្រជារាស្ត្រនានានៅអាស៊ី និងបានផ្តល់ឯករាជ្យដ៏ថ្លៃថ្លាមួយដែលមិនអាចកាត់ថ្លៃបាន ចំពោះប្រទេសកម្ពុជា។

ប៉ុន្តែបន្តិចក្រោយមក វាមិនដូចជាការរំពឹងទុករបស់ព្រះមហាក្សត្រនរោត្តម សីហនុ និងប្រជារាស្ត្រខ្មែរនោះឡើយ ព្រោះជប៉ុន ក៏មិនខុសពីបារាំងដែរ គឺជប៉ុន បានចាប់ផ្តើមប្លន់ទ្រព្យសម្បត្តិ និងប្រមូលស្រូវអង្កររាប់ពាន់តោន ដើម្បីយកទៅចិញ្ចឹមកងទ័ពរបស់ខ្លួន និងកេណ្ឌយុវជនខ្មែរ ឲ្យចូលបម្រើក្នុងជួរកងទ័ពពួកគេទៀតផង។

ជាមួយគ្នានោះដែរ ការចាប់ពួកមន្ត្រីរដ្ឋបាល និងមន្ត្រីបច្ចេកទេសបារាំង យកទៅដាក់នៅមន្ទីរឃុំឃាំងនោះ ធ្វើឲ្យសេដ្ឋកិច្ចខ្មែរកាន់តែធ្លាក់ដុនដាបថែមទៀត។ មិនតែប៉ុណ្ណោះ ជប៉ុនបានបង្ខិតបង្ខំឲ្យព្រះមហាក្សត្រនរោត្តម សីហនុ យល់ព្រមផ្តល់សិទ្ធិឲ្យពួកគេកេណ្ឌប្រជារាស្ត្រខ្មែរឲ្យទៅកាប់គាស់រំកែដី ដើម្បីលើកផ្លូវជាតិច្រើនកន្លែង និងតម្រូវឲ្យមានការបង្រៀនភាសាជប៉ុន នៅតាមគ្រឹះស្ថានសិក្សានានាក្នុងទីក្រុងភ្នំពេញ ទៀតផង។ ពិសេស ជប៉ុនបានបង្កើតរដ្ឋបាលយោធារបស់ខ្លួនមួយ ដើម្បីគ្រប់គ្រងប្រទេសកម្ពុជាដោយផ្ទាល់ទៀតផង។

ដោយយកគំរូតាមពួកជប៉ុន នៅក្នុងប្រទេសកម្ពុជានោះដែរ អាជ្ញាធរថៃ ដែលបានដណ្តើមយកខេត្តបាត់ដំបង សៀមរាប និងកំពង់ធំ តាំងពីឆ្នាំ១៩៤១ យកទៅគ្រប់គ្រងជាថ្មីម្តងទៀតនោះ ក៏ចាប់ផ្តើមរឹតបន្តឹងក្នុងការប្រមូលពន្ធ និងបានបង្ខំឲ្យប្រជារាស្ត្រខ្មែរនៅក្នុងខេត្តទាំង៣នោះ និយាយភាសាថៃផងដែរ។

ចំណែកសឺង ង៉ុកថាញ់ មេដឹកនាំចលនាអ្នកជាតិនិយមប្រឆាំងនឹងបារាំង ដែលបានរត់កៀសខ្លួនទៅជ្រកកោននៅប្រទេសជប៉ុន និងបានចូលបម្រើនៅក្នុងជួរកងទ័ពជប៉ុន នៅទីក្រុងតូក្យូ មានឋានន្តរស័ក្តិជាអនុសេនីយ៍ឯកនោះ ត្រូវបានជប៉ុន នាំមកប្រទេសកម្ពុជាវិញ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៤៥ និងបានតែងតាំងឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងរាជរដ្ឋាភិបាលនេះដែរ ។

ពេលនោះពួកជប៉ុន ក៏បានបង្កើតអង្គភាពកងទ័ពស្ម័គ្រចិត្តមួយ ដឹកនាំដោយទាហានជប៉ុនម្នាក់ឈ្មោះតាដាកូមា។ ពេលនោះ ទ្រង់នរោត្តម ចន្ទរង្សី ក៏បានចូលរួមនៅក្នុងអង្គភាពកងទ័ពស្ម័គ្រចិត្តនោះដែរ។

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤៥ សឺង ង៉ុកថាញ់ បានរៀបចំពិធីរំឭកដល់ខួបឆ្នាំទី៣ នៃការធ្វើបាតុកម្មថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ ដែលត្រូវអាជ្ញាធរបារាំងបង្ក្រាបយ៉ាងព្រៃផ្សៃនោះ នៅទីធ្លាមុខវត្តឧណ្ណាលោម។

ពេលនោះ គាត់បានឡើងថ្លែងពីវីរភាពរបស់អ្នកតស៊ូខ្មែរប្រឆាំងនឹងពួកអាណានិគមនិយមបារាំង តាំងពីសម័យអាចារ្យស្វា, អាចារ្យពោធិ៍កំបោរ រហូតដល់សម័យអាចារ្យហែមចៀវ ផងដែរ។

ក្រោយពីបង្កើតអង្គភាពកងទ័ពស្ម័គ្រចិត្តនោះមក មាននាយទាហានវ័យក្មេងៗនៅក្នុងអង្គភាពកងទ័ពនោះ មានការមិនសប្បាយចិត្តជាមួយរាជរដ្ឋាភិបាលដែលមានព្រះមហាក្សត្រនរោត្តម សីហនុ ជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីផ្សេងៗទៀត សុទ្ធតែពួកមន្ត្រីរបស់បារាំង និងពួកគហបតី ។

ពួកគេចាត់ទុកគណៈរដ្ឋមន្ត្រីនេះ សុទ្ធតែជាពួកមន្ត្រីមានគំនិតចាស់គំរឹល មិនអាចធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនបានទេ ហើយពួកគេចង់បានរាជរដ្ឋាភិបាលថ្មីមួយទៀតដែលមានសមាសភាពពួកអ្នកជាតិនិយម ពិសេសពួកគេចង់ឲ្យសឺង ង៉ុកថាញ់ ធ្វើជានាយករដ្ឋមន្ត្រីតែម្តង។

នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៤៥ ប្រធានាធិបតីអាមេរិក ហារី អេស ទ្រូម៉ាន់ (Harry S Truman) បានបញ្ជាឲ្យកងទ័ពរបស់ខ្លួនទម្លាក់គ្រាប់បែកបរមាណូនៅលើទីក្រុងហ៊ីរ៉ូហ្ស៊ីម៉ា (Hiroshima) បណ្តាលឲ្យមនុស្សប្រមាណ៨ម៉ឺននាក់ត្រូវបាត់បង់ជីវិត ព្រមទាំងរងផលប៉ះពាល់វិទ្យុសកម្ម ប្រមាណពី៩០០០០ ទៅ១៤០.០០០នាក់ទៀត។

នៅយប់ថ្ងៃទី៨ ឈានចូលដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៤៥ ពួកនាយទាហានក្មេងៗ ៧នាក់នៅក្នុងអង្គភាពកងទ័ពស្ម័គ្រចិត្តនោះ រួមមាន៖ ម៉ី ផូ , ម៉ៅ សារួត , លាង សាយ ,



**ទីក្រុងហ៊ីរ៉ូហ្ស៊ីម៉ា ក្លាយជាផេះដោយសារអាមេរិក ទម្លាក់គ្រាប់បែកបរមាណូ**

ហែម សាវ៉ាង , នេត , ម៉ម និង គួន បានចូលទៅលុកលុយក្នុងព្រះបរមរាជវាំង ដោយបានបាញ់កាំភ្លើងដៃជាច្រើនគ្រាប់ ដើម្បីគំរាមព្រះមហាក្សត្រនរោត្តម សីហនុ ឲ្យចុះចេញពីនាយករដ្ឋមន្ត្រី។

ក្នុងពេលអុកឡុកនៅក្នុងបរមរាជវាំងនោះ បណ្ដាលឲ្យលេខាធិការរបស់ព្រះមហាក្សត្រនរោត្តម សីហនុ ម្នាក់ត្រូវរងរបួស។

នៅយប់នោះដែរ មានសិស្សវិទ្យាល័យស៊ីសុវត្ថិ ដែលសុទ្ធតែជាអ្នកគាំទ្រចលនាជាតិនិយមរបស់សឺង ង៉ុកថាញ់ ប្រមាណ៥០នាក់ ក្នុងនោះក៏មានកេង វ៉ាន់សាក់ ម្នាក់ដែរ បានប្រមូលផ្ដុំគ្នានៅទីធ្លាមួយក្បែរព្រះបរមរាជវាំង ដើម្បីត្រៀមលក្ខណៈចូលរួមក្នុងការអុកឡុកព្រះបរមរាជវាំង នោះដែរ។

យប់នោះ ក្រុមនាយទាហានក្មេងៗទាំងនោះ បានចាប់ខ្លួនសមាជិករាជរដ្ឋាភិបាលស្ទើរតែទាំងអស់ យកមកទុកមួយកន្លែង ។ តែបន្តិចក្រោយមក សឺង ង៉ុកថាញ់ ក៏បានបញ្ជាឲ្យដោះលែងសមាជិករាជរដ្ឋាភិបាលទាំងអស់នោះវិញ ហើយបញ្ជាឲ្យគេចាប់ពួកនាយទាហានក្មេងៗ៧នាក់នោះទៅវិញ។

ក្នុងចំណោមពួកនាយទាហានក្មេងៗ ៧នាក់នោះ ខ្លះត្រូវចាប់ដាក់គុករយៈពេលខ្លី និងខ្លះទៀតរត់គេចខ្លួនទៅចូលរួមជាមួយពួកវៀតមិញ ដែលដឹកនាំដោយបក្សកុម្មុយនិស្ត

ឥណ្ឌូចិន។

ព្រឹត្តិការណ៍នៅយប់ថ្ងៃទី៨ ខែសីហា ឈានចូលដល់ថ្ងៃទី៩ ខែសីហានោះ វាជាព្រឹត្តិការណ៍ច្របូកច្របល់មួយពិបាកយល់បំផុត។ មជ្ឈដ្ឋានខ្លះថា ព្រឹត្តិការណ៍នេះ ជារដ្ឋប្រហារមិនបានសម្រេចក្នុងការទម្លាក់ព្រះមហាក្សត្រនរោត្តម សីហនុ ចេញពីនាយករដ្ឋមន្ត្រី ហើយព្រឹត្តិការណ៍នេះជាល្បិចកលរបស់សឺង ង៉ុកថាញ់ ឬយ៉ាងណា?

លុះស្អែកឡើង ថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៤៥ កងទ័ពសហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែកបរមាណូទៅលើទីក្រុងណាហ្គាសាគី របស់ជប៉ុន មួយគ្រាប់ទៀត តាមបញ្ជារបស់ប្រធានាធិបតីអាមេរិក ហារី អេស ទ្រូម៉ាន់ (Harry S Truman) បណ្តាលឲ្យប្រជាជនជប៉ុន ស្លាប់អស់ចំនួន៧៣.៨៨៤នាក់ថែមទៀត។

រយៈពេល៥ថ្ងៃ ក្រោយពួកនាយទាហានក្មេងៗ ៧នាក់ ជាអ្នកជាតិនិយមគាំទ្រសឺង ង៉ុកថាញ់ ចូលទៅអុកឡុកក្នុងព្រះបរមរាជវាំង គំរាមឲ្យព្រះមហាក្សត្រនរោត្តម សីហនុ ចុះចេញពីនាយករដ្ឋមន្ត្រីនោះ នៅថ្ងៃទី១៤ ខែសីហា ជប៉ុនបានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយ ដោយពុំឲ្យព្រះមហាក្សត្រសីហនុ ធ្វើជានាយករដ្ឋមន្ត្រីទៀតទេ ហើយការរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីនេះ បានធ្វើឡើងមុនពេលព្រះចៅអធិរាជរបស់ប្រទេសជប៉ុន បានប្រកាសសុំចុះចាញ់សង្គ្រាមតែមួយថ្ងៃប៉ុណ្ណោះ។

សមាសភាពរាជរដ្ឋាភិបាលថ្មីនោះ ជប៉ុន បានតែងតាំងសឺង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស , ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ជារដ្ឋមន្ត្រីក្រសួងកសិកម្ម, ស៊ុម ហៀង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, វ៉ា កាម៉ែល ជារដ្ឋមន្ត្រីក្រសួងធម្មការពុទ្ធិកសិក្សា និងវិចិត្រសិល្បៈ, ប៉ាច ឈឺន ដែលទើបរួចខ្លួនពីគុកកោះត្រឡាច និងក៏ជាអតីតចាងហ្វាងកាសែត "នគរវត្ត" ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងផ្គត់ផ្គង់, ពីទូ ដឺម៉ុងតេរ៉ូ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឃឹម ទិត ជារដ្ឋមន្ត្រីក្រសួងការពារជាតិ សាធារណការ និងសុខាភិបាល, ញឹក ជូឡុង ជារដ្ឋមន្ត្រីក្រសួងអប់រំ និងប៉ែន នុត ជារដ្ឋមន្ត្រីសួងហិរញ្ញវត្ថុ។

ប៉ាច ឈឺន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ និងផ្គត់ផ្គង់ កើតនៅក្នុងឆ្នាំ១៨៩៦ ។ ក្នុង



ប៉ាច ឈឿន

សង្គ្រាមលោកលើកទី១ ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨ គាត់បានចូលបម្រើក្នុងជួរកងទ័ពបារាំង ហើយបានត្រូវគេបញ្ជូនឲ្យទៅធ្វើសង្គ្រាមនៅប្រទេសបារាំង នៅក្នុងអង្គភាពបញ្ជូនសារ។

ក្រោយពីសង្គ្រាមលោកលើកទី១ត្រូវបានបញ្ចប់ គាត់បានវិលត្រឡប់មកមាតុប្រទេសវិញ និងរៀបការប្រពន្ធឈ្មោះ ឌុក អ៊ុក ជាបងស្រីបង្កើតរបស់ឌុក រ៉ាស៊ី។ គាត់បានចូលបម្រើការងារជាប្រធានផ្នែករដ្ឋបាលក្រុមហ៊ុនលក់រថយន្តម៉ាកស៊ីត្រូអែន និងក្រុមហ៊ុនលក់រថយន្ត ម៉ាកប៉ឺហ្សូ ក្នុងក្រុងភ្នំពេញ។

គាត់បានចូលរួមក្នុងចលនាតស៊ូអ្នកជាតិនិយមប្រឆាំងនឹងពួកអាណានិគមបារាំងជាមួយសឺង ង៉ុកថាញ់ ហើយបានឈរឈ្មោះជាចាងហ្វាងកាសែត "នគរវត្ត" ដែលសឺង ង៉ុកថាញ់ បង្កើតឡើងនៅក្នុងឆ្នាំ១៩៣៦នោះ ។

ចំណែក ឃឹម ទិត ជារដ្ឋមន្ត្រីក្រសួងការពារជាតិ សាធារណការ និងសុខាភិបាល កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៨៩៦។ ឪពុកឈ្មោះឃឹម ម្តាយឈ្មោះមួង ។

នៅក្នុងឆ្នាំ១៩១៧ គាត់បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពបារាំង ទៅធ្វើសង្គ្រាមប្រឆាំងនឹងកងទ័ពអាល្លឺម៉ង់ ដែលកំពុងឈ្លានពានប្រទេសបារាំង មានឋានន្តរស័ក្តិជាពល-បាលត្រី ហើយគាត់បានវិលត្រឡប់មកមាតុភូមិវិញ នៅក្នុងឆ្នាំ១៩១៩ ។

មួយឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ ១៩២០ គាត់បានប្រឡងជាប់សញ្ញាបត្របឋមសិក្សា និងបានប្រឡងជាប់ជាលេខាធិការនៃនិវេសនដ្ឋាន។

ក្នុងឆ្នាំ១៩២៤ គាត់បានប្រឡងជាប់សញ្ញាបត្រសាលារដ្ឋបាល។ មួយឆ្នាំក្រោយមក គឺក្នុងឆ្នាំ១៩២៥ គាត់បានចូលបម្រើការងារជាមន្ត្រីរដ្ឋបាលនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ។



ញ៉ឹក ជូឡុង

ក្នុងឆ្នាំ១៩២៧ ជាចៅហ្វាយស្រុកមួយ នៅខេត្តក្រចេះ។ ក្រោយមកទៀត បានក្លាយជាចៅហ្វាយស្រុកមួយនៅខេត្តតាកែវ។

នៅឆ្នាំ១៩៣៧ គាត់ត្រូវបានតែងតាំងឲ្យទៅធ្វើជាចៅហ្វាយស្រុកមួយទៀតនៅខេត្តក្រចេះ សំខាន់ដើម្បីឲ្យគាត់ប្រមូលកម្លាំងប្រជារាស្ត្រ កសាងផ្លូវជាតិលេខ១៣។ បន្ទាប់មកទៀត គាត់ផ្លាស់មកធ្វើជាចៅហ្វាយខេត្តកំពង់ស្ពឺ, ខេត្តសៀមរាប និងខេត្តកំពត ជាបន្តបន្ទាប់។

នៅក្នុងអំឡុងពេលកងទ័ពជប៉ុន បើកប្រតិបត្តិការផ្តេកបន្ទោរចាប់ពួកបារាំង ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៤៥ គាត់ក៏បានបង្ហាញជំហរគាំទ្រជប៉ុន និងប្រឆាំងនឹងបារាំង ផងដែរ ។

ចំណែកញ៉ឹក ជូឡុង ជារដ្ឋមន្ត្រីក្រសួងអប់រំ កើតនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩០៨ ក្នុងត្រកូលគ្រួសារអភិជនជិតស្និទ្ធនឹងព្រះបរមរាជវាំង។ បន្ទាប់ពីបានសិក្សានៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ គាត់បានបន្តការសិក្សានៅវិទ្យាល័យសាស្ស៊ីលូ ឡូបា (Chasseloup Laubat) នៅទីក្រុងព្រៃនគរ។

នៅក្នុងឆ្នាំ១៩៣២ គាត់បានចូលរួមបម្រើការងារជាចៅហ្វាយស្រុក ពីស្រុកមួយទៅស្រុកមួយជាបន្តបន្ទាប់ ។

គាត់ត្រូវបានតែងតាំងជាចៅហ្វាយខេត្តពោធិ៍សាត់ ពីឆ្នាំ១៩៣២ ដល់១៩៣៩ និងជាចៅហ្វាយខេត្តកំពង់ចាម ពីឆ្នាំ១៩៣៩ ដល់១៩៤៥។

របត់នយោបាយ

នៅពេលកងទ័ពជប៉ុន បើកប្រតិបត្តិការផ្តេកបន្ទោរចាប់បារាំងថ្ងៃទី០៩ ខែមីនា ឆ្នាំ ១៩៤៥ គាត់ត្រូវបានតែងតាំងជាអភិបាលក្រុងភ្នំពេញ។

ក្រោយពីបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី មក សឺង ង៉ុកថាញ់ មានបំណង ធ្វើទំនាក់ទំនងជាមួយប្រទេសវៀតណាម និងបណ្តាប្រទេសនៅអាស៊ីទាំងអស់ ឲ្យមាន ភាពល្អប្រសើរឡើងវិញ ដើម្បីរួបរួមសហការគ្នាប្រឆាំងនឹងបារាំង មិនឲ្យវិលត្រឡប់មក ត្រួតត្រាធ្វើអាណានិគមនិយមបន្តទៀត។

ពិសេសសឺង ង៉ុកថាញ់ បានអំពាវនាវឲ្យជនជាតិខ្មែរទាំងអស់ធ្វើសហប្រតិបត្តិការ ដោយចិត្តស្មោះស្ម័គ្រ និងដោយភាតរភាពជាមួយពួកវៀតមិញ ផងដែរ ។

សឺង ង៉ុកថាញ់ បានទទួលស្គាល់ឯករាជ្យនៃរបបសាធារណរដ្ឋប្រជាធិបតេយ្យ វៀតណាម របស់ហូ ជីមិញ ដែលបានប្រកាសជាផ្លូវការនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៤៥ ដែលជួនគ្នានឹងថ្ងៃព្រះចៅអធិរាជរបស់ប្រទេសជប៉ុន ធ្វើពិធីប្រកាសឲ្យចុះចាញ់សង្គ្រាម នៅអាស៊ីជាផ្លូវការដែរ។

ក្រោយពីការទម្លាក់គ្រាប់បែកបរមាណូរបស់សហរដ្ឋមេរិក ទៅលើទីក្រុងហ៊ីរ៉ូហ្ស៊ីម៉ា នៅថ្ងៃទី០៦ ខែសីហា និងទៅលើទីក្រុងណាហ្គាសាគី នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៤៥ នោះ ព្រះចៅអធិរាជរបស់ប្រទេសជប៉ុន បានប្រកាសសុំចុះចាញ់សង្គ្រាមនៅថ្ងៃទី១៥ ខែ សីហា ឆ្នាំ១៩៤៥ តែមិនទាន់ធ្វើពិធីប្រកាសឲ្យចុះចាញ់សង្គ្រាមជាផ្លូវការទេ គឺនៅថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ១៩៤៥ ទើបធ្វើពិធីនេះជាផ្លូវការ។

ចំណែកប្រទេសអ៊ីតាលី បានប្រកាសចុះចាញ់សង្គ្រាមតាំងពីឆ្នាំ១៩៤៣ ហើយ ប្រទេសអាល្លឺម៉ង់ ក៏បានប្រកាសទម្លាក់អាវុធចុះចាញ់សង្គ្រាមនៅអ៊ឺរ៉ុប ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៤៥ដែរ។

ដូច្នេះសង្គ្រាមលោកលើកទី២ ដែលចាប់ផ្តើមនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៤ បណ្តាល ឲ្យបាត់បង់ជីវិតមនុស្សសរុបចំនួន៥៥លាននាក់នោះ ត្រូវបានបញ្ចប់ទាំងស្រុងនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ខណៈដែលសង្គ្រាមលោកលើកទី១ ដែលចាប់ផ្តើមឡើងពីឆ្នាំ១៩១៤

ដល់ឆ្នាំ១៩១៨ មានការបាត់បង់ជីវិតមនុស្ស១៥លាននាក់។

ដោយសារដឹងច្បាស់ថា ខ្លួនត្រូវបាត់បង់ជប៉ុន ជាខ្នងបង្អែកក្នុងពេលដ៏ខ្លីខាងមុខនេះ លោកសឺង ង៉ុកថាញ់ បានចាត់ឲ្យយុវជនខ្មែរកាត់ចិនម្នាក់ឈ្មោះអៀ ស៊ីចូវ ដែលជាសហការីដ៏ជិតស្និទ្ធបំផុតរបស់គាត់ ឲ្យធ្វើដំណើរទៅប្រទេសចិន ដើម្បីស្វែងរកជំនួយពីមេដឹកនាំប្រទេសនេះផងដែរ ។

តាមរយៈប្អូនប្រុសគាត់ម្នាក់ឈ្មោះ សឺង ថៃង្វៀន ជាមេបញ្ជាការកងទ័ពវៀតមិញ ដែលនៅទឹកដីកម្ពុជាក្រោម សឺង ង៉ុកថាញ់ បានជួបទាក់ទងមេដឹកនាំវៀតមិញ ក្នុងគោលបំណងសហការគ្នាដើម្បីតស៊ូប្រឆាំងនឹងការវិលត្រឡប់របស់បារាំង មកត្រួតត្រាធ្វើអាណានិគមនៅកម្ពុជា ឡើងវិញ គាត់បានចាត់តំណាងម្នាក់ឲ្យជួបចរចាគ្នាជាមួយពួកមេដឹកនាំវៀតមិញ នៅវៀតណាមភាគខាងត្បូងនោះ ។ ប៉ុន្តែតំណាងដែលគាត់ចាត់ឲ្យទៅចរចានោះ អនុវត្តខុសគោលការណ៍ដែលគាត់បានគ្រោងទុក បែរជាដាក់លក្ខខណ្ឌចំពោះភាគីវៀតមិញថា ត្រូវប្រគល់ខេត្តត្រាវិញ និងសុកត្រាំង ដែលវៀតណាមដណ្តើមយកពីកម្ពុជាទៅនោះ ប្រគល់មកឲ្យកម្ពុជាវិញសិន ទើបកម្ពុជាយល់ព្រមសហការជាមួយ។

ដោយសារតែតំណាងរបស់គាត់ដាក់លក្ខខណ្ឌបែបនេះ ទើបធ្វើឲ្យផែនការចរចារវាងគាត់និងពួកវៀតមិញនោះ ត្រូវបរាជ័យទាំងស្រុង។

ឆ្លៀតឱកាសនោះដែរ នៅដើមខែតុលា ឆ្នាំ១៩៤៥ ដោយមានការឯកភាពពីព្រះមហាក្សត្រនរោត្តម សីហនុ ផងដែរ ឃឹម ទិត ជារដ្ឋមន្ត្រីក្រសួងការពារជាតិ សាធារណការ និងសុខាភិបាល នៅក្នុងរាជរដ្ឋាភិបាលដែល



**ឃឹម ទិត**

**របត់នយោបាយ**

សឹង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រី ក៏បានលួចធ្វើដំណើរទៅទីក្រុងព្រៃនគរ ជួបអគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ឈ្មោះឡឺគ្លេក ( Le clerc ) ប្រាប់ពីអាថ៌កំបាំងនៃផែនការរបស់ សឹង ង៉ុកថាញ់ ដែលមានបំណងចង់សហការជាមួយពួកវៀតមិញ ដើម្បីប្រឆាំងបារាំង មិនឲ្យចូលមកធ្វើអាណាព្យាបាលលើប្រទេសកម្ពុជា ជាថ្មីម្តងទៀតនោះផងដែរ។

ពេលនោះ ក្នុងនាមព្រះមហាក្សត្រនរោត្តម សីហនុ ឃឹម ទិត បានស្នើសុំឲ្យបារាំងវិលត្រឡប់ទៅទីក្រុងភ្នំពេញ វិញជាបន្ទាន់ និងជួយចាត់វិធានការយ៉ាងណា កុំឲ្យសឹង ង៉ុកថាញ់ ចងសម្ព័ន្ធភាពជាមួយពួកវៀតមិញ បាន ព្រោះសម្ព័ន្ធភាពនេះ ពុំមែននាំឯករាជ្យមកឲ្យកម្ពុជាទេ គឺមានតែធ្វើឲ្យពួកវៀតមិញ ចូលមកកាន់កាប់ត្រួតត្រាប្រទេសកម្ពុជា តែប៉ុណ្ណោះ ។

# ១៦
# បារាំង ត្រឡប់មកត្រួតត្រាប្រទេសខ្មែរវិញ



**កងទ័ពជប៉ុន ឈរគោរពមេទ័ពបារាំង ពេលវិលត្រឡប់មកត្រួតត្រាប្រទេសខ្មែរ វិញ**

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៤៥ កងទ័ពសម្ព័ន្ធមិត្ត បារាំង អង់គ្លេស និងឥណ្ឌា ដែលមានវរសេនីយ៍ អ៊ីឌី មូរ៉ាយ (E.D Murray) ជាមេបញ្ជាការរួម បាននាំកងទ័ពចូលមកដល់ទីក្រុងភ្នំពេញ ហើយបានរំដោះមន្ត្រីយោធា ស៊ីវិល និងជនជាតិបារាំងទាំងអស់ ដែលពួកជប៉ុន បានចាប់យកទៅឃុំឃាំងតាំងពីខែមីនា មកនោះ ឲ្យមានសេរីភាពវិញអស់ និងធ្វើការដកហូតអាវុធពីកងទ័ពជប៉ុនទាំងអស់ នៅក្នុងប្រទេសកម្ពុជា ផងដែរ ។

ពេលនោះ ឃឹម ទិត ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាមិត្តដ៏ស្និទ្ធស្នាលរបស់វរសេនីយ៍ អ៊ីឌី មូរ៉ាយ (E.D Murray) ផងនោះ មិនឲ្យមេបញ្ជាការកងទ័ពបារាំងរូបនេះ ចូលជួបសឹង ង៉ុកថាញ់ ជានាយករដ្ឋមន្ត្រីរបស់ខ្លួនទេ។



**កងទ័ពជប៉ុន ចុះចាញ់ និងប្រគល់អាវុធឱ្យមេបញ្ជាការបារាំង**

វរសេនីយ៍ អ៊ីឌី ម៉ូរ៉ាយ បានសួរទៅឃឹម ទិត ថា ហេតុអ្វីបានជាមិនឲ្យខ្ញុំទៅជួបនាយករដ្ឋមន្ត្រីសឺង ង៉ុកថាញ់? ឃឹម ទិត ឆ្លើយថា មកពីសឺង ង៉ុកថាញ់ មានគំនិតប្រឆាំងនឹងបារាំង ព្រមទាំងព្រះមហាក្សត្រសីហនុ ផងដែរ។

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៥ ឧត្តមសេនីយ៍ឡឺក្លែក (Le clerc) ជាអគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ដែលទើបតែមកទទួលមុខតំណែងបាន១៥ថ្ងៃ បានធ្វើដំណើរតាមយន្តហោះពីទីក្រុងព្រៃនគរ មកទីក្រុងភ្នំពេញ ។

ពេលនោះ វរសេនីយ៍ អ៊ីឌី ម៉ូរ៉ាយ (E.D Murray) បានឲ្យទាហាននៅក្រោមបញ្ជាលោក ទៅហៅសឺង ង៉ុកថាញ់ ឲ្យមកជួបគាត់នៅការិយាល័យគាត់ផ្ទាល់តែម្តង ដើម្បីរង់ចាំទទួលអគ្គទេសាភិបាល ឡឺក្លែក ( Leclerc ) ។

នៅពេលឧត្តមសេនីយ៍ឡឺក្លែក (Le clerc) ចូលមកដល់ក្នុងការិយាល័យ សឺង ង៉ុកថាញ់ បានក្រោកឈរដើម្បីទទួលស្វាគមន៍ ដោយនិយាយថា សួស្តី! តែឧត្តមសេនីយ៍

ឡឺគ្លែក (Leclerc) មិនបានទទួលស្វាគមន៍សឺង ង៉ុកថាញ់ វិញបន្តិចសោះឡើយ ហើយក្រុមអង្គរក្សរបស់ឧត្តមសេនីយ៍រូបនេះ ក៏បានទាញកអាវសឺង ង៉ុកថាញ់ ចាប់ចង ហើយរុញបញ្ចូលទៅក្នុងរថយន្ត បញ្ជូនទៅដាក់គុកនៅព្រៃនគរ កូសាំងស៊ីន (កម្ពុជាក្រោម) ។

ក្រោយមក បារាំងក៏បាននិរទេសសឺង ង៉ុក ថាញ់ ទៅបង្ខាំងទុកនៅព័រជេ (Poitiers) ប្រទេសបារាំង ។ រយៈពេលដែលបង្ខាំងទុកនៅប្រទេសបារាំងនោះ គាត់បានឆ្លៀតឱកាសរៀនបន្ត រហូតដល់បានប្រលងជាប់បរិញ្ញាបត្រផ្នែកច្បាប់។

ពេលកងទ័ពអង់គ្លេស បារាំង និងឥណ្ឌា ចូលមកដល់ទីក្រុងភ្នំពេញ អៀ ស៊ីចូវ ដែលសឺង ង៉ុកថាញ់ ចាត់ឲ្យទៅទាក់ទងមេដឹកនាំចិន ដើម្បីសុំជំនួយធ្វើសង្គ្រាមប្រឆាំងនឹងបារាំងនោះ ក៏ត្រូវពួកបារាំងចាប់បាននៅត្រង់ចំណុចព្រំដែនប្រទេសវៀតណាម និងចិន ។

ក្រោយពីបារាំង ចាប់សឺង ង៉ុកថាញ់ យកទៅបាត់នោះ មិនមានការធ្វើបាតុកម្មតវ៉ាទាមទារឲ្យដោះលែងគាត់មកវិញ ដូចកាលបារាំង ចាប់លោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង កាលពីខែកក្កដា ឆ្នាំ១៩៤២នោះទេ ផ្ទុយទៅវិញ សហការីជិតស្និទ្ធគាត់ជាច្រើន បាននាំគ្នារត់គេចខ្លួន ព្រោះខ្លាចបារាំង ចាប់ខ្លួនដែរ ។

ប៉ាច ឈឺន អតីតអ្នកទោសកោះត្រឡាច និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងផ្គត់ផ្គង់, ចៅសែន កុសល ចៅហ្វាយខេត្តកំពង់ចាម និងចៅហ្វាយស្រុក៧នាក់ទៀត បាននាំគ្នារត់គេចខ្លួនចូលទៅប្រទេសវៀតណាម ។

ចំណែកហែម សាវ៉ាង ជានាយទាហានម្នាក់ ក្នុងចំណោមកងទ័ពស្ម័គ្រចិត្តក្រោមការគ្រប់គ្រងរបស់ជប៉ុន រឺយុវក្មេងទាំង៧នាក់ ដែលបានចូលទៅអុកឡុកក្នុងព្រះបរមរាជវាំង ដើម្បីគំរាមព្រះមហាក្សត្រនរោត្តម សីហនុ ឲ្យចុះចេញពីនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី០៩ ខែសីហា ហើយត្រូវសឺង ង៉ុកថាញ់ ចាប់ដាក់ពន្ធនាគារដែរនោះ ក៏បានរត់ចេញពីពន្ធនាគារនៅក្នុងខែធ្នូ ឆ្នាំ១៩៤៥ ទៅចូលព្រៃតស៊ូដែរ។

ចំណែកទ្រង់នរោត្តម ចន្ទរង្សី បានរត់ទៅខេត្តបាត់ដំបង ដែលស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋាភិបាលសៀម ដើម្បីទៅរួបរួមជាមួយចលនាតស៊ូខ្មែរឥស្សរៈ ដែលរដ្ឋា-

ភិបាលសៀម បានជួយបង្កើតឡើងនោះផងដែរ។

ពេលនោះ មិនថាខ្មែរដែលមាននិន្នាការប្រឆាំងនឹងបារាំងនោះទេ សូម្បីតែជនជាតិវៀតណាម នៅទីក្រុងភ្នំពេញ និងតាមខេត្តនានាជាច្រើន ក៏បាននាំគ្នាគេចខ្លួនទៅទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) ដែលជាស្រុកកំណើតរបស់ពួកគេវិញដែរ ដោយសារខ្លាចបារាំង សងសឹកធ្វើបាបមកលើពួកគេវិញ ។

ក្រោយពេលបារាំង ត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ ព្រះមហាក្សត្រសីហនុ ដែលបានប្រកាសរំលាយចោលសន្ធិសញ្ញាខ្មែរបារាំង ឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤ ដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រនរោត្តម ជាព្រះអយ្យិកោព្រះអង្គ ហើយបានប្រកាសថា ចក្រភពព្រះអាទិត្យ (ប្រទេសជប៉ុន) បានមកជួយរំដោះប្រជាជនអាស៊ី ពិសេសបានផ្តល់ឯករាជ្យឲ្យប្រទេសកម្ពុជា រួចផុតពីកណ្តាប់ដៃរបស់ពួកអាណានិគមនិយមបារាំងនោះ ព្រះអង្គបានប្រើវិធីលួងលោម ដើម្បីឲ្យបារាំង មានការយោគយល់ចំពោះព្រះអង្គ។

ព្រះមហាក្សត្រសីហនុ បានលើកហេតុផលថា ប្រទេសយើងខ្ញុំក្រីក្រលំបាកតោក-យ៉ាកខ្លាំងណាស់ ដូច្នេះដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការផ្សេងៗ ឬដើម្បីការពារប្រទេស យើងខ្ញុំត្រូវតែរេទៅតាមសភាពការណ៍ជាក់ស្តែង ព្រោះយើងជាប្រជាជាតិមួយដែលមានប្រជាជនតែ៣លាននាក់ ហើយស្ថិតនៅចន្លោះប្រទេសសៀម ដែលមានប្រជាជន១២លាននាក់ និងប្រទេសវៀតណាម មានប្រជាជន២០លាននាក់ផងដែរ។

ឯពួកបារាំង ក៏បានដឹងច្បាស់តាមរយៈឃឹម ទិត ដែរថា ព្រះមហាក្សត្រនរោត្តម សីហនុ គឺជាអ្នកស្នើសុំឲ្យបារាំង ត្រឡប់មកកម្ចាត់ពួកសឹង ង៉ុកថាញ់ ដែលជាមនុស្សស្និទ្ធនឹងជប៉ុន ហើយព្រះអង្គក៏ចង់ឲ្យបារាំង ត្រឡប់មកគ្រប់គ្រងប្រទេសកម្ពុជាវិញដែរ។

ទីបំផុត បារាំង នៅតែរក្សាសម្តេចព្រះនរោត្តម សីហនុ ជាព្រះមហាក្សត្រ នៃប្រទេសកម្ពុជាដដែល។

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៤៥ បារាំង បានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយ ដោយបានតែងតាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ

និងរដ្ឋមន្ត្រីការពារជាតិ , ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស រដ្ឋមន្ត្រីកិច្ចការបរទេស និងអប់រំជាតិ, ចាន់ ណាក ជារដ្ឋមន្ត្រីយុត្តិធម៌, ឃឹម ទិត ជារដ្ឋមន្ត្រីសុខាភិបាល សាធារណការ និងទូរគមនាគមន៍, ស៊ុម ហៀង ជារដ្ឋមន្ត្រីធម្មការ ពុទ្ធិកសិក្សា និងវិចិត្រសិល្បៈ និងវ៉ា កាម៉ែល ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ។

នៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៤៦ បារាំង បានធ្វើសម្បទានឲ្យមានការចុះហត្ថលេខាលើអនុសញ្ញាបារាំង- ខ្មែរ បញ្ចប់ភាពជាអាណាព្យាបាលមកលើប្រទេសខ្មែរជាផ្លូវការ ដោយបានប្រគល់ស្វ័យភាពខាងកិច្ចការរដ្ឋបាលឲ្យខ្មែរវិញ ដោយគ្រាន់តែតម្រូវឲ្យមានមន្ត្រីបារាំងម្នាក់ធ្វើជាទីប្រឹក្សានៅគ្រប់ទីស្តីការរដ្ឋមន្ត្រី និងនៅគ្រប់ខេត្តប៉ុណ្ណោះ។

ជាមួយគ្នានោះ បារាំងបានសន្យាថានឹងធ្វើឲ្យប្រទេសកម្ពុជា មានរដ្ឋធម្មនុញ្ញមួយតាមបែបលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សទៀតផង ពោលគឺមិនឲ្យប្រទេសកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំងទាំងស្រុងដូចពីមុនទៀតទេ ហើយបារាំង ក៏បានបញ្ចូលប្រទេសកម្ពុជា ជាសមាជិកសហភាពបារាំង ដោយមានប្រទេសផ្សេងៗទៀត ជាអតីតប្រទេសក្រោមអាណានិគមនិយមបារាំងទាំងអស់ ចូលរួមជាសមាជិកផងដែរ។

# ១៧
# លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដំបូងនៅកម្ពុជា



**ឧត្តមសេនីយ៍ ឡឺគ្លេក (Le clerc) អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ធ្វើដំណើរទៅក្រុងហាណូយ ឆ្នាំ១៩៤៦**

ក្រោយពីបានត្រឡប់ចូលមកគ្រួតត្រានៅតំបន់ឥណ្ឌូចិន ជាថ្មីវិញ បារាំងក៏បានលើកព្រះចៅបៅ ដាយ ឲ្យកាន់អំណាចនៅប្រទេសវៀតណាមបន្តទៀត និងចាប់ផ្ដើមវាយបំបាក់ពួកវៀតមិញ និងប្រជាប្រិយភាពរបស់ ហូ ជីមិញ ដែលជាបិតាឯករាជ្យនៅវៀតណាមភាគខាងជើងនោះ មិនឲ្យសាយភាយមកដល់ភាគខាងត្បូងដោយងាយស្រួលឡើយ។

ចំណែកប្រទេសកម្ពុជា អគ្គទេសាភិបាលបារាំង ឡឺគ្លេក (Leclerc) បានរៀបចំសមាសភាពរាជរដ្ឋាភិបាលថ្មីមួយ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៤៥ ដោយបានតែងតាំងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារជាតិនោះ គឺដោយសារតែស្នងការជាន់ខ្ពស់បារាំងរូបនេះ មានមនោសញ្ចេតនាយោគយល់ចំពោះព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត តែប៉ុណ្ណោះ។

ក្រោយពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត បានឡើងធ្វើជានាយករដ្ឋមន្ត្រី នៅភូមិគ្រឹះដ៏ធំស៊ីមស្ទៃរបស់ប៉ុក ហ៊ែល ជាឪពុកក្មេករបស់ទ្រង់ មានភ្ញៀវជាមន្ត្រីធំៗ និងជំទាវៗជាភរិយា នាំគ្នាចេញចូលមិនដាច់ ដើម្បីយកគាប់យកគួរសុំបុណ្យស័ក្តិតួនាទីរៀងៗខ្លួន។

មហេសីដ៏ស្រស់ប្រិមប្រិយរបស់ព្រះ-អង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត គឺអ្នកម្នាងវ៉ាន់ណេរ៉ូហ្សេត ប៉ុក (Vanne Rosette Pok) ជាកូនស្រីរបស់ប៉ុក ហ៊ែល ហើយប៉ុក ហ៊ែល នេះ ជាកូនប្រសារបស់ឧកញ៉ាចៅហ្វាវាំងជួន។



**អ្នកម្នាង វ៉ាន់ណេ រ៉ូហ្សេត ប៉ុក មហេសី ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត**

អនុវត្តតាមអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៤៦ ចាប់ពីខែមីនា ឆ្នាំ ១៩៤៦នោះមក ដោយមានការឯកភាពពីព្រះមហាក្សត្រនរោត្តម សីហនុ ផងដែរនោះ ទេសាភិបាលបារាំង ឈ្មោះលុយស្សៀង វ៉ាំង សង់ លូបេត (Lucien Vincent Loubet) បានប្រគល់ភារកិច្ចឲ្យព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រី ដឹកនាំការតាក់តែងពង្រាងរដ្ឋធម្មនុញ្ញមួយ ដែលប្រទេសកម្ពុជា មិនធ្លាប់មានពីមុនមក ។

ទ្រង់ស៊ីសុវត្ថិ មុនីរ៉េត និងទីប្រឹក្សាជាជនជាតិបារាំងប៉ុន្មាននាក់ទៀត នាំគ្នាតាក់តែងពង្រាងរដ្ឋធម្មនុញ្ញនោះអស់ រយៈពេលជាច្រើនសប្តាហ៍ ទើបបានបញ្ចប់។ តែពង្រាងរដ្ឋ-ធម្មនុញ្ញនោះ តម្រូវឲ្យមានការដឹកនាំគ្រប់គ្រងប្រទេសមានភាពតឹងរ៉ឹងពេក មតិភាគច្រើនមិនអាចទទួលយកបាន អគ្គទេសាភិបាលបារាំង ឡឺគ្លែក (Leclerc) ក៏បានស្នើព្រះ-មហាក្សត្រនរោត្តម សីហនុ រៀបចំឲ្យមានការបោះឆ្នោតសាកលមួយ ដែលមានគណបក្ស

រូបតំណាងគណបក្សនយោបាយ

នយោបាយច្រើនចូលរួម ដើម្បីជ្រើសរើសតំណាងរាស្ត្រនៅក្នុងរដ្ឋសភា រួចហើយឲ្យតំណាងរាស្ត្រនៅក្នុងរដ្ឋសភានោះ ធ្វើការពិភាក្សា និងអនុម័តពង្រាងរដ្ឋធម្មនុញ្ញនោះតែម្ដងទៅ។

តែក្រុមអ្នកប្រជាធិបតេយ្យនិយម ទាមទារឲ្យមានការបោះឆ្នោតសាកលមួយ ដើម្បីបង្កើតសភាធម្មនុញ្ញ ហើយសភាធម្មនុញ្ញនោះ គឺជាអ្នកតាក់តែងរដ្ឋធម្មនុញ្ញប្រកបដោយឯករាជ្យពេញលេញ ។

តែយ៉ាងណា ទេសាភិបាលបារាំង នៅតែចង់បានរដ្ឋធម្មនុញ្ញមួយដែលមានការសម្បទានពីព្រះមហាក្សត្រ ហើយពង្រាងរដ្ឋធម្មនុញ្ញនោះត្រូវតែតាក់តែងដោយនាយករដ្ឋមន្ត្រីដដែល។

ក្រុមអ្នកប្រជាធិបតេយ្យនិយម នៅតែទាមទារឲ្យបង្កើតសភាធម្មនុញ្ញមួយ ដែលកើតចេញពីឆន្ទៈរបស់ប្រជារាស្ត្រ តាមរយៈការបោះឆ្នោតសាកល ហើយសភាធម្មនុញ្ញនោះជាអ្នកតាក់តែងធម្មនុញ្ញដោយផ្ទាល់តែម្ដង ដោយគ្មានការជ្រៀតជ្រែកពីពួកបារាំង និងពីរាជរដ្ឋាភិបាល ដោយគ្រាន់តែសុំឲ្យព្រះមហាក្សត្រគង់នៅជាអាជ្ញាកណ្ដាលប៉ុណ្ណោះ។

ទីបំផុត ទេសាភិបាលបារាំង លុយស្សៀង វ៉ាំងសង់ លូបេត (Lucien Vincent Loubet) បានសម្រេចថា ទោះបីយ៉ាងណា ព្រះមហាក្សត្រនរោត្តម សីហនុ ត្រូវតែជាអ្នកតាក់តែងរដ្ឋធម្មនុញ្ញនេះ ព្រោះមានតែព្រះអង្គទេ ដែលស្គាល់នូវផ្នត់គំនិត និងសេចក្ដីត្រូវការពិតប្រាកដរបស់ប្រជារាស្ត្រព្រះអង្គ ដោយមិនបណ្ដោយឲ្យពួកនយោបាយគ្មានបទពិសោធន៍ក្នុងការដឹកនាំប្រទេស ជាអ្នកតាក់តែងរដ្ឋធម្មនុញ្ញនេះតាមអំពើចិត្តបានឡើយ ។

តែព្រះមហាក្សត្រនរោត្តម សីហនុ បានសារភាពប្រាប់ទេសាភិបាលបារាំង តាមត្រង់ថា ការពិតព្រះអង្គក៏មិនដឹងច្បាស់ថា រដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យនោះគឺជាអ្វីផង ហើយបញ្ហាតាក់តែងរដ្ឋធម្មនុញ្ញនេះ គឺហួសពីសមត្ថភាពរបស់ព្រះអង្គផងដែរ។

ប៉ុន្តែដោយសារពួកប្រជាធិបតេយ្យ ក៏បានស្នើសុំឲ្យព្រះអង្គនៅជាអាជ្ញាកណ្ដាល ហើយដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នា រវាងក្រុមមន្ត្រីដែលមានគំនិតរាជាធិបតេយ្យនិយម និងពួកប្រជាធិបតេយ្យនិយម ក្នុងការបង្កើតរដ្ឋធម្មនុញ្ញនេះ តទៅទៀត ព្រះអង្គបានសម្រេចព្រះទ័យថា៖

ទី១ ព្រះអង្គនឹងធ្វើសម្បទាននូវរដ្ឋធម្មនុញ្ញមួយដល់ប្រជារាស្ត្ររបស់ព្រះអង្គ ស្របតាមបំណងដែលទេសាភិបាលបារាំង និងពួកមន្ត្រីខ្មែរដែលមានគំនិតរាជាធិបតេយ្យនិយម ចង់បាន។

ទី២ ព្រះអង្គយល់ព្រមទទួលយកពង្រាងរដ្ឋធម្មនុញ្ញដែលព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រី និងពួកទីប្រឹក្សាបារាំង ជាអ្នកតាក់តែងនោះជាបណ្ដោះអាសន្ន។

ទី៣ សភាដែលកើតឡើងចេញពីការបោះឆ្នោតនៅពេលខាងមុខនេះ មិនត្រូវឲ្យឈ្មោះថាសភាធម្មនុញ្ញទេ ប៉ុន្តែសភានេះមានសិទ្ធិកែប្រែខ្លឹមសារ និងមាត្រាខ្លះលើពង្រាងរដ្ឋធម្មនុញ្ញដែលតាក់តែងដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត នោះ តែមិនត្រូវឲ្យប៉ះពាល់ដល់ប្រការណាមួយដែលជាគោលការណ៍នៃរបបរាជាធិបតេយ្យឡើយ។

ការសម្រេចព្រះទ័យទាំងបីចំណុចខាងលើនេះ ធ្វើឲ្យទេសាភិបាលបារាំង លុយសៀង វ៉ាំងសង់ លូបេត និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រី មានការព្រួយបារម្ភយ៉ាងខ្លាំង។ ប៉ុន្តែការសម្រេចព្រះទ័យនេះ ត្រូវបានទទួលការអបអរសាទរដោយក្ដីរីករាយបំផុតពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស និងពួកអ្នកប្រជាធិបតេយ្យនិយម ។


ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ប្រសូតនៅក្នុងឆ្នាំ១៩១៣ នៅអតីតវាំងចាស់ឧដុង្គ ខេត្តកំពង់ស្ពឺ ជាបុត្រារបស់ព្រះអង្គម្ចាស់ចម្រើនវង្ស (១៨៧០-១៩១៦) និងម្ចាស់ក្សត្រីស៊ីសុវត្ថិ យប់ហ៊ីផាន (១៨៧៧-១៩៦៧) ។

បន្ទាប់ពីប្រឡងជាប់ថ្នាក់បណ្ឌិតផ្នែកគីមី ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស បានចាកចេញពីក្រុងម៉ុងប៉ីលីយេ (Montpellier) មករស់នៅទីក្រុងប៉ារីស និង

ចូលបម្រើការងារនៅក្រសួងអាណានិគមបារាំង។

ទ្រង់បានរៀបការជាមួយកញ្ញាដូមីនិក ឡាវ៉ឺន (Dominque Laverne) ជាជនជាតិបារាំង និងជាសកម្មជននៃគណបក្សសង្គមនិយមបារាំង នៅប្រទេសបារាំង។

ទ្រង់មានបុត្រី២អង្គ គឺស៊ីសុវត្ថិ កន្ទារ៉ា (កើតឆ្នាំ១៩៤៥) និងស៊ីសុវត្ថិ លីណានដា (កើតឆ្នាំ១៩៤៦ )។

នៅក្នុងឆ្នាំ១៩៤៥ ទ្រង់បានបង្កើតសមាគមមួយឈ្មោះថា សមាគមភាតរភាពខ្មែរ ដោយមាន ឈាន វ៉ម មានបរិញ្ញាបត្រទស្សនវិជ្ជា, ថុន អ៊ុក មានបរិញ្ញាបត្រប្រវត្តិវិទ្យា និង ងិន ការ៉េត មានបរិញ្ញាបត្រភូមិវិទ្យា ចូលរួមផងដែរ។

ការបង្កើតសមាគមភាតរភាពខ្មែរនេះ គឺដើម្បីជួយដល់ជនជាតិខ្មែរទាំងឡាយដែលជាប់កំណែន ត្រូវបារាំងបញ្ជូនឲ្យទៅធ្វើទាហាន ដើម្បីជួយធ្វើសង្គ្រាមវាយបណ្ដេញពួកណាហ្ស៊ីអាល្លឺម៉ង់ ចេញពីប្រទេសបារាំង ក្នុងសង្គ្រាមលោកលើកទី២ ។

សមាគមនេះ មានទីស្នាក់ការនៅនឹងផ្ទះរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស នៅក្នុងទីក្រុងប៉ារីស នោះតែម្ដង។

ពេលនោះ និស្សិតខ្មែរដែលបានទៅសិក្សានៅប្រទេសបារាំង មានតែ៨នាក់ប៉ុណ្ណោះ គឺក្រៅពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស, ឈាន វ៉ម, ថុន អ៊ុក និងងិន ការ៉េត មាននិស្សិតខ្មែរ៤នាក់ទៀត គឺជួន មុម្ម, ជួន ជឿន, ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត និងអូ ឈៀង ។

ឈាន វ៉ម បានត្រឡប់មកមាតុប្រទេសវិញមុនគេ ដោយបាននាំបណ្ដាំជាច្រើនរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស មកជាមួយផង។ ចំណែកនិស្សិតផ្សេងៗទៀតបានមកជាបន្តបន្ទាប់ ក្នុងចន្លោះពេលពីរបីខែក្រោយមក។

ពេលនោះ ពួកបញ្ញវន្តនៅទីក្រុងភ្នំពេញ ដូចជា អៀវ កើស និងស៊ឹម វ៉ា ដែលមានទស្សនៈដូចគ្នា បានចាប់ផ្ដើមធ្វើការទាក់ទងជាមួយឈាន វ៉ម និងថុន អ៊ុក ជាបញ្ញវន្តមកពីប្រទេសបារាំងនោះ ហើយបានជួបពិភាក្សាគ្នាជាញឹកញាប់ ដើម្បីបង្កើតគណបក្សនយោបាយមួយ ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនៅពេលខាងមុខ។

ដោយមានអ្នកច្បាប់ជាជនជាតិបារាំងម្នាក់ ជួយតាក់តែងលក្ខន្តិកៈផងនោះ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៤៦ ក្រុមអ្នកប្រជាធិបតេយ្យនិយមបានស្រុះស្រួលមូលមតិគ្នាបង្កើតគណបក្សមួយ ឈ្មោះគណបក្សប្រជាធិបតេយ្យ ដោយមានឈាន វ៉ម ជាអគ្គលេខាធិការគណបក្ស។

ពេលនោះ សឺន សាន ជាបញ្ញវន្តមានសញ្ញាបត្រជាន់ខ្ពស់ខាងពាណិជ្ជកម្ម មកពីទីក្រុងប៉ារីស ឆ្នាំ១៩៣៣ និងប៉ែន នុត ជាចៅហ្វាយក្រុងភ្នំពេញ មានសញ្ញាបត្រពីសាលាបណ្តុះបណ្តាលក្រមការនៅទីក្រុងភ្នំពេញ មានការស្ទាក់ស្ទើរមិនទាន់ចង់ចូលរួមជាមួយគណបក្សប្រជាធិបតេយ្យនោះទេ។

តែពេលនោះ ក្នុងនាមជាចៅហ្វាយក្រុងភ្នំពេញ បានអនុញ្ញាតឲ្យក្រុមប្រជាធិបតេយ្យប្រើប្រាស់បន្ទប់របស់គាត់មួយ សម្រាប់ធ្វើជាកន្លែងប្រជុំផ្សេងៗដែរ។

លុះដល់ខែមិថុនា ឆ្នាំ១៩៤៦ គឺបន្ទាប់ពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស យាងពីក្រុងប៉ារីស មកដល់ក្រុងភ្នំពេញ ទើបគណបក្សប្រជាធិបតេយ្យ ត្រូវបានប្រកាសបង្កើតឡើងជាផ្លូវការ ហើយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ត្រូវបានតែងតាំងជាប្រធានគណបក្ស ទើបសឺន សាន និងប៉ែន នុត សម្រេចចិត្តចូលរួមជាមួយគណបក្សប្រជាធិបតេយ្យនោះដែរ។

បាវចនារបស់គណបក្សប្រជាធិបតេយ្យ គឺសន្តិភាព ឯករាជ្យភាព វិន័យ ក្លាហាន និងមានរូបសញ្ញាក្បាលដំរី ប្រមោយត្រកងផ្កាឈូកបី ។

ដំរីជានិមិត្តរូបនៃកម្លាំងដ៏ខ្លាំងក្លា ចំណែកផ្កាឈូកបី ៖ ១.ជានិមិត្តរូបព្រះមហាក្សត្រ, ២.ជានិមិត្តរូបសាសនា និង៣.ជានិមិត្តរូបប្រជារាស្ត្រ។

គណបក្សប្រជាធិបតេយ្យកើតចេញពីបញ្ញវន្តបីក្រុម គឺក្រុមទី១ ជាអ្នកដែលមានសញ្ញាបត្រមកពីប្រទេសបារាំង ដែលមានចំនួនច្រើនជាងគេ។

ក្រុមនេះបានបង្កើតកាសែតជាភាសាបារាំង ប្រចាំសប្តាហ៍មួយឈ្មោះ "ឡឺ ដេម៉ូក្រាត" មានន័យថាប្រជាធិបតេយ្យ។

ក្រុមទី២ ជាអ្នកចេះដឹងដែលបានរៀនសូត្រនៅក្នុងប្រទេស និងទីក្រុងហាណូយ

# របត់នយោបាយ

ក្នុងនោះមាន អៀវ កើស ធ្លាប់បានទៅរៀននៅសាលាពាណិជ្ជកម្មក្រុងហាណូយ រហូតប្រឡងជាប់លេខ១ នៅក្នុងឆ្នាំ១៩២៧ និងក្រុមទី៣ ជាស្ថាបនិកកាសែត "នគរវត្ត" កាលពីឆ្នាំ១៩៣៦ រួមមាន ស៊ឹម វ៉ា និងប៉ាច ឈឺន ជាដើម។

គោលនយោបាយរបស់គណបក្សប្រជាធិបតេយ្យ គឺសុំឲ្យមានការចរចាទាមទារឯករាជ្យពីបារាំង ឱ្យបានឆាប់។

មជ្ឈដ្ឋានព្រះសង្ឃ អ្នករាជការតូចតាច គ្រូបង្រៀន ព្រមទាំងសិស្សៗនៅអនុវិទ្យាល័យ វិទ្យាល័យ ដែលពីមុនធ្លាប់គាំទ្រសឺង ង៉ុកថាញ់ បានងាកមកគាំទ្រគណបក្សនេះវិញភ្លូកទឹកភ្លូកដី។

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៤៦ ព្រះអង្គម្ចាស់នរោត្តម នរិន្ទ្រដេត (១៩០៦-១៩៧៥) ជាចៅរបស់ព្រះមហាក្សត្រនរោត្តម និងស៊ីសុវត្ថិ ដែលធ្លាប់បានទៅសិក្សានៅប្រទេសបារាំងដែរនោះ បានបង្កើតគណបក្សនយោបាយមួយ ឈ្មោះគណបក្សសេរីភាព ។

ព្រះអង្គម្ចាស់នរោត្តម នរិន្ទ្រដេត ប្រធានគណបក្សសេរីភាព យល់ឃើញដូចពួកបារាំងដែរថា ប្រជារាស្ត្រខ្មែរមិនសូវមានការយល់ដឹងទេ ដូច្នេះមិនអាចចង់បានឯករាជ្យឆាប់ៗពីបារាំងនោះទេ គឺត្រូវឱ្យកូនចៅរៀនសូត្រឲ្យបានចេះដឹងជាមុនសិន។

គណបក្សសេរីភាព ជាគណបក្សអភិរក្សនិយម មានការគាំទ្រពីមជ្ឈដ្ឋាននាម៉ឺនមន្ត្រីចាស់ៗ ពួកម្ចាស់ដី និងចាម ចិន ជាអ្នករកស៊ីលក់ដូរ។

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៤៦ ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា (១៩០២-១៩៧៥) ដែលជាចៅរបស់ព្រះអង្គម្ចាស់នរោត្តម ដួងចក្រ និងធ្លាប់បានទៅសិក្សានៅសាលាភូមិន្ទរដ្ឋបាល បានបង្កើតគណបក្សមួយ ឈ្មោះប្រជាធិបតេយ្យចម្រើនជឿនលឿន។

គណបក្សនេះ ជាគណបក្សអភិរក្សនិយម ដូចគណបក្សសេរីភាព ដែរ តែមានអ្នកគាំទ្រតិចតួចប៉ុណ្ណោះ។

នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស លើកដំបូងបង្អស់របស់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៤៦ ព្រះមហាក្សត្រនរោត្តម សីហនុ បាន

ធ្វើការកត់សម្គាល់ថា គណបក្សប្រជាធិបតេយ្យ របស់ទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស បានរៀបចំយុទ្ធនាការឃោសនាបោះឆ្នោតល្អបំផុត និងប្រកបដោយថាមពលខ្លាំងជាងគណបក្ស ២ ទៀត ដាច់ឆ្ងាយតែម្តង ។

គណបក្សប្រជាធិបតេយ្យ មានបញ្ញវន្តជាច្រើន ដូចជា សឺន សាន, ឈាន វ៉ម, ថុន អ៊ុក, ហ៊ុយ កន្ធុល, សុន វ៉ុនសៃ, សុខ ធុង, ស៊ឹម វ៉ា និងប៉ែន នុត ជាដើម បានបែងចែកគ្នាដើរឃោសនាគ្រប់ទិសទី ។

ស៊ឹម វ៉ា, ឈាន វ៉ម, សុខ ធុង, និងអៀវ កើស កាលនៅជាសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងឆ្នាំ១៩៣៧ ធ្លាប់ចូលរួមធ្វើកូដកម្មប្រឆាំងនឹងទេសាភិបាលជាន់ខ្ពស់បារាំងដែលបានសម្រេចឲ្យសិស្សវិទ្យាល័យទាំងអស់ដែលមានអាយុចាប់ពី២០ឆ្នាំឡើងទៅ ត្រូវបង់ពន្ធ (ពន្ធមនុស្ស) ឲ្យពួកបារាំង។

នៅក្នុងឆ្នាំ១៩៤៦ សិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ បានបង្កើតចលនាមួយ ឲ្យឈ្មោះថា ក្រុមរំដោះប្រទេសកម្ពុជា ពីអាណានិគមបារាំង។ ចលនានេះដឹកនាំដោយសិស្សម្នាក់ឈ្មោះ អៀង សារី មានដើមកំណើតនៅកម្ពុជាក្រោម (កូសាំងស៊ីន) ។ គាត់និយាយភាសាខ្មែរប៉ែឡាំៗ មានសំនៀងជាខ្មែរកម្ពុជាក្រោម ។

អៀង សារី មានឈ្មោះដើម គឹម ត្រាង កើតនៅឆ្នាំ១៩២៥ នៅខេត្តត្រាវិញ ទឹកដីកូសាំងស៊ីន ត្រូវបានឪពុកម្តាយប្តូរឈ្មោះឲ្យមកជា អៀង សារី នៅពេលមករៀននៅកម្ពុជា ដើម្បីឲ្យមានសូរសៀងជាឈ្មោះខ្មែរ។ គាត់បានបន្ថយអាយុ៤ឆ្នាំ ដោយប្តូរឆ្នាំកំណើតពីឆ្នាំ ១៩២៥ មកជាឆ្នាំ១៩២៩វិញ ដើម្បីបានចូលរៀននៅសាលាបឋមសិក្សា។

នៅឆ្នាំ១៩៤៥ អៀង សារី បានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ នៅទីក្រុងភ្នំពេញ ហើយបានចូលប្រឡូកក្នុងឆាកនយោបាយ នៅឆ្នាំ១៩៤៦ ដោយបានដឹកនាំក្រុមនិស្សិតប្រឆាំងនឹងអាណានិគមបារាំង។

មួយឆ្នាំក្រោយមក អៀង សារី បានជួបជាមួយសាឡុត ស ពេលដែលសាឡុត ស បានវិលត្រឡប់ពីអនុវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម មករៀននៅសាលាបច្ចេកទេស



**អៀង សារី និង កេង វ៉ាន់សាក់ ពេលនៅរៀននៅប្រទេសបារាំង**

ហៅសាលាដែក នៅឫស្សីកែវ។ អៀង សារី និងសាឡុត ស ក៏បានរាប់អានគ្នាជាមិត្តភក្តិយ៉ាងជិតស្និទ្ធ។

គាត់ជាសិស្សពូកែខាងគណិតវិទ្យា ហើយគាត់បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិភាគ១ (បាក់អង) ដោយមាននិទ្ទេសល្អណាស់។

ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ១៩៤៦ អៀង សារី ក៏ដូចជា អ៊ុំ ស៊ីម និងកេង វ៉ាន់សាក់ ព្រមទាំងសិស្សវិទ្យាល័យស៊ីសុវត្ថិ ជាច្រើនទៀត បានចូលរួមជួយឃោសនារកសំឡេងឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យ។

ជាមួយគ្នានោះ តាមរយៈការជួយឃោសនារបស់ព្រះសង្ឃ និងមន្ត្រីរាជការ ព្រមទាំងសាស្ត្រាចារ្យលោកគ្រូ អ្នកគ្រូផងដែរ គណបក្សប្រជាធិបតេយ្យ ទទួលបានការគាំទ្រពីសំណាក់ប្រជារាស្ត្រពីគ្រប់មជ្ឈដ្ឋាន ហើយអ្វីដែលជាការទាក់ទាញបំផុតនោះ គឺគណបក្សប្រជាធិប-តេយ្យ បានឃោសនាសន្យាថា នឹងទាមទារឯករាជ្យពីបារាំង មកវិញ និងឃោសនាថា បើគណបក្សពួកគេបានជាប់ឆ្នោត ពួកគេនឹងបង្កើតរាជរដ្ឋាភិបាលមួយដោយប្រជារាស្ត្រ និងដើម្បីប្រជារាស្ត្រ។

ព្រះមហាក្សត្រ សីហនុ បានធ្វើការកត់សម្គាល់ទៀតថា ពួកប្រជាធិបតេយ្យ បានដកស្រង់យកឃ្លាប្រយោគខ្លះៗក្នុងព្រះរាជសាររបស់ព្រះអង្គ ដែលបានថ្លែងទៅកាន់ប្រជារាស្ត្រថា ព្រះអង្គនឹងធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមានលទ្ធិប្រជាធិបតេយ្យ និងការអំពាវនាវឲ្យប្រជារាស្ត្រទាំងអស់នៅស្រុកស្រែចម្ការ ដែលស្រឡាញ់គាំទ្រព្រះអង្គ ឲ្យទទួលយកនូវការធ្វើប្រជាធិបតេយ្យូបកម្មនោះ ទៅឃោសនា ដើម្បីយកចំណោញឲ្យគណបក្សពួកគេផងដែរ ។

ព្រះមហាក្សត្រ ឈ្វេងយល់ថា ដោយដឹងច្បាស់ពីប្រជារាស្ត្រខ្មែរមានជំនឿជឿជាក់លើរបបរាជាធិបតេយ្យ គ្មានអ្វីប្រែក្រឡាស់បាននោះ ពួកប្រជាធិបតេយ្យមិនហ៊ានឃោសនាបញ្ចុះបញ្ចូលឲ្យប្រជារាស្ត្រខ្មែរទទួលយករបបប្រជាធិបតេយ្យមួយដែលដកហូតអំណាចទាំងអស់ពីព្រះមហាក្សត្រនោះឡើយ។ ផ្ទុយទៅវិញ ពួកគេបានយកព្រះរាជសង្កថាដែលព្រះអង្គបានប្រកាសអំពាវនាវសុំឲ្យប្រជារាស្ត្រខ្មែរទាំងអស់នាំគ្នាទៅបោះឆ្នោតឲ្យបានគ្រប់ៗគ្នានោះ ទៅឃោសនាទាក់ទាញប្រជារាស្ត្រ យកសន្លឹកឆ្នោតបានមួយចំណែកធំដែរ ។

ប៉ុន្តែសម្រាប់អ្នកគាំទ្រគណបក្សប្រជាធិបតេយ្យ យល់ថា ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលបានស្នាក់នៅ និងសិក្សារៀនសូត្រនៅប្រទេសបារាំង អស់រយៈពេល១៥ឆ្នាំនោះ បាននាំមកនូវគំនិតថ្មីៗ និងសេចក្ដីសង្ឃឹមដល់នយោបាយកម្ពុជា ដែលកំពុងនៅទ្រឹងស្ងៀម គ្មានសកម្មភាពអ្វីទាំងអស់ ហើយពួកគេជឿជាក់ថា ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស នឹងធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍រីកចម្រើនទៅមុខជាមិនខាន។

ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៤៦ ការបោះឆ្នោតសាកលដើម្បីជ្រើសរើសសមាជិកសភាបានប្រព្រឹត្តឡើងជាប្រវត្តិសាស្ត្រដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជា។

លទ្ធផលនៃការបោះឆ្នោតនោះ គឺក្នុងចំណោមអាសនៈសភាសរុប ៦៧អាសនៈ គណបក្សប្រជាធិបតេយ្យ ដែលដឹកនាំដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជាប់ឆ្នោតនៅក្នុងសភាបានចំនួន៥០អាសនៈ ក្នុងនោះ សម ញាណ (ឪពុកសម សារី) ក៏បានជាប់ឆ្នោតជាតំណាងរាស្ត្ររបស់គណបក្សប្រជាធិបតេយ្យម្នាក់ដែរ។

## របត់នយោបាយ

គណបក្សសេរីភាព ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ជាប់ឆ្នោតនៅក្នុងសភា បាន១៤អាសនៈ និងគណបក្សប្រជាធិបតេយ្យចម្រើនជឿនលឿន ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ជាប់ឆ្នោតនៅក្នុងសភាបាន៣អាសនៈ ។

ព្រះមហាក្សត្រនរោត្តម សីហនុ បានវាយតម្លៃថា ជ័យជម្នះរបស់គណបក្សប្រជាធិប-តេយ្យ ដែលទទួលបានអាសនៈនៅក្នុងសភាដ៏ច្រើនសន្ធឹកសន្ធាប់ដូច្នេះ គឺដោយសារប្រជាប្រិយភាពរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលជាជនជាតិខ្មែរដំបូងគេបង្អស់ដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត មកពីប្រទេសបារាំង និងមានមហេសីជាជនជាតិបារាំង ព្រមទាំងពូកែធ្វើនយោបាយបែបប្រជាភិថុតិផងដែរ ។

ក្រោយលទ្ធផលបោះឆ្នោតថ្ងៃទី០១ ខែកញ្ញា នោះ អៀវ កើស ត្រូវបានតែងតាំងជាប្រធានសភា តែមិនមែនជាសភាធម្មនុញ្ញទេ គឺសភាបណ្តោះអាសន្ន។

សភានេះ ត្រូវពិភាក្សាពិគ្រោះយោបល់លើខ្លឹមសារនៃការពង្រាងរដ្ឋធម្មនុញ្ញដែលមានស្រាប់ តែក្នុងលក្ខខណ្ឌមិនឲ្យប៉ះពាល់ដល់របបរាជាធិបតេយ្យ ដែលមាននៅកម្ពុជាតាំងពីយូរលង់ណាស់មកហើយនោះឡើយ។

សមាជិកសភាមកពីគណបក្សជាប់ឆ្នោតទាំង៣ បានធ្វើការសិក្សាពង្រាងរដ្ឋធម្មនុញ្ញនោះ និងបញ្ជូនមតិយោបល់កែប្រែខ្លឹមសារត្រង់ចំណុច ឬមាត្រាណាមួយ ទៅឲ្យគណៈកម្មការជំនាញមួយទទួលបន្ទុកការរៀបចំរដ្ឋធម្មនុញ្ញ ហើយគណៈកម្មការជំនាញនេះត្រូវបញ្ជូនមតិយោបល់កែប្រែខ្លឹមសារនោះទៅថ្វាយព្រះមហាក្សត្រ ដើម្បីពិនិត្យ រួចរង់ចាំព្រះមហាក្សត្រចារព្រះរាជតម្រិះសម្រេចយ៉ាងណា ទើបបញ្ជូនចំណារព្រះរាជតម្រិះនោះត្រឡប់ទៅសភាវិញ ដើម្បីពិភាក្សា និងអនុម័តសម្រេច ។

ទោះបីយ៉ាងណាក៏ដោយ ក៏ការពិភាក្សាលើគម្រោងរដ្ឋធម្មនុញ្ញនៅក្នុងសភានោះមានជំហរពីរផ្ទុយគ្នាដែរ គឺ៖

-ជំហរទី១ មានការខិតខំតស៊ូដោយប្រុងប្រយ័ត្ន ទៅលើការការពាររចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម និងឲ្យមានរបបនយោបាយមួយដែលមានលក្ខណៈប្រជាធិបតេយ្យល្មម

សមម្សេប៉ុណ្ណោះ ហើយរក្សាទុករបបរាជាធិបតេយ្យនិយមបន្តទៀត ដោយឈរលើគោល-ការណ៍ថា អំណាចទាំងអស់ត្រូវចេញពីព្រះមហាក្សត្រ ។

ចំណែកជំហរទី២ ជាគំនិតរបស់សមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ ដែលធ្លាប់ទទួលការសិក្សា និងទទួលមនោគមន៍វិជ្ជាពីប្រទេសលោកខាងលិច ពួកគេមិនចង់ឲ្យព្រះមហាក្សត្រមានអំណាចច្រើនលើសលប់ដូចមុនទៀតទេ ។

គោលនយោបាយគណបក្សប្រជាធិបតេយ្យ ដែលមានព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជាអ្នកដឹកនាំ ចង់ឲ្យមានការចរចាពីបញ្ហាឯករាជ្យជាមួយបារាំង ឲ្យបានឆាប់រហ័សដើម្បីឲ្យប្រទេសកម្ពុជា អនុវត្តលទ្ធិប្រជាធិបតេយ្យឲ្យបានល្អ ដូចនៅប្រទេសបារាំង។

ចំណែកគណបក្សសេរីភាព ដែលមានព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ជាអ្នកដឹកនាំទទួល១៤អាសនៈនៅក្នុងសភានោះ ជាគណបក្សអភិរក្សនិយម មិនចង់ឲ្យមានកំណែទម្រង់នយោបាយលឿនពេកទេ គឺសំខាន់ត្រូវអប់រំប្រជារាស្ត្រខ្មែរ ឲ្យយល់ពីលទ្ធិប្រជាធិបតេយ្យជាបណ្តើរៗសិន ហើយដំណាក់កាលនេះ គួរតែពឹងផ្អែកលើបារាំង ឲ្យជួយការពារប្រទេសមួយរយៈបន្តទៀតសិន។

ព្រះរាជវង្សានុវង្សទាំងអស់ បានគាំទ្រគំនិតរបស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ប្រធានគណបក្សសេរីភាព ហើយតាមប្រភពព័ត៌មានមួយបានឲ្យដឹងថា ពួកមន្ត្រីជាន់ខ្ពស់បារាំង ក៏បានលួចលាក់ផ្តល់លុយកាក់ខ្លះសម្រាប់ជួយទ្រទ្រង់គណបក្សនេះផងដែរ ដោយសារបារាំង ខ្លាចប្រជាប្រិយភាពរបស់គណបក្សប្រជាធិបតេយ្យ ។

ឯគណបក្សប្រជាធិបតេយ្យចម្រើនជឿនលឿន របស់ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ដែលទទួលបានអាសនៈ៣នៅក្នុងសភានោះ មិនមានឥទ្ធិពលអ្វីក្នុងសភាទេ ហើយគេសង្ស័យថា គណបក្សនេះមានពួកទីប្រឹក្សារបស់ព្រះមហាក្សត្រ នៅពីក្រោយ។

ក្រោយជាប់ឆ្នោតបានធ្វើតំណាងរាស្ត្របានបីខែ នៅថ្ងៃមួយ ពេលកំពុងប្រជុំរដ្ឋសភាពេញអង្គ ស្រាប់តែទេសាភិបាលជាន់ខ្ពស់បារាំង ប៉េណាវែរ (Penavaire) បានបញ្ជាឲ្យកម្លាំងសមត្ថកិច្ចមកចាប់ខ្លួនតំណាងរាស្ត្រស៊ឹម វ៉ា ដោយមិនគិតពីអភ័យឯកសិទ្ធិតំណាង



ស៊ឹម វ៉ា

រាស្ត្រឡើយ។

ទេសាភិបាលជាន់ខ្ពស់បារាំងរូបនេះ បានចោទស៊ឹម វ៉ា ថាជាមេដឹកនាំចលនាមួយឈ្មោះចលនាមេអំបៅខ្មៅ ដែលបម្រើនយោបាយឲ្យពួកជប៉ុន។

ជាមួយគ្នានោះ ពួកបារាំងបានចាប់សមាជិកគណបក្សប្រជាធិបតេយ្យជាច្រើនរូបទៀត ដែលក្នុងនោះ មានឈឹម ផុន និងហែម ចំរើន ជាមន្ត្រីរក្ខ-បាល ព្រមទាំងមន្ត្រីបម្រើការងារនៅរាជា-យស្ម័យយានប្រមាណ២០នាក់ទៀត។

ឈឹម ផុន ត្រូវបានពួកបារាំងយកទៅធ្វើទារុណកម្ម ដោយចាប់ជ្រមុជក្បាលទៅក្នុងអាងទឹក ដើម្បីឲ្យគាត់ឆ្លើយសារភាព។

មន្ត្រីរាជាយស្ម័យយានម្នាក់ទៀតឈ្មោះ អ៊ុយ កែវ ត្រូវបានគេធ្វើទារុណកម្មគ្មានត្រាប្រណីដែរ ប៉ុន្តែអ្នកដែលរងទារុណកម្មធ្ងន់ធ្ងរបំផុតនោះ គឺចៅក្រមម្នាក់ឈ្មោះឃីន ផៃ ធ្លាប់ជាមិត្តរួមថ្នាក់របស់ស៊ឹម វ៉ា កាលនៅវិទ្យាល័យព្រះស៊ីសុវត្ថិ។

ស៊ឹម វ៉ា និងហែម ចំរើន ជាមន្ត្រីរក្ខបាល ព្រមទាំងសមាជិកគណបក្សប្រជាធិបតេយ្យមួយចំនួនទៀត ត្រូវបានគេបញ្ជូនទៅទីក្រុងព្រៃនគរ ដាក់ក្នុងពន្ធនាគារមួយដោយសម្ងាត់បំផុត។

ទោះបីស៊ឹម វ៉ា ជាមនុស្សជិតស្និទ្ធនឹងព្រះបរមរាជវាំងក៏ដោយ ក៏ព្រះមហាក្សត្រសីហនុ មិនបានធ្វើអន្តរាគមន៍អ្វីដើម្បីជួយឲ្យបារាំងដោះលែងគាត់វិញដែរ។

ទេសាភិបាលជាន់ខ្ពស់បារាំង មិនត្រឹមតែចោទស៊ឹម វ៉ា ថាជាមេចលនាមេអំបៅខ្មៅ

ដែលមានគោលដៅសម្លាប់ជនជាតិបារាំង ដើម្បីបម្រើនយោបាយជប៉ុននោះទេ គឺថែមទាំងចោទប្រកាន់ថា គាត់បានលួចផ្តល់អាវុធយុទ្ធភណ្ឌឲ្យទៅចលនាពួកខ្មែរឥស្សរៈដែលកំពុងធ្វើការបះបោរប្រឆាំងនឹងពួកបារាំង ទៀតផង។

តែយ៉ាងណា បារាំង មិនបានបញ្ជូនស៊ឹម វ៉ា និងអ្នកផ្សេងទៀត ទៅឲ្យតុលាការ ដើម្បីកាត់ទោសអ្វីទាំងអស់។ រហូតដល់ឆ្នាំ១៩៤៩ ទេសាភិបាលជាន់ខ្ពស់បារាំង ដែលទើបមកកាន់តំណែងថ្មី បានសម្រេចដោះលែងស៊ឹម វ៉ា និងអ្នកទោសទាំងអស់ឲ្យត្រឡប់មកទីក្រុងភ្នំពេញ វិញ។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៤៦ គណបក្សប្រជាធិបតេយ្យ ដែលឈ្នះឆ្នោតដ៏ច្រើនលើសលប់នៅក្នុងរដ្ឋសភា បានបង្កើតរាជរដ្ឋាភិបាលថ្មីមួយ ដោយមានព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ វត្តធាយាវង្ស ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, សុន វ៉ុនសៃ ជារដ្ឋមន្ត្រីការពារជាតិ, សឺន សាន ជារដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ, ឈាន វ៉ម ជារដ្ឋមន្ត្រីអប់រំ, ប្រាក់ សារិន ជារដ្ឋមន្ត្រីសាធារណការទូរគមនាគមន៍ និងសុខាភិបាល, ប៉ែន នុត ជារដ្ឋមន្ត្រីទទួលលបន្ទុករាជធានីភ្នំពេញ, ហ៊ុយ កន្ធុល ជារដ្ឋលេខាធិការក្រសួងព័ត៌មាន និងឃោសនា, ហាក់ ម៉ុងសេង ជារដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ, អូ ឈឹន ជារដ្ឋលេខាធិការក្រសួងធម្មការ ពុទ្ធិកសិក្សា និងវិចិត្រសិល្បៈ និងអ៊ុក ធុច ជារដ្ឋលេខាធិការក្រសួងផ្គត់ផ្គង់ ។

ក្រោយពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ឡើងជានាយករដ្ឋមន្ត្រីជំនួសព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត មក អ្នកម្នាងប៉ុក វ៉ាណេ ជាព្រះជាយារបស់ទ្រង់មុនីរ៉េត បានចូលមកគាល់ព្រះមហាក្សត្រនរោត្តម សីហនុ គួញត្អែរទូលព្រះអង្គថា នៅផ្ទះរបស់អ្នកម្នាងលែងមានឯកឧត្តម លោកជំទាវ ឬអស់លោក លោកស្រីណាចេញចូលដូចកាលពីស្វាមីរបស់អ្នកម្នាងនៅជានាយករដ្ឋមន្ត្រីទៀតហើយ គឺស្ងាត់ជាងកន្លែងកប់ខ្មោចទៅទៀត។

នេះក៏ដោយសារពួកមន្ត្រីដែលពូកែអែបអបទាំងឡាយនោះ បានបែរក្បាលទៅរកភូមិគ្រឹះព្រះអង្គម្ចាស់យុត្តិវង្ស ជានាយករដ្ឋមន្ត្រីថ្មីវិញ។

## របត់នយោបាយ

នៅឯភូមិគ្រឹះរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជារៀងរាល់ថ្ងៃ គេឃើញអ្នកម្នាងជាជនជាតិបារាំង របស់ទ្រង់ ឈ្មោះ ដូមីនិក ឡាវ៉ឺន (Dominque Laverne) នៅជាប់ជាមួយទ្រង់ជានិច្ច ពេលមានភ្ញៀវជាមន្ត្រីធំៗចូលទៅសម្តែងការគោរពយកគាប់គួរម្តងៗ ។

ដោយសារតែរបូតតំណែងជានាយករដ្ឋមន្ត្រីផង និងប្រហែលដោយសារមានការច្រណែននិន្ទាឈ្នានីសផងនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ដែលព្រះមហាក្សត្រសីហនុបានកត់សម្គាល់ឃើញថា ទ្រង់ជាមនុស្សចូលចិត្តនិយាយដើមអ្នកដទៃនោះ ក៏បានមកញុះញង់ចាក់រុកព្រះអង្គថា ព្រះអង្គម្ចាស់យុត្តិវង្ស មិនត្រឹមតែមានមហិច្ឆតាចង់ធ្វើនាយករដ្ឋមន្ត្រីប៉ុណ្ណោះទេ គឺថែមទាំងមានមហិច្ឆតាចង់ឡើងធ្វើជាព្រះមហាក្សត្ររបស់ប្រទេសកម្ពុជាទៀតផង។

ទ្រង់មុនីរ៉េត បានទូលព្រះមហាក្សត្រសីហនុ ថា ភូមិគ្រឹះរបស់ទ្រង់យុត្តិវង្ស ប្រធានគណបក្សប្រជាធិបតេយ្យ ពេលនេះ មានបរិយាកាសប្រៀបដូចជាព្រះរាជវាំងមួយ ហើយអ្នកម្នាងដូមីនិក ឡាវ៉ឺន(Dominque Laverne) ជាព្រះជាយាជនជាតិបារាំងនោះ បានរៀបចំកម្មវិធីអបអរសាទរនៃការឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីរបស់ទ្រង់យុត្តិវង្ស នៅភូមិគ្រឹះនោះ យ៉ាងគគ្រឹកគគ្រេងបំផុត ដោយមានទាំងជំទាវៗខ្មែរ ទាំងជំទាវៗអឺរ៉ុប នាំគ្នាទៅសម្តែងការគោរពឱនលំទោន ក្រាបបង្គំអ្នកម្នាងដូមីនិក នោះ ប្រៀបដូចជាព្រះមហាក្សត្រីយានីមួយអង្គទៅហើយ។

ព្រះមហាក្សត្រនរោត្តម សីហនុ ស្តាប់ហើយ ព្រះអង្គក៏មិនមានប្រតិកម្មអ្វីទៅតាមការញុះញង់ចាក់រុករបស់ទ្រង់មុនីរ៉េត ជាព្រះបិតុលានោះដែរ។

ទោះបីគណបក្សប្រជាធិបតេយ្យឈ្នះឆ្នោតបានទទួលអាសនៈនៅក្នុងរដ្ឋសភាដ៏ច្រើនលើសលប់ក៏ពិតមែន ប៉ុន្តែនៅក្នុងស្ថាប័នក្រុមប្រឹក្សាព្រះរាជាណាចក្រ គណបក្សនេះមិនមានសំឡេងភាគច្រើនដូចនៅក្នុងសភាទេ។

ឆ្លៀតឱកាសដែលព្រះមហាក្សត្រ បើកដៃឲ្យពួកប្រជាធិបតេយ្យ ធ្វើការកែសម្រួលពង្រាងរដ្ឋធម្មនុញ្ញ ដែលតាក់តែងឡើងដោយទ្រង់មុនីរ៉េត ជាអតីតនាយករដ្ឋមន្ត្រី និងពួក

ទីប្រឹក្សាបារាំងមួយចំនួនទៀតនោះ ពួកប្រជាធិបតេយ្យ បានធ្វើការបញ្ចេញបញ្ចូលនូវខ្លឹមសារ តាមតែការនឹកឃើញរបស់ពួកគេ ក្នុងចេតនាចង់ដកហូតសិទ្ធិអំណាចពីព្រះមហាក្សត្រ និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ស្ទើរតែអស់រលីងពីពង្រាងដើមរបស់ទ្រង់មុនីរ៉េត។

# ១៨
# រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៩



**ព្រះមហាក្សត្រសីហនុ លើកបង្ហាញរដ្ឋធម្មនុញ្ញ**

នៅទីបំផុត រដ្ឋធម្មនុញ្ញមួយ មាន១០ជំពូក និង១០៧មាត្រា ត្រូវបង្កើតឡើងជាលើកដំបូងបង្អស់នៅប្រទេសកម្ពុជា។

ពេលនេះ យើងសូមលើកយកតែមាត្រាសំខាន់ៗមួយចំនួន ក្នុងចំណោមមាត្រាទាំង ១០៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ រួមមាន៖

## ជំពូក១
## ធម្មជាតិ និងសណ្ឋានរបស់រដ្ឋ

មាត្រា១- ប្រទេសកម្ពុជា ជាប្រជាជាតិមួយមានព្រះមហាក្សត្រិយ៍សោយរាជ្យ។

មាត្រា២- ភាសាដែលប្រើជាផ្លូវការ គឺភាសាខ្មែរ។

ភាសាបារាំង ជាភាសាផ្លូវការសម្រាប់ប្រើក្នុងការដែលទាក់ទងនឹងសហភាពបារាំង ហើយនឹងយកមកប្រើក្នុងការក្រៅពីនោះផងក៏បានដែរ ទម្រាំភាសាខ្មែរមានពាក្យបរិបូណ៌គ្រប់គ្រាន់នឹងប្រើការសម្រាប់ប្រជាជាតិសម័យថ្មី។

## ជំពូក២
## សេរីភាព សិទ្ធិ និងករណីយកិច្ចរបស់ខេមរជន

មាត្រា៣- សេរីភាពជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាង កុំឲ្យតែប៉ះពាល់ឲ្យខូចសិទ្ធិអ្នកដទៃ។ លក្ខខណ្ឌនៃការប្រើសេរីភាព មានគ្រាទុកក្នុងច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ។

មាត្រា៤- នឹងចោទចាប់ ឬឃុំឃាំងជនណាមួយបាន លុះតែជននោះប្រព្រឹត្តបទដែលមានគ្រាទុកក្នុងច្បាប់ ឯអ្នកចោទ-អ្នកចាប់ ឬអ្នកឃុំឃាំង ត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តិទុក ។

នឹងឃុំឃាំងជនណាទុកបាន លុះតែមានចៅក្រមពិនិត្យការឃុំឃាំងនោះឃើញថាត្រឹមត្រូវតាមច្បាប់ ហើយយល់ព្រមផង ដោយចង្អុលហេតុផលក្នុងរយៈវេលាដែលមានកំណត់ទុកក្នុងច្បាប់ ។

ទារុណកម្ម ឬការបង្ខំដែលឥតប្រយោជន៍ក្នុងខណៈចាប់ជនណាមួយ ការសង្កត់សង្កិនចិត្ត ឬការធ្វើបាបដល់រាងកាយចំពោះអ្នកជាប់ឃុំណាមួយ ការប្រព្រឹត្តិដែលបណ្តាលឲ្យធ្ងន់ថែមទៅលើទណ្ឌកម្មដែលតុលាការបានតម្រូវតាមច្បាប់ទៅលើអ្នកមានទោសណាមួយស្រេចហើយនោះ ច្បាប់ហាមមិនឲ្យប្រព្រឹត្ត ហើយនៅក្នុងបទទាំងនេះ អ្នកដៃដល់ អ្នកមេគំនិត អ្នកសមគំនិត ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន។

មាត្រា៥- ដរាបណាតុលាការមិនទាន់ប្រកាសថា អ្នកត្រូវចោទមានទោសទេ ដរាបនោះអ្នកត្រូវចោទជាមនុស្សឥតទោស។

ទណ្ឌកម្មដែលបំបាត់ ឬបន្ថយសេរីភាពដល់អ្នកប្រព្រឹត្តខុស ត្រូវដាក់ដោយញ៉ាំងឲ្យកែខ្លួនបានល្អឡើងវិញ។

មាត្រា៦- ខេមរជនមិនអាចត្រូវនិរទេសពីដែនខ្មែរបានឡើយ។

ការហាមខេមរជន មិនឲ្យនៅក្នុងកន្លែងណាមួយ ឬការបង្ខំឲ្យនៅក្នុងកន្លែងណាមួយ ត្រូវតែធ្វើក្នុងករណីដែលមានបញ្ញត្តិទុកក្នុងច្បាប់។

មាត្រា៧- កម្មសិទ្ធិឋិតនៅក្នុងការឃុំគ្រងនៃច្បាប់។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ ក៏ដោយហេតុជាសាធារណប្រយោជន៍ ក្នុងករណីដែលច្បាប់បាន

អនុញ្ញាត ហើយក៏ត្រូវឲ្យសោហ៊ុយជួសជុលជាមុនដោយយុត្តិធម៌។

មាត្រា៨- សេរីភាពខាងជំនឿត្រូវបើកឲ្យមានដោយបរិបូណ៌។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនាក៏ត្រូវបើកឲ្យមាន

ដូច្នោះដែរ បើនឹងបន្ថយខ្លះបាន តែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

មាត្រា៩- ខេមរជនមានសេរីភាពក្នុងការនិយាយ សរសេរ បោះពុម្ព និងការផ្សាយដល់មហាជន ។ ខេមរជនអាចសម្តែង

ផ្សាយ ឬការពារមតិគ្រប់យ៉ាង តាមផ្លូវកាសែតក្តី តាមវិធីណាឯទៀតក្តី កុំឲ្យតែប្រើសិទ្ធិនេះដោយរំលោភ ហើយកុំឲ្យតែញ៉ាំងឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

មិនត្រូវបង្ខំ ឬបង្គាប់នរណាឲ្យសម្តែងមតិថាដូច្នេះ ឬដូច្នោះបានឡើយ ។

មាត្រា១០- ខេមរជនទាំងពួង មានសិទ្ធិរួបរួមគ្នាជាសមាគមដោយសេរី កុំតែសមាគមនោះធ្វើឲ្យខូច ឬញ៉ាំងឲ្យខូចសេរីភាព

ទាំងឡាយដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឲ្យមាន ។

ត្រូវបើកឲ្យមានសេរីភាពក្នុងការប្រជុំផងដែរ ។

មាត្រា១១- ទីលំនៅមិនត្រូវនរណាចូលទៅរុករានបានឡើយ។ នឹងចូលទៅក្នុងទីលំនៅគេបាន តែក្នុងករណីដែលច្បាប់បាន

បញ្ញត្តិទុក ហើយឲ្យត្រូវតាមរបៀបច្បាប់ផង ។

មាត្រា១២- សំបុត្រដែលផ្ញើទៅមករកគ្នា មិនត្រូវនរណាបើកមើលបានឡើយ វៀរលែងតែមានច្បាប់អនុញ្ញាត ដោយដាក់

ស្តែងជាបណ្តោះអាសន្នឲ្យបើកក្នុងវេលាដែលប្រយោជន៍យ៉ាងធំរបស់ប្រជាជាតិបង្គាប់ឲ្យធ្វើ ដោយខានពុំបាន ។

មាត្រា១៣- ខេមរជនទាំងពួងត្រូវទទួលតំណែងរាជការបានដូចគ្នា។ ក្រៅអំពី

គុណសម្បត្តិនិងសមត្ថភាពរបស់សាមីខ្លួន

គ្មានអ្វីជាហេតុបណ្តាលឲ្យជននេះទទួលបាន ឲ្យជននោះទទួលពុំបានទេ ។

មាត្រា១៤- ខេមរជននីមួយៗ មានសិទ្ធិចូលពាក្យប្ដឹងសុំទៅអ្នកកាន់អំណាចសា-ធារណៈបាន ដើម្បីនាំឲ្យមានការពិចារណា

បញ្ហាទាំងឡាយ ដែលមានផលប្រយោជន៍ចំពោះបុគ្គល ឬដល់មហាជន ។

មាត្រា១៥- ការប្រើសិទ្ធិទាំងឡាយដែលរដ្ឋធម្មនុញ្ញនេះធានាអះអាង មិនត្រូវបង្អាក់បង្ខានបានឡើយ។ ប៉ុន្តែបើប្រជាជាតិ

ត្រូវប្រកាសថា នៅក្នុងភយន្តរាយ នោះសិទ្ធិដែលមានពណ៌នាក្នុងមាត្រា ៤ - ៩ (វគ្គទី ១). ១០ (វគ្គទី ២) និង១២ អាចត្រូវបង្អាក់ឲ្យឈប់ប្រើសិនបាន តាមកម្រិតនិងរបៀបដែលមានបញ្ញត្តិទុកក្នុងច្បាប់ ។

ការបង្អាក់បង្ខាននេះ មិនត្រូវឲ្យយូរលើសពីប្រាំមួយខែ ប៉ុន្តែនឹងបន្តជាថ្មីទៀត តាមរបៀបដដែលក៏បាន ។

ជនណារំលោភប្រើការបង្អាក់បង្ខាននេះ ដើម្បីធ្វើតាមទំនើងចិត្តឲ្យខូចសិទ្ធិអ្នកដទៃខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី ជននោះត្រូវទទួលខុសត្រូវក្នុងបទនេះ ដោយផ្ទាល់ខ្លួន ។

ដល់ផុតពេលបង្អាក់បង្ខាននេះហើយ ជនណាយល់ថាខ្លួនត្រូវគេធ្វើតាមទំនើងចិត្តឲ្យឈឺចាប់ដល់រាងកាយក្តី ឲ្យខូចខាតដល់ភោគទ្រព្យក្តី ជននោះអាចប្ដឹងសាលាជម្រះក្តីសុំឲ្យជួសជុលខាងផ្លូវចិត្ត ឬខាងធនធានបាន ។

មាត្រា១៦- ខេមរជននីមួយៗ ត្រូវមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ។ ត្រូវមានករណីយកិច្ចគោរពប្រតិបត្តិច្បាប់

ការពារប្រទេស ហើយជួយរដ្ឋាភិបាលដោយបង់ពន្ធដារ និងដោយវិធីគ្រប់យ៉ាងដែលមានបញ្ញត្តិទុកក្នុងច្បាប់ ។

## ជំពូក៣
## អំពីច្បាប់ និងអំណាច

## របត់នយោបាយ

មាត្រា១៧- ច្បាប់ជាសេចក្ដីសម្ដែងឆន្ទៈរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើទោះជាច្បាប់នោះរក្សា

ការពារក្ដី ផ្ដន្ទាទោសក្ដី បង្ខិតបង្ខំក្ដី ។

ច្បាប់ធានាអះអាងឲ្យខេមរជនទាំងពួងប្រើសេរីភាពនិងសិទ្ធិទាំងឡាយ ដូចមានរៀបរាប់នៅក្នុងជំពូកមុននេះ បើទោះជាដូចម្ដេចក៏ដោយ ច្បាប់មិនអាចធ្វើឲ្យខូចសេរីភាពនិងសិទ្ធិទាំងនោះបានឡើយ ។

មាត្រា១៨- ច្បាប់ធានាអះអាងឲ្យមនុស្សទាំងពួងមានសិទ្ធិឲ្យតុលាការទទួលជំនុំជម្រះ។ សេចក្ដីខ្វះខាតធនធានមិនគ្រប់

គ្រាន់ មិនអាចជាឧបសគ្គក្នុងការឲ្យតុលាការទទួលជំនុំជម្រះបានឡើយ ។

មាត្រា១៩- វៀរលែងតែមានបញ្ញត្តិពិសេសដោយជាក់ច្បាស់ក្នុងច្បាប់ ច្បាប់មិនត្រូវយកទៅប្រើលើអំពើដែលកន្លងទៅ

ហើយ មុនពេលឲ្យប្រតិបត្តិតាមនោះទេ ។

ប៉ុន្តែជនណាក៏ដោយ នឹងអាចត្រូវតុលាការជំនុំជម្រះ នឹងដាក់ទណ្ឌកម្មបាន លុះតែជននោះបានប្រព្រឹត្តបទល្មើសមានក្នុងច្បាប់ណាមួយដែលបានប្រកាសឲ្យប្រើហើយ ហើយដែលត្រូវប្រើមុនមានបទល្មើសនោះ។

មាត្រា២១- អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រិយ៍ ។ អំណាចទាំងនោះត្រូវប្រើទៅតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ ។

មាត្រា២២- រដ្ឋសភាជាអ្នកប្រើអំណាចនីតិប្បញ្ញត្តិ ក្នុងព្រះបរមនាមនៃព្រះមហា-ក្សត្រិយ៍ ។

អ្នកដែលមានសិទ្ធិផ្ដើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា និងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

មាត្រា២៣- គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះបរមនាម នៃព្រះមហាក្សត្រិយ៍ ។

មាត្រា២៤-សាលាជម្រះក្តីគ្រប់ជាន់ គ្រប់ប៉ែក ជាអ្នកប្រើអំណាចតុលាការ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

## ជំពូក៤
## អំពីព្រះមហាក្សត្រិយ៍

មាត្រា២៥- រាជសម្បត្តិប្រទេសកម្ពុជា ជាមត៌ករបស់ក្សត្រាទាំងឡាយដែលជាតំណពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតី

ព្រះអង្គឌួង ។

មាត្រា២៦- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជអំណាចចាត់តាំងរជ្ជទាយាទ និងព្រះរាជអំណាចដកព្រះរជ្ជទាយាទពីតំណែងបាន ដោយបានទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិពិគ្រោះជាមុនហើយ ។

មាត្រា២៧- កាលបើរាជសម្បត្តិទំនេរ ប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់តាំងព្រះរជ្ជទាយាទដូចខាងលើនេះទេ នោះក្រុមប្រឹក្សារាជសម្បត្តិចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មី ដោយយកតាមមតិនៃភាគច្រើនក្នុងទីប្រជុំ បើមតិនៃទីប្រជុំចែកជាពីរភាគស្មើគ្នានោះត្រូវយកតាមមតិនៃប្រធាន ។

មាត្រា២៨- ក្រុមប្រឹក្សារាជសម្បត្តិ មានសមាជិកដូចតទៅនេះ ៖

-អធិបតីនៃក្រុមសង្គហព្រះរាជវង្សានុវង្ស - ប្រធានរដ្ឋសភា - នាយករដ្ឋមន្ត្រី -ព្រះសង្ឃនាយកទាំងពីរគណៈ។

-អធិបតីក្រុមសង្គហព្រះរាជវង្សានុវង្ស ជាប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ ។

មាត្រា២៩- នីតិភាពនៃព្រះមហាក្សត្រិយ៍ ត្រូវកំណត់តាំងពីព្រះជន្មាយុដប់ប្រាំបីព្រះវស្សា។ បើប្រសិនជាព្រះមហាក្សត្រិយ៍

ឋិតនៅក្នុងអនីតិភាព ឬគ្មានសមត្ថភាពនឹងទ្រង់ប្រើព្រះរាជសិទ្ធិទេ នោះព្រះរាជសិទ្ធិនោះត្រូវជាភារៈរបស់ព្រះរាជានុសិទ្ធិមួយព្រះអង្គ ។

ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ហើយបើ

មានករណីដូច្នោះ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងក្សត្រាមួយព្រះអង្គក្នុងព្រះរាជវង្សានុវង្ស ជាព្រះរាជានុសិទ្ធិ ។

មាត្រា៣០- កាលបើរាជសម្បត្តិទំនេរ ហើយប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់-តាំងរជ្ជទាយាទទេ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវតែប្រជុំក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ ដែលធ្វើឲ្យរាជសម្បត្តិទំនេរ ដើម្បីចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មី ព្រមទាំងរាជានុសិទ្ធិ បើព្រះមហាក្សត្រិយ៍អង្គថ្មីឋិតនៅក្នុងអនីតិភាព ។

ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ត្រូវធ្វើដោយប្រធានអញ្ជើញ ឬបើប្រធានមិនបានអញ្ជើញទេ ត្រូវប្រជុំនៅថ្ងៃទីបីនៃ រយៈវេលាដែលមានកំណត់ក្នុងវគ្គមុននេះ ។

បើត្រូវវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍ក្នុងរាជសម្បត្តិគ្មានសមត្ថភាពនោះ ត្រូវប្រធានក្រុមប្រឹក្សារាជសម្បត្តិ អញ្ជើញសមាជិកមកប្រជុំ ដោយតម្រិះព្រះអង្គឯងក៏បាន ដោយសេចក្តីសុំនៃសមាជិកយ៉ាងតិចត្រឹមពីរនាក់ ក៏បាន ដើម្បីនឹងវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍មានសមត្ថភាពឬទេ ហើយបើព្រះមហាក្សត្រិយ៍គ្មានសមត្ថភាពទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងព្រះរាជានុសិទ្ធិមួយអង្គឡើង ។

មាត្រា៣១- ក្នុងរវាង៨ថ្ងៃ ក្រោយវេលាផ្លាស់ប្តូររជ្ជកាលមួយៗ រដ្ឋសភាត្រូវប្រជុំដោយខានពុំបាន ដើម្បីទទួលសច្ចាប្រណិធានអំពីព្រះមហាក្សត្រិយ៍ ឬអំពីព្រះរាជានុសិទ្ធិ ។

មាត្រា៣៤- ចាប់ផ្តើមតាំងពីវេលាដែលរាជសម្បត្តិទំនេរ រហូតដល់វេលាដែលព្រះមហាក្សត្រិយ៍អង្គថ្មី ឬព្រះរាជានុសិទ្ធិថ្លែងសច្ចាប្រណិធានក្នុងរវាងវេលានោះ ប្រធានរដ្ឋសភាប្រើអំណាចជាប្រមុខរបស់រដ្ឋ ស្នងព្រះអង្គ ដោយទទួលសេចក្តីខុសត្រូវលើខ្លួន ។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍ មិនបានគង់នៅក្នុងប្រទេសកម្ពុជា ឬពុំអាចទ្រង់ទទួលព្រះរាជភារៈបាន ព្រះមហាក្សត្រិយ៍ទ្រង់ប្រគល់ព្រះរាជភារៈនោះទៅក្រុមប្រឹក្សាមួយក្រុមជាបណ្តោះអាសន្ន ព្រះមហាក្សត្រិយ៍ទ្រង់តាំងអធិបតី និងសមាជិកនៃក្រុមប្រឹក្សានោះ ដោយចាត់តាំងយកក្រៅពីសមាជិកនៃរដ្ឋាភិបាល ។

មាត្រា៣៥- ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ ។ អង្គព្រះមហាក្សត្រិយ៍ជាទី

គោរពសក្ការៈ នរណានឹងល្មើសពុំបាន ។

មាត្រា៣៦- ព្រះមហាក្សត្រិយ៍ទ្រង់ប្រកាសឲ្យប្រើច្បាប់ទាំងឡាយ តាមមាត្រា៧៨ នៃរដ្ឋធម្មនុញ្ញនេះ ។

ក្នុងរយៈវេលាដែលមានកំណត់សម្រាប់ការប្រកាសឲ្យប្រើនេះ ព្រះមហាក្សត្រិយ៍ អាចផ្ញើព្រះរាជសារទៅឲ្យរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិចារណាច្បាប់នោះ ជាថ្មីទៀត ឯរដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវតែព្រមតាមព្រះរាជឱង្ការ ។

មាត្រា៣៨- ព្រះមហាក្សត្រិយ៍ ទ្រង់ហៅប្រជុំរដ្ឋសភា តាមបទប្បញ្ញត្តិនៃមាត្រា៥៨ នឹង៥៩ នៃរដ្ឋធម្មនុញ្ញនេះ ។

ព្រះអង្គទ្រង់នូវព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្ដីណែនាំគណៈរដ្ឋមន្ត្រី ។ ព្រះមហាក្សត្រិយ៍ទ្រង់រំលាយរដ្ឋសភាបានតែមួយដងដោយហេតុដដែល។ បើមានការរំលាយ រដ្ឋសភាដូចខាងលើនេះ ការជ្រើសតាំងជាថ្មីត្រូវឲ្យមានក្នុងរយៈវេលាពីរខែយ៉ាងយូរ ។

មាត្រា៣៩- ព្រះមហាក្សត្រិយ៍ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី ហើយទ្រង់តែងតាំង នាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រី ដែលនាយកនោះក្រាបបង្គំទូលសុំឲ្យតាំង ។

មាត្រា៤០- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី។ សេចក្ដីកត់ហេតុទាំងឡាយនៃពេល

ប្រជុំគណៈរដ្ឋមន្ត្រី ត្រូវនាំយកទៅក្រាបបង្គំថ្វាយព្រះមហាក្សត្រិយ៍ ។

មាត្រា៤១- ព្រះរាជលិខិតទាំងពួង វៀរលែងតែព្រះរាជលិខិតណាដែលទាក់ទងនឹង ការខាងក្នុងព្រះបរមរាជវាំងត្រូវឲ្យមាននាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីមួយនាក់ឬច្រើននាក់ ចុះ ហត្ថលេខាទទួលព្រះបរមរាជឱង្ការ។

មាត្រា៤២- ព្រះមហាក្សត្រិយ៍ទ្រង់បង្កើត ព្រមទាំងទ្រង់ព្រះរាជទានឋានន្តរស័ក្តិ ខាងស៊ីវិល និងខាងទាហាន ។

ព្រះមហាក្សត្រិយ៍ទ្រង់ជាអធិបតីធំបំផុតនៃក្រុមឥស្សរិយយស ហើយទ្រង់ព្រះរាជទាន គ្រឿងឥស្សរិយាករណ៍។

របត់នយោបាយ

មាត្រា៤៣- ព្រះមហាក្សត្រិយ៍ទ្រង់តែងតាំងចៅក្រមទាំងឡាយ តាមសេចក្តីសុំរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ នៃតុលាការ ។

មាត្រា៤៤-ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិលើកលែងទោសនឹងបន្ថយទោស។

មាត្រា៤៥- ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គសេនាប្រមុខលើកម្លាំងទាហានទាំងឡាយនៃព្រះរាជអាណាចក្រ។

មាត្រា៤៦- ព្រះមហាក្សត្រិយ៍ទ្រង់ចុះព្រះរាជហត្ថលេខាក្នុងសន្ធិសញ្ញាទាំងឡាយដែលធ្វើនឹងប្រទេសបារាំង ហើយនឹងសមាគមរដ្ឋឯទៀតក្នុងសហភាពបារាំង ហើយទ្រង់ព្រះរាជទានសច្ចាប័នដល់សន្ធិសញ្ញាទាំងនោះ ដោយអាស្រ័យការអនុម័តិនៃរដ្ឋសភា ។

ព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំងឥស្សរជនឲ្យកាន់តំណែង ឬទទួលបម្រើខាងផ្លូវទូតទៅប្រទេសក្រៅ ។

មាត្រា៤៧- មហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិរំលែកព្រះរាជអំណាចក្នុងការព្រះរាជទានឋានន្តរស័ក្តិខាងស៊ីវិល និងទាហាន ហើយក្នុងការចុះព្រះរាជហត្ថលេខាក្នុងលិខិតទាំងឡាយ។

## ជំពូក៥

## អំពីរដ្ឋសភា

មាត្រា៤៨- អ្នកដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ គឺពលរដ្ឋខ្មែរ ភេទបុរសអាយុ២០ឆ្នាំបរិបូណ៌ឡើងទៅ វៀរលែងតែបុរសនោះប្រាសចាកសិទ្ធិរបស់ពលរដ្ឋ ហើយបុរសនោះ ត្រូវប្រកបដោយលក្ខណសម្បត្តិតាមច្បាប់ស្តីអំពីការជ្រើសតាំងអ្នកតំណាងរាស្ត្រ។

-ទាហានក្នុងតំណែងគ្មានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ ហើយគ្មានទាំងសិទ្ធិឈរឈ្មោះឲ្យគេជ្រើសតាំងខ្លួនជាអ្នកតំណាងរាស្ត្រទៀតផង ។ បព្វជិតក៏គ្មានសិទ្ធិដូចខាងលើនេះដែរ ព្រោះទើសទាល់នឹងធម៌វិន័យព្រះពុទ្ធសាសនា ។

មាត្រា៤៩- អ្នកដែលមានសិទ្ធិឈរឈ្មោះឲ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្របាននោះ គឺបុរសដែលមានសិទ្ធិជ្រើសតាំង

អ្នកតំណាងរាស្ត្រទាំងឡាយ មានអាយុយ៉ាងតិច២៥ឆ្នាំ។ ច្បាប់ស្តីអំពីការជ្រើសតាំងអ្នកតំណាងរាស្ត្រមានកំណត់អំពីបុរសដែលគ្មានសិទ្ធិឈរឈ្មោះ ឲ្យគេជ្រើសតាំងខ្លួនជាអ្នកតំណាងរាស្ត្រ ។

ជនមួយនាក់ នឹងធ្វើជាអ្នករាជការកាន់កាប់តំណែងផង ហើយធ្វើជាអ្នកតំណាងរាស្ត្រផង ពុំបាន។

មាត្រា៥០- អ្នកតំណាងរាស្ត្រនៅក្នុងតំណែងត្រឹម៤ឆ្នាំ ដោយបានទទួលជ្រើសតាមវិធីបោះឆ្នោតសាកលដោយចំពោះ ។

រដ្ឋសភាក្នុងមួយលើកៗ អស់អំណាចនៅវេលាដែលរដ្ឋសភាលើកថ្មីចូលទទួលការ ។ ក្នុងវេលាដែលផុតនីតិកាលនីមួយ១ បើមានហេតុបណ្តាលមិនឲ្យមានការជ្រើសតាំងជាថ្មីទៀតបានទេ ព្រោះមហាក្សត្រិយ៍អាចបន្តនីតិកាលឲ្យវែងទៅបានម្តងមួយឆ្នាំ ។

បើកាលណាមានអ្នកតំណាងរាស្ត្រទទួលអនិច្ចកម្ម លាលែង ឬត្រូវបញ្ចេញនោះត្រូវជ្រើសតាំងជំនួសឡើង តាមបញ្ញត្តិច្បាប់ស្តីអំពីការជ្រើសតាំងអ្នកតំណាងរាស្ត្រ ។

មាត្រា៥១- មុននឹងចាប់ផ្តើមធ្វើការ រដ្ឋសភាត្រូវពិនិត្យដោយខានពុំបាននូវការតាំងសមាជិកដែលគួរតាំង ឲ្យបានជាអ្នកតំណាងរាស្ត្រពេញទី ។

មាត្រា៥២- នៅពេលដំបូងនៃនីតិកាលនីមួយៗ ហើយមុននឹងចូលកាន់តំណែងសមាជិកនៃរដ្ឋសភាដែលបានទទួលតាំងជាអ្នកតំណាងរាស្ត្រពេញទីហើយ តាំងសច្ចាប្រណិធានក្នុងទីប្រជុំចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ ជាសេចក្តីដូចតទៅនេះ៖

"ខ្ញុំសូមតាំងសច្ចាថា មានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ហើយនិងរដ្ឋធម្មនុញ្ញ ហើយថានឹងខំប្រឹងធ្វើការដោយពេញកម្លាំង ដើម្បីជាផលប្រយោជន៍ដល់ប្រទេសជាតិ " ។

អ្នកតំណាងរាស្ត្រណាដែលគេជ្រើសតាំងក្នុងរយៈវេលានីតិកាល ហើយដែលរដ្ឋសភាបានតាំងជាអ្នកតំណាងរាស្ត្រពេញទីហើយ ត្រូវតាំងសច្ចាប្រណិធានចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្មវស្សា (តាំងតុ) ដែលតបន្ទាប់ពីពេលនោះមួយអន្លើនឹងអ្នករាជការទាំងឡាយ ។

## របត់នយោបាយ

មាត្រា៥៣- សមាជិកទាំងឡាយនៃរដ្ឋសភា ជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនត្រឹមតែជាអ្នកតំណាងរបស់ជនដែលជ្រើសតាំងខ្លួនប៉ុណ្ណោះទេ។ អ្នកតំណាងរាស្ត្រមិនត្រូវជំពាក់ទាក់ទិនដោយអាណត្តិដាច់ខាតណាមួយឡើយ ។

មាត្រា៥៤- អ្នកតំណាងរាស្ត្រមិនអាចត្រូវគេចោទប្រកាន់រកខ្លួន ចាប់ខ្លួនឃុំឃាំង ឬជំនុំជម្រះដោយហេតុថា អ្នកតំណាងរាស្ត្រនោះបានសម្តែងយោបល់ ឬបញ្ចេញមតិថាដូច្នេះដូច្នោះក្នុងក្រសួងរបស់ខ្លួនឡើយ។ សេចក្តីខាងលើនេះ ជាអភ័យឯកសិទ្ធិរបស់សមាជិករដ្ឋសភា ។

មាត្រា៥៥- នៅវេលាដែលឋិតក្នុងសមាជិកភាព ហើយវៀរលែងតែបានប្រព្រឹត្តបទល្មើសដែលគេអត់បានទាន់ឃើញជាក់ស្តែង អ្នកតំណាងរាស្ត្របើនឹងត្រូវគេចោទប្រកាន់ ឬចាប់ខ្លួនបាន ដោយបទឧក្រិដ្ឋ ឬមជ្ឈិមនោះ លុះត្រាតែមានអនុញ្ញាតពីរដ្ឋសភាជាមុនសិន។

ការឃុំឃាំង ឬការចោទប្រកាន់អ្នកតំណាងរាស្ត្រណាមួយត្រូវបង្អង់សិន បើរដ្ឋសភាបញ្ចេញមតិសុំដោយមានភាគច្រើនដល់បួនក្នុងប្រាំ ( ៤/៥ ) នៃចំនួនសមាជិក ។

មាត្រា៥៦- នៅវេលាដែលឋិតក្នុងតំណែង បើអ្នកតំណាងរាស្ត្រណាមួយត្រូវទណ្ឌកម្មដែលនាំឲ្យបុគ្គលឈរឈ្មោះជាបេក្ខជនពុំបាន អ្នកតំណាងរាស្ត្រនោះធ្លាក់ចាកសមាជិកភាពរដ្ឋសភា ។

ការទម្លាក់ចាកសមាជិកភាពនេះ គឺរដ្ឋសភាជាអ្នកវិនិច្ឆ័យ ។

មាត្រា៥៧- អ្នកតំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់មានកំណត់ដោយប្រៀបស្មើទៅនឹងប្រាក់បៀវត្សនៃអ្នករាជការថ្នាក់ណាមួយ ។

មាត្រា៥៨- រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិចពីរដង ក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗ មានកំណត់យ៉ាងតិច៣ខែ។ ក្នុងសម័យប្រជុំសាមញ្ញពីរនេះ សម័យប្រជុំមួយត្រូវចាប់ផ្តើមក្នុងខែកញ្ញា (សេប តម) ។

ព្រះមហាក្សត្រីយ៍ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសាមញ្ញ ។

# ជំពូក៦
## អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

មាត្រា៧០- ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានសមាជិកដែលត្រូវចាត់តាំងខ្លះ និងសមាជិកដែលត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកលខ្លះ ។ សមាជិកទាំងនោះត្រូវមានអាយុ៤០ឆ្នាំយ៉ាងតិច ។

ជនមួយនាក់នឹងធ្វើជាទីប្រឹក្សាព្រះរាជអាណាចក្រផង ហើយធ្វើជាអ្នកតំណាងរាស្ត្រផងពុំបាន ។

មាត្រា៧១- សមាជិកដែលត្រូវចាត់តាំង មានចំនួនពីររូប។ ព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំងក្នុងបណ្តាព្រះរាជវង្សានុវង្ស ។

មាត្រា៧២- សមាជិកពីររូបត្រូវរដ្ឋសភាជ្រើសតាំងតាមភាគច្រើនដោយប្រៀបយកក្រៅពីអ្នកតំណាងរាស្ត្រ។

មាត្រា៧៣- សមាជិកប្រាំបីរូប រូបនីមួយៗ ជាអ្នកតំណាងភូមិភាគមួយ ឬក្រុងភ្នំពេញត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល មិនចំពោះទីប្រឹក្សាខែត្រជាអ្នកជ្រើសតាំងអ្នក-តំណាងភូមិភាគ ហើយមេសង្កាត់និងទីប្រឹក្សាក្រុង ជាអ្នកជ្រើសតាំងអ្នកតំណាងក្រុងភ្នំពេញ ។

មាត្រា៧៦- អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រ មានកំណត់បួនឆ្នាំ ។

មាត្រា៧៨- ក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យហើយ ឲ្យយោបល់អំពីសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយព្រមទាំងអំពីបញ្ហាទាំងពួងដែលរដ្ឋាភិបាលបានដាក់ឲ្យពិនិត្យ។

អំពីសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ ហើយនិងអំពីច្បាប់ថវិកា ក្រុមប្រឹក្សាព្រះរាជអាណាចក្រត្រូវឲ្យយោបល់កំណត់១ខែយ៉ាងយូរ។ បើជាការប្រញាប់កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះ៖ ក្នុងវេលាដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិ

យល់ព្រមហើយនោះ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ។ បើជាការប្រញាប់ កំណត់វេលានោះត្រូវបន្ថយមកនៅត្រឹមតែពីរថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រសូមឲ្យកែសម្រួលសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាម ជាលើកទី២ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្របដិសេធសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាមិនអាច យកមកពិចារណាជាលើកទី២ មុនកំណត់ពេលមួយខែទេ ។

ការពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវបញ្ចេញមតិដោយវិធីបោះឆ្នោតចំហ យកតាមភាគច្រើនដោយដាច់ខាត នៃសមាជិករដ្ឋសភា ។ សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ណាដែលបានធ្វើសម្រេចដូចខាងលើនេះហើយ ត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។

## ជំពូក៧
## អំពីរដ្ឋមន្ត្រី

មាត្រា៧៩- គណៈរដ្ឋមន្ត្រីជារដ្ឋាភិបាលនៃព្រះមហាក្សត្រិយ៍ ។ គណៈរដ្ឋមន្ត្រី មានសមាជិកយ៉ាងច្រើនត្រឹមដប់ពីររូប រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង ។

ជនម្នាក់អាចទទួលតំណែងជាអ្នកតំណាងរាស្ត្រឬទីប្រឹក្សាព្រះរាជអាណាចក្រផង ហើយជារដ្ឋមន្ត្រីផងបាន។ នឹងយកសមាជិកនៃរដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឬជនដែលពុំមែនជាសមាជិកនៃសភាទាំងពីរនេះ មកធ្វើជារដ្ឋមន្ត្រី ក៏បាន ។

មាត្រា៨៥- កាលបើរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រីនោះរដ្ឋមន្ត្រីត្រូវលាឈប់ទាំងគណៈ ។

កាលបើមានអ្នកតំណាងរាស្ត្រសុំឲ្យរដ្ឋសភាបញ្ចេញមតិតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នោះរដ្ឋសភាត្រូវបន្លង់វេលាមួយថ្ងៃគត់ គិតតាំងពីថ្ងៃជូនសេចក្តីសុំតាំងញត្តិ ទើបបញ្ចេញមតិពីរឿងនេះបាន ។ ការបញ្ចេញមតិនេះ ត្រូវធ្វើទៅដោយវិធីបោះឆ្នោតចំហ ។

ការតាំងញត្តិបន្ទោសគណៈរដ្ឋមន្ត្រី នឹងយកជាការបានលុះតែមានភាគច្រើនដោយ

ដាច់ខាតនៃសមាជិករដ្ឋសភាយល់ព្រមផង ។

មាត្រា៨៦- គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ ជួនកាលជាពេលប្រជុំធំដោយមានព្រះមហាក្សត្រិយ៍ ឬ នាយករដ្ឋមន្ត្រីជាប្រធាន ជួនកាលជាពេលប្រជុំតូច ។

មាត្រា៨៧- រដ្ឋមន្ត្រីទាំងឡាយអាចចូលនិយាយការក្នុងទីប្រជុំនៃសភាទាំងពីរ និងក្នុងទីប្រជុំគណៈកម្មការទាំងឡាយនៃសភាទាំងនោះបាន។ បើរដ្ឋមន្ត្រីទាំងនោះសុំនិយាយការ ត្រូវតែបើកឱកាសឲ្យនិយាយ ។

ក្នុងការពិភាក្សានៃសភាណានីមួយៗ រដ្ឋមន្ត្រីអាចចាត់តាំងអ្នកស្នងរាជការ ឲ្យជួយនិយាយការផងបាន ។

មាត្រា៨៨- នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួន ឲ្យទៅរដ្ឋមន្ត្រីណាមួយបាន។

មាត្រា៨៩- បើតំណែងនាយករដ្ឋមន្ត្រីទំនេរ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មីតាមលក្ខខណ្ឌដែលមានត្រាទុកក្នុង

រដ្ឋធម្មនុញ្ញនេះ។ បើការទំនេរនេះជាដាច់ខាត ឬត្រូវចាត់តាំងនាយករដ្ឋមន្ត្រីជាបណ្តោះអាសន្ន បើការទំនេរនេះជាមួយកាលមួយគ្រាទេ ។

មាត្រា៩០- បើមានការរំលាយរដ្ឋសភា នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឈប់ធ្វើការសិន រដ្ឋមន្ត្រីឯទៀត នៅ

ក្នុងតំណែងទាំងអស់គ្នា ដើម្បីសម្រេចកិច្ចការសាមញ្ញ ។

-ក្នុងខណៈនោះព្រះមហាក្សត្រិយ៍ទ្រង់ប្រទានភារៈទៅលើប្រធានរដ្ឋសភាឲ្យកាន់តំណែងនាយករដ្ឋមន្ត្រីជាបណ្តោះអាសន្ន។ ប្រធានរដ្ឋសភាចាត់តាំងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាថ្មី ដោយសេចក្តីយល់ព្រមនៃក្រុមអភិបាលរដ្ឋសភា។

## ជំពូក៨
## អំពីអំណាចតុលាការ

មាត្រា៩៥- ការរៀបចំនៃភារៈតុលាការមានបញ្ញត្តិទុកក្នុងច្បាប់ពិសេសមួយ ។

មាត្រា៩៦- ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវប្រព្រឹត្តតាមបញ្ញត្តិច្បាប់ ដើម្បីឲ្យ

ចៅក្រមទាំងឡាយរក្សាវិន័យ នឹង

ប្រតិបត្តិការជាឯកច្ឆន្ទបាន ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ មានសមាជិកដូចតទៅនេះ៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអធិបតី

- សមាជិកពីររូបដែលព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំង

-សមាជិកពីររូបដែលរដ្ឋសភាជ្រើសតាំង

-សមាជិកពីររូបដែលតុលាការទាំងឡាយជ្រើសតាំង ។

-ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការសម្រេចសេចក្តីតាមមតិនៃភាគច្រើន របស់សមាជិកទាំងនេះ បើមានមតិចែកជាពីរភាគស្មើគ្នា នោះត្រូវយកតាមមតិនៃអធិបតី ។

## ជំពូក៩

## បញ្ញត្តិទូទៅ

មាត្រា៩៧- បទបញ្ញត្តិទាំងឡាយដែលស្តីអំពីរបៀបគ្រប់គ្រង ដោយមានព្រះមហាក្សត្រិយ៍ជាអគ្គប្រមុខរបស់រដ្ឋនេះ៖

១. អំពីរបៀបគ្រប់គ្រងដោយអាស្រ័យអ្នកតំណាងរបស់ប្រជារាស្ត្រនេះ

១. អំពីគោលចារឹកនៃសេរីភាព នឹងសមភាពដែលរដ្ឋធម្មនុញ្ញនេះ ធានាអះអាងឲ្យមាន

១. មិនត្រូវសុំកែប្រែសោះឡើយ ។

មាត្រា៩៨- ហាមមិនឲ្យកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីនឹងបន្ថយព្រះរាជសិទ្ធិទាំងឡាយដែលមានត្រាទុកជាស្រេចហើយ។

មាត្រា៩៩- អ្នកដែលមានសិទ្ធិផ្តើមគំនិតកែប្រែរដ្ឋធម្មនុញ្ញនោះ គឺព្រះមហាក្សត្រិយ៍ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឯប្រធានទាំងពីរនេះត្រូវធ្វើទៅដោយសេចក្តីអនុម័តិនៃសភារបស់ខ្លួន ដែលបានបញ្ចេញមតិ ដោយមានចំនួនសមាជិកយ៉ាងតិចភាគមួយក្នុងបួន (១/៤) សុំ ។

មាត្រា១០០- របៀបកែប្រែរដ្ឋធម្មនុញ្ញដូចគ្នានឹងរបៀបដែលមានត្រាទុកសម្រាប់

បញ្ចេញមតិតាំងច្បាប់ធម្មតា។ ប៉ុន្តែត្រូវមានភាគច្រើនដល់បីក្នុងបួន (៣/៤) នៃរដ្ឋសភាយល់ព្រមផង ទើបយកជាការបាន ហើយមិនអាចប្រកាសថាជាការប្រញាប់បានទេ ។

មាត្រា១០១- រដ្ឋសភាមានសិទ្ធិបកស្រាយសេចក្តីបទរដ្ឋធម្មនុញ្ញនេះជាដាច់ខាត ។

មាត្រា១០៧- ក្នុងរយៈវេលាដូចបានពោលក្នុងមាត្រាខាងលើនេះ៖ ឥស្សរជនណាដែលព្រះមហាក្សត្រិយ៍ទ្រង់បានតម្រូវឲ្យតាំងគណៈរដ្ឋមន្ត្រីថ្មី នឹងធ្វើបញ្ជីរាយឈ្មោះសមាជិកនៃគណៈរដ្ឋមន្ត្រីនោះយកជាស្រេចដើម្បីនឹងនាំខ្លួនទៅបង្ហាញរដ្ឋសភាបាន លុះតែព្រះមហាក្សត្រិយ៍សព្វព្រះរាជហឫទ័យនឹងនាមដែលមានក្នុងបញ្ជីនោះជាមុនសិន ។

រដ្ឋធម្មនុញ្ញដំបូងនេះ ត្រូវបានព្រះមហាក្សត្រនរោត្តម សីហនុ ចេញព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧។

# ១៩
# ក្រោយទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស ឡើងធ្វើនាយករដ្ឋមន្ត្រី



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស

ចាប់ពីពេលនោះមក ព្រះរាជាណាចក្រកម្ពុជា ដែលធ្លាប់តែគ្រប់គ្រងប្រទេសតាមរបបសម្បូណ៌ាញ្ញាសិទ្ធិរាជ តាំងពីជាងពីរពាន់ឆ្នាំកន្លងមកនោះ ត្រូវបានក្លាយជាប្រទេសមួយដែលប្រកាន់យកនូវលទ្ធិប្រជាធិបតេយ្យ អាស្រ័យធម្មនុញ្ញដ៏ទាន់សម័យមួយជំនួសវិញ។ រដ្ឋធម្មនុញ្ញនោះ មានខ្លឹមសារប្រហាក់ប្រហែលនឹងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី៤របស់បារាំងដែរ ដោយអំណាចទាំងអស់ត្រូវចេញពីរដ្ឋសភា និងព្រឹទ្ធសភា។ គ្រាន់តែនៅកម្ពុជា មិនមានព្រឹទ្ធសភាទេ គឺមានក្រុមប្រឹក្សាព្រះរាជាណាចក្រ ហើយព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រនេះ។

ក្រោយពីទ្រង់យុត្តិវង្ស ឡើងកាន់អំណាចដឹកនាំប្រទេសបានប្រហែល៣-៤ខែមក ព្រះមហាក្សត្រសីហនុ បានសង្កេតឃើញថា អ្វីៗដែលទ្រង់យុត្តិវង្ស បានឃោសនាថា ទ្រង់គិតគូរផលប្រយោជន៍ប្រជារាស្ត្រនោះ គឺគ្រាន់តែជាការកែលម្អការផ្ទេរអំណាចពីព្រះមហាក្សត្រ

មកឲ្យក្រុមរបស់ទ្រង់តែប៉ុណ្ណោះ។

នៅចំពោះមុខប្រជារាស្ត្រ ពិសេសនៅចំពោះមុខព្រះភ័ក្ត្ររបស់ព្រះមហាក្សត្រផង ដែរ ទ្រង់យុត្តិវង្ស និងមន្ត្រីគណបក្សប្រជាធិបតេយ្យផ្សេងៗទៀត តែងតែមានមោទនភាព ពីចំណេះដឹងរបស់ពួកគេ ហើយអួតអាងថា ពួកគេជាស្នេហាជាតិ និងមានសមត្ថភាពក្នុង ការអភិវឌ្ឍប្រទេសជាតិឲ្យបានរីកចម្រើនក្នុងពេលដ៏ខ្លីខាងមុខ។

ដោយមានការក្ដៅក្រហាយនឹងការធ្វើនយោបាយប្រជាភិថុតិនេះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត បានបង្កើតកាសែតជាភាសាបារាំងមួយឈ្មោះ "ក្របីព្រៃ" សរសេរិះគន់វាយប្រហារ ទៅលើរដ្ឋាភិបាលរបស់ទ្រង់យុត្តិវង្ស យ៉ាងចាស់ដៃ។

ដោយសារកាសែត "ក្របីព្រៃ" សរសេររិះគន់វាយប្រហារទៅលើរាជរដ្ឋាភិបាលរបស់ ទ្រង់យុត្តិវង្ស ខ្លាំងពេក ព្រះអង្គម្ចាស់មុនីរ៉េត ត្រូវខ្ចាតចេញពីតំណែងប្រធានក្រុមប្រឹក្សា រាជាណាចក្រ ហើយកាសែតរបស់ទ្រង់បានក្លាយជាកាសែតប្រឆាំងជាចំហតែម្តង។

ចំណែកព្រះមហាក្សត្រសីហនុ ក៏មិនសប្បាយព្រះទ័យប៉ុន្មានចំពោះអំនួតអួតអាងពី រឿងស្នេហាជាតិ និងចំណេះដឹងរបស់ពួកមេដឹកនាំគណបក្សប្រជាធិបតេយ្យនោះប៉ុន្មានដែរ។

ព្រះអង្គបានលួចសរសេរអត្ថបទមួយចំនួនរិះគន់វាយប្រហារទៅលើពួកប្រជាធិបតេយ្យ តាមរយៈទំព័រកាសែត "ក្របីព្រៃ" របស់ព្រះអង្គម្ចាស់មុនីរ៉េត នោះដែរ ដោយដាក់ឈ្មោះ អ្នកនិពន្ធ នៅខាងក្រោមអត្ថបទថា នរោត្តម ថុល ដើម្បីកុំឲ្យពួកគេដឹងថា ព្រះអង្គជាអ្នក សរសេរអត្ថបទនោះ។ ព្រះនាម ថុល នេះ គឺព្រះអយ្យិកោព្រះមហាក្សត្រមុនីវង្ស បានប្រទាន តាំងពីព្រះអង្គនៅកុមារមកម៉្លេះ ។

ចំណែកពួកប្រជាធិបតេយ្យវិញ ក៏បានព្យាយាមស្រាវជ្រាវរកម្ចាស់អត្ថបទឈ្មោះ នរោត្តម ថុល នោះដែរ ព្រោះចង់ដឹងថា តើនរោត្តម ថុល នោះជានរណា? បានជាសរសេរ អត្ថបទវាយប្រហារទៅលើពួកគេចំបញ្ហាបានល្អ និងមានខ្លឹមសារស៊ីជម្រៅខ្លាំងម៉្លេះ?។

តែយ៉ាងណា ពួកគេមិនមានការសង្ស័យសូម្បីបន្តិចថា ព្រះអង្គជាអ្នកសរសេរអត្ថបទ ដែលដាក់ឈ្មោះអ្នកនិពន្ធថា នរោត្តម ថុល នោះទេ។

ផ្ទុយទៅវិញ ពួកគេបែរជាសង្ស័យទៅលើព្រះអង្គម្ចាស់នរោត្តម កន្តុល ដែលជាបងប្អូនជីដូនមួយរបស់ព្រះអង្គថា ជាអ្នកសរសេរអត្ថបទទាំងឡាយដែលដាក់ឈ្មោះនរោត្តម ថុល នោះទៅវិញ។



ព្រះអង្គម្ចាស់នរោត្តម កន្តុល

ព្រះមហាក្សត្រសីហនុ និងព្រះបិតុលា មុនីរ៉េត បានរួមគ្នាក្នុងការសរសេរអត្ថបទវាយប្រហារបកអាក្រាតនយោបាយបោកប្រាស់ និងឆ្កឹះកកាយរឿងរ៉ាវអាស្រូវ និងភាពអសកម្មនានារបស់ពួកមន្ត្រីនៅក្នុងជួររាជរដ្ឋាភិបាលដែលមានព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជានាយករដ្ឋមន្ត្រីនោះ រហូតធ្វើឲ្យកាសែត "ក្របីព្រៃ" នេះ ក្លាយជាកាសែតដ៏ល្បីល្បាញមួយ។

ចំណែកព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ប្រធានគណបក្សសេរីភាព ដែលមាន១៤អាសនៈនៅក្នុងសភា និងព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា ប្រធានគណបក្សប្រជាធិបតេយ្យចម្រើនជឿនលឿន ដែលជាប់ឆ្នោតបាន៣អាសនៈនៅក្នុងសភាដែរនោះ ហើយត្រូវសាធារណមតិខ្លះដាក់ឈ្មោះឲ្យទ្រង់ម៉ុងតាណា ថា មេបក្សចម្រើនជឿនលឿនតែខាងបុកប៊ីយ៉ា(ស្នូកឃ័រ) ដោយសារទ្រង់ចូលចិត្តលេងល្បែងបុកប៊ីយ៉ានោះ បានចូលមកទូលពិតព្រះមហាក្សត្រសីហនុ នៅក្នុងព្រះបរមរាជវាំង កើតទុក្ខមិនសុខចិត្តអំពីលទ្ធផលនៃការបោះឆ្នោតថា ពួកប្រជាធិបតេយ្យ មិនមានចិត្តជាអ្នកកីឡាទេ ពួកគេបានបំភ័ន្តបោកបញ្ឆោតប្រជារាស្ត្រ ដោយភូតកុហកថា ព្រះមហាក្សត្របានអំពាវនាវឲ្យប្រជារាស្ត្របោះឆ្នោតឲ្យ

គណបក្សរបស់ពួកគេ ទើបបានជាពួកគេទទួលជ័យជម្នះច្រើនសន្ទឹកសន្ធាប់យ៉ាងដូច្នេះ។

ព្រះមហាក្សត្រសីហនុ មិនបានឆ្លើយតបអ្វីទៅទ្រង់នរោត្តម នរិន្ទដេត និងទ្រង់នរោត្តម ម៉ុងតាណា នោះទេ ដោយព្រះអង្គគ្រាន់តែនឹកនៅក្នុងព្រះទ័យថា បញ្ហាឃោសនារកសំឡេងឆ្នោតនេះ ពួកអ្នកនយោបាយទាំងអស់គួរតែដឹងថា ក្នុងរបបលទ្ធិប្រជាធិបតេយ្យ គេត្រូវប្រើគ្រប់យុទ្ធសាស្ត្រ គ្រប់យុទ្ធវិធី ទាំងការពិត ទាំងការមិនពិត ដើម្បីទាក់ទាញយកការគាំទ្រពីប្រជារាស្ត្រជាម្ចាស់ឆ្នោត។

ព្រះមហាក្សត្រសីហនុ ក៏ឈ្វេងយល់ថា ការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យនាពេលនោះ គឺបានត្រឹមតែបង្កជម្លោះបែកបាក់គ្នារវាងរាជវង្ស ដែលជាមេដឹកនាំគណបក្សមានអាសនៈនៅក្នុងរដ្ឋសភា ទាំង៣អង្គ គឺទ្រង់យុត្តិវង្ស, ទ្រង់នរិន្ទដេត និងទ្រង់ម៉ុងតាណា ដើម្បីដណ្ដើមកម្ទេចកម្ទីអំណាចមួយបំណែកតូច ដែលបារាំង ទុកឲ្យព្រះអង្គជាព្រះមហាក្សត្រតែប៉ុណ្ណោះ ខណៈដែលអំណាចដ៏ធំសម្បើម បារាំងបានរក្សាទុកសម្រាប់ខ្លួនគេ។

តែទោះជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលដែលមានទ្រង់យុត្តិវង្ស ជាប្រមុខនោះ បានចាប់ផ្ដើមធ្វើកំណែទម្រង់ស្ថាប័នព្រះមហាក្សត្រ ដែលហួសសម័យហើយនោះបានខ្លះៗដែរ និងបានបង្កើតរចនាសម្ព័ន្ធផ្សេងៗ ដើម្បីអភិវឌ្ឍប្រទេសឲ្យរីកចម្រើនទាន់សម័យខ្លះៗដែរ ហើយពួកប្រជាធិបតេយ្យ បានអះអាងថា ពួកគេនឹងដឹកនាំប្រទេសដោយមិននៅក្រោមចំណុះនរណាឡើយ។

ចំពោះបញ្ហាទាមទារឯករាជ្យពីបារាំង រាជរដ្ឋាភិបាលទ្រង់យុត្តិវង្ស បានប្រើវិធីត្រជាក់ ដោយធ្វើឲ្យមន្ត្រីជាន់ខ្ពស់បារាំង ធ្វើការថ្លឹងថ្លែងថា តើបារាំង សុខចិត្តប្រគល់ឯករាជ្យមកដល់ពួកខ្លួនដែលជាពួកបញ្ញវន្តកំពុងកាន់អំណាចនៅពេលនេះ ឬមួយនៅទីបំផុត បារាំងត្រូវបង្ខំចិត្តប្រគល់ឯករាជ្យឲ្យពួកខ្មែរឥស្សរៈ ដែលកំពុងបះបោរប្រយុទ្ធតស៊ូធ្វើសង្គ្រាមបង្ហូរឈាមនៅក្នុងព្រៃ។

ពួកប្រជាធិបតេយ្យ បានធ្វើឲ្យដឹងខ្លួនថា ដរាបណាសង្គ្រាមនៅតែបង្កការរីករាលនៅប្រទេសវៀតណាមនោះ បារាំងក៏មិនអាចស្ថិតនៅក្នុងប្រទេសកម្ពុជា បានជារៀងរហូតដែរ។

ជាមួយគ្នានោះដែរ បានផ្សព្វផ្សាយឲ្យបារាំង គឺ៖

ព្រះមហាក្សត្រនរោត្តម សីហនុ បានធ្វើការកត់សម្គាល់ថា បន្ទាប់ពីបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី មិនបានប៉ុន្មានខែផង ជីវភាពរស់នៅរបស់ក្រុមគ្រួសារព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស បានស្ទុះឡើងខ្ពស់ត្រដែត។

មិនតែប៉ុណ្ណោះ ទ្រង់យុត្តិវង្ស បានស្នើសុំឲ្យព្រះអង្គជាព្រះមហាក្សត្រ ប្រគល់ព្រះរាជដំណាក់របស់ព្រះអង្គមួយនៅក្រុងកែប និងព្រះរាជដំណាក់របស់ព្រះអង្គមួយទៀត នៅទន្លេបាទី ក្នុងខេត្តតាកែវ ទៅឲ្យទ្រង់យកទុកធ្វើជាកម្មសិទ្ធិសម្រាប់សម្រាកលំហែកាយផ្ទាល់ខ្លួនរបស់ទ្រង់ទៀតផង។

ព្រះមហាក្សត្រនរោត្តម សីហនុ បញ្ជាក់ទៅទ្រង់យុត្តិវង្ស ថា ព្រះរាជដំណាក់ទាំងពីរកន្លែងនេះ ព្រះអង្គមិនចាត់ទុកជាទ្រព្យសម្បត្តិកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គទេ គឺព្រះអង្គទុកសម្រាប់ព្រះមហាក្សត្រក្រោយៗទៀត។

# ២០
# ព្រះមហាក្សត្រសីហនុ យាងសាងផ្នួសលាបំណាន់ មុននាយករដ្ឋមន្ត្រី យុត្តិវង្ស សុគត



**ព្រះមហាក្សត្រសីហនុ យាងសាងផ្នួស**

នៅក្នុងខែមិថុនា ឆ្នាំ១៩៤៧ ព្រះមហាក្សត្រនរោត្តម សីហនុ បានសម្រេចព្រះទ័យសាងផ្នួសរយៈពេលមួយវស្សា (៣ខែ) ដើម្បីលាបំណន់ ព្រោះកាលពីយប់ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ គឺពេលដែលកងទ័ពជប៉ុន បើកយុទ្ធនាការចាប់ពួកបារាំងទាំងអស់យកទៅឃុំឃាំងនោះ ព្រះអង្គមានការភ័យខ្លាចដែរ ក៏បានរត់ភៀសព្រះកាយចេញពីព្រះបរមរាជវាំងទៅគង់នៅក្នុងកុដិព្រះតេជគុណកែវ អ៊ូច ក្នុងវត្តបទុមវតី ហើយនៅក្នុងយប់គួរឲ្យភ័យខ្លាចនោះ ព្រះអង្គបានបន់ស្រន់ថា បើព្រះអង្គបានរួចផុតពីគ្រោះកាចចង្រៃនាពេលនេះ ព្រះអង្គនឹងសាងផ្នួស ដើម្បីជាការតបស្នងសងគុណដល់បារមីព្រះពុទ្ធជាអម្ចាស់វិញ។

នៅក្នុងឱកាសសាងផ្នួសដំបូងនោះ ព្រះអង្គបានព្យាយាមសម្របសម្រួលកាយចិត្តទាំងស្រុងក្នុងការធ្វើសមាធិយ៉ាងមុតមាំ ដោយព្រះអង្គមិនបាននិមន្តទៅទីណាឆ្ងាយពីទីក្រុងទេ ព្រោះកុំឲ្យមានការរំខានដល់ប្រជារាស្ត្រជាអ្នកស្រែចម្ការដែលកំពុងមមាញឹកក្នុងការបង្កបង្កើនផល។

## របត់នយោបាយ

កាលនោះ មានព្រះគ្រូ កែវ អ៊ូច, ព្រះគ្រូ ជួន ណាត, ព្រះគ្រូ ហួត តាត (កាលនោះព្រះគ្រូទាំង៣អង្គ មិនទាន់មានគោរម្យងារជាសម្តេចសង្ឃរាជនៅឡើយ) ជាអ្នកចេះដឹងជ្រៅជ្រះខាងវិស័យព្រះពុទ្ធសាសនា ជាអ្នកជួយបង្ហាត់បង្រៀនព្រះអង្គ។

កាសែតបរទេសជាច្រើនបានចុះផ្សាយរូបថតព្រះអង្គជាព្រះសង្ឃនោះ និងធ្វើអត្ថាធិប្បាយតាមការយល់ឃើញរបស់ពួកគេរៀងៗខ្លួន ស្តីពីព្រះមហាក្សត្រខ្មែរមួយអង្គ បានសាងផ្នួសក្នុងព្រះពុទ្ធសាសនា ដែលធ្វើឲ្យពុទ្ធបរិស័ទទាំងឡាយនៅក្នុងទ្វីបអាស៊ី មានការភ្ញាក់ផ្អើល និងរំភើបរីករាយយ៉ាងខ្លាំង។

ចំណែកប្រជារាស្ត្រខ្មែរនៅទូទាំងប្រទេស ក៏កាន់តែបង្ហាញនូវសមានចិត្តជ្រះថ្លា និងគោរពព្រះអង្គខ្លាំងក្លាជាងមុនទៅទៀត។ ឯពួកប្រជាធិបតេយ្យវិញ តែងតែនាំគ្នាចូលមកក្រាបបង្គំព្រះអង្គនៅក្នុងព្រះវិហារព្រះកែវមរកត ដើម្បីស្តាប់ព្រះអង្គសម្តែងធម៌ទេសនា ជាប់ជាប្រចាំនឹងគេដែរ។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៤៧ គម្រប់រយៈពេល៣ខែ ព្រះអង្គក៏បានលាចាកសិក្ខាបទត្រឡប់មកគ្រប់គ្រងព្រះរាជតួនាទីជាព្រះមហាក្សត្រវិញ។

ចំណែកព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីបានតែ៦-៧ខែ ជំងឺរបេងរបស់ទ្រង់ដែលមានពីមុនមកនោះ បានធ្វើទុក្ខកាន់តែធ្ងន់ធ្ងរទៅៗ ហើយបើទោះបីគ្រូពេទ្យជំនាញៗ ព្យាយាមប្រឹងប្រែងព្យាបាលអស់ពីសមត្ថភាពយ៉ាងណា ក៏នៅតែមិនអាចជួយសង្គ្រោះព្រះជន្មទ្រង់បានដែរ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស សុគតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៧ នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ក្រុងភ្នំពេញ ក្នុងព្រះជន្មាយុ៣៤ព្រះវស្សា ។

ទោះបីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស បានសុគតនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ដោយសារជំងឺរបេង ក៏ពិតមែន តែមន្ត្រីគណបក្សប្រជាធិបតេយ្យខ្លះនៅតែសង្ស័យថា នេះជាករណីអំពើឃាតកម្មនយោបាយដែរ។

ក្រោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ជានាយករដ្ឋមន្ត្រី សុគតទៅ ពួកមន្ត្រីគណបក្ស

ប្រជាធិបតេយ្យ មានគម្រោងសាងសង់មហាចេតិយមួយនៅលើកំពូលភ្នំព្រះរាជទ្រព្យ ក្នុងស្រុកឧដុង្គ ដែលជាកន្លែងកំណើតរបស់ទ្រង់ផងដែរនោះ ឲ្យមានទំហំធំ និងមានកម្ពស់ស្មើនឹងកំពូលភ្នំព្រះរាជទ្រព្យគឺធំនិងខ្ពស់ជាងព្រះចេតិយរបស់ព្រះបរមសពព្រះមហាក្សត្រនរោត្តម ស៊ីសុវត្ថិ និងព្រះបរមសពព្រះមហាក្សត្រព្រះមុនីវង្ស ទៅទៀត។

តែក្រោយពេលគូសវាសប្លង់ហើយ ទើបពួកគេដឹងថា ត្រូវចំណាយលុយកាក់សម្បើមណាស់។ ដំបូងពួកគេបានយកថវិកាជាតិមួយចំនួនទៅសាងសង់មហាចេតិយនោះ។

បន្ទាប់មក ពួកគេបានអំពាវនាវដល់សប្បុរសជនទូទៅឲ្យចូលរួមវិភាគទានជួយឧបត្ថម្ភបន្ថែម ។ ប៉ុន្តែសម្រាប់អ្នកក្រីក្រ គ្មានលទ្ធភាពអ្វីដើម្បីចូលរួមវិភាគទានឡើយ ។

បញ្ហាខ្វះខាតលុយកាក់ដ៏ច្រើនសន្ធឹកសន្ធាប់នោះ ធ្វើឲ្យមន្ត្រីជាន់ខ្ពស់គណបក្សប្រជាធិបតេយ្យមួយចំនួន ចង់ឲ្យមានការផ្លាស់ប្ដូរគម្រោងនេះ មកសាងសង់ចេតិយមធ្យមសមរម្យល្មមនឹងលុយកាក់ដែលប្រមូលបានវិញ។

តែពួកមន្ត្រីជិតស្និទ្ធជាមួយទ្រង់យុត្តិវង្ស នៅតែចចេសចង់សាងសង់មហាវិមានចេតិយដ៏ធំស្កឹមស្កៃ ដែលពុំមានលទ្ធភាពសាងសង់បាននោះដដែល។

ព្រះមហាក្សត្រនរោត្តម សីហនុ នៅចាំបានទៀតថា ចំណែកនៅក្នុងសភា បើទោះបីមានការជំទាស់ពីគណបក្សប្រឆាំងយ៉ាងណាក៏ដោយ ក៏មានសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យភាគច្រើនលើសលប់ បានបោះឆ្នោតអនុម័តឲ្យមានច្បាប់ពិសេសមួយ ដោយបង្ខំឲ្យប្រជាពលរដ្ឋទាំងអ្នកទីក្រុង និងអ្នកស្រែចម្ការ បង់វិភាគទានជាទឹកប្រាក់ស្មើនឹងចំនួន ៥ហ្វ្រង់បារាំង ក្នុងមួយខ្នងផ្ទះ ដើម្បីយកទៅសាងសង់មហាវិមានចេតិយនោះ ។

ប៉ុន្តែនៅទីបំផុត ពួកគេបានត្រឹមតែសាងសង់វិមានតម្កល់អដ្ឋិធាតុមួយតូចធម្មតាប៉ុណ្ណោះ ហើយមជ្ឈដ្ឋានខ្លះសង្ស័យថា អាចមានប្រាក់មួយចំនួនធំដែលនៅសល់ពីការសាងសង់នេះ ពួកមន្ត្រីជាន់ខ្ពស់គណបក្សប្រជាធិបតេយ្យ នឹងបង្វិលចូលជាថវិការដ្ឋវិញ ។

ប៉ុន្តែអ្នកដែលបានចូលជាវិភាគទានទាំងប៉ុន្មាន មានការខកចិត្តយ៉ាងខ្លាំង ព្រោះលុយកាក់ដែលពួកគេប្រមូលបានយ៉ាងច្រើនសន្ធឹកសន្ធាប់នោះមិនឃើញបង្វិលចូលជា

ថវិការដ្ឋវិញ ហើយធ្វើឲ្យបែកបាក់ផ្ទៃក្នុងគណបក្សប្រជាធិបតេយ្យ តាំងពីពេលនោះមក ។

ពីរសប្តាហ៍ក្រោយមក ដោយមានព្រះរាជតម្រិះរបស់ព្រះមហាក្សត្រ សីហនុ ផងដែរ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៤៧ រាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាធិបតេយ្យនេះ ត្រូវជ្រើសតាំងនាយករដ្ឋមន្ត្រីថ្មី រុះរើផ្លាស់ប្តូរសមាសភាព និងធ្វើការកែសម្រួលក្រសួងមួយចំនួន។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ វឌ្ឍឆាយាវង្ស ដែលជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវបានតែងតាំងដំឡើងជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, សឺន សាន ពីមុនជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ត្រូវបានតែងតាំងដំឡើងជាឧបនាយករដ្ឋមន្ត្រី, ប៉ែន នុត ជាទេសរដ្ឋមន្ត្រីទទួលបន្ទុកទីក្រុងភ្នំពេញដដែល អូ ឈឺន ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ហាក់ ម៉ុងសេង ជារដ្ឋ-មន្ត្រីក្រសួងហិរញ្ញវត្ថុ, សុន វ៉ីនសៃ ជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ប៉ែន សំអែល ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ, ប្រាក់ សារិន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សាធារណការ និងគមនាគមន៍, អ៊ុក ធុច ជារដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ និង ហ៊ុយ កន្ធុល ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងសង្គមកិច្ច ។

ដោយមើលឃើញថា ព្រះមហាក្សត្រនរោត្តម សីហនុ មានអំណាចក្នុងការតែងតាំងរាជរដ្ឋាភិបាលថ្មីនេះ ពួកមន្ត្រីធំៗមួយចំនួន ពិសេសភាគច្រើនជាជំទាវៗដែលខានឃើញមុខចូលព្រះបរមរាជវាំង តាំងពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនោះ ក៏បានចាប់ផ្តើមនាំគ្នាចេញចូលព្រះបរមរាជវាំង ដូចខ្យងបណ្តាក់គ្នាជាថ្មីឡើងវិញ ដើម្បីក្រាបថ្វាយបង្គំសម្តែងការគួរសមចំពោះម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសុមៈ ដែលជាព្រះមាតាព្រះមហាក្សត្រ ដោយរឹតតែឱនលំទោន និងទូលបញ្ជោរបូរបាច់យកគាប់គួរផ្អែមល្ហែមជាងពេលមុនទៅទៀត ។

# ២១
# ព្រះមហាក្សត្រសីហនុ ចាប់ផ្ដើមថ្លែងសង្កថាមិនស្របតាមបារាំង



ព្រះមហាក្សត្រសីហនុ ថ្លែងសង្កថា

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៤៧ គឺជាថ្ងៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ២៥វស្សារបស់ព្រះមហាក្សត្រនរោត្ដម សីហនុ មន្ត្រីជាន់ខ្ពស់ម្នាក់ តំណាងសាធារណរដ្ឋបារាំង ឈ្មោះ លូបេត៍ បានអញ្ជើញមកជាកិត្តិយស និងថ្លែងសុន្ទរកថា ថ្វាយព្រះពរក្នុងព្រះរាជពិធីដ៏អធិកអធមនេះ។

តាមទម្លាប់ពីដើមរៀងមក តំណាងប្រទេសបារាំងដែលត្រូវមកចូលរួមជាអធិបតីក្នុងពិធីនេះ ត្រូវផ្ញើខ្លឹមសារទាំងស្រុងនៃសុន្ទរកថានោះមកថ្វាយព្រះមហាក្សត្រជាមុនសិន ដើម្បីទុកឱកាសថ្វាយព្រះអង្គទត និងពិចារណាលើខ្លឹមសារសុន្ទរកថានោះ មុននឹងរៀបចំព្រះរាជសង្កថាមួយ ថ្លែងតបទៅតំណាងប្រទេសបារាំងវិញ ឲ្យបានសមស្របទៅនឹងខ្លឹមសារនៃសុន្ទរកថារបស់តំណាងប្រទេសបារាំងនោះ ។

តែនៅពេលព្រះអង្គទតខ្លឹមសារសុន្ទរកថា របស់តំណាងប្រទេសបារាំង ដែលផ្ញើមក

នោះ បានបង្ហាញឲ្យឃើញពីការខឹងសម្បារបស់លោក ចំពោះអត្ថបទទាំងឡាយរបស់មេដឹកនាំគណបក្សប្រជាធិបតេយ្យ ដែលចុះផ្សាយលើទំព័រកាសែតរបស់ពួកគេទៅវិញ ។

តំណាងប្រទេសបារាំងរូបនេះ ចាត់ទុកថា អត្ថបទទាំងឡាយរបស់មេដឹកនាំគណបក្សប្រជាធិបតេយ្យដែលចុះផ្សាយលើទំព័រកាសែតរបស់ពួកគេនោះ ជាអំពើវិទ្ធង្សនាមួយយ៉ាងពិតប្រាកដ ព្រោះពួកគេបានសរសេរវាយប្រហារប្រទេសបារាំងថា ពេលនេះ កម្ពុជាជាប្រទេសមានលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សហើយក៏ពិតមែន តែបារាំងនៅតែធ្វើអាណានិគមលើកម្ពុជាបន្តទៀត ខណៈដែលប្រទេសអង់គ្លេស បានប្រគល់ឯករាជ្យដល់ប្រទេសឥណ្ឌា និងភូមា ទៅហើយនោះ ហើយពួកគេថា ប្រទេសអង់គ្លេស មិនធ្វើដូចប្រទេសបារាំងបែបនេះទេ។

ក្នុងសុន្ទរកថារបស់តំណាងប្រទេសបារាំង លូបេត៍ បានបញ្ជាក់ថា ប្រទេសកម្ពុជានឹងលែងមានការអភិវឌ្ឍន៍តទៅទៀត ហើយសកម្មភាពអនាធិបតេយ្យនឹងកាន់តែរីកធំឡើងៗ ប្រសិនបើបារាំងប្រគល់ឯករាជ្យឲ្យកម្ពុជាវិញ ក្នុងពេលប្រទេសនេះមិនទាន់បានរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកស៊ីវិល ហើយផ្នែកយោធាក៏ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ព្រមទាំងពុំទាន់មានអ្នកបច្ចេកទេសជំនាញៗក្នុងការកសាងប្រទេសនៅឡើយនោះ ។

ទីប្រឹក្សារបស់ព្រះមហាក្សត្រ ឈ្មោះម៉ាជីវេត៍ ជនជាតិបារាំង បានតាក់តែងព្រះសង្កថាមួយទុកថ្វាយព្រះមហាក្សត្រ ដើម្បីថ្លែងតបទៅនឹងសុន្ទរកថារបស់តំណាងប្រទេសបារាំង នៅក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មនោះរួចស្រេចហើយដែរ។

តែក្រោយពីព្រះអង្គពិនិត្យថ្លឹងថ្លែងខ្លឹមសារក្នុងព្រះរាជសង្កថានេះមក ធ្វើឲ្យព្រះអង្គខ្វល់ខ្វាយព្រះទ័យបំផុត ព្រោះព្រះសង្កថានេះមានអត្ថន័យថា ព្រះអង្គត្រូវតែគាំទ្រ និងរក្សាទុកប្រទេសជាតិរបស់ព្រះអង្គឲ្យបារាំង ធ្វើជាអាណាព្យាបាលបន្តទៀត ហើយព្រះអង្គត្រូវតែប្រឆាំងពួកអ្នកប្រជាធិបតេយ្យដែលកំពុងលេងល្បែងប្រជាភិថុតិមួយគួរឲ្យស្អប់ខ្ពើម ព្រោះពេលនេះ ពួកគេកំពុងកាន់អំណាចពេញនៅក្នុងដៃហើយ បានត្រឹមតែស្រែកទាមទារឯករាជ្យតាមរយៈអត្ថបទដែលចុះផ្សាយលើទំព័រកាសែតរបស់ពួកគេប៉ុណ្ណោះ ដោយមិន

ហ៊ានចេញមុខទាមទារឯករាជ្យជាផ្លូវការនៅចំពោះមុខពួកបារាំងនោះឡើយ។

ព្រះមហាក្សត្រនរោត្តម សីហនុ មិនឯកភាពតាមខ្លឹមសារព្រះសង្កថាដែលទីប្រឹក្សារបស់ព្រះអង្គឈ្មោះម៉ាធីវេត៍ បានរៀបរៀងទុកថ្វាយនោះទេ។

នៅទីបំផុត ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មនៅក្នុងប្រាសាទទេវាវិនិច្ឆ័យ ព្រះអង្គសម្រេចព្រះទ័យអានព្រះសង្កថាមួយដែលរៀបរៀងដោយព្រះហស្តរបស់ព្រះអង្គផ្ទាល់ទៅវិញ ។

ក្នុងព្រះសង្កថានោះ ព្រះអង្គបានថ្លែងអំណរគុណចំពោះបំណងល្អរបស់តំណាងប្រទេសបារាំង លូបេត៍ ដែលចង់ឲ្យប្រទេសកម្ពុជា មានរចនាសម្ព័ន្ធក្របខ័ណ្ឌស៊ីវិល, មានកម្លាំងយោធាមួយប្រកបដោយសមត្ថភាពគ្រប់គ្រាន់ និងអ្នកបច្ចេកទេសមានជំនាញខ្ពស់ៗ មុនពេលប្រទេសទទួលយកឯករាជ្យ ដូចដែលតំណាងប្រទេសបារាំងបានលើកឡើងក្នុងសុន្ទរកថានោះ។

តែព្រះអង្គបានស្នើសុំឲ្យតំណាងជាន់ខ្ពស់របស់ប្រទេសបារាំង លូបេត៍ កុំយកបណ្ដាប្រទេសដែលពុំសូវមានអរិយធម៌ខ្ពង់ខ្ពស់ទាំងឡាយនៅលើសកលលោក ដែលទើបទទួលបានឯករាជ្យថ្មីៗ មកប្រៀបធៀបជាមួយប្រទេសកម្ពុជា។

ព្រះអង្គសង្កត់ធ្ងន់ថា ការដឹកនាំគ្រប់គ្រងប្រទេសរបស់ព្រះអង្គ និងរាជរដ្ឋាភិបាលនៅពេលនេះ ពិតជាខ្វះសមត្ថភាព គ្មានសណ្ដាប់ធ្នាប់ និងមានចន្លោះប្រហោងពិតមែន តែនៅពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យហើយនោះ ការខ្វះសមត្ថភាព គ្មានសណ្ដាប់-ធ្នាប់ និងចន្លោះប្រហោងនោះ ក៏មិនអាចកើតមានតទៅទៀតដែរ ។

ខ្លឹមសារនៃព្រះរាជសង្កថានេះ ធ្វើឲ្យអ្នកចូលរួមក្នុងព្រះរាជពិធី មានការស្រឡាំងកាំងភ្ញាក់ផ្អើលយ៉ាងខ្លាំង។

អ្នកដែលមានការស្រឡាំងកាំងខ្លាំងជាងគេ គឺម៉ាធីវេត៍ ជាទីប្រឹក្សារបស់ព្រះអង្គ ព្រោះលោកមិននឹកស្មានថា ព្រះអង្គបោះចោលនូវព្រះរាជសង្កថា ដែលលោកបានតាក់តែងនោះចោល បែរជាទៅយកព្រះរាជសង្កថា ដែលជាស្នាព្រះហស្តផ្ទាល់របស់ព្រះអង្គ មកថ្លែង

## របត់នយោបាយ

ក្នុងពិធីដ៏អធិកអធមនោះយ៉ាងដូច្នេះសោះ ?

ឯតំណាងជាន់ខ្ពស់របស់ប្រទេសបារាំង លូបេត៍ វិញ ស្ទើរតែទប់កំហឹងក្រេវក្រោធមិនបាន ខណៈមន្ត្រីបារាំង ដែលចូលរួមក្នុងព្រះរាជពិធីនោះទាំងប៉ុន្មាន ក៏មានការភ្ញាក់ផ្អើលគ្រប់ៗគ្នាដែរ។ តែពួកមន្ត្រីគណបក្សប្រជាធិបតេយ្យ និងមន្ត្រីខ្មែរផ្សេងៗទៀតបានងាកមកខ្សឹបខ្សៀវគ្នាទៅវិញទៅមកក្នុងអារម្មណ៍ខុសប្លែកពីធម្មតា ។

មួយថ្ងៃក្រោយមក ក្រោយពីបានដឹងពីព្រឹត្តិការណ៍នេះ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសក៏បាននាំគ្នាសម្តែងនូវទឹកចិត្តសោមនស្ស និងកោតសរសើរចំពោះសេចក្តីក្លាហានរបស់ព្រះមហាក្សត្រសីហនុ ដោយក្តីរំភើបរីករាយបំផុត ដែលហ៊ានថ្លែងព្រះរាជសង្កថាបែបនេះ នៅចំពោះមុខតំណាងជាន់ខ្ពស់របស់ប្រទេសបារាំង ដូច្នេះ។

# ២២
# ការបែកបាក់របស់គណបក្សប្រជាធិបតេយ្យ

នៅក្នុងឆ្នាំ១៩៤៦ បារាំង បានទាមទារទឹកដីខេត្តបាត់ដំបង និងទឹកដីមួយភាគធំនៃខេត្តសៀមរាប និងកំពង់ធំ ដែលថៃ បានដណ្តើមយកទៅនៅឆ្នាំ១៩៤១នោះ មកឲ្យប្រទេសកម្ពុជាវិញ ហើយប្រទេសថៃ ត្រូវបង្ខំចិត្តសុំអភ័យទោសចំពោះប្រទេសជាមហាអំណាច ពីការសមគំនិតរបស់ខ្លួនជាមួយពួកឈ្លានពានជប៉ុន និងពួកណាហ្ស៊ីអាល្លឺម៉ង់ ផងដែរ។

ពេលនោះ សឺន សាន ត្រូវបានតែងតាំងជាតំណាងព្រះមហាក្សត្រសីហនុ ឲ្យទៅចូលរួមក្នុងពិធីចុះហត្ថលេខាព្រមព្រៀងបារាំង-ថៃ ស្តីពីការប្រគល់ទឹកដីទាំងនោះ មកឲ្យប្រទេសកម្ពុជាវិញ នៅទីក្រុងវ៉ាស៊ីងតោន សហរដ្ឋអាមេរិក ។

បន្ទាប់មក នៅខេត្តបាត់ដំបង ដេរី ដាកហ្សង់លីយេ ជាតំណាងប្រទេសបារាំង ក៏បានរៀបចំពិធីថ្វាយទឹកដីខេត្តទាំងបីនោះ មកឲ្យព្រះមហាក្សត្រខ្មែរវិញ យ៉ាងអធិកអធមបំផុតដែរ។

ប៉ុន្តែមុនពេលដកថយទៅវិញ កងទ័ពថៃ បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធអស់ជាច្រើន ជាពិសេសគឺពួកគេបានដាក់គ្រាប់មីនបំផ្លាញស្ពានខ្ទេចខ្ទីស្ទើរតែទាំងអស់ ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧ មានការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាថ្មីម្តងទៀត ហើយគណបក្សដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ រួមមាន៖ គណបក្សប្រជាធិបតេយ្យ របស់អៀវ កើស, គណបក្សសេរីភាព របស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត, គណបក្សចំរើនជឿនលឿន របស់ព្រះអង្គម្ចាស់នរោត្តម ម៉ុងតាណា, គណបក្សខេមរៈប៉ុណ្ណការ របស់ញឹក ជូឡុង និងលន់ នល់ និងគណបក្សរួបរួមជាតិ របស់ឃឹម ទិត។ ទោះបីព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស បានសុគតទៅហើយក្តី ក៏គណបក្សប្រជាធិបតេយ្យនៅតែមានប្រជាប្រិយភាពដដែល ។

អៀវ កើស បានបន្តដឹកនាំគណបក្សនេះ ចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាង



អៀវ កើស ប្រធានរដ្ឋសភា

រាស្ត្រនោះប្រកបដោយជោគជ័យ ទទួលបានអាសនៈនៅក្នុងរដ្ឋសភា ចំនួន៥៤ អាសនៈ។ គណបក្សសេរីភាព របស់ព្រះអង្គម្ចាស់ នរិន្ទដេត ទទួលបាន២១អាសនៈ ក្នុងចំណោមអាសនៈសរុប៧៥ ក្នុងរដ្ឋសភា។ ក្រោយលទ្ធផលនៃការបោះឆ្នោត ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៧ អៀវ កើស បានកាន់តំណែងជាប្រធានរដ្ឋសភាបន្តទៀត ។

ចំណែកមេដឹកនាំគណបក្សទាំងឡាយដែលមិនបានជាប់ឆ្នោត ក៏ត្រូវបានតែងតាំងជាសមាជិក របស់ក្រុមប្រឹក្សាព្រះរាជាណាចក្រដែរ ។

មុនពេលចូលកាន់តំណែងជាសមាជិកសភា អៀវ កើស តែងតែផ្តល់ឱវាទដល់សមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យថា អស់លោក! បន្ទុករដ្ឋសភាលើកនេះកាន់តែធ្ងន់ធ្ងរជាងបន្ទុករដ្ឋសភាបណ្តោះអាសន្នទៅទៀត ព្រោះសភាយើងត្រូវអនុម័តតាមច្បាប់រដ្ឋធម្មនុញ្ញ ហើយការអនុវត្តច្បាប់រដ្ឋធម្មនុញ្ញនេះ ពុំមែនជាការងាយស្រួលប៉ុន្មានទេ ព្រោះផ្ទះមួយមានម្ចាស់ពីរ។ បើយើងចង់រៀបចំផ្ទះយ៉ាងនេះ តែបារាំងថា ឲ្យរៀបចំយ៉ាងនោះទៅវិញ យើងត្រូវតែធ្វើតាមបារាំង។ បើយើងមិនស្តាប់បារាំងទេ ប្រាកដជាមានឧបសគ្គដល់គណបក្សយើងទៀតហើយ។ តែបើយើងស្តាប់តាមបារាំង រដ្ឋធម្មនុញ្ញជាមាគ៌ានយោបាយរបស់ជាតិយើងនឹងក្លាយទៅជារបស់ឥតមានតម្លៃ ហើយថែមគណបក្សយើងភាគច្រើននឹងក្លាយទៅជាមនុស្សជាប់ចោទពីប្រជាពលរដ្ឋថែមទៀតផង។

ជាមួយគ្នានោះ អៀវ កើស បានណែនាំដល់តំណាងរាស្ត្រជាប់ឆ្នោតមកពីគណបក្ស

ប្រជាធិបតេយ្យទាំងអស់ថា អស់លោកគ្រប់រូបត្រូវជ្រាបថា លទ្ធិប្រជាធិបតេយ្យមានអត្ថន័យស៊ីជម្រៅទូលំទូលាយណាស់ និស្ស័យដូចទឹកសមុទ្រ។ ម្ល៉ោះហើយខ្លួនខ្ញុំក្តី អស់លោកគ្រប់គ្នាក្តី មិនយល់នូវអត្ថន័យលិទ្ធិប្រជាធិបតេយ្យនេះឱ្យបានសព្វគ្រប់ទេ ប៉ុន្តែខ្ញុំសូមសង្ខេបសេចក្តីជាមូលដ្ឋាននៃលទ្ធិនេះថា សំខាន់នៅលើមតិភាគច្រើន តែមតិភាគច្រើន ពុំមែនសុទ្ធតែត្រូវឥតខ្ចោះនោះទេ ជួនកាលកាលៈទេសៈខ្លះខុសទៅវិញក៏មានដែរ។ ប៉ុន្តែគេសន្មតចាត់ទុកមតិភាគច្រើន ជាមតិត្រឹមត្រូវនោះ ព្រោះមតិភាគតិចគ្មានមូលដ្ឋាន និងទ្រទ្រង់រដ្ឋាភិបាលជាតំណាងប្រជាជាតិទេ ទើបបានជាគេសន្មតឱ្យមតិភាគតិច ចាញ់មតិភាគច្រើននេះហើយជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ។

អៀវ កើស បានពន្យល់ថា លទ្ធិប្រជាធិបតេយ្យ ត្រូវអាស្រ័យទៅលើការពឹងផ្អែកប្រជែងប្រណាំងគ្នាក្នុងការសម្តែងយោបល់នៃអ្នកតំណាងរាស្ត្រលើវេទិកា។ អ្នកតំណាងរាស្ត្រណាមានមធ្យោបាយច្រើនចេះនិយាយឲ្យអ្នកតំណាងរាស្ត្រ ឯទៀតចាប់អារម្មណ៍ គឺមតិអ្នកតំណាងរាស្ត្រនោះពិតជាមានប្រសិទ្ធភាពក្នុងពេលវិនិច្ឆ័យ ដូច្នេះគូប្រជែងប្រណាំងមិនត្រូវខូចចិត្តទេ ហើយត្រូវទទួលស្គាល់សមត្ថភាពរបស់ខ្លួនថា មកពីខ្លួនខ្វះមធ្យោបាយ មិនបានរិះគិតនូវសុខទុក្ខរបស់ប្រជារាស្ត្របានសព្វគ្រប់ ទើបមតិរបស់ខ្លួនចាញ់គេ។ ដូច្នេះត្រូវរិះរកមធ្យោបាយសាជាថ្មីឡើងវិញ ដើម្បីជ័យជម្នះនៅថ្ងៃក្រោយ ខែក្រោយ ឆ្នាំក្រោយទៅទៀតសូមកុំអស់សង្ឃឹមឲ្យសោះ។

ការប្រណាំងប្រជែងគ្នានេះពុំមែនជាការឥតប្រយោជន៍ទេ គឺមានប្រយោជន៍សំខាន់ណាស់ ព្រោះក្នុងគោលគំនិតដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់វឌ្ឍនភាព និងសុភមង្គល។ តាមធម្មតា អ្នកប្រឆាំងចាញ់គេក្នុងផ្លូវគំនិតតែងមានចិត្តគុំកួនបៀមទុក។ នៅពេលសន្សំគំនុំគុំកួនបានច្រើនហើយ ថ្ងៃក្រោយមនុស្សនោះឯងពិតជាក្លាយខ្លួនទៅជាអ្នកកាន់អំណាចលទ្ធិផ្តាច់ការទៅវិញ។ ដល់ពេលខ្លួនប្រមូលយកអំណាចបាន អួតអាងមួយថ្នាក់ទៀតថាខ្លួនកាន់លទ្ធិប្រជាធិបតេយ្យ ពិសេសដូចលោកហ៊ីត្លែរ៍ នាយករដ្ឋមន្ត្រីប្រទេសអាល្លឺម៉ង់ចោទប្រកាន់គេឯងថា គេធ្វើឲ្យខូចនយោបាយខ្លួន ក៏បញ្ជាឲ្យមនុស្សដុតរដ្ឋសភាចោល រួច

ចោទអ្នកតំណាងរាស្ត្រថា ដុតរដ្ឋសភាទៅវិញ ហើយយកតំណាងរាស្ត្រដែលមានយោបល់នឹងខ្លួនទៅសម្លាប់ចោលអស់ ដូចសុភាសិតបារាំងថា មុននឹងសម្លាប់ឆ្កែចោល ត្រូវចោទថាឆ្កែនោះឆ្កួតសិន បើមិនដូច្នោះទេ អ្នកផងគេចោទថា ម្ចាស់ឆ្កែឆ្កួតទៅវិញ។ នេះហើយដែលចាត់ទុកថា លទ្ធិផ្ដាច់ការដែលជ្រៀតតាមប្រជាធិបតេយ្យ សូមអស់លោកប្រយ័ត្ន...។

លុះដល់ថ្ងៃទី២ ខែមករា ឆ្នាំ១៩៤៨ គណបក្សប្រជាធិបតេយ្យ ក៏បានរៀបចំរាជរដ្ឋាភិបាលថ្មីមួយ ដោយមាន ឈាន វ៉ម កាលនោះទើបមានអាយុ៣២ឆ្នាំ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ, សឺន សាន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ , ពីទូ ដឺម៉ុងតេរ៉ូ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, យិត ស្រ៊ុន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, សុន វ៉ុនសៃ ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ សាធារណការ និងការពារជាតិ, ហ៊ុយ កន្ថុល ជារដ្ឋមន្ត្រីក្រសួងធម្មការ ពុទ្ធិកសិក្សា និងសង្គមកិច្ច, ម៉ម ស៊ុន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល, យ៉ែម សំបូរ ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកនគរបាលជាតិ, មៀច គន្ធ រដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ, ហ៊ុយ ម៉ោង ជារដ្ឋលេខាធិការក្រសួងការពារជាតិ, ថុន អ៊ុក ជារដ្ឋលេខាធិការក្រសួងព័ត៌មាន និងអ៊ិត ស៊ាម ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងផ្គត់ផ្គង់ ។

ដើមខែកុម្ភៈ ឆ្នាំ១៩៤៨ រដ្ឋាភិបាលបារាំង បានយាងព្រះមហាក្សត្រនរោត្តម សីហនុ ទៅចូលរួមជាព្រះរាជាធិបតី ក្នុងពិធីបើកការដ្ឋានសាងសង់អគារសម្រាប់និស្សិតខ្មែរស្នាក់នៅ។

គម្រោងសាងសង់អគារនេះ ជាជំនួយរបស់រដ្ឋាភិបាលបារាំង ស្ថិតនៅក្នុងបុរីសាកលវិទ្យាល័យទីក្រុងប៉ារីស ។

ឈាន វ៉ម ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីអប់រំ, ឡេអុង ពីញ៉ុង ទេសាភិបាលជាន់ខ្ពស់បារាំងប្រចាំកម្ពុជា និងម៉ាធឺវេត៍ ជាទីប្រឹក្សាព្រះមហាក្សត្រ ក៏បានអមព្រះរាជដំណើរផងដែរ ។

ឈាន វ៉ម ជានាយករដ្ឋមន្ត្រីវ័យក្មេង បានរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញាជួន ជឿម ជាចៅរបស់ឧកញ៉ាចៅហ្វាវាំងជួន ។

កញ្ញាជួន ជឿម នេះហើយ ដែលអគ្គទេសាភិបាលបារាំង ឈ្មោះហ្សក ហ្គោតដេ



ព្រះមហាក្សត្រសីហនុ យាងទៅក្រុងប៉ារីស ឆ្នាំ១៩៤៨

មានគម្រោងឲ្យព្រះមហាក្សត្រនរោត្តម សីហនុ រៀបអភិសេកជាមួយ កាលពីឆ្នាំ១៩៤២ តែព្រះអង្គមិនមានមនោសញ្ចេតនាជាមួយនាងបន្តិចឡើយនោះ ។

ល្ងាចមួយ ពេលព្រះអង្គកំពុងសោយភោជនាហារនៅតុមួយដែលគេតុបតែងយ៉ាងល្អប្រណីត ក្នុងភោជនីយដ្ឋានឡឺដូយាង នៅដងមហាវិថីហ្សង់អេលីហ្សេ ក្នុងក្រុងប៉ារីស ម្ចាស់ភោជនីយដ្ឋាននេះ ក៏បានមកសុំថតព្រះឆាយាល័ក្ខណ៍ព្រះអង្គ ទុកជាអនុស្សាវរីយ៍ ។

បន្ទាប់មកទៀត ម្ចាស់ភោជនីយដ្ឋាននោះ ក៏បានសុំរាជានុញ្ញាតពីព្រះអង្គ ដើម្បីឲ្យស្រីបារាំង ដ៏ស្រស់ស្អាតម្នាក់ ដែលគាត់បានណែនាំឲ្យព្រះអង្គស្គាល់កាលពីដំបូងនោះ មកអង្គុយក្បែរព្រះអង្គ ដើម្បីថតរូបទុកជាអនុស្សាវរីយ៍ផងដែរ ព្រះអង្គក៏យល់ព្រមដោយព្រះ-ទ័យរីករាយ ។

ស្រាប់តែមួយថ្ងៃក្រោយមក នៅលើទំព័រកាសែតហ្វ្រង់ស្វ័រ ក៏មានការចុះផ្សាយរូបថតរបស់ព្រះអង្គជាមួយស្រីបារាំងដ៏ស្រស់ស្អាតនោះ និងអត្ថបទមួយដាក់ចំណងជើងថា "ព្រះមហាក្សត្រខ្មែរ នឹងរៀបការជាមួយនារីគង្វាលចៀមបារាំង ម្នាក់" ។

## របត់នយោបាយ

ក្រោយកាសែតហ្វ្រង់ស្វ័រ ចុះផ្សាយរឿងនេះមក ធ្វើឲ្យពួកនិស្សិតខ្មែរដែលកំពុងបន្តការសិក្សានៅក្រុងប៉ារីសនោះ មានការខឹងសម្បា និងអាក់អន់ចិត្តយ៉ាងខ្លាំង ហើយតំណាងសមាគមនិស្សិតខ្មែរ បានទទូចសុំចូលគាល់ព្រះអង្គជាបន្ទាន់ ។

ព្រះអង្គ ក៏មិនចង្អៀតចង្អល់ដែរ គឺបានអនុញ្ញាតឲ្យពួកគេចូលគាល់នៅក្នុងបន្ទប់របស់ព្រះអង្គក្នុងសណ្ឋាគារ ដោយមានឡេអុង ពីញ៉ុង ទេសាភិបាលជាន់ខ្ពស់បារាំងប្រចាំកម្ពុជា និងម៉ាធីវេត៍ ជាទីប្រឹក្សាព្រះអង្គកំពុងស្ថិតនៅក្នុងបន្ទប់នោះជាមួយដែរ ។

តំណាងសមាគមនិស្សិតខ្មែរនោះ រួមមាន អៀ ស៊ីចូវ ដែលជាមេដឹកនាំចលនាជាតិនិយមរបស់សឹង ង៉ុកថាញ់ តាំងពីគេកំពុងរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ព្រមទាំងជួន ជុំ និងជួន មុម្ម ជាប្អូនប្រុសរបស់អ្នកស្រីជួន ជឿន ជាភរិយារបស់នាយករដ្ឋមន្ត្រីឈាន វ៉ម ។

ពួកគេបានពោលពាក្យសម្ដីគំរោះគំរើយ ចោទប្រកាន់ព្រះមហាក្សត្រថា ជាជនអនាចារ បានប្រព្រឹត្តអំពើផ្ដេសផ្ដាសជាមួយស្រីបារាំងម្នាក់នោះ ធ្វើឲ្យអាប់ឱនកិត្តិយសរបស់ជាតិខ្មែរទាំងមូល ។

ទង្វើដ៏ព្រហើនកោងកាចនេះ ធ្វើឲ្យព្រះអង្គភាន់ភាំង ស្រឡាំងកាំង រកពាក្យអ្វីតបទៅពួកគេវិញមិនបាន ក្រៅតែគង់នៅស្ងៀមឈឹង ។

ប៉ុន្តែ ឡេអុង ពីញ៉ុង ទេសាភិបាលជាន់ខ្ពស់ប្រចាំកម្ពុជា ដែលធ្លាប់តែជាមនុស្សចេះគួរសម និងតែងតែគោរពទំនាក់ទំនងបារាំង-ខ្មែរ បានបញ្ជាក់ការពិតប្រាប់ពួកគេថា ព្រះអង្គមិនបានប្រព្រឹត្តអំពើមិនគួរគប្បីជាមួយស្រីបារាំងម្នាក់នោះទេ ដោយព្រះអង្គគ្រាន់តែបានសោយភោជនាហារជាមួយស្រីម្នាក់នោះជាធម្មតាតែប៉ុណ្ណោះ។

បន្ទាប់មក លោកក៏បានបន្ទោសតំណាងសមាគមនិស្សិតទាំងនោះថា "ពួកអ្នកឯងមិនត្រូវភ័ន្តច្រឡំតាមអត្ថបទដែលចុះផ្សាយលើទំព័រកាសែតហ្វ្រង់ស្វ័រ ដោយគ្រាន់តែដាក់ចំណងជើងដើម្បីកន្ត្រាក់អារម្មណ៍របស់មិត្តអ្នកអានគេបែបនេះទេ "។

ឡេអុង ពីញ៉ុង បញ្ជាក់បន្ថែមថា "ទោះជាយ៉ាងណា ក៏ពួកអ្នកឯងគ្មានសិទ្ធិអ្វីនាំគ្នាមកអុកឡុកដល់កន្លែងព្រះមហាក្សត្របែបនេះដែរ ។ ពួកអ្នកឯងដឹងទេ ពេលនេះព្រះមហា-

ក្សត្រខ្មែរ កំពុងគង់នៅជាភ្ញៀវដ៏ខ្ពង់ខ្ពស់របស់ប្រទេសបារាំង ហើយពួកអ្នកឯងពល់គ្នាដែលបានមករៀនសូត្រនៅប្រទេសបារាំងនេះក៏ដោយសារតែព្រះអង្គដែរ"។

ឡេអុង ពីញ៉ុង បន្ថែមទៀតថា "ពេលនេះ ក្នុងនាមប្រទេសបារាំង ខ្ញុំសូមបញ្ជាឲ្យពួកអ្នកឯងចាកចេញពីទីនេះជាប្រញាប់ "។

ភ្លាមនោះ អៀ ស៊ីចូវ, ជួន ជុំ , ជួន មុម្ម ក៏លែងព្រហើនកោងកាចដាក់ព្រះមហាក្សត្រសីហនុ មួយរំពេច ហើយក៏នាំគ្នាចាកចេញទៅវិញបាត់អស់ ។



ឡេអុង ពីញ៉ុង ទេសាភិបាលជាន់ខ្ពស់បារាំង
ប្រចាំប្រទេសខ្មែរ ឆ្នាំ១៩៤៨

ទោះបីជាជួន ជុំ , ជួន មុម្ម ជាប្អូនថ្លៃរបស់នាយករដ្ឋមន្ត្រីឈាន វ៉ម ក៏ពិតមែន តែព្រះមហាក្សត្រ សីហនុ បានកោតសរសើរថា ថ្វីត្បិតតែពេលនោះ ឈាន វ៉ម មានវ័យក្មេងខ្ចី និងខ្វះបទពិសោធន៍ក្នុងការដឹកនាំរាជរដ្ឋាភិបាលក៏ដោយ ក៏គាត់មានបរិញ្ញាបត្រអក្សរសាស្ត្រ និងមានចរិតសុភាពរាបសា គួរសមរាក់ទាក់ជាងគេ ក្នុងចំណោមអ្នកនយោបាយខ្មែរទាំងអស់នៅកម្ពុជា។

រាជរដ្ឋាភិបាលឈាន វ៉ម កើតឡើងមិនបានប៉ុន្មានខែផង ក៏កើតមានបញ្ហាចម្រូង-ចម្រាស ដោយសារយ៉ែម សំបូរ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកនគរបាលជាតិ បានបញ្ចេញឯកសារសំខាន់ៗជាច្រើន ដែលទាក់ទងនឹងរឿងអាស្រូវរបស់តំណាងរាស្ត្រមកពីគណបក្សប្រជាធិបតេយ្យមួយចំនួន ធ្វើឲ្យឈាន វ៉ម ជានាយករដ្ឋមន្ត្រី មានការខឹងសម្បារឿងនេះយ៉ាងខ្លាំង រហូតដល់មានការទាមទារឲ្យចាប់ខ្លួន យ៉ែម សំបូរ ទៀតផង តែមិនបានសម្រេច ព្រោះទំនងមានព្រះមហាក្សត្រសីហនុ ជាអ្នកជួយការពារ។

ពេលនោះ ស៊ឺន សាន , ថុន អ៊ុក , ពីទូ ដឺម៉ុងតេរ៉ូ, ឃិត ស្រ៊ុន, សុន វ៉ឺនសៃ, ហ៊ុយ ម៉ោង, ម៉ម ស៊ុន, មៀច គន្ធ ជាដើម ជាសមាជិកគណៈរដ្ឋមន្ត្រី នាំគ្នាគាំទ្រនាយករដ្ឋមន្ត្រី ឈាន វ៉ម ដែលជាបញ្ញវន្តមានដើមកំណើតចេញពីគ្រួសារកសិករ ។

ឯយ៉ែម សំបូរ ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកនគរបាលជាតិ ដែលចូលចិត្តកីឡាប្រដាល់ខ្លាំងបំផុត និងមន្ត្រីចាស់ៗមួយចំនួន កាលនៅក្នុងសមាសភាពគណៈរដ្ឋមន្ត្រីរបស់ទ្រង់យុត្តិវង្ស ពីមុន យល់ថា ពួកអ្នកគាំទ្រនាយករដ្ឋមន្ត្រីឈាន វ៉ម បានប្រមាថមើលងាយពួកខ្លួនដែលមិនបានទៅរៀនសូត្រដល់ប្រទេសបារាំង ពិសេសយ៉ែម សំបូរ ផ្ទាល់ថា មើលស្រាលលោក ដែលពីមុនគ្រាន់តែជាប្រធានកងអង្គរក្សតាមការពារសន្តិសុខឲ្យព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស នោះ បណ្តាលឲ្យមានបញ្ហាជម្លោះបែកបាក់គ្នាកាន់តែខ្លាំងឡើងៗ រហូតក្រុមយ៉ែម សំបូរ កៀងគរប្រមូលបក្ខពួកក្នុងគណបក្សប្រជាធិបតេយ្យ និងមានការគាំទ្រពីតំណាងរាស្ត្រមកពីគណបក្សសេរីភាព របស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ប្រឆាំងផងនោះ ឈាន វ៉ម ក៏លាឈប់ពីតំណែង។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៤៨ រាជរដ្ឋាភិបាលថ្មីមួយទៀតត្រូវបានបង្កើតឡើង។

រាជរដ្ឋាភិបាលថ្មីនោះ ប៉ែន នុត ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងសារព័ត៌មាន, ស៊ឺន សាន ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច។ ឯឈាន វ៉ម ដែលចុះចេញពីតំណែងពីនាយករដ្ឋមន្ត្រីនោះ ជារដ្ឋមន្ត្រីក្រសួងការពារ ជាតិ, សុន វ៉ឺនសៃ ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងសាធារណការ, ហ៊ុយ កន្ធុល ជារដ្ឋមន្ត្រីអប់រំ កីឡា និងយុវជន, មៀច គន្ធ ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, ម៉ម ស៊ុន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សង្គមកិច្ច, ឃិត ស្រ៊ុន រដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ, ទេព ផន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ, ងិន ការ៉េត ជារដ្ឋលេខាធិការក្រសួងសាធារណការ និងថុល អ៊ុក ជារដ្ឋលេខាធិការក្រសួងព័ត៌មានដដែល ។

ចំណែកយ៉ែម សំបូរ ជារដ្ឋលេខា ធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកនគរបាលជាតិ ជាអ្នកប្រឆាំងនឹងឈាន វ៉ម នោះ មិនមានឈ្មោះក្នុងសមាសភាពគណៈរដ្ឋមន្ត្រីថ្មីនេះទេ។

តែទោះបីយ៉ែម សំបូរ មិនមានឈ្មោះនៅក្នុងសមាសភាពគណៈរដ្ឋមន្ត្រីថ្មីនេះក៏ដោយ ក៏ក្រោយរាជរដ្ឋាភិបាលប៉ែន នុត មានរឿងអាស្រូវ ដោយសារមៀច គន្ធ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ប្រើឥទ្ធិពលរបស់ខ្លួន ដើម្បីឲ្យសាច់ញាតិរបស់គាត់ដេញថ្លៃយកទឡ្ហត់នេសាទមួយនៅម្តុំភូមិខ្លាគ្រហឹម ខេត្តកំពង់ឆ្នាំង ដោយគ្មានតម្លាភាព និងធ្វើឱ្យត្រីងាប់ពេញបឹងទន្លេសាបមក នៅខែមករា ឆ្នាំ១៩៤៩ យ៉ែម សំបូរ ដែលគេចាត់ទុកថា ជាមនុស្សរបស់ព្រះមហាក្សត្រសីហនុ និងបក្ខពួកនៅក្នុងសភា បាននាំគ្នាគាស់កកាយរឿងអាស្រូវនេះ និងរឿងអាស្រូវផ្សេងៗទៀត ក្នុងបំណងផ្តួល រំលំរាជរដ្ឋាភិបាលប៉ែន នុត បន្តទៀត។



**យ៉ែម សំបូរ**

ពេលនោះ អៀវ កើស ក្នុងនាមជាប្រធានរដ្ឋសភា និងជាប្រធានគណបក្សប្រជាធិបតេយ្យ មិនចង់ប្រឈមមុខវែងឆ្ងាយជាមួយព្រះមហាក្សត្រសីហនុ គាត់ក៏បាននិយាយបញ្ចុះបញ្ចូលតំណាងរាស្ត្រមកពីគណបក្សប្រជាធិបតេយ្យ ឲ្យបោះឆ្នោតគាំទ្រយ៉ែម សំបូរ ធ្វើជានាយករដ្ឋមន្ត្រី និងបញ្ចុះបញ្ចូលមន្ត្រីគណបក្សប្រជាធិបតេយ្យ ឲ្យចូលរួមនៅក្នុងរាជរដ្ឋាភិបាលនោះផងដែរ តាមការចង់បានរបស់ព្រះមហាក្សត្រសីហនុ ។

តែមន្ត្រីគណបក្សប្រជាធិបតេយ្យ ភាគច្រើន បានបដិសេធមិនព្រមចូលរួមនៅក្នុងរាជរដ្ឋាភិបាល យ៉ែម សំបូរ នោះទេ។

ទោះបីយ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៤៩ ព្រះមហាក្សត្រនរោត្តម សីហនុ បានតែងតាំងរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយមានយ៉ែម សំបូរ ជានាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងព័ត៌មាន, ស៊ុំ ហៀង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការសេដ្ឋកិច្ច និងផែនការ, ហ៊ុយ ម៉ាង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ស្វាយ សូ ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ចៅសែន កុសល ជារដ្ឋមន្ត្រីយុត្តិធម៌, ផ្លែក ភីន ជារដ្ឋមន្ត្រីកសិកម្ម សាធារណការ និងគមនាគមន៍, មាស សាអែម ជារដ្ឋមន្ត្រីអប់រំ, រ៉ាយ លុត ជារដ្ឋមន្ត្រីឧស្សាហកម្ម ពាណិជ្ជកម្ម និងផ្គត់ផ្គង់, យុត ឃឿន ជារដ្ឋមន្ត្រីធម្មការ និងនាល ផ្លែង ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសង្គមកិច្ច។

ក្រោយពីបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីមក យ៉ែម សំបូរ តែងតែធ្វើការរិះគន់មន្ត្រីរបស់គណបក្សប្រជាធិបតេយ្យ ថាជាពួកពុករលួយ និងបង្កបញ្ហាផ្សេងៗទៀត បណ្តាលឲ្យមានជម្លោះបែកបាក់គ្នាកាន់តែធ្ងន់ធ្ងរទៅ។

ពេលនោះដែរ នាយករដ្ឋមន្ត្រី យ៉ែម សំបូរ បានបើកឲ្យមានកាស៊ីណូ ដើម្បីរកលុយចូលថវិកាជាតិផងដែរ ហើយការបើកកាស៊ីណូនោះ បណ្តាលឲ្យសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ នាំគ្នាធ្វើកូដកម្មប្រឆាំងយ៉ាងខ្លាំងក្លាឡើងៗ ។ រហូតដល់មាស សាអែម រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ក៏សម្រេចបិទវិទ្យាល័យព្រះស៊ីសុវត្ថិ ជាបណ្តោះអាសន្ន ។

ក្រោយពីនាយករដ្ឋមន្ត្រី យ៉ែម សំបូរ បើកឲ្យមានកាស៊ីណូ ហើយរដ្ឋមន្ត្រីក្រសួងអប់រំជាតិ មាស សាអែម បិទវិទ្យាល័យព្រះស៊ីសុវត្ថិនោះមក ធ្វើឲ្យសិស្សវិទ្យាល័យនេះ មានការខឹងសម្បារីតែតែខ្លាំងថែមទៀត ក៏នាំគ្នាធ្វើបាតុកម្មកាន់តែខ្លាំងជាងមុន ដោយស្រែកនូវពាក្យស្លោកតាមចង្វាក់ភ្លេងធៃយ៉ាំព្រមៗគ្នា និងដដែលៗថា មាស សាអែម, យ៉ែម សំបូរ បើកកាស៊ីណូ បិទវិទ្យាល័យ! ហ៊ុយ ម៉ាងៗៗៗ (ហ៊ុយ ម៉ាង ជារដ្ឋមន្ត្រីក្រសួងការពារជាតិ)។

ក្រោយពីមានទំនាស់រវាងរាជរដ្ឋាភិបាលរបស់យ៉ែម សំបូរ និងពួកតំណាងរាស្ត្រនៅក្នុងសភា កាន់តែរីករាលដាលខ្លាំងឡើងៗមក យ៉ែម សំបូរ នាយករដ្ឋមន្ត្រី បានសំណូមពរទៅព្រះមហាក្សត្រសីហនុ ត្រាស់បង្គាប់ឲ្យរំលាយសភាចោល និងត្រាស់បង្គាប់ឲ្យមានការបោះឆ្នោតជាថ្មី។

ដោយឈ្វេងយល់ថា នេះជាដំណោះស្រាយសមហេតុសមផលដែរនោះ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៤៩ ព្រះមហាក្សត្រសីហនុ បានចេញព្រះរាជក្រឹត្យសម្រេចរំលាយសភាចោល ហើយមួយថ្ងៃក្រោយមក គឺនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៤៩ ព្រះមហាក្សត្រសីហនុ ក៏បានចេញព្រះរាជក្រឹត្យ រំលាយរាជរដ្ឋាភិបាលរបស់យ៉ែម សំបូរ ចោលដែរ ។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៤៩ ព្រះអង្គបានតែងតាំងសមាសភាពរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយមានអៀវ កើស ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ស៊ុំ ហៀង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច និងផែនការ, ចំណែកយ៉ែម សំបូរ (នាយករដ្ឋមន្ត្រីមុននោះ) ជារដ្ឋមន្ត្រីព័ត៌មាន, ហ៊ុយ ម៉ោង រដ្ឋមន្ត្រីការពារជាតិ, ស្វាយ សូ ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ចៅសែន កុសល ជារដ្ឋមន្ត្រីយុត្តិធម៌, ផ្លែក ភឺន ជារដ្ឋមន្ត្រីកសិកម្ម សាធារណការ និងគមនាគមន៍, មាស សាអែម ជារដ្ឋមន្ត្រីអប់រំជាតិ, រ៉ាយ ល្មុត ជារដ្ឋមន្ត្រីឧស្សាហកម្ម ពាណិជ្ជកម្ម និងផ្គត់ផ្គង់, យុត ឃឿន ជារដ្ឋមន្ត្រីធម្មការ និងនាល ផ្លែង ជារដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច។

ក្រោយពេលបង្កើតរាជរដ្ឋាភិបាលដឹកនាំដោយអៀវ កើស បានតែមួយសប្តាហ៍ប៉ុណ្ណោះ ស្រាប់តែនៅថ្ងៃទី២៨ ខែកញ្ញា ព្រះមហាក្សត្រសីហនុ បានប្រកាសព្យួររដ្ឋធម្មនុញ ហើយមួយថ្ងៃក្រោយមក គឺនៅថ្ងៃទី២៩ ខែកញ្ញា ព្រះអង្គក៏បានប្រកាសតែងតាំងគណៈរដ្ឋមន្ត្រីថ្មីមួយទៀត ដោយតែងតាំងយ៉ែម សំបូរ ជានាយករដ្ឋមន្ត្រី វិញដដែល។

សមាសភាពគណៈរដ្ឋមន្ត្រីថ្មីនោះ រួមមាន យ៉ែម សំបូរ ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ និងរដ្ឋមន្ត្រីការពារជាតិ, ស៊ុំ ហៀង រដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច ផែនការធម្មការ, ចៅសែន កុសល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, មាស សាអែម រដ្ឋមន្ត្រីអប់រំ និងយុវជន, ផ្លែក ភឺន រដ្ឋមន្ត្រីកសិកម្ម សាធារណការ និងគមនាគមន៍, រ៉ាយ ល្មុត រដ្ឋមន្ត្រីពាណិជ្ជកម្ម ឧស្សាហកម្ម និងផ្គត់ផ្គង់, នាល ផ្លែង រដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច, យុត ឃឿន រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងវិចិត្រសិល្បៈ និងផូ គ្រឿង រដ្ឋលេខាធិការក្រសួងការពារជាតិ។

ពេលនោះ លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស នៅប្រទេសកម្ពុជា បានឈានចូល

ដល់ដំណាក់កាលមួយ ដែលគ្មានទាំងរដ្ឋសភា ហើយថែមទាំងគ្មានរដ្ឋធម្មនុញ្ញទៀតផង។

ការសម្រេចព្រះទ័យរំលាយសភា និងព្យួររដ្ឋធម្មនុញ្ញ ព្រមទាំងផ្លាស់ប្តូររាជរដ្ឋាភិបាលថ្មីភ្លាមៗ ពីរបីដងបែបនេះ មិនមែនព្រះមហាក្សត្រសីហនុ ធ្វើឡើងតាមទំនើងព្រះទ័យរបស់ព្រះអង្គនោះទេ តែព្រះអង្គផ្អែកទៅលើរដ្ឋធម្មនុញ្ញ មាត្រា៣៨ ដែលបានចែងថា ព្រះអង្គទ្រង់នូវព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្តីណែនាំគណៈរដ្ឋមន្ត្រី។ ព្រះមហាក្សត្រិយ៍ ទ្រង់រំលាយរដ្ឋសភាបានតែមួយដងដោយហេតុដដែល។ បើមានការរំលាយរដ្ឋសភាដូចខាងលើនេះ ការជ្រើសតាំងជាថ្មីត្រូវឲ្យមានក្នុងរយៈវេលាពីរខែយ៉ាងយូរ។

មាត្រា៣៩- ព្រះមហាក្សត្រិយ៍ ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី ហើយទ្រង់តែងតាំងនាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រី ដែលនាយកនោះក្រាបបង្គំទូលសុំឲ្យតាំង ។

ពិសេសការសម្រេចរំលាយសភាចោល ហើយតែងតាំងរាជរដ្ឋាភិបាលថ្មីដូច្នេះ ព្រះអង្គបានលើកហេតុផលថា ពេលនោះ ប្រទេសជាតិកំពុងឆ្លងកាត់គ្រោះអាសន្ន ដោយសារពួកខ្មែរឥស្សរៈ និងពួកវៀតមិញ កំពុងបង្កអសន្តិសុខនៅទូទាំងប្រទេស ពិសេសមាត្រា២១ នៃរដ្ឋធម្មនុញ្ញ ក៏បានចែងច្បាស់ថា៖ អំណាចគ្រប់យ៉ាងបានមកពីព្រះមហាក្សត្រ ផងដែរ ។

ចំណែកឈាន វ៉ម ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាធិបតេយ្យ និងជាអតីតនាយករដ្ឋមន្ត្រី ក្រោយមកដោយសារឆ្អែតឆ្អន់ និងធុញទ្រាន់នឹងជម្លោះបែកបាក់ផ្ទៃក្នុងគណបក្សប្រជាធិបតេយ្យ គាត់ក៏សម្រេចចិត្តដើរចេញពីឆាកនយោបាយ ទៅប្រកបមុខរបររកស៊ីផ្សេងវិញ។

# ២៣
# ការបាត់បង់ទឹកដីកូសាំងស៊ីន




**ផែនទីកម្ពុជាក្រោម**

នៅចុងឆ្នាំ១៩៤៥ រដ្ឋាភិបាលចិនជាតិនិយម (ចិនសេរី ជៀង កៃជៀក) ដែលបានបញ្ជូនកងទ័ពខ្លួនប្រមាណ២០ម៉ឺននាក់ ឲ្យមកជួយបណ្តេញកងទ័ពជប៉ុន នៅវៀតណាមភាគខាងជើងនោះ បានដកថយទៅវិញដែរ តែបានរក្សាទុកកងទ័ពខ្លួនមួយចំនួន ហើយសន្យាជាមួយរដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម ថា នឹងជួយការពារមិនឲ្យកងទ័ពបារាំង វិលត្រឡប់មកត្រួតត្រាវៀតណាមភាគខាងជើងវិញ ជាដាច់ខាត។

តែរដ្ឋាភិបាលចិនជាតិនិយម ជៀង កៃជៀក មិនចង់ឲ្យពួកកុម្មុយនិស្ត ហូ ជីមិញ ឡើងកាន់អំណាចប៉ុន្មានទេ គឺចង់ឲ្យពួកអ្នកជាតិនិយមវៀតណាម (វៀតណាមសេរី)

ឡើងកាន់ អំណាចវិញ។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៤៦ រដ្ឋាភិបាលចិនជាតិនិយម និងបារាំង បានចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ដោយចិនជាតិនិយម សុខចិត្តប្រគល់ទឹកដីវៀតណាមដែលនៅភាគខាងជើងខ្សែបន្ទាត់ស្របទី១៧ ទៅឲ្យបារាំងត្រួតត្រាដូចមុនវិញ។

ចំណែកបារាំង ក៏សុខចិត្តប្រគល់ទីក្រុងសៀងហៃ , ទីក្រុងជិនសិក , ទីក្រុងហាន់កូវ និងទីក្រុងក្វាងទុង ដែលខ្លួនកាន់កាប់នោះ ទៅឲ្យប្រទេសចិនវិញ ហើយយល់ព្រមលក់ផ្លូវរទេះភ្លើងដែលខ្លួនបានកសាងនៅក្នុងខេត្តយូណាន ទៅឲ្យចិន វិញទៀតផង។

ជាមួយគ្នានោះ បារាំងបានសន្យាថា នឹងយកចិត្តទុកដាក់ក្នុងការលើកស្ទួយសិទ្ធិសេរីភាព ដល់ជនជាតិចិនទាំងឡាយដែលរស់នៅក្នុងតំបន់ឥណ្ឌូចិនឲ្យមានសិទ្ធិស្មើគ្នាជាមួយនឹងជនជាតិដើមដែលជាម្ចាស់ប្រទេសនោះផងដែរ។

ដោយសារតែរដ្ឋាភិបាលចិនជាតិនិយម ប្រែក្រឡាស់កិច្ចសន្យារបស់ខ្លួន ដោយយល់ព្រមអនុញ្ញាតឲ្យកងទ័ពបារាំង ចូលមកកាន់កាប់វៀតណាមភាគខាងជើង ដូចមុនវិញនោះ រដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម ( ពួកកុម្មុយនិស្តវៀតណាម និងពួកអ្នកជាតិនិយមវៀតណាម ) គ្មានជម្រើសអ្វីក្រៅពីសុំជួបចរចាជាមួយបារាំង ជាមុនសិននោះឡើយ។

នៅក្នុងការចរចានោះ រដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម មានហូ ជីមិញ តំណាងឲ្យពួកវៀតមិញ និងវូ ហុងខាញ់ តំណាងឲ្យអ្នកជាតិនិយមវៀតណាម យល់ព្រមឲ្យកងទ័ពបារាំង ចូលមកបោះទីតាំងនៅទឹកដីរបស់ខ្លួន តែពួកគេទាមទារលក្ខខណ្ឌ ២ចំណុច គឺទី១. ឲ្យបារាំងប្រគល់ឯករាជ្យដល់ប្រទេសខ្លួន និងទី២.ទាមទារឲ្យបារាំង ប្រគល់ទឹកដីកូសាំងស៊ីន ( កម្ពុជាក្រោម ) ឲ្យមកជាទឹកដីរបស់វៀតណាម។

តែបើបារាំង មិនយល់ព្រមតាមការទាមទាររបស់ខ្លួនទាំងពីរចំណុចនេះទេ ភាគីវៀតណាម ក៏មិនព្រមឲ្យបារាំង ចូលមកបោះទីតាំងនៅលើទឹកដីរបស់ខ្លួនវិញដែរ។

ភាគីបារាំង បានបដិសេធមិនឲ្យភាគីវៀតណាម ប្រើពាក្យថា បារាំង យល់ព្រមប្រគល់ឯករាជ្យឲ្យវៀតណាមនោះទេ គឺបារាំង ឲ្យប្រើពាក្យថា បារាំង យល់ព្រមប្រគល់

សេរីភាពឲ្យវៀតណាម ជំនួសពាក្យប្រគល់ឯករាជ្យនោះវិញ។

ចំណែកបញ្ហាប្រគល់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) ទៅឲ្យវៀតណាម ឬយ៉ាងណានោះ បារាំង ប្រាប់ថា ត្រូវរង់ចាំនៅក្រោយពេលធ្វើប្រជាមតិសិន។

ដោយសារភាគីរដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម នៅតែរក្សាគោលជំហរចចេសកេងចំណេញច្រើនពេក ធ្វើឲ្យកាន់តែមានបញ្ហាស្មុគស្មាញប្រទាញប្រទង់គ្នាខ្លាំងឡើងៗ រហូតធ្វើឲ្យការចរចានោះឈានដល់ភាពទាល់ច្រក។

ពេលនោះ រដ្ឋាភិបាលចិនជាតិនិយម ក៏បានសម្រេចចូលធ្វើអន្តរាគមន៍ ដោយធ្វើការគាបសង្កត់លើភាគីរដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម ឲ្យបន្ទន់ឥរិយាបថ និងធ្វើសម្បទានខ្លះចំពោះបារាំង។

នៅទីបំផុត កិច្ចព្រមព្រៀងមួយរវាងភាគីបារាំង និងភាគីរដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម ដែលគេឲ្យឈ្មោះថា កិច្ចព្រមព្រៀងទីក្រុងហាណូយ ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៤៦ ក៏បានប្រព្រឹត្តទៅឡើងដោយជោគជ័យ។

កិច្ចព្រមព្រៀងនេះ មាន៣ចំណុចសំខាន់ គឺ៖

ទី១. រដ្ឋាភិបាលបារាំង ព្រមទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលរួមមានតុងកឹង និងអណ្ណាម ជារដ្ឋតែមួយ មានរដ្ឋាភិបាលតែមួយ, សភាតែមួយ, កងទ័ពតែមួយ និងមានហិរញ្ញវត្ថុតែមួយ ហើយរដ្ឋនេះត្រូវស្ថិតនៅក្នុងសហព័ន្ធឥណ្ឌូចិន របស់សហភាពបារាំង។ ចំណែកការបញ្ចូលទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) ឲ្យទៅជាទឹកដីរបស់វៀតណាម ឬយ៉ាងណានោះ ត្រូវធ្វើតាមរយៈការធ្វើប្រជាមតិមួយនៅពេលក្រោយ។

ទី២. រដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម ប្រកាសយល់ព្រមឲ្យកងទ័ពបារាំង ក្នុងនាមជាសម្ព័ន្ធមិត្តរបស់ខ្លួន ចូលមកបោះទីតាំងនៅលើទឹកដីរបស់ខ្លួន ជំនួសកងទ័ពរដ្ឋាភិបាលចិនជាតិនិយម ជៀង កៃជៀក។

ទី៣. កិច្ចព្រមព្រៀងនេះ នឹងត្រូវចាប់អនុវត្តភ្លាមៗ ក្រោយពីការចុះហត្ថលេខា ដើម្បីឈានទៅរកការចរចាកំពូលរវាងបារាំង និងវៀតណាម ស្តីអំពីឯករាជ្យរបស់វៀតណាម និង

លក្ខន្តិកៈនៃអនាគតរបស់ឥណ្ឌូចិន បន្តទៀត។

អ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ភាគីរដ្ឋាភិបាលបង្រួបបង្រួមជាតិវៀតណាម មានលោកហូ ជីមិញ តំណាងឲ្យពួកវៀតមិញ និងវូ ហុងខាញ់ តំណាងឲ្យអ្នកជាតិនិយម វៀតណាម ។ ចំណែកភាគីបារាំង មាន សាំងតឺនី (Sainteny ) និងអាហ្សង់លីយើ( Ar-genlieu ) ។

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៤៦ នោះដែរ ឧត្តមសេនីយ៍សាឡង់ ជាតំណាងកងទ័ព បារាំង និងឧត្តមសេនីយ៍ វ៉ៃ ង្វៀងយ៉ាប់ ជាតំណាងកងទ័ពរដ្ឋាភិបាលបង្រួបបង្រួមជាតិ វៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឧបសម្ព័ន្ធមួយទៀត ស្ដីពីរបៀបរបបដែល កងទ័ពបារាំង ត្រូវចូលមកបោះទីតាំងនៅលើទឹកដីតុងកឹង ជំនួសកងទ័ពរដ្ឋាភិបាលចិន ជាតិនិយមនោះ។

កិច្ចព្រមព្រៀងឧបសម្ព័ននេះ មាន៣ចំណុច គឺៈ

ចំណុចទី១. កងទ័ពដែលត្រូវចូលមកបោះទីតាំងជំនួសកងទ័ពចិនជាតិនិយម នៅ ប៉ែកខាងជើងបន្ទាត់ខ្សែស្របទី ១៧នោះ រួមមាន កងទ័ពសាធារណរដ្ឋប្រជាធិបតេយ្យ វៀតណាម (វៀតណាមខាងជើង) ចំនួន១០០០០នាក់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ មេបញ្ជាការជាជនជាតិវៀតណាម និងកងទ័ពបារាំង មានចំនួន១៥០០០នាក់ ត្រូវស្ថិតនៅ ក្រោមបញ្ជាការរបស់មេបញ្ជាការជនជាតិបារាំង។

កងទ័ពសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងកងទ័ពបារាំង សរុបទាំងអស់ ចំនួន២៥០០០នាក់នេះ ត្រូវស្ថិតនៅក្រោមបញ្ជាការរបស់មេបញ្ជាការម្នាក់ជាជនជាតិបារាំង តែមានជាមេបញ្ជាការរងម្នាក់ទៀតជាជនជាតិវៀតណាម។

ចំណុចទី២. កងទ័ពបារាំង ត្រូវបែងចែកជាបីអង្គភាព គឺៈ

អង្គភាពទី១ៈ មានភារកិច្ចយាមការពារពួកឈ្លើយសឹកជប៉ុន ដែលត្រូវដឹកចេញ ឲ្យអស់ពីទឹកដីវៀតណាម ក្នុងរយៈពេល៦ខែ។

អង្គភាពទី២ៈ មានភារកិច្ចធ្វើកិច្ចសហប្រតិបត្តិការជាមួយកងទ័ពវៀតណាម នៅ



**មេដឹកនាំវៀតមិញ វ៉ ង្វៀងយ៉ាប់ ហូ ជីមិញ ផាំ វ៉ាន់ដុង (ពីស្តាំទៅឆ្វេង)**

ក្នុងការថែរក្សាសន្តិសុខ និងសុវត្ថិភាពរបស់ប្រទេសវៀតណាម។

អង្គភាពទី៣៖ មានភារកិច្ចការពារមូលដ្ឋានកងទ័ពវៀតណាម។

ចំណុចទី៣. រដ្ឋាភិបាលបារាំង សន្យាថា នឹងមិនប្រើប្រាស់ឈ្លើយសឹកជប៉ុន ដើម្បីជាគុណប្រយោជន៍របស់កងទ័ពរបស់ខ្លួនឡើយ។

មួយថ្ងៃក្រោយពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងខាងលើនេះ នៅមុខរោងល្ខោនដ៏ល្បីល្បាញមួយនៅទីក្រុងហាណូយ ហូ ជីមិញ បានរៀបចំឲ្យមានអង្គមីទិ្ទញដ៏ធំមួយ ដោយមានមនុស្សប្រមាណ១០ម៉ឺននាក់ចូលរួម។

ជាដំបូង ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់ បានឡើងថ្លែងពន្យល់ប្រជាជនវៀតណាមថា "សព្វថ្ងៃស្ថានការណ៍នយោបាយអន្តរជាតិ បានប្រែក្រឡាស់អស់ទៅហើយ ដូច្នេះយើង (វៀតណាម) ត្រូវសួរខ្លួនឯងថា តើយើងត្រូវប្រយុទ្ធតស៊ូយូរអង្វែងបន្តទៅទៀត លុះត្រា

បានសម្រេចជោគជ័យ ? ឬមួយយើងត្រូវផ្អាកការប្រយុទ្ធតស៊ូ ?" ។

ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់ បានបន្តថា "តែពេលនេះ ទោះបីយើងចង់តស៊ូបន្តទៀតក្តី ឬមិនចង់ក្តី ក៏សភាពការណ៍នយោបាយអន្តរជាតិបានបង្ខំឲ្យយើងបញ្ឈប់ការប្រយុទ្ធតស៊ូមួយគ្រាសិនដែរ ព្រោះសហរដ្ឋអាមេរិក , អង់គ្លេស និងចិន បាននាំគ្នាទៅកាន់ជើងបារាំងអស់ទៅហើយ ដូច្នេះយើងត្រូវតែចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្ងៃទី៦ ខែមីនា នោះ " ។

ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់ បានពន្យល់ពីផលចំណេញដែលបានមកពីកិច្ចព្រមព្រៀងថ្ងៃទី៦ ខែមីនា នោះថា " ពេលនេះ បារាំងបានទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ជារដ្ឋមួយដែលមានសេរីភាពប៉ុណ្ណោះ ដូច្នេះទោះបីយើងមិនទាន់បានទទួលឯករាជ្យពិតប្រាកដមែន តែយើងមានសេរីភាពច្រើនជាងមុន។ សេរីភាពនេះហើយ ដែលនាំយើងឈានឆ្ពោះទៅរកឯករាជ្យពិតប្រាកដនោះ។ មិនតែប៉ុណ្ណោះ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមយើង មានរដ្ឋាភិបាលតែមួយ, សភាតែមួយ, ហិរញ្ញវត្ថុតែមួយ និងកងទ័ពតែមួយ ដែលអាចជួយឲ្យយើងពង្រឹកកម្លាំងឲ្យបានខ្លាំងក្លាថែមទៀត " ។

ចំពោះបញ្ហាប្រគល់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) ឲ្យមកជាទឹកដីរបស់វៀតណាមនោះ ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់ បានថ្លែងបញ្ជាក់ថា " ថ្វីដ្បិតតែពេលនេះ បញ្ហាប្រគល់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) នៅតែមានការតានតឹង មិនទាន់បានសម្រេចក៏ពិតមែន តែនៅទីបំផុត យើងសង្ឃឹមថា បារាំងនឹងយល់ព្រមឲ្យមានការបង្រួបបង្រួមទឹកដីតុងកឹង និងអណ្ណាម ព្រមទាំងប្រគល់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) មកឲ្យយើងផងដែរ ក្រោយពីបារាំង ធ្វើប្រជាមតិនៅពេលខាងមុខនេះរួច " ។

ចំពោះការខាតបង់របស់វៀតណាមវិញ ឧត្តមសេនីយ៍ វ៉ូ ង្វៀងយ៉ាប់ បានបញ្ជាក់ប្រាប់អង្គមីទ្ទិញថា "មូលហេតុដែលយើងសុខចិត្តចុះហត្ថលេខាលើកិច្ចព្រមព្រៀងឲ្យបារាំងចូលមកប្រទេសយើងវិញនេះ ក៏ដោយសាររដ្ឋាភិបាលចិនជាតិនិយម បានចុះហត្ថលេខាយល់ព្រមឲ្យកងទ័ពបារាំង ចូលមកជំនួសគេដែរ។ ដូច្នេះយើងត្រូវតែបង្ខំចិត្តចរចាជាមួយបារាំង ព្រោះយើងមិនអាចនៅឯកោតែម្នាក់ឯងបានទេ ។ ជាការពិតហើយ ដែលថា យើង

ត្រូវតែរឹងមាំ តែពេលខ្លះ យើងក៏ត្រូវតែទន់ភ្លន់ទៅតាមស្ថានភាពជាក់ស្ដែងផងដែរ " ។

អ្នកឡើងមានមតិទី២ គឺ វូ ហុងខាញ់ ជាមេដឹកនាំចលនាជាតិនិយមវៀតណាម និងជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្ងៃទី៦មីនា នោះដែរ។

តែការលើកឡើងរបស់ វូ ហុងខាញ់ គឺមិនខុសគ្នាប៉ុន្មានពីការលើកឡើងរបស់ឧត្ដម-សេនីយ៍ វូ ង្វៀងយ៉ាប់ នោះទេ។

ចុងក្រោយ គឺហូ ជីមិញ ដែលជាតួឯកក្នុងអង្គមីទ្ទិញនោះ បានឡើងថ្លែងថា "ការពិតយើងទទួលបានឯករាជ្យតាំងពីខែសីហា ឆ្នាំ១៩៤៥ មកម្ល៉េះ តែគ្មានមហាអំណាចណាទទួលស្គាល់ឯករាជ្យយើងនោះទេ។ ដូច្នេះកិច្ចព្រមព្រៀងដែលខ្ញុំទើបតែចុះហត្ថលេខាថ្មីៗនេះ (ថ្ងៃទី៦ ខែមីនា) គឺដើម្បីឲ្យមានការទទួលស្គាល់ឯករាជ្យហ្នឹងឯង " ។

ហូ ជីមិញ បានបញ្ជាក់ថា " យើងចង់បង្រួបបង្រួមទឹកដីរបស់យើងទាំងបី គឺតុងកឹង, អណ្ណាម និងកូសាំងស៊ីន (កម្ពុជាក្រោម) តែយើងមិនអាចទាមទារបានទាំងអស់ក្នុងពេលតែមួយបាននោះទេ។

ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយបារាំង នៅថ្ងៃទី៦ ខែមីនា នោះបាន១១ថ្ងៃ ហូ ជីមិញ បានបញ្ជូនគណៈប្រតិភូមួយក្រុម ដឹកនាំដោយង្វៀង ទុងតាំ ជាតំណាងអ្នកជាតិនិយម និងអតីតព្រះចៅបៅ ដាយ ដែលដូរឈ្មោះមកជា វិញ ធុយ ហើយនោះ ឲ្យទៅជួបជៀង កៃជៀក ប្រធានាធិបតីចិនជាតិនិយម និងឧត្ដមសេនីយ៍ម៉ា ហ្សាលដែលជាឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំប្រទេសចិន ដើម្បីទាក់ទងឲ្យរដ្ឋាភិបាលសាធារណរដ្ឋចិនជាតិនិយម និងសហរដ្ឋអាមេរិក ទទួលស្គាល់ និងគាំទ្ររបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ជាផ្លូវការ។

ជាមួយគ្នានោះដែរ ហូ ជីមិញ ក៏បានលួចបញ្ជូនគណៈប្រតិភូមួយក្រុមទៀតដែលមានសមាសភាពសុទ្ធតែពួកកុម្មុយនិស្ដនិយម ឲ្យទៅជួបម៉ៅ សេទុង មេដឹកនាំបដិវត្តន៍កុម្មុយនិស្ដចិន ដែលកំពុងស្ថិតនៅក្នុងខេត្តយូណាន ដើម្បីសុំការគាំទ្រផងដែរ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៤៦ កងទ័ពបារាំងរាប់ពាន់នាក់ ដែលស្ថិតនៅក្រោម



ឧត្តមសេនីយ៍ ឡឺក្លេក ទៅដល់ក្រុងហាណូយ ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៤៦

បញ្ជារបស់នាយឧត្តមសេនីយ៍ ឡឺក្លេក(Leclerc) បានធ្វើដំណើរទៅដល់ទីក្រុងហាណូយ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៦ តាមការទាមទាររបស់ហូ ជីមិញ ភាគីបារាំង បានយល់ព្រមជួបចរចាគ្នាជាមួយភាគីវៀតណាម នៅក្នុងបរិវេណវិទ្យាល័យយ៉េស៊ីន (Yersin) នៅក្រុងដាឡាត់។

ក្នុងពេលជួបចរចាគ្នានោះ មានឧត្តមសេនីយ៍ អាហ្សង់លីយើ (Argenlieu) ជាអធិបតី ហើយគណៈប្រតិភូវៀតមិញ មានសមាជិក១០នាក់ ដឹកនាំដោយ ង្វៀង ទុងតាំ ជាមេដឹកនាំចលានាអ្នកជាតិនិយមវៀតណាម។ ចំណែកគណៈប្រតិភូបារាំង មានសមាជិក ១១នាក់ ដឹកនាំដោយម៉ាក់ អង់ដ្រេ (Max Andre)។

ក្នុងជំនួបចរចាគ្នានោះ បញ្ហាសំខាន់គឺ ខាងភាគីវៀតមិញ នៅតែទាមទារឲ្យបារាំងបញ្ចូលទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) ឲ្យទៅជារបស់ខ្លួន។ តែភាគីបារាំង បានលើកឡើងថា បញ្ហាទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) នេះ មិនទាន់ចោទជាបញ្ហាអ្វីធ្ងន់ធ្ងរនៅឡើយ

ទេ ពេលនេះត្រូវយកបញ្ហាផ្សេងៗទៀតមកធ្វើការពិភាក្សាគ្នាវិញ ដូចជា បញ្ហាសហព័ន្ធឥណ្ឌូចិន, បញ្ហាកងទ័ពឥណ្ឌូចិន និងបញ្ហាឯករាជ្យវៀតណាម មកដោះស្រាយសិន។

ចំពោះបញ្ហាសហព័ន្ធឥណ្ឌូចិន បើទោះបីភាគីវៀតមិញ ទាមទារអំណាចខ្លះ ដើម្បីត្រួតត្រាក៏ដោយ ក៏ភាគីបារាំង នៅតែមានបំណងត្រួតត្រាឥណ្ឌូចិនទាំងមូល ដាច់តែម្នាក់ឯងដដែល។

ទីបំផុត លទ្ធផលក្នុងកិច្ចចរចានោះ បារាំង និងពួកវៀតមិញ បានសម្រេចបង្កើតសភាចម្រុះមួយសម្រាប់គ្រប់គ្រងឥណ្ឌូចិន។

សភាចម្រុះនោះ មានសមាជិកចំនួន៦០នាក់ ក្នុងនោះមានតំណាងសាធារណរដ្ឋបារាំង ចំនួន១០នាក់, តំណាងប្រទេសអណ្ណាម ចំនួន១០នាក់, តំណាងប្រទេសតុងកឹងចំនួន១០នាក់, តំណាងប្រទេសកម្ពុជា ចំនួន១០នាក់, តំណាងប្រទេសឡាវ ចំនួន១០នាក់ និងតំណាងប្រទេសកូសាំងស៊ីន (កម្ពុជាក្រោម) ចំនួន១០នាក់ដែរ តែ១០នាក់នេះសុទ្ធតែជាជនជាតិវៀតណាម។

ភារកិច្ចសំខាន់របស់សភានេះ គឺអនុម័តថវិកាសម្រាប់កសាងសហព័ន្ធឥណ្ឌូចិន។ ដោយសារក្នុងសហព័ន្ធឥណ្ឌូចិននោះ មានសមាជិកជាជនជាតិវៀតណាម រហូតដល់ ៣០នាក់ទៅហើយនោះ ពោលគឺមកពីតុងកឹង ១០នាក់, មកពីអណ្ណាម ១០នាក់ និងមកពីកូសាំងស៊ីន (កម្ពុជាក្រោម) ១០នាក់ ថវិការបស់សហព័ន្ធឥណ្ឌូចិន ដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានអនុម័តឲ្យយកទៅកសាងសមិទ្ធផលដ៏ស្កឹមស្កៃជាច្រើន តែនៅលើទឹកដីវៀតណាមប៉ុណ្ណោះ ។ ចំណែកប្រទេសខ្មែរ និងឡាវ ទទួលបានថវិកានោះតិចតួចបំផុត។

ក្រោយពេលកងទ័ពបារាំងចូលទៅបោះទីតាំងនៅតុងកឹងវិញ បារាំង ក៏បានបង្កើតការិយាល័យគយ របស់ខ្លួនមួយដែរ នៅកំពង់ផែហៃហ្វុង ដើម្បីយកពន្ធលើមុខទំនិញដែលឆ្លងកាត់កំពង់ផែនោះ បង្កឲ្យមានការឈ្លោះប្រកែកគ្នារវាងអ្នកជំនួញវៀតណាម ជាមួយនឹងមន្ត្រីគយបារាំង នៅកំពង់ផែនោះ និងជម្លោះរវាងអ្នកជំនួញបារាំង ជាមួយប៉ូលិសវៀតណាមជាញឹកញាប់ រហូតដល់មានការត្រៀមកងទ័ពវាយប្រយុទ្ធគ្នាទៀតផង ហើយដោយកងឈ្លប

វៀតមិញ បានលួចធ្វើឃាតជនជាតិស៊ីវិលបារាំង និងទាហានបារាំង ជាញឹកញាប់ផងនោះ ធ្វើឲ្យសភាពការណ៍កាន់តែតានតឹងឡើងៗ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៤៦ ហូ ជីមិញ បានផ្ញើលិខិតតវ៉ាជាផ្លូវការមួយច្បាប់ ទៅរដ្ឋាភិបាលបារាំង នៅក្រុងប៉ារីស ដោយបានលើកឡើងថា ការបង្កើតការិយាល័យគយរបស់បារាំង នៅកំពង់ផែហៃហ្វុងនោះ គឺជាការរំលោភបំពានមួយយ៉ាងធ្ងន់ធ្ងរបំផុត ទៅលើកិច្ចព្រមព្រៀងទាំងឡាយ ដែលបារាំង និងវៀតមិញ បានចុះហត្ថលេខាជាមួយគ្នាពីមុនមក។

តែរដ្ឋាភិបាលបារាំង នៅតែមិនអើពើចំពោះការតវ៉ារបស់ហូ ជីមិញ ពីបញ្ហានេះ ខណៈដែលកងទ័ពវៀតមិញ ក៏ចាប់ផ្តើមធ្វើសកម្មភាពបាញ់សម្លាប់ជនស៊ីវិល និងកងទ័ពបារាំង កាន់តែសាហាវខ្លាំងក្លាថែមទៀត រហូតដល់បារាំង បញ្ជូនរថក្រោះ និងរថពាសដែកទៅបង្ក្រាបវិញ។

តែកងទ័ពវៀតមិញ ក៏នាំគ្នាកាប់រំលំដើមឈើដាក់កាត់ទទឹងផ្លូវសំខាន់ៗ ដើម្បីបង្កការលំបាកដល់រថក្រោះ និងរថពាសដែករបស់បារាំង ទាំងនោះ ដើម្បីកុំឲ្យបើកបរទៅមុខបានដោយងាយស្រួលដែរ។ ក្រោយពីមានការវាយប្រយុទ្ធគ្នាធំៗចំនួនបីលើករួចមក បារាំង និងពួកវៀតមិញ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយទៀត ហៅថា កិច្ចព្រមព្រៀងអេកែល ណាំ (Herkel Nam) មាន៣ចំណុចគឺ៖

ទី១. កងទ័ពបារាំង និងកងទ័ពវៀតមិញ មិនត្រូវវាយប្រយុទ្ធគ្នាទៀតទេ បើទោះបីក្នុងករណីបែបណាក៏ដោយ។

ទី២.បារាំង ត្រូវដកថយកងរថក្រោះ និងកងរថពាសដែកចូលបន្ទាយវិញ។

ទី៣. ការធ្វើចរាចរណ៍នៅពេលយប់ ត្រូវកាត់បន្ថយឲ្យនៅតិចបំផុត។

ប៉ុន្តែដោយសារភាគីវៀតមិញ មិនបានគោរពកិច្ចព្រមព្រៀងឈប់បាញ់គ្នានោះឲ្យបានត្រឹមត្រូវ ពោលគឺពួកគេនៅតែបន្តធ្វើសកម្មភាពលបបាញ់សម្លាប់ទៅលើជនស៊ីវិល និងទាហានបារាំងទៀតនោះ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៤៦ ឧត្តមសេនីយ៍ វ៉ាល្លី (Vally) ស្នងការបារាំង ប្រចាំនៅក្រុងហាណូយ បានបញ្ជាឲ្យដកកងទ័ពវៀតមិញ ដែលបោះទីតាំង



**ឧត្តមសេនីយ៍ ឡឺក្លេក , ហូ ជីមិញ និង ហ្សង់ សាំងតឺនី**

នៅក្នុងសង្កាត់ចិន ឲ្យចេញពីក្រុងហៃហ្វុង ឲ្យអស់ក្នុងរយៈពេលតែ២ទៅ៣ម៉ោងប៉ុណ្ណោះ។

តែពួកវៀតមិញ មិនព្រមធ្វើតាមបញ្ជានេះ កងទ័ពបារាំង ក៏ចាប់ផ្ដើមបើកការវាយ-ប្រហារ ដោយមានកងកាំភ្លើងធំ និងកងទ័ពជើងទឹកចូលរួមផង ធ្វើឲ្យកងទ័ព និងប្រជាជនវៀតណាមនៅទីនោះ ស្លាប់អស់រាប់ពាន់នាក់។

បន្ទាប់មក កងទ័ពវៀតមិញ បានប្រមូលគ្នាធ្វើការវាយបកទៅលើកងទ័ពបារាំង ឲ្យដកថយចេញពីក្រុងហៃហ្វុង អស់វិញ នៅថ្ងៃទី២៥ ខែវិច្ឆិកា។

លុះបីថ្ងៃក្រោយមក គឺនៅថ្ងៃទី២៥ ខែវិច្ឆិកា កងទ័ពបារាំងក៏វាយដណ្ដើមកាន់កាប់ទីក្រុងហៃហ្វុង បានទាំងស្រុងមកវិញ។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៤៦ រដ្ឋាភិបាលបារាំង បានផ្លាស់ប្ដូរស្នងការថ្មីម្នាក់ទៀត ឈ្មោះហ្សង់ សាំងតឺនី (Jean Sainteny) ឲ្យមកគ្រប់គ្រងដឹកនាំនៅទីក្រុងហាណូយ ជំនួសឧត្តមសេនីយ៍ វ៉ាល្លី (Vally) ។

ស្នងការបារាំងថ្មីនេះ បានចូលជួបពិភាក្សាគ្នាជាមួយហូ ជីមិញ ដើម្បីបន្ធូរបន្ថយសភាពការណ៍ដែលកំពុងតានតឹងនោះដែរ តែការជួបពិភាក្សាគ្នានោះ មិនមានការចុះសម្រុង

គ្នាអ្វីបន្តិចទាល់តែសោះ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៤៦ កងទ័ពវៀតមិញ បានស្ទាក់បាញ់ប្រហារទៅលើរថយន្តកងទ័ពបារាំងមួយគ្រឿង ដែលកំពុងបើកចេញពីបន្ទាយទៅផ្សារ ដើម្បីទិញស្បៀងអាហារយកមកផ្គត់ផ្គង់កងទ័ពរបស់ខ្លួន បណ្តាលឲ្យអ្នកបើកបរ និងទាហានបារាំង២នាក់ទៀតនៅលើរថយន្តនោះត្រូវស្លាប់។

ភ្លាមនោះដែរ ស្នងការបារាំង ហ្សង់ សាំងតូនី (Jean Sainteny) ក៏បញ្ជាឲ្យកងទ័ពរបស់ខ្លួនចេញទៅកម្ទេចកងទ័ពវៀតមិញវិញ បណ្តាលឲ្យស្លាប់១៥នាក់ និងផ្ទះជាច្រើនខ្នងនៅតំបន់វាយប្រយុទ្ធគ្នានោះត្រូវភ្លើងឆាបឆេះផងដែរ។

ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី១៩ ខែធ្នូ ឧត្តមសេនីយ៍ វូ ង្វៀងយ៉ាប់ បានដាក់ពង្រាយកងទ័ពវៀតមិញ ប្រមាណ៣ម៉ឺននាក់ ព័ទ្ធជុំវិញជាយទីក្រុងហាណូយ ។

នៅវេលាម៉ោង៨ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៦ ភ្លើងអគ្គិសនីនៅក្នុងក្រុងហាណូយទាំងមូល ត្រូវបានកងទ័ពវៀតមិញ លួចកាត់ផ្តាច់ បណ្តាលឲ្យងងឹតសូន្យឈឹង ហើយស្នូរកាំភ្លើងគ្រប់ធុន ក៏បានចាប់ផ្តើមផ្ទុះឡើងគ្រប់មុខព្រួញ ។

នៅក្នុងសង្កាត់មួយ ដែលមានផ្ទះជនជាតិបារាំង រស់នៅច្រើនជាងគេ ត្រូវកងទ័ពវៀតមិញ ចូលទៅចាប់ខ្លួន និងបាញ់សម្លាប់ម្ចាស់ផ្ទះចោលឆៅៗតែម្តង។ ពេលនោះ ក្រុងហាណូយទាំងមូលត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃកងទ័ពវៀតមិញ ទាំងស្រុង។

លទ្ធផលនៃការប្រយុទ្ធគ្នានេះ គឺជាជនស៊ីវិល និងទាហានបារាំង ប្រមាណ៤០នាក់ត្រូវស្លាប់ និង២០០នាក់ទៀតត្រូវចាប់ខ្លួន។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៤៦ ម៉ារីយ៉ូស មូតេត (Marius moutet ) រដ្ឋមន្ត្រីទទួលបន្ទុកប្រទេសអាណានិគមនៅឯនាយសមុទ្រ បានធ្វើដំណើរពីប្រទេសបារាំង មកទីក្រុងព្រៃនគរ ក្នុងបំណងមកដោះស្រាយបញ្ចប់ការវាយប្រយុទ្ធគ្នារវាងកងទ័ពបារាំង និងកងទ័ពវៀតមិញ នៅទីក្រុងហាណូយនោះ។ បន្ទាប់មក ឧត្តមសេនីយ៍ ឡឺគ្លេក អតីតស្នងការបារាំង ប្រចាំឥណ្ឌូចិន និងឧត្តមសេនីយ៍ អាហ្សង់លីយើ (Argenlieu) ជាស្នងការ

ជាន់ខ្ពស់ និងជាអគ្គមេបញ្ជាការកងទ័ពបារាំង ប្រចាំឥណ្ឌូចិន បានធ្វើដំណើរពីទីក្រុងព្រៃនគរ ទៅដល់ទីក្រុងហាណូយ ដើម្បីរង់ចាំរដ្ឋមន្ត្រីម៉ារីយ៉ូស មូតេត ( Marius moutet ) នៅទីនោះមុន ។

ចំណែករដ្ឋមន្ត្រី ម៉ារីយ៉ូស មូតេត ( Marius moutet ) មិនទាន់ធ្វើដំណើរទៅទីក្រុងហាណូយ ភ្លាមៗទេ ដោយលោកឆ្លៀតឱកាសទៅបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ, ខេត្តបាត់ដំបង, ខេត្តសៀមរាប និងទីក្រុងវៀងច័ន្ទ ប្រទេសឡាវ សិន។

តែទោះបីយ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៤៦ វិទ្យុរបស់ពួកវៀតមិញបានផ្សាយថា ហូ ជីមិញ បានផ្ញើលិខិតមួយទៅនាយករដ្ឋមន្ត្រីបារាំង ឡេអុង ប្លុម ( Leon Blum ) ដោយបានសម្ដែងនូវការមិនសប្បាយចិត្តរបស់គាត់ ចំពោះការអញ្ជើញមកដល់ឥណ្ឌូចិន របស់រដ្ឋមន្ត្រីទទួលបន្ទុកប្រទេសអាណានិគមនៅឯនាយសមុទ្រ ម៉ារីយ៉ូស មូតេត ( Marius moutet ) ហើយគាត់បានស្នើសុំឲ្យកងទ័ពបារាំង ដែលកំពុងឈរជើងនៅទីក្រុងហាណូយ ដកថយមកនៅទីតាំងចាស់ដូចមុនថ្ងៃ១៧ ខែធ្នូ នោះវិញ និងសុំឲ្យមានការឈប់បាញ់គ្នា។

នៅថ្ងៃទី១ ខែមេសា ១៩៤៧ វិទ្យុរបស់ពួកវៀតមិញ បានផ្សាយថា ហូ ជីមិញ បានផ្ញើលិខិតមួយទៀត ទៅជូននាយករដ្ឋមន្ត្រី ឡេអុង ប្លុម ( Leon Blum ) ស្នើសុំបញ្ចប់ការវាយប្រយុទ្ធគ្នាជាបន្ទាន់ និងសុំឲ្យកងទ័ពបារាំង ដកថយទៅនៅទីតាំងដែលបានព្រមព្រៀងគ្នា តាមកិច្ចព្រមព្រៀងក្រុងដាឡាត់ ព្រមទាំងដោះលែងឈ្លើយសឹកទាំងអស់ ហើយសុំឲ្យបញ្ឈប់ការបញ្ជូនកងទ័ពជំនួយរបស់បារាំង មកថែមទៀតជាបន្ទាន់។ ពិសេស ហូ ជីមិញ បានស្នើសុំឲ្យមានការជួបចរចាជាមួយរដ្ឋមន្ត្រី ម៉ារីយ៉ូស មូតេត ( Marius moutet ) ដើម្បីដោះស្រាយគ្នាដោយសន្តិវិធី ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងនៅទីក្រុងហាណូយ ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៤៦។

តែរដ្ឋមន្ត្រីទទួលបន្ទុកប្រទេសអាណានិគមនៅឯនាយសមុទ្ររបស់បារាំង រូបនេះបានវាយតម្លៃថា អ្វីដែលហូ ជីមិញ បានលើកឡើងនេះ មិនអាចយកជាការបានទេ ព្រោះវា

# របត់នយោបាយ

គ្រាន់តែជាការលើកឡើង ដើម្បីបំភាន់ភ្នែកសាធារណមតិអន្តរជាតិតែប៉ុណ្ណោះ ហើយលោកជឿជាក់ថា ហូ ជីមិញ មេដឹកនាំវៀតមិញ មិនដែលមានចេតនាក្នុងការរកដំណោះស្រាយពិតប្រាកដនោះឡើយ។

នៅទីបំផុត រដ្ឋមន្ត្រី ម៉ារីយ៉ូស មូតេត (Marius moutet ) បានបង្ខំចិត្តចាកចេញពីក្រុងហាណូយ មកសម្រាកនៅទីក្រុងព្រៃនគរ មួយរយៈខ្លី រួចធ្វើដំណើរត្រឡប់ទៅប្រទេសបារាំង វិញ ដោយគ្មានបានទទួលលទ្ធផលអ្វីបន្តិចឡើយ។

ក្រោយពីការស្វែងរកការចរចាជាមួយបារាំង ត្រូវបរាជ័យមក ហូ ជីមិញ មេដឹកនាំវៀតមិញ គ្មានជម្រើសអ្វីក្រៅពីការប្រយុទ្ធតស៊ូជាមួយបារាំង បន្តទៀតនោះឡើយ ។

ពួកវៀតមិញ បានចាប់ផ្តើមដាក់ពង្រាយកងទ័ពខ្លួននៅតុងកឹង, អណ្ណាម, ឡាវ, កម្ពុជា និងកូសាំងស៊ីន ហើយចាប់ផ្តើមធ្វើការវាយប្រហារទៅលើទីតាំងកងទ័ពបារាំងទាំងឡាយដែលនៅតំបន់តុងកឹងទាំងមូល ពិសេសកាត់ផ្តាច់ផ្លូវសំខាន់ៗដែលជាច្រកចេញចូលទៅក្រុងហាណូយ ។

ឧត្តមនាវី អាហ្សង់លីយើ (Argen-lieu) អគ្គស្នងការកងទ័ពបារាំងនៅឥណ្ឌូចិន យល់ថា ពួកវៀតមិញ គ្មានអ្វីក្រៅពីយកមេដឹកនាំសហភាពសូវៀត ធ្វើជាខ្នងបង្អែក ដើម្បីដឹកនាំប្រទេសវៀតណាម ឲ្យក្លាយទៅជាកុម្មុយនិស្តនោះឡើយ ហើយបារាំង ត្រូវតែទប់ស្កាត់។



**ឧត្តមនាវី អាហ្សង់លីយើ**
(រូបថត getty images)

ដើម្បីទប់ស្កាត់ប្រទេសវៀតណាម មិនឲ្យក្លាយទៅជាកុម្មុយនិស្ត បារាំង បង្វែរទៅរកការចរចាជាមួយមេដឹកនាំអ្នកជាតិនិយម (វៀតណាមសេរី) វិញម្តង។

ឧត្តមនាវី អាហ្សង់លីយើ (Argenlieu) បានអញ្ជើញឧត្តមសេនីយ៍ ង៉ូ ឌិនយៀម, ង្វៀង ម៉ាន់ហា និងហាង សាន ជាមេដឹកនាំពួកវៀតណាមសេរី នៅទីក្រុងព្រៃនគរ ឲ្យមកជួបពិភាក្សាគ្នាបង្កើតរដ្ឋាភិបាលថ្មីមួយ ដើម្បីទប់ទល់ជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមវិញ។

ប៉ុន្តែមេដឹកនាំអ្នកជាតិនិយម (វៀតណាមសេរី) ទាំងបីនាក់នេះ មិនហ៊ានបង្កើតរដ្ឋាភិបាលថ្មីមួយតាមការផ្តួចផ្តើមរបស់បារាំង នេះទេ ព្រោះពេលនោះ ពួកគេមិនសូវទុកចិត្តលើកម្លាំងកងទ័ពបារាំងប៉ុន្មានទេ ហើយឃើញកម្លាំងកងទ័ពវៀតមិញ កំពុងធ្វើសកម្មភាពយ៉ាងខ្លាំងក្លានៅពាសពេញឥណ្ឌូចិនទាំងមូល ពិសេសសូម្បីចលនាតស៊ូវៀតណាមមួយចំនួនដែលធ្លាប់ប្រឆាំងនឹងពួកវៀតមិញ ពីមុនមកនោះ ក៏សុខចិត្តចុះចាញ់ និងចូលរួមជាមួយពួកវៀតមិញដែរ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៤៧ នាយករដ្ឋមន្ត្រីបារាំងថ្មី រ៉ាម៉ាឌីយេ (Ramadier) ដែលទើបនឹងឡើងជំនួសរដ្ឋាភិបាលបណ្តោះអាសន្នរបស់ឡេអុង ប្លុម (Leon Blum) បានបញ្ជាឲ្យឧត្តមនាវី អាហ្សង់លីយើ (Argenlieu) ដែលជាស្នងការជាន់ខ្ពស់ និងជាអគ្គស្នងការកងទ័ពបារាំងនៅឥណ្ឌូចិន រិះរកមធ្យោបាយយ៉ាងណា ដើម្បីចរចាជាមួយមេដឹកនាំវៀតណាមផ្សេងៗទៀតដែលមិនមែនជាពួកកុម្មុយនិស្ត ដែលបារាំង ចាត់ទុកថា ជាមនុស្សមានពុតត្បុតអាក្រក់ ហើយមិនមែនជាតំណាងប្រទេសវៀតណាមពិតប្រាកដនោះផងដែរ។

តែនៅពេលឧត្តមនាវី អាហ្សង់លីយើ (Argenlieu) មិនទាន់បានអនុវត្តតាមបញ្ជារបស់នាយករដ្ឋមន្ត្រីថ្មីរបស់បារាំង នោះផង ពួកមេដឹកនាំវៀតមិញ បានបញ្ជាឲ្យកងទ័ពរបស់ខ្លួនធ្វើការវាយប្រហារទៅលើកងទ័ពបារាំង គ្រប់ទិសទី នៅពាសពេញឥណ្ឌូចិនទាំងមូល ជាហេតុធ្វើឲ្យឧត្តមនាវី អាហ្សង់លីយើ (Argenlieu) មិនអាចស្វែងរកការចរចាជាមួយពួកមេដឹកនាំវៀតណាមមិនមែនកុម្មុយនិស្តតាមបញ្ជានោះបាន។

ឧត្តមនាវី អាហ្សង់លីយើ (Argenlieu) ក៏ត្រូវបានរដ្ឋាភិបាលបារាំង ដកចេញពីតំណែងស្នងការជាន់ខ្ពស់ និងជាមេបញ្ជាការកងទ័ពបារាំងនៅឥណ្ឌូចិន ហើយបានប្រគល់

តំណែងនេះទៅឲ្យឧត្តមសេនីយ៍ឡឺគ្លេក (Leclerc) ដែលធ្លាប់កាន់តំណែងនេះ កាលពីខែតុលា ឆ្នាំ១៩៤៥ វិញ។ តែពេលនោះ គាត់កាន់តំណែងនេះបានតែរយៈពេល២៦ថ្ងៃប៉ុណ្ណោះ គឺពីថ្ងៃទី៥ ខែតុលា ដល់ថ្ងៃទី៣១ ខែតុលា។

ឧត្តមសេនីយ៍ឡឺគ្លេក (Leclerc) បានដាក់លក្ខខណ្ឌជាមុនថា បើឱ្យលោកទៅទទួលតំណែងនោះវិញ ទាល់តែប្រគល់សិទ្ធិឲ្យលោកដោះស្រាយបញ្ហាឥណ្ឌូចិន ទៅតាមឧត្តមគតិរបស់លោកផ្ទាល់។

តែរដ្ឋាភិបាលបារាំង មិនយល់ព្រមប្រគល់សិទ្ធិឲ្យឡឺគ្លេក (Leclerc) ដោះស្រាយបញ្ហាឥណ្ឌូចិននោះ ស្រេចតែចិត្តរបស់លោកនោះបានទេ។

ដូច្នេះតំណែងស្នងការជាន់ខ្ពស់របស់បារាំង ប្រចាំឥណ្ឌូចិននេះ ត្រូវបានរដ្ឋាភិបាលបារាំង ប្រគល់ទៅឲ្យអ៊ីមីល បូល្លាអេត (Emile Bollaert) ដែលពីមុនមក លោកមិនដែលស្គាល់ឥណ្ឌូចិន នេះម្តងណាសោះ ហើយក៏មិនដែលមានបទពិសោធន៍អ្វីពីកិច្ចការនយោ-បាយនៅអាស៊ីនោះដែរ។

តែទោះបីយ៉ាងណា អ៊ីមីល បូល្លាអេត (Emile Bollaert) ជាអ្នកជំនាញខាងកិច្ចការរដ្ឋបាលម្នាក់ ហើយលោកក៏បានយកអតីតលេខាធិការគណៈកម្មការអន្តរក្រសួងនៅឥណ្ឌូចិនម្នាក់ ឈ្មោះព្យែរ ម៉េសស្មេ (Pierre Messmer) ឲ្យធ្វើជានាយកខុទ្ទកាល័យរបស់លោក និងយកប៉ូល មុស (Paul Mus) អតីតនាយកសាលាជាតិបារាំងនៅឯនាយសមុទ្រ និងជាអតីតទីប្រឹក្សានយោបាយជាន់ខ្ពស់របស់ឧត្តមសេនីយ៍ឡឺគ្លេក (Leclerc) ស្នងការជាន់ខ្ពស់ និងជាមេបញ្ជាការកងទ័ពបារាំងនៅឥណ្ឌូចិន ពីមុន មកធ្វើជាទីប្រឹក្សាផ្ទាល់របស់លោកផងដែរ។

លុះដល់ដើមឆ្នាំ១៩៤៨ ដោយសារមិនអាចរកវិធីដោះស្រាយបញ្ហាវៀតណាមបាន បូល្លាអេត ក៏បានសម្រេចចិត្តលាឈប់ពីតំណែងស្នងការជាន់ខ្ពស់បារាំង ប្រចាំឥណ្ឌូចិននោះវិញ ហើយឡេអុង ពីញ៉ុង (Leon Pignong) ជាអតីតទីប្រឹក្សារបស់ឧត្តមសេនីយ៍អាហ្សង់លីយើ (Argenlieu) និងជាទេសាភិបាលជាន់ខ្ពស់ប្រចាំប្រទេសកម្ពុជា ត្រូវបាន





**អគ្គស្នងការបារាំង ឡេអុង ពីញ៉ុង និង ហូ ជីមិញ**

តែងតាំងជាស្នងការជាន់ខ្ពស់បារាំង ប្រចាំឥណ្ឌូចិន បន្តទៀត។

ឡេអុង ពីញ៉ុង (Leon Pignong) នេះហើយ ដែលបានអមព្រះរាជដំណើរព្រះមហាក្សត្រនរោត្តម សីហនុ ក្នុងនាមជាទេសាភិបាលជាន់ខ្ពស់ប្រចាំប្រទេសកម្ពុជា ទៅទីក្រុងប៉ារីស នៅក្នុងឆ្នាំ១៩៤៧ និងជាអ្នកស្តីបន្ទោសឱ្យពួកនិស្សិតឆ្វេងនិយម ជួន ម៉ុម, ជួន ជឿន, និងអៀ ស៊ីចូវ ដែលបាននាំគ្នាមកចោទប្រកាន់ព្រះអង្គថា បានប្រព្រឹត្តអំពើស្នេហាផ្តេសផ្តាសជាមួយស្រីមេម៉ាយកូនមួយបារាំងម្នាក់ តាមការចុះផ្សាយរបស់កាសែតហ្វ្រង់ស្វ័រ ដែលមានចំណងជើងថា ព្រះមហាក្សត្រខ្មែរនឹងរៀបការជាមួយនារីគង្វាលចៀមបារាំង ម្នាក់នោះ។

ក្រោយពីឡើងកាន់តំណែងជាស្នងការជាន់ខ្ពស់បារាំងប្រចាំឥណ្ឌូចិនមក ឡេអុង ពីញ៉ុង (Leon Pignong) ក៏បានឲ្យយន្តហោះម៉ាស៊ីន២ ម៉ាកដាកូតាដ ១គ្រឿង មកដឹកព្រះមហាក្សត្រសីហនុ និងរាជវង្សមួយចំនួន ដើម្បីយាងទៅប្រទេសបារាំង ក្នុងឆ្នាំ១៩៤៩ នោះដែរ។

តែ ឡេអុង ពីញ៉ុង (Leon Pignong) នេះ នៅតែបន្តការគាំទ្រព្រះចៅបៅ ដាយ និងពួកអ្នកជាតិនិយម (វៀតណាមសេរី) ព្រមទាំងពួកវៀតមិញផងដែរ ស្របពេលដែល

# របត់នយោបាយ

មតិអន្តរជាតិភាគច្រើន ពិសេសសហរដ្ឋអាមេរិក អង់គ្លេស នៅតែយល់ថា ការតស៊ូធ្វើសង្គ្រាមរបស់ពួកវៀតមិញនេះ គឺដើម្បីរំដោះជាតិរបស់ខ្លួនចេញពីពួកអាណានិគមបារាំង តែប៉ុណ្ណោះ គឺពុំមែនធ្វើសង្គ្រាមដើម្បីពង្រីកទឹកដី ឬដើម្បីលទ្ធិកុម្មុយនិស្តនោះទេ។

នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៤៨ ព្រះមហាក្សត្រនរោត្តម សីហនុ បានផ្ញើព្រះរាជសារមួយជូន ឡេអុង ពីញ៉ុង (Leon Pignong) ស្នងការជាន់ខ្ពស់បារាំងប្រចាំឥណ្ឌូចិន។

ព្រះរាជសារនោះមានខ្លឹមសារថាៈ

លោកស្នងការជាន់ខ្ពស់! ខ្ញុំមានកិត្តិយសផ្ញើជូនលោកនូវព្រះរាជសារនេះ ដើម្បីសម្តែងពីបំណងដែលស្ថិតនៅក្នុងហឫទ័យរបស់ខ្ញុំជានិច្ច ហើយស្នើសុំលោកជួយបំពេញបំណងនេះឲ្យបានសម្រេចផង។ ខ្ញុំជឿថា ខ្ញុំមានការខ្វះខាតចំពោះករណីយកិច្ចរបស់ខ្ញុំក្នុងការការពារទឹកដីដែលខ្ញុំត្រូវធ្វើចំពោះប្រជារាស្ត្រខ្ញុំ។

ប្រសិនបើខ្ញុំមិនអាចការពារទឹកដីពីការរំលោភបំពានពីសំណាក់រដ្ឋជិតខាង ជាពិសេសបាត់បង់ទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) វាអាចនឹងមានផលអាក្រក់ មិនអាចចៀសវាងបានទៅលើវាសនាអនាគតរបស់ប្រជារាស្ត្រខ្មែរទាំងអស់ ដែលបានរស់នៅទីនោះតាំងពីដើមមក។

ព្រះរាជសារបានបន្តថា ដោយដឹងថា រហូតមកដល់សព្វថ្ងៃនេះ តើអ្វីទៅជាផលលំបាកនៃនយោបាយដែលនឹងកើតមាននៅក្នុងប្រទេសជិតខាងនេះ ចាប់ពីពេលនេះទៅខ្ញុំយល់ឃើញថា ខ្ញុំត្រូវតែធ្វើលក្ខខណ្ឌស្តីពីការវិវត្តនយោបាយនៅតាមបណ្តាខេត្តទាំងឡាយនៅកូសាំងស៊ីន ដែលមានប្រជាជនខ្មែរដ៏ច្រើនលើសលប់នោះ ឬយ៉ាងហោចណាស់ក៏មានបំណងចង់ដឹងនូវអ្វីៗដែលនឹងត្រូវមកដល់នោះដែរ។

ប្រជារាស្ត្រខ្មែរនៅកូសាំងស៊ីន បានរួបរួមគ្នាការពារផលប្រយោជន៍របស់ខ្លួននៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាលកូសាំងស៊ីន ។ ពួកគេបានបំពេញនូវភាពត្រឹមត្រូវតាមច្បាប់ ទៅនឹងបំណងប្រាថ្នារបស់ពួកគេ ។ ចំពោះរឿងនេះ ខ្ញុំធ្លាប់គិតថា មិនត្រូវធ្វើអន្តរាគមន៍ក្នុងរឿងនេះទេ គឺទុកឲ្យប្រទេសបារាំង បន្តតួនាទីរបស់ខ្លួនជាអ្នកអាណាព្យាបាលចុះ ហើយ

កាលនោះ គេមានជំនឿថា បើសិនជាខ្ញុំធ្វើអន្តរាគមន៍ នឹងធ្វើឲ្យជម្លោះនេះកាន់តែរីកធំថែមទៀត។ ប៉ុន្តែមិនមានន័យថា ខ្ញុំបោះបង់ចោលបញ្ហានេះទេ។

ព្រះរាជសារដដែលបានបន្តទៀតថា នៅក្នុងព្រឹត្តិការណ៍ប្រកបដោយសោកនាដកម្ម នៅក្នុងអំឡុងខែមីនា ឆ្នាំ១៩៤៥ ហើយប្រទេសបារាំង លែងមានសិទ្ធិត្រួតត្រាកម្ពុជា មួយរយៈនោះ ខ្ញុំបានប្រកាសថា សូមឲ្យប្រទេសបារាំង ជាមិត្តបញ្ឈប់ការត្រួតត្រាទាំងស្រុង និងផ្តល់សិទ្ធិដ៏ពិសិដ្ឋដល់ព្រះរាជាណាចក្រកម្ពុជា និងប្រជារាស្ត្រខ្មែរ នូវបណ្តាខេត្តទាំងឡាយនៅកូសាំងស៊ីន ផងដែរ។

ព្រះរាជសារបានបន្តទៀតថា យោងតាមច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី ពិសេសក្នុងមាត្រា១ នៃសេចក្តីប្រកាស ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៣៤ ស្តីពីសញ្ជាតិខ្មែរនោះ ព្រះមហាក្សត្រមុនៗ ដែលជាទីគោរពរបស់ខ្ញុំ បានសម្តែងនូវសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះប្រទេសបារាំង និងជឿជាក់ថា ប្រជាជាតិដ៏ធំមួយនេះ នឹងមិនរំលោភបំពាននូវបុព្វសិទ្ធិណាមួយរបស់កម្ពុជាឡើយ ។

ខ្ញុំបានដឹងថា បើប្រជារាស្ត្ររបស់ខ្ញុំស្ថិតនៅដាច់ចេញពីទឹកដីកំណើត ( កូសាំងស៊ីន ) នោះ ក៏ពួកគេមិនសប្បាយចិត្តក្នុងការរស់នៅក្រោមអាណាព្យាបាល និងក្រោមការឧបត្ថម្ភគាំទ្ររបស់បារាំង ដែរ។

នៅទីបញ្ចប់នេះ ខ្ញុំសូមលោកស្នងការជាន់ខ្ពស់នៃសាធារណរដ្ឋបារាំង ជាទីគោរពមេត្តាពិនិត្យពិចារណាចំពោះខ្លឹមសារលិខិតនេះ ដែលមិនមែនជាការអំពាវនាវដោយឥតន័យនោះទេ ប៉ុន្តែគឺក្នុងបំណងដ៏ក្លៀវក្លា និងស្រួចស្រាវបំផុត ដើម្បីការពារផលប្រយោជន៍នៃប្រជារាស្ត្រខ្ញុំ ទាំងនៅកម្ពុជា និងទាំងនៅកូសាំងស៊ីន។

ទោះបីមានការតវ៉ារបស់ព្រះមហាក្សត្រនរោត្តម សីហនុ ដូចក្នុងព្រះរាជសារខាងលើនេះយ៉ាងណាក៏ដោយ ក៏បារាំង នៅតែធ្វើមិនដឹង មិនឮដដែល។

បន្ទាប់មក ព្រះមហាក្សត្រនរោត្តម សីហនុ បានបញ្ជូនគណៈប្រតិភូខ្មែរមួយក្រុមរួមមាន៖ ព្រះអង្គម្ចាស់ក្សត្រីនរោត្តម ប៉េងប៉ោះយុគន្ធរ, ឈាន វ៉ម, សុខ ធុង និងថុន អ៊ុក

បានចូលរួមប្រជុំនៅក្នុងសភាសហភាពបារាំង ដើម្បីសុំឲ្យមានការចរចារវាងរដ្ឋាភិបាលបារាំងជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្តីអំពីការផ្ទេរអំណាចនៅកម្ពុជាក្រោម។

នៅអង្គប្រជុំនោះ សុខ ធុង បានធ្វើបាយការណ៍យ៉ាងពិស្តារ ស្តីពីប្រវត្តិទឹកដីកម្ពុជាក្រោមនេះ និងបានតវ៉ាថា៖ យើងទាមទារអ្វីៗដែលជារបស់យើងប៉ុណ្ណោះ គឺយើងមិនបានទាមទារអ្វីៗដែលមិនមែនជារបស់យើងនោះទេ។

ស្រាប់តែនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៤៩ ដើម្បីលួងចិត្តព្រះចៅបៅ ដាយ ឲ្យវិលមកកាន់អំណាចដើម្បីដឹកនាំការប្រឆាំងនឹងពួកកុម្មុយនិស្តហូ ជីមិញ ប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល ( Vincent Auriol ) បានធ្វើលិខិតមួយទៅព្រះចៅបៅ ដាយ បញ្ជាក់ពីការព្រមព្រៀងឲ្យវៀតណាម ក្លាយទៅជាប្រទេសឯករាជ្យមួយ ដោយរួមបញ្ចូលតំបន់ទាំង៣ គឺតុងកឹង អណ្ណាម និងកូសាំងស៊ីន។

នៅដើមខែមេសា ឆ្នាំ១៩៤៩ រាជរដ្ឋាភិបាលខ្មែរ ដែលមានយ៉ែម សំបូរ ជានាយករដ្ឋមន្ត្រី ព្រួយបារម្ភចំពោះរឿងនេះ ក៏ចាត់គណៈប្រតិភូមួយក្រុម ដឹកនាំដោយអតីតនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ ឈាន វ៉ម ទៅចរចាជាមួយរដ្ឋាភិបាលបារាំង ដើម្បីសុំផ្អាកការបញ្ចូលទឹកដីកូសាំងស៊ីននេះទៅឲ្យព្រះចៅ បៅ ដាយ សិន ហើយសុំឲ្យបារាំងចេញច្បាប់រក្សាទុកដងទន្លេមេគង្គជាដែនទឹកអន្តរជាតិ ដែលខ្មែរអាចចរាចរនាវាចេញចូលទៅសមុទ្របានដោយសេរី និងសុំឲ្យបារាំងប្រកាសទទួលស្គាល់ខ្មែរនៅកូសាំងស៊ីន ជាជនជាតិដើមម្ចាស់ស្រុកមានសិទ្ធិសេរីភាពក្នុងការថែរក្សាអត្តសញ្ញាណវប្បធម៌របស់ខ្លួនផងដែរ។

ពេលនោះ អគ្គទេសាភិបាលបារាំងនៅឥណ្ឌូចិន បានធ្វើដំណើរមកភ្នំពេញ ជួបព្រះមហាក្សត្រនរោត្តម សីហនុ នៅភ្នំពេញ និយាយបញ្ចុះបញ្ចូលព្រះអង្គថា ពេលនេះ ព្រះអង្គត្រូវគិតពីរឿងឯករាជ្យនៅកម្ពុជាសិន ចំណែកការបញ្ចូលទឹកដីកូសាំងស៊ីននេះទៅឲ្យព្រះចៅបៅ ដាយ មិនទាន់សម្រេចជាផ្លូវការទេ គឺត្រូវប្រគល់ឲ្យសភាសហភាពឥណ្ឌូចិន ជាអ្នកសម្រេចជាចុងក្រោយទៀត។

ដោយយល់ឃើញថា បើប្រទេសជាតិមិនទាន់ទទួលបានឯករាជ្យពីបារាំង ទេ ការ

ទាមទារទឹកដីកូសាំងស៊ីនមកវិញ ក៏មិនអាចទៅរួចដែរ ព្រះមហាក្សត្រសីហនុ ក៏យល់ព្រម តាមអគ្គទេសាភិបាលបារាំង។

ភ្លាមនោះ អគ្គទេសាភិបាលបារាំង បានផ្ញើសារទូរលេខមួយ ទៅឲ្យរដ្ឋាភិបាលខ្លួន នៅក្រុងប៉ារីស បានដឹងពីរឿងនេះ ធ្វើឲ្យការចរចារបស់គណៈប្រតិភូដឹកនាំដោយអតីត នាយករដ្ឋមន្ត្រី ឈាន វ៉ម ដែលពេលនោះ មានហ្សាល ដឺហ្គោល មេដឹកនាំគណបក្សប្រឆាំង កំពុងរង់ចាំជួយអន្តរាគមន៍ការតវ៉ានេះ ត្រូវចាត់ទុកជាមោឃៈ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៤៩ សភាចម្រុះនោះ មានសមាជិកចំនួន៦០នាក់ ក្នុងនោះមានតំណាងសាធារណរដ្ឋបារាំង ចំនួន១០នាក់, តំណាងប្រទេសអណ្ណាម ចំនួន ១០នាក់, តំណាងប្រទេសតុងកឹង ចំនួន១០នាក់ , តំណាងប្រទេសកម្ពុជា ចំនួន១០នាក់ , តំណាងប្រទេសឡាវ ចំនួន១០នាក់ និងតំណាងប្រទេសកូសាំងស៊ីន (កម្ពុជាក្រោម) ចំនួន១០នាក់ដែរ តែ១០នាក់នេះ សុទ្ធតែជាជនជាតិវៀតណាមនោះ បានប្រជុំបោះឆ្នោត សម្រេចជោគវាសនាកូសាំងស៊ីន ដោយសំឡេងភាគច្រើនលើសលប់ គាំទ្រប្រគល់ទឹកដី កូសាំងស៊ីន ឲ្យទៅវៀតណាម ដូចបារាំង បានសម្រេចពីមុនដែរ។

កាលដើមឡើយ ទឹកដីកម្ពុជាក្រោម បែកចេញជាខេត្តធំៗ ៤គឺៈ ១-ខេត្តដូនណៃ, ២-ខេត្តលង់ហោរ , ៣-ខេត្តមាត់ជ្រូក និង៤-ខេត្តពាម។

ក្រោយមក ខេត្តទាំងនោះ ត្រូវបានបែងចែកជាខេត្តតូចៗចំនួន ២១ខេត្តគឺៈ ១-ខេត្តព្រះត្រពាំង ២-ខេត្តឃ្លាំង, ៣-ខេត្តមាត់ជ្រូក, ៤-ខេត្តក្រមួនស, ៥-ខេត្តពលលាវ, ៦-ខេត្តទឹកខ្មៅ, ៧-ខេត្តពាម, ៨-ខេត្តព្រែកឫស្សី, ៩-ខេត្តលង់ហោរ, ១០-ខេត្តពាមបារ៉ាជ្ជ, ១១-ខេត្តរោងដំរី, ១២-ខេត្តព្រៃនគរ, ១៣-ខេត្តទួលតាមោក, ១៤-ខេត្តផ្សារដែក, ១៥-ខេត្តចង្វាត្រពាំង-ស្រកាត្រី, ១៦-ខេត្តមេស, ១៧-ខេត្តកោះគង, ១៨-ខេត្តព្រះសួគ៌ា, ១៩-ខេត្តផ្សំអំបើស, ២០-ខេត្តឈ្មោះថ្មី និង២១-ខេត្តអូរកាប់។

នៅក្នុងជំនាន់អាណានិគមនិយមបារាំង ឈ្មោះខេត្តទាំង២១នេះ បានដូរទៅជា ភាសាវៀតណាម វិញ គឺៈ ១- ខេត្តព្រះត្រពាំង ដូរទៅជាខេត្តត្រាវិញ ( Tra Vinh ), ២-ខេត្ត

ស្រុកឃ្លាំង ដូរទៅជាខេត្តសុកត្រាំង (Soc Trang), ៣-ខេត្តមាត់ជ្រូក ដូរទៅជាខេត្តចូវដុក (Chau Doc), ៤-ក្រមួនស ដូរទៅជាខេត្តរ៉ាចយ៉ា (Rach Gia), ៥-ខេត្តពលលាវ ដូរទៅជាខេត្តបាក់លៀវ (Bac Lieu ), ៦-ខេត្តទឹកខ្មៅ ដូរទៅជាខេត្តកាម៉ាវ (Ca Mao), ៧-ខេត្តពាម ដូរទៅជាខេត្តហាទៀង (Ha Tien ), ៨-ខេត្តព្រែកឫស្សី ដូរទៅជាខេត្តកានថឺ (Can Tho), ៩-ខេត្តលង់ហោរ ដូរទៅជាខេត្តវិញឡុង (Vinh Long), ១០-ខេត្តពាមបារ៉ាជ្ជ ដូរទៅជាខេត្តឡុងស្វៀន (Long Xuyen), ១១-ខេត្តរោងដំរី ដូរទៅជាខេត្តតៃនិញ (Tay Ninh), ១២-ខេត្តព្រៃនគរ ដូរទៅជាខេត្តសាយហ្គន(Sai Gon), ១៣-ខេត្តទួលតាមោក ដូរទៅជាខេត្តធូយ៉ូវម៉ុត(THu Dau Mot), ១៤-ខេត្តផ្សារដែក ដូរទៅជាខេត្តសាដេក(Sa Dec),១៥-ខេត្តចង្វាត្រពាំង-ស្រកាត្រី ដូរទៅជាខេត្តបៀនហ៊ា (Bien Hoa), ១៦-ខេត្តមេស ដូរទៅជាខេត្តមីថ(My Tho ), ១៧-ខេត្តកោះគង ដូរទៅជាខេត្តហ្គកុង (Go Cong), ១៨-ខេត្តព្រះសួគ៌ា ដូរទៅជាខេត្តបារៀ (Ba Ria),១៩-ខេត្តផ្សំអំបើស ដូរទៅជាខេត្តបេនត្រែ (Ben Tre),២០-ខេត្តឈ្មោះថ្មី ដូរទៅជាខេត្តតឹនអាន(Tan An ) និង២១-ខេត្តអូរកាប់ ដូរទៅជាខេត្តកាបសាំងហ្សាក់ (Cap. St. Jacques) ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ជំនាន់ប្រធានាធិបតីង៉ូ ឌីញយៀម បានធ្វើការដូរឈ្មោះខេត្តទាំងអស់នេះជាបន្តទៀត។

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ សភាបារាំងក៏បានអនុម័តច្បាប់មួយប្រគល់ទឹកដីនៅនាយសមុទ្ររបស់ខ្លួន គឺកូសាំងស៊ីន ជាទឹកដីរបស់ខ្មែរ ទៅឲ្យប្រទេសវៀតណាម។

១០ថ្ងៃក្រោយមក គឺនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៤៩ តុងកឹង អណ្ណាម និងកូសាំងស៊ីន ត្រូវបានគេច្របាច់បញ្ចូលគ្នាបង្កើតជារដ្ឋវៀតណាមឯករាជ្យមួយ ដែលមានរាជធានីនៅព្រៃនគរ ក្រោមការដឹកនាំរបស់អតីតអធិរាជបៅដាយ។

តែការពិត ព្រះចៅបៅ ដាយ គ្រប់គ្រងតែនៅកូសាំងស៊ីន និងអណ្ណាម ប៉ុណ្ណោះព្រោះនៅភាគខាងជើង ឬតុងកឹង គឺស្ថិតក្រោមការគ្រប់គ្រងរបស់ពួកកុម្មុយនិស្ត ហូ ជីមិញ។

ចំណែកឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំទីក្រុងព្រៃនគរ អាប៊ុត្ត (Abbott) ក៏បានស្នើឲ្យ

ក្រសួងការបរទេសសហរដ្ឋអាមេរិក ធ្វើសេចក្ដីប្រកាសមួយ ទទួលស្គាល់រដ្ឋាភិបាលរបស់ព្រះចៅបៅ ដាយ ជារដ្ឋាភិបាលស្របច្បាប់។

ក្នុងខែសីហា ឆ្នាំ១៩៤៩ ហូ ជីមិញ បានថ្លែងប្រាប់អ្នកកាសែតអាមេរិកម្នាក់ថា ឥឡូវនេះ យើងបានសម្រេចប្ដូរយុទ្ធសាស្ត្រថ្មីហើយ ។ យើងចាប់ផ្ដើមធ្វើការតស៊ូដំបូងមានតែដំបង កាំបិត ពូថៅប៉ុណ្ណោះ ឥឡូវយើងមានកម្លាំង និងកាំភ្លើងសមល្មម ដើម្បីធ្វើការវាយលុកជាទូទៅហើយ ដោយយើងរង់ចាំតែកងទ័ពដ៏ខ្លាំងពូកែរបស់សមមិត្តប្រធានម៉ៅ (ម៉ៅ សេទុង) ដែលជាជំនួយដ៏ពូកែស័ក្ដិសិទ្ធិមកដល់ព្រំដែន(ចិន-វៀតណាម) តែប៉ុណ្ណោះ។

ចំណែកនៅប្រទេសចិន ក្រោយពួកកុម្មុយនិស្តបានទទួលជ័យជម្នះលើពួកអ្នកជាតិនិយម ជៀង កៃជៀក នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ មក ម៉ៅ សេទុង បានប្រកាសឈ្មោះប្រទេសចិន ជាសាធារណរដ្ឋប្រជាមានិតចិន ។

ឯមេដឹកនាំអ្នកជាតិនិយម ជៀង កៃជៀក បាននាំកងទ័ពប្រមាណ៦០០.០០០នាក់ និងប្រជាជនដែលប្រកាន់លទ្ធិសេរីនិយមប្រមាណ២លាននាក់ទៀត រត់ភៀសខ្លួនទៅរស់នៅលើកោះតៃវ៉ាន់។

ជ័យជម្នះនេះ ធ្វើឲ្យពួកវៀតមិញ កាន់តែមានសង្ឃឹមក្នុងការប្រយុទ្ធប្រឆាំងនឹងបារាំងថែមទៀត រហូតពួកនេះហ៊ានបោះពាក្យសម្ដីទៅបារាំងថា មានតែគ្រាប់កាំភ្លើងទេ ដែលអាចធ្វើឲ្យបារាំងនិយាយគ្នាស្ដាប់បាន ហើយថា ជោគជ័យរបស់ប្រជាជនចិន នឹងក្លាយទៅជាខ្នងបង្អែកដ៏រឹងមាំរបស់វៀតណាម និងជនជាតិផ្សេងៗទៀតនៅអាស៊ី ផងដែរ។

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៤៩ ហូ ជីមិញ បានផ្ញើសារទូរលេខមួយទៅជូនលោកប្រធានម៉ៅ ដើម្បីអបអរសាទរដល់ថ្ងៃបង្កើតរបបសាធារណរដ្ឋប្រជាមានិតនៅប្រទេសចិននោះផងដែរ។

ពីរថ្ងៃក្រោយមក គឺនៅថ្ងៃ១៨ ខែតុលា ឆ្នាំ១៩៤៩ ហូ ជីមិញ បានថ្លែងប្រាប់អ្នកកាសែតអង់គ្លេសម្នាក់ថា យើងនឹងដេញបារាំង ចេញពីឥណ្ឌូចិន មិនឲ្យសល់ម្នាក់ឡើយ។

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៤៩ ដោយមានការគាំទ្រពីរដ្ឋាភិបាលបារាំង ផងនោះ

ព្រះចៅបៅ ដាយ បានវិលត្រឡប់មកប្រទេសវៀតណាមខាងត្បូងវិញ និងបានកាន់តំណែងជាប្រមុខរដ្ឋ តែមិនមែនសោយរាជ្យជាមហាក្សត្រដូចមុននោះទេ។

ចាប់ពីពេលនោះមក សាធារណមតិពិភពលោក ពិសេសពួកលោកខាងលិច មើលឃើញកាន់តែច្បាស់ថា ការតស៊ូរបស់ពួកវៀតមិញ មិនមែនតស៊ូដើម្បីប្រឆាំងនឹងពួកអាណានិគមបារាំង នោះទេ គឺពួកគេតស៊ូដើម្បីពង្រីកឥទ្ធិពលលទ្ធិកុម្មុយនិស្តនៅឥណ្ឌូចិន ដោយមានបក្សកុម្មុយនិស្តចិន និងបក្សកុម្មុយនិស្តសហភាពសូវៀត នៅពីក្រោយខ្នង។

ថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៥០ សាធារណរដ្ឋប្រជាមានិតចិន បានផ្សារទំនាក់ទំនងការទូតជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។

បន្ទាប់មកទៀត នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៥០ដដែលនោះ សហភាពសូវៀតក៏បានផ្សារទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែរ។

នៅក្នុងខែមីនា ឆ្នាំ១៩៥០ សហរដ្ឋអាមេរិក ដែលពីមុនបានទទួលស្គាល់ និងគាំទ្ររដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមរបស់ហូ ជីមិញ ដែរនោះ ក៏បានត្រឡប់មកផ្សារទំនាក់ទំនងការទូតជាមួយរដ្ឋាភិបាលរបស់ព្រះចៅបៅ ដាយ ។

ចាប់ពីពេលនោះមក សង្គ្រាមរវាងពួកវៀតមិញ និងបារាំងនៅឥណ្ឌូចិន កាន់តែរីកធំឡើងៗជាលំដាប់ ហើយសហរដ្ឋអាមេរិក ក៏បានផ្តល់ជំនួយផ្នែកយោធាខ្លះដល់បារាំង ដើម្បីបង្ក្រាបពួកវៀតមិញ ផងដែរ។

ចំណែកពួកវៀតមិញ ក៏បានបើកការវាយប្រហារទៅលើកងទ័ពបារាំង នៅទូទាំងឥណ្ឌូចិនតែម្តង ដោយក្នុងនោះ នៅក្នុងប្រទេសកម្ពុជា ពួកវៀតមិញ បានសហការជាមួយចលនាតស៊ូខ្មែរឥស្សរៈ កាន់កាប់ត្រួតត្រានៅតំបន់ដាច់ស្រយាលស្ទើរតែទាំងអស់។

# ២៤
# ចលនាតស៊ូខ្មែរឥស្សរៈ



**ព្រឹឌី ផាណុំយ៉ុខ និខ ហូ ជីមិញ**

ក្រោយពីបារាំងវិលត្រឡប់មកកាន់កាប់ប្រទេសកម្ពុជា វិញសាជាថ្មីម្តងទៀត ចលនាតស៊ូដែលហៅថា ពួកខ្មែរឥស្សរៈជាច្រើនក្រុមត្រូវបានបង្កើតឡើងស្ទើរតែឈាមពេញប្រទេស ដោយមានការបែងចែកកាន់កាប់គ្រប់គ្រងតាមតំបន់ផ្សេងៗគ្នារៀងៗខ្លួន ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងបារាំង ។

តែក្នុងនោះ ក៏មានពួកឥស្សរៈខ្លះបានធ្វើសកម្មភាពដូចពួកចោរ ពួកចោរព្រៃ លួចឆក់ប្លន់បាញ់សម្លាប់ប្រជារាស្ត្រយ៉ាងព្រៃផ្សៃបំផុតផងដែរ។

ដោយសារមានជំនួយពីពួកវៀតមិញ ប៉ាច ឈឺន និងចៅ សែនកុសល ដែលរត់គេចខ្លួនដោយសារតែខ្លាចបារាំង ចាប់កាលពីចុងខែតុលា ឆ្នាំ១៩៤៥នោះ បានបង្កើតចលនាតស៊ូខ្មែរឥស្សរៈមួយ នៅតាមបណ្តោយព្រំដែនវៀតណាម-កម្ពុជា ដើម្បីប្រឆាំងនឹងបារាំងបន្តទៀត ។

ប៉ាច ឈឺន បានអះអាងថា មានបងប្អូនខ្មែរកម្ពុជាក្រោមចំនួន៦០០០នាក់ បាន

ចូលរួមគាំទ្រក្នុងចលនាតស៊ូរបស់គាត់ ហើយមានយុវជនជាច្រើនរយនាក់ បានស្ម័គ្រចិត្តចូលបម្រើជាកងទ័ពក្នុងចលនាតស៊ូរបស់គាត់ទៀតផង។

ប៉ុន្តែ៤ខែក្រោយមក នៅពេលកងទ័ពបារាំង ចូលទៅកាន់កាប់តំបន់ព្រំដែនវៀតណាម-កម្ពុជា ដែលជាកន្លែងប៉ាច ឈឺន បង្កើតចលនាតស៊ូខ្មែរឥស្សរៈនោះ ចលនាតស៊ូរបស់គាត់ក៏ត្រូវបានរលាយទៅវិញបន្តិចម្តងៗដែរ ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៤៦ ចៅ សែនកុសល ជាអតីតចៅហ្វាយខេត្តកំពង់ចាម ដែលរត់ចូលព្រៃជាមួយប៉ាច ឈឺន នោះដែរ បានសម្រេចចិត្តសុំចុះចូលជាមួយបារាំង វិញ។

ចំណែកប៉ាច ឈឺន ដោយសារចលនាតស៊ូរបស់គាត់ត្រូវរលាយបន្តិចម្តងៗ និងមានការអាក់អន់ចិត្តចំពោះកងទ័ពវៀតមិញ ដែលគាត់ស្នើសុំឲ្យបើកការវាយប្រហារទៅលើក្រុងភ្នំពេញ តែពួកវៀតមិញ មិនព្រមធ្វើតាមការស្នើសុំនោះ គាត់ក៏សុំចុះចូលជាមួយបារាំង នៅក្នុងខែមេសា ឆ្នាំ១៩៤៦ នោះដែរ។

ដោយឡែក អ្នកដែលមិនព្រមចុះចូលជាមួយបារាំង មួយចំនួនទៀត ក៏បានចូលទៅរួបរួមតស៊ូជាមួយពួកវៀតមិញ បន្តទៀត។

ពេលនោះ ពួកវៀតមិញ ក៏មានគម្រោងបញ្ជូនជនជាតិវៀតណាម ជាសកម្មជនប្រឆាំងនឹងបារាំង ដែលបានរត់គេចខ្លួនពីទីក្រុងភ្នំពេញ និងខេត្តនានានោះ ឲ្យត្រឡប់ទៅធ្វើសកម្មភាពនៅកន្លែងដើមរបស់ពួកគេវិញដែរ ។

ដោយឡែក អតីតពួកនាយទាហានវ័យក្មេងៗ៧នាក់ ដែលបាននាំគ្នាទៅអុកឡុកនៅក្នុងព្រះបរមរាជវាំង កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៤៥នោះ មានម្នាក់ឈ្មោះ ហែម សាវ៉ាង បានរត់ចូលព្រៃ ដើម្បីធ្វើការតស៊ូបន្តទៀតក៏ពិតមែន តែគាត់មិនទៅចូលរួមជាមួយពួកវៀតមិញទេ ។

គាត់ទៅចូលរួមជាមួយចលនាតស៊ូខ្មែរឥស្សរៈនៅភាគខាងលិចប្រទេស ដែលនៅទីនោះ គាត់បានជួបម៉ី ផូ ដែលធ្លាប់រួមគ្នាចូលទៅអុកឡុកនៅក្នុងព្រះបរមរាជវាំងនោះដែរ។

ចលនាតស៊ូខ្មែរឥស្សរៈភាគខាងលិចប្រទេសនោះ គឺស្ថិតនៅក្រោមការជួយឧបត្ថម្ភ

គាំទ្ររបស់នាយករដ្ឋមន្ត្រីថៃ ឈ្មោះ ព្រីឌី ផាណុំយ៉ុង ដែលធ្លាប់សហការជាមួយកងទ័ពជប៉ុន និងមានទំនាក់ទំនងការទូតជាមួយរបបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម របស់ ហូ ជីមិញ ។

ចុងឆ្នាំ១៩៤៥ រដ្ឋាភិបាលសៀម បានជ្រោមជ្រែងប្រមែប្រមូលចលនាតស៊ូខ្មែរឥស្សរៈជាច្រើនក្រុម ឲ្យរួបរួមគ្នាបង្កើតជាគណៈកម្មាធិការឥស្សរៈមួយ ដែលមានមូលដ្ឋាននៅក្នុងប្រទេសសៀម ហើយក្នុងចំណោមសមាសភាពដឹកនាំគណៈកម្មាធិការនេះ១២នាក់ គឺមានតែម៉ី ផូ ម្នាក់ប៉ុណ្ណោះ ដែលមានគោលជំហរលម្អៀងទៅលើពួកវៀតមិញ។

ប៉ុន្តែដោយសារគណៈកម្មាធិការឥស្សរៈនេះ ចេះតែមានជម្លោះបែកបាក់ មិនស៊ី-ចង្វាក់គ្នានោះ នៅដើមឆ្នាំ១៩៤៦ នៅផ្ទះរបស់ឥស្សរជនសៀមម្នាក់ឈ្មោះផៅ អភ័យវង្ស នៅក្រុងបាងកក ពួកគេបានប្រជុំគ្នាបង្កើតគណៈកម្មាធិការថ្មីមួយឲ្យឈ្មោះគណៈកម្មាធិការរួមជាតិ ជំនួសគណៈកម្មាធិការឥស្សរៈនោះវិញ ក្នុងគោលបំណងមិនឲ្យមានជម្លោះបែកបាក់បែងចែកបក្ខពួកគ្នាបន្តទៀត ។

ផៅ អភ័យវង្ស ជាពូជពង្សអតីតមន្ត្រីជាន់ខ្ពស់ខ្មែរម្នាក់ឈ្មោះចៅហ៊្វា បែន ដែលបានចុះចូលជាមួយសៀម និងបានត្រួតត្រាខេត្តបាត់ដំបង, សៀមរាប និងកំពង់ធំ ចាប់ពីឆ្នាំ១៧៩៥មក ដែលកាលនោះ ខេត្តទាំង៣នេះ ត្រូវបានក្លាយទៅជាខេត្តរបស់សៀម ។

ផៅ អភ័យវង្ស ធ្លាប់កាន់តំណែងជាចៅហ្វាយខេត្តបាត់ដំបង កាលខេត្តនេះនៅក្រោមការគ្រប់គ្រងរបស់សៀមជាថ្មីម្តងទៀត ក្រោយឆ្នាំ១៩៤១ ហើយផៅ អភ័យវង្ស នេះក៏ត្រូវជាបងថ្លៃរបស់ប៉ុក គុណ (ឬ ប៉ុក ផល្គុណ) ហៅតាត្រឡាច ផងដែរ។

គណៈកម្មាធិការរួមជាតិនេះ ហៅកាត់ថា គ.រ.ជ មានសមាជិក១២រូប ដូចជា ប៉ុក គុណ ហៅតាត្រឡាច , ដាប ឈួន , ព្រះអង្គម្ចាស់ នរោត្តម ចន្ទរង្សី , រស់ យឿន , ម៉ី ភូរិន្ទ , កៅ តក់ , ស្ត្រីឈ្មោះ លាត មួន ហៅម៉ែមួន (ជាបងចិញ្ចឹមកៅ តក់) , ហែម សាវ៉ាង , ម៉ៅ សារួត, ប្រាក់ សាវិន ជាដើម ។ ប៉ុន្តែមេដឹកនាំធំរបស់គណៈកម្មាធិការរួមជាតិ (គ.រ.ជ) នោះគឺ ផៅ អភ័យវង្ស និងជនជាតិសៀម២នាក់ទៀត។

## របត់នយោបាយ



សឺង ង៉ុកមិញ

ចំណែកនៅភាគខាងត្បូងប្រទេស គឺត្រង់ព្រំដែនខេត្តតាកែវ ជាប់នឹងទឹកដីកូសាំង-ស៊ីន សឺង ង៉ុកមិញ និងទូ សាមុត ដែលជាអតីតព្រះសង្ឃនៅទីក្រុងភ្នំពេញ បានបង្កើតចលនាឥស្សរៈខ្មែរមួយដែរ ដោយបានសហ-ការយ៉ាងជិតស្និទ្ធបំផុតជាមួយង្វៀង ថាញ់សឺន ដែលជាមេដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិន នៅកូសាំងស៊ីន។

សឺង ង៉ុកមិញ និងទូ សាមុត បានចូលទៅឃោសនាបំផុសឲ្យបងប្អូនខ្មែរនៅកូសាំងស៊ីន រួបរួមសាមគ្គីគ្នាជាមួយខ្មែរនៅភាគកណ្តាល ដើម្បីធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង ផងដែរ។

នៅដើមឆ្នាំ១៩៤៦ ដើម្បីប្រឆាំងនឹងបារាំង ដែលវិលត្រឡប់មកត្រួតត្រាតំបន់ឥណ្ឌូចិន ជាថ្មីម្តងទៀតដែរនោះ រដ្ឋាភិបាលសៀម ដែលមានព្រីឌី ផាណុំយ៉ុង ជានាយករដ្ឋមន្ត្រី បានអនុញ្ញាតឲ្យរបបសាធារណរដ្ឋប្រជាធិប-តេយ្យវៀតណាម របស់ហូ ជីមិញ មកតាំងស្ថានបេសកកម្មការទូត នៅទីក្រុងបាងកក ដោយមានចិន វ៉ិនហ្សូវ ជាតំណាង។

ដោយសារទទួលបានការជួយឧបត្ថម្ភ គាំទ្រទាំងស្មារតី និងលុយកាក់ពីសំណាក់មេដឹកនាំវៀតមិញ ដែលមកបោះទីតាំងនៅលើទឹកដីកម្ពុជានោះ សឺង ង៉ុកមិញ ហៅអាចារ្យមៀន បានធ្វើដំណើរទៅប្រទេសថៃ ដើម្បីទៅទិញគ្រឿងអាវុធមួយចំនួន យកមកបំពាក់ឲ្យកងកម្លាំងរបស់ខ្លួនបន្ថែមទៀត។

ពេលទៅដល់ក្រុងបាងកក ប្រទេសសៀម សឺង ង៉ុកមិញ ហៅអាចារ្យមៀន បាន

សម្រេចចិត្តចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន តាមរយៈចិន វ៉ិនហ្សូវ ជាតំណាង របបសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងជាតំណាងបក្សកុម្មុយនិស្តឥណ្ឌូចិន នៅក្រុងបាងកកនោះ ។

នៅប៉ែកខាងលិចប្រទេស ក៏មានចលនាខ្មែរឥស្សរៈប្រឆាំងនឹងបារាំង មួយចំនួនដែរ ក្នុងនោះមានចលនាខ្មែរឥស្សរៈខ្លះ សៀមជាអ្នកជួយបង្កើតឡើង និងចលនាខ្មែរឥស្សរៈខ្លះទៀត គឺពួកវៀតមិញ ជាអ្នកជួយបង្កើតឡើង ។

មេដឹកនាំចលនាខ្មែរឥស្សរៈល្បីៗនៅទីនោះ រួមមានប៉ុក គុណ ហៅតាត្រឡាច, ម៉ី ភូរិន្ទ, ហែម សាវ៉ាង, ហែម សាវ៉ាត, ងុក សាន, ព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី , រស់ យឿន និង ម៉ី ផូ ជាដើម។

ម៉ី ផូ ជាអ្នកចូលរួមអុកឡុកនៅក្នុងព្រះបរមរាជវាំង មិនបានសម្រេចកាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៤៥ ហើយបានរត់គេចខ្លួនទៅធ្វើការតស៊ូនៅក្នុងព្រៃតាំងពីពេលនោះមក។

នៅប៉ែកខាងលិចប្រទេសនោះ សឺង ង៉ុកមិញ ហៅអាចារ្យមៀន បានឆ្លៀតទាក់ទងជាមួយម៉ី ផូ រួមគ្នាធ្វើសកម្មភាពជ្រើសរើសកម្លាំងទ័ពឲ្យបានច្រើនបន្ថែមទៀត នៅក្នុងខេត្តបាត់ដំបង និងសៀមរាប ដែលពេលនោះ កំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀមនៅឡើយ ដើម្បីបញ្ចូលទៅក្នុងអង្គភាពចម្រុះខ្មែរ-វៀតមិញ ដែលបានបង្កើតឡើងនៅក្នុងខេត្តបាត់ដំបង តាំងពីខែមិថុនា ឆ្នាំ១៩៤៦មកនោះ។

អង្គភាពកងទ័ពចម្រុះខ្មែរ-វៀតមិញនោះ មានមេបញ្ជាការចម្រុះ គឺខ្មែរផង និងពួកវៀតមិញផង ។

នៅខេត្តបាត់ដំបងនោះ ក៏មានអតីតអ្នកចូលរួមអុកឡុកនៅក្នុងព្រះបរមរាជវាំង មិនបានសម្រេចកាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៤៥ ម្នាក់ទៀតឈ្មោះ នេត លាងសាយ ក៏មានតួនាទីជាប្រធាននយោបាយរបស់ចលនាខ្មែរឥស្សរៈនៅទីនោះដែរ។

នៅក្នុងឆ្នាំ១៩៤៦នោះដែរ នាយករដ្ឋមន្ត្រីសៀម ព្រីឌី ផាណុំយ៉ុង ត្រូវបង្ខំចិត្តប្រគល់ខេត្តសៀមរាប និងបាត់ដំបង ដែលគេបានដណ្តើមយកទៅកាលពីឆ្នាំ១៩៤១នោះ

មកឲ្យប្រទេសខ្មែរវិញ ក្រោមការគាបសង្កត់របស់ប្រទេសបារាំង និងសហគមន៍អន្តរជាតិ បើមិនដូច្នោះទេ ប្រទេសថៃ នឹងមិនត្រូវអនុញ្ញាតឲ្យចូលជាសមាជិកអង្គការសហប្រជាជាតិឡើយ។

នៅចុងឆ្នាំ១៩៤៦ សឺង ង៉ុកមិញ ក៏បានវិលត្រឡប់មកមូលដ្ឋានតស៊ូរបស់គាត់នៅព្រំដែនខេត្តតាកែវ ជាប់នឹងកូសាំងស៊ីន វិញ ហើយបានយកអាវុធដែលទិញមកពីប្រទេសថៃនោះ មកបំពាក់ឲ្យកម្លាំងរបស់គាត់បានមួយកងអនុសេនាធំ នៅបាយនួយ (Bay Nui)។

នៅក្នុងឆ្នាំ១៩៤៦នោះដែរ ង្វៀង ថាញ់សឺន ជាមេដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិន នៅកូសាំងស៊ីន បានអូសទាញណី សាវ៉ាន់ (ម៉ែន សាន ហៅយ៉ា ) ជាស្មៀនឃុំគគីរសោម ស្រុករំដួល ខេត្តស្វាយរៀង និងកែវ មាស ដែលជាសិស្សសាលាគរុកោសល្យ នៅទីក្រុងភ្នំពេញ ឲ្យចូលរួមនៅក្នុងចលនាតស៊ូប្រឆាំងបារាំង ដែរ។

បន្ទាប់មកទៀត ង្វៀង ថាញ់សឺន ក៏បានអូសទាញឈ្មោះញ៉ែម ស៊ុន ជាពលបាលទោនៅក្នុងជួរកងទ័ពបារាំង ឲ្យមកចូលរួមជាមួយចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ ផងដែរ។

# ២៥
# ខ្មែរឥស្សរៈវាយប្រហារក្រុងសៀមរាប



សណ្ឋាគារសៀមរាប

ក្រោយពីបារាំង ចាប់នាយករដ្ឋមន្ត្រីសឹង ង៉ុកថាញ់ យកទៅបាត់ ប៉ុណ្ណ ចន្ទម៉ុល ដែលជាសហការីដ៏ជិតស្និទ្ធម្នាក់ និងជាអតីតអ្នកទោសនៅក្នុងគុកកោះត្រឡាចនោះ មានការភ័យខ្លាចបារាំង ចាប់យកទៅដាក់គុកជាថ្មីម្តងទៀត ក៏បានរត់គេចខ្លួនពីក្រុងភ្នំពេញ ទៅខេត្តបាត់ដំបង ដែលសៀមកំពុងគ្រប់គ្រងកាន់កាប់នោះបន្តទៀត ដើម្បីស្វែងរកឪពុកមាគាត់ម្នាក់ឈ្មោះប៉ុក គុណ ហៅតាត្រឡាច ជាមេដឹកនាំចលនាខ្មែរឥស្សរៈប្រឆាំងនឹងបារាំងដ៏ល្បីល្បាញម្នាក់ តាំងពីឆ្នាំ១៩៤០មក ។

ក្រោយពេលស្នាក់នៅជាមួយឪពុកមាជាមេដឹកនាំចលនាខ្មែរឥស្សរៈ នៅក្រុងបាត់ដំបងនោះ មិនយូរប៉ុន្មាន ប៉ុណ្ណ ចន្ទម៉ុល ក៏បានសម្រេចចិត្តចូលរួមក្នុងចលនាតស៊ូរបស់ឪពុកមាគាត់នោះដែរ។

បើតាមឯកសារដែលប៉ុណ្ណ ចន្ទម៉ុល បានបន្សល់ទុក បានឱ្យដឹងថា កាលពីដើមឡើយ ដាប ឈួន ជាប្រធានក្រុមរបស់ទាហានរាជការខ្មែរ-បារាំង ដែលច្បាំងជាមួយកងទ័ពសៀម។

ប៉ុន្តែក្រោយពីសៀម ចូលមកគ្រប់គ្រងខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៤១ សៀមបានប្រើល្បិចចូលលួងលោមដល់ពលទាហាន នាយទាហានរបស់រាជការខ្មែរ-បារាំង ឲ្យចូល

បម្រើការងារនៅក្រោមការគ្រប់គ្រងរបស់ពួកគេបន្តទៀត ដោយសន្យាផ្តល់បុណ្យស័ក្តិឲ្យធំជាងកាលនៅក្នុងជួរទាហានមន្ត្រីរាជការខ្មែរ-បារាំង ទៅទៀត។

ពេលនោះ ដាប ឈួន ដែលមានឋានន្តរស័ក្តិជាពលបាល ក៏បានសម្រេចចិត្តចុះចូលជាមួយនឹងពួកសៀម នៅខេត្តបាត់ដំបងនោះ ហើយពួកសៀមបានស្វាគមន៍ដាប ឈួន យ៉ាងរាក់ទាក់បំផុត និងសន្យាថា នឹងដំឡើងឋានន្តរស័ក្តិឲ្យកាន់តែខ្ពស់ទៀតផង ។

ក្រោយពីដាប ឈួន ចុះចូលពួកសៀម គាត់បានឲ្យនាំកម្លាំងទៅបោះទីតាំងឈរជើងនៅភូមិមួយនៅម្តុំស្វាយចេក ដែលសម័យនោះជាព្រំប្រទល់ខ្មែរ-សៀម។

ប៉ុន្តែអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ពួកសៀម មិនបានដំឡើងបុណ្យស័ក្តិឲ្យគាត់តាមពាក្យសន្យារបស់ពួកគេទេ ធ្វើឲ្យដាប ឈួន មានការអាក់អន់ស្រពន់ចិត្តជាខ្លាំង។

តែគាត់មិនហ៊ានរត់មកខាងរាជការខ្មែរ-បារាំងវិញទេ ព្រោះខ្លាចគេយកទោស ក៏សម្រេចចិត្តស៊ូទ្រាំរស់នៅបម្រើសៀម បន្តទៀត ទាំងបង្ខំចិត្ត។

ក្រោយពីបារាំង វិលត្រឡប់មកកាន់កាប់ប្រទេសកម្ពុជាវិញ ដាប ឈួន ក៏រត់ចោលជួរកងទ័ពសៀម នៅម្តុំស្វាយចេកនោះ ទៅចូលរួមជាមួយចលនាខ្មែរឥស្សរៈ នៅឯអន្លង់វិល ដែលដឹកនាំដោយប៉ុក គុណ ហៅតាត្រឡាច វិញ។

ចំណែកប៊ុណ្ណ ចន្ទម៉ុល ក្រោយពេលចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈនៅខេត្តបាត់ដំបងមក គាត់មិនសប្បាយចិត្តចំពោះការចោទប្រកាន់ខ្មែរគ្នាឯងថាជាគិញ ឬជាខ្ញុំកញ្ជះបារាំង ហើយចាប់យកមកសម្លាប់ធ្វើបាបដោយគ្មានភស្តុតាងអ្វីបន្តិចសោះឡើយនោះទេ ហើយគាត់បានអប់រំណែនាំដល់អ្នកតស៊ូជាមួយគ្នាមួយចំនួន កុំឲ្យជឿលើមន្តអាគមបាញ់មិនចេញ កាប់មិនមុត ដុតមិនឆេះ ខ្សែគាថា ខ្សែចង្កេះ កន្សែងយ័ន្ត ចែកាច់នោះខ្លាំងពេកផងដែរ ។

ក្នុងខែមិថុនា ឆ្នាំ១៩៤៦នោះដែរ មេដឹកនាំចលនាតស៊ូក្នុងខេត្តបាត់ដំបង បានដើររៃអង្គាសប្រាក់កាក់ពីប្រជាជន បានប្រមាណ១៥ម៉ឺនរៀល យកទៅប្រគល់ឲ្យប៉ុក គុណ ហៅតាត្រឡាច មេចលនាខ្មែរឥស្សរៈដែលកំពុងស្នាក់នៅបាងកក ប្រទេសថៃ ហើយប៉ុក គុណ បានយកលុយនោះទៅទិញបានកាំភ្លើង១៥០ដើម ព្រមទាំងគ្រាប់រំសេវ និងគ្រាប់

បែកដៃមួយចំនួនទៀត មកបំពាក់បន្ថែមឲ្យកងទ័ពខ្មែរឥស្សរៈនៅខេត្តបាត់ដំបង ដែលមានគ្នាប្រមាណជាង៤០០នាក់។

ដើមខែសីហា ឆ្នាំ១៩៤៦ ក្រោយពីមេដឹកនាំធំៗបានប្រជុំឯកភាពគ្នាថា ត្រូវតែបើកការវាយប្រហារទៅលើក្រុងសៀមរាប រួចមក កងទ័ពខ្មែរឥស្សរៈដែលនៅអន្លង់វិលទាំងអស់ ខ្លះត្រូវចេញដំណើរកាត់តាមព្រៃ ខ្លះទៀតធ្វើដំណើរតាមផ្លូវជាតិ កាត់ទីប្រជុំជនសិរីសោភ័ណ (កាលនោះសៀម ឲ្យឈ្មោះថា ស៊ីសុផុន) សំដៅទៅរកក្រុងសៀមរាប ។

ក្រោយធ្វើដំណើរអស់រយៈពេល៥ថ្ងៃ ទើបទៅដល់ត្រង់ស្ពានមួយ ចម្ងាយប្រមាណ ៥គីឡូម៉ែត្រ ពីទីរួមស្រុកក្រឡាញ់។

ចំណុចស្ពាននោះ គឺជាព្រំប្រទល់ជាប់ប្រទេសខ្មែរ-សៀម កាលសម័យនោះ ហែម សាវ៉ាង និងម៉ៅ សារួត បានលាតផ្ទាំងផែនទី មកពិនិត្យ និងបែងចែកកម្លាំង ដើម្បីធ្វើការវាយប្រហារទៅលើសាលាស្រុកថ្មពួក និងកម្លាំងប្រមាណជាង៣០០នាក់ទៀត ត្រូវចេញដំណើរទៅវាយប្រហារក្រុងសៀមរាប។ កម្លាំងដែលត្រូវបើកការវាយប្រហារទៅលើក្រុងសៀមរាបនោះដឹកនាំដោយដាប ឈួន, ហែម សាវ៉ាង និងម៉ៅ សារួត ចែកចេញជា៥មុខព្រួញ គឺ៖

មុខព្រួញទី១ វាយសម្រុកចូលសាលាខេត្ត ដែលមានពួកមន្ត្រីបារាំងនៅទីនោះ ។

មុខព្រួញទី២ វាយសម្រុកចូលចូលបន្ទាយទាហានជើងខ្មៅ ។

មុខព្រួញទី៣ វាយសម្រុកចូលប៉ុស្តិ៍ខ្សែលួស (វិទ្យុទាក់ទង)។

មុខព្រួញទី៤ វាយសម្រុកចូលពន្ធនាគារ រំដោះអ្នកទោស។

មុខព្រួញទី៥ វាយសម្រុកចូលផ្ទះមេគិញ មេគយ និងប៉ូលិសខេត្ត។

ពេលនោះ ក្រុមស៊ើបការណ៍របស់ពួកខ្មែរឥស្សរៈ បានឲ្យដឹងថា នៅក្នុងទីរួមខេត្តសៀមរាប មាននាយទាហានបារាំងប្រហែល២៥នាក់ សម្រាកនៅសណ្ឋាគារខេត្ត។

នៅវេលាកណ្តាលអធ្រាត្រ ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៤៦ កងទ័ពឥស្សរៈទាំង៥ មុខព្រួញ បានលបចូលទៅដល់ក្នុងក្រុងសៀមរាប តាមមុខព្រួញនីមួយៗ ដូចផែនការដែល

បានគ្រោងទុក។

មុខព្រួញទី១ នៅតែប្រមាណ២គីឡូម៉ែត្រទៀត នឹងចូលទៅដល់សណ្ឋាគារខេត្ត ស្រាប់តែលាន់សន្ធឹករថពាសដែកទាហានបារាំង-ខ្មែរ ចេញល្បាតក្នុងក្រុងដូចសព្វដង ចំមុខព្រួញរបស់ពួកគេ។

ពេលនោះ មេបញ្ជាការមុខព្រួញទី១ បញ្ជាឲ្យកូនចៅក្រាបសំងំ និងនៅឲ្យស្ងៀម ដើម្បីកុំឲ្យបែកការ ព្រោះមិនទាន់ដល់គោលដៅនៅឡើយ ។

ប៉ុន្តែពេលនោះ មានកងទ័ពឥស្សរៈម្នាក់ឈ្មោះម៉ែន ពេលឃើញរថពាសដែកនោះ ចូលមកជិតដល់ ក៏បានបាញ់ផាំង ហើយទាហានបារាំង-ខ្មែរដែលនៅក្នុងរថពាសដែកនោះ ក៏បាញ់តបតវិញបណ្ដើរ និងវិលត្រឡប់ចូលទៅបន្ទាយវិញបណ្ដើរ ប្រកាសអាសន្ន បណ្ដាលឲ្យមានការភ្ញាក់ផ្អើលពេញក្រុងសៀមរាប តែម្ដង។

ក្រោយពេលបែកការ មុខព្រួញទី១ ក៏បានបាញ់សម្រុកដេញតាមក្រោយរថពាសដែក ដែលវិលចូលទៅបន្ទាយទាហានវិញនោះ រហូតទៅដល់ក្នុងបរិវេណសណ្ឋាគារខេត្ត ហើយចាប់ផ្ដើមបាញ់រះសំដៅទៅលើបន្ទប់ទាំងឡាយនៃសណ្ឋាគារនោះពីចម្ងាយ តែត្រូវបានពួកនាយទាហានបារាំង ដែលមានតាំងពីស័ក្តិ២ ដល់ស័ក្តិ៥ ស្នាក់នៅទីនោះបាញ់តបតវិញ។

ពេលនោះ ពួកមេខ្មែរឥស្សរៈនៅទីព្រួញទី១ សង្ស័យកូនចៅរបស់ខ្លួនឈ្មោះម៉ែន ជាភ្នាក់ងារផ្ទៃក្នុងរបស់បារាំង ព្រោះមិនគោរពតាមបញ្ជារបស់ខ្លួនដែលពេលឃើញរថពាសដែកទាហានបារាំង-ខ្មែរ ដំបូងនោះ ខ្លួនបានបញ្ជាឲ្យក្រាបសំងំ និងនៅឲ្យស្ងៀម បែរជាឈ្មោះ ម៉ែននោះ បាញ់រថពាសដែកនោះ ធ្វើឲ្យបែកការសម្ងាត់មុនកាលកំណត់នៃការផ្ទុះអាវុធទៅវិញ។

ចំណែកកម្លាំងនៅ៤មុខព្រួញទៀត ក៏បានធ្វើការវាយលុកតាមមុខព្រួញរៀងៗខ្លួន យ៉ាងអង់អាចក្លាហានដែរ។

ពិសេសមុខព្រួញទី២ ដែលវាយបន្ទាយទាហានជើងខ្មៅ និងមុខព្រួញទី៤ ដែលវាយពន្ធនាគារ ទទួលបានជោគជ័យគួរឲ្យកោតសរសើរ។

លុះដល់ព្រឹកព្រលឹមស្រាងៗ ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៦ ពេលកងទ័ពខ្មែរឥស្សរៈ

កំពុងនាំគ្នាដើរប្រមូលកាំភ្លើង ដែលពួកទាហានបារាំង-ខ្មែរ រត់ចោលទាំងអស់បានជាង១០០ ដើម ស្រាប់តែកងទ័ពបារាំង ចាប់ផ្តើមធ្វើការវាយបកជាទ្រង់ទ្រាយធំពីក្រៅក្រុងសៀមរាប មកវិញ។

ដោយដឹងច្បាស់ថា មិនអាចទប់ទល់នឹងទាហានបារាំង-ខ្មែរ បាន កងទ័ពខ្មែរឥស្សរៈ ក៏បង្ខំចិត្តដកថយតាមក្បួនយុទ្ធសាស្ត្រចេញពីក្រុងសៀមរាប ឆ្ពោះទៅកាន់ទិសខាងជើង តាមផ្លូវទៅអង្គរវត្ត ដោយនាំយកអ្នករបួសស្រាលៗទៅជាមួយផង។

ឯអ្នករងរបួសធ្ងន់ ត្រូវសែងយកទៅទុកចោលនៅមុខគិលានដ្ឋានក្រុងសៀមរាប។ ឯពួកទាហានបារាំង-ខ្មែរ ក៏បានដេញតាមបាញ់រះ រហូតដល់ប្រាសាទអង្គរវត្ត ទើបកងទ័ពខ្មែរឥស្សរៈបំបែកផ្លូវគ្នាបង្វែងដានទាហានបារាំង-ខ្មែរ ដោយណាត់ជួបគ្នានៅកំពង់ថ្កូវ។

បន្ទាប់មក កងទ័ពខ្មែរឥស្សរៈទាំងនោះ បានបន្តដំណើរទៅដល់ជួរភ្នំដងរែក ទើបបំបែកគ្នាជា៣ក្រុម គឺក្រុមទី១ ដឹកនាំដោយដាប ឈួន, ក្រុមទី២ ដឹកនាំដោយហែម សាវ៉ាង និងម៉ៅ សារួត និងក្រុមទី៣ ដឹកនាំដោយមេខ្មែរឥស្សរៈម្នាក់ទៀត ទៅបោះទីតាំងនៅតំបន់ផ្សេងៗពីគ្នាតែរៀងៗខ្លួន ។

ចំពោះកងទ័ពឥស្សរៈ ដែលរងរបួសធ្ងន់នៅក្នុងការវាយប្រយុទ្ធនៅក្រុងសៀមរាប កាលពីយប់ថ្ងៃទី៧ ខែសីហា ហើយត្រូវបានពួកគេសែងយកទៅទុកចោលនៅមុខគិលានដ្ឋានក្រុងសៀមរាបនោះ ដោយសង្ឃឹមថា គ្រូពេទ្យនៅទីនោះ នឹងជួយព្យាបាលមុខរបួសក្នុងន័យមនុស្សធម៌ ក៏ត្រូវពួកបារាំង មិនអនុញ្ញាតឲ្យគ្រូពេទ្យនៅទីនោះ ជួយព្យាបាលសង្គ្រោះអាយុជីវិតពួកគេឡើយ គឺពួកបារាំង យកទៅបាញ់សម្លាប់ចោលទាំងអស់។

ចំណែកនៅសាលាស្រុកពួក វិញ នៅយប់ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៤៦នោះ កងទ័ពឥស្សរៈក៏បានធ្វើការវាយប្រហារដែរ ប៉ុន្តែមិនធ្វើឲ្យមានការភ្ញាក់ផ្អើលខ្លាំងប៉ុន្មាន ដូចការវាយប្រហារនៅទីរួមខេត្តសៀម រាបនោះទេ។

ប៉ុន្តែក្រោយកងទ័ពឥស្សរៈដកថយពីសាលាស្រុកពួកវិញ ពួកបារាំងបានចាប់គ្រូបង្រៀន និងមន្ត្រីសាលាស្រុកមួយចំនួនដែលនៅជុំគ្នាស៊ីផឹកជប់លៀងនៅក្នុងសាលាស្រុក ក្នុងយប់



ប៊ុណ្ណ ចន្ទម៉ុល

នោះ យកទៅវាយសួរចម្លើយ ដោយចោទប្រកាន់ថា អ្នកទាំងអស់នោះជានេកក្នុងរបស់ពួកឥស្សរៈទៅវិញ។

ក្រោយពីព្រឹត្តិការណ៍វាយ-ប្រហារក្រុងសៀមរាបនោះមក មេខ្មែរឥស្សរៈ ប៉ុក គុណ ហៅតាត្រឡាច ក៏បានបោះបង់ចោលទីតាំងតស៊ូនៅអន្លង់វិល ព្រោះពេលនោះ បារាំងបានទាមទារយកខេត្តបាត់ដំបង ពីសៀមវិញ ។ ពិសេស ប៊ុណ្ណ ចន្ទម៉ុល បើហ៊ានរស់នៅទីនោះទៀត បារាំងប្រាកដជាចាប់យកទៅដាក់គុកកោះត្រឡាច ជាថ្មីម្តងទៀតមិនខាន ព្រោះកាលគាត់ជាប់គុកកោះត្រឡាច មិនទាន់គ្រប់រយៈពេល៥ឆ្នាំតាមសាលក្រមតុលាការនៅឡើយទេ តែត្រូវបានកងទ័ពជប៉ុន ទៅជួយដោះលែងគាត់ចេញពីគុកកោះត្រឡាច ជាមួយ ប៉ាច ឈឺន និងនួន ឌួង យកទៅក្រុងភ្នំពេញវិញ កាលពីខែកុម្ភៈ ឆ្នាំ១៩៤៥។

បន្ទាប់មក ប៊ុណ្ណ ចន្ទម៉ុល បានរួមដំណើរជាមួយឪពុកមាគាត់ឈ្មោះ ប៉ុក គុណ ហៅតាត្រឡាច ជាមេចលនាខ្មែរឥស្សរៈដែលសៀមជួយបង្កើតឡើងនោះ ទៅទីក្រុងបាងកក ដើម្បីរកទិញកាំភ្លើងកាប៉ាប៊ីន មីត្រៃយើ និងគ្រាប់បែក បញ្ជូនមកឲ្យពួកខ្មែរឥស្សរៈដែលនៅក្នុងប្រទេស។

ប៊ុណ្ណ ចន្ទម៉ុល បានរំលឹកថា ថ្ងៃមួយ វេលាម៉ោង៤រសៀល នៅទីក្រុងបាងកក ពួកគាត់មានគ្នា៨នាក់ បាននាំគ្នាជញ្ជូនអាវុធគ្រប់ធុនជាច្រើនដើម ដាក់លើរថយន្តឈ្នួលធុនធំមួយ ដើម្បីលួចដឹកចេញឆ្ពោះមកស្រុកអារញ្ញ ខេត្តស្រះកែវ ក្បែរព្រំដែនខ្មែរ ស្រាប់តែ

កម្លាំងរាជអាវុធហត្ថសៀម ប្រមាណ១០០នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ បាននាំគ្នាមកឡោមព័ទ្ធរថយន្តឈ្នួលដែលរៀបចេញដំណើរនោះ ហើយភ្ជង់កាំភ្លើងបញ្ជាឲ្យពួកគាត់លើកដៃឡើងលើទាំងអស់គ្នា ។

ពេលនោះ មានគ្នាគាត់ម្នាក់ឈ្មោះអាចារ្យ ហេង បានប្រាប់កងរាជអាវុធហត្ថសៀមថា អាវុធទាំងអស់នេះ មានច្បាប់អនុញ្ញាតពីរាជការសៀម ឲ្យដឹកចេញទៅប្រទេសខ្មែរ ទើបកងរាជអាវុធហត្ថសៀម នាំគ្នាដកថយទៅវិញ ដោយទុកតែគ្នាគេ២នាក់ នៅយាមការពារសិន ដើម្បីរង់ចាំពួកគេសួរបញ្ជាក់ពីថ្នាក់លើរបស់ពួកគេសិន។

រហូតដល់ស្អែកឡើង ម៉ោង១១ព្រឹក ទើបប៉ុក គុណ ហៅតាត្រឡាច ជាឪពុកមាគាត់យកលិខិតអនុញ្ញាតពីរាជការសៀម មកបង្ហាញកងរាជអាវុធហត្ថសៀមដែលនៅយាមការពារនោះ ទើបគេព្រមឲ្យចេញដំណើរពីក្រុងបាងកក រហូតដល់ម៉ោង៤ទៀបភ្លឺ ទើបដល់ស្រុកអារញ្ញ។

ក្រោយពីឈប់សម្រាកនៅទីរួមស្រុកអារញ្ញ ប្រហែល៤ម៉ោង រថយន្តដឹកអាវុធនោះក៏បន្តដំណើរកាត់តាមស៊ីសុផុន និងទីរួមខេត្តបាត់ដំបង រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបទៅដល់វត្តមួយឈ្មោះវត្តភ្នំទ្រង់បាត្រ ក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលជាទីបញ្ជាការធំមួយរបស់ខ្មែរឥស្សរៈ។

ពួកគាត់បានប្រគល់អាវុធទាំងអស់នោះ ឲ្យអ្នកទទួលខុសត្រូវនៅទីនោះ ដើម្បីបែងចែកទៅឲ្យកងទ័ពខ្មែរឥស្សរៈ ដែលនៅក្រោមបញ្ជារបស់ដាប ឈួន និងហែម សាវ៉ាង ព្រមទាំងមេខ្មែរឥស្សរៈផ្សេងៗទៀត។

នៅក្នុងខែតុលា ឆ្នាំ១៩៤៦ មេដឹកនាំឥស្សរៈម្នាក់ឈ្មោះនេត លាងសាយ ដែលបានចូលរួមធ្វើរដ្ឋប្រហារមិនបានសម្រេចនៅក្នុងព្រះបរមរាជវាំង កាលពីយប់ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៤៥នោះ ត្រូវបានទាហានរាជការខ្មែរ-បារាំង ពួនស្ទាក់បាញ់សម្លាប់នៅក្នុងខេត្តកំពង់ស្ពឺ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៤៦ បារាំង និងបណ្តាប្រទេសជាសម្ព័ន្ធមិត្ត បានបង្ខំឲ្យរដ្ឋាភិបាល

សៀម ប្រគល់ទឹកដីខេត្តបាត់ដំបង សៀមរាប និងកំពង់ធំ មកឲ្យខ្មែរវិញ ។

ពេលនោះ កៅ តក់ ជាមេចលនាឥស្សរៈដែលគាំទ្រដោយរដ្ឋាភិបាលសៀម និងជាកូនចិញ្ចឹមរបស់អាណិកជនចិនម្នាក់ ឈ្មោះ កៅ ដែលសៀម តែងតាំងឲ្យធ្វើជាចៅហ្វាយស្រុកសំរោង តាំងពីមុនមានកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ១៩០៧នោះ បានបើកអង្គប្រជុំដ៏ធំមួយនៅជិតផ្សារក្រុងបាត់ដំបង ដោយមាន ផៅ អភ័យវង្ស ជាមេដឹកនាំធំពីលើគណៈកម្មាធិការរួមជាតិ,ឈ្មោះយ៉ាត វ៉ាយឌី ជាអ្នកទទួលខុសត្រូវវិស័យសិក្សាធិការនៅប្រទេសសៀម និងមន្ត្រីជាន់ខ្ពស់សៀម២នាក់ទៀត ព្រមទាំងដាប ឈួន ចូលរួមជាអធិបតីនៅក្នុងអង្គប្រជុំនោះដែរ។

ពេលនោះ យ៉ាត វ៉ាយឌី បានព្យាយាមពន្យល់ប្រជាជន និងកូនសិស្សខ្មែរថា យើងជាជនជាតិថៃ និងជាបងប្អូននឹងគ្នា ប៉ុន្តែយើងបែកបាក់គ្នា ដោយសារតែពួកអាណានិគមនិយមបារាំង ឥឡូវយើងបានមកជួបជុំគ្នានៅលើទឹកដីមួយដុំនេះវិញ ដោយមានព្រះមហាក្សត្រថៃមួយអង្គ ជាអ្នកគ្រប់គ្រង។

បន្ទាប់មក កៅ តក់ ដែលជាដៃជើងរបស់យ៉ាត វ៉ាយឌី បានស្នើសុំឲ្យយ៉ាត វ៉ាយឌី នេះ ធ្វើជាទីប្រឹក្សាជាន់ខ្ពស់របស់ចលនាតស៊ូរបស់ខ្លួន។

បន្ទាប់មកទៀត យ៉ាត វ៉ាយឌី, កៅ តក់ និងដាប ឈួន ក៏បានផឹកទឹកសម្បថជាមួយគ្នា ដើម្បីបញ្ជាក់ពីភាពស្មោះត្រង់នឹងគ្នាទៅវិញទៅមកទៀតផង។

កៅ តក់ នេះ មានឈ្មោះជាភាសាសៀមមួយទៀត គឺតួលឹម ត្រាគុណ ជាអតីតអ្នកជំនួញដ៏ធំម្នាក់នៅខេត្តសៀមរាប។

ពួកសៀម បានសន្យាថា នឹងជួយផ្តល់អាវុធដល់ចលនាតស៊ូឥស្សរៈគណៈកម្មាធិការរួមជាតិ (គ.រ.ជ) នេះផងដែរ។ ប៉ុន្តែបើតាមភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់បារាំង បានរាយការណ៍ថា គណៈកម្មាធិការរួមជាតិនេះ រង់ចាំអាវុធដែលសៀម សន្យាផ្តល់ឲ្យអស់រយៈពេលជាច្រើនខែ នៅតែមិនឃើញទៀត គេក៏សម្រេចចិត្តរកលុយទិញអាវុធនោះដោយខ្លួនឯង ហើយពួកសៀមនោះ គ្រាន់តែជាឈ្មួញក្នុងការជួញដូរអាវុធ ដើម្បីរកប្រាក់ចំណេញតែប៉ុណ្ណោះ។



**ផ្សារនៅក្នុងក្រុងសៀមរាប**

នៅចុងខែធ្នូ ឆ្នាំ១៩៤៦ នៅភូមិខ្ទៅពួយ ស្ថិតនៅខាងត្បូងក្រុងបាត់ដំបង ប្រមាណ ៨គីឡូម៉ែត្រ អ្នកភូមិនោះភាគច្រើនជាអ្នកកាន់សាសនាកាតូលិក ត្រូវពួកឥស្សរៈចូលមកសម្លាប់នឹងផ្លែដាវ អស់ជាង១០០នាក់ ទំនងមកពីសង្ស័យថា អ្នកភូមិខ្ទៅពួយនេះចូលដៃចូលជើងជាមួយបារាំង ។

អំឡុងពេលនោះដែរ តំណាងឥស្សរៈខ្មែរ និងតំណាងឥស្សរៈលាវ ដែលបានធ្វើដំណើរទៅដល់ស្ថានបេសកកម្មទូតរបស់វៀតមិញ(សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម) នៅទីក្រុងបាងកក ប្រទេសសៀម ដើម្បីផ្ញើសារលិខិតរួមគ្នាមួយទៅជូនត្រាវ លី (TRYGVE LIE) ជនជាតិន័រវេយ៍ ជាអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានបង្កើតឡើងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ ដើម្បីសុំជួយអន្តរាគមន៍ឲ្យប្រទេសបារាំង ប្រគល់ឯករាជ្យដល់ប្រទេសខ្មែរ និងលាវ វិញ ។

នៅដើមខែមករា ឆ្នាំ១៩៤៧ តំណាងពួកវៀតមិញ នៅក្រុងបាងកក ក៏បានផ្ញើសារ

## របត់នយោបាយ

លិខិតមួយ ស្តីពីបញ្ហាទាមទារឯករាជ្យនេះ ទៅជូនអេវិន អែហ្វ ស្តេនតុន (EDWIN F STANTON) ជាតំណាងសហរដ្ឋអាមេរិក នៅក្រុងបាងកក ផងដែរ។

បន្ទាប់ពីបានទទួលសារលិខិតនោះមក តំណាងសហរដ្ឋអាមេរិក នៅក្រុងបាងកករូបនេះ ក៏បានទទូចឲ្យក្រសួងការបរទេសសហរដ្ឋអាមេរិក ធ្វើយ៉ាងណា សូមឲ្យអង្គការសហប្រជាជាតិ គិតគូរពីបញ្ហាឯករាជ្យនៅឥណ្ឌូចិននេះឲ្យបានឆាប់រហ័សផង ព្រោះបើពុំដូច្នេះទេ នឹងមានបញ្ហារីករវធ្ងន់ធ្ងរនៅឥណ្ឌូចិន ថែមទៀតជាមិនខាន។

ប៉ុន្តែក្រសួងការបរទេសអាមេរិក បានប្រាប់មកតំណាងរបស់ខ្លួននៅក្រុងបាងកកវិញថា គួរតែបញ្ជូនសារលិខិតទាំងអស់នោះ ទៅឲ្យម្ចាស់ដើមគេវិញ។

# ២៦
# នរណាសម្លាប់មេខ្មែរឥស្សរៈរស់ យឿន និងម៉ី ភូរិន្ទ ?

នៅក្នុងខែឧសភា ឆ្នាំ១៩៤៧ សមាជិកគណៈកម្មាធិការរួមជាតិ២នាក់ គឺរស់ យឿន និងម៉ី ភូរិន្ទ ដែលជាមនុស្សជំនិតរបស់ប៉ុក គុណ ហៅតាត្រឡាច ( ឪពុកមាប៊ុណ្ណ ចន្ទម៉ុល ) ត្រូវរងការបាញ់សម្លាប់យ៉ាងអាថ៌កំបាំងបំផុត។

ក្រោយការបាញ់សម្លាប់នោះ ប្រហែល៤ថ្ងៃ ទើបដំណឹងនេះបានឮទៅដល់ប៉ុក គុណ ហៅតាត្រឡាច ដែលកំពុងស្នាក់នៅឯក្រុងបាងកក។

ពេលនោះ ប៉ុក គុណ ក៏បានដាក់ពាក្យបណ្ដឹងទៅតម្រួតសៀម ពីករណីឃាតកម្មដ៏អាថ៌កំបាំងនេះ ហើយគាត់បានបញ្ជាឲ្យប៊ុណ្ណ ចន្ទម៉ុល ជាក្មួយ និងសហការី៣នាក់ទៀត ទៅពិនិត្យសាកសពមេឥស្សរៈទាំង២នាក់នោះ ដោយមានតម្រួតសៀមទៅជាមួយដែរ។

ផ្ទះរបស់មេឥស្សរៈទាំង២នាក់នេះ ស្ថិតនៅចម្ងាយពីគ្នាប្រមាណ៥ម៉ែត្រ។ ប៊ុណ្ណ ចន្ទម៉ុល ក៏សុំគាស់សាកសពនោះមើលឲ្យច្បាស់ ដោយខំប្រឹងកាប់គាស់ដីកាយផ្នូរសពរស់ យឿន ដែលហើមស្អុយខ្លាំងទៅហើយនោះ តែម្នាក់ឯង និងបានយកម៉ាស៊ីនថតរូបទៅថតសាកសពជាច្រើនប៉ុស្តិ៍។

បន្ទាប់មក គាត់ក៏សុំលើកសាកសពម៉ី ភូរិន្ទ ចេញពីផ្នូរ ដើម្បីយកមកពិនិត្យ និងថតរូបបន្ថែមទៀត ប៉ុន្តែតម្រួតសៀម ប្រាប់ថា ថ្នាក់លើរបស់គេគ្រាន់តែឲ្យមកពិនិត្យមើលសាកសពតែប៉ុណ្ណោះ គឺមិនឲ្យថតរូបទេ។ តែបើបានជាជ្រុលថតសពហើយ ថតបុណ្ណឹងចុះ តែកុំថតបន្តទៀត ហើយពួកតម្រួតសៀម ក៏ធ្វើជាសុំហ្វីលដែលថតហើយនោះទុក ដើម្បីយកទៅផ្ដិត ក៏យកទៅបាត់រហូតទៅ។

ក្រោយមក រឿងអាថ៌កំបាំងឃាតកម្មទៅលើសមាជិកគណៈកម្មាធិការរួមជាតិទាំង២នាក់នោះ ត្រូវបានពួកសៀម បំបាត់សូន្យឈឹង ហើយចាប់ពីពេលនោះមក ដាប ឈួន ក៏ផ្ដាច់ទំនាក់ទំនងជាមួយប៉ុក គុណ ហៅតាត្រឡាច ផងដែរ។

របត់នយោបាយ

ទាក់ទងករណីឃាតកម្មទៅលើសមាជិកគណៈកម្មាធិការរួមជាតិ ទាំង២នាក់នោះ ប៊ុណ្ណ ចន្ទម៉ុល បានចោទប្រកាន់ថា ដាប ឈួន បានគប់គិតគ្នាជាមួយពួកសៀម ដែលជាមេដឹកនាំកំពូលរបស់គណៈកម្មាធិការរួមជាតិ (គ.រ.ជ) នោះ សម្លាប់រស់ យឿន និងមីកូរិន្ទ ដោយសារមានបញ្ហាទំនាស់ផ្ទៃក្នុង ពិសេសគឺដោយសារខឹងមេឥស្សរៈទាំង២នាក់នេះ ហ៊ានប្រឆាំងនឹងផែនការរបស់ពួកសៀម ដែលឲ្យពួកមេឥស្សរៈទាំងអស់នៅក្នុងគណៈកម្មាធិការរួមជាតិ (គ.រ.ជ) របស់ខ្លួន លួចធ្វើសកម្មភាពឆក់ប្លន់លុយកាក់មាសប្រាក់ពីប្រជារាស្ត្រខ្មែរ ដើម្បីយកលុយកាក់មកទ្រទ្រង់ដល់ចលនាតស៊ូប្រឆាំងនឹងបារាំងនោះ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៤៧ នាយករដ្ឋមន្ត្រីថៃ ព្រីឌី ផាណុំយ៉ុង ត្រូវពួកឧត្តមសេនីយ៍ ភិបុល សង្គ្រាម ធ្វើរដ្ឋប្រហារទម្លាក់ចេញពីអំណាចមក កិច្ចសហការរវាងប្រទេសថៃ និងពួកវៀតមិញ ក៏ត្រូវបានបញ្ចប់ដែរ។

បន្ទាប់ពីមានករណីឃាតកម្មទៅលើសមាជិកគណៈកម្មាធិការរួមជាតិទាំង២នាក់នោះមក ព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី, ម៉ី ផូ, ហែម សាវ៉ាង និងម៉ៅ សារួត ក៏បានដកខ្លួនចេញពីសមាជិកគណៈកម្មាធិការរួមជាតិ (គ.រ.ជ) ដែលរដ្ឋាភិបាលថៃ ជួយបង្កើតឡើងនោះដែរ។

បន្ទាប់មកទៀត ស៊ីវ ហេង ក៏បានដកខ្លួនចេញដែរ ហើយនាំកងទ័ពទៅបោះទីតាំងនៅភាគខាងត្បូងខេត្តបាត់ដំបង ដើម្បីសហការជាមួយកងទ័ពវៀតមិញ ម្តងវិញ។

ចំណែកសមាជិកគណៈកម្មាធិការរួមជាតិម្នាក់ទៀតឈ្មោះប្រាក់ សារិន ក៏បានដកខ្លួនចេញ ដោយធ្វើដំណើរទៅសហការជាមួយពួកវៀតមិញ នៅឯខេត្តស្វាយរៀង។

សមាជិកគណៈកម្មាធិការរួមជាតិ (គ.រ.ជ) ម្នាក់ទៀត ក៏បាននាំកងទ័ពខ្លួន ជាង ២០០នាក់ ទៅចុះចូលជាមួយអាជ្ញាធរបារាំង នៅប៉ោយប៉ែត។

ជាមួយគ្នានោះដែរ សមាជិកគណៈកម្មាធិការរួមជាតិ (គ.រ.ជ) ម្នាក់ផ្សេងទៀត ក៏បាននាំកងទ័ពខ្លួន ជាង២០០នាក់ទៀតដែរ ទៅចុះចូលជាមួយពួករាជការខ្មែរ-បារាំង នៅឯខេត្តកំពង់ឆ្នាំង។

នៅក្នុងឆ្នាំ១៩៤៧នោះដែរ ទូ សាមុត បានបង្កើតសាលានយោបាយនៅក្នុងព្រៃ ដើម្បីបើកវគ្គរៀនសូត្រជាបន្តបន្ទាប់ ដល់អ្នកចូលរួមធ្វើបដិវត្តន៍រាប់រយនាក់ ឲ្យយល់ដឹងពីសភាពការណ៍សាកលលោក, សភាពការណ៍កម្ពុជា, ការតស៊ូវណ្ណៈ, ការកេងប្រវ័ញ្ចរបស់វណ្ណៈជិះជាន់មកលើប្រជាជន កសិករ កម្មករ ជាដើម ។

ទូ សាមុត បានលើកឡើងតាមទ្រឹស្តីកុម្មុយនិស្តថា វណ្ណៈកម្មករ គឺជាគ្រឹះនៃវណ្ណៈដឹកនាំ ។ ឯបញ្ញាជន គ្រូបង្រៀន សិស្សនិស្សិត កសិករ ជាវណ្ណៈបដិវត្តន៍ ហើយនាយទុនខ្លះក៏ជួយដល់បដិវត្តន៍ដែរ។ ឯវណ្ណៈមិនបដិវត្តន៍ គឺពួកសក្តិភូមិ, ពួកប្រតិកិរិយា និងពួកអព្យាក្រឹតនិយម។

នៅចុងខែឧសភា ឆ្នាំ១៩៤៧ កងទ័ពបារាំង បានបើកប្រតិបត្តិការសងសឹក បោសសម្អាតពួកឥស្សរៈជាទ្រង់ទ្រាយធំនៅទូទាំងប្រទេស។

វរសេនីយ៍យេស ហ្គ្រាស ( Yes Gras) ជានាយទាហានជាន់ខ្ពស់របស់ប្រទេសបារាំង បានឲ្យដឹងថា នៅក្នុងប្រតិបត្តិការសងសឹក បោសសម្អាតនោះ ចលនាតស៊ូឥស្សរៈប្រមាណ៥០០នាក់ ត្រូវបានកម្ទេច និងរឹបអូសអាវុធបានចំនួន១៣៦ដើម ។

ប៉ុន្តែ យ៉េស ហ្គ្រាស ក៏បានដឹងដែរថា ដោយឡែក ចលនាតស៊ូឥស្សរៈនៅប៉ែកពាយ័ព្យប្រទេស កងទ័ពបារាំងមិនទាន់ធ្វើការបង្ក្រាបបាននៅឡើយទេ ដោយសារពួកនេះមានការគាំទ្រពីពួកអាជ្ញាធរសៀម និងពួកវៀតមិញ។ មិនតែប៉ុណ្ណោះ ចលនានោះថែមទាំងមានការរីកធំជាត់ឡើងៗ ដែលអាចបង្កជាការគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរមួយសម្រាប់កម្ពុជាទៀតផង។

វរសេនីយ៍យេស ហ្គ្រាស ( Yes Gras ) បានធ្វើការប៉ាន់ស្មានថា នៅក្នុងខេត្តបាត់ដំបង សៀមរាប និងតាមជួរភ្នំដងរែក មានកងទ័ពឥស្សរៈប្រដាប់ដោយអាវុធគ្រប់ដៃប្រមាណ១២០០នាក់ និងកងទ័ពវៀតមិញ ចំនួនប្រមាណ២០០នាក់ ផងដែរ។

នៅក្នុងរយៈពេល៦ខែ ចុងឆ្នាំ១៩៤៧ ផ្នែកស៊ើបការណ៍សម្ងាត់របស់បារាំង បានរាយការណ៍ថា កងកម្លាំងចម្រុះរបស់វៀតមិញ និងលាវ ក៏បានបោះទីតាំងនៅតាមមូលដ្ឋាននានា ជាច្រើន នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប ដោយបានសហការជាមួយកងទ័ព

## របត់នយោបាយ

សៀម ប្រមាណ៤០០នាក់ ដឹកនាំដោយជនកុម្មុយនិស្តសៀមម្នាក់ ដែលបានរត់ចេញពីប្រទេសថៃ ក្រោយពីព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់នាយករដ្ឋមន្ត្រីសៀម ព្រីឌី ផាណុំយ៉ុង ពីខែវិច្ឆិកា ឆ្នាំ១៩៤៧នោះ ។

នៅដំណាច់ឆ្នាំ១៩៤៧ សឺង ង៉ុកមិញ បានបង្កើតគណៈកម្មាធិការរំដោះមួយនៅភាគពាយ័ព្យប្រទេស ដឹកនាំដោយស៊ីវ ហេង។

ជាមួយគ្នានោះ សឺង ង៉ុកមិញ បានចាត់តាំងឲ្យអតីតព្រះសង្ឃមួយអង្គឈ្មោះ កែវ មុនី ដែលទើបតែចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិនថ្មីៗ ឲ្យដើរប្រមូលកម្លាំងតាមភូមិស្រុកនានា បង្កើតជាកងទ័ពអ្នកតស៊ូនៅក្នុងខេត្តព្រៃវែង ។

# ២៧
# គណៈកម្មាធិការរំដោះប្រជាជនខ្មែរ



**សឺង ង៉ុកមិញ និង ហូ ជីមិញ**

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៤៨ ចលនាតស៊ូខ្មែរឥស្សរៈចម្រុះនិន្នាការនយោបាយ នៅប៉ែកខាងលិចប្រទេស បានរួបរួមគ្នាជាថ្មីម្តងទៀត បង្កើតអង្គការមួយ ឲ្យឈ្មោះថា គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (Khmer People Liberation Committee ហៅកាត់ថា KPLC ) ដែលហៅជាភាសាបាលីថា គណៈមុតៈគាហៈមជ្ឈិមនគរខ្មែរ។

គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) ឬគណៈមុតៈគាហៈមជ្ឈិមនគរខ្មែរ នេះ មានសមាជិក១១នាក់ រួមមាន៖ ដាប ឈួន , ម៉ី ផូ ,ស៊ីវ ហេង ,ហុង ឈុន , លាវ កែវមុនី, ស្រីឈ្មោះលាត មួន (ម៉ែមួន), កៅ តក់, ហែម សាវ៉ាង និងម៉ៅ សារួត ជាដើម។

ដាប ឈួន ដែលជាមេឥស្សរៈល្បីជាងគេនៅទីនោះ ត្រូវបានតែងតាំងជាប្រធាន គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) នេះ និងជាមេបញ្ជាការកងទ័ព, ម៉ៅ សារួត ជាប្រធាននយោបាយកងទ័ព និងហែម សាវ៉ាង ជាប្រធានកិច្ចការបរទេស។

គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC ) នេះ មានកងទ័ពសរុប ចំនួន

ប្រមាណ៨០០នាក់។

ចំណែកព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី មិនព្រមចូលរួមក្នុងគណៈកម្មាធិការដែលទើបបង្កើតថ្មីនេះទេ ដោយទ្រង់យល់ឃើញថា គណៈកម្មាធិការនេះ លម្អៀងទៅខាងពួកវៀតមិញ ។

មិនខុសពីការវាយតម្លៃរបស់ព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី នោះទេ ព្រោះពាក្យពេចន៍ និងខ្លឹមសារគោលការណ៍របស់គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) នេះ មិនខុសពីគោលការណ៍របស់ពួកកុម្មុយនិស្តវៀតមិញ ប៉ុន្មានឡើយ។

គោលការណ៍របស់គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) បានចែងថា ពួកចក្រពត្តិនិយមបារាំង កំពុងតែចុះខ្សោយ។ ពួកវានឹងត្រូវស្លាប់ក្រោមការតស៊ូប្រយុទ្ធរបស់ប្រជាជនវៀតណាម កម្ពុជា និងលាវ។ ដូច្នេះចាំបាច់យើងត្រូវតែបង្កើតរណសិរ្សឥណ្ឌូចិនមួយជាបន្ទាន់ ហើយប្រជាជនខ្មែរត្រូវតែដើរតាមគន្លងផ្លូវដែលត្រួសត្រាយដោយពួកអ្នកប្រជាធិបតេយ្យ និងពួកអ្នកប្រឆាំងនឹងពួកអាណានិគមនិយម។

ពោលគឺគោលការណ៍របស់គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) នេះ មិនខុសពីគោលការណ៍របស់ពួកកុម្មុយនិស្តវៀតមិញ ប៉ុន្មានឡើយ។

កាន់តែច្បាស់ជាងនេះទៅទៀតនោះ ដាប ឈួន ជាមេដឹកនាំគណៈកម្មាធិការនេះ និងហូ ជីមិញ មេដឹកនាំពួកវៀតមិញ ក៏បានផ្ញើសារជូនពរគ្នាទៅវិញទៅមកទៀតផង។

នៅក្នុងថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៤៨ កងទ័ពចម្រុះរបស់គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) ជាច្រើនកងអនុសេនាធំ ដឹកនាំដោយកៅ តក់, ហុង ឈុន និងលាវកែវមុនី បានពួនស្ទាក់វាយប្រហារទៅលើខ្សែរថភ្លើងមួយខ្សែពីភ្នំពេញ ទៅបាត់ដំបង ធ្វើឲ្យអ្នកដំណើរតាមរថភ្លើងនោះស្លាប់ និងរងរបួសជាច្រើននាក់ ក្នុងនោះក៏មានទាហានបារាំង ១០នាក់ ត្រូវបានពួកគេសម្លាប់ផងដែរ។

នៅដើមឆ្នាំ១៩៤៨ សឺង ង៉ុកមិញ ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការកិច្ចការឃោសនារបស់កងទ័ពខ្មែរ និងវៀតមិញ នៅប៉ែកនិរតីប្រទេស។

នៅចុងឆ្នាំ១៩៤៨ កម្លាំងចលនាតស៊ូឥស្សរៈបានរួបរួមគ្នាបង្កើតជាគណៈកម្មាធិការយោធាមួយនៅទូទាំងប្រទេស និងបានបែងចែកផ្នែកយោធាជា៤ភូមិភាគ គឺភូមិភាគអាគ្នេយ៍ ដឹកនាំដោយ កែវ មុនី, ភូមិភាគឦសាន ដឹកនាំដោយ សឺន ស៊ីចាន់ , យោធភូមិភាគនិរតី ដឹកនាំដោយ សឺង ង៉ុកមិញ និងយោធភូមិភាគពាយ័ព្យ ដឹកនាំដោយ ដាប ឈួន ដែលពេលនោះ គាត់ជាប្រធានគណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) ផងដែរ។

នៅក្នុងជួរគណៈកម្មាធិការយោធានៅទូទាំងប្រទេសនេះ លើកលែងតែដាប ឈួនចេញ គឺសឺង ង៉ុកមិញ , សឺន ស៊ីចាន់ និងកែវ មុនី សុទ្ធតែជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន។

នៅភូមិភាគពាយ័ព្យដែលដឹកនាំដោយដាប ឈួន នោះ ក៏មានមេដឹកនាំសាខាបក្សកុម្មុយនិស្តឥណ្ឌូចិនមួយនៅទីនោះដែរ ។

នៅក្នុងឆ្នាំ ១៩៤៨ ដោយឃើញចលនាខ្មែរឥស្សរៈចេះតែបែកបាក់ បាញ់សម្លាប់ព្រោះតែម្នាក់ៗចង់ធ្វើធំនោះ ប៊ុណ្ណ ចន្ទម៉ុល ក៏សម្រេចចិត្តបោះបង់ការតស៊ូ ចូលទៅស្រុកវិញ។ ពេលមកដល់ភ្នំពេញវិញ ដោយគាត់ធ្លាប់ឃើញនៅបាងកក រថយន្តក្រុងមានអ្នក-ដំណើរជិះពេញ គាត់ដែលសល់ប្រាក់កាសបន្តិចបន្តួច បានចូលហ៊ុនជាមួយបងប្អូនទិញរថយន្តក្រុងចំនួនបីគ្រឿង ដើម្បីរកស៊ីដឹកអ្នកដំណើរពីផ្សារថ្មី ទៅតាមផ្លូវមាត់ទន្លេ រួចបត់ទៅលិច ដល់ផ្លូវមុនីវង្ស ទើបបត់មកផ្សារថ្មីវិញ។ ប៉ុន្តែរបរនេះមិនកាក់កបប៉ុន្មានទេ ដោយអ្នកដំណើរភាគច្រើនចូលចិត្តជិះស៊ីក្លូវិញ ព្រោះវារហ័សទាន់ចិត្តជាង។

បន្ទាប់មក ប៊ុណ្ណ ចន្ទម៉ុល ក៏បែកគំនិតរកស៊ីជាអ្នកដើរថតរូបវិញម្តង ព្រោះកាលណោះ រាជការបង្កើតឲ្យមានអត្តសញ្ញាណប័ណ្ណ ដូច្នេះប្រជារាស្ត្រដែលគ្រប់វ័យទាំងអស់ត្រូវថតរូប ដើម្បីយកទៅបិតអត្តសញ្ញាណប័ណ្ណនោះ។ គាត់បានខ្ចីរថយន្តហ្ស៊ីបមួយរបស់បងគាត់ឈ្មោះ ប៊ុណ្ណ ចន្ទថាត់ រស់នៅទន្លេបិទ បើកដើររកស៊ីថតរូបប្រជារាស្ត្រដែលគ្រប់វ័យត្រូវធ្វើអត្តសញ្ញាណប័ណ្ណ ពីរនាក់ប្អូនប្រុសពៅគាត់ឈ្មោះ ប៊ុណ្ណ ចន្ទថាណារិត នៅគ្រប់ច្រកល្ហក តាំងពីខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តបាត់ដំបង។

តែពេលទៅដល់ខេត្តបាត់ដំបង ស្រាប់តែមានមេឥស្សរៈ ដែលទើបកើតថ្មីម្នាក់

## របត់នយោបាយ

ឈ្មោះហ៊ុលវង្ស អានុភាព បានប្រាប់កូនចៅដៃជើងគេថា បើឃើញគាត់ពីរនាក់ប្អូនប្រុស ចូលទៅក្នុងតំបន់ដែលគេត្រួតត្រា ត្រូវចាប់យកទៅសម្លាប់ចោល កុំត្រាប្រណីឡើយ។

ប៊ុណ្ណ ចន្ទម៉ុល ចេះតែនឹកឆ្ងល់ថា គាត់មានរឿងអីបានជាមេឥស្សរៈឈ្មោះ ហ៊ុលវង្ស អានុភាព នេះ រកសម្លាប់គាត់បែបនេះ?

នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៤៩ នៅប៉ែកអាគ្នេយ៍ប្រទេស កងទ័ពខ្មែរឥស្សរៈប្រមាណ ៣០០នាក់ ដឹកនាំដោយពុត ឆាយ, វិញ ធិញ (ជាជនជាតិវៀតណាម) និងមនុស្សជំនិត របស់សឺង ង៉ុកមិញ ២នាក់ទៀត ព្រមទាំងងិន ហោ និងកែវ មុនី មកពីខេត្តព្រៃវែង បាន បើកការវាយប្រហារទៅលើសាលាស្រុកលើកដែក ខេត្តកណ្ដាល។

ពេលនោះ កែវ មុនី ត្រូវរងរបួស ហើយត្រូវពួកទាហានរាជការខ្មែរ-បារាំង ចាប់ខ្លួន បាន។ ប៉ុន្តែជាង៣ខែក្រោយមក ដោយមានការស្នើសុំពីមេខ្មែរឥស្សរៈម្នាក់ ដែលទៅចុះ ចូលជាមួយរាជការខ្មែរ-បារាំងនោះ កែវ មុនី ក៏ត្រូវបានអាជ្ញាធររាជការខ្មែរ-បារាំង ដោះលែង វិញ ហើយគាត់ក៏បានត្រឡប់ទៅដឹកនាំតស៊ូប្រឆាំងនឹងបារាំង បន្តទៀត។

ចំណែកកងទ័ពខ្មែរឥស្សរៈ កំពុងឈរជើងនៅតំបន់ត្រើយខាងលិចទន្លេបាសាក់ បាន ត្រៀមខ្លួនឆ្លងទៅតំបន់ខាងលិចទន្លេបាសាក់ ដើម្បីឡោមព័ទ្ធទីក្រុងភ្នំពេញ ។

ពេលនោះ សូម្បីតែស្ទឹងព្រែកត្នោត ដែលនៅក្បែរទីរួមខេត្តកណ្ដាល ក៏រងនូវការ គំរាមកំហែងរបស់ពួកខ្មែរឥស្សរៈដែរ ហើយទីប្រជុំជនកំពង់កន្ទួត ក្នុងស្រុកកណ្ដាលស្ទឹង ក៏មានមុខសញ្ញាវាយប្រហាររបស់ពួកខ្មែរឥស្សរៈផងដែរ។

នៅក្នុងស្រុកខ្សាច់កណ្ដាល និងស្រុកល្វាឯម ដែលស្ថិតនៅខាងកើតទន្លេមេគង្គ ពួក ខ្មែរឥស្សរៈបានចូលទៅធ្វើសកម្មភាពពាសពេញ ។

កម្លាំងប៉ូលិសរាជការខ្មែរ-បារាំង នៅវិហារសួគ៌ ត្រូវថ្នាក់លើពួកគេបញ្ជាឲ្យដកថយពី ប៉ុស្តិ៍ ព្រោះខ្លាចពួកខ្មែរឥស្សរៈវាយដណ្ដើមយកអាវុធ។

បើតាមប្រភពពីអាជ្ញាធររាជការខ្មែរ-បារាំង បានឲ្យដឹងថា ពុត ឆាយ គឺជាមនុស្ស ពាលាអាវាសែ គិតតែលេងល្បែងស៊ីសង ផល់មាន់ និងលួចប្លន់ប្រជារាស្ត្រតែប៉ុណ្ណោះ។

នៅក្នុងឆ្នាំ១៩៣៤ ពុត ឆាយ ត្រូវអាជ្ញាធរចាប់ដាក់គុករយៈពេល១ខែ ពីបទលួច។

បន្ទាប់មកទៀត នៅក្នុងឆ្នាំ១៩៤៤ ពុត ឆាយ ត្រូវជាប់ឃុំក្នុងជំរំកែប្រែរយៈពេល១ឆ្នាំ ពីបទលេងល្បែងស៊ីសង។

នៅក្នុងខែកញ្ញា ឆ្នាំ១៩៤៨ ពុត ឆាយ បានប្រមូលបក្ខពួកបង្កើតជាចលនាខ្មែរឥស្សរៈ ដែលមានកងទ័ពមួយក្រុមតូចប៉ុណ្ណោះ។

មួយខែក្រោយមក គឺនៅក្នុងខែតុលា ឆ្នាំដដែលនោះ ពុត ឆាយ បានដឹកនាំកម្លាំង ពួនស្ទាក់បាញ់សម្លាប់កងរក្សាសន្តិសុខខ្មែរ និងប៉ូលិសបារាំង ចំនួន៤នាក់។

ក្រោយហេតុការណ៍បាញ់សម្លាប់នោះ អាជ្ញាធរបារាំង ក៏បានប្រកាសផ្តល់រង្វាន់ជាទឹកប្រាក់ចំនួន១ម៉ឺនរៀល ចំពោះជនណាដែលចាប់បានពុត ឆាយ យកមកប្រគល់ឲ្យពួកគេ។ ពេលនោះហើយ ដែលធ្វើឲ្យឈ្មោះរបស់ពុត ឆាយ កាន់តែល្បីរន្ទឺខ្លាំងឡើងៗបន្តិចម្តងៗ។

នៅក្នុងខែសីហា ឆ្នាំ១៩៤៨ មាននាយទាហានថ្នាក់អនុសេនីយ៍ម្នាក់ឈ្មោះ ហូ ធិញ ក៏បានរត់ចោលជួរទាហានបារាំង ជាមួយកូនទាហាន៤នាក់ទៀត ទៅចូលរួមជាមួយចលនាតស៊ូខ្មែរឥស្សរៈសឹង ង៉ុកមិញ នៅខេត្តកំពត ហើយគាត់ត្រូវបានឲ្យចូលរួមដឹកនាំចលនាតស៊ូនៅក្នុងទីតាំងឈរជើងរបស់កងទ័ពវៀតមិញ នៅភ្នំដំរីរមៀល។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៤៩ តាមរបាយការណ៍សម្ងាត់មួយរបស់បារាំង បានឲ្យដឹងថា ឈ្មោះជា កែវ ជាអតីតម្ចាស់ផ្សារឯកជនមួយនៅទីក្រុងភ្នំពេញ ដែលចេះនិយាយ៥ភាសា គឺ៖ ខ្មែរ វៀតណាម បារាំង ថៃ និងលាវ បានក្លាយទៅជាមេទ័ពឥស្សរៈខ្មែរ-វៀតមិញដ៏ល្បីល្បាញម្នាក់ដែរ។

ជា កែវ នេះ ជាសិស្សគណរបស់ព្រះសង្ឃពុទ្ធសាសនាមហាយានវៀតណាមមួយអង្គ ព្រះនាមតាយ ណាម គង់នៅល្អាងភ្នំញ៉ាបាង ស្រុកចូវដុក ខេត្តមាត់ជ្រូក ដែលល្បីថាចេះមន្តអាគមខ្លាំងពូកែ និងចេះបំបាំងខ្លួនផងនោះ មានព្រះជន្មរហូតដល់១០០វស្សា ទើបសុគត។

ចំណែកជា កែវ ជាសិស្សគណ ក៏ល្បីថាខ្លាំងពូកែខាងមន្តអាគមនេះដែរ ក៏ត្រូវបាន

## របស់នយោបាយ

ប្រជារាស្ត្រខ្មែរ និងវៀតណាម ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា នៅខេត្តកណ្តាល និងខេត្តតាកែវ នាំគ្នាជឿជាក់ និងគោរពកោតខ្លាចបំផុត ។

ដោយសារល្បីថា ជា កែវ នេះ ចេះមន្តអាគមខ្លាំងពូកែ ក៏មានអ្នកស្រុកជាច្រើនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពគាត់ ហើយមេដឹកនាំវៀតមិញ បានផ្តល់ជំនួយជាគ្រឿងអាវុធមួយចំនួនដល់កងទ័ពរបស់គាត់ផងដែរ តែអាវុធមួយចំនួនទៀត គឺគាត់ជាអ្នករកលុយទិញដោយខ្លួនឯង ។

តាមរបាយការណ៍របស់កម្លាំងសម្ងាត់បារាំង បានឲ្យដឹងថា ក្រោយមក ជា កែវ បានបង្កើតកងទ័ពរបស់គាត់នៅក្នុងស្រុកចំនួន៧ នៅប៉ែកខាងត្បូងនៃខេត្តកណ្តាល និងប៉ែកខាងលិចនៃខេត្តតាកែវ ដែលមានកម្លាំងសរុបប្រមាណ២៥០០នាក់ តែអាវុធមានតិចតួចក្នុងនោះ មានកងទ័ពពិសេសប្រដាប់ដោយអាវុធទំនើបៗ ចំនួន៤០នាក់ ជាអ្នកតាមហែហមការពារគាត់ផងដែរ។

ជា កែវ បានបែងចែកកងទ័ពគាត់ជាក្រុមតូចៗ មានគ្នាពី១០ ទៅ១៥នាក់ ដោយខ្លះមានភារកិច្ចតាមដានសកម្មភាពពួករាជការខ្មែរ-បារាំង នៅតាមឃុំ ស្រុក។ ខ្លះជាអ្នកស៊ើបការណ៍ពីកងទ័ព និងអាជ្ញាធរខ្មែរ-បារាំង និងខ្លះទៀតជាអ្នកដើររៃអង្គាស និងទារពន្ធប្រជារាស្ត្រនៅតាមភូមិស្រុកនានា។

នៅក្នុងខេត្តតាកែវ ដែលជាទូទៅ ប្រជារាស្ត្រមានជីវភាពក្រីក្រនោះ ជា កែវ តម្រូវឲ្យទារពន្ធក្នុងមួយខ្នងផ្ទះ ចំនួន៦រៀល។

ចំណែកនៅក្នុងខេត្តកណ្តាល ដែលប្រជារាស្ត្រភាគច្រើនមានជីវភាពធូរជារបន្តិច ជា កែវ តម្រូវឲ្យបង់ពន្ធក្នុងមួយខ្នងផ្ទះ ពី១២ ទៅដល់១០០រៀលឯណោះ គឺអាស្រ័យលើការពិនិត្យឃើញមាន ឬក្រជាក់ស្តែង។

ខុសគ្នាពីនៅខេត្តព្រៃវែង មេដឹកនាំឥស្សរៈខ្មែរ-វៀតមិញ ទូ សាមុត និងអនុប្រធានរបស់គាត់ម្នាក់ទៀតជាជនជាតិវៀតណាម បានទារពន្ធជាមធ្យម ត្រឹមតែចំនួន៤រៀលប៉ុណ្ណោះក្នុងមួយខ្នងផ្ទះ។

របាយការណ៍សម្ងាត់របស់បារាំងមួយផ្សេងទៀត បានឲ្យដឹងថា អតីតពលបាលនៅក្នុងជួរកងទ័ពរាជការខ្មែរ-បារាំង ម្នាក់ឈ្មោះ ណុប ប៉ែន ក៏បានរត់ចោលជួរ ទៅចុះចូលជាមួយពួកវៀតមិញ និងបានប្រមែប្រមូលអ្នកស្រុកនៅប៉ែកខាងជើងនៃខេត្តកំពត និងនៅខាងត្បូងនៃខេត្តតាកែវ បង្កើតជាកងទ័ពប្រដាប់ដោយអាវុធគ្រប់ដៃ បានចំនួន១០០នាក់ផងដែរ។

ក្រៅពីណុប ប៉ែន ក៏មានមេខ្មែរឥស្សរៈ២នាក់ទៀតគឺ មាស វង្ស ជាខ្មែរកម្ពុជាក្រោម និងញ៉ែម ស៊ុន ជាពលបាលទោនៅក្នុងជួរកងទ័ពបារាំង ត្រូវបានសឺន ស៊ីចាន់ អូសទាញឲ្យមកចូលរួមជាមួយចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ ផងដែរ។

ចំណែកនៅខេត្តកំពង់ស្ពឺ មានកងទ័ពខ្មែរឥស្សរៈប្រមាណ៨០០នាក់ ដឹកនាំបញ្ជាដោយហូ ធិញ ។

# ២៨
# គណៈកម្មាធិការរំដោះជាតិខ្មែរ

នៅដើមឆ្នាំ១៩៤៩ គណៈកម្មាធិការរំដោះប្រជាជនខ្មែរ (KPLC) ឬគណៈមុត្តៈគាហៈមជ្ឈិមនគរខ្មែរ បានប្តូរឈ្មោះមកជា "គណៈកម្មាធិការរំដោះជាតិខ្មែរ (Khmer National Liberation Committee ហៅកាត់ថា KNLC ) ឬគណៈកម្មាធិការខ្មែរកសាងជាតិ" វិញ។

គណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) នេះ មានសមាជិក៧រូប ដោយដាប ឈួន នៅតែជាប្រធានគណៈកម្មាធិការនេះ ។ ឯកៅ តក់ ត្រូវបានតែងតាំងជាអនុប្រធាន ។

យោងតាមការសរុបរបាយការណ៍របស់ចៅហ្វាយខេត្តនានាទូទាំងប្រទេស បានឲ្យដឹងថា នៅដើមឆ្នាំ១៩៤៩ កងទ័ពខ្មែរឥស្សរៈសរុបទាំងអស់ មានចំនួនប្រមាណ១០.៦០០ នាក់។ ប៉ុន្តែមន្ត្រីបារាំង បានបញ្ជាក់ថា តួលេខនេះដូចជាមានការពន្លើសពេកហើយ។

ក្នុងចំណោមចលនាខ្មែរឥស្សរៈទាំងនោះ ក៏មានចលនាតស៊ូខ្មែរឥស្សរៈមួយចំនួនទៀត ត្រូវបានពួកមន្ត្រីគណបក្សប្រជាធិបតេយ្យ ដែលកំពុងកាន់អំណាចជាអ្នកបង្កើតឡើងផងដែរ ។ តែកងទ័ពចលនាតស៊ូខ្មែរឥស្សរៈដែលពួកមន្ត្រីគណបក្សប្រជាធិបតេយ្យ បានលួចបង្កើតឡើងទាំងអស់នោះ មិនសូវមានទីតាំងមាំទាំ និងគ្មានអាវុធគ្រប់គ្រាន់ដែរ គឺកងទ័ពទាំងនោះគ្រាន់តែមានលក្ខណៈជាកងឈ្លបដែលលាក់ខ្លួននៅតំបន់ជនបទ និងព្រៃភ្នំប៉ុណ្ណោះ។

រាជការខ្មែរ-បារាំង បានធ្វើការប៉ាន់ស្មានថា មានកងទ័ពវៀតមិញ មិនដល់១០០០ នាក់ទេ ដែលចូលមកសហការជាមួយពួកតស៊ូខ្មែរឥស្សរៈទាំងនោះ។

ពេលនោះដែរ ឈ្មោះចាន់ ដារ៉ា អតីតអ្នកចូលរួមបាតុកម្មប្រឆាំងនឹងបារាំងនៅភ្នំពេញ កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤២ ហើយបានរត់គេចខ្លួនទៅបម្រើក្នុងជួរកងទ័ពជប៉ុន នៅខេត្តស្ទឹងត្រែង កាលពីពីឆ្នាំ១៩៤៥ នោះ ក៏បានបង្កើតកងទ័ពខ្មែរឥស្សរៈមួយក្រុមដែរ និងបានបោះទីតាំងឈរជើងនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជាមួយមេខ្មែរឥស្សរៈ

ម្នាក់ទៀតឈ្មោះ ងិន ហោ។

ចំណែកនៅស្រុកពាមជរ ដែលនៅជាប់ស្រុកកំពង់ត្របែក ក្នុងខេត្តព្រៃវែង នោះដែរ ក៏មានពួកខ្មែរឥស្សរៈប្រមាណ៥០នាក់ និងពួកវៀតមិញប្រមាណ១៣០នាក់ ក្នុងនោះមាន ស្រីក្មេងៗផងដែរ ហើយនៅភាគខាងជើងទីរួមខេត្តព្រៃវែង នៅតាមដងទន្លេតូច ក្នុងស្រុក ពារាំង មានកងទ័ពខ្មែរឥស្សរៈ និងវៀតមិញ ប្រមាណ៥០០នាក់ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៩ ចាន់ ដារ៉ា និងងិន ហោ បានដឹកនាំកម្លាំងរបស់ ខ្លួន៤០នាក់ ធ្វើការវាយប្រហារទៅលើប៉ុស្តិ៍ទាហានរាជការខ្មែរ-បារាំង ដែលទើបតែបង្កើត ថ្មីមួយ នៅក្នុងស្រុកពាមជរ តែមិនបានលទ្ធផលអ្វីទេ។

ក្រោយមកទៀត ពួកគាត់បានកេណ្ឌកម្លាំងអ្នកស្រុកប្រមាណ៧០នាក់ ដើម្បីធ្វើការ វាយប្រហារទៅលើទាហានរាជការខ្មែរ-បារាំង នោះជាថ្មីម្តងទៀត។

៣សប្តាហ៍ក្រោយការវាយប្រហារនោះ ចៅហ្វាយខេត្តព្រៃវែង បានរាយការណ៍ទៅ ថ្នាក់លើរបស់គាត់នៅទីក្រុងភ្នំពេញ ថា ពួកឥស្សរៈចម្រុះដែលប្រមូលផ្តុំគ្នាវាយប្រហារទៅលើ ប៉ុស្តិ៍ទាហានរាជការខ្មែរ-បារាំង នៅស្រុកពាមជរនោះ មានគ្នាពី១០០ ទៅ២០០នាក់ឯណោះ ។

នៅខេត្តព្រៃវែង មានចលនាតស៊ូខ្មែរឥស្សរៈច្រើនក្រុម ដឹកនាំដោយមេផ្សេងៗគ្នា ដូចជា អាចារ្យយីចាន់ ដារ៉ា, កែវ មុនី និងទូ សាមុត ជាដើម ។

អាចារ្យយី ជាអតីតអង្គរក្សរបស់ដាប ឈួន កាលនៅភាគខាងលិចប្រទេស ។ តែ ក្រោយមក គាត់បានរត់ចោលដាប ឈួន ហើយមកធ្វើជាសកម្មជនម្នាក់ របស់គណបក្ស ប្រជាធិបតេយ្យ នៅក្រុងភ្នំពេញ ។

នៅក្នុងឆ្នាំ១៩៤៩ អៀវ កើស មេដឹកនាំគណបក្សប្រជាធិបតេយ្យ និងជាប្រធាន រដ្ឋសភា បានចាត់តាំងគាត់ឲ្យទៅបង្កើតកងទ័ពស្វយ័តមួយនៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល ហើយគាត់បានបង្កើតកងទ័ពបានចំនួន៣០០នាក់ (គិតទាំងអ្នកគ្មានអាវុធភាគច្រើន) ។

តែអាចារ្យយី នេះ មិនត្រឹមតែដឹកនាំកងទ័ពគាត់វាយប្រហារទៅលើទីតាំងរដ្ឋបាល របស់រាជការខ្មែរ-បារាំងទេ គឺគាត់ថែមទាំងបានធ្វើការវាយប្រហារទៅលើកងទ័ពវៀតមិញ

## របត់នយោបាយ

ដើម្បីដណ្ដើមអាវុធ និងដុតកម្ទេចភូមិអ្នកនេសាទវៀតណាម ដែលតាំងនៅត្រើយខាងកើតទន្លេមេគង្គ ទៀតផង។

លើសពីនេះទៅទៀត សូម្បីតែវត្តខ្មែរណាដែលជាវត្តធម្មយុត្តិកនិកាយ ក៏គាត់ដុតកម្ទេចអស់មួយចំនួនដែរ។

នៅក្នុងខែឧសភា ឆ្នាំ១៩៤៩ អៀវ កើស មេដឹកនាំគណបក្សប្រជាធិបតេយ្យ ជាប្រធានរដ្ឋសភាដែលជាអ្នកចាត់តាំងអាចារ្យយី ឲ្យទៅបង្កើតកងទ័ពស្វយ័តនៅក្នុងស្រុកល្វាឯម កាលពីដំបូងទីនោះ បានធ្វើការព្រមានទៅអាចារ្យយី ថា ប្រជារាស្ត្រខ្មែរត្រូវរួបរួមគ្នាដើម្បីដណ្ដើមឯករាជ្យមកជូនប្រទេសជាតិ ដូច្នេះមិនត្រូវសម្លាប់គ្នាឯង មិនត្រូវដុតភូមិករអ្នកស្រុកនោះទេ ពិសេសត្រូវគោរពទីវត្តអារាមដែលជាកន្លែងសក្ការបូជា ឲ្យបានល្អ ។

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៤៩ គណៈប្រតិភូរបស់គណបក្សប្រជាធិបតេយ្យមួយក្រុម ដោយមានជនជាតិចិនម្នាក់ជាតំណាងបក្សកុម្មុយនិស្តចិន នៅទីក្រុងភ្នំពេញ រួមដំណើរផង បានធ្វើដំណើរទៅទស្សនកិច្ចជាសម្ងាត់នៅក្នុងតំបន់ដែលអាចារ្យយី ត្រួតត្រាគ្រប់គ្រង។

ពេលនោះ តំណាងបក្សកុម្មុយនិស្តចិនម្នាក់នោះ បានថ្លែងបញ្ជាក់ក្នុងនាមបក្សកុម្មុយនិស្តចិន ពីការគាំទ្ររបស់ខ្លួនចំពោះការតស៊ូរបស់អាចារ្យយី ផងដែរ។

៣ថ្ងៃក្រោយពីដំណើរទស្សនកិច្ចជាសម្ងាត់នោះ នៅក្នុងអង្គប្រជុំមួយនៅស្រុកល្វាឯម ក្រុមឥស្សរៈរបស់អាចារ្យយី ដែលមានគណបក្សប្រជាធិបតេយ្យ នៅពីក្រោយខ្នង បានបញ្ជាក់គោលជំហររបស់ខ្លួនថា យើងមិនត្រូវឲ្យពួកវៀតមិញ ចូលមកឈ្លានពានប្រទេសយើងទេ ហើយបើពួកគេតាំងខ្លួនជាស្នេហាជាតិ គឺត្រូវតែទៅស្នេហាជាតិនៅក្នុងប្រទេសគេទៅ។

៦ថ្ងៃក្រោយពីអាចារ្យយី ប្រជុំគ្នានៅស្រុកល្វាឯមនោះ ចៅហ្វាយខេត្តព្រៃវែង របស់រាជការខ្មែរ-បារាំង បានធ្វើរបាយការណ៍ថា អាចារ្យយី បានដឹកនាំកម្លាំងប្រមាណ៣០០នាក់ ធ្វើការវាយប្រហារនៅទីតាំងកងទ័ពវៀតមិញ ដែលស្ថិតនៅខាងជើងទីរួមខេត្តព្រៃវែង ឲ្យរត់ខ្ចាត់ខ្ចាយអស់។

មួយខែក្រោយមក កងទ័ពអាចារ្យយី ក៏បានប្រកាសថា ពួកគេបានសម្លាប់ជនជាតិ

វៀតណាម នៅក្នុងស្រុកពាមរក៍ អស់ជាច្រើននាក់ ទោះបីពួកជនជាតិវៀតណាមទាំងនោះ មិនមែនជាកងទ័ពវៀតមិញកុម្មុយនិស្តក៏ដោយ។

ពេលនោះ នៅក្នុងស្រុកបាភ្នំ មេខ្មែរឥស្សរៈឈ្មោះងិន ហោ ជាអ្នកដឹកនាំកងទ័ពខ្មែរ ៤០នាក់ និងមានកងទ័ពវៀតមិញ៨០នាក់ ។

នៅក្នុងស្រុកព្រៃវែង (សព្វថ្ងៃដូរឈ្មោះជាស្រុកស្វាយអន្ទរ) មានជនជាតិវៀតណាម ដើមកំណើតខ្មែរម្នាក់ ក៏បានដឹកនាំកងទ័ពខ្មែរ២០០នាក់ និងមានកងទ័ពវៀតមិញ ៥០នាក់ ទៀតដែរ។

ចំណែកនៅខេត្តស្វាយរៀង ក៏មានកងទ័ពចម្រុះខ្មែរ-វៀតមិញ ចំនួន២០០នាក់ ដឹកនាំដោយជនជាតិវៀតណាមម្នាក់ កាន់សាសនាការដាយ។

ក្រោយពេលព្រះមហាក្សត្រនរោត្តម សីហនុ ប្រកាសរំលាយសភាដែលមានតំណាង រាស្ត្ររបស់គណបក្សប្រជាធិបតេយ្យភាគច្រើនលើសលប់នោះចោល ក្នុងខែកញ្ញា ឆ្នាំ១៩៤៩ អាចារ្យឃី ត្រូវបានកងទ័ពរាជការខ្មែរ-បារាំង ចាប់ខ្លួនបាន ។

ទោះបីអាចារ្យឃី ជាមេឥស្សរៈម្នាក់ដែលប្រឆាំងនឹងពួកវៀតមិញ យ៉ាងប្តូរផ្តាច់ក៏ដោយ ក៏ត្រូវតុលាការរាជការខ្មែរ-បារាំង នៅក្រុងភ្នំពេញ ផ្តន្ទាទោសឲ្យគាត់ជាប់ពន្ធនាគារ រយៈពេល ១០ឆ្នាំ និងបង្ខំឲ្យធ្វើការជាទម្ងន់ដែរ។

នៅដើមឆ្នាំ១៩៤៩ ពុត ឆាយ បានដឹកនាំកងទ័ពធ្វើសកម្មភាពនៅខេត្តកណ្តាល និងតាកែវ។ ពេលនោះ គាត់បានដឹកនាំកម្លាំងធ្វើការវាយប្រហារទៅលើសាលាស្រុកបាទី មួយប្រាវ បង្កឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

ក្នុងខែកុម្ភៈ ឆ្នាំ១៩៤៩ ដាប ឈួន ក្នុងនាមជាប្រធានគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) បានបញ្ជាឲ្យស្ត្រីឈ្មោះលាត មួន (ម៉ែមួន) ជាសមាជិកគណៈកម្មាធិការនេះ ដែលពេលនោះ កំពុងឈរជើងនៅក្នុងតំបន់ជនបទមួយនៅក្នុងខេត្តសៀមរាប ឲ្យប្រមូល រទេះគោ និងរទេះក្របីរាប់សិបគ្រឿង មកដឹកអង្ករ និងត្រី យកទៅលក់នៅប្រទេសសៀម ដើម្បីយកលុយទៅទិញកាំភ្លើង៨០ដើម យកមកបំពាក់ឲ្យកម្លាំងតស៊ូរបស់គាត់ នៅប៉ែក

និរតីខេត្តបាត់ដំបង និងឲ្យគាត់ធ្វើយ៉ាងណាទាក់ទាញឲ្យទ្រង់ចន្ទរង្សី មកចូលរួមជាមួយ គណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) វិញផងដែរ។

ស្រីឈ្មោះលាត មួន (ម៉ែមួន) ដែលមានគំនិតចង់ឲ្យចលនាតស៊ូខ្មែរឥស្សរៈរួបរួម គ្នាវិញនោះ ក៏បានប្រឹងប្រែងធ្វើតាមបញ្ជារបស់ដាប ឈួន រហូតបានសម្រេច។

ប៉ុន្តែមិនយូរប៉ុន្មាន ដាប ឈួន មិនចោលចរិតដឹកនាំផ្តាច់ការ អាងអំណាចបុណ្យស័ក្តិ របស់ខ្លួន មិនស្តាប់មតិយោបល់នរណាទាំងអស់នោះ ធ្វើឲ្យមានការបែកបាក់ផ្ទៃក្នុងរបស់ គណៈកម្មាធិការរំដោះជាតិខ្មែរ កាន់តែធ្ងន់ធ្ងរទៅៗ។

ដោយដឹងខ្លួនថា សមាជិកគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC)ភាគច្រើនមិន ពេញចិត្តនឹងការដឹកនាំរបស់ខ្លួន ស្របពេលព្រះមហាក្សត្រនរោត្តម សីហនុ និងអាជ្ញាធរ បារាំងអំពាវនាវឲ្យពួកមេឥស្សរៈ ចូលខ្លួនមករួបរួមក្នុងសង្គមជាតិវិញ និងសន្យាមិនយក ទោសពៃរ៍ ព្រមទាំងផ្តល់បុណ្យស័ក្តិខ្ពង់ខ្ពស់ផងនោះ ដាប ឈួន ក៏ចាត់មនុស្សជំនិតរបស់ ខ្លួនឲ្យលួចទាក់ទងសម្ងាត់ជាបណ្តើរៗជាមួយរាជការខ្មែរ-បារាំង ក្នុងបំណងចុះចូលក្នុងសង្គម ជាតិវិញ ។

ដោយសារមិនអាចសហការជាមួយដាប ឈួន បានតទៅទៀត សមាជិកគណៈកម្មា ធិការរំដោះជាតិខ្មែរម្នាក់ ឈ្មោះលាវ កែវមុនី ក៏បានបង្ខំចិត្តនាំកងទ័ពរបស់ខ្លួនចំនួន១០០ នាក់ ដកខ្លួនចេញពីដាប ឈួន ។

នៅក្នុងខែមីនា ឆ្នាំ១៩៤៩ អនុសេនីយ៍សាវ៉ាង វង្ស ជាមេបញ្ជាការទាហានរាជការ ខ្មែរ-បារាំង នៅស្រុកលើកដែក ខេត្តកណ្តាល បាននាំកូនទាហានរបស់គាត់រត់ចោលជួរ ទៅចូលរួមជាមួយងិន ហោ និងពួកវៀតមិញ ។

តែក្រោយមក មិនដឹងមូលហេតុអ្វី ស្រាប់តែពួកកងទ័ពវៀតមិញ ទៅធ្វើការវាយប្រហារ ទីតាំងរបស់គាត់ បង្កឲ្យមានការភ្ញាក់ផ្អើលជាខ្លាំង។ តែការវាយប្រហារនេះ ត្រូវបានអាជ្ញាធរ រាជការខ្មែរ-បារាំង ចាត់ទុកថា គ្រាន់តែជាឆាកល្ខោនមួយ ដែលរៀបចំដោយសាវ៉ាង វង្ស និងពួកវៀតមិញតែប៉ុណ្ណោះ ។

ក្រោយមក អាជ្ញាធររាជការខ្មែរ-បារាំង បានប្រកាសជាសាធារណៈថា បើជនណាអាចកាត់ក្បាលសារ៉ាំង វង្ស យកមកប្រគល់ឲ្យអាជ្ញាធររាជការខ្មែរ-បារាំង បាននោះ អាជ្ញាធរនឹងប្រគល់រង្វាន់ជាទឹកប្រាក់ចំនួន២ម៉ឺនរៀល ហើយបើជនណាកាត់ក្បាលងិន ហោ យកមកប្រគល់ឲ្យអាជ្ញាធរបារាំងដែរនោះ នឹងផ្តល់រង្វាន់ជាកង់ថ្មីមួយគ្រឿង និងប្រាក់ចំនួន១ម៉ឺនរៀលផងដែរ ។

មិនយូរប៉ុន្មាន សារ៉ាំង វង្ស ក៏បានដកខ្លួនចេញពីងិន ហោ និងវៀតមិញ ទៅចូលរួមជាមួយពុត ឆាយ វិញ ព្រោះឃើញពុត ឆាយ ប្រឆាំងនឹងពួកវៀតមិញ ដែលដើរបង្ខំឲ្យប្រជារាស្ត្រខ្មែរបង់ពន្ធឲ្យពួកគេ។ប៉ុន្តែគាត់នៅតែសហការជាមួយពួកវៀតមិញ ក្នុងការប្រឆាំងនឹងពួកបារាំង ដដែល។ បន្ទាប់មក ហ៊ូ ធិញ ក៏បាននាំកងទ័ពគាត់ទៅចូលរួមជាមួយពុត ឆាយ ដែរ។

ដោយសារតែមានមេខ្មែរឥស្សរៈផ្សេងៗទៀតបាននាំគ្នាមកចូលរួមជាមួយគាត់ជាបន្តបន្ទាប់ ពេលនោះ ពុត ឆាយ ក៏បានប្រកាសខ្លួនឯងថា ជាមេបញ្ជាការកងទ័ពកម្ពុជាតែម្តង។

នៅក្នុងខែឧសភា ឆ្នាំ១៩៤៩ ពុត ឆាយ បានធ្វើសកម្មភាពសម្លាប់ភ្នាក់ងាររបស់ពួកវៀតមិញមួយចំនួន នៅតំបន់ដែលខ្លួនកាន់កាប់ ។ ពេលនោះ ចាន់ ដារ៉ា ព្យាយាមធ្វើអន្តរាគមន៍មិនឱ្យគាត់សម្លាប់ដែរ តែពុត ឆាយ មិនព្រមស្តាប់។

លើសពីនេះទៅទៀត មេខ្មែរឥស្សរៈពុត ឆាយ បានសម្លាប់ជនជាតិវៀតណាម ចំនួន៦០នាក់ទៀតនៅក្នុងខេត្តកណ្តាល ។

ដោយសារមានការខឹងសម្បាពីរឿងសម្លាប់ជនជាតិវៀតណាមនេះ ពួកវៀតមិញ ក៏បានធ្វើការពួនស្ទាក់បាញ់សម្លាប់ពុត ឆាយ វិញដែរ តែគាត់រត់រួច។

នៅក្នុងខែមេសា ឆ្នាំ១៩៤៩ កៅ តក់ ជាអនុប្រធានគណៈកម្មធិការរំដោះជាតិខ្មែរ (KNLC) ក៏បាននាំកងទ័ពខ្លួន៤០០នាក់ ចេញពីដាប ឈួន បន្តទៀត។ ប៉ុន្តែមកដល់ខែកក្កដា ឆ្នាំ១៩៤៩ ដាប ឈួន បានប្រើល្បិចបោកប្រាស់ឲ្យសមាជិកគណៈកម្មាធិការរំដោះ

ជាតិខ្មែរ២នាក់ គឺហែម សារ៉ាំង និងម៉ៅ សារួត ដែលធ្លាប់រួមសហការជាមួយខ្លួនបើកការវាយប្រហារទៅលើក្រុងសៀមរាប កាលពីយប់ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៤៦នោះ ឲ្យមកចូលរួមកិច្ចប្រជុំពិសេសមួយ រួចហើយបានចាប់អ្នកទាំងពីរនោះ យកទៅសម្លាប់ចោលយ៉ាងសាហាវបំផុត ។

ជាមួយគ្នានោះដែរ សមាជិកគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ៣នាក់ទៀតក៏ត្រូវដាប ឈួន បណ្តេញចេញពីគណៈកម្មាធិការនេះ ដោយចោទប្រកាន់ថា អ្នកទាំង២បានធ្វើទុក្ខបុកម្នេញប្រជារាស្ត្រដែលស្ថិតក្រោមតំបន់កាន់កាប់របស់ពួកគេ មានលក្ខណៈធ្ងន់ធ្ងរពេក។

សារាចររបស់ពួកវៀតមិញមួយ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៤៩ ដែលផ្សព្វផ្សាយដោយសម្ងាត់នៅក្នុងប្រទេសកម្ពុជា បានសរសេរថា អង្គការបដិវត្តន៍ខ្មែរ និងវៀតមិញត្រូវតែប្រកៀកស្មាសហការគ្នាទៅវិញទៅមក ហើយផ្លាស់ប្តូរគំនិត មេរៀន និងបទពិសោធន៍គ្នា ធ្វើយ៉ាងណាឲ្យប្រជាជនប្រទេសទាំងពីរ យោគយល់ និងរឹតចំណងមិត្តភាពឲ្យបានល្អដោយឈរលើមូលដ្ឋាននៃសម្ព័ន្ធភាពស្មើភាពរវាងប្រជាជនទាំងពីរ ដើម្បីប្រឆាំងនឹងពួកអាណានិគម ប្រតិកិរិយាបារាំង ដែលចូលមកឈ្លានពានប្រទេសកម្ពុជា និងវៀតណាម។

សារាចរពួកវៀតមិញ ដដែលនេះ ក៏បានលើកឡើងពីគោលនយោបាយរួបរួមសហការគ្នា ៣ចំណុច គឺ៖

១-នៅក្នុងមូលដ្ឋានណាដែលមានប្រជាជនវៀតណាម រស់នៅទាំងស្រុងនោះ ប្រជាជនវៀតណាម អាចចូលរួមជាមួយរដ្ឋអំណាចមូលដ្ឋាននោះ ។

២-នៅក្នុងមូលដ្ឋានណាដែលមានប្រជាជនកម្ពុជា រស់នៅច្រើនជាងប្រជាជនវៀតណាម គឺភាគីវៀតណាមអាចកាន់តំណែងបន្ទាប់បន្សំ នៅក្នុងជួររដ្ឋអំណាចមូលដ្ឋាននោះ ដើម្បីជាជំនួយដល់រដ្ឋអំណាចមូលដ្ឋាននៅកម្ពុជា និងជួយសម្របសម្រួលផលប្រយោជន៍ របស់ប្រជាជនទាំង២ ។

៣-រដ្ឋបាលផ្ទៃក្នុង គឺស្ថិតនៅក្នុងរង្វង់ដៃនៃរដ្ឋបាលកម្ពុជាសុទ្ធសាធ និងត្រូវរៀបចំ

ឡើងដោយកម្ពុជា។

ក្នុងខែមិថុនា ឆ្នាំ១៩៤៩ ពួកវៀតមិញ បានចេញសារាចរមួយទៀត ដើម្បីរំឭកដល់ចលនាតស៊ូខ្មែរថា គេ (ខ្មែរ) មិនត្រូវប្រញាប់ប្រញាល់ក្នុងការបង្កើតរណសិរ្សប្រជាជនកម្ពុជាដាច់តែឯងនោះបានទេ ព្រោះចលនាតស៊ូរបស់កម្ពុជានៅខ្សោយណាស់ ហើយបើបង្កើតរណសិរ្សដាច់តែឯង ក៏គ្មានប្រសិទ្ធភាពអ្វីដែរ។

នៅដើមខែមិថុនា នោះដែរ ដោយមានការគាំទ្រពីសំណាក់ង៉ិន ហោ និងកែវ មុនីផងនោះ កងទ័ពវៀតមិញ បានចូលធ្វើសកម្មភាពនៅក្នុងស្រុកល្វាឯម ស្រុកលើកដែក ស្រុកកណ្តាលស្ទឹង និងស្រុកកៀនស្វាយ។ តែការធ្វើសកម្មភាពនៅក្នុងស្រុកទាំង៤ ក្នុងខេត្តកណ្តាលនេះ មិនមែនដើម្បីធ្វើការវាយប្រហារទៅលើទាហានរាជការខ្មែរ-បារាំងនោះទេ គឺក្នុងបំណងតាមកម្ទេចកងទ័ពរបស់ពុត ឆាយ ។

ឆ្លើយតបនឹងបំណងតាមកម្ទេចពីពួកវៀតមិញនេះ ពុត ឆាយ ក៏បានបញ្ជាឲ្យកងទ័ពគាត់ដុតភូមិជនជាតិវៀតណាម មួយចំនួននៅស្រុកល្វាឯម និងចាប់ជនជាតិវៀតណាមមួយចំនួនទៀត នៅស្រុកស្អាង យកទៅសម្លាប់ចោល និងទុកជាចំណាប់ខ្មាំងមួយចំនួនផងដែរ។

ពេលនោះ ពួកវៀតមិញ បានឲ្យទូ សាមុត ដឹកនាំកងទ័ពប្រមាណ៣០០នាក់ ពីខេត្តព្រៃវែង ចូលមកខេត្តកណ្តាលបន្ថែមទៀត ដើម្បីសហការគ្នាបង្ក្រាបកងទ័ពពុត ឆាយ។

ក្នុងរបាយការណ៍មួយ ក្នុងខែមិថុនា ឆ្នាំ១៩៤៩ ចៅហ្វាយខេត្តតាកែវ របស់រាជការខ្មែរ-បារាំង បានឲ្យដឹងថា ពួកឥស្សរៈបានបង្ខំទារពន្ធពីអ្នកស្រុកត្រាំកក់ យ៉ាងធ្ងន់ធ្ងរ ហើយនៅឆ្នាំបន្ទាប់មក ប្រជាកសិករប្រមាណ៨ពាន់នាក់ ដែលរស់នៅរាយប៉ាយក្នុងស្រុកត្រាំកក់ត្រូវបានអាជ្ញាធរឲ្យរុះរើលំនៅឋានមករស់នៅប្រមូលផ្តុំគ្នាបង្កើតជាភូមិ បានចំនួន៩៨ភូមិ ដើម្បីងាយស្រួលក្នុងការជួយការពារសកម្មភាពលួចប្លន់របស់មេខ្មែរឥស្សរៈឈ្មោះម៉ុក (ឈិត ជឿន ហៅម៉ុក ) ។

ក្រោយមកទៀត នៅស្រុកបាទី ស្រុកសំរោង ស្រុកទ្រាំង ក្នុងខេត្តតាកែវ ក៏មានការ

ប្រមូលផ្តុំបង្កើតជាភូមិធំៗ ដើម្បីទប់ទល់ជាមួយពួកឥស្សរៈផងដែរ ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៤៩ សឺង ង៉ុកមិញ បានបោះទីតាំងមូលដ្ឋានតស៊ូធំមួយ នៅក្នុងស្រុកឈូក ខេត្តកំពត ដោយមានកងទ័ពបំពាក់អាវុធគ្រប់ដៃ ចំនួន៣០០នាក់ ក្នុងនោះក៏មាននារីផង។

សឺង ង៉ុកមិញ បានកសាងមន្ទីរពេទ្យមួយ សម្រាប់ព្យាបាលកងទ័ពរបស់គាត់ដែលមានជំងឺ និងរងរបួស ព្រមទាំងអ្នករបួសមកពីក្រុមចលនាតស៊ូឥស្សរៈផ្សេងៗទៀតដែលនៅក្បែរៗនោះផងដែរ ។

ចំណែកនៅភូមិភាគពាយ័ព្យ ចលនាតស៊ូឥស្សរៈខ្មែរ-វៀតមិញ បានបើកវគ្គអប់រំបំពាក់បំប៉នមនោគមន៍វិជ្ជាកុម្មុយនិស្ត ឲ្យសិក្ខាកាមជាអ្នកចូលរួមចលនាបដិវត្តន៍រាប់រយនាក់ ដោយមានអាចារ្យប្រុស និងកម្មាភិបាលវៀតមិញ ជាអ្នកបង្រៀនផ្នែកចរិតសង្គម កសិកម្ម យុទ្ធសាស្ត្រកងទ័ព និងលទ្ធិកុម្មុយនិស្តផងដែរ។

សឺង ង៉ុកមិញ ហៅអាចារ្យមៀន នេះ បានរត់គេចខ្លួនពីក្រុងភ្នំពេញ ពេលពួកបារាំងតាមរកចាប់ខ្លួន ពីបទចូលរួមធ្វើបាតុកម្មទាមទារឲ្យបារាំង ដោះលែងលោកគ្រូអាចារ្យហែម ចៀវ និងនួន ឌួង វិញ កាលពីឆ្នាំ១៩៤២ ហើយបានមកដឹកនាំចលនាតស៊ូប្រឆាំងនឹងបារាំង ដោយដូរឈ្មោះថា សឺង ង៉ុកមិញ នោះ ត្រូវបានមជ្ឈដ្ឋានខ្លះយល់ថា ការជ្រើសរើសយកឈ្មោះ សឺង ង៉ុកមិញ របស់អាចារ្យមៀន នេះ ក្នុងគោលបំណងធ្វើឲ្យប្រជារាស្ត្រខ្មែរមានការចាប់អារម្មណ៍ថា សឺង ង៉ុកមិញ និងសឺង ង៉ុកថាញ់ ដែលជាអតីតនាយករដ្ឋមន្ត្រីកាលពីឆ្នាំ ១៩៤៥ ដែលត្រូវបារាំងចាប់យកទៅឃុំទុកនៅប្រទេសបារាំងនោះ គឺជាបងប្អូននឹងគ្នា ។

មជ្ឈដ្ឋានខ្លះយល់ថា នេះជាការបូកបញ្ចូលគ្នារបស់ឈ្មោះសឺង ង៉ុកថាញ់ និងឈ្មោះ ហូ ជីមិញ ដើម្បីឲ្យចេញជាឈ្មោះសឺង ង៉ុកមិញ នេះ។

ក្នុងឆ្នាំ១៩៤៩នោះដែរ ពួកខ្មែរឥស្សរៈដែលគាំទ្រដោយពួកវៀតមិញ ប្រកាសខ្លួនឯងថា ពួកគេកាន់កាប់ត្រួតត្រាភូមិចំនួន៤១៨ ស្រុកចំនួន៤០ និងខេត្តចំនួន១០ ។

ចំណែកចាន់ ដារ៉ា វិញ ក៏បានប្រកាសខ្លួនឯងថា គាត់មានកងទ័ពចំនួន៣៦០០នាក់

ហើយគាត់បានទិញអាវុធពីប្រទេសសៀម មកបំពាក់ឲ្យកងទ័ពគាត់ចំនួន៧កងវរសេនាតូច ក្នុងនោះក៏មានកូនប្រុសគាត់ម្នាក់ឈ្មោះចាន់ សេរី ជាមេបញ្ជាការកងវរសេនាតូចម្នាក់ដែរ។

នៅក្នុងអង្គប្រជុំធំមួយ មានមនុស្សប្រមាណ៣០០០នាក់ ដោយមានគណៈបញ្ជាការ និងគណៈបញ្ជាការរងចំនួន៥៧នាក់ មកពីកងវរសេនាតូចចំនួន១១នោះ ចាន់ ដារ៉ា ក៏បានប្រកាសខ្លួនឯងថា គាត់ជាអគ្គមេបញ្ជាការកងទ័ពឥស្សរៈនៅទូទាំងប្រទេស។

តែគាត់ក៏បានប្រកាសដែរថា គាត់នឹងព្យាយាមឲ្យអស់ពីសមត្ថភាព ដើម្បីអញ្ជើញមេៗខ្មែរឥស្សរៈទាំងអស់មកប្រជុំគ្នា ដើម្បីបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ ក្នុងពេលឆាប់ៗខាងមុខនេះ ហើយគាត់សង្ឃឹមថាពួកវៀតមិញ នឹងគាំទ្រគំនិតផ្តួចផ្តើមរបស់គាត់នេះជាមិនខាន ។

# ២៩
# ដាប ឈួន ចុះចូលជាមួយព្រះមហាក្សត្រសីហនុ




ដាប ឈួន

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៤៩ កងទ័ពរបស់ទូ សាមុត , ងិន ហោ , កែវ មុនី , វង្ស កាន់ និងខៀវ តែន ក៏បានចូលរួមជាមួយកងទ័ពវៀតមិញ ដែលដឹកនាំដោយឌិញ វ៉ាន់ឡាន (Dinh Van Lan) ដើម្បីសហការគ្នាកម្ទេចកងទ័ពពុត ឆាយ នៅក្នុងខេត្តកណ្តាល បន្តទៀត។

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៤៩ កងទ័ពវៀតមិញចំនួន២០០នាក់ ដឹកនាំដោយខ្មែរកម្ពុជាក្រោមម្នាក់ឈ្មោះសាយ ចូលមកសហការជាមួយកងទ័ពទូ សាមុត , ងិន ហោ និងកែវ មុនី ដែរ។

នៅក្នុងខែតុលា ឆ្នាំ១៩៤៩ កងទ័ពវៀតមិញ មានគ្នាសរុបប្រមាណ៣០០០នាក់ មានវត្តមាននៅលើទឹកដីកម្ពុជា។

នៅខែកញ្ញា ឆ្នាំ១៩៤៩ សាវ៉ាង វង្ស និងហ៊ូ ធិញ ដែលបានបំបែកខ្លួនចេញពីងិន ហោ ទៅចូលរួមជាមួយពុត ឆាយ វិញ។ ប៉ុន្តែរយៈពេល៦ខែក្រោយមក ដោយឃើញពុត ឆាយ ប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃខ្លាំងពេក ពួកគាត់ក៏បានផ្តាច់ខ្លួនចេញពីពុត ឆាយ វិញ ហើយនៅជាឯករាជ្យ មិននៅក្រោមចំណុះមេឥស្សរៈធំៗណាទៀតទេ។

នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ ដូចការគ្រោងទុក ដាប ឈួន ក៏បានចុះចូលជាមួយព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ និងពួកបារាំង ដោយនាំកងទ័ពប្រដាប់អាវុធគ្រប់ដៃចំនួន៣០០នាក់ ក្នុងនោះមានស្រីៗជាបរិវារមួយចំនួនផងដែរ។

ជាថ្នូរនឹងការវិលត្រឡប់មកចូលរួមក្នុងសង្គមជាតិវិញ និងស្របតាមការសន្យាក្នុងសេចក្តីអំពាវនាវរបស់ព្រះអង្គផងដែរ ព្រះមហាក្សត្រសីហនុ ក៏បានប្រទានឋានន្តរស័ក្តិជាវរសេនីយ៍ត្រីដល់ដាប ឈួន និងឲ្យធ្វើជាមេបញ្ជាការកងវរសេនាតូចប្រចាំខេត្តសៀមរាប។

ក្រោយដាប ឈួន ចុះចូលជាមួយបារាំង ប៉ុក គុណ ហៅតាត្រឡាច បានឡើងមកដឹកនាំគណៈកម្មាធិការរំដោះជាតិខ្មែរ (KPLC) ជំនួសវិញ ។

ចំណែកពុត ឆាយ ក្រោយមកក៏ត្រូវរងរបួសត្រង់ពោះ ដោយសារការបាញ់កាំភ្លើងផ្លោងរបស់កងទ័ពវៀតមិញ ហើយគាត់បានបំផុសដំណឹងប្រឌិតមួយថា គាត់បានស្លាប់នៅពេលនោះហើយ ដើម្បីបង្វែងដានកុំឲ្យពួកវៀតមិញ និងពួកខ្មែរឥស្សរៈជាសម្ព័ន្ធមិត្ត តាមរកគាត់បន្តទៀត។

ចាប់ពីពេលនោះមក កងទ័ពពុត ឆាយ មិនសូវមានសកម្មភាពអ្វីខ្លាំងក្លាទៀតទេ។ ចំណែកព្រះអង្គម្ចាស់នរោត្តម ចន្ទរង្សី ដែលបានបំបែកខ្លួនចេញពីចលនាឥស្សរៈចម្រុះនៅខេត្តបាត់ដំបង បាននាំកងទ័ពប្រមាណ៣៥០នាក់ មកបោះទីតាំងនៅក្នុងព្រៃ ក្នុងទឹកដីខេត្តពោធិ៍សាត់ និងកំពង់ស្ពឺ។

ចុងឆ្នាំ១៩៤៩នោះ នៅខេត្តក្រចេះ មានមេខ្មែរឥស្សរៈជាអតីតព្រះសង្ឃម្នាក់ឈ្មោះគ្រូអ៊ុម ដឹកនាំកងទ័ព១០០នាក់ ក្នុងនោះ ក៏មានអតីតក្រុមចោរប្លន់មួយចំនួនដែលដឹកនាំដោយឈ្មោះប៉ក់ ស៊ុនហេង ផងដែរ។

ប៉ុន្តែអាជ្ញាធររាជការខ្មែរ-បារាំង ដឹងច្បាស់ថា កងទ័ពឥស្សរៈរបស់គ្រូអ៊ុម នេះ មិនមានសមត្ថភាពអ្វីធ្វើសកម្មភាពគួរឲ្យព្រួយបារម្ភ ក្រៅតែពីដើរលួចប្លន់ទ្រព្យសម្បត្តិអ្នកស្រុក និងបង្ខំទារពន្ធពីបងប្អូនជនជាតិចាម នៅស្រុកក្រូចឆ្មារ នោះឡើយ ហើយពេលខ្លះ ដោយមិនអាចស៊ូទ្រាំនឹងការទារពន្ធនោះបាន បងប្អូនជនជាតិចាម ក៏បានធ្វើការប្រឆាំងតបតនឹង

កងទ័ពឥស្សរៈរបស់គ្រូអ៊ុម នេះវិញខ្លះៗដែរ។

នៅក្នុងចុងឆ្នាំ១៩៤៩ នោះដែរ នៅក្នុងខេត្តតាកែវ ក៏មានមេឥស្សរៈម្នាក់ឈ្មោះ ម៉ុក (ឈិត ជឿនហៅតាម៉ុក) ដែលរួមសហការជាមួយពួកវៀតមិញនោះ បើទោះបីគាត់មានកងទ័ពតិចតួចក៏ដោយ ក៏គាត់ហាក់ដូចជាសាហាវព្រៃផ្សៃណាស់ដែរ ហើយគាត់បានធ្វើការប្រយុទ្ធប្រឆាំងជាមួយកងទ័ពឥស្សរៈឯករាជ្យ ដែលដឹកនាំដោយសារ៉ាង វង្ស ផងដែរ។

ក្រោយដាប ឈួន ចុះចូលជាមួយសម្ដេចសីហនុ និងបារាំង ហើយទទួលបានតំណែងជាមេបញ្ជាការកងទ័ពត្រួតត្រាខេត្តសៀមរាប និងកំពង់ធំ នោះមក ដោយធ្លាប់តស៊ូធ្វើខ្មែរឥស្សរៈជាមួយគ្នា ពេលចូលទៅរកស៊ីថតរូបធ្វើអត្តសញ្ញាណប័ណ្ណឲ្យប្រជារាស្ត្រនៅខេត្តសៀមរាប ប៊ុណ្ណ ចន្ទម៉ុល បានចូលទៅជម្រាបសុំការអនុញ្ញាតពីដាប ឈួន ផងដែរ។ ដាប ឈួន បានទទួលស្វាគមន៍គាត់ដោយរីករាយ និងអនុញ្ញាតឲ្យគាត់រកស៊ីថតរូបធ្វើអត្តសញ្ញាណប័ណ្ណនេះតាមសម្រួលចុះ ហើយថែមទាំងឲ្យពួកទាហានគេជួយការពារទៀតផង។

ប៊ុណ្ណ ចន្ទម៉ុល ក៏សប្បាយរីករាយណាស់ដែរ។ ប៉ុន្តែពេលគាត់កំពុងប្រកបរបររកស៊ីថតរូបនេះ មិនទាន់បានប៉ុន្មានផង ក៏ស្រាប់តែមានស័ក្តិបីម្នាក់ នៅក្រោមបញ្ជាដាប ឈួន ដែលកាលពេលនៅតស៊ូ ធ្លាប់ជាកូនចៅ និងស្រឡាញ់ស្មោះត្រង់ជាមួយគាត់ដែរនោះ បានមកលួចប្រាប់ឲ្យគាត់ប្រញាប់ចាកចេញពីខេត្តសៀមរាប ជាបន្ទាន់ ព្រោះដាប ឈួន កំពុងចាត់ការឲ្យពួកកូនទាហានគេចាប់គាត់ហើយ។

ប៊ុណ្ណ ចន្ទម៉ុល គិតថា ដាប ឈួន ប្រហែលជាខ្លាចគាត់និយាយពីរឿងអតីតកាលរបស់គេជាមួយគាត់ នាំឲ្យអាប់ឱនដល់កិត្តិយសគេ ទើបគេត្រូវតែកម្ចាត់គាត់បែបនេះ? ឬក៏មកពីគ្រានោះ គាត់ពុំបានឲ្យប្រាក់កម្រៃដល់រូបគេក៏មិនដឹង ព្រោះសម័យនោះ ពេលប្រកបមុខរបររកស៊ីអ្វីមួយ ថៅកែចិនៗគ្រប់ៗគ្នាត្រូវតែយកសួយសារអាករច្រើនសន្ធឹកសន្ធាប់មកជូនដល់គេ។

ទីបំផុត គាត់មានតែប្រញាប់ចាកចេញពីទឹកដីដែលឈួន ម្ចុលពេជ្រ គ្រប់គ្រងនោះដោយគ្មានបង្អែបង្អង់ឡើយ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥០ សាវ៉ាង វង្ស ក៏មានបំណងចង់ត្រឡប់ចូលសង្គមជាតិវិញ តាមការអំពាវនាវរបស់ព្រះមហាក្សត្រសីហនុ ដែរ តែគាត់ទាមទារតំណែងចៅហ្វាយខេត្ត កំពង់ស្ពឺ ជាថ្នូរនឹងការចុះចូលនោះ ដោយគាត់សំអាងថា គាត់ជាមេខ្មែរឥស្សរៈឯករាជ្យ និង ធ្លាប់បានសហការជាមួយកម្លាំងអាជ្ញាធរក្នុងការបង្ក្រាបពួកវៀតមិញផងដែរ។

បើតាមប្រភពស៊ើបការណ៍សម្ងាត់របស់បារាំង បានឲ្យដឹងថា សាវ៉ាង វង្ស មាន កងទ័ពប្រមាណ៤០០នាក់ កាន់កាប់តំបន់ប៉ែកខាងត្បូងនៃខេត្តកំពង់ស្ពឺ និងភាគខាងជើង នៃខេត្តតាកែវ ។

គាត់ដឹកនាំកងទ័ពប្រឆាំងនឹងពួកវៀតមិញ យ៉ាងខ្លាំងក្លា ហើយគាត់មិនធ្វើសកម្មភាព ប្រឆាំងនឹងរាជការបារាំង-ខ្មែរទេ ប៉ុន្តែគាត់ជាមនុស្សញៀនអាភៀន ។

ក្រោយពីដាប ឈួន ចុះចូលជាមួយព្រះមហាក្សត្រសីហនុ និងពួកបារាំងមក នៅ ក្នុងខែកុម្ភៈ ឆ្នាំ១៩៥០ ពួកមេដឹកនាំវៀតមិញ បានអញ្ជើញស្រីឈ្មោះលាត មួន ហៅម៉ែមួន (បងចិញ្ចឹមកៅ តក់), ហុង ឈុន និងអាចារ្យដួង ជាតំណាងគណៈកម្មាធិការរំដោះជាតិ ខ្មែរ (KPLC) នៅខេត្តបាត់ដំបង ឲ្យទៅរួមប្រជុំជាមួយមេខ្មែរឥស្សរៈជាសម្ព័ន្ធមិត្តរបស់ខ្លួន នៅខេត្តហាទៀង ប្រទេសវៀតណាមខាងត្បូង ។

កម្លាំងសម្ងាត់របស់បារាំង បានឲ្យដឹងថា ការរួមប្រជុំនោះ គឺដើម្បីពិភាក្សាគ្នាបង្កើត រដ្ឋាភិបាលមួយ ក្នុងតំបន់ដែលពួកឥស្សរៈកាន់កាប់ ។

នៅក្នុងខែកុម្ភៈ នោះដែរ នៅក្នុងមហាសន្និបាតរបស់គណៈកម្មាធិការមជ្ឈិមបក្ស កុម្មុយនិស្តឥណ្ឌូចិន ដែលមានមេដឹកនាំឥស្សរៈខ្មែរ និងឡាវ ចូលរួមដែរនោះ វ៉ូ ង្វៀងយ៉ាប់ ជាមេទ័ពកំពូលរបស់ពួកវៀតមិញ បានចាត់ទុកឆ្នាំ១៩៥០នោះថា ជាឆ្នាំលោតផ្លោះរបស់ បដិវត្តន៍នៅកម្ពុជា និងលាវ ហើយគាត់ប្រកាសគាំទ្រដល់ការបង្កើតកងទ័ពតស៊ូដើម្បីឯករាជ្យ នៅកម្ពុជា និងលាវ និងបានសន្យាថា គាត់នឹងជួយកងទ័ពនេះឲ្យបានរឹងមាំខ្លាំងពូកែ ដើម្បី រំដោះប្រទេសជាតិទាំង២នេះឲ្យបានទៀតផង។

ប៉ុន្តែគាត់បានណែនាំឲ្យបំបែកការប្រមូលផ្តុំកងទ័ពដែលនៅទីតាំងធំៗ ឲ្យទៅជាក្រុម

តូចៗ ហើយឲ្យអនុវត្តយុទ្ធសាស្ត្រសង្គ្រាមឈ្លបវិញ ទើបកម្ពុជា និងលាវ ទទួលបានជោគជ័យ ។

នៅក្នុងមហាសន្និបាតរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមានរយៈពេល១០ថ្ងៃ នៅខេត្តហាទៀង នោះ សឺង ង៉ុកមិញ និងមេឥស្សរៈខ្មែរជាច្រើននាក់ទៀត បានជួបពិភាក្សាជាមួយឡេ ឌឹកថូ ដែលជាតំណាងឲ្យហូ ជីមិញ ដើម្បីរៀបចំឲ្យមានមហាសន្និបាតលើកទី១ របស់ចលនាតស៊ូខ្មែរឥស្សរៈផងដែរ។

ដូចការគ្រោងទុក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៥០ មហាសន្និបាតមួយមានរយៈពេល៣ថ្ងៃ ត្រូវបានប្រារព្ធធ្វើឡើងនៅជាយក្រុងកំពង់សោម ភាគនិរតី នៃប្រទេសកម្ពុជា ដោយមានតំណាងឥស្សរៈខ្មែរចំនួន២០០នាក់ ក្នុងនោះមានព្រះសង្ឃជាច្រើនអង្គក៏បានចូលរួមផងដែរ។

នៅថ្ងៃបញ្ចប់ មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សឯកភាពឥស្សរៈ (UIF) មួយដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិមជ្ឈិម រួមមាន សឺង ង៉ុកមិញ ជាប្រធាន, ចាន់ សម័យ ជាអនុប្រធាន, ស៊ីវ ហេង ជាលេខាធិការ, ទូ សាមុត, កែវ មុនី , ណឺ សារ៉ាន់ និងតំណាងអ្នកតស៊ូប្រចាំក្រុងភ្នំពេញម្នាក់ទៀត អាចជា កែវ មាស ព្រមទាំងមេបញ្ជាការកងទ័ពចំនួន៧នាក់ រួមមាន៖ ចាន់ ដារ៉ា , មាស វង្ស, មាស វណ្ណៈ, ចូវ យីន, ញ៉ែម ស៊ុន, សុខ សាផាយ និងងិន ហោ ដែលសុទ្ធតែជាមេបញ្ជាការសំខាន់ៗរបស់ពួកឥស្សរៈខ្មែរ-វៀតមិញ ជាសមាជិក។

ក្នុងចំណោមសមាសភាពមេដឹកនាំរណសិរ្សឯកភាពឥស្សរៈ (UIF) ខាងលើនេះ មាន៥នាក់ជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន (CIP) ក្នុងនោះ ណឺ សារ៉ាន់ ទើបតែបានចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន នៅដើមឆ្នាំ១៩៥០ ។

សមាសភាពសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន មិនមែនមានតែនៅក្នុងរណសិរ្សឯកភាពឥស្សរៈ (UIF) ដែលទើបតែបង្កើតថ្មីនេះទេ គឺនៅក្នុងជួរគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ដែលនៅភាគពាយ័ព្យប្រទេស ក៏មានដែរ ដូចជា ម៉ី ផូ និងហុង ឈុន ជាដើម។

ជាមួយគ្នានេះ រណសិរ្សឯកភាពឥស្សរៈ ក៏បានបង្កើតគណៈកម្មាធិការមួយទៀត

ហៅថា  គណៈកម្មាធិការមជ្ឈិមរំដោះប្រជាជន ដែលមានសឹង ង៉ុកមិញ ជាប្រធាន និងមាន អនុប្រធាន ៣នាក់ទៀត គឺ៖

១. ចាន់ សម័យ ជាអនុប្រធាន ទទួលបន្ទុកជាប្រធានគណៈកម្មាធិការរំដោះប្រជាជន នៅភូមិភាគនិរតី ។

២. ស៊ីវ ហេង ជាអនុប្រធាន  ទទួលបន្ទុកជាប្រធានគណៈកម្មាធិការរំដោះប្រជាជន នៅភូមិភាគពាយ័ព្យ  និងជាប្រធានរណសិរ្សឯកភាពឥស្សរៈ (UIF) នៅភូមិភាគពាយ័ព្យ នោះ ។

៣. ទូ សាមុត ជាអនុប្រធាន ទទួលបន្ទុកជាអនុប្រធានគណៈកម្មាធិការរំដោះប្រជាជន នៅភូមិភាគបូព៌ា ។

ការរៀបចំរចនាសម្ព័ន្ធដឹកនាំនេះ  ជាការចម្លែកដែរ  ព្រោះកែវ  មុនី  ដែលត្រូវបាន តែងតាំងជាប្រធានគណៈកម្មាធិការរំដោះប្រជាជននៅភូមិភាគបូព៌ា មិនមានឈ្មោះជាអនុ-ប្រធានគណៈកម្មាធិការមជ្ឈិមរំដោះប្រជាជនទេ  បែរជាតែងតាំងទូ  សាមុត  អនុប្រធាន គណៈកម្មាធិការមជ្ឈិមរំដោះប្រជាជន  ឲ្យទទួលបន្ទុកជាអនុប្រធានគណៈកម្មាធិការរំដោះ ប្រជាជននៅភូមិភាគបូព៌ា ទៅវិញ។

ចំណែកសឺន ភ្លួករតនា ដែលបានរត់ចេញពីជួរកងទ័ពរាជការខ្មែរ-បារាំង ទៅប្រទេស សៀម កាលពីខែមិថុនា ឆ្នាំ១៩៤៩នោះ ត្រូវបានតែងតាំងជាប្រធានមន្ទីរគណៈកម្មាធិការ មជ្ឈិមរំដោះប្រជាជន។ នង សួន ទៅពីភូមិភាគនិរតី ក៏បានក្លាយទៅជាកម្មាភិបាលជាន់ខ្ពស់ នៅមន្ទីរគណៈកម្មាធិការមជ្ឈិមរំដោះប្រជាជន ។

# ៣០
# នួន ជា ចូលរួមក្នុងចលនាតស៊ូជាមួយស៊ីវ ហេង



នួន ជា

នៅក្នុងឆ្នាំ១៩៥០ នួន ជា បានត្រឡប់ពីប្រទេសថៃ មកមាតុប្រទេសវិញ ដើម្បីចូលរួមក្នុងចលនាតស៊ូជាមួយស៊ីវ ហេង ដែលជាប្រធានគណៈកម្មាធិការរំដោះប្រជាជន (KNLC) និងជាប្រធានរណសិរ្សឯកភាពឥស្សរៈ (UIF) នៅភូមិភាគពាយ័ព្យ។

ពេលចូលរួមក្នុងចលនាតស៊ូខ្មែរឥស្សរៈដំបូង នួន ជា មានតួនាទីជាសមាជិកគណៈកម្មាធិការនយោបាយយោធាភូមិភាគពាយ័ព្យ ។

នួន ជា មានឈ្មោះដើម ឡៅ គឹមរន (ខ្លះថា ឡៅ បេងគន) កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។

ឪពុកឈ្មោះឡៅ លីវ ជាកូនចៅចិន ម្តាយឈ្មោះដុស ពាញ ជាជនជាតិខ្មែរសុទ្ធ។ នួន ជា មានបងប្អូន៩នាក់ ក្នុងនោះគាត់ជាកូនទី៣ តែស្លាប់អស់៣ នៅសល់៦នាក់ គឺទី១. ឡៅ រឿត ភេទស្រី ពិការជើងទាំង២, ទី២. រូបគាត់ (នួន ជា), ទី៣.ឡៅ ហ៊ិច ភេទស្រី, ទី៤.ឡៅ ធូពុន ភេទស្រី មានប្តីឈ្មោះ អ៊ឹម សាន ធ្វើទាហានមានឋានន្តរស័ក្តិវរសេនីយ៍ឯក

ក្នុងរបបសាធារណរដ្ឋខ្មែរ, ទី៥.ឡៅ ប៊ុនមី ភេទប្រុស ជាមន្ត្រីគយក្នុងសម័យសង្គមរាស្ត្រនិយម និងទី៦. ឡៅ គឹមនី ភេទស្រី មានប្តីឈ្មោះកោះ ៣៧ ជាមន្ត្រីធនាគារ និងជាប្អូនប្រុសបង្កើតរបស់វរសេនីយ៍ឯក កោះ ឈួន ជាមេបញ្ជាការនៅក្នុងរបបសាធារណរដ្ឋខ្មែរ។

ម្តាយរបស់នួន ជា ឈ្មោះដុស ៣៧ ជាកូនច្បងគេក្នុងគ្រួសារមួយ ដែលមានសុទ្ធតែប្អូនស្រីចំនួន៥នាក់។ ប្អូនស្រីទាំង៤របស់ម្តាយនួន ជា ទី១. ឈ្មោះដុស ពឿត, ទី២. ឈ្មោះដុស យ៉ៅ, ទី៣. ឈ្មោះដុស ឈឿត និងទី៤. ឈ្មោះដុស អ៊ឹង ជាប្អូនពៅ។

ឈ្មោះដុស អ៊ឹង ជាប្អូនពៅគេនេះ ជាប្រពន្ធរបស់ស៊ីវ ហេង ដែលជាប្រធានគណៈកម្មាធិការរំដោះប្រជាជន (KNLC) និងជាប្រធានរណសិរ្សឯកភាពឥស្សរៈ (UIF) នៅភូមិភាគពាយ័ព្យនោះ។ ដូច្នេះនួន ជា ត្រូវជាក្មួយប្រសារបស់ស៊ីវ ហេង ។

នួន ជា ហៅឡៅ គឹមរន ដែលមានឈ្មោះប្រចាំគ្រួសារមួយទៀត គឺឈ្មោះទូច ពេលមានអាយុ៧ឆ្នាំ គាត់បានចូលរៀននៅសាលាបឋមសិក្សា រហូតបានចូលរៀននៅអនុវិទ្យាល័យបាត់ដំបង។

ក្រោយពីខេត្តបាត់ដំបង ត្រូវសៀម ដណ្តើមយកទៅកាន់កាប់ជាថ្មីម្តងទៀត គាត់បានទៅបន្តការសិក្សានៅទីក្រុងបាងកក ប្រទេសថៃ នៅក្នុងឆ្នាំ១៩៤២ ។

តែមុនពេលទៅបន្តការសិក្សានៅទីក្រុងបាងកកនោះ គាត់បានសាងផ្នួស ដើម្បីតបស្នងសងគុណឪពុកម្តាយគាត់ រយៈពេល៣ខែដែរ។

នៅក្នុងក្រុងបាងកក ព្រះសង្ឃមួយអង្គព្រះនាមគ្រូអាចារ្យអ៊ុក ជា បានឲ្យគាត់ទៅស្នាក់នៅក្នុងកុដិរបស់ព្រះអង្គក្នុងវត្តប្រាំព្រះអង្គ។

នៅក្នុងឆ្នាំ១៩៤៥ ក្រោយបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យមក នួន ជា បានបន្តការសិក្សានៅមហាវិទ្យាល័យធម្មសាស្ត្រ ក្នុងទីក្រុងបាងកកនោះបន្តទៀត។

នៅក្នុងឆ្នាំ១៩៤៧ ឡៅ លីវ ជាឪពុកគាត់បានទទួលមរណភាពដោយសារជំងឺរាកមួល នួន ជា ក៏បានធ្វើដំណើរពីក្រុងបាងកក មកធ្វើបុណ្យសពឱ្យឪពុកគាត់ដែរ។

ពេលកំពុងសិក្សានៅមហាវិទ្យាល័យនោះ គាត់មានការជក់ចិត្តជិតអារម្មណ៍ក្នុងការ

## របស់នយោបាយ

អានសៀវភៅ និងកាសែតមាននិន្នាការទៅរកពួកកុម្មុយនិស្ត ដែលនិយាយពីការរំដោះប្រជាជន និងប្រទេសជាតិឲ្យរួចផុតពីវណ្ណៈជិះជាន់ និងពួកអាណានិគម ចក្រពត្តិនិយម។

នួន ជា ចាប់អារម្មណ៍បំផុតចំពោះសៀវភៅកុម្មុយនិស្តមួយ ដែលមានរូបគំនូរជនជាតិវៀតណាម ថៃ និងឡាវ រួបរួមគ្នាស្រោចស្រង់ប្រទេសជាតិរបស់ពួកគេ ចេញពីពួកសក្តិភូមិវណ្ណៈជិះជាន់ រហូតគាត់ស្ម័គ្រចិត្តចូលជាសមាជិកអង្គការយុវជនប្រជាធិបតេយ្យសៀម ដែលពួកកុម្មុយនិស្តថៃ ជាអ្នកបង្កើតឡើង ហើយមិនបានប៉ុន្មាន គាត់ក៏បានក្លាយជាបក្ខជនរបស់បក្សកុម្មុយនិស្តថៃ។

គាត់បានចូលរួមយ៉ាងសកម្មដល់ការងារសង្គម និងបានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងអំពើផ្តាច់ការនិងការជិះជាន់របស់ពួកសក្តិភូមិ ពួកអ្នកមានអំណាចថៃ នៅទីក្រុងបាងកកជាបន្តបន្ទាប់។

ពេលកំពុងសិក្សានៅមហាវិទ្យាល័យធម្មសាស្ត្រនោះដែរ នួន ជា បានឆ្លៀតឱកាសធ្វើការក្រៅម៉ោងនៅក្រសួងហិរញ្ញវត្ថុ (ឃ្លាំងប្រាក់) ផងដែរ។

ប៉ុន្តែដោយសារគាត់មិនចូលចិត្តធ្វើការផ្នែកហិរញ្ញវត្ថុ ដែលមួយថ្ងៃៗគិតតែពីរឿងគុណគូរលេខ រាប់លុយនោះ គាត់ក៏បានសុំផ្លាស់ប្តូរទៅធ្វើការនៅក្រសួងការបរទេស វិញនៅដើមឆ្នាំ១៩៥០។

គាត់ធ្វើការនៅក្រសួងការបរទេសនោះ បានប្រហែលមួយខែ គាត់ឃើញទូតថៃ នៅក្រុងភ្នំពេញ រាយការណ៍ជាញឹកញាប់មកថា ពួកអាណានិគមបារាំង បានធ្វើបាប កាប់សម្លាប់ប្រជារាស្ត្រខ្មែរសាហាវឃោរឃៅបំផុតមក គាត់មានការឈឺចាប់ខ្លាំងពេក ក៏សម្រេចចិត្តត្រឡប់មកមាតុប្រទេសវិញ ដើម្បីធ្វើការតស៊ូប្រឆាំងនឹងពួកបារាំង។

ចំណែក ស៊ីវ ហេង មានដើមកំណើតមកពីកម្ពុជាក្រោម មានឈ្មោះដើមគឺ ថាច់ ហេង។ ឪពុកគាត់ឈ្មោះថាច់ ហួត ។

ពេលធំដឹងក្តី គាត់បានមករស់នៅទីក្រុងភ្នំពេញ ជួយលក់ថ្នាំឲ្យថៅកែហាងលក់ថ្នាំចិនសែល្បីឈ្មោះមួយឈ្មោះស៊ីវ ប៉ាវ ដែលស្ថិតនៅខាងលិចផ្សារថ្មី។

កាលសម័យនោះ ថ្នាំចិនសែឃីហោស៊ីវ ប៉ាវ នេះ ល្បីល្បាញនិងពូកែស័ក្តិសិទ្ធណាស់ពិសេសថ្នាំសម្រាប់ព្យាបាលជំងឺគ្រុនក្តៅ ស្រែង កញ្ជ្រឹល កមរមាស់ តាអក រដូវស្ត្រីមិនទៀងនិងជំងឺផ្សេងៗទៀត។

ថៅកែហាងថ្នាំចិនសែនេះ បានយកថាច់ ហេង ធ្វើជាកូនចិញ្ចឹម ហើយបានដូរត្រកូលទៅជា ស៊ីវ ហេង វិញ។

ក្នុងដើមទសវត្សរ៍ឆ្នាំ១៩៤០ គាត់បានធ្វើដំណើរចុះឡើងពីភ្នំពេញ ទៅបាត់ដំបងហើយបានរៀបការជាមួយម្តាយមីងពៅរបស់នួន ជា ឈ្មោះដុស អ៊ឹង នោះ នៅក្នុងឆ្នាំ១៩៤៥ ។ បន្ទាប់មក គាត់ក៏បានចូលរួមដឹកនាំចលនាតស៊ូខ្មែរឥស្សរៈជាមួយកៅ តក់ នៅខេត្តបាត់ដំបងនោះតែម្តងទៅ។

# ៣១
# ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ



**ស៊ីវ ហេង ប្រជុំជាមួយ តុង ឌឹកថាំង និងទុងសុផាន់ទង្ស**

មកដល់ឆ្នាំ១៩៥០ អ្នកតស៊ូខ្មែរឥស្សរៈដែលនៅក្រោមឥទ្ធិពលរបស់ពួកវៀតមិញ បានចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន តែ៤០នាក់ប៉ុណ្ណោះ។

នៅក្នុងខែមេសា ឆ្នាំ១៩៥០ រណសិរ្សឯកភាពឥស្សរៈ (UIF) បានបើកមហាសន្និបាតរបស់ខ្លួនជាលើកដំបូង។

ពេលនោះ ចាន់ ដារ៉ា ក្នុងនាមជាមេបញ្ជាការកងទ័ពរណសិរ្សនោះម្នាក់ដែរ បានឲ្យដឹងថា ក្នុងឱកាសនោះ មានឧត្តមសេនីយ៍វៀតមិញម្នាក់ឈ្មោះ អុង សារ បានស្នើឲ្យមហាសន្និបាតនេះ ធ្វើការពិភាក្សាពីបញ្ហាបង្កើតសហព័ន្ធឥណ្ឌូចិន និងធ្វើការជ្រើសរើសប្រធានម្នាក់ និងអនុប្រធានម្នាក់ ។

ប៉ុន្តែ ចាន់ ដារ៉ា បានលើកហេតុផលថា ការតស៊ូរបស់កម្ពុជា លាវ វៀតណាម (វៀតណាមភាគខាងត្បូង) មិនទាន់បង្កើតឲ្យមានរដ្ឋាភិបាលនៅឡើយទេ ហើយកាន់កាប់ទឹកដីមិនទាន់ដល់៥០ភាគរយផង ដូច្នេះការលើកយកបញ្ហាបង្កើតសហព័ន្ធឥណ្ឌូចិន មក

ធ្វើការពិភាក្សានៅក្នុងមហាសន្និបាតនេះ ជាការពុំត្រឹមត្រូវទេ។

ក្នុងនាមគាត់ជាមេទ័ពម្នាក់ដែលចលនាតស៊ូខ្មែរឥស្សរៈស្មើរតែទូទាំងប្រទេសគាំទ្រនោះ គាត់ស្នើឲ្យមហាសន្និបាតផ្អាកការពិភាក្សាពីបញ្ហាបង្កើតសហព័ន្ធឥណ្ឌូចិននោះមួយរយៈសិន។

ប៉ុន្តែទោះបីគម្រោងបង្កើតសហព័ន្ធឥណ្ឌូចិនរបស់ពួកវៀតមិញ ត្រូវបរាជ័យក៏ពិតមែនក៏នៅក្នុងខែមីនា ឆ្នាំ១៩៥០ សម័យប្រជុំត្រីភាគី (វៀតណាម-កម្ពុជា-លាវ) នៅលើភ្នំមួយនៃភាគខាងជើងវៀតណាម ដែលមានតុង ឌឹកថាំង តំណាងភាគីវៀតណាម, ទ្រង់សុផាន់វង្ស តំណាងភាគីឡាវ និងស៊ីវ ហេង អនុប្រធានរណសិរ្សឯកភាពឥស្សរៈ (UIF) និងជាប្រធានគណកម្មាធិការរំដោះប្រជាជនភូមិភាគពាយ័ព្យ តំណាងភាគីកម្ពុជានោះ បានឯកភាពគ្នាបង្កើតរណសិរ្សមួយឲ្យឈ្មោះថា រណសិរ្សរួបរួមឥណ្ឌូចិន។

នៅក្នុងខែមិថុនា ឆ្នាំ១៩៥០ ដើម្បីជាការរំឭកគុណដល់ពួកអ្នកជាតិនិយមទាំងឡាយដែលបានពលីជីវិតនៅក្នុងសង្គ្រាមលោកលើកទី២ ចាន់ សម័យ ជាប្រធានគណៈកម្មាធិការរំដោះជាតិនៅភូមិភាគនិរតី បានបង្កើតឲ្យមានសាលានយោបាយមួយជាលើកដំបូង ដោយបានដាក់ឈ្មោះថា សាលានយោបាយអាចារ្យហែម ចៀវ ហើយសាលានេះបានបើកវគ្គរៀនសូត្រកម្មាភិបាល តាំងពីថ្នាក់ភូមិ ដល់ថ្នាក់ស្រុក បានចំនួន១៤០នាក់។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៥០ សឺង ង៉ុកមិញ បានប្រកាសថា រណសិរ្សឯកភាពឥស្សរៈ(UIF) បានកាន់កាប់ទឹកដី១ភាគ៣ នៃប្រទេសកម្ពុជាទាំងមូល ហើយថា ពួកគាត់ដណ្តើមបានឯករាជ្យពីពួកបារាំង បានទាំងស្រុងហើយទៀតផង។

នៅក្នុងខែធ្នូ ឆ្នាំ១៩៥០ ពុត ឆាយ ដែលជាមេដឹកនាំខ្មែរឥស្សរៈប្រឆាំងនឹងពួកវៀតមិញ ក៏បានចរចាជាមួយរាជការខ្មែរ-បារាំង ដើម្បីវិលមកចូលក្នុងសង្គមជាតិវិញដែរ ។ ប៉ុន្តែដោយសារគាត់ចង់បានតំណែងខ្ពស់ដូចដាប ឈួន គឺគាត់ទាមទារតំណែងជាមេបញ្ជាការកងទ័ពស្វយ័តនៅខេត្តកណ្តាល និងកំពង់ស្ពឺ ទាំងមូល ជាថ្នូរនឹងការចុះចូលនោះ អ្វីៗក៏ត្រូវចាត់ទុកថាជាមោឃៈវិញ។

## របត់នយោបាយ

នៅពេលដែលចលនាតស៊ូខ្មែរឥស្សរៈកាន់តែរីកធំឡើងៗនោះ នៅក្នុងឆ្នាំ១៩៥០ អាជ្ញាធររាជការខ្មែរ-បារាំង ក៏សម្រេចចិត្តបង្ខំឲ្យប្រជាជនដែលរស់នៅរាយប៉ាយក្នុងតំបន់ប្រទាញប្រទង់ជាមួយពួកឥស្សរៈ នៅក្នុងខេត្តតាកែវ, ខេត្តព្រៃវែង, ខេត្តស្វាយរៀង និងខេត្តកំពង់ឆ្នាំង សរុបប្រមាណ២២៨០០គ្រួសារ ឲ្យមករស់នៅជាលក្ខណៈប្រមូលផ្តុំ ដោយបានបង្កើតជាភូមិធំៗនៅជាប់នឹងផ្លូវជាតិ ដោយមានការការពារពីសំណាក់ទាហានរាជការខ្មែរ-បារាំង ផងដែរ។

នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៥១ សឺង ង៉ុកមិញ,ចាន់ សម័យ និងចាន់ ដារ៉ា បានរៀបចំឲ្យមានសន្និបាតពុទ្ធសាសនិកខ្មែរមួយ មានរយៈពេល៣ថ្ងៃ ដើម្បីអប់រំឃោសនាព្រះសង្ឃ និងប្រជាជនខ្មែរ ឲ្យចូលរួមក្នុងចលនាតស៊ូដណ្តើមឯករាជ្យពីបារាំង ឲ្យបានខ្លាំងក្លាថែមទៀត ដោយបានលើកយកវីរភាពរបស់លោកគ្រូអាចារ្យ ហែម ចៀវ ធ្វើជាគំរូក្នុងការតស៊ូដណ្តើមឯករាជ្យពីបារាំង ទៀតផង ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៥១ ឡេ ឌឹកថូ មេដឹកនាំវៀតមិញ ប្រចាំការនៅក្នុងប្រទេសកម្ពុជា បានស្នើឲ្យមេដឹកនាំខ្មែរឥស្សរៈជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន ធ្វើការប្រជុំពិភាក្សាគ្នា ដើម្បីបង្កើតបក្សរបស់កម្ពុជា ។

ឡេ ឌឹកថូ កើតនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩១១ ។ គាត់មានគំនិតជាតិនិយមតាំងពីវ័យជំទង់។ នៅឆ្នាំ១៩៣០ គាត់បានចូលរួមជាមួយបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលបង្កើតដោយហូ ជីមិញ ធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង គាត់ត្រូវអាជ្ញាធរអាណានិគមបារាំង ចាប់យកទៅដាក់គុកកោះត្រឡាច ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៣៦។

ក្រោយពេលចេញពីគុកកោះត្រឡាច វិញ គាត់នៅតែបន្តធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមនិយមបារាំង ហើយក៏ត្រូវពួកអាណានិគមនិយមបារាំង ចាប់យកទៅដាក់គុកកោះត្រឡាច ម្តងទៀត នៅក្នុងឆ្នាំ១៩៣៩។

ក្រោយបារាំង ចាញ់សង្គ្រាម គាត់ត្រូវបានដោះលែងវិញនៅក្នុងឆ្នាំ១៩៤៥ ហើយបានក្លាយជាមេដឹកនាំចលនាសម្ព័ន្ធដើម្បីឯករាជ្យវៀតណាម ហៅកាត់ថា វៀតមិញ ប្រឆាំង



**សឺង ង៉ុកមិញ**

នឹងពួកអាណានិគមនិយមបារាំង បន្តទៀតនៅលើទឹកដីឥណ្ឌូចិនទាំងមូល។

នៅក្នុងឆ្នាំ១៩៤៨ គាត់ត្រូវបានចាត់តាំងជាអនុលេខាបក្សកុម្មុយនិស្តឥណ្ឌូចិន នៅកូសាំងស៊ីន និងបានចូលមកជួយពង្រឹងដល់ចលនាឥស្សរៈខ្មែរដែលដឹកនាំដោយសឺង ង៉ុកមិញផងដែរ។

តាមប្រភពពីពួកវៀតមិញ បានឲ្យដឹងថា សមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន ជាជនជាតិខ្មែរនៅក្នុងប្រទេសនៅពេលនោះ មានចំនួនប្រហែល៣០០នាក់ ចែកចេញជាសាខាបក្សយោធា ២០សាខា, សាខាបក្សតាមភូមិភាគ ១៦សាខា, សាខាបក្សតាមស្រុក ១២សាខា, សាខាបក្សតាមរោងចក្រ៤សាខា និងសាខាបក្សក្រុងភ្នំពេញ ១សាខា។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ នៅត្រពាំងរូង ស្រុកស្រែអំបិល ក្នុងខេត្តកំពត (សព្វថ្ងៃនៅក្នុងខេត្តកោះកុង) ដោយមានការគាំទ្រពួកវៀតមិញ ផងដែរ មេដឹកនាំខ្មែរឥស្សរៈដែលមាននិន្នាការទៅរកលទ្ធិកុម្មុយនិស្ត បានប្រារព្ធធ្វើពិធីបង្កើតបក្សខ្លួនឯងមួយហៅថា បក្សប្រជាជនបដិវត្តន៍ខ្មែរ។

បក្សប្រជាជនបដិវត្តន៍ខ្មែរ ដឹកនាំដោយគណៈកម្មាធិការមជ្ឈិមបក្ស១៥រូប ក្នុងនោះសឺង ង៉ុកមិញ ជាលេខាបក្ស, ទូ សាមុត ជាអនុលេខា ។

## របត់នយោបាយ

គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ មាន៥រូប គឺ សឺង ង៉ុកមិញ, ទូ សាមុត, ស៊ីវ ហេង, ចាន់ សម័យ, កែវ មុនី និងសមាជិកគណៈកម្មា ធិការមជ្ឈិមបក្ស ចំនួន១០រូប។ ចំណែកម៉ី ផូ ដែលជាមេដឹកនាំនៅភូមិភាគពាយ័ព្យប្រទេស បន្តិចក្រោយមក ក៏ត្រូវបានចាត់តាំងឲ្យមកធ្វើជាប្រធានព័ត៌មាននៅមន្ទីរមជ្ឈិមបក្ស ដែលមានទីតាំងនៅភ្នំល្អាង ខេត្តកំពត។

នៅក្នុងខែកក្កដា ឆ្នាំ១៩៥១ ដោយសារព្រះមហាក្សត្រនរោត្តម សីហនុ ដឹងថា ពួកខ្មែរឥស្សរៈដឹកនាំដោយសឺង ង៉ុកមិញ និងទូ សាមុត មានពួកវៀតមិញ ជាអ្នកឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង ដើម្បីប្រឆាំងនឹងបារាំង ក៏ដូចជាប្រឆាំងនឹងព្រះអង្គផងដែរនោះ ព្រះអង្គក៏បានហៅឈ្មោះឲ្យពួកនេះថា ពួកខ្មែរ-វៀតមិញ ចាប់ពីពេលនោះមក។

ទោះបីបានបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរហើយក៏ដោយ ក៏សឺង ង៉ុកមិញ នៅតែដឹកនាំរណសិរ្សឯកភាពឥស្សរៈ (UIF) បន្តទៀត ដើម្បីសហការជាមួយចលនាតស៊ូឥស្សរៈមិនមែនកុម្មុយនិស្តផ្សេងៗទៀត ពិសេសចលនាឥស្សរៈដែលនៅក្នុងគណៈកម្មាធិការរំដោះជាតិខ្មែរ (KPLN) នៅប៉ែកពាយ័ព្យប្រទេសដដែល។

ឯកសារសម្ងាត់មួយចុះនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៥១ របស់គណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម ដែលបានផ្ញើទៅមេដឹកនាំសាខាបក្សទាំង៣ភូមិភាគរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា ដោយភ្ជាប់មកជាមួយនូវពង្រាងលក្ខន្តិកៈ និងគោលនយោបាយរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ជាភាសាវៀតណាម ដែលអាជ្ញាធរបារាំង រឹបអូសបាននោះ មានខ្លឹមសារជាអាទិ៍ថា៖

យើងស្នើឲ្យមេដឹកនាំភូមិភាគទាំង៣ ចាត់ចែងបកប្រែខ្លឹមសារទាំងស្រុងដែលមាននៅក្នុងឯកសារលក្ខន្តិកៈ និងគោលនយោបាយរបស់គណបក្សប្រជាជនបដិវត្តន៍ខ្មែរនេះ ហើយផ្សព្វផ្សាយតែនៅក្នុងរង្វង់អង្គការចាត់តាំងរបស់បក្សបានហើយ និងធ្វើការពិភាក្សា ផ្តល់មតិយោបល់លើពង្រាងខ្លឹមសារលក្ខន្តិកៈ និងគោលនយោបាយនេះ ដើម្បីបញ្ជូនទៅខាងគណៈកម្មាធិការមជ្ឈិមបក្ស (បក្សពលករវៀតណាម) ឲ្យបានមុនខែកុម្ភៈ ឆ្នាំ១៩៥២ ។

គណៈកម្មាធិការមជ្ឈិមបក្ស នឹងយកមតិយោបល់ទាំងនោះ ទៅធ្វើការពិចារណា និងដាក់បញ្ចូលទៅក្នុងពង្រាងដើម ដើម្បីដាក់ជូនគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ខ្មែរ អនុម័តជាផ្លូវការ មុននឹងធ្វើការផ្សព្វផ្សាយទៅក្នុងចំណោមហាជន។

ចាប់តាំងពីពេលនោះមក កម្មាភិបាលរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរមួយចំនួនធំ ក៏ត្រូវបានគេបញ្ជូនឲ្យទៅរៀនសូត្រវគ្គនយោបាយ, ជំនាញសន្តិសុខ និងរដ្ឋបាល រយៈពេល ៨ខែ នៅខេត្តហាទៀង (ខេត្តពាម) វៀតណាមខាងត្បូង ផងដែរ។

បើតាមឯកសារសម្ងាត់មួយទៀតរបស់មេដឹកនាំវៀតមិញ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៥១ ដែលអាជ្ញាធរបារាំង រឹបអូសបានដែរនោះ បានសរសេរថា បក្សរបស់វៀតណាម រក្សាសិទ្ធិក្នុងការគ្រប់គ្រងបក្សរបស់លាវ និងកម្ពុជា ជាបងប្អូន ហើយប្រសិនបើស្ថានភាពមានលក្ខណៈអនុគ្រោះ បក្សបដិវត្តន៍ទាំង៣ វៀតណាម កម្ពុជា និងលាវ នឹងអាចរួបរួមគ្នាជាបក្សតែមួយវិញ។

នៅក្នុងឆ្នាំ១៩៥១នោះដែរ ពួកឥស្សរៈដែលព្រះមហាក្សត្រសីហនុ ឲ្យឈ្មោះថា ពួកខ្មែរ-វៀតមិញ នោះ បានបង្កើតកាសែតដោយលួចលាក់មួយ ឈ្មោះកាសែត "ឥស្សរៈ" ។ កាសែតនេះ មានទូ សាមុត ជាចាងហ្វាងនយោបាយ និងចេញផ្សាយរយៈពេលកន្លះខែម្តង។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៥១ កាសែត "ឥស្សរៈ" បានចុះផ្សាយអត្ថបទស្តីពីពិធីរំឭកខួបជ័យជម្នះបដិវត្តន៍ខែតុលា ឆ្នាំ១៩១៧ នៅសហភាពសូវៀត ដែលអាចបញ្ជាក់ច្បាស់ថា ជាការផ្សព្វផ្សាយឥទ្ធិពលនៃលទ្ធិកុម្មុយនិស្ត យ៉ាងពិតប្រាកដ។

បន្ទាប់មកទៀត ទូ សាមុត បានបង្កើតកាសែតដោយលួចលាក់មួយទៀតឈ្មោះ "សាមគ្គី" ដើម្បីប្រឆាំងនឹងបារាំងផង និងដើម្បីបញ្ជ្រាបលទ្ធិកុម្មុយនិស្តនៅក្នុងមជ្ឈដ្ឋានប្រជាជនខ្មែរផង ។

ពេលនោះ ឈ្មោះព្រំ សាមិត អតីតព្រះសង្ឃគង់នៅវត្តឧណ្ណាលោម ជាមួយលោកគ្រូអាចារ្យហែម ចៀវ និងជាអ្នកចូលរួមធ្វើបាតុកម្មទាមទារឲ្យអាជ្ញាធរបារាំង ដោះលែងលោកគ្រូអាចារ្យហែម ចៀវ និងប៉ាច ឈឺន មកវិញ កាលពីឆ្នាំ១៩៤២នោះ ក៏បានចូលរួមក្នុងចលនា

## របត់នយោបាយ

តស៊ូជាមួយបក្សប្រជាជនបដិវត្តន៍ខ្មែរដែរ ដោយគាត់បានបម្រើការងារជាអ្នកនិពន្ធកាសែត "ឥស្សរៈ" ដែលមានទូ សាមុត ជាចាងហ្វាងនយោបាយ នោះ។

# ៣២
# ប៉ែន សុវណ្ណ ចូលបម្រើកងទ័ពឥស្សរៈ តាំងពីអាយុ១៤ឆ្នាំ



**ប៉ែន សុវណ្ណ**

ក្នុងឆ្នាំ១៩៥០ ប៉ែន សុវណ្ណ ទើបមានអាយុ១៤ឆ្នាំ បានសុំលាម្តាយជាស្ត្រីមេម៉ាយ ទៅចូលបម្រើក្នុងជួរកងទ័ពឥស្សរៈ ក្រោមបញ្ជាការរបស់ញ៉ែម ស៊ុន។

ប៉ែន សុវណ្ណ កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៣៦ នៅភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ ជាកូនទី៣ ក្នុងចំណោមបងប្អូន ៧នាក់ ក្នុងគ្រួសារកសិករក្រីក្រ មួយ ។

ក្រោយពេលចូលបម្រើក្នុងជួរកងទ័ពឥស្សរៈ បានរយៈពេលជាង១ឆ្នាំ នៅរដូវប្រាំង ឆ្នាំ១៩៥១ គាត់ និងមិត្តភក្តិរួមអាវុធម្នាក់ទៀត ឈ្មោះញៀន ត្រូវបានថ្នាក់លើបញ្ជាឲ្យធ្វើ ដំណើរចេញពីមូលដ្ឋានរបស់ពួកគាត់នៅភាគខាងត្បូងនៃខេត្តកំពត ទៅតំបន់ប៉ែកខាងជើង នៃខេត្តកំពង់ស្ពឺ ដោយមានបាឡូដាក់ខោអាវម្នាក់មួយ និងកាំភ្លើងម្នាក់មួយដើមទៅតាម ខ្លួនផងដែរ។

## របត់នយោបាយ

ពួកគាត់ចេញដំណើរតាំងពីព្រលឹមស្រាងៗ កាត់តាមជើងព្រៃសម្បូរដោយសត្វសាហាវៗ រហូតដល់ពេលព្រលប់ ទើបបានទៅដល់ព្រំប្រទល់ខេត្តកំពត និងកំពង់ស្ពឺ ជាតំបន់ព្រៃភ្នំ តែក៏មានភូមិរបស់អ្នកស្រុកមួយៗដែរ ។

ប៉ែន សុវណ្ណ និងញៀន បានចូលទៅសុំផ្ទះយាយតាប្តីប្រពន្ធ២នាក់ និងកូនរបស់គាត់ ដើម្បីសម្រាកមួយយប់។

យាយតាចិត្តធម៌២នាក់នោះ ក៏បានដាំបាយ និងចំហុយប្រហុកឲ្យពួកគាត់ទទួលទានជុំគ្នា។ សម័យនោះ ប្រជាជននៅតាមជនបទព្រៃភ្នំមានជីវភាពក្រីក្រណាស់ សូម្បីតែស្លាបព្រាសម្រាប់ទទួលទានបាយ ក៏គ្មានផង។ ពួកគាត់នាំគ្នាទទួលទានបាយដោយប្រើម្រាមដៃ ។

ពេលយប់ត្រជាក់ ក៏គ្មានភួយ មុង កន្ទេលដែរ គឺត្រូវនាំគ្នាដុតភ្នក់ភ្លើងក្រោមផ្ទះរនាបឫស្សី ដើម្បីទប់ទល់នឹងអាកាសធាតុត្រជាក់ ។

លុះឮសូរមាន់រងាវ២ដង ប៉ែន សុវណ្ណ និងញៀន ដេកមិនសូវលក់ ក៏នាំគ្នាចុះមករកអាំងភ្លើងនៅក្រោមផ្ទះ។

តាយាយបម្រុងដាំបាយឲ្យប៉ែន សុវណ្ណ និងញៀន ទទួលទាន មុននឹងចេញដំណើរបន្តទៅមុខទៀតដែរ ស្រាប់តែឮសំឡេងស្នូរកាំភ្លើងចូលមកកាន់តែជិតបន្តិចម្តងៗ។

ពេលនោះ ប៉ែន សុវណ្ណ និងញៀន ត្រូវបង្ខំចិត្តឡើងទៅលើផ្ទះ ហើយលើកបាឡូស្ពាយ និងទាញកាំភ្លើងលោតចុះមកក្រោមវិញ។ តែយាយតាស្រែកឃាត់ថា កុំចេញទៅឲ្យសោះ ព្រោះទាហានបារាំង ព័ទ្ធជុំវិញភូមិអស់ហើយ។

ភ្លាមៗនោះដែរ យាយតាក៏ទាញយកបាឡូ និងកាំភ្លើងរបស់ប៉ែន សុវណ្ណ និងញៀន យកទៅកប់នៅក្នុងស្រូវនៅក្នុងដោក ហើយទាញដៃញៀន ឡើងលើផ្ទះវិញ រួចយកកន្ទេលកញ្ចាស់មួយមកដណ្តប់ ធ្វើជាអ្នកមានជំងឺគ្រុនចាញ់។

ចំណែកប៉ែន សុវណ្ណ តាយាយឲ្យអង្គុយនៅក្រោមផ្ទះអាំងភ្លើងជាមួយកូនៗពួកគាត់ រួចហើយពួកគាត់រត់ទៅកាត់ធាងម្នាស់មួយធាង មកចងសំយាបផ្ទះ នៅចំពីខាងលើមាត់ទ្វារជណ្តើរឡើងផ្ទះ។

តាមទំនៀមទម្លាប់ប្រពៃណីរបស់អ្នកស្រុកនៅទីនោះ បើឃើញម្ចាស់ផ្ទះណាចងព្យួរជាងម្នាស់នៅសំយាបផ្ទះដូចនេះ ជាសញ្ញាបញ្ជាក់ថា សមាជិកគ្រួសារនៅក្នុងផ្ទះនោះកំពុងមានជំងឺធ្ងន់ធ្ងរ និងតមនិយាយស្តីជាមួយមនុស្សដែលមកពីក្រៅ ហើយក៏មិនឲ្យមនុស្សដែលមកពីក្រៅនោះ ឡើងលើផ្ទះរបស់ខ្លួនដែរ។ មិនយូរប៉ុន្មាន ពួកទាហានខ្មែរ និងបារាំង បានចូលមកដល់មុខផ្ទះយាយតា ហើយដើរក្រឡឹងជុំវិញបន្តិចក្រោយមក ក៏មានទាហានខ្មែរម្នាក់ស្រែកសួរយាយដែលកំពុងអង្គុយធ្វើមុខស្រងូតស្រងាត់នៅមាត់ជណ្តើរថា៖ "យាយ! យប់មិញមានឃើញពួកឥស្សរៈឃួន-រៀតមិញ មកដេកក្នុងភូមិនេះទេ? "។

យាយម្ចាស់ផ្ទះមិនទាន់ឆ្លើយថាយ៉ាងម៉េចផង ស្រាប់តែមានទាហាន ២នាក់ទៀតដើរចូលមកក្នុងបំណាងឡើងឆែកឆេរលើផ្ទះ។

យាយម្ចាស់ផ្ទះក៏ចង្អុលប្រាប់ថា មានឃើញជាងម្នាស់ចងនៅលើសំយាបផ្ទះនេះដែរឬទេ? តែពួកទាហាននៅតែជម្នះឡើងទៅលើផ្ទះនោះ រហូតមានការប្រទាញប្រទង់គ្នា។

ពេលនោះដែរ ក៏មានទាហាន២នាក់ទៀតបានដើរចូលទៅក្រោមផ្ទះ ចាប់ក្របួចសក់ក្បាលប៉ែន សុវណ្ណ ដែលកំពុងអង្គុយធ្វើជាអាំងភ្លើង ឲ្យក្រោកឈរឡើង ហើយទាត់២ជើង រួចសួរថា៖ " អាឯង! មិនមែនជាអ្នករស់នៅក្នុងស្រុកភូមិនេះទេ? "។

ប៉ុន្តែដោយសារប្រាជ្ញាដ៏ឈ្លាសវៃរបស់តាយាយម្ចាស់ផ្ទះ នៅទីបំផុត ពួកទាហានខ្មែរ និងបារាំងទាំងនោះ ក៏បានចាកចេញទៅវិញអស់។

# ៣៣
# ខ្មែរឥស្សរៈបែកបាក់ សម្លាប់តែគ្នាឯង



**ទ្រង់ចន្ទរង្សី**

ក្នុងឆ្នាំ១៩៥១ នៅទឹកដីកម្ពុជាក្រោម ដែលបារាំង បានកាត់ទៅឲ្យវៀតណាម កាលពី ៣ឆ្នាំមុននោះ ព្រះសង្ឃ និងប្រជាពលរដ្ឋរស់នៅទីនោះ មានជំនឿលើចលនាតស៊ូខ្មែរឥស្សរៈ នៅក្នុងប្រទេសកម្ពុជា ខ្លាំងណាស់ ព្រោះពួកគេមើលឃើញថា ពួកខ្មែរឥស្សរៈនេះប្រឆាំង នឹងពួកអាណានិគមបារាំង យ៉ាងប្តូរផ្តាច់បំផុត ហើយព្រះសង្ឃជាច្រើននៅទីនោះ ក៏បាន ចូលរួមយ៉ាងសកម្មក្នុងចលនាតស៊ូនោះដែរ ដោយអនុញ្ញាតយកសាលាពុទ្ធិកៈ ឲ្យពួកមេ ខ្មែរឥស្សរៈធ្វើជាសាលាបើកវគ្គបំពាក់បំប៉ននយោបាយដល់ពួកអ្នកតស៊ូខ្មែរឥស្សរៈ រហូត ដល់អាជ្ញាធររាជការខ្មែរ-បារាំង ចាត់ទុកថា វត្តទាំងនោះជាមូលដ្ឋានតស៊ូរបស់ពួកឥស្សរៈ ទៀតផង។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៥១ ព្រំ សាមិត ជាអ្នកនិពន្ធកាសែតឥស្សរៈ បានអមដំណើរ សឹង ង៉ុកមិញ ហៅអាចារ្យមៀន និងចាន់ សម័យ ព្រមទាំងព្រះសង្ឃនៅក្នុងខេត្តកំពត ៥

អង្គទៀត ទៅកាន់ស្រុកមួយចំនួននៅទឹកដីកម្ពុជាក្រោម។

ក្នុងឱកាសជួបប្រជុំព្រះសង្ឃ និងប្រជាពលរដ្ឋជាពុទ្ធបរិស័ទពីវត្តមួយទៅវត្តមួយ ពីស្រុកមួយទៅស្រុកមួយ សឺង ង៉ុកមិញ តែងតែព្យាយាមឃោសនាពន្យល់ដល់អង្គប្រជុំពីតួនាទីរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទនៅក្នុងព្រះពុទសាសនា ដែលត្រូវបំពេញកាតព្វកិច្ចក្នុងបុព្វហេតុរួមចំណែកក្នុងការតស៊ូដើម្បីឯករាជ្យរបស់ប្រទេសជាតិ ។

សឺង ង៉ុកមិញ បានលើកឡើងថា ជាតិសាសន៍ខ្មែរ ជាជាតិសាសន៍អង់អាចក្លាហាន មិនខ្លាចស្លាប់ក្នុងការប្រយុទ្ធប្រឆាំងជាមួយសត្រូវ ដើម្បីការពារព្រះពុទ្ធសាសនា និងប្រទេសជាតិរបស់ខ្លួន។

ប្រជាជនខ្មែរទាំងមូលជាអ្នកគោរពប្រតិបត្តិតាមឱវាទព្រះពុទ្ធ ហើយស៊ូស្លាប់ មិនព្រមធ្វើជាទាសករ និងមិនព្រមឲ្យគេមើលងាយ មើលថោកដល់សាសនារបស់ខ្លួនឯងដាច់ខាត។

ប៉ុន្តែនៅប្រជុំក្នុងចំណោមព្រះសង្ឃ និងប្រជាជននៅកម្ពុជាក្រោមនោះ សឺង ង៉ុកមិញ មិនដែលលើកឡើងអ្វីៗដែលពាក់ព័ន្ធនឹងលទ្ធិកុម្មុយនិស្តបន្តិចឡើយ។

ចំណែកនៅប៉ែកពាយ័ព្យប្រទេសវិញ ក្រោយពីដាប ឈួន ចុះចូលជាមួយមន្ត្រីរាជការខ្មែរ-បារាំងមក កៅ តក់ និងលាវ កែវមុនី បានរួបរួមគ្នាជាក្រុមតែមួយ និងមានកងទ័ពប្រហែល២៥០នាក់ ដោយមានកៅ តក់ ជាមេបញ្ជាការ។

ឯលាវ កែវមុនី ធ្លាប់កាន់តំណែងជាចៅហ្វាយស្រុក កាលសៀម ចូលមកកាន់កាប់ខេត្តបាត់ដំបង ពីឆ្នាំ១៩៤១-ដល់១៩៤៦នោះ មានបទពិសោធន៍ខាងនយោបាយ និងការដឹកនាំជាងកៅ តក់ ។

បន្ទាប់មក កៅ តក់ និងលាវ កែវមុនី បាននាំគ្នាមកចូលរួមក្នុងគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) វិញ ដែលពេលនោះ ប៉ុក ផល្គុណ ឬប៉ុក គុណ ហៅតាត្រឡាច បានឡើងជាប្រធានគណៈកម្មាធិការរំដោះជាតិខ្មែរនេះ ជំនួសដាប ឈួន ហើយកៅ តក់ ត្រូវបានទទួលតំណែងមេបញ្ជាការកងទ័ពគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) នោះ។

ប៉ុន្តែមិនបានប៉ុន្មានខែផង ប៉ុក គុណ ហៅតាត្រឡាច ត្រូវរងការចោទប្រកាន់ថា

បានកិបកេងប្រាក់ដែលគណៈកម្មាធិការឲ្យគាត់យកទៅទិញអាវុធ នៅក្រុងបាងកក ចំនួន ៦០ម៉ឺនរៀល។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥១ លាវ កែវមុនី ត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ជំនួសប៉ុក គុណ ហៅតាត្រឡាច ហើយប៉ុក គុណ ហៅតាត្រឡាច ត្រូវបញ្ចុះតំណែងមកជាមេបញ្ជាការរងកងទ័ពគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) វិញ។

ក្រោយបានឡើងធ្វើជាប្រធានគណៈកម្មាធិការរំដោះជាតិខ្មែរ លាវ កែវមុនី មានបំណងចង់សហការជាមួយរណសិរ្សឯកភាពឥស្សរៈ (UIF) ដែលមានសឺង ង៉ុកមិញ ជាប្រធាននោះដែរ តែកៅ តក់ ប្រឆាំងមិនព្រមឲ្យរួមសហការជាមួយរណសិរ្សដែលស្និទ្ធនឹងពួកវៀតមិញនោះជាដាច់ខាត។

ដោយសារមិនមានការឯកភាពគ្នាពីរឿងនេះ ក្រោយមក លាវ កែវមុនី បានចោទប្រកាន់កៅ តក់ ថា បានធ្វើបាបជិះជាន់សង្កត់សង្កិនប្រជាជនជាច្រើនករណី។

ចាប់ពីពេលនោះមក អ្នកទាំង២ ក៏កាន់តែមានទំនាស់នឹងគ្នាតានតឹងឡើងៗ។ មិនយូរប៉ុន្មាន កៅ តក់ ក៏ត្រូវបានដកចេញពីតំណែងមេបញ្ជាការកងទ័ពគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ដោយសារគាត់បានធ្វើសកម្មភាពដើររំអែអង្គាស និងទារពន្ធពីប្រជាជនតាមទំនើងចិត្តខ្លួនឯង។

បើតាមប្រភពស៊ើបការណ៍របស់បារាំង បានឲ្យដឹងថា ក្រោយការដកហូតតំណែងជាមេបញ្ជាការកងទ័ពគណៈកម្មាធិការរំដោះជាតិខ្មែរ មក កៅ តក់ បាននាំកងទ័ពមួយចំនួនពួនស្ទាក់ចាំបាញ់សម្លាប់ លាវ កែវមុនី ។

ប៉ុន្តែពេលនោះ លាវ កែវមុនី មានកងទ័ពតាមការពារច្រើនជាង ក៏បានវាយបកទៅលើកងទ័ពកៅ តក់ ឲ្យបរាជ័យ ហើយកៅ តក់ ខ្លួនឯងក៏ត្រូវរបួសដែរ តែបានរត់គេចខ្លួនរួច។

ក្រោយហេតុការណ៍ពួនស្ទាក់បាញ់សម្លាប់លាវ កែវមុនី មក គណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ក៏បានប្រកាសតាមរកចាប់ខ្លួនកៅ តក់ យកមកប្រហារជីវិត។

ចំណែកកៅ តក់ ដែលរងរបួសនោះ បានគេចខ្លួនទៅព្យាបាលមុខរបួសនៅក្នុងបន្ទាយទាហានរាជការខ្មែរ-បារាំង នៅក្នុងស្រុកសំរោង មួយរយៈពេលខ្លី រួចបន្តទៅព្យាបាលនៅប្រទេសសៀម។

លុះបានជាសះស្បើយ គាត់ក៏បានត្រឡប់ចូលមកក្នុងទឹកដីខ្មែរ វិញ ប្រមែប្រមូល និងបង្កើតកងទ័ពជាថ្មីម្តងទៀត បានចំនួន៣០០នាក់ បំពាក់អាវុធគ្រប់ដៃ ដែលទិញមកពីប្រទេសសៀម។

ក្រោយពេលដឹងថា កៅ តក់ បានត្រឡប់ចូលមកបង្កើតទ័ពជាថ្មីម្តងទៀតនោះ លាវ កែវមុនី ដែលពេលនោះមានកងទ័ពចំនួន៣វរសេនាតូច ដោយមានអាចារ្យទុំ សុខ , អ៊ូជ នីលពេជ្រ និងជឹម ត្រឡាយ ជាមេបញ្ជាការផងនោះ ក៏បានសហការជាមួយរណសិរ្សឯកភាពឥស្សរៈ (UIF) និងពួកវៀតមិញ បើកការវាយប្រហារបោសសម្អាតកងទ័ពរបស់ កៅ តក់ មិនឲ្យធ្វើព្យុះ ធ្វើភ្លៀងបានទៀតឡើយ។

ក្នុងអំឡុងពេលវាយប្រយុទ្ធគ្នានោះ កៅ តក់ បានសម្លាប់ប្រជាជនចំនួន៥០នាក់ ដែលគាត់បានចោទប្រកាន់ថា ប្រជាជនទាំងនោះ គឺជាដៃជើង ឬជានេុកក្នុងរបស់លាវ កែវមុនី។

ពេលកំពុងធ្វើសកម្មភាពនៅខេត្តកំពង់ឆ្នាំង និងនៅភាគខាងជើងនៃខេត្តកណ្តាល ដោយសារមានជម្លោះវាយប្រហារគ្នាជាមួយក្រុមទ្រង់ចន្ទរង្សី ពិសេសនៅតំបន់ស្រះឃ្លាំងអង្គខ្មៅ ក្នុងស្រុកសំរោង-ទង និងស្រុកឧដុង្គ ព្រមទាំងមានការប្រណែននិន្នាឈ្នានីសផងដែរ មេខ្មែរឥស្សរៈឈ្មោះពុត ឆាយ បានប្រើល្បិចឱ្យមេទ័ព



ពុត ឆាយ

## របត់នយោបាយ

ដ៏ល្បីរបស់គាត់ម្នាក់ឈ្មោះ ស៊ាប ព្រមជាមួយកូនចៅប្រហែល៣០នាក់ ធ្វើជាទៅចុះចូលជាមួយទ្រង់ចន្ទ រង្សី។

ស៊ាប ជាមនុស្សសម្បុរខ្មៅ មាឌធំក្រអាញ តែងតែស្លៀកតែខោខុងម៉ូវ លែងខ្លួនទទេពាក់ខ្សែកតេជៈ បន្តោងរូបព្រះគោដាំពេជ្រគ្រាប់ធំៗ ដើម្បីបង្ហាញឱ្យគេឯងឃើញថា គាត់ជាអ្នកមានបារមីខ្លាំងពូកែ បាញ់មិនត្រូវ កាប់មិនមុតដុតមិនឆេះ គាត់ល្បីល្បាញថាជាមេទ័ពដ៏ក្លាហាន ដឹកនាំកងទ័ពប្រយុទ្ធយ៉ាងអង់អាចក្លាហាន មិនខ្លាចស្លាប់បន្តិចឡើយ។

ក្រោយពីចុះចូលមក គាត់បានដឹកនាំការប្រយុទ្ធវាតតំបន់ត្រួតត្រារបស់ទ្រង់ចន្ទរង្សីឱ្យកាន់តែរីកធំឡើងជាលំដាប់ ហើយគាត់តែងតែនាំភរិយាទាំងពីរនាក់ (ម្នាក់ជាតិខ្មែរ ម្នាក់ទៀតយួន) របស់គាត់ដើរធ្វើសង្គ្រាមគ្រប់ទិសទីពីខេត្តកំពង់ស្ពឺ រហូតដល់ខេត្តកោះកុង។

ចំណែកទ្រង់ចន្ទរង្សី ដោយឃើញស៊ាប បានខិតខំដឹកនាំកងទ័ពចេញច្បាំងឈ្នះជាច្រើនសមរភូមិ ហើយមានការនឿយហត់ច្រើន ទើបទ្រង់បញ្ជាឱ្យអ្នកនាំសារទៅហៅគាត់ពីខេត្តកោះកុង មកក្រោយវិញ ហើយឱ្យពួកគាត់មកសម្រាកយកកម្លាំងមួយរយៈនៅភូមិក្រាំងម្កាក់ ឃុំក្រាំងម្កាក់ ក្នុងស្រុកច្បារមន ខេត្តកំពុងស្ពឺ។

ទ្រង់ចន្ទរង្សី បានឱ្យគេរៀបចំពិធីស៊ីផឹកឱ្យស៊ាប និងកូនចៅគាត់ទាំងអស់រយៈពេល៧យប់៧ថ្ងៃ។

អំឡុងពេលនោះ ជាចៃដន្យថ្ងៃមួយ យុទ្ធជនរបស់ទ្រង់ចន្ទរង្សី ចាប់បានសំបុត្រសម្ងាត់មួយដែលពុត ឆាយ ផ្ញើផ្ញើឱ្យស៊ាប ប្រញាប់ចាត់ការសម្លាប់ទ្រង់ចន្ទរង្សី ដូចបានគ្រោងទុក។

តែ ស៊ាប មិនបានដឹងខ្លួនថារឿងនេះត្រូវបែកការណ៍ហើយទេ។

ទ្រង់ចន្ទរង្សី បានបញ្ជាឱ្យសុកសេង រឿងមុនី និងនី វ៉ាន់ធី ធ្លាប់មានស្នាដៃខ្លាំងពូកែក្នុងការប្រយុទ្ធតតាំងជាមួយសត្រូវ ដើម្បីរៀបចំកម្លាំងទៅកម្ចាត់ស៊ាប ឱ្យបានមុន។

តែទោះបីជាយ៉ាងណា ក៏កូនចៅទ្រង់ទាំងអស់នោះនៅតែញញើតដែរ ព្រោះនរណាក៏ល្បីថា ស៊ាប មានបារមីខ្លាំងពូកែ បាញ់មិនត្រូវ កាប់មិនមុត ដុតមិនឆេះដែរ។

នៅពេលយប់ កងទ័ពទ្រង់ចន្ទរង្សី បានលបទៅព័ទ្ធភូមិដែលពួកស៊ាប ជប់លៀងស៊ីផឹកនោះចំនួន៣ជាន់។

បន្ទាប់ពីស៊ីផឹកសប្បាយរហូតដល់រំលងអធ្រាត្រ កងទ័ពស៊ាប ដែលនៅខាងក្រោមក៏ស្រវឹងដេកលក់អស់។ តែស៊ាប ដែលកំពុងដេកនៅលើផ្ទះខ្ពស់នោះជាមនុស្សមានការប្រយ័ត្នប្រយែងណាស់ គាត់នៅចុះពីលើផ្ទះមកដាស់តឿនឱ្យកូនចៅគាត់ម្នាក់ក្រោកឡើងហើយឱ្យអង្គុយយាមនៅលើកាំជណ្តើរ។

តែដោយសារដឹងថា អ្នកអង្គុយយាមនៅលើកាំជណ្តើរនោះ ដេកលក់ទាំងអង្គុយទើបសុកសេង រឿងមុនី និងនី វ៉ាន់ជី មានឱកាសលបចូលទៅខាងក្រោយផ្ទះដែលស៊ាបដេកនោះ។

តែចៃដន្យ មានកូនចៅសុកសេង រឿងមុនី និងនី វ៉ាន់ជី ម្នាក់បានធ្វើឲ្យរៀលកៃកាំភ្លើងផ្ទុះលាន់ឡើង ធ្វើឲ្យកូនចៅស៊ាប ដែលកំពុងដេកលក់នៅក្រោមផ្ទះភ្ញាក់មមីងមមាំង។ ចំណែកស៊ាប ស្ទុះទៅទាញកាំភ្លើងយន្តដាក់បង់ពីលើ ស្ទុះលោតចុះពីលើផ្ទះ ហើយបាញ់រះតបតវិញធ្វើឱ្យអ្នកឡោមព័ទ្ធភ័យលស់ព្រលឹងគ្រប់ៗគ្នា។

ពេលនោះដែរ កូនចៅសុកសេង រឿងមុនី ពីរនាក់ដែលចូលទៅជិតផ្ទះនោះបានបាញ់ ស៊ាប ពីក្រោយខ្នងដែរ តែបាញ់មិនផ្ទុះសោះ។

ទីបំផុត ស៊ាប បានបាញ់បើកផ្លូវរំដោះខ្លួន នាំប្រពន្ធយួន និងកូនចៅមួយចំនួនចេញពីការឡោមព័ទ្ធនោះដោយសុវត្ថិភាព។ តែកូនចៅគាត់មួយចំនួនត្រូវស្លាប់ និងប្រពន្ធជាជនជាតិខ្មែររបស់គាត់ ក្រុមទ្រង់ចន្ទរង្សី ចាប់ខ្លួនបាន ហើយខ្សែកគេជៈ បន្តោងរូបព្រះគោដាំពេជ្រគ្រាប់ធំៗរបស់ស៊ាប នោះ ក៏ត្រូវរឹបអូសបានដែរ ព្រោះពេលនោះគាត់ស្រវាយកមកពាក់និងកមិនទាន់។

ក្រោយពីបានទៅរួមប្រជុំត្រីភាគី (វៀតណាម-កម្ពុជា-លាវ) នៅលើភ្នំមួយ នៃភាគខាងជើងវៀតណាម ជាមួយគួន ឌឹកថាំង តំណាងភាគីវៀតណាម និងទ្រង់សុផានវង្សតំណាងភាគីឡាវ កាលពីខែមីនា ឆ្នាំ១៩៥១មក ស៊ីវ ហេង បានវិលត្រឡប់មកដល់មាតុ

ប្រទេសវិញ នៅក្នុងខែសីហា ឆ្នាំ១៩៥១ ដដែល។

ពេលនោះ គាត់បានចុះពង្រឹងចលនាបដិវត្តន៍នៅភូមិភាគនិរតី មួយរយៈ ទើបគាត់វិលត្រឡប់ទៅកាន់ភូមិភាគពាយ័ព្យ ដែលជាមូលដ្ឋានតស៊ូដើមរបស់គាត់វិញ ដើម្បីពង្រឹងចលនាបដិវត្តន៍នៅទីនោះផង និងធ្វើការបង្រួបបង្រួមគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) ជាមួយរណសិរ្សឯកភាពឥស្សរៈ (UIF) ផង។

ជាមួយគ្នានោះ គាត់ក៏បានព្យាយាមធ្វើការសម្របសម្រួល ដើម្បីឲ្យលាវ កែវមុនី និងកៅ តក់ ជានានឹងគ្នាវិញផងដែរ។

នៅភូមិភាគពាយ័ព្យនោះ មានគណៈកម្មាធិការយោជាមួយ មានមូល សម្បត្តិ ហៅរស់ ញឹម ជាអ្នកទទួលខុសត្រូវរួម។

ចំណែកនួន ជា ជាអ្នកទទួលខុសត្រូវខាងនយោបាយ និងអាចារ្យប៊ុន កាសេន ជាអ្នកទទួលខុសត្រូវខាងសេដ្ឋកិច្ច ។

ស៊ីវ ហេង និងស្ត្រីឈ្មោះលាត មួន ហៅម៉ែមួន ដែលជាវីរនារីចលនាតស៊ូខ្មែរឥស្សរៈដ៏ឈ្លាសវៃ និងក្លៀវក្លាបំផុតតាំងពីដើមមកនោះ បានខិតខំប្រឹងប្រែងយ៉ាងអស់ពីចិត្តពីថ្លើមក្នុងការបញ្ចុះបញ្ចូលកៅ តក់ ជាប្អូនប្រុសចិញ្ចឹមរបស់គាត់ឲ្យជានាជាមួយលាវ កែវមុនី រហូតបានសម្រេច ហើយបានធ្វើឲ្យគណៈកម្មាធិការរំដោះជាតិខ្មែរ (KNLC) និងរណសិរ្សឯកភាពឥស្សរៈ(UIF) ចងសម្ព័ន្ធភាពនឹងគ្នាប្រកបដោយជោគជ័យផងដែរ ។

# ៣៤
# ឃាតកម្មគប់គ្រាប់បែកដែលសម្លាប់អៀវ កើស



អៀវ កើស



ទិដ្ឋភាពដង្ហែសពលោកអៀវ កើស

នៅព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥០ គណៈកម្មាធិការនាយកគណបក្សប្រជាធិបតេយ្យ បានបើកអង្គប្រជុំមួយនៅក្នុងស្នាក់ការគណបក្សស្តីពីបញ្ហាបង្កើតឱ្យមានសភាឡើងវិញ ក្រោយពីព្រះមហាក្សត្រសីហនុ ប្រកាសរំលាយសភាកាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៤៩មក និងបញ្ហាព្រះមហាក្សត្រសីហនុ ចង់កែប្រែមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ព្រមទាំងបញ្ហាផ្សេងៗមួយចំនួនទៀត។

ពេលនោះអង្គប្រជុំបានអូសបន្លាយរហូតដល់វេលារសៀល ទើបរំសាយ ហើយគណៈ-កម្មាធិការនាយកគណបក្សប្រជាធិបតេយ្យ បានចាកចេញពីស្នាក់ការគណបក្ស ត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញអស់ នៅសល់តែ អៀវ កើស ប្រធានគណបក្ស និងតំណាងរាស្ត្រម្នាក់ឈ្មោះហាក់ ម៉ុងសេង នៅពិភាក្សាគ្នាបន្តទៀត។

លុះប្រហែលម៉ោង៥ល្ងាច តំណាងរាស្ត្រម្នាក់ទៀតឈ្មោះង៉ែត ហៀន បានចូលមកដល់ អៀវ កើស ក៏សួរថា ម៉េចក៏មកយឺតពេលម្ល៉េះ? ង៉ែត ហៀន ឆ្លើយថា សុំទោស! ខ្ញុំប្រឡំស្មានតែលោកប្រធានឱ្យជួបថ្ងៃស្អែក។

ដោយឃើញថា អៀវ កើស មានការណាត់ជួបង៉ែត ហៀន ហើយគាត់ត្រូវដល់ពេលទៅឱ្យគ្រូពេទ្យចាក់ថ្នាំផងដែរនោះ ហាក់ ម៉ុងសេង ក៏បានសុំលាអៀវ កើស ទៅមុន។

# របត់នយោបាយ

អៀវ កើស បានឱ្យង៉ែត ហៀន អង្គុយកៅអីទល់មុខគ្នា រួចសួរថា ម៉េចហើយរឿងឱ្យទៅរកកន្លែងបើកសន្និបាតគណបក្សនោះ?

ង៉ែត ហៀន ជម្រាបថា កន្លែងបើកសន្និបាតគណបក្សនោះរកបានហើយ គឺនៅរោងល្ខោនផ្សារកាប់គោ។

ពេលកំពុងពិភាក្សាគ្នាបន្តទៀតនោះ ស្រាប់តែមានជនអនាមិកម្នាក់បានបោះគ្រាប់-បែកដៃមួយគ្រាប់ចូលមកផ្ទុះលាន់កក្រើក បណ្ដាលឱ្យង៉ែត ហៀន ត្រូវរបួសបាក់ជើង។ ឯ អៀវ កើស ដែលរងរបួសធ្ងន់កំពុងដេកនៅក្នុងថ្លុកឈាម ខំប្រឹងត្រដរផ្ដាំផ្ញើង៉ែត ហៀន ថា សូមប្រាប់គ្នាយើងឱ្យបន្តនយោបាយទៅមុខទៀត រហូតដល់បានឯករាជ្យជូនជាតិ ។

អៀវ កើស ខំប្រឹងត្រដរផ្ដាំផ្ញើបន្តទៀតថា សូមប្រាប់គ្នាយើង កុំឱ្យមានការចងគំនុំតទៅទៀត ទុកឱ្យប្រជារាស្ត្រយើងរស់ក្នុងសុខសន្តិភាព...។

ក្រោយពីបញ្ជូនដល់មន្ទីរពេទ្យ អៀវ កើស ក៏ត្រូវបាត់បង់ជីវិតគួរឱ្យស្ដាយស្រណោះបំផុត ហើយត្រូវបានក្រុមគ្រួសារ និងមន្ត្រីគណបក្សប្រជាធិបតេយ្យ ដឹកសពយកមកគេហដ្ឋានដើម្បីតម្កល់ទុកធ្វើបុណ្យតាមប្រពៃណី។

ចំណែកង៉ែត ហៀន ត្រូវសម្រាកនៅមន្ទីរពេទ្យព្យាបាលមុខរបួសអស់រយៈពេល៨ខែទើបបានជាសះស្បើយ។

ហេតុការណ៍ឃាតកម្មគប់គ្រាប់បែកដៃសម្លាប់ប្រធានគណបក្សប្រជាធិបតេយ្យ ដ៏សាហាវព្រៃផ្សៃនេះ បើតាមឯកសារដែលង៉ែត ហៀន បានបន្សល់ទុកនោះ គាត់ហ៊ានសន្និដ្ឋានថា អ្នកគប់គ្រាប់បែកនោះ គ្មាននរណាក្រៅពីពួកភ្នាក់ងារសម្ងាត់បារាំង ទេ ព្រោះពេលកើតហេតុនោះ មានវត្តមានភ្នាក់ងារសម្ងាត់របស់បារាំង ជាច្រើននាក់បានមកឈ្លបយកការណ៍នៅជុំវិញស្នាក់ការគណបក្ស។ ដូច្នេះប្រសិនបើមានក្រុមណាផ្សេងទៀតចូលមកបោះគ្រាប់បែកនោះ ពួកគេប្រាកដជាចាប់បានមិនខាន។ ពិសេស ក្រោយពេលគាត់រងរបួសដោយសារគ្រាប់បែកផ្ទុះឡើងនោះ គាត់បានស្រែកហៅមន្ត្រីប្រចាំការស្នាក់ការគណបក្សម្នាក់ឈ្មោះសែម ឱ្យមកជួយ ស្រាប់តែឃើញមេប៉ូលិសខាងយកការណ៍សម្ងាត់ឈ្មោះ សេង

ទឹម ចូលមករកគាត់មុនគេទៅវិញ។ គាត់នឹកស្មានថា មេប៉ូលិសនោះ មកបាញ់គាត់ និង អៀវ កើស បន្ថែមទៀត។ តែបន្តិចក្រោយមក មេប៉ូលិសនោះក៏ចេញទៅវិញបាត់។



ទិដ្ឋភាពដង្ហែសពលោកអៀវ កើស

លុះពេលគេនាំគ្នាលើកគាត់ដាក់លើរថយន្ត ដើម្បីយកទៅសង្គ្រោះនៅមន្ទីរពេទ្យព្រះកេតុមាលា ក៏ឃើញមេប៉ូលិសសម្ងាត់ឈ្មោះសេង ទឹម នោះត្រឡប់មកវិញដោយមានភរិយាអៀវ កើស មកជាមួយផងដែរ។

ឃាតកម្មដ៏កំសាកថោកទាបនេះ មិនត្រូវបានសមត្ថកិច្ចរាជការខ្មែរ-បារាំង រកឃើញជនដៃដល់ ឬអ្នកនៅពីក្រោយខ្នងនោះឡើយ។ ប៉ុន្តែមន្ត្រីគណបក្សប្រជាធិបតេយ្យខ្លះសង្ស័យទៅលើពួកបារាំង ខ្លះចោទថា យ៉ែម សំបូរ ជាមេខ្លោង។

ករណីឃាតកម្មនេះ សមាជិកគណបក្សសេរីភាពម្នាក់ឈ្មោះនូ យ៉ា នៅបឹងបាយាបត្រូវសមត្ថកិច្ចប៉ូលិសចាប់យកទៅវាយសួរចម្លើយ ហើយគាត់បានឆ្លើយសារភាពថា ខ្លួនជាអ្នកគប់គ្រាប់បែកដៃចូលទីស្នាក់ការគណបក្សប្រជាធិបតេយ្យ ដើម្បីសម្លាប់អៀវ កើស។

សពអៀវ កើស ត្រូវបានគេយកទៅតម្កល់នៅគេហដ្ឋានរបស់គាត់ នៅផ្ទះលេខ ២៣៣ ផ្លូវសុជារស មាត់ទន្លេ ខាងត្បូងវត្តកែវព្រះភ្លើង ដើម្បីធ្វើបុណ្យទក្ខិណានុប្បទាន៧យប់៧ថ្ងៃ។

លុះដល់ថ្ងៃទី២២ ខែមករា ឆ្នាំ១៩៥០ សពត្រូវដង្ហែជាក្បួនយ៉ាងមហោឡារិក ឆ្ពោះទៅឈាបនដ្ឋាននៅវត្តបទុមវតី។

អៀវ កើស កើតនៅក្នុងឆ្នាំ១៩០៥ នៅឃុំសង្កែ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

## របត់នយោបាយ

គាត់ជាកូនប្រុសទោលនៅក្នុងគ្រួសារមួយ ដែលមានឪពុកឈ្មោះ អៀវ ហេង និងម្តាយឈ្មោះ ទឹក ។

កាលនៅវ័យកុមារ គាត់បានចូលរៀននៅសាលាវត្តកណ្តាល។ បន្ទាប់មកទៀតគាត់បានចូលរៀននៅសាលាបឋមសិក្សាខេត្តបាត់ដំបង រួចមកបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ និងបានចេញទៅសិក្សានៅសាលាពាណិជ្ជកម្ម ក្រុងហាណូយ ហើយបានប្រឡងជាប់លេខ១ នៅសាលាពាណិជ្ជកម្មនោះ នៅក្នុងឆ្នាំ១៩២៧។

ក្នុងឆ្នាំ១៩២៨ គាត់បានត្រឡប់មកមាតុប្រទេសវិញ ហើយបានចូលធ្វើការនៅក្នុងក្រុមហ៊ុនដឺនីហ្វ្រេរ នៅក្រុងភ្នំពេញ និងក្រុមហ៊ុនចម្ការកៅស៊ូបារាំង នៅស្រុកមេមត់ ខេត្តកំពង់ចាម។

នៅឆ្នាំ១៩២៨នោះ គាត់បានឈ្នះក្តីប្រធានក្រុមហ៊ុនកៅស៊ូជាជនជាតិបារាំង ពីបទប្រមាថមើលងាយគាត់នៅទីនោះ ហើយគាត់បានមកចាប់ផ្តើមអាជីពជាសហគ្រិនសាធារណការមួយ នៅស្រុកមេមត់ នោះបន្តទៀត។

នៅក្នុងឆ្នាំ១៩២៩ គាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកគ្រូម្នាក់ឈ្មោះ គឹម ស៊ីរី ហៅពាញ និងមានកូន២នាក់ ក្នុងនោះមានម្នាក់ឈ្មោះ អៀវ បណ្ណាការ។

អៀវ បណ្ណាការ នេះហើយ ដែលបានរៀបការជាមួយនារីឈ្មោះ អ៊ុំ សុផានិត ជាកូនស្រីពៅរបស់អ្នកស្រីប៉ុម ពាង (ម្តាយអ្នកម្នាងម៉ូនិក) ជាមួយស្វាមីទី១ ឈ្មោះអ៊ុំ ផាន់កែវ ហើយអ៊ុំ សុផានិត នេះ ត្រូវជាបងបង្កើតអ្នកម្នាងម៉ូនិក តែឪពុកផ្សេងគ្នា។

ទោះបីរវល់ក្នុងមុខរបររកស៊ីជាសហគ្រិនស្ថាបនាយ៉ាងណា អៀវ កើស ក៏បានឆ្លៀតឱកាសរៀនសូត្រខ្លួនឯងបន្ថែមទៀត រហូតប្រឡងជាប់អាហារូបករណ៍ទៅបន្តសិក្សានៅវិទ្យាស្ថានគីមី នៅទីក្រុងប៊័រដូ (Bordaux) ប្រទេសបារាំង នៅក្នុងឆ្នាំ១៩៣២។

ប៉ុន្តែពួកបារាំង បែរជារារាំងមិនឲ្យទៅបន្តការសិក្សានោះទៅវិញ ធ្វើឲ្យគាត់ត្រូវត្រឡប់មករកស៊ីជាសហគ្រិនសាធារណការ នៅស្រុកកំណើតរបស់គាត់ ឯក្រុងបាត់ដំបងវិញ ។

ក្រោយមក គាត់ក៏បានក្លាយជាសមាជិកគណៈកម្មការចម្រុះ នៃឧត្តមក្រុមប្រឹក្សា

ការពារផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អមពរាជរដ្ឋាភិបាលខ្មែរផងដែរ។



រូបសញ្ញាគណបក្សប្រជាធិបតេយ្យ

នៅក្នុងឆ្នាំ១៩៤១ គាត់បើកហាងលក់ឱសថ និងបើកសិប្បកម្មធ្វើសាប៊ូ នៅក្រុងបាត់ដំបង រហូតដល់ឆ្នាំ១៩៤៥ គាត់ក៏បានទៅបម្រើការងារជាមន្ត្រីជាន់ខ្ពស់នៅក្រសួងសេដ្ឋកិច្ច នៅឯក្រុងភ្នំពេញ។

ក្នុងឆ្នាំ១៩៤៦ អៀវ កើស បានចូលរួមជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលទើបមកពីប្រទេសបារាំង បង្កើតគណបក្សប្រជាធិបតេយ្យ ដើម្បីចូលរួមបោះឆ្នោតនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ ទទួលបានជោគជ័យយ៉ាងធំធេង ហើយគាត់បានឡើងជាប្រធានសភា។

ក្រោយព្រះមហាក្សត្រនរោត្តម សីហនុ ប្រកាសរំលាយសភា នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៤៩ អៀវ កើស ក៏ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី ពីថ្ងៃ២០ ខែកញ្ញា ដល់ថ្ងៃ២៨ ខែកញ្ញា ១៩៤៩ ពេលគឺគាត់ធ្វើនាយករដ្ឋមន្ត្រី បានរយៈពេលតែ៨ថ្ងៃប៉ុណ្ណោះ។

លុះដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥០ អៀវ កើស ក៏ត្រូវបាត់បង់ជីវិតដោយសារការគប់គ្រាប់បែកដៃចូលស្នាក់ការគណបក្សប្រជាធិបតេយ្យនោះតែម្តងទៅ ។

នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៥០ ព្រះមហាក្សត្រនរោត្តម សីហនុ បានរំលាយរាជរដ្ឋាភិបាល ដែលមាន យ៉ែម សំបូរ ជានាយករដ្ឋមន្ត្រីចោល ហើយបង្កើតរាជរដ្ឋាភិបាលថ្មីមួយទៀត ដោយមានព្រះអង្គផ្ទាល់ជានាយករដ្ឋមន្ត្រី , តាន់ ម៉ៅ ជាទេសរដ្ឋមន្ត្រី, ប៉ែន នុត ជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ, ឃិត ស្រ៊ុន ជារដ្ឋមន្ត្រីមហាផ្ទៃ, ម៉ម សុន ជារដ្ឋមន្ត្រីការបរទេស សាធារណការ និងគមនាគមន៍, អ៊ូ ឈីន ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ឃួន ណៃ ជារដ្ឋ

មន្ត្រីសេដ្ឋកិច្ចជាតិ, ចាន់ ណាក ជារដ្ឋមន្ត្រីយុត្តិធម៌, ពីទូ ដឺម៉ង់តេរ៉ូ ជារដ្ឋមន្ត្រីអប់រំជាតិ, នាល ផ្លេង ជារដ្ឋមន្ត្រីសាធារណសុខាភិបាល ការងារ និងសង្គមកិច្ច និងអ៊ុន ធិន ជារដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ ។

ប៉ុន្តែក្រោយបង្កើតរាជរដ្ឋាភិបាលថ្មីនេះមិនបានមួយខែពេញផង នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៥០ដដែលនោះ ព្រះមហាក្សត្រនរោត្តម សីហនុ បានរំលាយរាជរដ្ឋាភិបាលនេះចោលវិញ ហើយបបង្កើតរាជរដ្ឋាភិបាលថ្មីមួយទៀត។

រាជរដ្ឋាភិបាលថ្មីនោះ មានព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមហាផ្ទៃ និងព័ត៌មាន, រ៉ាយ ល្មុត ជារដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ និងផែនការ, សុន វ៉ុនសៃ រដ្ឋមន្ត្រីការពារជាតិ, អូ ឈីន ជារដ្ឋមន្ត្រីហិរញ្ញវត្ថុ, ទឹម កេន ជារដ្ឋមន្ត្រីសាធារណការ និងគមនាគមន៍, ចាន់ ណាក ជារដ្ឋមន្ត្រីយុត្តិធម៌, ពីទូ ដឺម៉ង់តេរ៉ូ ជារដ្ឋមន្ត្រីអប់រំជាតិ និងយុវជន, ឃួន ណៃ ជារដ្ឋមន្ត្រីកសិកម្ម និងចិញ្ចឹមសត្វ, នាល ផ្លេង ជារដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច, មាស ហ៊ែល ជារដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ, សឺន សាន ជារដ្ឋមន្ត្រីការបរទេស និងជា ជិនកុក ជារដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥០ សហរដ្ឋអាមេរិក បានចាប់ផ្តើមបង្កើតទំនាក់ទំនងការទូតជាលើកដំបូង ជាមួយប្រទេសកម្ពុជា ដោយបានតែងតាំងមន្ត្រីម្នាក់ឈ្មោះដូណាល់ ហ៊ីល( Donald R. Heath ) ឲ្យមកធ្វើជាតំណាង។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៥០ ដូណាល់ ហ៊ីល ( Donald R. Heath ) បានចូលថ្វាយសារតាំងទៅព្រះមហាក្សត្រនរោត្តម សីហនុ នៅក្នុងព្រះបរមរាជវាំង។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ ស្ថានតំណាងសហរដ្ឋអាមេរិក បានបើកឲ្យមានជាលើកដំបូងនៅភ្នំពេញ ដោយមានទីតាំងនៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ ស្ថានតំណាងសហរដ្ឋអាមេរិក ត្រូវបានដំឡើងឲ្យទៅជាស្ថានឯកអគ្គរដ្ឋទូត ហើយដូណាល់ ហ៊ីល (Donald R. Heath )បានក្លាយទៅជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅប្រទេសកម្ពុជាផងដែរ។

# ៣៥
# ស៊ីន សាន ឡើងជាប្រធានសភា ដោះស្រាយបញ្ហាបាតុកម្ម



**ស៊ីន សាន**

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ ព្រះមហាក្សត្រនរោត្តម សីហនុ បានធ្វើការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ដែលមានព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស ជានាយករដ្ឋមន្ត្រីនោះ មួយចំនួន ដោយដក ប៉ាយ ល្មុត , ចាន់ ណាក , នាល ផ្លេង និងជា ជិនកុក ចេញ ហើយដាក់សម ញាណ (ឪពុកសម សារី) ជារដ្ឋមន្ត្រីក្រសួងធម្មការ និងវិចិត្រសិល្បៈ , ញឹក ជូឡុង ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, ហ៊ុយ កន្ធុល ជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងយុវជន, ម៉ម សុន ជារដ្ឋលេខាធិការក្រសួងសុខាភិបាល និងសង្គមកិច្ច ។

ប៉ុន្តែរាជរដ្ឋាភិបាលនេះ មានអាយុ២ខែប៉ុណ្ណោះ ក៏ត្រូវព្រះមហាក្សត្រប្រកាស

វិលោយវិញ ហើយនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥១ ព្រះអង្គក៏បានរៀបចំសមាសភាពរដ្ឋាភិបាលថ្មីមួយទៀត ដោយមានអ៊ុម ឈាងស៊ុន ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ , ម៉ម សុន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល , ហ៊ុយ កន្ធុល ជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ , នាល ផ្លែង ជារដ្ឋមន្ត្រីក្រសួងការបរទេស , ញឹក ជូឡុង ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ , សម ញាណ ( ឪពុកសម សារី) ជារដ្ឋមន្ត្រីក្រសួងធម្មការ , ពីទូ ដឺម៉ុងតេរ៉ូ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ , អូ ឈីន ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងព័ត៌មាន , ផ្លែក ភឺន ជារដ្ឋមន្ត្រីក្រសួងកសិកម្ម , សុន វ៉ុនសៃ ជារដ្ឋមន្ត្រីក្រសួងសាធារណការ និងសម សារី (ឪពុកសម រង្ស៊ី) ជាអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ។

ប៉ុន្តែមកដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥១ រាជរដ្ឋាភិបាលដឹកនាំដោយអ៊ុម ឈាងស៊ុន បានធ្វើការរុះរើផ្លាស់ប្តូរសមាសភាពគណៈរដ្ឋមន្ត្រីមួយចំនួន ដោយដកហ៊ុយ កន្ធុល, ជា ជិនកុក, សុន វ៉ុនសៃ និងសម សារី ចេញ ហើយដាក់ប្រាក់ សារិន ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ចៅសែន កុសល ជារដ្ឋមន្ត្រីក្រសួងសាធារណការ-ផែនការ-គមនាគមន៍ និងប្រៃសណីយ៍, ទេព ផន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម និងជួប ហែល ជារដ្ឋមន្ត្រីក្រសួងកសិកម្ម។ ក្រៅពីនោះរក្សាទុកនៅដដែល ។

ក្រោយពីព្យួររដ្ឋធម្មនុញ្ញ និងគ្មានរដ្ឋសភាជាងមួយឆ្នាំមក នៅក្នុងខែកក្កដា ឆ្នាំ ១៩៥១ ព្រះមហាក្សត្រនរោត្តម សីហនុ បានត្រាស់បង្គាប់ឲ្យមានរបបសភានិយមឡើងវិញ ដោយឲ្យមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាថ្មីម្តងទៀត។

ពេលនោះ គណបក្សនយោបាយជាច្រើន បានរៀបចំខ្លួនដើម្បីចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិថ្មី។

យ៉ែម សំបូរ បានបំបែកខ្លួនទៅបង្កើតគណបក្សខ្លួនឯងមួយឈ្មោះគណបក្សហនុមាន និងសម ញាណ ( ឪពុកសម សារី) បានបំបែកខ្លួនទៅបង្កើតគណបក្សខ្លួនឯងមួយឈ្មោះគណបក្សប្រជារាស្ត្រ។

ការបោះឆ្នោតនោះ រៀបចំដោយនាយករដ្ឋមន្ត្រីអ៊ុម ឈាងស៊ុន និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រាក់ សារិន។ តែគណបក្សប្រជាធិបតេយ្យ ធ្វើការចោទប្រកាន់ថា អ៊ុម ឈាងស៊ុន និងប្រាក់ សារិន ជាមនុស្សពុំសូវមានអព្យាក្រឹតភាព និងមិនមានសមត្ថភាពប៉ុន្មានឡើយ។

សឺន សាន ត្រូវបានគណបក្សប្រជាធិបតេយ្យ ចាត់តាំងឲ្យឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រនៅមណ្ឌលភ្នំពេញ។

ពេលយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សសេរីភាព របស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត ដែលគេសង្ស័យថា ជាអ្នកនៅពីក្រោយខ្នងឃាតករបោកគ្រាប់បែកសម្លាប់អៀវ កើស នោះ បានដើរឃោសនាមួលបង្កាច់ថា សឺន សាន ជាជនជាតិយួន...។

ពេលនោះ សឺន សាន បានធ្វើការបកស្រាយបំភ្លឺវិញថា គឺព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ ពិនដារា ជាមាតារបស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត និងអនុជព្រះនាង គឺសម្តេចក្រុមហ្លួង ស៊ីសុវត្ថិ សុផាណាវង្ស ជាអ្នកនាំឪពុករបស់គាត់ឈ្មោះ សឺន សាច់ និងបងប្អូនជីដូនមួយម្នាក់ទៀត ពីទឹកដីកូសាំងស៊ីន (កម្ពុជាក្រោម) មករស់នៅក្រុងភ្នំពេញ តាំងពីមុនឆ្នាំ១៩០០មកម្ល៉េះ។ ក្រោយមក គាត់ និងភរិយាបានយកព្រះអង្គម្ចាស់នរោត្តម នរិន្ទវិទ្ធីវង្ស ជាបុត្រារបស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត នេះ មកចិញ្ចឹមបីបាច់ថែរក្សាទុកដូចជាកូនផងដែរ។

សឺន សាន ចង់បញ្ជាក់ប្រាប់សាធារណជនថា បើគាត់ជាជនជាតិយួន ដូចការចោទប្រកាន់របស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត មែននោះ ក៏មិនអាចលាក់ជិតដែរ។

លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិថ្មី ដែលបានធ្វើឡើងនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៥១នោះ បើទោះបីអស់ពីព្រះអង្គម្ចាស់យុត្តិវង្ស និងអៀវ កើស ទៅក៏ពិតមែន ក៏គណបក្សប្រជាធិបតេយ្យនៅតែឈ្នះឆ្នោតទទួលបាន៥៤អាសនៈ ក្នុងចំណោមអាសនៈសរុបក្នុងរដ្ឋសភា ចំនួន៧៨អាសនៈ, គណបក្សសេរីភាព រូបប្រាសាទកំពូលបី របស់ព្រះអង្គម្ចាស់នរោត្ត នរិន្ទដេត ដែលមានពួកបារាំង អ្នកគាំទ្រ ទទួលបាន១៨អាសនៈ , គណបក្សខេមរៈបុនក្ការ រូបនាងគង្ហីងព្រះធរណី របស់លន់ នល់ និងញឹក ជូឡុង ទទួល

បាន២អាសនៈ, គណបក្សឿសានមានជ័យ រូបទង់ជាតិពីរខ្វែងគ្នាទ្រមកុដ របស់ម៉ៅ ចយ ទទួលបាន៤អាសនៈ។

ចំណែកគណបក្សហនុមាន របស់យ៉ែម សំបូរ, គណបក្សចំរើនជាតិ រូបព្រួញទម្លុះកងបួន របស់ជា ជិនកុក, គណបក្សរូបសំបុកឃ្មុំ របស់ម៉ម សុទ្ធ, គណបក្សប្រជារាស្ត្រ រូបកណ្ដាប់ស្រូវ របស់សម ញាណ ជាដើម រកតែអាសនៈមួយមិនបានផង ។

ពេលបោះឆ្នោតនោះ ប៉ុណ្ណ ចន្ទម៉ុល ដែលបានចូលរួមក្នុងគណបក្សប្រជាធិបតេយ្យក្នុងឆ្នាំ១៩៥០ តាមរយៈម៉ិញ ណាគ្រី, ជុំ មួង និងប៉ាច ឈឿន ដែលធ្លាប់ជាប់គុកជាមួយគ្នានៅកោះត្រឡាចនោះ ក៏បានជាប់ឆ្នោតជាតំណាងរាស្ត្រម្នាក់ដែរ នៅមណ្ឌលព្រៃកតាមាក់។

ក្រោយប្រកាសលទ្ធផលនៃការបោះឆ្នោតនោះ រដ្ឋសភាដែលព្រះមហាក្សត្រសីហនុបិទទ្វារជិត២ឆ្នាំមកហើយនោះ ត្រូវបានដំណើរការតាមលទ្ធិប្រជាធិបតេយ្យឡើងវិញ។

សឺន សាន ជាមន្ត្រីជាន់ខ្ពស់ម្នាក់របស់គណបក្សប្រជាធិបតេយ្យ ដែលជាប់ឆ្នោតជាតំណាងរាស្ត្រនៅមណ្ឌលសង្កាត់លេខ៦ ក្រុងភ្នំពេញ ត្រូវបានសភាបោះឆ្នោតគាំទ្រឲ្យធ្វើជាប្រធានរដ្ឋសភា ទោះបីតំណាងរាស្ត្រទាំង១៨រូប មកពីគណបក្សសេរីភាព របស់ព្រះអង្គម្ចាស់នរោត្តម នរិន្ទដេត មិនបានបោះឆ្នោតគាំទ្រក៏ដោយ។

ពេលប្រជុំពិភាក្សាលើរបៀបវារៈអ្វីមួយ សឺន សាន ជាប្រធានរដ្ឋសភា តែងផ្ដល់ឱកាសឲ្យតំណាងរាស្ត្រមកពីគណបក្សប្រឆាំងមួយនេះ (គណបក្សសេរីភាព) ឡើងមានមតិមុនតំណាងរាស្ត្រមកពីគណបក្សប្រជាធិបតេយ្យរបស់គាត់ ដើម្បីចៀសវាងកុំឲ្យមានការចោទប្រកាន់ថា គាត់ជាប្រធានរដ្ឋសភា មានការលម្អៀងទៅរកគណបក្សកាន់អំណាចរបស់គាត់ ។

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៥១ គណបក្សប្រជាធិបតេយ្យ ដែលឈ្នះឆ្នោតបានអាសនៈ៥៤ ក្នុងរដ្ឋសភា បានរៀបចំរាជរដ្ឋាភិបាលមួយ ដោយមានហ៊ុយ កន្ធុល ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីសង្គមកិច្ច ឃួន ណៃ ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងធម្មការ, ប៉ាច ឈឿន (អតីតអ្នកទោសគុកកោះត្រឡាច) ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន, ឥន្ទ

តាវង្ស ជារដ្ឋមន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍, សឺន វ៉ុនសៃ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារជាតិ, ថុន អ៊ុក ជារដ្ឋមន្ត្រីក្រសួងអប់រំជាតិ យុវជន និងវិចិត្រសិល្បៈ, ម៉ម សុន ជារដ្ឋមន្ត្រីក្រសួងការបរទេស, ឌួង សំអាន ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសុក ធុង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច (រួមមាន កសិកម្ម, ចិញ្ចឹមសត្វ, ឧស្សាហកម្ម និងពាណិជ្ជកម្ម) ។

ក្រោយពីសឺន សាន បានឡើងជាប្រធានរដ្ឋសភា មិនយូរប៉ុន្មានមក ក៏មានយុវជនរាប់រយនាក់ ដែលភាគច្រើនជាសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បាននាំគ្នាមកធ្វើបាតុកម្មនៅមុខអគាររដ្ឋសភា តវ៉ាឲ្យរាជរដ្ឋាភិបាលហ៊ុយ កន្ធុល ទាមទារឯករាជ្យពេញលេញពីបារាំង តាមការសន្យារបស់គណបក្សប្រជាធិបតេយ្យ ក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោត គឺមិនមែនឯករាជ្យនៅក្នុងក្របខ័ណ្ឌសហភាពបារាំងនោះតទៅទៀតទេ ។

ពេលនោះ សឺន សាន បានទូរស័ព្ទទៅប្រាប់ហ៊ុយ កន្ធុល ជានាយករដ្ឋមន្ត្រី មកពីគណបក្សប្រជាធិបតេយ្យជាមួយគ្នា ឲ្យអញ្ជើញមកជួបពួកយុវជនក្មេងៗជាបាតុករទាំងអស់នោះ ដើម្បីរកវិធីដោះស្រាយដែរ ។ ប៉ុន្តែហ៊ុយ កន្ធុល បានឆ្លើយតបមកវិញដោយពាក្យសុំទោស ព្រោះគាត់មិនអាចជួបក្មេងៗជាក្រុមបាតុករទាំងអស់នោះបានទេ ហើយគាត់សុំឲ្យសឺន សាន លៃលករកវិធីដោះស្រាយជាមួយក្រុមបាតុករនោះដោយខ្លួនឯងចុះ ។

ពេលនោះ សឺន សាន បានស្នើសុំឲ្យក្រុមបាតុករចាត់តំណាងពួកគេ៤-៥នាក់ ដើម្បីចូលជួបពិភាក្សាគ្នានៅក្នុងការិយាល័យរបស់គាត់នៅក្នុងអគាររដ្ឋសភានោះ តែពួកគេមិនព្រមហើយទាមទារឲ្យគាត់ចេញមុខមកឆ្លើយបំភ្លឺនៅចំពោះក្រុមបាតុករទាំងអស់តែម្តង។

សឺន សាន បានសម្រេចចិត្តនាំតំណាងរាស្ត្រមួយចំនួនទៀត ចេញទៅជួបហ្វូងបាតុករតាមការទាមទារ ដោយមិនទាំងដឹងថា គាត់ត្រូវនិយាយអ្វីជាមួយពួកគេផង។

តែទោះបីជាយ៉ាងណា សឺន សាន បាននិយាយទៅកាន់ហ្វូងបាតុករថា រាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាធិបតេយ្យ មិនព្រងើយកន្តើយទេ គឺជានិច្ចកាលតែងតែមានទិសដៅទាមទារឯករាជ្យទាំងស្រុងមកជូនប្រទេសជាតិវិញ ប៉ុន្តែជារឿងមួយពិបាក និង

ត្រូវការពេលវេលាយូរតទៅទៀត...។

ពេលនោះ ស្រាប់តែមានយុវសិស្សបាតុករម្នាក់ឈ្មោះអ៊ុម ស៊ីម បានស្រែកឡើងថាៈ "បើអ៊ីចឹង! សូមឲ្យលោកឯងធ្វើប្រធានរដ្ឋសភានេះ យូររាប់រយឆ្នាំទៅទៀតចុះ!..." ។

ឮដូច្នេះ សឺន សាន ឡើងក្ដៅស្លឹកត្រចៀក តែគាត់អត់ធ្មត់ មិនប្រឡោតតបតវិញទេ ហើយគាត់ព្យាយាមនិយាយពន្យល់បញ្ចុះបញ្ចូលទៅហ្វូងបាតុករថាៈ " បើអស់លោកនាំគ្នាមករដ្ឋសភា ដើម្បីស្នើសុំឲ្យពួកយើងខ្ញុំទាមទារឯករាជ្យជូនប្រទេសជាតិនោះ សូមអស់លោកមេត្តាស្ដាប់ខ្ញុំ គឺត្រូវនាំគ្នាត្រឡប់ទៅវិញដោយរបៀបរៀបរយ និងស្ងៀមស្ងាត់ ដើម្បីទុកឱកាសឲ្យពួកយើងខ្ញុំដោះស្រាយបញ្ហានេះ"។ ពេលនោះយុវសិស្សបាតុករ ដែលក្នុងនោះមានមួយចំនួនធំជាសិស្សស្នាក់នៅមជ្ឈមណ្ឌលអន្តេវាសិកដ្ឋានក្នុងវិទ្យាល័យ ដែល សឺន សាន ជាអ្នកបង្កើតឡើង បានយល់ព្រមនាំគ្នាបំបែកហ្វូងត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញតាមសំណូមពររបស់គាត់ដោយងាយបំផុត។

មួយថ្ងៃក្រោយមក ស្រាប់តែមានមេប៉ូលិសជាន់ខ្ពស់ម្នាក់ ឈ្មោះប្រាក់ ប្រព្រឿង បានរាយការណ៍ទូលទៅព្រះមហាក្សត្រនរោត្តម សីហនុ ថា អ្នករៀបចំឲ្យមានបាតុកម្មនោះ គឺគ្មាននរណាក្រៅពីសឺន សាន ប្រធានរដ្ឋសភានោះទេ ព្រោះពេលនោះ គ្រាន់តែសឺន សាន អំពាវនាវឲ្យពួកបាតុករត្រឡប់ទៅវិញដោយរបៀបរៀបរយ និងស្ងៀមស្ងាត់ ដើម្បីទុកឱកាសឲ្យគាត់ដោះស្រាយបញ្ហានេះ ស្រាប់តែក្រុមបាតុករនាំគ្នាត្រឡប់ទៅវិញដោយស្ងៀមស្ងាត់ និងដោយងាយស្រួលបំផុត ។

មិនត្រឹមតែប៉ុណ្ណោះ មេប៉ូលិសឈ្មោះប្រាក់ ប្រព្រឿង នេះ បានទៅចាប់យុវសិស្សម្នាក់ឈ្មោះសៅ ង៉ុយ ដែលស្នាក់នៅមជ្ឈមណ្ឌលអន្តេវាសិកក្នុងវិទ្យាល័យ យកទៅវាយធ្វើទារុណកម្ម ដើម្បីឲ្យឆ្លើយថា សឺន សាន ជាអ្នករៀបចំឲ្យមានបាតុកម្មនោះទៀតផង។

នៅក្នុងឆ្នាំ១៩៥៣ មេប៉ូលិសឈ្មោះប្រាក់ ប្រព្រឿង នេះ ត្រូវបានព្រះមហាក្សត្រនរោត្តម សីហនុ តែងតាំងជារដ្ឋលេខាធិការថវិកា ពីខែកក្កដា ដល់ខែវិច្ឆិកា និងនៅក្នុងឆ្នាំ ១៩៥៥ តែងតាំងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងការពារលើផ្ទៃប្រទេស ពីខែមករា ដល់ខែ

គុលា ។

ចំណែកយុវជនឈ្មោះ សៅ ង៉ុយ នៅដើមទសវត្សរ៍១៩៦០ ក៏បានទៅចូលរួមក្នុងចលនាតស៊ូខ្មែរសេរី របស់សឺង ង៉ុកថាញ់ ហើយត្រូវរាជរដ្ឋាភិបាលសម្តេចនរោត្តម សីហនុចាប់បាន រួចកាត់ទោសយកទៅប្រហារជីវិតនៅភ្នំត្រពាំងក្រឡឹង ខេត្តកំពង់ស្ពឺ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៦៧ ។

ដើម្បីបង្ហាញការពិត សឺន សាន ក៏បានសុំចូលគាល់ព្រះមហាក្សត្រនរោត្តម សីហនុ ដោយគាត់បានប្រកែកដាច់អហង្ការថា គាត់មិនបានរៀបចំឲ្យពួកយុវសិស្សនៅតាមវិទ្យាល័យ ធ្វើបាតុកម្មនៅមុខរដ្ឋសភា ដូចការចោទប្រកាន់នោះទេ ហើយប្រសិនបើករណីខាងលើនេះជាការពិតនោះ គាត់នឹងសុំលាចេញពីតំណែងប្រធានរដ្ឋសភាតែម្តង។

---

# សូមរង់ចាំអានភាគ២ បន្តទៀត
# សូមអរគុណ

# ឯកសារយោង៖

1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .

2. Le mal Cambodge Histoire D´une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .

3. Pol Pot Frère Numéro Un. par Davidp – Chandler.

4. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .

5. Cambodge : Rêves et Réalités. par Vandy Kaonn.

6. Histoire du Cambodge 1863 – 1992. par Vandy Kaonn .

7. Cambodia: Year Zero by Francois Ponchaud

8. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.

9. When the War Was Over by Elizabeth Becker

10. How Pol Pot to come Power. By Ben Kiernan .

11. Wikipedia The free encyclopedia .

12. Wikipedia Org. wiki.

13. DP. Pedia org. page.

14.Wikiwand.

15. U.S. Embassy in Cambodia document.

16. Cold war international history Project.

17. The New York Times newspaper.

18. Times Magazine.

19. The Far Eastern Economic Review Magazine.

20. Le Figaro newspaper.

21. Le Monde newspaper.

22. Les Echos newspaper.

23. Le Parisien newspaper.

24. L´ humanite newspaper.

25. Liberation newspaper.

26. Washington Post newspaper.

27. Pol Pot by Philip Short.

28. The Gate by Francois Bizot.

29. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.

30. My War With the CIA by Norodom Sihanouk .

31. War and Hope: The Case for Cambodia by Norodom Sihanouk .

32. Flying Tigers Over Cambodia by Larry Partridge.

33. The United States and Cambodia, 1870-1969 By Kenton Clymer.

34 .L´histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).

35. Souvenir doux et amers  par Norodom Sihanouk.

36. គុកនយោបាយ  ដោយ ប៊ុណ្ណ ចន្ទម៉ុល.

37. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.

38. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្រី ទត់.

39. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយប៉ែន សុវណ្ណ និងនាង សារ៉ុន.

40. Des racines dans lapierre par Sam raingsy

# ជីវប្រវត្តិសង្ខេបរបស់អ្នកសិក្សាស្រាវជ្រាវ




**រូបថត ឆ្នាំ១៩៨៥** **រូបថត បច្ចុប្បន្ន**

ឈ្មោះ **ឈឹម សេរីវុត្ថន** កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ ។ ឪពុកឈ្មោះ **ឈឹម ចាំង** មានស្រុកកំណើតនៅខេត្តព្រៃវែង មុខរបរជាអ្នកថែសួននៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត។ ម្តាយឈ្មោះ **ទេព ឌុន** មានស្រុកកំណើតនៅខេត្តស្វាយរៀង មុខរបរជាមេផ្ទះ។ មានបង៣នាក់(ស្រី១ប្រុស២) និងប្អូន៣នាក់(ស្រី២ប្រុស១)។

ឆ្នាំ១៩៦២ - ៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ នៅម្តុំខាងក្រោយ សាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រសព្វថ្ងៃ ។

ឆ្នាំ១៩៦៣ - ៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ)

ឆ្នាំ១៩៦៩ - ៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក)

ឆ្នាំ១៩៧៤ - ៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម (វិទ្យាល័យ១៨មីនា ១៩៧០ ឬវិទ្យាល័យព្រះយុគន្ធរ)។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ត្រូវជម្លៀសជាមួយក្រុមគ្រួសារទៅរស់នៅក្នុង

សង្កាត់ព្រៃរំដេង ស្រុកមេសាងតំបន់២០ ភូមិភាគបូព៌ា។

ដើមឆ្នាំ១៩៧៦ ត្រូវជម្លៀសបន្តតែម្នាក់ឯង ទៅរស់នៅក្នុងសង្កាត់តាប្រ៉ុក ស្រុកចម្ការលើ តំបន់៤២ ភូមិភាគឧត្តរ (ក្រោយមក នៅឆ្នាំ ១៩៧៧ ដូរឈ្មោះជាភូមិភាគកណ្តាល) ហើយត្រូវពួកខ្មែរក្រហមបញ្ចូលជាកងចល័តតំបន់៤២ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ឪពុកម្តាយ និងបងប្អូនបង្កើតទាំង៦នាក់ ព្រមទាំងក្មួយៗប្រមាណ១០នាក់ទៀត ត្រូវពួកខ្មែរក្រហមប៉ុល ពត សម្លាប់ចោលទាំងអស់ កាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ពីឆ្នាំ១៩៧៩ ដល់ដើម១៩៩៣ ៖**

-បម្រើការងារជា ជាបុគ្គលិករដ្ឋ នៅស្រុកមេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអ៊ុនតាក់(UNTAC)ប្រចាំស្រុក មេសាង ខេត្តព្រៃវែង។

-ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាន នគរបាលជាតិ ក្រសួងមហាផ្ទៃ។

**ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២១៖**

-ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយឱ្យកាសែតចក្រវាឡ កាសែតអរិយធម៌ កាសែតសំឡេងនិស្សិត ទស្សនាវដ្តីកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-ជានិពន្ធនាយកទស្សនាវដ្តីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្តីខេមរា, ជានិពន្ធនាយកទស្សនាវដ្តីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្តីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មាន SBM News ។

**UNITED NATIONS**
**UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA (UNTAC)**

**NATIONS UNIES**
**AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE (APRONUC)**

# CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93

# លិខិតថ្លែងអំណរគុណ



ឯកសារប្រវត្តិសាស្ត្រដែលមានចំណងជើងថា **របត់នយោបាយ សីហនុ - លន់ នល់ - ប៉ុល ពត - ហ៊ុន សែន** ត្រូវបានរៀបចំចងក្រងបោះពុម្ពជាសៀវភៅនេះឡើង ក្រោមការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីសំណាក់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អ្វីដែលធ្វើខ្ញុំបាទ ជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្រនេះ មានការរំភើបរីករាយ និងមានកិត្តិយសបំផុតនោះ គឺនៅក្នុងលិខិតមួយដាក់ជូនសុំអនុសាសន៍ **សម្តេចក្រឡាហោម** សម្រេចយកជម្រើសមួយក្នុងចំណោមជម្រើសពីរ ដើម្បីការរៀបចំបោះពុម្ពសៀវភៅនេះ **សម្តេច** បានចារបញ្ជាក់ថា៖ ជម្រើសណាក៏បាន សំខាន់ចង់បានសៀវភៅប្រវត្តិសាស្ត្រមួយនេះទុកឲ្យកូនចៅរៀនសូត្រ ។

នេះជាបំណងប្រកបដោយគតិបណ្ឌិតគួរឱ្យគោរពបំផុតរបស់សម្តេចដែលចង់ឱ្យបោះពុម្ពសៀវភៅនេះឡើង ដើម្បីឱ្យកូនចៅជំនាន់ក្រោយៗទៀត បានរៀនសូត្រស្វែងយល់ពីប្រវត្តិសាស្ត្រពិតរបស់ប្រទេសជាតិខ្លួន។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងប្រសិទ្ធិពរជ័យជូន **សម្តេច** សូមប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

**ឈឹម សេរីតួន**

9 789924 969808 >